# រៀនភាសាបាលី
# បែបទំនើប

## ភាគ ១

អ្នករៀបរៀង ញឹម ថារី

អ្នកផ្ទៀងផ្ទាត់ ទូច សុវណ្ណមុនី

ព.ស.២៥៥៧ គ.ស២០១៤

# រៀនភាសាបាលី
# បែបទំនើប

## ភាគ ១

អ្នករៀបរៀង **ញឹម ថារី**
អ្នកផ្ទៀងផ្ទាត់ ទូច សុវណ្ណមុនី

ព.ស.២៥៥៧ គ.ស២០១៤

ឈ្មោះសៀវភៅ : រៀនភាសាបាលីបែបទំនើប

ឈ្មោះអ្នករៀបរៀង : ញឹម ថារី

អ្នកផ្ទៀងផ្ទាត់ : ភិក្ខុមុំ យ៉ាងពុំង, ភិក្ខុនឹម ណាន,
លោកទូច សុវណ្ណមុនី

ខ្នាត់សៀវភៅ : ១៥, ៥ ស.ម.x២១, ៥ ស.ម. ៦២០ ទំព័រ

បោះពុម្ពលើកទី : ចំនួន ៥០០ ក្បាល

ទីកន្លែងបោះពុម្ព : រោងពុម្ពភ្នំពេញ

កាលបរិច្ឆេទបោះពុម្ព : ថ្ងៃអង្គារ ៨ រោច ខែចែត្រ ឆ្នាំមមី ឆស័ក
ព.ស.២៥៥៧ ត្រូវនឹងថ្ងៃទី ២២
ខែមេសា ឆ្នាំ ២០១៤

ISBN

# សម្មោទនីយកថា

ខ្ញុំសូមចូលរួមអនុមោទនាជាមួយលោកឧទ្ទេសាចារ្យ **ញឹម ថារី** ក្នុងការប្រឹងប្រែងរៀបរៀងនូវសៀវភៅរៀនភាសាបាលីបែបទំនើបនេះ រហូតបានចេញជារូបរាងឡើង ។ ខ្ញុំបានអានសៀវភៅនេះហើយ ឃើញថាមានលក្ខណៈពិសេសជាច្រើន ព្រោះលោកបានដកស្រង់យកចំណុចសំខាន់ ៗ ជាច្រើនពីគម្ពីរនានាដែលមានក្នុងភាសាផ្សេង ៗ ដូចជា ខ្មែរ អង់គ្លេស ថៃ បាលីជាដើម ។ សៀវភៅនេះចាត់ទុកថាមានសារៈសំខាន់មួយបន្ថែមទៀត ដើម្បីជាជំនួយក្នុងការសិក្សាភាសាបាលីនិងជាសម្បត្តិផ្នែកខាងវណ្ណកម្មអក្សរសាស្ត្របាលីរបស់កុលបុត្រខ្មែរយើងក្នុងសម័យបច្ចុប្បន្ននេះ ។

ដោយកុសលចេតនាក្នុងការធ្វើសៀវភៅនេះ សូមបុណ្យកុសលកើតមានដល់លោកឧទ្ទេសាចារ្យ ញឹម ថារី និងសហការីដទៃទៀតមាន ភិក្ខុឋិតប្បញ្ញោ នឹម ណាន (អ្នករចនាក្រប), ភិក្ខុបរិសុទ្ធោ រី សារឹម លោក ទូច សុវណ្ណមុនី និងអ្នកចូលបោះពុម្ពដូចមាននាមនៅផ្នែកខាងក្រោយគម្ពីរនេះស្រាប់ ។ សូមព្រះតេជគុណ លោកឧទ្ទេសាចារ្យ និងពុទ្ធបរិស័ទដែលជាសប្បុរសជនទាំងអស់បានជួបប្រទះតែព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនិងទីបំផុតជាតិ សូមបាន សម្រេចព្រះបរមសុខគឺព្រះនិព្វានកុំបីក្លាយទៅជាបការៈដទៃឡើយ ។

សូមអនុមោទនា !

ថ្ងៃ ១៤ កើត ខែ ចែត្រ ឆ្នាំ ម្សាញ់ បញ្ចស័ក ព ស ២៥៥៧

ត្រូវនឹងថ្ងៃទី ១៣ ខែ មេសា គ ស ២០១៤

វត្តពុទ្ធជ័យមហានាថ ក្រុងវៃល្ងិងតុន ប្រទេសញូហ្ស៊ីឡែន

ភិក្ខុ **ញាណសារោ** មុំ យ៉ារ៉ាំង

# បុព្វកថា

*ខ្ញុំបាទសូមជំរាបថា ខ្ញុំសប្បាយរីករាយចិត្តណាស់ដែលខ្ញុំបាទមានភ័ព្វសំណាងបានសរសេរសៀវភៅនេះ ។ ខ្ញុំបានចែកសៀវភៅនេះជា ២ ភាគ ដើម្បីកុំឱ្យក្រាស់ពេក ព្រោះអាចមានការលំបាកក្នុងការកាន់រៀន ។ ភាគ ១ ចាប់ពីមេរៀនទី ១ ដល់មេរៀនទី ២៥ និងភាគ ២ ចាប់ពីមេរៀនទី ២៦ ដល់មេរៀនទី ៥០ ។*

*បុព្វហេតុដែលបណ្តាលឱ្យខ្ញុំចងក្រងសៀវភៅនេះឡើង គឺដំបូងឡើយខ្ញុំមានចិត្តចង់ត្រឹមតែរៀនសូត្រព្រះធម៌ខ្លះ ៗ ដើម្បីសូត្រជាមួយលោកយាយលោកតាក្នុងពេលមានបុណ្យទានម្តង ៗ ប៉ុណ្ណោះ ។ ប៉ុន្តែក្នុងពេលរៀននោះ ខ្ញុំបានចាប់អារម្មណ៍ថាភាសានេះមានការប្រែប្រួលពាក្យយ៉ាងខ្លាំង ដូចក្នុងបទនមស្សការព្រះរតនត្រៃ ពាក្យថា* **ពុទ្ធ**, *ម្តងថា* **ពុទ្ធំ**, *ម្តងទៀតថា* **ពុទ្ធា** *និងម្តងទៀតថា* **ពុទ្ធោ** *ហើយនឹងមានពាក្យដែលមានរូបដូចជាពាក្យខ្មែរតែម្តង ដូចជាពាក្យថា* **ឧត្តមង្គេន** (ឧត្តម) **មាតា បិតា** *ជាដើម ។ ខ្ញុំក៏សម្រេចចិត្តថារៀនភាសានេះ បើរៀនមិនបានចេះណាស់ណាទេ បានត្រឹមតែយល់ខ្លះ ៗ ក៏ខ្ញុំសុខចិត្តដែរ ។ បន្ទាប់មកខ្ញុំបានស្វែងរកសៀវភៅដើម្បីរៀន ការនេះពុំជាការងាយទេ ប៉ុន្តែបុណ្យជួយខ្ញុំចេះតែរកបានជាបន្តបន្ទាប់ ។*

*ភាសាបាលីពុំមែនជាភាសាក្នុងអំបូររបស់ភាសាយើងទេ ជាភាសា*

ក្នុងអំបូរឥណ្ឌូយូរ៉ូភាន (Indo-European language) ដែលអ្នករស់នៅក្នុងប្រទេសឥណ្ឌាកាលពីសម័យបូរាណបានប្រើប្រាស់ ជាពិសេសគឺ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានទ្រង់ប្រើក្នុងការប្រកាសសាសនារបស់ព្រះអង្គ ដូចមានចារក្នុងគម្ពីរព្រះត្រៃបិដកជាក់ស្តែង ។

ពាក្យថា បាលិ ឬ បាឡី មានមតិខ្លះឱ្យន័យថា "ការសរសេរជាបន្ទាត់ (Line)" ឬ "អត្ថបទ (Text)" ដែលចារចងក្រងជាគម្ពីរសម្រាប់រៀន ជាពិសេសពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។ មតិខ្លះថាជាឈ្មោះរបស់ភាសាហៅថាបាលីតែម្តង ដោយយល់ថាជាភាសាតែមួយជាមួយគ្នានឹង **មាគធី** ។ ប៉ុន្តែមានមតិមួយទៀតថា **មាគធី** និង **បាលី** មិនមែនជាភាសាតែមួយទេ ដោយសំអាងលើការប្រៀបធៀបស័ព្ទដែលចារឹកនៅលើសរសេរស្តម្ភរបស់ស្តេចអសោក នឹងស័ព្ទដែលចារក្នុងគម្ពីរព្រះពុទ្ធសាសនាថាមិនដូចគ្នា គឺគ្រាន់តែស្រដៀងគ្នាប៉ុណ្ណោះ ។

យ៉ាងណាក៏ដោយចុះ មានសំនួរមួយសួរថា តើយើងជាជាតិខ្មែររៀនភាសាបាលីបានប្រយោជន៍អ្វី ?

បាលីជាភាសាចំណាស់មួយ ។ ក្នុងបុព្វកថានៃសៀវភៅរៀនបាលី The New Pali course book 1 របស់ Prof. A. P. Buddhatatta Maha Nayaka Thera លោកពោលថា ភាសាបាលីជាភាសាចាស់ជាងភាសាសំស្ក្រឹតបូរាណទៅទៀត ហើយការចេះបាលីមានប្រយោជន៍ណាស់ចំពោះសិស្សឬនិស្សិតខាងទស្សនវិជ្ជានិងប្រវត្តិសាស្ត្របូរាណ ។

តើជនណាគប្បីរៀនភាសាបាលី ?

ការសិក្សាភាសាបាលីនៅក្នុងស្រុកយើងពុំសូវមានការរីកចម្រើនប៉ុន្មានទេ ដោយសារតែយុវជនសម័យបច្ចុប្បន្នយល់ថាភាសានេះពុំមានសេចក្តីត្រូវការចាំបាច់នៅលើផ្សារការងារទេ គឺជាភាសាសម្រាប់អ្នកបួស ឬយាយតាចាស់ ៗ ប៉ុណ្ណោះ ។ ការយល់ដូច្នេះក៏ត្រូវម្យ៉ាងដែរ ប៉ុន្តែយើងភ្លេចថា ខ្លួនយើងសព្វថ្ងៃប្រើប្រាស់ភាសាបាលីជាប្រចាំរាល់ ៗ ថ្ងៃដោយមិនទាំងដឹងខ្លួនផង ។ ខ្មែរយើងបានខ្ចីពាក្យបាលី-សំស្ក្រឹតមកប្រើប្រាស់ច្រើនណាស់ ដូចមានមេពាក្យក្នុងវចនានុក្រមខ្មែរជាសាក្សីស្រាប់ ថ្វីត្បិតមានពាក្យខ្លះជាពាក្យចាស់ដែលអាចថាមិនមានអ្នកណាគេប្រើ ឬមានប្រើតែក្នុងការសរសេរបន្តិចបន្តួចក៏ដោយ ។

ពាក្យបាលីដែលមានប្រើប្រាស់ប្រចាំថ្ងៃខ្លះមានការសរសេរ និងការអានមើលទៅហាក់ដូចជាពាក្យខ្មែរសុទ្ធ ៗដូចពាក្យថា "គោ, សាលា, កាល, មុខ, បរិភោគ, ទាន, នាវា, លោក, មេត្តា, មេធាវី, នារី ជាដើម ។

ពាក្យខ្លះទៀតមានការសរសេរដែលមើលទៅអាចដឹងថាជាពាក្យកម្ចី ប៉ុន្តែយើងត្រូវការប្រើរាល់ថ្ងៃដូចពាក្យថា "សម័យ, ផលិតកម្ម, រដ្ឋសភា, ការិយាល័យ, មន្ទីរពេទ្យ, រថយន្ត, វត្តអារាម, វិហារ, កុដិ, ភូមិ, ទ្វារ ជាដើម ។

អាស្រ័យហេតុនេះ ទាំងភិក្ខុសាមណេរ (អ្នកបួស) និងសិស្សនិស្សិតព្រមទាំងបុគ្គលិកការងារក្នុងក្រសួងនានា ជាពិសេសគ្រូបង្រៀន

សាស្ត្រាចារ្យគប្បីរៀនភាសាបាលីឱ្យបានយល់ពីដំណើរនៃភាសានេះខ្លះ ៗ ដើម្បីឱ្យកើតជំនាញក្នុងភាសាយើងកាន់តែប្រសើរឡើងថែមទៀត ។

តើបាលីពិបាករៀនមែនឬ?

ពិតណាស់ គឺថាការរៀនភាសាថ្មីមួយជាការពិបាក មិនថាភាសាណាមួយទេ ពីព្រោះត្រូវការរៀនពាក្យថ្មី ៗ ជាច្រើនដែលយើងពុំធ្លាប់ចេះ ពុំធ្លាប់និយាយ ព្រមទាំងវេយ្យាករណ៍ក៏ប្លែកគ្នាផងទៀតនោះ ។

សូម្បីភាសាអង់គ្លេសដែលមានមនុស្សម្នាក្នុងលោកចេះនិយាយរាប់លាននាក់ ក៏ក្នុងការរៀនត្រូវការការអនុវត្តដូចជាការហាត់សរសេរ ហាត់អាននិងហាត់និយាយយ៉ាងច្រើនម៉ោង ច្រើនខែថ្ងៃរហូតដល់ច្រើនឆ្នាំទៀតផង ។ ប៉ុន្តែបើយើងសម្រេចចិត្តថារៀនឱ្យចេះហើយចាប់ផ្ដើមរៀនពីតិច ដូចការរៀនភាសាអង់គ្លេសដែលរៀនពី អេ ប៊ី ស៊ី ឌី (a b c d) ឡើងទៅក៏គង់នឹងចេះពុំខានឡើយ ។

មុននឹងបញ្ចប់នូវបុព្វកថានេះ ខ្ញុំបាទសូមថ្លែងអំណរគុណជាអនេកចំពោះលោក **ឌួច សុវណ្ណមុនី** ដែលលោកបានខិតខំខ្នះខ្នែងជួយពិនិត្យមើលនិងកែតម្រូវនូវកំហុសឆ្គាំឆ្គងផ្សេង ៗ ដែលមាននៅក្នុងសៀវភៅនេះតាំងពីដើមរហូតចប់ភាគទី ១ ។ មួយចំណែកទៀត ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកផងដែរ ចំពោះសប្បុរសជនទាំងអស់ដែលមានសទ្ធាបានចូលជាបច្ច័យសម្រាប់ចំណាយក្នុងការបោះពុម្ព ។ ប្រសិនបើគ្មានជំនួយទាំងពីរយ៉ាងនេះទេ សៀវភៅនេះមិនអាចមាន

លទ្ធភាពបោះពុម្ពដើម្បីផ្សព្វផ្សាយបានឡើយ ។

អវសាននេះខ្ញុំបាទសូមជូនពរដល់លោក លោកស្រី និង នាងកញ្ញាទាំងអស់ សូមឱ្យបានជួបតែនឹងសេចក្តីសុខនិងសេចក្តីចម្រើនកុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃទី ៥ កើតខែស្រាពណ៍ ព.ស. ២៥៥៧ ត្រូវនឹង
ថ្ងៃទី ១១ ខែសីហា គ.ស. ២០១៣
ទីក្រុងស៊ីដនីយ៍ (អូស្ត្រាលី)
ញឹម ថារី

# មាតិកា


បុព្វកថា ក

សម្មោទនីយកថា ច

មាតិកា (១)

អក្សរសង្ខេប (១៤)

**មេរៀនទី ១** ១

អក្ខរវិធីសង្ខេប, ស្រះ ឬ សរៈ, ព្យញ្ជនៈ, អឃោសៈនិងឃោសៈ, វិធីសំយោគព្យញ្ជនៈ, វិធីអានភាសាបាលី, លំហាត់នៃមេរៀនទី ១ ។

**មេរៀនទី ២** ១៤

អធិប្បាយអំពីនាមស័ព្ទ, នាមស័ព្ទ, នាមនាម, ការន្ត, លិង្គ, ជាតិលិង្គ, សម្មតិលិង្គ, វចនៈ, វិភត្តិ, ការកៈ, អាយតនិបាត, វិធីបំបែកនាមស័ព្ទ អ ការន្ត, វិភត្តិសម្រេចរូបរបស់ អ ការន្តបុំលិង្គ, វិធីបំបែក **បុរិស**, វិធីប្រែនាមស័ព្ទបំបែករួចហើយ, នាមស័ព្ទ អ ការន្តបុំលិង្គ, វិភត្តិសម្រេចរូបរបស់ អ ការន្តនបុំសកលិង្គ, វិធីបំបែក **កុល**, នាមស័ព្ទ អ ការន្តនបុំសកលិង្គ, វាក្យាង្គ, វិធីប្រើនិងប្រែនាមនាមបំបែករួចហើយ, លំហាត់នៃមេរៀនទី ២ ។

**មេរៀនទី ៣** ៣៧

អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត), អាខ្យាតកិរិយា, ធាតុ, បច្ច័យ, វិភត្តិ, វត្តមានាវិភត្តិ, បុរិសៈ, វចនៈ, បទ, កាល, កិរិយានុគ្រោះ, វាចកៈ, វិធីរូបសិទ្ធិជាកិរិយាស័ព្ទ, វិធីបំបែកធាតុពួកទី ១, វិធីផ្លាស់រូបរបស់ធាតុក្នុងពួក **ភូ** ធាតុ, វិធីបំបែក **អស**, វិធីតែងប្រយោគនិងវិធីប្រែបាលី, ប្រយោគកត្តុវាចកៈ, វិធីបំបែកនាមស័ព្ទ **អា** ការន្ត, វិភត្តិសម្រេចរូបរបស់ **អា** ការន្តឥត្ថីលិង្គ, វិធីបំបែក **កញ្ញា**, នាមស័ព្ទ **អា** ការន្តឥត្ថីលិង្គ, ធាតុស័ព្ទក្នុងពួកទី ១ (ភូធាតុ), លំហាត់នៃមេរៀនទី ៣ ។

**មេរៀនទី ៤** ៦៤

អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត), វិធីបំបែកធាតុពួកទី ២ (ពួក **រុធ** ធាតុ), វិធីរូបសិទ្ធិកិរិយាជាកត្តុវាចកៈ, វិធីផ្លាស់និគ្គហិត, ធាតុស័ព្ទក្នុងពួកទី ២ (រុធធាតុ), បញ្ចមីវិភត្តិ, វិធីរូបសិទ្ធិជាកិរិយាស័ព្ទ, វិធីបំបែក **អស** ធាតុជាមួយបញ្ចមីវិភត្តិ, វិធីបំបែកនាមស័ព្ទ **ឥ** ការន្ត, វិភត្តិសម្រេចរូបរបស់ **ឥ** ការន្តបុំលិង្គ, វិធីបំបែក **មុនិ**, នាមស័ព្ទ **ឥ** ការន្តបុំលិង្គ, វិភត្តិសម្រេចរូបរបស់ **ឥ** ការន្តនបុំសកលិង្គ, វិធីបំបែក **អក្ខិ**, នាមស័ព្ទ **ឥ** ការន្តនបុំសកលិង្គ, និបាតស័ព្ទ, លំហាត់នៃមេរៀនទី ៤ ។

មេរៀនទី ៥ ៨១

*អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត), វិធីបំបែកធាតុពួកទី ៣ (ពួក **ទិវ** ធាតុ) វិធីរូបសិទ្ធិកិរិយាជាកត្តុវាចកៈ, ធាតុ-ស័ព្ទក្នុងពួកទី ៣ (ទិវធាតុ), សត្តមីវិភត្តិ, វិធីរូបសិទ្ធិជាកិរិយាស័ព្ទ, វិធីបំបែកធាតុជាមួយសត្តមីវិភត្តិ, វិធីបំបែក **អស** ធាតុជាមួយសត្តមីវិភត្តិ, បរិកប្បនិបាត, បដិសេធវិធី, វិភត្តិសម្រេចរូបរបស់ **ឥ** ការន្តឥត្ថីលិង្គ, វិធីបំបែក **ភូមិ**, នាមស័ព្ទ **ឥ** ការន្តឥត្ថីលិង្គ, ធាតុគណៈទី ១, លំហាត់នៃមេរៀនទី ៥ ។*

មេរៀនទី ៦ ៩៦

*អធិប្បាយអំពីអាខ្យាតកិរិយា, សព្វនាមនិងនាមស័ព្ទ (ត), វិធីបំបែកធាតុពួកទី ៤ (ពួក **សុ** ធាតុ), ធាតុស័ព្ទក្នុងពួកទី ៤ (ពួកសុធាតុ), វិធីបំបែកធាតុពួកទី ៥ (ពួក **កី** ធាតុ), ធាតុស័ព្ទក្នុងពួកទី ៥ (កីធាតុ), សព្វនាម, បុរិសសព្វនាម, វិធីបំបែកបុរិសសព្វនាម, វិធីបំបែក **ត** សព្វនាម, វិភត្តិសម្រេចរូបរបស់ **ត** សព្វនាមជាបុំលិង្គ, វិធីបំបែក **ត** សព្វនាមជាបុំលិង្គ, វិភត្តិសម្រេចរូបរបស់ **ត** សព្វនាមជាឥត្ថីលិង្គ, វិធីបំបែក **ត** សព្វ-នាមជាឥត្ថីលិង្គ, វិធីបំបែក **ត** សព្វនាមជានបុំសកលិង្គ, វិធីបំបែក **តុម្ហ** សព្វនាម, វិធីបំបែក **អម្ហ** សព្វនាម, វិធីប្រើនិងប្រែ*

សព្វនាម, វិធីបំបែកនាមស័ព្ទ ឦ ការន្ត, វិភត្តិសម្រេចរូបរបស់ ឦ ការន្តបុំលិង្គ, វិធីបំបែក **សេដ្ឋី**, នាមស័ព្ទ ឦ ការន្តបុំលិង្គ, វិភត្តិសម្រេចរូបរបស់ ឦ ការន្តឥត្ថីលិង្គ, វិធីបំបែក **នារី**, នាមស័ព្ទ ឦ ការន្តឥត្ថីលិង្គ, លំហាត់នៃមេរៀនទី ៦ ។

**មេរៀនទី ៧** ១១៧

អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត), ហីយត្តនីវិភត្តិ, វិធីបំបែកធាតុពួកទី ៦ (ពួក **គហ** ធាតុ), ធាតុស័ព្ទក្នុងពួកទី ៦, វិធីបំបែកធាតុពួកទី ៧ (ពួក **តន** ធាតុ), ធាតុស័ព្ទក្នុងពួកទី ៧, វិធីបំបែកធាតុពួកទី ៨ (ពួក **ចុរ** ធាតុ), ធាតុស័ព្ទក្នុងពួកទី ៨ (ចុរធាតុ) , វិធីបំបែកនាមស័ព្ទ **ឧ** ការន្ត, វិភត្តិសម្រេចរូបរបស់ **ឧ** ការន្តបុំលិង្គ, វិធីបំបែក **គរុ**, នាមស័ព្ទ **ឧ** ការន្តបុំលិង្គ, វិភត្តិសម្រេចរូបរបស់ **ឧ** ការន្តឥត្ថីលិង្គ, វិធីបំបែក **យាគុ**, នាមស័ព្ទ **ឧ** ការន្តឥត្ថីលិង្គ, វិភត្តិសម្រេចរូបរបស់ **ឧ** ការន្តនបុំសកលិង្គ, វិធីបំបែក **វត្ថុ**, នាមស័ព្ទ **ឧ** ការន្តនបុំសកបុំលិង្គ, នាមស័ព្ទ **អ** ការន្តបុំលិង្គ (ត), លំហាត់នៃមេរៀនទី ៧ ។

**មេរៀនទី ៨** ១៣៨

អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត), អជ្ជតនីវិភត្តិ,

*វិធីបំបែកបែបទី ១, របៀបមិនមាន* **អ** *អាគម, របៀបមាន* **អ** *អាគម, វិធីបំបែកបែបទី ២, វិធីបំបែកបែបទី ៣, របៀបបំបែក* **ហុ** *ធាតុជាមួយអជ្ជតនីវិភត្តិ, របៀបបំបែក* **អស** *ធាតុជាមួយអជ្ជតនីវិភត្តិ, អាគម, វិធីបំបែកនាមស័ព្ទ (តចប់), វិធីបំបែកនាមស័ព្ទ* **ឱ** *ការន្ត, វិភត្តិសម្រេចរូបរបស់* **ឱ** *ការន្តបុំលិង្គ, វិធីបំបែក* **វេធគូ**, *នាមស័ព្ទ* **ឱ** *ការន្តបុំលិង្គ, វិភត្តិសម្រេចរូបរបស់* **ឱ** *ការន្តឥត្ថីលិង្គ, វិធីបំបែក* **វជ្ជ**, *នាមស័ព្ទ* **ឱ** *ការន្តឥត្ថីលិង្គ, ធាតុស័ព្ទពួក* **ភូ** *ធាតុ (ត), និបាតស័ព្ទដែលមានប្រើញឹកញាប់, លំហាត់នៃមេរៀនទី ៨ ។*

## មេរៀនទី ៩ ១៨៧

*អធិប្បាយអំពីអាខ្យាតកិរិយានិងសព្វនាម (ត(, ភវិស្សន្តិវិភត្តិ, របៀបទី ១ (ចុះ* **ឥ** *អាគម), របៀបទី ២ (ពុំបាច់ចុះ* **ឥ** *អាគម), របៀបទី ៣, ប្រយោគភាវវាចកៈ, វិធីរូបសិទ្ធិជាភាវវាចកកិរិយា, វិសេសនសព្វនាម, និយមសព្វនាម, វិធីបំបែក* **ឯត** *ស័ព្ទជាបុំលិង្គ, វិធីបំបែក* **ឯត** *ស័ព្ទជានបុំសកលិង្គ, វិធីបំបែក* **ឯត** *ស័ព្ទជាឥត្ថីលិង្គ, វិធីបំបែក* **ឥម** *ស័ព្ទជាបុំលិង្គ, វិធីបំបែក* **ឥម** *ស័ព្ទជានបុំសកលិង្គ, វិធីបំបែក* **ឥម** *ស័ព្ទជាឥត្ថីលិង្គ, វិធីបំបែក* **អមុ** *ស័ព្ទជាបុំលិង្គ, វិធីបំបែក* **អមុ** *ស័ព្ទជានបុំសកលិង្គ,*

*វិធីបំបែក* **អមុ** *ស័ព្ទជាឥត្ថីលិង្គ, វិធីប្រើនិងប្រែនិយមសព្វនាម, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ៩ ។*

**មេរៀនទី ១០** ១៧៨

*អធិប្បាយអំពីអាខ្យាតកិរិយានិងគុណនាម, កាលាតិបត្តិវិភត្តិ, បែបចុះ* **អ** *អាគម, បែបមិនមានចុះ* **អ** *អាគម, គុណនាម, វិធីប្រើគុណនាម, ការប្រៀបធៀបគុណនាម, វិធីប្រើគុណនាមក្នុងប្រយោគ, បទគុណឬបទវិសេសនៈ, វិធីធ្វើបដិសេធគុណនាម, គុណនាមដែលប្រើញឹកញាប់, លំហាត់នៃមេរៀនទី ១០ ។*

**មេរៀនទី ១១** ២០០

*អធិប្បាយអំពីវិសេសនសព្វនាម (ត) និង* **កឹ** *ស័ព្ទ, អនិយមសព្វនាម, អនិយមសព្វនាមមាន ១៣ ស័ព្ទ, វិធីបំបែកអនិយមសព្វនាម, វិធីបំបែក* **យ** *ស័ព្ទ, វិធីបំបែក* **យ** *ស័ព្ទជាបុំលិង្គ, វិធីបំបែក* **យ** *ស័ព្ទជានបុំសកលិង្គ, វិធីបំបែក* **យ** *ស័ព្ទជាឥត្ថីលិង្គ, វិធីប្រើនិងប្រែអនិយមសព្វនាម, វិធីប្រែ* **ឯក** *ស័ព្ទ, វិធីបំបែក* **កឹ** *ស័ព្ទ, វិធីបំបែក* **កឹ** *សព្ទ័ជាបុំលិង្គ, វិធីបំបែក* **កឹ** *ស័ព្ទជានបុំសកលិង្គ, វិធីបំបែក* **កឹ** *ស័ព្ទជាឥត្ថីលិង្គ, វិធីប្រើនិងប្រែ* **កឹ** *ស័ព្ទ, ប្រយោគសំនួរក្នុងភាសាបាលី, លំហាត់នៃមេរៀនទី*

១១ ។

មេរៀនទី ១២ ២២០

*អធិប្បាយអំពីសំខ្យាស័ព្ទពី ១-១០០, សំខ្យាស័ព្ទ, បកតិសំខ្យា, ប្រភេទរបស់បកតិសំខ្យា, វិធីបំបែកបកតិសំខ្យាស័ព្ទ, វិធីបំបែក* **ឯក** *ស័ព្ទ, វិធីបំបែក* **ទ្វិ** *និង* **ឧភ** *ស័ព្ទ, វិធីបំបែក* **តិ** *ស័ព្ទ,វិធីបំបែក* **ចតុ** *ស័ព្ទ, វិធីបំបែក* **បញ្ច** *ស័ព្ទ, វិធីប្រើនិងប្រែបកតិសំខ្យា, វិធីបំបែក* **ឯកូនវីស***, វិធីបំបែក* **ឯកូនវីសតិ***, វិធីបំបែក* **ឯកូនសដ្ឋី***, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ១២ ។*

មេរៀនទី ១៣ ២៤៥

*អធិប្បាយអំពីសំខ្យាស័ព្ទពី ១០០ ឡើង, វិធីផ្សំសំខ្យាស័ព្ទដោយប្រើ* **ឧត្តរ** *និង* **អធិក***, វិធីផ្សំសំខ្យាស័ព្ទដោយប្រើ* **ឧត្តរ***, វិធីផ្សំសំខ្យាស័ព្ទដោយប្រើ* **អធិក***, វិធីផ្សំសំខ្យាស័ព្ទដោយប្រើ* **ឧត្តរ** *និង* **អធិក** *រួមគ្នា, វិធីផ្សំបកតិសំខ្យាស័ព្ទរួមគ្នាជាមួយនាមស័ព្ទ, វិធីផ្សំជា សកវាជ, វិធីផ្សំបកតិសំខ្យាជាមួយ* **អឌ្ឍ** *ស័ព្ទ, វិធីផ្សំ* **អឌ្ឍ** *ស័ព្ទរួមជាមួយនាមស័ព្ទ, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ១៣ ។*

មេរៀនទី ១៤ ២៧០

*អធិប្បាយអំពីវិធីរូបសិទ្ធិកិរិយាជាកម្មវាចកៈ, វិធីបំបែ* **បច** *ធាតុជាកម្មវាចកៈ, វិធីចុះ* **យ** *បច្ច័យនិង* **ឥ** *អាគម, វិធីមិនបាច់ចុះ* **ឥ** *អាគម, ចំពោះធាតុឯកព្យាង្គ, វិធីធ្វើសមានកម្ម* **យ** *បច្ច័យជាមួយព្យញ្ជនៈទីបំផុតធាតុ, វិធីប្រែប្រយោគកម្មវាចកៈបែបទី ១, វិធីផ្លាស់ប្រយោគពីកត្តុវាចកៈទៅជាកម្មវាចកៈ, វិធីប្រែប្រយោគកម្មវាចកៈបែបទី ២, នាមស័ព្ទ (ត), ធាតុសព្វក្នុងពួកទី ១ (ត), លំហាត់នៃមេរៀនទី ១៤ ។*

មេរៀនទី ១៥ ២៨៨

*អធិប្បាយអំពីអាខ្យាតកិរិយានិងវិធីអញ្ញាស, បរោក្ខាវិភត្តិ, វិធីបំបែក* **ព្រ** *ធាតុ, វិធីធ្វើអញ្ញាស, វិធីធ្វើអញ្ញាសស្រៈ, វិធីធ្វើអញ្ញាសព្យញ្ជនៈ, បច្ចេកបច្ច័យក្នុងអាខ្យាតកិរិយា, វិធីប្រើ* **អាយ** *និង* **ឦយ** *បច្ច័យ, បច្ចេកបច្ច័យ(ត), ស័ព្ទដែលប្រើកិរិយាវិសេសន៍, នាមស័ព្ទនិងគុណនាម (ត), លំហាត់នៃមេរៀនទី ១៥ ។*

មេរៀនទី ១៦ ៣១២

*អធិប្បាយអំពីហេតុវាចកកិរិយាស័ព្ទ, វិធីរូបសិទ្ធិជាហេតុកត្តុវាចកកិរិយាស័ព្ទ, ហេតុកត្តុវាចកៈនៃធាតុពួកទី ៨, វិធីផ្លាស់រូប*

*របស់ធាតុក្នុងហេតុកត្តុវាចកៈ, វិធីប្រែប្រយោគហេតុកត្តុវាចកៈ បែបទី ១, វិធីប្រែប្រយោគហេតុកត្តុវាចកៈបែបទី ២, វិធីផ្លាស់ប្រយោគពីកត្តុវាចកៈទៅជាហេតុកត្តុវាចកៈ, វិធីរូបសិទ្ធិហេតុកម្មវាចកកិរិយាស័ព្ទ, វិធីប្រែប្រយោគហេតុកម្មវាចកៈ បែបទី ១, វិធីប្រែប្រយោគហេតុកម្មវាចកៈ បែបទី ២, នាមនាមនិងគុណនាម (ត), លំហាត់នៃមេរៀនទី ១៦ ។*

**មេរៀនទី ១៧** ៣៣២

*អធិប្បាយអំពីបូរណសំខ្យា និង វិធីសង្កេតកាលនៃអាខ្យាតកិរិយា, វិធីចុះបច្ច័យក្នុងទីបំផុតនៃបកតិសំខ្យា, វិធីប្រើនិងប្រែបូរណសំខ្យាក្នុងប្រយោគ, វិធីប្រើបកតិសំខ្យាក្នុងបែបផ្សេង ៗ ទៀត, ការប្រើបកតិសំខ្យាផ្ទួនគ្នា, វិធីសង្កេតកាលនៃអាខ្យាតកិរិយា, វិកត្តិអាខ្យាតផ្លាស់ប្តូររូប, នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ១៧ ។*

**មេរៀនទី ១៨** ៣៤៦

*អធិប្បាយអំពីកិតកិរិយា, គ្រឿងប្រកបរបស់កិតកិរិយា, ការចែកបច្ច័យតាមកាលនីមួយ ៗ, ការចែកបច្ច័យតាមវាចកៈ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **អន្ត** *បច្ច័យ, បច្ចុប្បន្នកិតកិរិយា,*

*វិធីបំបែកកិរិយាកិតកៈ, វិធីបំបែក* **តច្ចន្ត** *ជាបុំលិង្គ, វិធីបំបែក* **តច្ចន្ត** *ជានបុំសកបុំលិង្គ, វិធីបំបែក* **តច្ចន្ត** *ជាឥត្ថីលិង្គ, មហា-កិរិយាស័ព្ទនិងអនុកិរិយាស័ព្ទ, វិធីប្រែប្រយោគកត្តុវាចកៈ* (ត), *វិធីប្រែប្រយោគហេតុកត្តុវាចកៈ* (ត), *វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **មាន** *បច្ច័យ, វិធីមានចុះ* **ឥ** *អាគម, វិធីមិនមានចុះ* **ឥ** *អាគម, នាមស័ព្ទ* (ត), *ធាតុស័ព្ទ* (ត), *លំហាត់នៃមេរៀនទី ១៨ ។*


## មេរៀនទី ១៩ ៣៨៨

*អធិប្បាយអំពីកិតកិរិយា* (ត), *អតីតកិតកិរិយា, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **ត** *បច្ច័យ, រូបកិតកិរិយាក្នុងវាចកៈនីមួយ ៗ ទាំងបីលិង្គ, វិធីប្រើកិតកិរិយា* **ត** *បច្ច័យក្នុងប្រយោគ, នាមស័ព្ទ* (ត), *លំហាត់នៃមេរៀនទី ១៩ ។*

## មេរៀនទី ២០ ៤១០

*អធិប្បាយអំពីកិតកិរិយា* (ត), *អព្យយកិតកិរិយា, ត្វាទិបច្ច័យ, វិធីចុះ* **ត្វាទិ** *បច្ច័យ, អព្យយកិតកិរិយាជាកត្តុវាចកៈ, វិធីផ្លាស់ត្វាទិបច្ច័យទៅជារូបផ្សេងៗ, ប្រភេទផ្លាស់* **ត្វា** > **យ**, *ប្រភេទធ្វើសមានកម្ម* **យ** *ជាមួយព្យញ្ជនៈទីបំផុតធាតុ, អព្យយកិតកិរិ-*

*យាជាហេតុកត្តុវាចកៈ, វិធីប្រើអព្យយកិតកិរិយាក្នុងប្រយោគ, វិធីប្រែអព្យយកិតកិរិយាក្នុងករណីពិសេស, នាមស័ព្ទ(ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ២០ ។*

**មេរៀនទី ២១** ៤៣៣

*អធិប្បាយអំពីកិតកិរិយា (ត), អនុត្តកាលកិតកិរិយា, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **អនីយ** *បច្ច័យ, វិធីប្រកបរូប* **អនីយ** *បច្ច័យជាកម្មវាចកៈ, វិធីប្រកបរូប* **អនីយ** *បច្ច័យជាហេតុកម្មវាចកៈ, វិធីប្រើក្នុងប្រយោគ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **តព្វ** *បច្ច័យ, វិធីរូបសិទ្ធិ* **តព្វ** *បច្ច័យជាកម្មវាចកៈ, វិធីរូបសិទ្ធិ* **តព្វ** *បច្ច័យជាហេតុកម្មវាចកៈ,វិធីប្រើ* **តព្វ** *បច្ច័យក្នុងប្រយោគ, លំហាត់នៃមេរៀនទី ២១ ។*

**មេរៀនទី ២២** ៤៥១

*អធិប្បាយអំពីកិតកិរិយា (តចប់),* **តវន្តុ**, **តាវី** *បច្ច័យ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **តវន្តុ** *បច្ច័យ, វិធីបំបែក* **សុតវន្តុ** *ជាបុំ-លិង្គតាមបែប* **បុរិស** , *វិធីបំបែក* **សុតវន្តុ** *ជាបុំលិង្គតាមបែប* **គុណវន្តុ** , *វិធីបំបែក* **សុតវន្តុ** *ជានបុំសកលិង្គ, វិធីបំបែក* **សុត-វន្តុ** *ជាឥត្ថីលិង្គតាមបែប* **នារី**, *វិធីប្រើ* **តវន្តុ** *បច្ច័យក្នុងប្រ-*

*យោគ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **តាវី** *បច្ច័យ, វិធីប្រើ* **តាវី** *ក្នុងប្រយោគ,* **តុំ** *និង* **តវេ** *បច្ច័យ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **តុំ** *បច្ច័យ, វិធីចុះ* **តុំ** *បច្ច័យជាកត្តុវាចកៈ, វិធីចុះ* **តុំ** *បច្ច័យជាហេតុកត្តុវាចកៈ,វិធីប្រើនិងប្រែ* **តុំ***បច្ច័យក្នុងប្រយោគ, វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ* **តវេ** *បច្ច័យ, វិធីប្រើនិងប្រែ* **តវេ** *បច្ច័យក្នុងប្រយោគ, ជាតុស័ព្ទ (ត), នាមស័ព្ទ (ត), លំហាត់នៃមេរៀនទី ២២ ។*

## មេរៀនទី ២៣ ៤៧៤

*អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ, វិធីបំបែកបកិណ្ណកនាមស័ព្ទ, វិធីបំបែកពួកទី១ (រាជាទិគណៈ), វិកត្តិសម្រេចរបស់* **រាជ** *ស័ព្ទ, វិធីបំបែក* **រាជ**, *វិធីបំបែក* **មហារាជ** *បំបែកតាមបែប* **បុរិស**, *វិធីបំបែក* **មហារាជ** *តាមបែប* **រាជ** *ស័ព្ទ, ឧទាហរណ៍នៃការប្រើ* **រាជ** *ស័ព្ទ, វិកត្តិសម្រេចរបស់* **ព្រហ្ម** *ស័ព្ទ, វិធីបំបែក* **ព្រហ្ម**, *ឧទាហរណ៍នៃកាប្រើ* **ព្រហ្ម** *ស័ព្ទ, វិធីបំបែក* **បុម**, *វិធីបំបែក* **មុទ្ធ**, *វិធីបំបែក* **អទ្ធ**, *វិធីបំបែក* **សខ**, *វិកត្តិសម្រេចរបស់* **អត្ត** *ស័ព្ទ, វិធីបំបែក* **អត្ត**, *នាមស័ព្ទ (ត), ជាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ២៣ ។*

## មេរៀនទី ២៤ ៤៩៦

*អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (ត) និងប្រយោគជ្រែក, វិធីបំបែកពួកទី ២ (ភគវន្តាទិគណៈ), វិភត្តិសម្រេរបស់* **ភគវន្តុ** *ស័ព្ទ, វិធីបំបែក* **ភគវន្តុ**, *វិធីបំបែក* **អរហន្ត**, *វិធីបំបែក* **ភវន្ត**, *វិធីបំបែក* **សន្ត**, *ប្រយោគជ្រែក, ប្រយោគអនាទរៈ, ប្រយោគលក្ខណៈ, នាមស័ព្ទ (ត), ធាតុស័ព្ទ (ត), លំហាត់នៃមេរៀនទី ២៤ ។*

## មេរៀនទី ២៥ ៥១៥

*អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (ត) និងវិធីប្រើនិងប្រែអាលបនស័ព្ទ, វិធីបំបែកពួកទី ៣ (សត្ថាទិគណៈ), វិភត្តិសម្រេចរូបនៃ* **សត្ថុ** *ស័ព្ទ, វិធីបំបែក* **សត្ថុ**, *វិធីបំបែក* **កាត្តុ**, *វិភត្តិសម្រេចរូបរបស់* **បិតុ** *ស័ព្ទ, វិធីបំបែក* **បិតុ**, *វិភត្តិសម្រេចរូបរបស់* **មាតុ** *ស័ព្ទ, វិធីបំបែក* **មាតុ**, *វិធីប្រែភាសាបាលីពេញបរិបូណ៌, វិធីប្រែប្រយោគកត្តុវាចកៈ (តចប់), វិធីប្រើនិងប្រែស័ព្ទអាលបន, វិធីប្រើអាលបននាម, វិធីប្រើនិងប្រែបទអាលបននាម, វិធីប្រើអាលបននិបាត, វិធីប្រើនិងប្រែបទអាលបននិបាត, វិធីប្រែប្រយោគបទវិកតិកត្តា, វិធីប្រែប្រយោគហេតុកត្តុវាចកៈ (តចប់), វិធីប្រែប្រយោគកម្មវាចកៈ (តចប់), វិធីប្រែប្រយោគហេតុកម្ម*

វាចកៈ (តចប់), លំហាត់នៃមេរៀនទី ២៥ ។

វាក្យានុក្រម ៤៤៥
អាខ្យាតកិរិយានុក្រម ៤៦៦
វេយ្យាករណតដ្ឋនី ☞ ៤៨២
ឈ្មោះសៀវភៅប្រើប្រាស់ក្នុងការរៀបរៀង ៤៨៧
បញ្ជីរាយនាមសប្បុរសជនចូលបច្ច័យ ៤៨៩

# អក្សរសង្ខេប

អព្យ. អព្យយស័ព្ទ
អា. អាលបនវិភត្តិ
ឧ.បុ. ឧត្តមបុរិសៈ
ឥ. ឥត្ថីលិង្គ
កិ. កិរិយាស័ព្ទ
កិត. កិតកិរិយា
គុ. គុណនាម
ច.ចតុត្ថីវិភត្តិ
ឆ. ឆដ្ឋីវិភត្តិ
ត. តតិយាវិភត្តិ
ទុ. ទុតិយាវិភត្តិ
ន. នាម
នបុំ. នបុំសកលិង្គ
និ. និបាត
ប. បឋមាវិភត្តិ
បញ្ច. បញ្ចមីវិភត្តិ
ប.បុ. បឋមបុរិសៈ
បុំ. បុំលិង្គ
ម.បុ. មជ្ឈិមបុរិសៈ
ស. សត្តមីវិភត្តិ

# មេរៀនទី ១

## អក្ខរវិធីសង្ខេប

*អក្ខរៈឬអក្សរ ជាគ្រឿងសម្រាប់សរសេរជំនួសការនិយាយសន្ទនាគ្នា។ អ្នកកាន់ព្រះពុទ្ធសាសនានិកាយថេរវាទនិយមប្រើភាសាបាលី ប៉ុន្តែមិនឃើញមានប្រើតួអក្សររបស់ភាសាបាលីទេ ឃើញប្រើតែតួអក្សរនៃជាតិខ្លួន ។ ខ្មែរយើងក៏ដូច្នោះដែរ គឺប្រើតួអក្សរខ្មែរដូចមានតទៅនេះ*

*តួអក្សរដែលប្រើក្នុងភាសាបាលីមាន ៤១ តួ និងចែកចេញជាពីរយ៉ាងគឺ* **ស្រៈ** *និង* **ព្យញ្ជនៈ** *។*

## ស្រៈ ឬ សរៈ (Vowels)

*ស្រៈមាន ៨ តួ, ចែកចេញជា ២ ប្រភេទគឺ ស្រៈពេញតួ និង ស្រៈនិស្ស័យ ។*

១. **ស្រៈពេញតួ** (Independent vowels) **អ**, **អា**, **ឥ**, **ឦ**, **ឧ**, **ឩ**, **ឯ**, **ឱ** ។

២. **ស្រៈនិស្ស័យ** (Dependent vowels) *អៈ, អា, អិ, អី, អុ, អូ, អេ, អោ* ។

*ស្រៈទាំង ៨ តួនេះចែកចេញជា ៣ សំឡេងគឺ ស្រៈសំឡេងខ្លីឬស្រៈរស្សៈ, ស្រៈសំឡេងវែងឬស្រៈទីឃៈនិងស្រៈសំឡេងផ្សំឬស្រៈសំយុត្ត ។*

***កំណត់ចំណាំ*** *ពួកស្រៈនិស្ស័យ វេលាយកទៅសរសេរផ្សំជាមួយព្យញ្ជនៈត្រូវលុបតួអក្សរ អ និង អ៊ ចេញ ។ ការសរសេរដូច្នេះក្នុង*

សៀវភៅនេះសម្រាប់អានបញ្ចោញសំឡេងតែប៉ុណ្ណោះ នៅខាងមុខនឹងមានការសរសេរដូច្នេះទៀត ។

១. **ស្រះរស្សៈ** ឬស្រៈសំឡេងខ្លី (Short vowels) គឺស្រៈ **អ, ឥ, ឧ** ។

២. **ស្រះទីឃៈ** ឬស្រៈសំឡេងវែង (Long vowels) គឺស្រៈ **អា, ឦ, ឩ, ឯ, ឱ** ។

៣. **ស្រះសំយុត្ត** ឬ ស្រៈសំឡេងផ្សំ (Diphthongs) មាន ២ តួគឺស្រៈ **ឯ, ឱ** ។

ស្រៈសំឡេងផ្សំគឺថាស្រៈ **ឯ** កើតពីស្រៈ (**អ** + **ឥ**) > **ឯ**, និងស្រៈ **ឱ** កើតពីស្រៈ (**អ** + **ឧ**) > **ឱ** ។

## ព្យញ្ជនៈ (Consonants)

ព្យញ្ជនៈក្នុងភាសាបាលីមាន ៣៣ តួគឺ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | | | |
| ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | | | |
| ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ | | | |
| ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | | | |
| ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម | | | |
| យ្យ | ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | ំ |

ព្យញ្ជនៈទាំង ៣៣ តួនេះចែកជា ៥ វគ្គដូចខាងក្រោមនេះ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វគ្គទី ១ | ឬកវគ្គមាន | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង | | | |
| វគ្គទី ២ | ឬចវគ្គមាន | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ | | | |
| វគ្គទី ៣ | ឬដវគ្គមាន | ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ | | | |
| វគ្គទី ៤ | ឬតវគ្គមាន | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន | | | |
| វគ្គទី ៥ | ឬបវគ្គមាន | ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម | | | |
| សេសវគ្គ | ឬអវគ្គមាន | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ្ឡ | ំ |

## អឃោសៈនិងឃោសៈ (Surd and Sonant)

*ព្យញ្ជនៈទាំងនេះមានពីរបែបគឺ អឃោសៈ និង ឃោសៈ ។*

១. *អឃោសៈមាន ១១ តួគឺ* ក, ខ, ច, ឆ, ដ, ឋ, ត, ថ, ប, ផ, ស ។

២. *ឃោសៈមាន ២១ តួគឺ* គ, ឃ, ង, ជ, ឈ, ញ, ឌ, ឍ, ណ, ទ, ធ, ន, ព, ភ, ម, យ, រ, ល, វ, ហ, ឡ ។

៣. *ចំពោះនិគ្គហិត (ំ) មិនរាប់ថាជាអឃោសៈឬឃោសៈទេ ។*

*ព្យញ្ជនៈក្នុងវគ្គនិមួយ ៗ នៃវគ្គទាំងប្រាំ បើហៅតាមលេខរៀងគឺ*

| | | |
|---|---|---|
| ក | *ហៅថា* | *តួទី ១* |
| ខ | *ហៅថា* | *តួទី ២* |
| គ | *ហៅថា* | *តួទី ៣* |
| ឃ | *ហៅថា* | *តួទី ៤* |
| ង | *ហៅថា* | *តួទី ៥ ឬ ព្យញ្ជនវគ្គន្តៈ ។* |

វគ្គឯទៀត ៗ ក៏មានការរាប់ដូចគ្នាដែរ ។

ព្យញ្ជនៈទាំងនេះមិនអានឱ្យមានសំឡេងជា អ ឬ អ៊ ដូចភាសាខ្មែរយើងទេ ត្រូវអានបញ្ចោញសំឡេងជា អៈ (អាក់) ឬ អ៊ៈ (អ៊ាក់) តាមឃោសៈឬអឃោសៈដែលស្មើនឹងសញ្ញាចុចពីរ (ៈ) នេះ ។ បើខ្មែរមានសំឡេង អ ខាងបាលីអានថា អៈ, បើខ្មែរអានថា អ៊ ខាងបាលីអានថា អ៊ៈ ដូច្នេះ កៈ, ខៈ, គៈ, ឃៈ, ងៈ ....... យៈ, រៈ, លៈ, វៈ, សៈ, ហៈ, ឡៈ ។ ប៉ុន្តែចំពោះតួ ប ត្រូវអានថា ប៉ៈ=ប៉ាក់ មិនមែន បាក់ ទេ ។

រីឯនិគ្គហិត (ំ) អានថា អ័ង (អាំង) មិនមែន អំ ទេ ។

## វិធីសំយោគព្យញ្ជនៈ

(Conjunct consonants)

វិធីសំយោគព្យញ្ជនៈជាវិធីតម្រួតតួអក្សរលើគ្នា ។ ក្នុងភាសាបាលីមានវិធីតម្រួតតួអក្សររៀបរយត្រឹមត្រូវល្អណាស់ ដូចមានតទៅនេះ

១. ព្យញ្ជនៈទី ១ អាចតម្រួតតែលើតួខ្លួនឯងនិងតួទី ២ ដូចជា

| | | | | | |
|---|---|---|---|---|---|
| ក វគ្គ | ក្ក | ដូចពាក្យថា | ចក្ក | ប្រែថា | កង់, ចក្រ |
| | ក្ក | .......ដ....... | ឧក្កា | ....ដ.... | គុបភ្លើង |
| | ក្ខ | .......ដ....... | បក្ខ | ....ដ.... | ពួក, បក្ស |
| | ក្ខ | .......ដ....... | ភិក្ខុ | ....ដ.... | ភិក្ខុ, អ្នកបួស |

| | | | | | |
|---|---|---|---|---|---|
| ច វគ្គ | ច្ច | ដូចពាក្យថា | សច្ច | ប្រែថា | ការពិត |
| | ច្ច | .......ដ....... | អនិច្ច | ....ដ.... | មិនទៀង |
| | ច្ឆ | .......ដ....... | មច្ឆ | ....ដ.... | ត្រី |
| | ច្ឆ | .......ដ....... | អច្ឆរ | ....ដ.... | ស្រីអប្សរ |
| ដ វគ្គ | ដ្ដ | .......ដ....... | វដ្ដ | ....ដ.... | ការវិល |
| | ដ្ដ | .......ដ....... | កេវដ្ដ | ....ដ.... | អ្នកនេសាទ |
| | ដ្ឋ | .......ដ....... | រដ្ឋ | ....ដ.... | ដែន, រដ្ឋ |
| | ដ្ឋ | .......ដ....... | ទិដ្ឋិ | ....ដ.... | ការឃើញ |
| ត វគ្គ | ត្ត | .......ដ....... | អត្ត | ....ដ.... | ខ្លួន, អាត្មា |
| | ត្ត | .......ដ....... | សត្ត | ....ដ.... | សត្វ |
| | ត្ថ | .......ដ....... | ហត្ថ | ....ដ.... | ដៃ |
| | ត្ថ | .......ដ....... | អត្ថ | ....ដ.... | ប្រយោជន៍ |
| ប វគ្គ | ប្ប | .......ដ....... | សប្ប | ....ដ.... | ពស់ |
| | ប្ប | .......ដ....... | សិប្ប | ....ដ.... | សិល្បៈ |
| | ប្ផ | .......ដ....... | បុប្ផ | ....ដ.... | ផ្កា |
| | ប្ផ | .......ដ....... | គោប្ផក | ....ដ.... | កជើង |

២. ព្យញ្ជនទី ៣ អាចតម្រួតតែលើខ្លួនឯងនិងតួទី ៤ ដូចជា

| | | | | | |
|---|---|---|---|---|---|
| ក វគ្គ | គ្គ | ដូចពាក្យថា | វគ្គ | ប្រែថា | ពួក, វគ្គ |

| | | | | | |
|---|---|---|---|---|---|
| | គ្គ | .......ជ....... | អគ្គិ | ....ជ.... | ភ្លើង |
| | ក្ខ | .......ជ....... | យក្ខ | ....ជ.... | សូមតេជៈ |
| | គ្ឃ | .......ជ....... | ព្យគ្ឃ | ....ជ.... | ខ្លាធំ |
| ច វគ្គ | ជ្ជ | .......ជ....... | អជ្ជ | ....ជ.... | ក្នុងថ្ងៃនេះ |
| | ជ្ជ | .......ជ....... | មជ្ជ | ....ជ.... | ការស្រវឹង |
| | ជ្ឈ | .......ជ....... | មជ្ឈ | ....ជ.... | កណ្តាល |
| | ជ្ឈ | .......ជ....... | សជ្ឈុ | ....ជ.... | ប្រាក់(លោហ) |
| ដ វគ្គ | ឌ្ឌ | .......ជ....... | លេឌ្ឌុ | ....ជ.... | ដុំដី |
| | ឌ្ឌ | .......ជ....... | កុឌ្ឌ | ....ជ.... | ជញ្ជាំង |
| | ឌ្ឍ | .......ជ....... | វុឌ្ឍិ | ....ជ.... | សេចក្តីចម្រើន |
| | ឌ្ឍ | .......ជ....... | អឌ្ឍ | ....ជ..... | កន្លះ |
| ត វគ្គ | ទ្ទ | .......ជ....... | សទ្ទ | ....ជ.... | សំឡេង, ស័ព្ទ |
| | ទ្ទ | .......ជ....... | និទ្ទ | ....ជ.... | ការដេក, និទ្រា |
| | ទ្ធ | .......ជ....... | ពុទ្ធ | ....ជ.... | ព្រះពុទ្ធ |
| | ទ្ធ | .......ជ....... | លទ្ធិ | ....ជ.... | ទំនៀម, លទ្ធិ |
| ប វគ្គ | ព្វ | .......ជ....... | សព្វ | ....ជ.... | ទាំងពួង, សព្វ |
| | ព្វ | .......ជ....... | បព្វត | ....ជ.... | ភ្នំ |
| | ព្ភ | .......ជ....... | គព្ភ | ....ជ.... | ពោះ, គភ៌ |
| | ព្ភ | .......ជ....... | អារព្ភ | ....ជ..... | ប្រារព្ធហើយ |

៣. ព្យញ្ជនៈទី ៥ អាចតម្រួតលើតួខ្លួនឯងនិងតួឯទៀតក្នុងវគ្គផងគ្នាបានដូចជា

| | | | | | |
|---|---|---|---|---|---|
| ក វគ្គ | ង្ក | ដូចពាក្យថា | សង្ការ | ប្រែថា | សម្រាម |
| | ង្ខ | .......ដ....... | សង្ខារ | ....ដ.... | សង្ខារ |
| | ង្គ | .......ដ....... | អង្គ | ....ដ.... | ខ្លួន, អង្គ |
| | ង្ឃ | .......ដ....... | សង្ឃ | ....ដ.... | ក្រុម, សង្ឃ |
| | ង្ង | .......ដ....... | គ្មាន? | ....ដ.... | |
| ច វគ្គ | ញ្ច | .......ដ....... | បញ្ច | ....ដ.... | ប្រាំ |
| | ញ្ឆ | .......ដ....... | ឧញ្ឆ | ....ដ.... | ស្បៀងត្រៀម |
| | ញ្ជ | .......ដ....... | កុញ្ជរ | ....ដ.... | ដំរី |
| | ញ្ឈ | .......ដ....... | វញ្ឈា | ....ដ.... | ស្រីអារ |
| | ញ្ញ | .......ដ....... | បុញ្ញ | ....ដ.... | បុណ្យ |
| ដ វគ្គ | ណ្ដ | .......ដ....... | កណ្ដក | ....ដ.... | បន្លា |
| | ណ្ឋ | .......ដ....... | សណ្ឋាន | ....ដ.... | ទ្រង់ទ្រាយ |
| | ណ្ឌ | .......ដ....... | កណ្ឌ | ....ដ.... | ព្រួញ |
| | ណ្ឍ | .......ដ....... | គ្មាន? | ....ដ.... | |
| | ណ្ណ | .......ដ....... | វណ្ណ | ....ដ.... | ពណ៌ |
| ត វគ្គ | ន្ត | .......ដ....... | ខន្តិ | ....ដ.... | សេចក្ដីអត់ធន់ |
| | ន្ថ | .......ដ....... | គន្ថ | ....ដ.... | គម្ពីរ |

| | | | | | |
|---|---|---|---|---|---|
| | ន្ទ | ដូចពាក្យថា | មន្ទ | ប្រែថា | តិច, ខ្សោយ |
| | ន្ធ | .......ដ....... | ឥន្ធ | ....ដ.... | ខ្លៅ, ល្ងង់ |
| | ន្ន | .......ដ....... | សន្និបាត | ....ដ.... | ការប្រជុំ |
| ប វគ្គ | ម្ប | .......ដ....... | កម្បតិ | ....ដ.... | កក្រើក, ញ័រ |
| | ម្ផ | .......ដ....... | សម្ផស្ស | ....ដ.... | ការប៉ះពាល់ |
| | ម្ព | .......ដ....... | អម្ព | ....ដ.... | ដើមស្វាយ |
| | ម្ភ | .......ដ....... | សម្ភាវន | ....ដ.... | សេចក្តីសរសើរ |
| | ម្ម | .......ដ....... | កម្ម | ....ដ.... | អំពើ, ការងារ |

៤. ព្យញ្ជនអវគ្គទាំង ៨ តួមាន ៣ តួអាចតម្រួតលើខ្លួនឯងបានគឺ យ, ល, ស និងខ្លះទៀត អាចតម្រួតលើតួឯទៀតក្នុងវគ្គផងគ្នាបានដូចជា

| | | | | |
|---|---|---|---|---|
| យ្យ | ដូចពាក្យថា | សេយ្យា | ប្រែថា | ការដេក |
| ល្ល | .......ដ....... | សល្ល | ....ដ.... | កូនសរ |
| ស្ស | .......ដ....... | សិស្ស | ....ដ.... | សិស្ស |

៥. មានវិធីតម្រួតតួអក្សរក្រៅពីពោលហើយខាងលើនេះខ្លះទៀត ប៉ុន្តែការតម្រួតរបៀបនេះមានការអានដូចជាព្យញ្ជនៈផ្ញើរជើងក្នុងភាសាខ្មែរយើង ។

៥.១ ព្យញ្ជនវគ្គលើព្យញ្ជនអវគ្គដូចជា

| | | | | |
|---|---|---|---|---|
| ក្ខ | ដូចពាក្យថា | ក្ខចិ | ប្រែថា | ក្នុងទីខ្លះ |
| ក្យ | .......ដ....... | សក្យ | ....ដ.... | ផៅពង្សសក្យៈ |
| ត្រ | .......ដ....... | តត្រ | ....ដ.... | ទីនោះ |
| ត្វំ | .......ដ....... | ត្វំ | ....ដ.... | អ្នក, ឯង, លោក |
| ទ្វិ | .......ដ....... | ទ្វិ | ....ដ.... | ២ |
| ន្វ | .......ដ....... | អន្វេសនា | ....ដ.... | ការស្វែងរក |
| ព្រ | .......ដ....... | ព្រហ្ម | ....ដ.... | ព្រះព្រហ្ម |
| ព្យ | .......ដ....... | ព្យាធិ | ....ដ.... | ជំងឺ |

៥.២ ព្យញ្ជនអវគ្គលើព្យញ្ជនវគ្គដូចជា

| | | | | |
|---|---|---|---|---|
| ស្ម | ដូចពាក្យថា | តស្មា | ប្រែថា | ព្រោះហេតុនោះ |
| ហ្ម | .......ដ....... | ព្រហ្ម | ....ដ.... | ព្រះព្រហ្ម |

៥.៣ ព្យញ្ជនអវគ្គលើព្យញ្ជនអវគ្គដូចជា

| | | | | |
|---|---|---|---|---|
| ល្យ | ដូចពាក្យថា | កល្យាណ | ប្រែថា | ល្អ, ពិរោះ |
| វ្យ | .......ដ....... | វ្យាធាទ | ....ដ.... | ព្យាបាទ |
| ស្វ | .......ដ....... | ស្វេ | ....ដ.... | ក្នុងថ្ងៃស្អែក |

៦. ចំពោះអក្សរ ហ អាចសរសេរក្រោមតួឯទៀតៗបានច្រើនតួដូច

| | | | | |
|---|---|---|---|---|
| ញ្ហ | ដូចពាក្យថា | បញ្ហា | ប្រែថា | សំនួរ, បញ្ហា |
| ណ្ហ | .......ដ....... | តណ្ហា | ....ដ.... | ចំណង់ |
| ម្ហ | .......ដ....... | តុម្ហេ | ....ដ.... | អ្នកទាំងឡាយ |
| យ្ហ | .......ដ....... | មយ្ហំ | ....ដ.... | របស់យើង |
| វ្ហ | .......ដ....... | ជីវ្ហា | ....ដ.... | អណ្ដាត |
| ឡ្ហ | .......ដ....... | ទឡ្ហ | ....ដ.... | មាំមួន, ខ្លាំង |

៧. និគ្គហិត (ំ) អាចសរសេរលើព្យញ្ជនគ្រប់តួនិងស្រៈ ៣ តួគឺ អ, ឥ, ឧ ដែលមានសំឡេងស្មើនឹងតួអក្សរ ង ដូចជា អំសុ (អាំងសុ), សង្ខឹ (សាត់ធឹង), កិត្តុំ, កាតុំ, ឯវំ, ពុទ្ធំ, ធម្មំ, សង្ឃំ ជាដើម ។

## វិធីអានភាសាបាលី

១. ព្យញ្ជនៈដែលមិនមានស្រៈអាស្រ័យទេ ត្រូវអានបញ្ចោញសំឡេងថា អៈ ឬ អ៊ៈ ទៅតាមឃោសាឃោសៈគ្រប់វេលាដូចជា

| | | |
|---|---|---|
| ធមោ | អានថា | ន:-មោ |
| បសាទ | ....ដ.... | ប៉:-សា-ទ: |
| គោតម | ....ដ.... | គោ-ត:-ម៉: |
| ភគវា | ....ដ.... | ភ:-គ:-វា |
| រតន | ....ដ.... | រ:-ត:-ន៉: |

២. ព្យញ្ជនសំយោគមានវិធីអានដូចភាសាខ្មែរយើងដែរ គឺយកតួខាងដើមប្រកបជាមួយតួខាងលើ ។ រីឯតួខាងក្រោមដែលនិយមហៅថា "ជើង" ប្រកបជាមួយស្រៈ ឧ. បង្កើត អានថា (បង់កើត) ។

| | | |
|---|---|---|
| កម្ម | អានថា | កាំ-ម៉ៈ |
| សន្តិ | ....ដ.... | សាន់-តិ |
| សន្និបាត | ....ដ.... | សាន់-និ-ប៉ា-តៈ |
| ភិក្ខវេ | ....ដ.... | ភិក-ខៈ-វេ |
| សម្បត្តិ | ....ដ.... | សាំ-ប៉ាត់-តិ |
| អដ្ឋង្គិកោ | ....ដ.... | អាត់-ឋាំង-គិ-កោ |

៣. ចំពោះនិគ្គហិត បើមាននៅលើតួអក្សរណាក៏ដោយ ត្រូវអានឱ្យមានសំឡេងដូច ង ដូចជា

| | | | | | |
|---|---|---|---|---|---|
| ពុទ្ធំ | អានថា | ពុត-ធាំង | ឧទកំ | អានថា | ឧ-ទៈ-កាំង |
| ធម្មំ | ....ដ.... | ធាំ-មាំង | ឈានំ | ....ដ.... | ឈា-នាំង |
| សង្ឃំ | ....ដ.... | សាំង-ឃាំង | ធាតុំ | ....ដ.... | ធា-តុង |
| បុរិសំ | ....ដ.... | ប៉ុ-រ៉ិ-សាំង | កុហឹ | ....ដ.... | កុ-ហឹង |

រឿងអក្ខរវិធីនេះ បើប្រាថ្នាជ្រាបឲ្យបានពិស្តារថែមទៀត សូមរកមើលនៅក្នុងភាគទី ២ ។ ក្នុងទីនេះសូមអធិប្បាយដោយសង្ខេបប៉ុណ្ណោះ

សិន ដើម្បីកុំឱ្យអ្នកសិក្សាថ្មីមានការធុញទ្រាន់ ។

## លំហាត់នៃមេរៀនទី ១

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើ អក្ខរ ឬ អក្សរប្រើក្នុងភាសាបាលីមានប៉ុន្មានតួ ? គឺអ្វីខ្លះ ?
២. តើ ស្រៈ មានប៉ុន្មានតួនិងចែកជាប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?
៣. ស្រៈមានសំឡេងខ្លីឬស្រៈរស្សៈមានប៉ុន្មានតួ ? គឺស្រៈអ្វីខ្លះ ?
៤. ស្រៈមានសំឡេងវែងឬស្រៈទីឃៈមានប៉ុន្មានតួ ? គឺស្រៈអ្វីខ្លះ ?
៥. ស្រៈសំឡេងផ្សំឬស្រៈសំយុត្តមានប៉ុន្មានតួ ? គឺស្រៈអ្វីខ្លះ ?
៦. តើស្រៈ ឯ និង ស្រៈ ឱ កើតចេញពីស្រៈអ្វីខ្លះ ?
៧. តើព្យញ្ជនៈទាំងអស់មានប៉ុន្មានតួ ?
៨. តើព្យញ្ជនៈទាំងអស់ចែកចេញជាប៉ុន្មានវគ្គ ? ក្នុងវគ្គនិមួយ ៗ មានប៉ុន្មាតួ ?
៩. តើព្យញ្ជនអឃោសៈមានប៉ុន្មានតួ ? គឺអ្វីខ្លះ ?
១០. តើព្យញ្ជនឃោសៈមានប៉ុន្មានតួ ? គឺអ្វីខ្លះ ?

### ខ. ចូរហាត់អានស័ព្ទភាសាបាលីដែលមាននៅខាងក្រោមនេះ

១. នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
២. ឥមេសំ ឧសន្នំ ឧនវណ្ណានំ វាណិជានំ បញ្ញោ សុខំ ជីវតិ ។

៣. តុម្ហាកំ បុត្តា គេហស្ស ច រុក្ខស្ស ច អន្តរា គាំឡឹសុ ។

៤. <u>ធម៌នមស្ការព្រះរតនត្រ័យ</u>

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

យោ សន្និសន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ វិជេ-យ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ ....។បេ។

៥. <u>ពុទ្ធជយមង្គលគាថា</u>

ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។
នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។
ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។
កត្វាន កដ្ឋមុទរំ ឥវ គព្ភិនិយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។ ... ។បេ។

(ចប់មេរៀនទី ១)

# មេរៀនទី ២

## អធិប្បាយអំពីនាមស័ព្ទ

***វចីវិភាគ*** *ប្រែថា ការចែកពាក្យឬសម្តី ។*

*ពាក្យឬសម្តីសម្រាប់ប្រើប្រាស់ក្នុងការនិយាយប្រស្រ័យទាក់ទងគ្នា ក្នុងភាសាបាលីចែកជា ៦ ចំណែកធំ ៗ គឺ*

*១. នាមស័ព្ទ* *២. អព្យយស័ព្ទ* *៣. អាខ្យាតកិរិយាស័ព្ទ*

*៤. កិតកិរិយាស័ព្ទ* *៥. តទ្ធិតស័ព្ទ* *៦. សមាសស័ព្ទ*

## នាមស័ព្ទ (Nouns)

**ណាម** *ប្រែថា ឈ្មោះ ។ ក្នុងវេយ្យាករណ៍នៃភាសាបាលីជាពាក្យសម្រាប់ប្រើហៅអ្វី ៗ ទាំងពួងក្នុងលោក ទាំងមានជីវិតនិងគ្មានជីវិត ទាំងមានរូបនិងគ្មានរូបផងដែរ ដូចជាពាក្យថា មនុស្ស, សត្វ, តុ, កៅអី, ជីវិត, ចិត្ត, សេចក្តីសុខ, សេចក្តីទុក្ខ ជាដើម ។*

*នាមស័ព្ទទាំងឡាយនេះចែកជា ៣ យ៉ាងគឺ* **ណាមណាម**, **គុណ-ណាម** *និង* **សព្វណាម** *។ តទៅនេះនឹងអធិប្បាយអំពី* **ណាមណាម** *មុនគេ ។*

## នាមនាម (Nouns)

**ណាមណាម** *ប្រែថា ឈ្មោះនៃឈ្មោះ ដូចជាពាក្យថា ដី, ទឹក, ភ្លើង,*

ខ្យល់, គោ, ក្របី, ត្រី ឬ ភ្នំពេញ, កម្ពុជា, អង្គរវត្ត, សាវត្ថី, ពារាណសី, មោគ្គល្លាន, សារីបុត្ត ជាដើម ។

នាមនាមទាំងនោះមាន ២ យ៉ាងគឺ **សាធារណនាម** (Common noun) និង **អសាធារណនាម** (Proper noun) ។

១. **សាធារណនាម** (Common noun) ជានាមសព្ទសម្រាប់ហៅទូទៅ មិនចំពោះនិងមិនកំណត់ថាណាមួយទេដូចជាពាក្យថា តុ, កៅអី, ដំរី, សេះ, ផ្ទះ, វត្ត, វិហារ, លទ្ធិ, សាសនា ។ល។

២. **អសាធារណនាម** (Proper noun) ជានាមសព្ទសម្រាប់ហៅបានតែចំពោះអ្វីមួយប៉ុណ្ណោះ មិនមានមួយណាទៀតទេ ដូចជាពាក្យថា មោគ្គល្លាន, សារីបុត្ត, កម្ពុជា, ភ្នំពេញ, សាវត្ថី ។ល។

នាមសព្ទទាំងឡាយក្នុងភាសាបាលីមានគ្រឿងដែលត្រូវដឹងដូចតទៅនេះគឺ ១. **ការន្ត**, ២. **លិង្គ**, ៣. **វចន**, ៤. **វិភត្តិ**, ៥. **ការក**, និង ៦. **អាយតនិបាត** ។

## ១. ការន្ត (Stem of nouns)

**ការន្ត** គឺជាស្រៈទីបំផុតនៃនាមសព្ទនោះ ៗ ។ ក្នុងភាសាបាលីលោកបានចែកការន្តចេញជា ៦ គឺ **អ**, **អា**, **ឥ**, **ឦ**, **ឧ**, **ឩ** (មាន **ឱ** ការន្តមួយទៀត ប៉ុន្តែមិនមាននាមជាការន្តនេះច្រើនទេ) ។

ការន្តទាំង ៦ នេះមានឈ្មោះហៅដូចខាងក្រោមនេះ

## ឈ្មោះរបស់ការន្ត

| នាមស័ព្ទ | ឈ្មោះការន្ត |
|---|---|
| បុរិស | អ ការន្ត មានស្រៈ អ ជាទីបំផុតតែមិនមានរូបស្រៈទេ ។ |
| កញ្ញា | អា ការន្ត មានស្រៈ អា ជាទីបំផុតនិងមានរូបស្រៈ ។ |
| មុនិ | ឥ ការន្ត មានស្រៈ ឥ ជាទីបំផុតនិងមានរូបស្រៈ ។ |
| ជាតី | ឦ ការន្ត មានស្រៈ ឦ ជាទីបំផុតនិងមានរូបស្រៈ ។ |
| ភិក្ខុ | ឧ ការន្ត មានស្រៈ ឧ ជាទីបំផុតនិងមានរូបស្រៈ ។ |
| វធូ | ឩ ការន្ត មានស្រៈ ឩ ជាទីបំផុតនិងមានរូបស្រៈ។ |

## ២. លិង្គ (Gender)

លិង្គ ប្រែថា ភេទ, លក្ខណៈឬគ្រឿងសម្គាល់ ជាគ្រឿងសម្គាល់របស់នាមស័ព្ទ ។ ក្នុងភាសាបាលីលោកបានកំណត់នាមស័ព្ទនោះ ៗ ឱ្យមានលិង្គឬភេទដែលមាន ៣ លិង្គគឺ **បុំលិង្គ** ឬ **បុល្លិង្គ** (Masculine), **ឥត្ថីលិង្គ** (Feminine) និង **នបុំសកលិង្គ** (Neuter) ។

| ឈ្មោះលិង្គ | អក្សរសង្ខេប | |
|---|---|---|
| ១. **បុំលិង្គ** | បុំ. | ភេទប្រុស ឬ ឈ្មោល ។ |
| ២. **ឥត្ថីលិង្គ** | ឥ. | ភេទស្រី ឬ ញី ។ |
| ៣. **នបុំសកលិង្គ** | នបុំ. | មិនមែនភេទប្រុសឬស្រី ។ |

## ប្រភេទរបស់លិង្គ

ក្នុងលិង្គទាំងបីនេះមាន ២ ប្រភេទគឺ **ជាតិលិង្គ** និង **សម្មតិលិង្គ** ។

## ២.១ ជាតិលិង្គ

ពាក្យដូចជា **បុរិស**=ប្រុស, បុរស, **ភិក្ខុ**=អ្នកបួស, ភិក្ខុ, **ហត្ថី**=ដំរីឈ្មោល ។ល។ ពាក្យទាំងនេះវេលាប្រែជាខ្មែរប្រាប់ឱ្យដឹងភេទរួចស្រេច, ពាក្យដូចជា **ឥត្ថី**=ស្រី, **នារី**=ស្រី, **កញ្ញា**=ស្រីក្រមុំ, **ធេនុ**=មេគោឬគោញី ។ល។ ពាក្យទាំងនេះវេលាប្រែជាខ្មែរក៏ប្រាប់ឱ្យដឹងភេទរួចជាស្រេចដែរ ។ ពាក្យទាំងឡាយណា វេលាប្រែជាភាសាខ្មែរប្រាប់ឱ្យដឹងភេទរួចជាស្រេចដូចនៅខាងលើនេះ ពាក្យទាំងឡាយនោះហៅថា **ជាតិលិង្គ** ប្រែថា **លិង្គពីកំណើត** ។

## ២.២ សម្មតិលិង្គ

ពាក្យដូចជា **បទេស**=ប្រទេស, **ភូមិ**=ដី, **នទី**=ស្ទឹង, ទន្លេ, **ឱទន**=បាយ, **មធុ**=ទឹកឃ្មុំ, **សភា**=ទីប្រជុំ, **គាម**=ស្រុក, **ខេត្ត**=ស្រែ ។ល។ ពាក្យទាំងនេះវេលាប្រែជាខ្មែរមិនប្រាប់ឱ្យដឹងថាជាភេទអ្វីទេ ។ ប៉ុន្តែក្នុងភាសាបាលីលោកចាត់ឱ្យមានលិង្គដូច្នេះ

ពាក្យថា **បទេស**, **ឱទន**, **គាម** លោកចាត់ជា បុំលិង្គ ។

ពាក្យថា **ភូមិ, ជជី, សភា** លោកចាត់ជា ឥត្ថីលិង្គ ។

ពាក្យថា **មធុ, ខេត្ត** លោកចាត់ជា នបុំសកលិង្គ ។

ពាក្យដូច្នេះហៅថា សម្មតិលិង្គ (គឺ **លិង្គដោយសន្មតិ**) ។

សម្មតិលិង្គនេះជាការលំបាកមួយសម្រាប់អ្នករៀនដំបូង ដែលអាចធ្វើឱ្យនឿយណាយចិត្តមិនចង់រៀនតទៅទៀត ។ ប៉ុន្តែវិធីល្អដែលអាចជួយដោះស្រាយក្នុងរឿងនេះ គឺត្រូវរៀនចំណាំទុករាល់ពេលដែលបានជួបនាមសព្ទថ្មី ។ លិង្គនីមួយ ៗ មានការន្តដូចគ្នាខ្លះនិងខុសគ្នាខ្លះដូចខាងក្រោមនេះ

| | | | |
|---|---|---|---|
| ១. | **បុំលិង្គ** | មាន ៥ ការន្តគឺ | **អ, ឥ, ឦ, ឧ, ឩ** ។ |
| ២. | **ឥត្ថីលិង្គ** | មាន ៥ ការន្តគឺ | **អា, ឥ, ឦ, ឧ, ឩ** ។ |
| ៣. | **នបុំសកលិង្គ** | មាន ៣ ការន្តគឺ | **អ, ឥ, ឧ** ។ |

## ៣. វចនៈ (Number)

**វចន** ប្រែថា សម្តី តែក្នុងវេយ្យាករណ៍បានដល់ "ចំនួន" ដែលមានពីរយ៉ាងគឺ **ឯកវចន** (Singular) និង **ពហុវចន** (Plural) ។ នាមនាមណាប្រាប់ឱ្យដឹងថាមានចំនួនតែមួយហៅថា **ឯកវចន** ដូចជា មនុស្សម្នាក់, គោមួយ ជាដើម ។ នាមនាមណាប្រាប់ឱ្យដឹងថាមានចំនួនចាប់ពីពីរឡើងទៅហៅថា **ពហុវចន** ដូចជា មនុស្សប្រាំនាក់, គោបីក្បាល ជាដើម ។

## ៤. វិភត្តិ (Case endings)

**វិភត្តិ** *ប្រែថា ការចែក, ចំណែក ។ វិភត្តិមាន ២ យ៉ាងគឺ* **វិភត្តិនាម** *និង* **វិភត្តិអាខ្យាតកិរិយា** *។ វិភត្តិនាមប្រើសម្រាប់ចុះត្រង់ចុងនាមស័ព្ទ ដើម្បីធ្វើឱ្យនាមស័ព្ទនោះ ៗ មានវចនៈគឺជាឯកវចនៈឬពហុវចនៈ ថែមទាំងឱ្យមានមុខងារក្នុងប្រយោគទៀតផង ។ ក្នុងទីនេះនឹងអធិប្បាយអំពីវិភត្តិនាមមុនគេដែលទាំងអស់មាន ១៦ តួ និង ២ វចនៈដូចមានឈ្មោះហៅខាងក្រោមនេះ*

| | *ឈ្មោះវិភត្តិនាម* | *អក្សរសង្ខេប* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|---|---|
| ១. | បឋមាវិភត្តិ | *ប.* | សិ | យោ |
| ២. | ទុតិយាវិភត្តិ | *ទុ.* | ំ | យោ |
| ៣. | តតិយាវិភត្តិ | *ត.* | នា | ហិ |
| ៤. | ចតុត្ថីវិភត្តិ | *ច.* | ស | នំ |
| ៥. | បញ្ចមីវិភត្តិ | *បញ្ច.* | ស្មា | ហិ |
| ៦. | ឆដ្ឋីវិភត្តិ | *ឆ.* | ស | នំ |
| ៧. | សត្តមីវិភត្តិ | *ស.* | ស្មឹ | សុ |
| ៨. | អាលបនវិភត្តិ | *អា.* | សិ | យោ |

*សូមចំណាំអក្សរសង្ខេបឱ្យបានល្អព្រោះនឹងមានប្រើជាញឹកញយក្នុងពេលខាងមុខ ។*

## ៤. ការក: (Cases)

**ការក** ប្រែថា អ្នកធ្វើ ស្មើគ្នានឹងភាសាអង់គ្លេសថា Case (ឃេស) មាន ៨ យ៉ាងដូចវិភត្តិដែរ ដូចមានឈ្មោះហៅខាងក្រោមនេះ

| | | | | |
|---|---|---|---|---|
| ១. | **បឋមាវិភត្តិ** | **ហៅ** | កត្តុការក | Nominative case |
| ២. | **ទុតិយាវិភត្តិ** | ...ដ... | កម្មការក | Accusative case |
| ៣. | **តតិយាវិភត្តិ** | ...ដ... | ករណការក | Instrumental case |
| ៤. | **ចតុត្ថីវិភត្តិ** | ...ដ... | សម្បទានការក | Dative case |
| ៥. | **បញ្ចមីវិភត្តិ** | ...ដ... | អបាទានការក | Ablative case |
| ៦. | **ឆដ្ឋីវិភត្តិ** | ...ដ... | សាមីការក* | Genitive case |
| ៧. | **សត្តមីវិភត្តិ** | ...ដ... | អធិករណការក | Locative case |
| ៨. | **អាលបនវិភត្តិ** | ...ដ... | អាលបនការក* | Vocative case |

ពាក្យថា ការក: បានដល់ នាមបទដែលបំបែករួចហើយតាមវិភត្តិទាំង ៨ ឈ្មោះដូចបានពោលនៅខាងលើនោះ ដែលប្រាប់ឱ្យដឹងថានាមបទនោះ ៗ មានមុខងារយ៉ាងណាក្នុងប្រយោគ និងត្រូវប្រែដូចម្ដេចជាភាសាខ្មែរ ។ ចំពោះពាក្យប្រែវិញគឺជាពាក្យប្រែរបស់វិភត្តិនីមួយ ៗ នោះឯង ។ ដូច្នេះចូរចាំឈ្មោះរបស់វិភត្តិនិងឈ្មោះរបស់ការក: ព្រមទាំងអាយតនិបាត(អធិប្បាយនៅខាងក្រោម)ឱ្យបានល្អ ព្រោះនេះជាជំហានដំបូងបង្អស់របស់អ្នកសិក្សាភាសាបាលីក្នុងការរៀនប្រែជាភាសាខ្មែរ ។

*<u>បញ្ជាក់</u> នៅក្នុងគម្ពីរកច្ចាយននិងមោគ្គល្លានប្រាប់ថាមានការក:

ត្រឹមតែ ៦ ទេ ។ ប៉ុន្តែនៅខាងលើនេះបានរាប់សង្គ្រោះចូលថែមពីរទៀត គឺទី ៦ និងទី ៨ ដើម្បីឱ្យគ្រប់ចំនួនតាមគម្ពីរភាសាអឺរ៉ុប ។

## ៦. អាយតនិបាត (Prepositions)

អាយតនិបាត ប្រែថា និបាតប្រើញែកឬវាតឱ្យស្រឡះនឹងស្តាប់បានសេចក្តីពិរោះល្អ ។ ក្នុងភាសាបាលីសំដៅយកទីបំផុតនៃនាមស័ព្ទនីមួយ ៗ ដែលសម្រេចហើយដោយវិភត្តិឬពាក្យប្រែមកជាភាសាខ្មែរនោះឯង ។

| **វិភត្តិ** | **ឯក.** | **ពហុ.** | **អាយតនិបាត ឬ ពាក្យប្រែ** |
|---|---|---|---|
| ប. | សិ | យោ | រី ។ |
| ទុ. | ំ | យោ | នូវ, កាន់, នឹង, អស់, ចំពោះ, ញុំាង ។ |
| ត. | នា | ហិ | ដោយ, ដោយនូវ, ជាមួយ, តាម, ខាង, ដែល, គឺ, ព្រោះ, ហេតុ, មាន ។ |
| ច. | ស | នំ | ដល់, ដើម្បី, បំរុង, នឹង, ចំពោះ ។ |
| បញ្ច | ស្មា | ហិ | ពី, ចាក, ជាង, ហេតុ, ព្រោះ, ព្រោះតែ ។ |
| ឆ. | ស | នំ | នៃ, របស់, កាល, កាលបើ, កាលដែល, បណ្តា, ជំនុំ ។ |
| ស. | ស្មឹ | សុ | ក្នុង, ឰដ៏, នា, ទៀប, ជិត, លើ, ត្រង់, កាល, នា-កាល, កាលបើ, ជំនុំ, បណ្តា, និមិត្ត ។ |
| អា. | សិ | យោ | បពិត្រ, ម្នាល, នែ, ហៃ ។ |

ពាក្យប្រែទាំងឡាយខាងលើនេះជា **ឯកវចនៈ** តែម្យ៉ាង ។ ប្រសិនបើចង់ឱ្យទៅជា **ពហុវចនៈ** ត្រូវថែមពាក្យថា "...ទាំងឡាយ" នៅខាងចុងពាក្យប្រែទាំងនេះដែលសរសេរកាត់ជា ".ទ." ឧទាហរណ៍

**បុរិសោ** ប្រែថា "វីប្រុស, វីបុរស" នេះជា **ឯកវចនៈ** ។

**បុរិសា** ប្រែថា "វីប្រុសទាំងឡាយ, វីបុរស.ទ." នេះជា **ពហុវចនៈ** ។

ចំពោះវិភត្តិឯទៀត ៗ ក៏មានគតិដូចគ្នាដែរ ។

## វិធីបំបែកនាមស័ព្ទ អ ការន្ត

(Declension of noun in a-stem)

សូមរំលឹកថានាមស័ព្ទក្នុងភាសាបាលីមាន ៦ ការន្តគឺ អ, អា, ឥ, ឦ, ឧ, ឩ អាស្រ័យហេតុនេះ ការបំបែកនាមក៏មានភាពប្លែក ៗ គ្នាផងដែរ ។ សូមជំរាបថា ក្នុងសៀវភៅនេះមិនយកវិភត្តិដែលពោលហើយខាងលើនោះមកប្រើទេ គឺប្រើរូបមន្តមួយទៀតដែលឱ្យឈ្មោះថា **វិភត្តិសម្រេចរូប** ដូចមានអធិប្បាយជាបន្តបន្ទាប់តទៅនេះ

## វិភត្តិសម្រេចរូបរបស់ អ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឱ | អា |
| ទុ. | អំ | ឯ |

| | | |
|---|---|---|
| ត. | ឯង | ឯហិ, ឯភិ |
| ប. | អស្ម, អាយ, អត្តំ | អានំ |
| បញ្ច. | អស្មា, អម្ហា, អា | ឯហិ, ឯភិ |
| ឆ. | អស្ម | អានំ |
| ស. | អស្មឹ, អម្ហិ, ឯ | ឯសុ |
| អា. | អ | អា |

## កំណាត់សម្គាល់

*រាល់តួអក្សរ **អ** ដែលសរសេរឱ្យស្រៈនិស្ស័យអាស្រ័យដូចមាននៅខាងលើនេះគឺសម្រាប់អានបញ្ចោញសំឡេងតែប៉ុណ្ណោះ ។ វេលាយកវិភត្តិសម្រេចរូបទាំងនេះទៅប្រើ ត្រូវលុបតួអក្សរ **អ** ទាំងនេះចេញ ឧ.*

**កុមារ** + ( **អា** > ◌ា ) > **កុមារា** ។

**កុមារ** + ( **អស្ម** > **ស្ម** ) > **កុមារស្ម** ។

*ចំពោះស្រៈពេញតួត្រូវផ្លាស់ជាស្រៈនិស្ស័យវិញ ឧទាហរណ៍*

**បុរិស** + ( **ឯង** > េ◌ង ) > **បុរិសេង** ។

**បុរិស** + ( **ឯហិ** > េ◌ហិ ) > **បុរិសេហិ** ។

☸ **បញ្ជាក់** *វិធីសរសេរវិភត្តិសម្រេចរូបនៅក្នុងសៀវភៅនេះ អាចមិនស្រប ឬប្លែកពីគម្ពីរធំ ៗ មានគម្ពីរកច្ចាយននិងមោគ្គល្លានជាដើម ។ ការសរសេរបែបនេះគឺក្នុងបំណងឱ្យអ្នកសិក្សាដំបូងងាយយល់តែប៉ុណ្ណោះ ។*

## វិធីបំបែក បុរិស (ប្រុស, បុរស) អ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | បុរិសោ | បុរិសា |
| ទុ. | បុរិសំ | បុរិសេ |
| ត. | បុរិសេន | បុរិសេហិ, បុរិសេភិ |
| ច. | បុរិសស្ស, បុរិសាយ, បុរិសត្ថំ | បុរិសានំ |
| បញ្ច. | បុរិសស្មា, បុរិសម្ហា, បុរិសា | បុរិសេហិ, បុរិសេភិ |
| ឆ. | បុរិសស្ស | បុរិសានំ |
| ស. | បុរិសស្មឹ, បុរិសម្හិ, បុរិសេ | បុរិសេសុ |
| អា. | បុរិស | បុរិសា |

*សូមសង្កេតមើលក្នុងវិភត្តិខ្លះមានរូបដូចគ្នា តែអាចដឹងបានថាជាវិភត្តិអ្វីគឺនៅពេលប្រើក្នុងប្រយោគ និងនាមស័ព្ទដទៃទៀតក៏មានដំណើរបំបែកដូច្នេះដែរ ។*

## វិធីប្រែនាមស័ព្ទបំបែករួចហើយ

*នាមស័ព្ទនីមួយ ៗ ដែលបំបែកជាមួយវិភត្តិរួចហើយ អាចប្រែតាមឈ្មោះរបស់វិភត្តិនោះ ៗ ដោយប្រើពាក្យប្រែឬអាយតនិបាតពីខាងដើម ដូចមានគំរូប្រែ* **បុរិស** *ខាងក្រោមនេះ*

## ឯកវចនៈ

| *វិភត្តិ* | *ឯកវចនៈ* | *ពាក្យប្រែ* |
|---|---|---|
| *ប.* | បុរិសោ | *រីបុរស ។* |
| *ទុ.* | បុរិសំ | *នូវបុរស, ... ។* |
| *ត.* | បុរិសេន | *ដោយបុរស, ... ។* |
| *ច.* | បុរិសស្ស, -សាយ, -សត្ថំ | *ដល់បុរស, ... ។* |
| *បញ្ច.* | បុរិសស្មា, បុរិសម្ហា, បុរិសា | *អំពីបុរស, ... ។* |
| *ឆ.* | បុរិសស្ស | *នៃបុរស, ... ។* |
| *ស.* | បុរិសស្មឹ, បុរិសម្හិ, បុរិសេ | *ក្នុងបុរស, ... ។* |
| *អា.* | បុរិស | *នៃបុរស, ... ។* |

## ពហុវចនៈ

| *វិភត្តិ* | *ពហុវចនៈ* | *ពាក្យប្រែ* |
|---|---|---|
| *ប.* | បុរិសា | *រីបុរស.ទ. ។* |
| *ទុ.* | បុរិសេ | *នូវបុរស.ទ., ... ។* |
| *ត.* | បុរិសេហិ, បុរិសេភិ | *ដោយបុរស.ទ., ... ។* |
| *ច.* | បុរិសានំ | *ដល់បុរស.ទ., ... ។* |
| *បញ្ច.* | បុរិសេហិ, បុរិសេភិ | *អំពីបុរស.ទ., ... ។* |
| *ឆ.* | បុរិសានំ | *នៃបុរស.ទ., ... ។* |

| | | |
|---|---|---|
| *ស.* | **បុរិសេសុ** | *ក្នុងបុរស.ទ., ... ។* |
| *អា.* | **បុរិសា** | *នៃបុរស.ទ., ... ។* |

## កំណត់សម្គាល់

*វិភត្តិនីមួយ ៗ មានពាក្យប្រែច្រើនយ៉ាង ដូច្នេះត្រូវលើកយកពាក្យប្រែ ឬ អាយតនិបាតណាមួយមកប្រើឱ្យត្រូវតាមសេចក្ដីរបស់ប្រយោគនោះ ៗ ។ នាមស័ព្ទឯទៀត ៗ ក៏មានគតិដូចគ្នាដែរ ។ ខាងក្រោមនេះជានាមស័ព្ទខ្លះនៃពួក អ ការន្តបុំលិង្គ ។*

## នាមស័ព្ទ អ ការន្តបុំលិង្គ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| **ពុទ្ធ** | *ព្រះពុទ្ធ* | **ហត្ថ** | *ដៃ* |
| **ធម្ម** | *ព្រះធម៌* | **សុកណ** | *សត្វស្លាប, បក្សី* |
| **សង្ឃ** | *ក្រុម, សង្ឃ* | **ជន** | *ជន* |
| **សាវក** | *សាវ័ក* | **វេជ្ជ** | *គ្រូពេទ្យ* |
| **កេស** | *សក់* | **វាណិជ** | *ឈ្មួញ, ពាណិជករ* |
| **លោម** | *រោម* | **គាម** | *ស្រុក, ភូមិ* |
| **ឆវ** | *ក្របក* | **រុក្ខ** | *ដើមឈើ* |

| | | | |
|---|---|---|---|
| ឆន្ទ | ឆន្ទៈ | បព្វត | ភ្នំ, បព្វតា |
| តច | ស្បែក | រថ | រទេះ, រថ |
| មំស | សាច់ | អស្ស | សេះ |
| មនុស្ស | មនុស្ស | បុគ្គល | បុគ្គល |
| បាទ | ជើង, បាទ | វាត | ខ្យល់, វាយោ |
| ទារក | ក្មេងប្រុស, ទារក | ឱទន | បាយ |
| បត្ត | បាត្រ | កុមារ | ក្មេងប្រុស |
| គារវ | សេចក្តីគោរព | គន្ធ | ក្លិន |
| បសាទ | សេចក្តីជ្រះថ្លា | កាយ | កាយ |
| អាចរិយ | គ្រូ, អាចារ្យ | បុត្ត | កូនប្រុស |

## វិភត្តិសម្រេចរូបរបស់ អ ការន្តនបុំសកលិង្គ

| វិភត្តិ | ឯកវចន | ពហុវចន |
|---|---|---|
| ប. | អំ | អានិ |
| ទុ. | អំ | អានិ |
| អា. | អ | អានិ |

នាមសព្ទដែលជា អ ការន្តនបុំសកលិង្គមានវិធីបំបែកស្ទើរតែដូច

វិធីបំបែករបស់នាមបុំលិង្គទាំងអស់ គឺមានខុសតែត្រង់បឋមាវិភត្តិឯក-វចនៈនិងពហុវចនៈ និងទុតិយាវិភត្តិពហុវចនៈហើយនឹងអាលបនវិភត្តិពហុវចនៈប៉ុណ្ណោះ ។

ចាប់ពីតតិយាវិភត្តិរហូតដល់សត្តមីវិភត្តិទាំងឯកវចនៈនិងពហុវចនៈហើយនឹងអាលបនៈខាងឯកវចនៈបំបែកដូច អ ការន្តបុំលិង្គទាំងអស់ ។

ចូរមើលវិធីបំបែក កុល ខាងក្រោមនេះ

## វិធីបំបែក កុល (ត្រកូល)

## អ ការន្តនបុំសកលិង្គ

| វិភត្តិ | ឯកវចន | ពហុវចន |
|---|---|---|
| ប. | កុលំ | កុលានិ |
| ទុ. | កុលំ | កុលានិ |
| ត. | កុលេន | កុលេហិ, កុលេភិ |
| ច. | កុលស្ស, កុលាយ, កុលត្ថំ | កុលានំ |
| បញ្ច. | កុលស្មា, កុលម្ហា, កុលា | កុលេហិ, កុលេភិ |
| ឆ. | កុលស្ស | កុលានំ |
| ស. | កុលស្មឹ, កុលម្ហិ, កុលេ | កុលេសុ |
| អា. | កុល | កុលានិ |

# នាមស័ព្ទ អ ការន្តនបុំសកលិង្គ

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អក្ខរ* | អក្សរ, អក្ខរៈ | ទិវស* | ថ្ងៃ |
| អគារ* | រោង, ផ្ទះ | កម្ម | អំពើ, ការងារ |
| ឧទក | ទឹក | យាន | គ្រឿងជិះ, យាន |
| សីល | សីល | អង្គ | ខ្លួន, អង្គ |
| ឃរ* | ផ្ទះ | សំវច្ឆរ* | ឆ្នាំ |
| ជល | ទឹក | ចក្ក | កង់, ចក្រ |
| អារម្មណ | អារម្មណ៍ | ផល | ផ្លែឈើ, ផល |
| បណ្ណ | សៀវភៅ, ស្លឹក | ភត្ត | បាយ, ភត្ត |
| ឥណ | បំណុល | មាស* | ខែ |
| តេល | ប្រេង | បុប្ផ | ផ្កាឈើ, បុប្ផា |
| គន្ធ | ក្លិន | កមល | ផ្កាឈូក |
| វចន | ពាក្យ, សម្ដី | ធន | ទ្រព្យ, ធន |
| បទុម | ផ្កាឈូក | ពល | កម្លាំង, ពល |
| ឱឃ* | អន្លង់ទឹក | អណ្ឌ | ស៊ុត, ពងសត្វ |
| ញាណ | សេចក្ដីដឹង | អទ្ធាន | ផ្លូវឆ្ងាយ |

ពាក្យណាមានសញ្ញានេះ (*) អាចប្រព្រឹត្តទៅបាន ២ លិង្គគឺ

បុំលិង្គផងនិងនបុំសកលិង្គផង ។

## វាក្យាង្គ (Phrase)

កាលបើចេះបំបែកនាមស័ព្ទហើយ យើងអាចយកនាមស័ព្ទនោះ ៗ ទៅរៀងជា **វាក្យាង្គ** (Phrase) គឺកន្សោមពាក្យដែលមិនទាន់មានកិរិយាស័ព្ទនៅឡើយ ។ ឃ្លារបៀបនេះចាំបាច់ត្រូវមាន ២ ស័ព្ទនិង ២ វិភត្តិឡើងទៅដូចមានវិធីរៀងនិងវិធីប្រែខាងក្រោមនេះ

១. **បទបឋមាវិភត្តិ** ជាបទប្រធាន រៀងទី ២ ប្រែទី ១ ។
២. **បទឆដ្ឋី ឬ សត្តមីវិភត្តិ** ជាបទវិសេសនៈ រៀងទី ១ ប្រែទី ២ ។

| | | |
|---|---|---|
| ១. | ពុទ្ធស្ស សាវកោ | វីសាវ័ករបស់ព្រះពុទ្ធ ។ |
| ២. | ធម្មេ បសាទោ | វីសេចក្តីជ្រះថ្លាក្នុងព្រះធម៌ ។ |
| ៣. | សិស្សានំ សង្ឃោ | វីពួកនៃសិស្សទាំងឡាយ ។ |
| ៤. | ឧទកេ បទុមានិ | វីផ្កាឈូកទាំងឡាយក្នុងទឹក ។ |
| ៥. | មនុស្សានំ ធនានិ | វីទ្រព្យទាំងឡាយរបស់មនុស្ស.ទ. ។ |
| ៦. | រុក្ខស្មឹ សកុណា | វីសត្វស្លាបទាំងឡាយលើដើមឈើ ។ |
| ៧. | រុក្ខានំ បណ្ណានិ | វីស្លឹកទាំងឡាយរបស់ដើមឈើ.ទ. ។ |
| ៨. | វានរស្ស លោមា | វីរោមទាំងឡាយរបស់ស្វា ។ |
| ៩. | បព្វតស្មឹ អស្សោ | វីសេះលើភ្នំ ។ |
| ១០. | វាណិជស្ស ឃរានិ | វីផ្ទះទាំងឡាយរបស់ពាណិជ ។ |

## វិធីប្រើនិងប្រែនាមនាមបំបែករួចហើយ

*ដោយហេតុតែនាមនីមួយ ៗ បំបែកបានច្រើនវិភត្តិដូចនៅខាងលើ ដូច្នេះរបៀបប្រើក្នុងប្រយោគក៏មានច្រើនយ៉ាងដែរ ។ ខាងក្រោមនេះជាឧទាហរណ៍នៃកាប្រើដោយសង្ខេប (ចំពោះវិធីប្រើពិស្តារមានអធិប្បាយនៅខាងចុងក្នុងភាគទី ២ នៃសៀវភៅនេះ) ។*

**១. បឋមាវិភត្តិ កត្តុការក** (Nominative case)

*១.១ ប្រើជា* **បទប្រធាន** (Subject) *របស់កិរិយាស័ព្ទដូចជា*

**<u>បុរិសោ</u> គច្ឆតិ** ។ *វី<u>បុរស</u> រមែងទៅ ។*

**ពុទ្ធោ <u>ធម្មោ</u> ទេសីយតេ** ។ *<u>វីធម៌</u> គឺព្រះពុទ្ធ រមែងសំដែង ។*

*១.២ ប្រើជា* **វិកតិកត្តា** (Subjective Complement) *(មានអធិប្បាយនៅខាងមុខ)ដូចជា*

**ឃសោ <u>ទារកោ</u> ហោតិ** ។ *នុ៎ះ <u>ជាក្មេងប្រុស</u> ។*

**២. ទុតិយាវិភត្តិ កម្មការក** (Accusative case)

*២.១ ប្រើជា* **កម្មបទ** (Object) *របស់កិរិយាស័ព្ទដូចជា*

**អហំ <u>លេខនំ</u> លិខាមិ** ។ *ខ្ញុំ កំពុងសរសេរ <u>នូវសំបុត្រ</u> ។*

*២.២ ប្រើប្រាប់រយៈពេលឬទិសដៅ* (Adverb or object) *ដូចជា*

**ឥធ សោ <u>តេមាសំ</u> វសិ** ។ *គេ នៅ ក្នុងទីនេះ <u>អស់បីខែ</u> ។*

**សោ <u>គាមំ</u> គច្ឆតិ** ។ *គេ កំពុងទៅ <u>កាន់ស្រុក</u> ។*

**៣. តតិយាវិភត្តិ ករណការក** (Instrumental case)

*ប្រើប្រាប់អំពីវិធីឬឧបករណ៍* (Instrument) *ដែលត្រូវគេប្រើប្រាស់ក្នុងការងារដូចជា*

**ហត្ថេន កម្មំ ករោតិ ។** *គេ រមែងធ្វើ នូវការងារ ដោយដៃ ។*

**ចក្ខុនា បស្សាម ។** *យើង ឃើញ ដោយភ្នែក ។*

**ញាណេន សុខំ ភវតិ ។** *គេ រមែងសោយ សេចក្ដីសុខ ដោយញាណ ។*

**៤. ចតុត្ថីវិភត្តិ សម្បទានការក** (Dative case)

*ប្រើប្រាប់ថាជាអ្នកទទួលការឱ្យឬការទំនុកបំរុងចំពោះ* (Indirect Object) *ដូចជា*

**យាចកស្ស ទានំ ទេតិ ។** *គេ កំពុងឱ្យ នូវទាន ដល់ស្មូម ។*

**សត្ថា ភិក្ខូនំ ធម្មំ ទេសេតិ ។** *ព្រះសាស្ដា កំពុងសំដែង នូវធម៌ ដល់ភិក្ខុ.ទ. ។*

**សោ តស្ស លេខនំ បហិណាតិ ។** *គេ តែងផ្ញើ នូវសំបុត្រ ដល់គាត់ នោះ ។*

**៥. បញ្ចមីវិភត្តិ អបាទានការក** (Ablative case)

*ប្រើប្រាប់អំពីវត្ថុឬអ្វីមួយដែលឃ្លាតចាកទីដូចជា*

**រុក្ខស្មា ផលានិ បតន្តិ ។** *ផ្លែឈើ.ទ. ជ្រុះ ចាកដើមឈើ ។*

សិស្សា <u>អាចរិយា</u> បណ្ណាការំ លភន្តិ ។ *សិស្ស.ទ. ទទួល នូវអំណោយ អំ<u>ពីគ្រូ</u> ។*

៦. ឆដ្ឋីវិភត្តិ សាមីការក (Genitive case)

*ប្រើប្រាប់ថាជាម្ចាស់នៃវត្ថុដូចជា*

<u>ពុទ្ធស្ស</u> ធម្មោ ។ *វិធម៌ <u>របស់ព្រះពុទ្ធ</u> ។*

<u>រុក្ខស្ស</u> ឆាយា ។ *វិម្លប់ <u>នៃដើមឈើ</u> ។*

៧. សត្តមីវិភត្តិ អធិករណការក (Locative case)

*ប្រើប្រាប់ទីតាំងឬកន្លែងដូចជា*

មនុស្សា <u>ឃរេសុ</u> វសន្តិ ។ *មនុស្ស.ទ. រមែងនៅ <u>ក្នុងផ្ទះ.ទ.</u> ។*

<u>ថាលិយំ</u> ឱទនំ បចតិ ។ *គេ កំពុងចំអិន នូវបាយ <u>ក្នុងឆ្នាំង</u> ។*

៨. អាលបនវិភត្តិ អាលបនការក (Vocative case)

*ប្រើសម្រាប់ហៅរកគ្នាដូចជា*

<u>បុត្ត</u> ឥធាគច្ឆ! *<u>នែកូនប្រុស</u> (អ្នក) ចូរមកនេះ!*

ធម្មំ តេ <u>ភិក្ខវេ</u> ទេសិស្សាមិ ។ *<u>ម្នាលភិក្ខុ.ទ.</u> វិតថាគត នឹងសំដែង នូវធម៌ ដល់អ្នក.ទ. ។*

## លំហាត់នៃមេរៀនទី ២

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

១. ពាក្យក្នុងភាសាបាលីចែកជា ៦ ប្រភេទ គឺអ្វីខ្លះ ?

២. នាមសព្ទមាន ៣ យ៉ាង គឺអ្វីខ្លះ ?

៣. **នាមនាម** មាន ២ យ៉ាង គឺអ្វីខ្លះ ?

៤. តើពាក្យថា **ការន្ត** ជាអ្វី ? មានប៉ុន្មាន ? គឺអ្វីខ្លះ ?

៥. តើ **លិង្គ** មានប៉ុន្មានយ៉ាង គឺលិង្គអ្វីខ្លះ ?

៦. តើ **បុំលិង្គនាម** មានប៉ុន្មានការន្ត ? គឺអ្វីខ្លះ ?

៧. តើ **ឥត្ថីលិង្គនាម** មានប៉ុន្មានការន្ត ? គឺអ្វីខ្លះ ?

៨. តើ **នបុំសកលិង្គនាម** មានប៉ុន្មានការន្ត ? គឺអ្វីខ្លះ ?

៩. ក្នុងវេយ្យាករណ៍តើពាក្យថា **វចន** ជាអ្វី ? មាន ២ គឺអ្វីខ្លះ ?

១០. វិភត្តិមាន ១៦ តួ គឺអ្វីខ្លះ ?

១១. វិភត្តិទាំងអស់មាន ៨ យ៉ាង តើមានឈ្មោះហៅដូចម្តេចខ្លះ ?

១២. តើ **បឋមាវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៣. តើ **ទុតិយាវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៤. តើ **តតិយាវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៥. តើ **ចតុត្ថីវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៦. តើ **បញ្ចមីវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៧. តើ **ឆដ្ឋីវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៨. តើ **សត្តមីវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

១៩. តើ **អាលបនវិភត្តិ** មានអាយតនិបាតឬពាក្យប្រែថាដូចម្តេចខ្លះ ?

២០. ប្រសិនបើជា ពហុវចន តើត្រូវថែមពាក្យថាដូចម្ដេច ?

## ខ. ចូររៀនបំបែកនាមសព្ទខាងក្រោមនេះជាមួយនឹងវិភត្តិនានា

១. ពុទ្ធ ២. ធាន ៣. សីល ៤. រុក្ខ ៥. បុប្ផ
៦. កុមារ ៦. សិស្ស ៨. ឧទក ៩. សកុណ ១០. កម្ម

## គ. ចូរប្រែវាក្យាផ្សេងខាងក្រោមនេះជាភាសាខ្មែរ

១. ពុទ្ធស្ស សារកោ ។ ២. សារកានំ សង្ឃោ ។
៣. បុប្ផានំ គន្ធោ ។ ៤. រុក្ខេ សកុណា ។
៥. មនុស្សានំ ឧទ្ធា ។ ៦. វានរស្ស លោមា ។
៧. ពុទ្ធស្ស ធម្មោ ។ ៨. ឧទកោ បទុមានិ ។
៩. ធម្មេ បសាទោ ។ ១០ ហត្ថេសុ បណ្ណានិ ។

(ចប់មេរៀនទី ២)

# មេរៀនទី ៣

## អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត)

*កិរិយាស័ព្ទជាស័ព្ទប្រាប់ អំពើ ឬ សភាវៈ ។ មនុស្សសត្វនិងអ្វី ៗ ទាំងពួងក្នុងលោកតែងមានអាកប្បកិរិយាយ៉ាងណាមួយមិនខានឡើយ, មនុស្សនិងសត្វត្រូវការ ដេក, ដើរ, ឈរ, អង្គុយ, ស៊ី, ផឹក, គិត, នឹក, ចង់ ជាដើម, ពាក្យថា ដេក, ដើរ, ឈរ, អង្គុយ ជាដើមហៅថា កិរិយាស័ព្ទ ។*

*កិរិយាស័ព្ទក្នុងភាសាបាលីមាន ៣ ប្រភេទគឺ* **អាខ្យាតកិរិយា, អព្យយកិរិយា** *និង* **កិតកិរិយា** *។*

*តទៅនេះនឹងអធិប្បាយពីអាខ្យាតកិរិយាមុនគេ ។ បណ្តាកិរិយា-ស័ព្ទទាំង ៣ យ៉ាងខាងលើនេះចាំបាច់ត្រូវសម្រេចមកពី* **ធាតុ**, **បច្ច័យ**, **វិភត្តិ** *(វៀរតែអព្យយកិរិយាដែលមិនមានចុះវិភត្តិ) ។*

## អាខ្យាតកិរិយា (Finite verb)

*គ្រឿងសំខាន់ ៗ សម្រាប់ប្រកបរូបឱ្យទៅជាអាខ្យាតកិរិយាមាន ៣ យ៉ាងគឺ*

*១.* **ធាតុ** (Roots) *ជាមូលស័ព្ទឬជាឫសគល់របស់ពាក្យមានដូចជា* **បច**, **គម**, **ភូ** *ជាដើម ។*

*២.* **បច្ច័យ** (Suffixes) *ជាគ្រឿងសម្រាប់ចុះនៅខាងចុងនៃធាតុមានដូចជា* **អ**, **ឯ**, **យ** *ជាដើម ។*

៣. **វិភត្តិអាខ្យាត** (Personal endings) ជាគ្រឿងសម្រាប់ចុះបន្តពីបច្ច័យ ដើម្បីចែក មានដូចជា **តិ**, **អន្តិ** ជាដើម ។

## ១. ធាតុ (Roots)

ជាតុក្នុងភាសាបាលីដោយពិស្ដារចែកជា ៨ ពួកដូចខាងក្រោមនេះ

១. ពួក **ភូ** ធាតុ ឬ **ភ្វាទិគណ** (First conjugation)
២. ពួក **រុធ** ធាតុ ឬ **រុធាទិគណ** (Second conjugation)
៣. ពួក **ទិវ** ធាតុ ឬ **ទិវាទិគណ** (Third conjugation)
៤. ពួក **សុ** ធាតុ ឬ **ស្វាទិគណ** (Forth conjugation)
៥. ពួក **កី** ធាតុ ឬ **កិយាទិគណ** (Fifth conjugation)
៦. ពួក **គហ** ធាតុ ឬ **គហាទិគណ** (Sixth conjugation)
៧. ពួក **តន** ធាតុ ឬ **តនាទិគណ** (Seventh conjugation)
៨. ពួក **ចុរ** ធាតុ ឬ **ចុរាទិគណ** (Eighth conjugation)

ធាតុទាំង ៨ ពួកនេះមាន ៣ ប្រភេទគឺ **សកម្មធាតុ** (Transitive roots) និង **អកម្មធាតុ** (Intransitive roots) និង **ទ្វិកម្មធាតុ** (Di-transitive roots) ។

១. **សកម្មធាតុ** (Transitive roots) ជាពួកធាតុដែលហៅរក **កម្ម-**

**បទ**(Object) គឺពួកនាមស័ព្ទដែលបំបែកជាទុតិយាវិភត្តិកម្មការកៈ ដើម្បីបំពេញសេចក្ដីឱ្យពេញលេញនិងស្ដាប់បានដូចក្នុងភាសាខ្មែរថា "ពូសុខពិសារបាយ" ។ ពាក្យថា "បាយ" ជាកម្មបទរបស់កិរិយាស័ព្ទថា "ពិសារ" បើគ្មានពាក្យថា **បាយ** ទេ ឃើញថាមានសេចក្ដីមិនទាន់គ្រប់គ្រាន់ ។

២. **អកម្មធាតុ** (Intransitive roots) ជាពួកធាតុដែលមិនត្រូវការកម្មបទមកបំពេញទេដូចក្នុងភាសាខ្មែរថា "ក្មេងប្រុសនោះយំ" ត្រឹមតែប៉ុណ្ណោះស្ដាប់បានសេចក្ដីពេញលេញហើយ ។

៣. **ទ្វិកម្មធាតុ** (Ditransitive roots) ជាពួកធាតុដែលត្រូវការកម្មបទមកបំពេញចំនួន ២ ដូចក្នុងប្រយោគថា "**អជបាលោ អជំ គាមំ នេតិ**" អ្នកឃ្វាលពពែកំពុងនាំទៅនូវពពែកាន់ភូមិ ។ ពាក្យថា "**អជំ**=ពពែ" ក្នុងទីនេះជា **កម្មបទផ្ទាល់** ឬ **បធានកម្ម** (Direct object) រងអំពើពីអ្នកឃ្វាលផ្ទាល់ ។ រីឯពាក្យថា "**គាមំ**=ភូមិ" ជាកម្មបទដែរ ប៉ុន្តែមិនផ្ទាល់ទេ ខាងវេយ្យាករណ៍ហៅថា **អបធានកម្ម** (Indirect object) ។

## ២. បច្ច័យរបស់អាខ្យាត (Suffixes)

បច្ច័យ គឺជាគ្រឿងសម្រាប់ចុះនៅខាងចុងធាតុដើម្បីប្រែធាតុនោះ ៗ ឱ្យទៅជាកិរិយាស័ព្ទនិងប្រាប់ឱ្យដឹងថាជាវាចកៈអ្វីផង ។

បច្ច័យមានច្រើនតួ ប៉ុន្តែដែលប្រើក្នុងអាខ្យាតកិរិយាមាន ២៥ តួគឺ **អ, ឯ, ឡ, ឃ, យ, ណុ, ណា, ឧណា, ណ, ណោ, ណាយ, ណាបេ,**

ណាបយ, ណ្ហា, ឱ, យិរ, ខ, ឯ, ស, ឞ, អាយ, ឡៀយ, អល, អារ, អាល ។

បច្ច័យទាំងឡាយនេះមានប្រើញឹកញាប់តែ ១០ តួទេគឺ អ, ឯ, យ, ណុ, ណា, ឯា, ណ្ហា, ឱ, ណេ, ណាយ ដែលបែកឱ្យធាតុទាំង ៨ ពួក ដូចខាងក្រោមនេះ

| | | | | |
|---|---|---|---|---|
| ១. | ពួក ភូ ធាតុ | មានបច្ច័យ | ១ តួគឺ | អ ។ |
| ២. | ពួក រុធ ធាតុ | មានបច្ច័យ | ២ តួគឺ | អ ។ |
| ៣. | ពួក ទិវ ធាតុ | មានបច្ច័យ | ១ តួគឺ | យ ។ |
| ៤. | ពួក សុ ធាតុ | មានបច្ច័យ | ២ តួគឺ | ណា, ណុ ។ |
| ៥. | ពួក កី ធាតុ | មានបច្ច័យ | ១ តួគឺ | ឯា ។ |
| ៦. | ពួក គហ ធាតុ | មានបច្ច័យ | ១ តួគឺ | ណ្ហា ។ |
| ៧. | ពួក តន ធាតុ | មានបច្ច័យ | ១ តួគឺ | ឱ ។ |
| ៨. | ពួក ចុរ ធាតុ | មានបច្ច័យ | ២ តួគឺ | ណេ, ណាយ ។ |

បច្ច័យទាំង ១០ តួនេះសម្រាប់ចុះក្នុងកត្តុវាចកៈដែលនឹងអធិប្បាយជាបន្តបន្ទាប់នៅខាងមុខ ។

## ៣. វិភត្តិអាខ្យាត (Personal endings)

វិភត្តិមាន ២ យ៉ាងគឺ វិភត្តិនាម (បានអធិប្បាយហើយក្នុងមេរៀនទី ២) និង **វិភត្តិអាខ្យាត** ។ វិភត្តិអាខ្យាតជាគ្រឿងសម្រាប់ចុះក្នុងធាតុ

ដែលប្រកបបច្ច័យរួចហើយនិងដើម្បីប្រាប់ឱ្យដឹង បុរិសៈ, វចនៈ, កាល, បទ ។ វិភត្តិអាខ្យាតមាន ៨ ពួកដូចមានឈ្មោះហៅខាងក្រោមនេះ

| | |
|---|---|
| ១. វត្តមានាវិភត្តិ | ២. បញ្ចមីវិភត្តិ |
| ៣. សត្តមីវិភត្តិ | ៤. ហីយត្តនីវិភត្តិ |
| ៥. អជ្ជតនីវិភត្តិ | ៦. បរោក្ខាវិភត្តិ |
| ៧. ភវិស្សន្តិវិភត្តិ | ៨. កាលាតិបត្តិវិភត្តិ |

ក្នុងទីនេះសូមលើកយកវត្តមានាវិភត្តិមកបង្ហាញមុន ។

## (១). វត្តមានាវិភត្តិ

(Present Tense endings)

| បរស្សបទ | | | អត្តនោបទ | | |
|---|---|---|---|---|---|
| បុរិសៈ | ឯកវចនៈ | ពហុវចនៈ | បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| ប.បុ. | តិ | អន្តិ | ប.បុ. | តេ | អន្តេ |
| ម.បុ. | សិ | ថ | ម.បុ. | សេ | វ្ហេ |
| ឧ.បុ. | មិ | ម | ឧ.បុ. | ឯ | ម្ហេ |

វត្តមានាវិភត្តិប្រើប្រាប់នូវអំពើណាមួយដែលកំពុងតែកើតក្នុងពេលបច្ចុប្បន្ន, អំពើណាមួយកំពុងប្រព្រឹត្តទៅនិងអ្វី ៗ ដែលជាភាវៈពិតដូចជា សព្វេ សត្តា មរន្តិ (សត្វទាំងឡាយ ទាំងពួង រមែងស្លាប់) ជាដើម ។

## ៣.១ បុរិស: (Persons)

**បុរិស** ប្រែថា "បុរស, ប្រុស" ជាអ្នកដែលមានទំនាក់ទំនងក្នុងការនិយាយសន្ទនាគ្នាចែកចេញជា ៣ បុរិស:គឺ **បឋមបុរិស**, **មជ្ឈិមបុរិស** និង **ឧត្តមបុរិស** ។ បុរិស:ទាំង ៣ យ៉ាងនេះត្រូវតែប្រើកិរិយាដែលប្រកបវិភត្តិឱ្យស្មើគ្នា មានឧទាហរណ៍នៅខាងមុខ ។

១. **បឋមបុរិស** (ប.បុ.) (ត្រូវនឹងអង់គ្លេសថា Third person) បានដល់អ្នកដែលបុរសទី ១ និងបុរសទី ២ និយាយអំពីខ្លួន ដូចជាពាក្យថា "ពូសុខ, តាម៉ៅ, គាត់, វា" ជាដើម ជាអ្នកនៅក្រៅការសន្ទនា ។

២. **មជ្ឈិមបុរិស** (ម.បុ.) (ត្រូវនឹងអង់គ្លេសថា Second person) បានដល់អ្នកដែលកំពុងស្ដាប់បុរសទី ១ និយាយដូចជាពាក្យថា "លោក, អ្នក, ឯង, នាង, ព្រះអង្គ" ជាដើម ជាអ្នកកំពុងចូលរួមធ្វើការសន្ទនា ។

៣. **ឧត្តមបុរិស** (ឧ.បុ.) (ត្រូវនឹងអង់គ្លេសថា First person) បានដល់អ្នកដែលកំពុងនិយាយដោយខ្លួនឯង ដូចជាពាក្យថា "ខ្ញុំ, ខ្ញុំបាទ, ខ្ញុំព្រះករុណា, អាត្មា, អញ, យើង" ជាដើម ។

## ៣.២ វចនៈរបស់កិរិយាស័ព្ទ (Numbers)

**វចន** មាន ២ យ៉ាងដូចវចនៈរបស់នាមស័ព្ទដែរគឺ ឯកវចនៈ និងពហុវចនៈ ។ វចនៈនេះបានពោលរួចម្ដងហើយក្នុងមេរៀនទី ២ ។ សូម

រកមើលថែមទៀតផងដើម្បីឱ្យបានយល់ច្បាស់ ។

## ៣.៣ បទ

**បទ** ជាចំណែករបស់វិភត្តិទាំង ៨ ពួកដែលក្នុងមួយពួក ៗ មាន ២ បទគឺ **បរស្សបទ** និង **អត្តនោបទ** ។ បទទាំងពីរនេះប្រើសម្រាប់ប្រាប់ឱ្យដឹងនូវវាចកៈដែលមានអធិប្បាយនៅខាងមុខ ។

១. **បរស្សបទ** (Active) ប្រែថា បទដើម្បីអ្នកដទៃ ។

២. **អត្តនោបទ** (Reflexive) ប្រែថា បទដើម្បីខ្លួនឯង ។

១. **បរស្សបទ** (Active) ប្រែថា បទដើម្បីអ្នកដទៃ ក្នុងសេចក្តីថា បទប្រធានក្នុងប្រយោគប្រព្រឹត្តអំពើទៅលើអ្នកដទៃដូចជា **មាតា បុត្តំ បហរតិ** (ម្តាយ វាយ កូន) ។ ប្រយោគនេះសឱ្យឃើញថា **មាតា**=ម្តាយដែលជាបទប្រធានរបស់កិរិយាសព្ទ **បហរតិ**=វាយ គឺម្តាយសាងអំពើទៅលើ **បុត្តំ**=កូន ។

២. **អត្តនោបទ** (Reflexive) ប្រែថា បទដើម្បីខ្លួនឯង ក្នុងសេចក្តីថា បទប្រធានរបស់ប្រយោគទទួលរងនូវអំពើពីអ្នកដទៃ ដូចជា **បុត្តោ មាតរា បហរីយតេ** (កូន ត្រូវម្តាយ វាយ) ។ ប្រយោគនេះសឱ្យឃើញថា **បុត្តោ**=កូន ដែលជាបទប្រធាននៃកិរិយាសព្ទ **បហរីយតេ**=វាយទទួលរងនូវអំពើពីម្តាយដែលសាងទៅវិញ ។

## ៣.៤ កាល (Tenses)

**កាល** ជាគ្រឿងប្រាប់ឱ្យដឹងថាអំពើនោះ ៗ ប្រព្រឹត្តឡើងក្នុងពេលណា ពីព្រោះអំពើខ្លះកើតមាននៅចំពោះមុខ អំពើខ្លះកើតមានរួចហើយ និងអំពើខ្លះទៀតនឹងកើតមាននាពេលខាងមុខ ។ កាលរបស់អាខ្យាតកិរិយានេះចែកជាកាលធំ ៗ ៣ គឺ **បច្ចុប្បន្នកាល**, **អតីតកាល** និង **អនាគតកាល** ។

### ១. បច្ចុប្បន្នកាល (Present tense)

បច្ចុប្បន្នកាលជាកាលដែលប្រាប់ថាអំពើនោះ ៗ កំពុងតែកើតមាននៅចំពោះមុខឬនឹងកើតមាននៅពេលឆាប់ ៗ ខាងមុខ ។

### ២. អតីតកាល (Past tense)

អតីតកាលជាកាលដែលប្រាប់ថាអំពើនោះ ៗ បានកើតមានរួចហើយ ។

### ៣. អនាគតកាល (Future tense)

អនាគតកាលជាកាលដែលប្រាប់ថាអំពើនោះ ៗ នឹងកើតមានក្នុងកាលខាងមុខ ។

កាលធំ ៗ ទាំងបីខាងលើនេះ លោកបានចែកទៅជាកាលតូច ៗ ថែមទៀតគឺ

១. **បច្ចុប្បន្នកាល** *ចែកជា ៣ គឺ* **សុទ្ធបច្ចុប្បន្នកាល, អតីតបច្ចុប្បន្នកាល** *និង* **អនាគតបច្ចុប្បន្នកាល** ។

២. **អតីតកាល** *ចែកជា ៣ គឺ* **អប្បច្ចក្ខាតីតកាល, ហីយោបក្ខត្យាតីតកាល** *និង* **អជ្ជបក្ខត្យាតីតកាល** ។

៣. **អនាគតកាល** *ចែកជា ២ គឺ* **បច្ចុប្បន្នាគតកាល** *និង* **អតីតានាគតកាល** ។

## ៤. អនុត្តកាល (Imperative tense)

*មានកាលមួយទៀតមិនប្រាប់ឱ្យដឹងថាជា បច្ចុប្បន្នកាល, អតីតកាល ឬ អនាគតកាលទេ ហៅថា* **អនុត្តកាល** *ចែកជា ៤ យ៉ាងគឺ* **អាណត្តិ, អាសិដ្ឋ, អនុមត្តិ** *និង* **បរិកប្ប** *។*

## កិរិយានុគ្រោះ (Auxiliary verbs)

*កិរិយានុគ្រោះ (ក្នុងភាសាខ្មែរច្រើនជានិបាតស័ព្ទ) បានដល់ស័ព្ទសម្រាប់ប្រើនិយាយខាងដើមឬខាងក្រោយកិរិយាស័ព្ទ ដើម្បីប្រាប់ឱ្យដឹងកាលនោះ ៗ ។ ក្នុងភាសាបាលីជាពាក្យប្រែរបស់កាលនីមួយ ៗ ។ កិរិយានុគ្រោះទាំងនោះចែកក្នុងកាលទាំងឡាយដូចនៅខាងក្រោមនេះ*

### ១. បច្ចុប្បន្នកាល

**សុទ្ធបច្ចុប្បន្នកាល** *ឬ បច្ចុប្បន្នសុទ្ធ* មាន **កិរិយានុគ្រោះ** *ប្រែថា កំពុង..., កំពុងតែ...* ។

**អតីតបច្ចុប្បន្នកាល** *ឬ បច្ចុប្បន្នជិតអតីត* មាន **កិរិយានុគ្រោះ** *ប្រែថា ទើប..., ទើបនឹង..., ...ហើយ* ។

**អនាគតបច្ចុប្បន្នកាល** *ឬ បច្ចុប្បន្នជិតអនាគត* មាន **កិរិយានុគ្រោះ** *ប្រែថា នឹង..., រមែង..., តែងតែ..., គង់..., គង់តែ...* ។

## ២. អតីតកាល

**អប្បច្ចក្ខាតីតកាល** *ឬ អតីតកាលកន្លងមិនកំណត់* មាន **កិរិយានុគ្រោះ** *ប្រែថា ...ហើយ* ។

**ហីយោបក្ខត្យាតីតកាល** *ឬ អតីតកាលក្នុងថ្ងៃម្សិល* មាន **កិរិយានុគ្រោះ** *ប្រែថា ...ហើយ, បាន...ហើយ, ...ឡើយ* ។

**អជ្ជបក្ខត្យាតីតកាល** *ឬ អតីតកាលក្នុងថ្ងៃនេះ* មាន **កិរិយានុគ្រោះ** *ប្រែថា ...ហើយ, បាន...ហើយ* ។

## ៣. អនាគតកាល

**បច្ចុប្បន្នាគតកាល** *ឬ អនាគតរបស់បច្ចុប្បន្ន* មាន **កិរិយានុគ្រោះ** *ប្រែថា នឹង...* ។

**អតីតានាគតកាល** ឬ *អនាគតរបស់អតីត* មាន **កិរិយានុក្រោះ** *ប្រែថា នឹង...ហើយ, នឹងបាន...ហើយ ។*

## ៤. អនុត្តកាល

**អាណត្តិ** (Command) *ប្រើប្រាប់សេចក្តីបង្គាប់* មាន **កិរិយានុក្រោះ** *ប្រែថា ចូរ..., ចូរ......ចុះ ។*

**អាសិដ្ឋ** (Request) *ប្រើប្រាប់សេចក្តីប្រាថ្នា*មាន **កិរិយានុក្រោះ** *ប្រែថា ចូរ..., សូម..., សូមឱ្យ......ចុះ ។*

**អនុមត្តិ** (Potential) *ប្រើប្រាប់សេចក្តីយល់ឃើញ* មាន **កិរិយានុក្រោះ** *ប្រែថា គួរ..., គួរតែ... ។*

**បរិកប្ប** (Conditional) *ប្រើប្រាប់សេចក្តីកំណត់* មាន **កិរិយានុក្រោះ** *ប្រែថា គប្បី..., ត្រូវ... ។*

## វាចក: (Voices)

**វាចក** *ប្រែថា អ្នកពោល, អ្នកនិយាយ ។ ធាតុណាមួយដែលប្រកបដោយបច្ច័យនិងវិភត្តិរួចហើយក៏ក្លាយជាកិរិយាស័ព្ទ ដែលប្រាប់កាល, បុរិស:, វចន:, បទ នឹងប្រាប់ឱ្យដឹងថាបទប្រធានក្នុងប្រយោគជាប្រធានដូចម្តេច ហើយក៏ប្រាប់ឱ្យដឹង***វាចក:***ផងដែរ ដែលចែកចេញជា*

៥ វាចក:គឺ **កត្តុវាចក**, **កម្មវាចក**, **ភាវវាចក**, **ហេតុកត្តុវាចក** និង **ហេតុកម្មវាចក** ។

១. **កត្តុវាចក** (Active voice) បានដល់ វាចក:ណាដែលមានបទកិរិយាស័ព្ទប្រាប់ឱ្យដឹងថា បទប្រធានក្នុងប្រយោគជាអ្នកធ្វើអំពើខ្លួនឯងដូចជា **ឧបាសកោ អារាមំ គច្ឆតិ** ប្រែថា "រីឧបាសក កំពុងទៅកាន់វត្ត" ជាដើម ។ ពាក្យថា ***ឧបាសក*** ជាសយកត្តា (Subject) គឺជាអ្នកធ្វើអំពើ "ទៅ" ដោយខ្លួនឯង ។

២. **កម្មវាចក** (Passive voice) បានដល់ វាចក:ណាដែលមានបទកិរិយាស័ព្ទប្រាប់ឱ្យដឹងថា បទប្រធានក្នុងប្រយោគជាអ្នករងអំពើ ជាតួកម្ម ដូចជា **ភិក្ខុនា ភត្តំ ភុញ្ជតិ** ប្រែថា "រីបាយ គឺភិក្ខុ កំពុងឆាន់" ជាដើម ។ ពាក្យថា **បាយ** ជាតួកម្ម (Object) រងនូវអំពើ "ឆាន់" របស់ភិក្ខុ ។

៣. **ភាវវាចក** (Impersonal voice) បានដល់ វាចក:ណាដែលមានបទកិរិយាស័ព្ទប្រាប់ឱ្យដឹងត្រឹមតែភាវ:ដូចជា **បុត្តេន ភូយតេ** ប្រែថា "គឺកូន កើត" ជាដើម ។ វាចក:នេះមិនប្រាប់ថាបទប្រធានជាកត្តា ឬជាតួកម្មទេ ។

៤. **ហេតុកត្តុវាចក** (Causal active voice) បានដល់ វាចក:ណាដែលមានបទកិរិយាស័ព្ទប្រាប់ឱ្យដឹងថា បទប្រធានក្នុងប្រយោគជាអ្នកប្រើអ្នកដទៃទៀតឱ្យធ្វើនូវអំពើ ជាប្រធានដែរ ។ ប៉ុន្តែគ្រាន់តែជាហេតុ

ហៅថា **ហេតុកត្តា** (Causal subject) ដូចជា **សេដ្ឋី សូទេន ឱទនំ ចាចាបេតិ** ប្រែថា "រីសេដ្ឋី ញ៉ាំងអ្នកគ្រួ ឱ្យចម្អិន នូវបាយ" ជាដើម ។ ពាក្យថា **សេដ្ឋី** ជាតួហេតុកត្តាប្រើគេឱ្យសម្រេចនូវកិច្ច "ចម្អិន" ។

៥. **ហេតុកម្មវាចក** (Causal passive voice) បានដល់ វាចក: ណាដែលមានបទកិរិយាស័ព្ទប្រាប់ឱ្យដឹងថា បទប្រធានក្នុងប្រយោគជាអ្នករងនូវអំពើ ជាតួកម្ម ។ ប៉ុន្តែមានតួហេតុកត្តាជាអ្នកញ៉ាំងគេដទៃឱ្យធ្វើនូវកិច្ចដូចជា **ឱទនោ សេដ្ឋិនា សូទំ ចាចាបិយតេ** ប្រែថា "រីបាយ គឺសេដ្ឋី ញ៉ាំងអ្នកគ្រួ រមែងឱ្យចម្អិន" ជាដើម ។ ពាក្យថា **បាយ** ជាតួកម្ម រងអំពើ "ចម្អិន" របស់អ្នកគ្រួ ។

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

## (Verb Formation)

កាលបើបានដឹងថាអ្វីជា ធាតុ, បច្ច័យ, វិភត្តិ, បុរិស:, វចន:, កាល, បទ, វាចក:រួចហើយ យើងអាចធ្វើរូបសិទ្ធិកិរិយាស័ព្ទគឺការប្រកបរូបជាកិរិយាស័ព្ទបានហើយ ។ កាលបើមានវាចក: ៥ យ៉ាងដូចពោលខាងលើនេះ ចំពោះអាខ្យាតកិរិយាក៏មានរូប ៥ បែបដូចវាចក:ដែរ គឺមានរូបជា **កត្តុវាចក**, **កម្មវាចក**, **ភាវវាចក**, **ហេតុកត្តុវាចក**, **ហេតុកម្មវាចក** និងដែលអាចដឹងបានដោយសារបច្ច័យប្រាប់ ។ វិធី

រូបសិទ្ធិជាកិរិយាស័ព្ទនឹងមានអធិប្បាយជាបន្តបន្ទាប់ដូចតទៅនេះ ។

ការប្រកបរូបកិរិយាស័ព្ទជាកត្តុវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ

(ធាតុ + អ បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ

ឧ. **បច** (ធាតុ)=ចម្អិន + **អ** (បច្ច័យកត្តុវាចកៈ) + **តិ** ឬ **អន្តិ** (ជាវត្តមានាវិភត្តិខាងបរស្សបទ) មានវិធីផ្សំដូច្នេះ

| **ធាតុ** | + | **បច្ច័យ** | + **វិភត្តិ** | > **កិរិយាស័ព្ទ** | **ពាក្យប្រែ** |
|---|---|---|---|---|---|
| **បច** | + | អ | + **តិ** | > **បចតិ** | (គេ)កំពុងចម្អិន ។ |
| **បច** | + | អ | + **អន្តិ** | > **បចន្តិ** | (គេ.ទ.)កំពុងចម្អិន ។ |

## វិធីបំបែកធាតុពួកទី ១ (ពួក ភូ ធាតុ)

## (First conjugation)

ធាតុទាំងឡាយមានវិធីផ្សំជាមួយបច្ច័យនិងវិភត្តិនិងបំបែកតាមបុរិសៈនោះ ៗ ជាឯកវចនៈឬពហុវចនៈដូចខាងក្រោមនេះ

**បច** ធាតុប្រែថា "ចម្អិន" និង **វត្តមានាវិភត្តិ**

| **បុរិស** | **ឯកវចន** | **ពហុវចន** |
|---|---|---|
| ប.បុ. | **បចតិ** | **បចន្តិ** |
| ម.បុ. | **បចសិ** | **បចថ** |
| ឧ.បុ. | **បចាមិ** | **បចាម** |

## កំណាត់សម្គាល់

១. **អ** បច្ច័យដែលចុះជាមួយធាតុ កាលបើចុះវិភត្តិមកទៀតត្រូវលុប **អ** បច្ច័យនេះចោលជានិច្ច ដូចជា (**បច** + **អ** + **តិ**) > **បចតិ**, (**បច** + **អ** + **សិ**) > **បចសិ** ជាដើម ។

២. **តិ**, **សិ**, **ថ** វត្តមានាវិភត្តិ កាលណាចុះជាមួយធាតុដែលចុះ **អ** បច្ច័យរួចហើយត្រូវលុប **អ** បច្ច័យចោល មិនថាធាតុនោះ ៗ មានស្រៈអ្វីទេ ដូចជា (**ភា** + **អ** + **តិ**) > **ភាតិ** ប្រែថា រះ, (**ទា** + **អ** + **តិ**) > **ទេតិ** ប្រែថា ឱ្យ ។

៣. **អន្តិ** វត្តមានាវិភត្តិពហុវចនៈ កាលណាចុះជាមួយធាតុដែលចុះបច្ច័យរួចហើយ មិនថាជាបច្ច័យអ្វីទេ ចាំបាច់ត្រូវផ្លាស់ **អន្តិ** > **ន្តិ** ជានិច្ច ដូចជា (**បច** + **អ** + **អន្តិ**) > **បចន្តិ** ជាដើម ។

៤. **មិ**, **ម** វត្តមានាវិភត្តិ កាលបើចុះមកហើយ ប្រសិនបើបច្ច័យនៅខាងដើមជា **អ** ដែលលុបបាត់ទៅ ចាំបាច់ត្រូវទីឃៈស្រៈទីបំផុតធាតុជានិច្ច ដូចជា (**បច** + **អ** + **មិ**) > **បចាមិ**, (**បច** + **អ** + **ម**) > **បចាម** ។ (ធាតុឯទៀត ៗ គប្បីជ្រាបតាមសេចក្ដីនេះផងចុះ) ។

## វិធីផ្លាស់រូបរបស់ធាតុក្នុងពួក ភូ ធាតុ

១. បើទីបំផុតធាតុជាស្រៈ **អ**, **អា**, **ឯ**, **ឱ** ឬជាធាតុទោល(ជាតុមួយ

ព្យាង្គ) មិនមានឱ្យធ្វើការផ្លាស់ប្ដូរទេ ដូចជា កស > កសតិ=ភ្ជួរ, រាស់, ហរ > ហរតិ =នាំទៅ, វស > វសតិ =នៅ, ភា > ភាតិ =រះ, កេល > កេលតិ =ទៅ, ដល់, ចោស > ចោសតិ =បិញ្ចឹម ។

២. ធាតុណាមានព្យញ្ជនៈពីរតួឬតម្រួតគ្នា គឺសំយោគនៅទីបំផុត មិនមានការផ្លាស់ប្ដូរទេដូចជា រក្ខ > រក្ខតិ =រក្សា, ពន្ធ > ពន្ធតិ =ចង, បុច្ឆ > បុច្ឆតិ =សួរ, ឥក្ខ > ឥក្ខតិ =មើល, ឃើញ ។

៣. ធាតុណាមានស្រៈ ឧ, ឦ នៅខាងដើមនិងមានព្យញ្ជនៈនៅខាងចុង មិនមានធ្វើការផ្លាស់ប្ដូរទេ ដូចជា សុប > សុបតិ =ដេក, ជីវ > ជីវតិ =រស់នៅ, និសីទ > និសីទតិ =អង្គុយចុះ ។

៤. ការផ្លាស់ប្ដូរនោះគឺស្រៈ ឥ, ឦ ផ្លាស់ជា ឯ, ស្រៈ ឧ, ឩ ផ្លាស់ជា ឱ ប្រសិនបើជាធាតុទោលគ្មានព្យញ្ជនៈនៅខាងចុង ដូចជា ឥ > ឯតិ =ទៅ, ជិ > ជេតិ =ឈ្នះ, នី > នេតិ =នាំទៅ, ហុ > ហោតិ =មាន, ជា, ភូ > ភោតិ =មាន, ជា ។

៥. ជួនកាលផ្លាស់ ឯ > អយ, អាយ, ផ្លាស់ ឱ > អវ ទៀតពីព្រោះមាន អ បច្ច័យនៅខាងចុង ដូចជា (នី > នេ > នយ) + អ + តិ > នយតិ =នាំទៅ, (ភី > ភេ > ភាយ) + អ + តិ > ភាយតិ =ខ្លាច, ភ័យ, (ភូ > ភោ > ភវ) + អ + តិ > ភវតិ =មាន, (ជិ > ជេ > ជយ) + អ + តិ > ជយតិ =ឈ្នះ, (ចុ > ចោ > ចវ) + អ + តិ > ចវតិ =ច្យុត, ឃ្លាត ។

៦. ធាតុខ្លះមានវិធីផ្លាស់រូបតាមទំនើងរបស់ខ្លួនក៏មានដែរ ដូចជា

(គម > គច្ឆ) + អ + តិ > គច្ឆតិ =ទៅ, ដល់, (ឋា > តិដ្ឋ) + អ + តិ > តិដ្ឋតិ =ឈរ, តាំងនៅ, (បា > បិវ) + អ + តិ > បិវតិ =ផឹក, (ឥស > ឥច្ឆ) + អ + តិ > ឥច្ឆតិ =ចង់, ប្រាថ្នា, (ឈេ > ឈាយ) + អ + តិ > ឈាយតិ =ដុត, (ប + ហា > បជហ) + អ + តិ > បជហតិ =លះបង់, ប + វិស + អ + តិ > បវិសតិ =ចូល (មិនផ្លាស់ប្តូរទេ) ។ល។

## វិធីបំបែក អស ធាតុប្រែថា "មាន"

អស ជាធាតុដែលមានវិធីបំបែកប្លែកពីគេគ្រប់វិភត្តិទាំងអស់ ។ ខាងក្រោមនេះជាការបំបែកក្នុងរូបវត្តមានាវិភត្តិខាងបរស្សបទ ។

| បុរិស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អត្ថិ | សន្តិ |
| ម.បុ. | អសិ | អត្ថ |
| ឧ.បុ. | អម្ហិ, អស្មិ | អម្ហ, អស្ម |

អស ធាតុនេះក៏មានវិធីប្រើប្លែកពីធាតុឯទៀត ៗ ដែរ គឺនិយមប្រើនៅខាងដើមប្រយោគ ឧ. នត្ថិ មេ បរំ សុខំ ។ សេចក្ដីសុខ ដទៃសម្រាប់ខ្ញុំ មិនមាន ។ នត្ថិ < (ន + អត្ថិ) ។ មានធាតុ ៣ តួគឺ អស, ភូ, ហុ ប្រែថា "កើត, មាន, ជា" ។ ប្រសិនបើប្រើនៅក្នុងប្រយោគមានបទវិកតិកត្តាពុំចាំបាច់ប្រែចេញពាក្យថា "កើត, មាន" ទេ ត្រូវប្រែថា "ជា" ។ រឿងបទវិកតិកត្តានឹងមានអធិប្បាយនៅខាងមុខ ។

# វិធីតែងប្រយោគនិងវិធីប្រែឬាលី

ដូចបានពោលរួចហើយថា កិរិយាស័ព្ទមានរូប ៥ យ៉ាងដូចវាចកៈ ដូច្នេះប្រយោគក៏មានឈ្មោះហៅ ៥ យ៉ាងតាមវាចកៈដែរគឺ ប្រយោគ-កត្តុវាចកៈ, ប្រយោគកម្មវាចកៈ, ប្រយោគភាវវាចកៈ, ប្រយោគហេតុ-កត្តុវាចកៈ និង ប្រយោគហេតុកម្មវាចកៈ ។

ប្រយោគទាំង ៥ យ៉ាងនេះជាប្រយោគមានសេចក្ដីពេញលេញ ។ មានប្រយោគមួយពួកទៀតដែលមានសេចក្ដីមិនពេញលេញ នឹងមានអធិប្បាយនៅខាងមុខ ។

## ប្រយោគកត្តុវាចកៈ

(Active voice sentence)

ស័ព្ទសំខាន់ ៗ ដែលត្រូវមានក្នុងប្រយោគកត្តុវាចកៈមាន ២ យ៉ាង គឺ បទប្រធាន និង បទកិរិយាស័ព្ទ ។

**១. បទប្រធាន** (Subject) មានរូបជាបឋមាវិភត្តិមាននាទីជាកត្តុ-ការកៈ រៀងទី ១ ប្រែទី ១ ។

**២. បទកិរិយា** (Finite Verb) មានរូបជាអាខ្យាតកិរិយាកត្តុវាចកៈ រៀងទី ២ ប្រែទី ២ ។

# ឧទាហរណ៍

**កសកោ**១ **ចរតិ**២ ។ *ប្រែថា រីកសិករ១ កំពុងត្រាច់ទៅ២ ។*

**កុមារោ**១ **រោទតិ**២។ *ប្រែថា រីក្មេងប្រុស១ កំពុងយំ២ ។*

*តាមឧទាហរណ៍ទាំងពីរខាងលើនេះឃើញថា កិរិយាស័ព្ទជាអកម្មធាតុ គឺធាតុមិនហៅរកបទកម្មទេ ។ ប្រសិនបើជាសកម្មធាតុ គឺធាតុហៅរកបទកម្មវិញ ត្រូវថែមវិធីទៀតគឺ*

១. **បទប្រធាន** (Subject) *មានរូបជាបឋមាវិភត្តិមាននាទីជាកត្តុការកៈ រៀងទី ១ ប្រែទី ១ ។*

២. **បទកម្ម** (Object) *មានរូបជាទុតិយាវិភត្តិមាននាទីកម្មការកៈ រៀងទី ២ ប្រែទី ៣ ។*

៣. **បទកិរិយា** (Finite Verb) *មានរូបជាអាខ្យាតកិរិយាកត្តុវាចក រៀងទី ៣ ប្រែទី ២ ។*

# ឧទាហរណ៍

**សូទោ**១ **ឱទនំ**៣ **បចតិ**២។ *រីអ្នកគ្រួ១ កំពុងចម្អិន២ នូវបាយ៣ ។*

**កសកា**១ **អាហារំ**៣ **ភុញ្ជន្តិ**២។ *រីកសិករ.ទ.១ កំពុងស៊ី២ នូវអាហារ៣។*

*វិធីរៀងប្រយោគបាលីមិនកំណត់ថាត្រូវរៀងដូច្នេះជាដរាបទេ គឺអាចរៀងបាន ៤ បែបដូចខាងក្រោមនេះ*

## ឧទាហរណ៍

១. សូទោ ឱទនំ បចតិ ។ ២. បចតិ សូទោ ឱទនំ ។
៣. ឱទនំ សូទោ បចតិ ។ ៤. សូទោ បចតិ ឱទនំ ។

*ទោះបីជាមានការរៀងយ៉ាងដូចម្ដេចក៏ដោយ ក៏អត្ថន័យមិនប្រែប្រួលខុសសេចក្ដីឡើយ ពីព្រោះភាសាបាលីមានវិភត្តិជាគ្រឿងសម្គាល់ ប៉ុន្តែនិយមរៀងតាមប្រយោគលេខ ១ ។*

*ប្រសិនបើមានបទដទៃចូលមកអធិប្បាយបទនីមួយ ៗ ក្នុងឧទាហរណ៍ខាងលើនេះ ត្រូវថែមវិធីប្រែទៀតគឺ*

១. **បទប្រធាន** *មានរូបជាបឋមាវិភត្តិមាននាទីជាកត្តុការកៈ ប្រែទី ១ ។*
២. **បទវិសេសនៈ** (Modifier) *នៃបទប្រធាន មានរូបជាឆដ្ឋីវិភត្តិសាមីការកៈឬសត្តមីវិភត្តិអធិការណការកៈ ឬក៏គុណនាម ប្រែទី ២ ។*
៣. **បទកិរិយា** (Finite verb) *មានរូបជាអាខ្យាតកិរិយាកត្តុវាចកៈ ប្រែទី ៣ ។*
៤. **បទកម្ម** (Object) *មានរូបជាទុតិយាវិភត្តិកម្មការកៈ ប្រែទី ៤ ។*
៥. **បទវិសេសនៈ** (Modifier) *នៃបទកម្ម មានរូបជាតតិយាវិភត្តិករណការកៈ, ឆដ្ឋីវិភត្តិសម្ពន្ធការកៈ, សត្តមីវិភត្តិអធិករណការកៈឬគុណ-នាម ប្រែទី ៥ ។*

## ប្រយោគឧទាហរណ៍

១. <u>សាវកានំ</u>២ សង្ឃោ១ <u>ពុទ្ធស្ស</u>៥ ធម្មំ៤ ចរតិ៣។

*ពួក១ <u>នៃសាវក.ទ.</u>២ កំពុងប្រព្រឹត្ត៣ នូវធម៌៤ <u>របស់ព្រះពុទ្ធ</u>៥ ។*

២. ទារិកា១ អាចរិយស្ស៦ វិហារេ៥ ឧទកំ៤ បិវតិ៣។

*ក្មេងស្រី១ កំពុងផឹក៣ នូវទឹក៤ ក្នុងវិហារ៥ របស់អាចារ្យ៦ ។*

៣. សកុណា១ អាកាសេន៥ មគ្គំ៤ គច្ឆន្តិ៣។

*បក្សី.ទ.១ តែងទៅ៣ នូវផ្លូវ៤ តាមអាកាស៥ ។*

៤. អាចរិយស្ស២ សិស្សា១ គាមស្ស៥ វិហារេ៤ វសន្តិ៣។

*សិស្ស.ទ.១ របស់អាចារ្យ២ កំពុងនៅ៣ ក្នុងវិហារ៤ ជិតស្រុក៥ ។*

*ប្រយោគភាសាបាលី ជួនកាលបទប្រធានមិនមានរូបឱ្យឃើញទេ ក្នុងករណីដូច្នេះ វេលាប្រែត្រូវរកបទប្រធានមកបំពេញឱ្យត្រូវតាមវិភត្តិនោះ ៗ ពីព្រោះវិភត្តិប្រាប់ឱ្យដឹងថាជាប្រធានណាមួយរួចស្រេចហើយ ឧទាហរណ៍*

១. បច<u>តិ</u>. តិ *ប្រាប់ឱ្យដឹងថា (គេ, គាត់, វា ...) កំពុងចម្អិន ។*

២. បច<u>ន្តិ</u>. ន្តិ *ប្រាប់ឱ្យដឹងថា (គេ.ទ., គាត់.ទ. វា.ទ., ...) កំពុងចម្អិន ។*

៣. ភាស<u>សិ</u>. សិ *ប្រាប់ឱ្យដឹងថា (លោក, ឯង, ...) កំពុងនិយាយ ។*

៤. ភាស<u>ថ</u>. ថ *ប្រាប់ឱ្យដឹងថា (លោក,ទ., ឯង.ទ., ...) កំពុងនិយាយ ។*

៥. សិក្ខា<u>មិ</u>. មិ *ប្រាប់ឱ្យដឹងថា (ខ្ញុំ) កំពុងសិក្សា ។*

៦. សិក្ខា<u>ម</u>. ម *ប្រាប់ឱ្យដឹងថា (យើង.ទ. ) កំពុងសិក្សា ។*

*៧.* ពុទ្ធំ សរណំ គច្ឆាមិ ។ *(ខ្ញុំ)(សូម)ដល់នូវព្រះពុទ្ធជាទីពឹង(ទីរលឹក)។*

# វិធីបំបែកនាមស័ព្ទ អា ការន្ត

(Declension of noun in ā-stem)

## វិភត្តិសម្រេចរូបរបស់ អា ការន្តឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | អាយោ, អា |
| ទុ. | អំ | អាយោ, អា |
| ត. | អាយ | អាហិ, អាភិ |
| ច. | អាយ | អានំ |
| បញ្ច. | អាយ | អាហិ, អាភិ |
| ឆ. | អាយ | អានំ |
| ស. | អាយ, អាយំ | អាសុ |
| អា. | អា, អេ | អាយោ, អា |

## វិធីបំបែក កញ្ញា =ស្រីក្រមុំ អា ការន្តឥត្ថីលិង្គ

| វិភត្តិ | ឯកវចន | ពហុវចន |
|---|---|---|
| ប. | កញ្ញា | កញ្ញាយោ, កញ្ញា |
| ទុ. | កញ្ញំ | កញ្ញាយោ, កញ្ញា |
| ត. | កញ្ញាយ | កញ្ញាហិ, កញ្ញាភិ |

| | | |
|---|---|---|
| ប. | កញ្ញាយ | កញ្ញាជំ |
| បញ្ច. | កញ្ញាយ | កញ្ញាហិ, កញ្ញាភិ |
| ឆ. | កញ្ញាយ | កញ្ញានំ |
| ស. | កញ្ញាយ, កញ្ញាយំ | កញ្ញាសុ |
| អា. | កញ្ញេ | កញ្ញាយោ, កញ្ញា |

## កំណត់សម្គាល់

*ស្រះដូចគ្នាពីរតួនៅជាប់គ្នាត្រូវលុបមួយតួចេញដូច្នេះ* (កញ្ញា + អា) > កញ្ញា, (កញ្ញា + អាយោ) > កញ្ញាយោ, (កញ្ញា + អាយ) > កញ្ញាយ *ជាដើម ។*

## នាមស័ព្ទ អា ការន្តឥត្ថីលិង្គ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| បញ្ញា | *បញ្ញា* | ជវិកា | *ជង់* |
| អាភា | *រស្មី* | ធារា | *ធារទឹក* |
| ឱជា | *រស, ឱជា* | មាលា | *កម្រងផ្កា,របៀប* |
| បភា | *រស្មី* | សិលា | *ថ្ម, សិលា* |
| ភាសា | *ភាសា* | គធា | *ដំបង, ព្រនួង* |
| កច្ឆា | *ក្លៀក* | ទោលា | *ទោង* |

| | | | |
|---|---|---|---|
| ចេតនា | ចេតនា | វិជ្ជា | ចំណេះ, វិជ្ជា |
| ទារិកា | ក្មេងស្រី | ភរិយា | ប្រពន្ធ, ភរិយា |
| នារី | ស្ត្រី | នាវា | ទូក, នាវា |
| សាលា | សាលា, រោង | អច្ឆរា | ស្រីអប្សរ |
| ហនុកា | ចង្កា | តារា | ផ្កាយ, តារា |
| ឧបាសិកា | ឧបាសិកា | ពាហា | ខែល |
| សភា | ទីប្រជុំ | ជបា | ផ្កាកុលាប |
| ទេវតា | ទេវតា | វាចា | សម្ដី, វាចា |

## ធាតុស័ព្ទក្នុងពួកទី ១ (ភូធាតុ)

| ធាតុ | ផ្លាស់ជា | ពាក្យប្រែ | ធាតុ | ពាក្យប្រែ |
|---|---|---|---|---|
| គមុ | > គច្ឆ | ទៅ, ដល់ | លភ | បាន, ទទួល |
| ទិស | > បស្ស | ឃើញ | លិខ | សរសេរ |
| បា | > បិវ | ផឹក | ចរ | ដើរទៅ, ប្រព្រឹត្ត |
| ហុ | > ហោ | មាន, ជា | សរ | រលឹក |
| ទា | > ទេ, ទទា | ឱ្យ | ហរ | នាំទៅ |
| ឋា | > តិដ្ឋ | ឈរ, តាំងនៅ | យាច | សុំ, សូម |
| ភូ | > ភវ, ភោ | មាន, ជា | វស | នៅ, អាស្រ័យ |
| សី | > សេ, សយ | ដេក | ភាស | និយាយ, ពោល |

# លំហាត់នៃមេរៀនទី ៣

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើកិរិយាស័ព្ទក្នុងភាសាបាលីមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

២. គ្រឿងសម្រាប់ប្រកបជាអាខ្យាតកិរិយាមានអ្វីខ្លះ ?

៣. តើធាតុចែកជាប៉ុន្មានពួក ? ជាពួកអ្វីខ្លះ ?

៤. តើធាតុទាំង ៨ ពួកនោះមានប៉ុន្មានយ៉ាង ? តើជាធាតុដូចម្តេចខ្លះ ?

៥. បច្ច័យសម្រាប់ចុះក្នុងកិរិយាអាខ្យាតទាំងអស់មានប៉ុន្មានតួ គឺអ្វីខ្លះ ?

៦. បច្ច័យដែលមានប្រើញឹកញាប់មានប៉ុន្មានតួ ? ជាបច្ច័យអ្វីខ្លះ ?

៧. តើធាតុមួយពួក ៗ មានបច្ច័យប៉ុន្មានតួ ? សូមអធិប្បាយ ។

៨. តើវិភត្តិមានប៉ុន្មានយ៉ាង ? ជាវិភត្តិអ្វីខ្លះ ?

៩. វិភត្តិអាខ្យាតមានប៉ុន្មានពួក ? មានឈ្មោះហៅដូចម្តេចខ្លះ ?

១០. តើវត្តមានាវិភត្តិខាងបរស្សបទមានវិភត្តិអ្វីខ្លះ ? ខាងអត្តនោបទមានអ្វីខ្លះ ?

១១. តើបុរិសឬបុរសមានប៉ុន្មានយ៉ាង ? មានឈ្មោះដូចម្តេចខ្លះ ?

១២. បទមាន ២ យ៉ាង តើជាបទអ្វីខ្លះ ?

១៣. កាលក្នុងភាសាបាលីចែកជាកាលធំ ៗ ៣ តើជាកាលអ្វីខ្លះ ?

១៤. កាលធំ ៗ ទាំងបីចែកជាកាលតូច ៗ ទៀតមានឈ្មោះហៅដូចម្តេចខ្លះ ?

១៥. តើកិរិយានុគ្រោះជាអ្វី ?

១៦. តើបច្ចុប្បន្នកាលមានកិរិយានុគ្រោះថាដូចម្ដេចខ្លះ ?

១៧. តើអតីតកាលមានកិរិយានុគ្រោះថាដូចម្ដេចខ្លះ ?

១៨. តើអនាគតកាលមានកិរិយានុគ្រោះថាដូចម្ដេចខ្លះ ?

១៩. អនុត្តកាលចែកជា ៤ តើមានកិរិយានុគ្រោះថាដូចម្ដេចខ្លះ ? សូមអធិប្បាយ ។

២០. តើវាចកៈមានប៉ុន្មានយ៉ាង ? គឺវាចកៈអ្វីខ្លះ ?

**ខ. ចូរបំបែកធាតុស័ព្ទទាំងឡាយខាងក្រោមនេះជាមួយវត្តមានាវិភត្តិខាងបរស្សបទទាំង ៣ បុរិសៈ ។**

១. បច, ២. កាស, ៣. ហា, ៤. គច្ឆ, ៥. ឋា ។

គ. ចូរបំបែកនាមស័ព្ទខាងក្រោមនេះជាមួយវិភត្តិនានាទាំងពីរវចនៈឱ្យត្រូវតាមលិង្គនោះ ។

១. ឧបាសិកា ២. សាលា ៣. ទារិកា ៤. មាលា ។

ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. ភរិយា ឱទនំ បចតិ ។

២. ទារិកាយោ ចាលិកាសំ លិខន្តិ ។

៣. ឧបាសិកា ពុទ្ធស្ស ធម្មំ ចរតិ ។

៤. កុមារោ ទារិកាយ បទុមានិ យាចតិ ។

៥. កញ្ញាយោ ឧទកំ បិវន្តិ ។

៦. មនុស្សោ អាហារំ ខាទតិ ។

៧. អាចរិយស្ស សិស្សា ធានំ ទេន្តិ ។

៨. ទារកា សាលាយំ តិដ្ឋន្តិ ។

៩. វានរា រុក្ខស្មឹ សយន្តិ ។

១០. ជនំ លភន្តិ ។

ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. យើង.ទ. កំពុងឈរ ឯទ្វារ នៃផ្ទះ ។

២. លោក.ទ. តែងត្រាច់ទៅ តាមផ្លូវ ជិតផ្ទះ ។

៣. ខ្ញុំ នឹងទៅ កាន់សាលា របស់លោកគ្រូ ។

៤. មនុស្ស.ទ. រមែង ស្លាប់ ។

៥. ស្វា កំពុងស៊ី ផ្លែ(ឈើ) លើដើមឈើ ។

៦. សិស្ស.ទ. កំពុងសរសេរ នូវអក្សរ.ទ. លើសៀវភៅ ។

៧. ជន.ទ. តែងឃើញ នូវធម៌ របស់ព្រះពុទ្ធ ។

៨. ពោម.ទ. លើស្វា មាន ។

៩. ផ្កាឈូក.ទ. មាន ក្នុងដៃ របស់កញ្ញា ។

១០. កុមារ.ទ. កំពុងដេក ក្នុងផ្ទះ ។

(ចប់មេរៀនទី ៣)

# មេរៀនទី ៨

## អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត)

## វិធីបំបែកធាតុពួកទី ២ (ពួក រុធ ធាតុ)

*ធាតុស័ព្ទពួកទី ២ គឺពួក* **រុធ** *ធាតុ* (Second conjugation) *។ ធាតុពួកនេះតាមពិតមានបច្ច័យ ៥ តួគឺ* **អ ឥ ឦ ឯ ឱ** *និងត្រូវបុះនិគ្គហិតអាគមលើដើមធាតុផង រួចផ្លាស់និគ្គហិតនោះជាព្យញ្ជនវគ្គន្តៈគឺព្យញ្ជនៈទី ៥ ក្នុងវគ្គរបស់តួព្យញ្ជនៈចុងធាតុ ។ បើព្យញ្ជនៈចុងធាតុជា* **អ** *វគ្គព្យញ្ជនៈ ត្រូវទុកនិគ្គហិតឱ្យគង់រូបដូចតារាងខាងក្រោមនេះ*

| | | | |
|---|---|---|---|
| *បើព្យញ្ជនៈចុងធាតុជា* | **ក** *វគ្គ* | *ត្រូវផ្លាស់និគ្គហិតជា* | **ង** |
| ................*ដ*.............. | **ច** *វគ្គ* | ................*ដ*................ | **ញ** |
| ................*ដ*.............. | **ដ** *វគ្គ* | ................*ដ*................ | **ណ** |
| ................*ដ*.............. | **ត** *វគ្គ* | ................*ដ*................ | **ន** |
| ................*ដ*.............. | **ប** *វគ្គ* | ................*ដ*................ | **ម** |
| *បើព្យញ្ជនៈចុងធាតុជា* | **អ** *វគ្គ* | *ត្រូវទុកនិគ្គហិតឲ្យគង់រូប* | ំ |

## វិធីរូបសិទ្ធិកិរិយាជាកត្តុវាចកៈ

*ការប្រកបរូបកិរិយាជាកត្តុវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ*

(*ធាតុ* + -ំ + **អ** *ឬ* **ឯ** *បច្ច័យ* + *វិភត្តិ*) > *កិរិយាស័ព្ទ*

រុធ ជាតុប្រែថា "បិទ" និង វត្តមានាវិភត្តិ

| បុរិសៈ | ឯកវចនៈ | | ពហុវចនៈ | |
|---|---|---|---|---|
| ប.បុ. | រុន្ធតិ | រុន្ធេតិ | រុន្ធន្តិ | រុន្ធេន្តិ |
| ម.បុ. | រុន្ធសិ | រុន្ធេសិ | រុន្ធថ | រុន្ធេថ |
| ឧ.បុ. | រុន្ធាមិ | រុន្ធេមិ | រុន្ធាម | រុន្ធេម |

## វិធីផ្លាស់និគ្គហិត

១. បើព្យញ្ជនៈទីបំផុតធាតុជា **ក** វគ្គត្រូវផ្លាស់និគ្គហិតជា **ង** ដូចជា **អង្កតិ** =ទៅ, ដល់, ប្រព្រឹត្ត ។ សម្រេចមកពី **អក** ជាតុចុះនិគ្គហិតទៅជា (**អំក** > **អង្ក**) + **អ** + **តិ** > **អង្កតិ** ។ ទោះបីជាព្យញ្ជនៈឯទៀតក្នុង **ក** វគ្គនេះ ក៏ធ្វើដូច្នេះទាំងអស់ ។

២. បើព្យញ្ជនៈទីបំផុតធាតុជា **ច** វគ្គត្រូវផ្លាស់និគ្គហិតជា **ញ** ដូចជា **មុញ្ចតិ** =ដោះ, លែង ។ សម្រេចមកពី **មុច** ជាតុចុះនិគ្គហិតទៅជា (**មុំច** > **មុញ្ច**) + **អ** + **តិ** > **មុញ្ចតិ** ។ ទោះបីជាព្យញ្ជនៈឯទៀតក្នុង **ច** វគ្គនេះ ក៏ធ្វើដូច្នេះទាំងអស់ ។

៣. បើព្យញ្ជនៈទីបំផុតធាតុជា **ឌ** វគ្គត្រូវផ្លាស់និគ្គហិតជា **ណ** ដូចជា **អាហិណ្ឌតិ** =ដើរ, ត្រាច់ ។ សម្រេចមកពី **អា** (បុព្វបទ) + **ហិឌ** ជាតុចុះនិគ្គហិតទៅជា (**អាហិំឌ** > **អាហិណ្ឌ**) + **អ** + **តិ** > **អាហិ-ណ្ឌតិ** ។ ទោះបីជាព្យញ្ជនឯទៀតក្នុង **ឌ** វគ្គនេះ ក៏ធ្វើដូច្នេះទាំងអស់ ។

៤. បើព្យញ្ជនៈទីបំផុតធាតុជា **ត** វគ្គត្រូវផ្លាស់និគ្គហិតជា **ង** ដូចជា **រុង្គតិ** =បិទ ។ សម្រេចមកពី **រុដ** ធាតុចុះនិគ្គហិតទៅជា (**រុំដ** > **រុង្ន**) + **អ** + **តិ** > **រុង្គតិ** ។ ទោះបីជាព្យញ្ជនឯទៀតក្នុង **ត** វគ្គនេះ ក៏ធ្វើដូច្នេះទាំង-អស់ ។

៥. បើព្យញ្ជនៈទីបំផុតធាតុជា **ប** វគ្គត្រូវផ្លាស់និគ្គហិតជា **ម** ដូចជា **លិម្បតិ** =លាប ។ សម្រេចមកពី **លិប** ធាតុចុះនិគ្គហិតទៅជា (**លឹប** > **លិម្ប**) + **អ** + **តិ** > **លិម្បតិ** ។ ទោះបីជាព្យញ្ជនៈឯទៀតក្នុង **ប** វគ្គនេះ ក៏ធ្វើដូច្នេះទាំងអស់ ។

៦. បើព្យញ្ជនៈទីបំផុតធាតុជា **អ** វគ្គត្រូវទុកនិគ្គហិតឱ្យគង់រូបដើម ំ ដូចជា **ហឹសតិ** =បៀតបៀន ។ សម្រេចមកពី **ហិសិ** ធាតុចុះនិគ្គហិតទៅជា **ហឹសិ** + **អ** + **តិ** > **ហឹសតិ** (លុប **ឥ** នៃ **សិ** ចេញ) ។ ទោះបីជាព្យញ្ជនៈឯទៀតក្នុង **អ** វគ្គនេះ ក៏ធ្វើដូច្នេះទាំងអស់ ។

## កំណត់សម្គាល់

១. ពួក **រុដ** ធាតុនេះមាន **អ** និង **ឯ** ជាបច្ច័យប្រចាំពួក ។

២. ធាតុណាក៏ដោយចាំបាច់ត្រូវតែចុះនិគ្គហិតអាគមលើដើមធាតុសិន រួចផ្លាស់និគ្គហិតជាព្យញ្ជនវគ្គន្តៈ (សូមមើលវិធីនៅខាងលើ) ទើបចុះបច្ច័យនិងវិភត្តិ ។

៣. ដូចធាតុក្នុងពួក **ភូ** ធាតុដែរគឺត្រូវលុប **អ** បច្ច័យចោលជានិច្ច ។

## ធាតុសព្វក្នុងពួកទី ២ (រុធធាតុ)

| ធាតុ | ផ្លាស់ជា | ពាក្យប្រែ | ធាតុ | ផ្លាស់ជា | ពាក្យប្រែ |
|---|---|---|---|---|---|
| មុច | > មុញ្ច | លែង, រួច | ហិសិ | > ហឹស | បៀតបៀន |
| កុជ | > កុញ្ជ | ស៊ី, បរិភោគ | សុភ | > សុម្ភ | វាយ, ប្រហារ |
| ភិទ | > ភិន្ទ | ទំលាយ | សិច | > សិញ្ច | ស្រោច, ប្រោះ |
| លិប | > លិម្ប | លាប | វិទ | > វិន្ទ | ប្រសប់, ទទួល |
| យុជ | > យុញ្ជ | ប្រកប | លុប | > លុម្ប | ប្លន់ |
| អគ | > អង្គ | ទៅ, ដល់ | វឆ | > វញ្ឆ | ប្រាថ្នា, ចង់ |
| ឆិទ | > ឆិន្ទ | កាត់, ផ្ដាច់ | វចិ | > វញ្ច | ភ្លឺ, រុងរឿង |

## (២) បញ្ចមីវិភត្តិអាខ្យាត

( Imperative endings )

| បរស្សបទ | | | អត្តនោបទ | | |
|---|---|---|---|---|---|
| បុរិសៈ | ឯកវចនៈ | ពហុវចនៈ | បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| ប.បុ. | តុ | អន្តុ | ប.បុ. | តំ | អន្តំ |
| ម.បុ. | ហិ | ថ | ម.បុ. | ស្សុ | វ្ហោ |
| ឧ.បុ. | មិ | ម | ឧ.បុ. | ឯ | អាម្ហសេ |

*បញ្ចមីវិភត្តិសម្រាប់ប្រើប្រាប់អនុត្តកាល ២ យ៉ាងគឺ* **អាណត្តិ** និង

អាសិដ្ឋ ។

១. **អាណត្តិ** (Command) *ប្រើប្រាប់សេចក្ដីបង្គាប់ មានកិរិយានុគ្រោះ ប្រែថា ចូរ..., ចូរ...ចុះ ។*

២. **អាសិដ្ឋ** (Request/Wish) *ប្រើប្រាប់សេចក្ដីប្រាថ្នា, ប្រាប់សេចក្ដីប៉ុនប៉ង មានកិរិយានុគ្រោះ ប្រែថា ចូរ..., សូម..., សូមឱ្យ...ចុះ ។*

*ពាក្យប្រែទាំងនេះចូរលើកយកមួយណាមកប្រើឱ្យត្រូវតាមសេចក្ដីក្នុងទីនោះ ៗ ។*

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

## (Verbs Formation)

*ការប្រកបរូបកិរិយាជាមួយបញ្ចមីវិភត្តិ មានគតិដូចវត្តមានាវិភត្តិដែរ ប្រើធាតុណាមួយក៏បាន ប៉ុន្តែត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយជានិច្ចដូចមានរូបមន្តខាងក្រោមនេះ*

*(ធាតុ + បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ*

បច ធាតុប្រែថា "ចម្អិន" និង **បញ្ចមីវិភត្តិបរស្សបទ**

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **បចតុ** *(គេ)ចូរចម្អិន* | **បចន្តុ** *(គេ.ទ.)ចូរចម្អិន* |
| *ម.បុ.* | **បចាហិ**, **បច***(ឯង)ចូរចម្អិន* | **បចថ** *(ឯង.ទ.)ចូរចម្អិន* |
| *ឧ.បុ.* | **បចាមិ** *(ខ្ញុំ)ចូរចម្អិន* | **បចាម** *(យើង.ទ.)ចូរចម្អិន* |

ធាតុឯទៀត ៗ ក៏មានវិធីការប្រកបរូបជាកិរិយាបែប បច ធាតុដែរ ។ សូមសង្កេតមើលវិភត្តិនេះបំបែកដូចវត្តមានាវិភត្តិ ៣ វិភត្តិគឺ ថ, មិ, ម ។

## កំណត់សម្គាល់

១. តុ វិភត្តិបើផ្សំជាមួយធាតុនិងបច្ច័យហើយពុំចាំបាច់ផ្លាស់ប្តូរអ្វីទេ ។ ប្រសិនបើជា អ បច្ច័យត្រូវលុបចោលដូចជា (គម > គច្ឆ) + អ + តុ > គច្ឆតុ ។

២. អន្តុ ត្រូវផ្លាស់ជា ន្តុ ដូចជា (គម > គច្ឆ) + អ + ន្តុ > គច្ឆន្តុ ។

៣. ហិ, មិ, ម វិភត្តិបើចុះផ្សំនឹងធាតុបច្ច័យហើយត្រូវទីឃៈទីបំផុតធាតុ ឧ. (គម + អ + ហិ) > គច្ឆាហិ, (គម + អ + មិ) > គច្ឆាមិ, (គម + អ + ម) > គច្ឆាម ។

៤. ហិ បញ្ចមីវិភត្តិច្រើននិយមលុបចោលក៏មានខ្លះ ឧ. (គម + អ + ហិ) > គច្ឆ =(ឯង)ចូរទៅ, (ខាទ + អ + ហិ) > ខាទ =(ឯង)ចូរស៊ី, (ភូ > ភវ + អ + ហិ) > ភវ =(ឯង)ចូរជា, (ករ + ឱ + ហិ) > ករោហិ, ករ =(ឯង)ចូរធ្វើ ជាដើម ។ ចំពោះ ករ ធាតុនឹងមានអធិប្បាយនៅខាងមុខ ។

៥. ចំពោះ ណា, នា, ណ្ហា បច្ច័យនៅខាងដើម អន្តុ ចាំបាច់ត្រូវរស្សៈ ឧ. (សុ + ណា + អន្តុ) > សុណន្តុ, (ជិ + នា + អន្តុ) > ជិនន្តុ,

( **គហ** + **ណ្ហា** + **អន្តុ** ) > **គណ្ហន្តុ** (*វិធីបំបែកពួក* **សុ**, **កី**, **គហ** *ធាតុនឹងមានអធិប្បាយនៅខាងមុខ*) ។

## វិធីបំបែក អស ធាតុជាមួយបញ្ចមីវិភត្តិ

*ដូចបានពោលរួចហើយថា* **អស** *ធាតុមានវិធីបំបែកប្លែកពីគេគ្រប់វិភត្តិទាំងអស់ ខាងក្រោមនេះជាការបំបែកជាមួយបញ្ចមីវិភត្តិខាងបរស្សបទ ។*

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **អត្ថុ** | **សន្តុ** |
| *ម.បុ.* | **អាហិ** | **អត្ថ** |
| *ឧ.បុ.* | **អម្ហិ**, **អស្មិ** | **អម្ហ**, **អស្ម** |

(*ប្រែថា ចូរឬសូមមាន, ចូរឬសូមជា*)

*សូមសង្កេតមើលក្នុងការបំបែកជាមួយបញ្ចមីវិភត្តិនេះ មានរូបខ្លះដូចវត្តមានាវិភត្តិដែរ គឺត្រង់មជ្ឈិមបុរិសពហុវចនៈនិងឧត្តមបុរិសៈទាំងពីរវចនៈ ។*

## ឧទាហរណ៍នៃការប្រើបញ្ចមីវិភត្តិ

១. *ប្រើប្រាប់សេចក្តីបង្គាប់* (**អាណត្តិ**)

**កុញ្ជរាហិ ឱធនំ** ។ (ឯង) ចូរស៊ី នូវបាយ ។

**គច្ឆាហិ** ។ (ឯង) ចូរទៅចុះ ។

២. ប្រើប្រាប់សេចក្តីប្រាថ្នា ឬ ប្រាប់សេចក្តីប៉ុនប៉ង (**អាសិដ្ឋ**)

**ភវថ សុខំ** ។ ចូរ(អ្នក.ទ.) មាន សេចក្តីសុខចុះ ។

**ភវតុ សព្វមង្គលំ** ។ មង្គលទាំងពួង សូមមាន ។

**សព្វេ សត្តា អវេរា ហោន្តុ** ។ សូមឱ្យសត្វ.ទ. ទាំងពួង ជាអ្នកមិនមានវេរាចុះ ។

៣. ប្រើប្រាប់សេចក្តីហាមឃាត់ (Prohibition) ។ បើប្រើដូច្នេះត្រូវប្រើ **មា** ស័ព្ទប្រែថា "មិន, កុំ" ដាក់ខាងដើមនៃប្រយោគឬពីខាងដើមកិរិយាស័ព្ទ ឧ. **មា គច្ឆ** (ឯង)ចូរកុំទៅ ។ **ត្វំ ឥធ មា តិដ្ឋ** ឯង ចូរកុំឈរក្នុងទីនេះ ។

ប្រសិនបើប្រើ **មា** ស័ព្ទខាងដើមកិរិយាស័ព្ទ ពេលប្រែត្រូវអានគួបគ្នាដូចជា **មា-តិដ្ឋ** ជាដើម ។ សូមបញ្ជាក់ថាវិធីលើកស័ព្ទប្រែគឺដូចការប្រែពួកវត្តមានាវិភត្តិដែរ ព្រោះក្នុងទីនេះជាប្រយោគកត្តុវាចក:ដូចគ្នា ។

៤. ប្រសិនបើប្រយោគនោះ ៗ ផ្តើមដោយអាលបនបទ នោះកិរិយាស័ព្ទត្រូវប្រើជាមជ្ឈិមបុរិស:ជាឯកវចន:ឬពហុវចន:ជានិច្ច ដូចជា

**សិស្សា សទា កតញ្ញូ ហោថ** ។

ម្នាលសិស្ស.ទ. ចូរមាន កតញ្ញូ ជានិច្ច ។

(សូមអ្នកសិក្សាគប្បីជ្រាបតាមសេចក្តីនេះផងចុះ)

# វិធីបំបែកនាមសព្ទ ឥ ការន្ត

(Declension of noun in i-stem)

*នាមសព្ទដែលមានទីបំផុតជា ឥ ការន្តមានក្នុងលិង្គទាំង ៣ គឺ បុំលិង្គ, ឥត្ថីលិង្គ និង នបុំសកលិង្គ ។ ក្នុងលិង្គនីមួយ ៗ មានវិធីបំបែកផ្សេងគ្នាដូចតទៅនេះ*

## វិភត្តិសម្រេចរូបរបស់ ឥ ការន្តបុំលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ឥ | អយោ, ឦ |
| *ទុ.* | ឥំ | អយោ, ឦ |
| *ត.* | ឥនា | ឦហិ, ឦភិ |
| *ច.* | ឥស្ស, ឥនោ | ឦនំ |
| *បញ្ច.* | ឥស្មា, ឥម្ហា | ឦហិ, ឦភិ |
| *ឆ.* | ឥស្ស, ឥនោ | ឦនំ |
| *ស.* | ឥស្មឹ, ឥម្ហិ | ឦសុ |
| *អា.* | ឥ | អយោ, ឦ |

## វិធីបំបែក មុនិ=អ្នកប្រាជ្ញ ឥ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មុនិ | មុនយោ, មុនី |
| ទុ. | មុនឹ | មុនយោ, មុនី |
| ត. | មុនិនា | មុនីហិ, មុនីភិ |
| ច. | មុនិស្ស, មុនិនោ | មុនីនំ |
| បញ្ច. | មុនិស្មា, មុនិម្ហា | មុនីហិ, មុនីភិ |
| ឆ. | មុនិស្ស, មុនិនោ | មុនីនំ |
| ស. | មុនិស្មឹ, មុនិម្ហិ | មុនីសុ |
| អា. | មុនិ | មុនយោ, មុនី |

## នាមស័ព្ទ ឥ ការន្តបុំលិង្គ

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| មុនិ | អ្នកចេះ, មុនី | សមាធិ | ការតាំងចិត្ត, សមាធិ |
| អហិ | ពស់ | វិធិ | របៀប, វិធី |
| មណិ | ត្បូង, កែវមណី | រាសិ | គំនរ, រាសី |
| ឥសិ | ឫសី, ឥសី | កាបិ | ស្វា |
| អតិថិ | ភ្ញៀវ | ព្យាធិ | ជំងឺ |
| ថបតិ | ជាងឈើ | អរិ | សត្រូវ |

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| បតិ | ម្ចាស់, ប្ដី | អសិ | ដាវ |
| អគ្គិ | ភ្លើង, អគ្គី | ចាណិ | បាតដៃ |
| និធិ | កំណប់ទ្រព្យ | ចក្កវត្តិ | ស្ដេចចក្រពត្តិ |
| វីហិ | ស្រូវ | កុច្ឆិ | ពោះ |
| គហបតិ | គហបតី | គិរិ | ភ្នំ, គីរី |
| ឧទធិ | សមុទ្រ | អទ្ទិ | ភ្នំ |

## វិភត្តិសម្រេចរូបរបស់ ឥ ការន្តនបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឥ | ឦនិ, ឦ |
| ទុ. | ឥំ | ឦនិ, ឦ |
| ត. | ឥនា | ឦហិ, ឦភិ |
| ច. | ឥស្ស, ឥនោ | ឦនំ |
| បញ្ច. | ឥស្មា, ឥម្ហា | ឦហិ, ឦភិ |
| ឆ. | ឥស្ស, ឥនោ | ឦនំ |
| ស. | ឥស្មឹ, ឥម្ហិ | ឦសុ |
| អា. | ឥ | ឦនិ, ឦ |

## វិធីបំបែក អគ្គិ =ភ្លើង ៩ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
| --- | --- | --- |
| ប. | អគ្គិ | អគ្គីនិ, អគ្គី |
| ទុ. | អគ្គឹ | អគ្គីនិ, អគ្គី |
| ត. | អគ្គិនា | អគ្គីហិ, អគ្គីភិ |
| ច. | អគ្គិស្ស, អគ្គិនោ | អគ្គីនំ |
| បញ្ច. | អគ្គិស្មា, អគ្គិម្ហា | អគ្គីហិ, អគ្គីភិ |
| ឆ. | អគ្គិស្ស, អគ្គិនោ | អគ្គីនំ |
| ស. | អគ្គិស្មឹ, អគ្គិម្ហិ | អគ្គីសុ |
| អា. | អគ្គិ | អគ្គីនិ, អគ្គី |

## កំណត់សម្គាល់

*ស្រៈដូចគ្នាពីរតួនៅជាប់គ្នាត្រូវលុបមួយចេញដូច្នេះ (មុនិ + ឥ) > មុនិ ។ ចំពោះបឋមា, ទុតិយានិងអាលបនវិភត្តិពហុវចនៈត្រូវលុបស្រៈ ឥ នៃនាមសព្ទចេញដូច្នេះ (មុនិ + អយោ) > មុនយោ ។*

*សូមសង្កេតមើលវិភត្តិសម្រេចខាងលើនេះមានរូបដូច ឥ ការន្តបុំ-លិង្គស្ទើរតែទាំងអស់ មានខុសតែត្រង់ បឋមា, ទុតិយានិងអាលបនវិភត្តិដែលជា នី និ ប៉ុណ្ណោះ ។*

## នាមសព្ទ ៩ ការន្តនបុំសកលិង្គ

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អច្ចិ | អណ្ដាតភ្លើង | វារិ | ទឹក, វារី |
| អដ្ឋិ | ឆ្អឹង, អដ្ឋិ | សត្ថិ | ភ្លៅ |
| សប្បិ | ទឹកដោះថ្លា | ទធិ | ទឹកដោះជូរ |

## និបាតសព្ទ (Particles)

និបាតសព្ទជាអព្យយសព្ទគឺពុំចាំបាច់បំបែកតាមវិភត្តិដូចនាមនាមទេ ។ និបាតទាំងអស់មានឈ្មោះហៅ ១៥ យ៉ាងដែលនឹងមានអធិប្បាយនៅខាងមុខ ។ ក្នុងទីនេះសូមនាំយកនិបាតដែលនិយមប្រើញឹកញាប់ដូចមានខាងក្រោមនេះ

**ហិ** ក៏, ពិត, មែនពិត, ព្រោះថា, ដូចមានសេចក្ដីឬពោលថា ។

**ច** ក៏, ផង, ម្យ៉ាងទៀត ។

**បន** ប៉ុន្តែ, ក៏, ឯ, ចំណែកខាង ។

**ន** មិន.......ទេ (សំរាប់ប្រើបដិសេធកិរិយាសព្ទ) ។

**សទ្ធឹ** ជាមួយ, ព្រមជាមួយ, មួយអន្លើ (ប្រើជាមួយតតិយាវិ.) ។

**សហ** ជាមួយ, ព្រមជាមួយ, មួយអន្លើ ។

**វា** ឬ, ក្ដី, ខ្លះ, ម្យ៉ាងទៀត ។

# លំហាត់នៃមេរៀនទី ៤

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើវិធីរូបសិទ្ធិជាកិរិយាស័ព្ទរបស់ពួក រុធ ជាតុមានខុសប្លែកពីពួក ភូ ជាតុដូចម្ដេចខ្លះ ?

២. កាលបើចុះនិគ្គហិតមកហើយ តើត្រូវធ្វើដូចម្ដេចចំពោះព្យញ្ជនៈទីបំផុតជាតុ ?

៣. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង ក វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

៤. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង ច វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

៥. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង ដ វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

៦. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង ត វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

៧. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង ប វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

៨. បើព្យញ្ជនៈទីបំផុតជាតុជាព្យញ្ជនៈក្នុង អ វគ្គ តើត្រូវផ្លាស់ជាព្យញ្ជនៈមួយណា ? សូមឱ្យឧទាហរណ៍ ។

*៩. តើបញ្ចមីវិភត្តិខាងបរស្សបទមានវិភត្តិអ្វីខ្លះ ?*

*១០. អន្តុ វិភត្តិកាលបើចុះមកហើយ តើត្រូវធ្វើដូចម្តេច ?*

*១១. ហិ, មិ, ម វិភត្តិកាលបើចុះមកហើយ ត្រូវទីឃៈទីបំផុតធាតុឬទេ ?*

*១២. តើ ហិ វិភត្តិអាចលុបចេញបានដែរឬទេ ?*

*១៣. ប្រសិនបើបច្ច័យនោះជា ណា, នា, ណ្ហា ចុះជាមួយ អន្តុ វិភត្តិ តើត្រូវធ្វើដូចម្តេច ?*

***ខ. ចូរបំបែកធាតុស័ព្ទទាំងឡាយខាងក្រោមនេះជាមួយបញ្ចមីវិភត្តិខាងបរស្សបទទាំង ៣ បុរិសៈ***

១. កុជ, ២. សិច, ៣. ហិសិ, ៤. ធិន, ៥. វិន ។

***គ. ចូរបំបែកនាមស័ព្ទខាងក្រោមនេះជាមួយវិភត្តិនានាទាំងពីរវចនៈឱ្យត្រូវតាមលិង្គនោះ ។***

១. សេនាបតិ, ២. មណិ, ៣. អគ្គិ, ៤. អដ្ឋិ, ៥. ភារិ ។

***ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ***

១. គហបតិ អតិថិស្ស ជនំ ទេតុ ។

២. ថបតយោ គិរិស្មឹ រុក្ខេ ធិន្ទន្តុ ។

៣. ចាទេហិ ចរាម, អគ្គីហិ បស្សាម ។

៤. ភាជរា កសកស្ស កុច្ឆឹ សុម្ភតិ ។

៥. ឧបាសិកា វិហារេ និសីទន្តុ ។

៦. អហិ បតិស្ស ហត្ថំ <u>ឌំសតិ</u> *(ចឹក)*។

៧. ធារិកា មាលំ ហរតិ ។

៨. កុមារ, ឧទកម្ហិ មច្ឆេ មុញ្ច ។

៩. កញ្ញេ, អាភមេ (សួន) ជទាយោ សិញ្ចាហិ ។

១០. មុនិ គហបតិនោ គេហស្មឹ ធម្មំ ភាសតុ ។

១១. កសកា ខេត្តេ ឧទកំ ន រុន្ធន្តិ ។

១២. បុរិសា ច ធារិយោ ច គេហេ អាហារំ កុញ្ជន្តិ, សុខំ វិន្ទន្តិ ។

១៣. កុមារា, មា គេហស្ស ទ្វារេ លិម្បថ ។

១៤. ពុទ្ធស្ស សាវកា កិលេសំ ភិន្ទន្តិ ។

១៥. អតិថយោ គហបតិនោ គេហំ អាគច្ឆន្តិ ។

*ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. អ្នក.ទ. នឹងរួច ពីទុក្ខ ព្រោះបុណ្យ ។*

*២. ព្រះអរិយៈ.ទ. រមែងរួច ពីសេចក្តីប្រកាន់មាំ ។*

*៣. ថ្នាំង នៃបាយ នឹងបែក ។*

*៤. ចូរអ្នក.ទ. ទទួលទាន នូវអាហារ ក្នុងផ្ទះ ។*

*៥. សូមគេ.ទ. បាន នូវសេចក្តីសុខ ។*

*៦. នៃសិស្ស.ទ. ចូរអ្នក.ទ. ស្តាប់(សុណាថ) នូវធម៌ ក្នុងវិហារ ។*

*៧. កសិករ.ទ. កំពុងបិទ(ទប់) នូវទឹក ក្នុងស្រែ ។*

*៨. នៃក្មេង.ទ. កុំរត់ តាមផ្លូវ ជិតភ្នំ ។*

*៩. លោកគ្រូ រមែងឱ្យ នូវឱវាទ ដល់សិស្ស.ទ. ។*

១០. ជន.ទ. កំពុងសំពះ នូវព្រះសង្ឃ.ទ. ដោយសេចក្ដីគោរព ។
១១. លោកគ្រូ រមែងរស់ ដោយសេចក្ដីជ្រះថ្លា របស់សិស្ស.ទ. ។
១២. ពន្លឺ នៃបញ្ញា រមែងភ្លឺ <u>ជាងពន្លឺ.ទ.</u> (ប្រើបញ្ចមីវិភត្តិ) ។

(ចប់មេរៀនទី ៤)

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| រៀនសរសេរ | រៀនទន្ទេញ | ស័ព្ទឱ្យចាំ |
| ខំចំណាំ | ចាំជំនាញ | ស្ទាញចំណាន |
| ចូរខ្នះខ្នែង | ប្រឹងប្រែងរៀន | ខាងការអាន |
| អានហើយអាន | ឱ្យបានខ្លាំង | និងច្បាស់ ៗ ។ |
| អានញយ ៗ | ជាញឹកៗ | ក៏ថ្នឹកមាត់ |
| យូរទៅស្ទាញ | ជំនាញស្ទាត់ | ឆាប់រហ័ស |
| រៀននិយម | ខំនិយាយ | កុំអៀនខ្មាស់ |
| និយាយញឹក | ញយរហ័ស | បានការអើយ ។ |

(មិនដឹងប្រភពដើម)

# មេរៀនទី ៨

## អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត)

## វិធីបំបែកធាតុពួកទី ៣ (ពួក ទិវ ធាតុ)

*ធាតុស័ព្ទពួកទី ៣ គឺពួក* **ទិវ** *ធាតុ* (Third conjugation) *។ ធាតុពួកនេះមាន យ ជាបច្ច័យ ។ ដោយអំណាចនៃ យ បច្ច័យ អាចធ្វើឱ្យធាតុនោះ ៗ ផ្លាស់ប្តូររូបដូចមានពោលខាងក្រោមនេះ*

*១. បើជាធាតុទោលឬមួយព្យាង្គមិនមានការផ្លាស់ប្តូរទេដូចជា*

(**ទី** + យ + **តិ**) > **ទីយតិ** *ប្រែថា អស់, អស់ទៅ ។*

*២. ប្រសិនបើជាធាតុពីរតួឬពីរព្យាង្គ ដែលមានព្យញ្ជនៈទីបំផុតធាតុជា* ច, ជ, ទ, ធ, ប, វ, ស, ហ *មានវិធីផ្លាស់ដូចខាងក្រោមនេះ*

| | | | |
|---|---|---|---|
| *បើទីបំផុតធាតុជា* | ( ច + យ > ច្យ ) | *ទៅជា* | > ច្ច |
| ............ដ៏............ | ( ជ + យ > ជ្យ ) | ....ដ៏.... | > ជ្ជ |
| ............ដ៏............ | ( ទ + យ > ទ្យ ) | ....ដ៏.... | > ជ្ជ |
| ............ដ៏............ | ( ធ + យ > ធ្យ ) | ....ដ៏.... | > ជ្ឈ |
| ............ដ៏............ | ( ប + យ > ប្យ ) | ....ដ៏.... | > ប្ប |
| ............ដ៏............ | ( វ + យ > វ្យ ) | ....ដ៏.... | > ព្វ |
| ............ដ៏............ | ( ស + យ > ស្យ ) | ....ដ៏.... | > ស្ស |
| ............ដ៏............ | ( ហ + យ > ហ្យ ) | ....ដ៏.... | > យ្ហ |

## វិធីរូបសិទ្ធិកិរិយាជាកត្តុវាចកៈ

*ការប្រកបរូបជាកិរិយាកត្តុវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ*

*(ធាតុ + **យ** បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ*

**ជិរ** *ធាតុប្រែថា "លេង" និង* **វត្តមានាវិភត្តិ**

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **ជិព្វតិ** | **ជិព្វន្តិ** |
| *ម.បុ.* | **ជិព្វសិ** | **ជិព្វថ** |
| *ឧ.បុ.* | **ជិព្វាមិ** | **ជិព្វាម** |

*ធាតុស័ព្ទក្នុងពួកទី ៣ នេះក៏អាចជាធាតុពួកទី ២ ផងដែរ ដោយ-សារការចុះបច្ច័យ ដូចជា*

*១.* **ភិទ** *បើចុះ* **អ, ំ** *បច្ច័យនោះជាធាតុពួកទី ២ ឧ.* (**ភិទ** + ំ + **អ** + **តិ**) > **ភិន្ទតិ** *ប្រែថា "ទំលាយ" ដូចជា ទំលាយកិលេស ជាដើម ។ ប៉ុន្តែបើចុះ* **យ** *បច្ច័យនោះជាធាតុពួកទី ៣ វិញ ឧ.* (**ភិទ** + **យ** + **តិ**) > **ភិជ្ជតិ** *ប្រែថា "បែក" ដូចជា ចានបែក ជាដើម ។*

*២.* **មុច** *បើចុះ* **អ, ំ** *បច្ច័យនោះជាធាតុពួកទី ២ ឧ.* (**មុច** + ំ + **អ** + **តិ**) > **មុញ្ចតិ** *ប្រែថា "លែង" ដូចជា លែងចាប ជាដើម ។ ប៉ុន្តែបើចុះ* **យ** *បច្ច័យនោះជាធាតុពួកទី ៣ វិញ ឧ.* (**មុច** + **យ** + **តិ**) > **មុច្ចតិ**

ប្រែថា "រួច" ដូចជា រួចពីចំណង ជាដើម ។

៣. **លិប** បើចុះ អ, ឯ បច្ច័យនោះជាធាតុពួកទី ២ ឧ. (**លិប** + ំ + អ + តិ) > **លិម្បតិ** ប្រែថា "លាប" ដូចជា លាបពណ៌ ជាដើម ។ ប៉ុន្តែ បើចុះ យ បច្ច័យនោះជាធាតុពួកទី ៣ វិញ ឧ. (**លិប** + **យ** + **តិ**) > **លិប្បតិ** ប្រែថា "ប្រឡាក់, ជ្រលក់" ដូចជា ជ្រលក់ពណ៌ ជាដើម ។

ដូច្នេះធាតុតួខ្លះអាចមានសេចក្តីច្រើនយ៉ាង ។

## ធាតុសព្វក្នុងពួកទី ៣ (ទិវធាតុ)

| ធាតុ | ផ្លាស់ជា | ពាក្យប្រែ | ធាតុ | ផ្លាស់ជា | ពាក្យប្រែ |
|---|---|---|---|---|---|
| កុជ | > កុជ្ឈ | ក្រោធ, ខឹង | ជិប | > ជិប្ប | រះ |
| ជិវ | > ជិព្វ | លេង | ភិជ | > ភិជ្ជ | បែក |
| ពុជ | > ពុជ្ឈ | ចេះ, ត្រាស់ដឹង | មុច | > មុច្ច | រួច, ផុត |
| មុហ | > មុយ្ហ | វង្វេង | មុស | > មុស្ស | ភ្លេច |
| រជ | > រជ្ជ | ជ្រលក់ | រជ | > រជ្ឈ | បៀតបៀន |
| លិប | > លិប្ប | ប្រឡាក់, ជាប់ | សិវ | > សិព្វ | ដេរ |

## (៣) សត្តមីវិភត្តិអាខ្យាត

(Optative endings)

| | បរស្សៃបទ | | | អត្តនោបទ | |
|---|---|---|---|---|---|
| បុរិសៈ | ឯកវចនៈ | ពហុវចនៈ | បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| ប.បុ. | ឃយ្យ | ឃយ្យុំ | ប.បុ. | ឃេ | ឃរំ |
| ម.បុ. | ឃយ្យាសិ | ឃយ្យាថ | ម.បុ. | ឃថោ | ឃយ្យវ្ហោ |
| ឱ.បុ. | ឃយ្យាមិ | ឃយ្យាម | ឱ.បុ. | ឃយ្យំ | ឃយ្យម្ហេ |

☸ វេលាផ្សំជាមួយធាតុត្រូវផ្លាស់ពី ឃ នេះទៅជា េ- នេះវិញដូចជា េយ្យ ជាដើម ។

សត្តមីវិភត្តិសម្រាប់ប្រើប្រាប់អនុត្តកាល ២ យ៉ាង់គឺ **អនុមត្តិ** និង **បរិកប្ប** ។

១. **អនុមត្តិ** (Potential) ប្រាប់សេចក្តីយល់ឃើញ មានកិរិយានុគ្រោះ ប្រែថា គួរ......, គួរតែ...... ។

២. **បរិកប្ប** (Conditional) ប្រាប់សេចក្តីកំណត់, ប្រាប់សេចក្តីត្រិះរិះ មានកិរិយានុគ្រោះ ប្រែថា គប្បី......, ត្រូវ...... ។

ពាក្យប្រែទាំងនេះ សូមលើកយកណាមួយមកប្រើឱ្យត្រូវតាមសេចក្តីក្នុងទីនោះ ៗ ។ ប៉ុន្តែប្រយោគដែលប្រកបជាមួយសត្តមីវិភត្តិនេះ ក៏អាចប្រែជាអនាគតកាលបានដែរ ។ សូមមើលឧទាហរណ៍នៅខាងមុខ ។

## វិធីរូបសិទ្ធិជាកិរិយាសព្ទ

ការប្រកបរូបកិរិយាជាមួយសត្តមីវិភត្តិមានគតិដូចវត្តមានាវិភត្តិដែរ

ប្រើធាតុណាមួយក៏បាន ។ ប៉ុន្តែត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយដូចមានរូបមន្តខាងក្រោមនេះ

(ធាតុ + បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ

## វិធីបំបែកធាតុជាមួយសត្តមីវិភត្តិ

បច ធាតុប្រែថា "ចម្អិន" នឹង **សត្តមីវិភត្តិបរស្សបទ**

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
| --- | --- | --- |
| ប.បុ. | បចេយ្យ, បចេ | បចេយ្យុំ |
| ម.បុ. | បចេយ្យាសិ | បចេយ្យាថ |
| ឧ.បុ. | បចេយ្យាមិ | បចេយ្យាម |

(ធាតុឯទៀត ៗ ក៏មានវិធីប្រកបរូបដូច **បច** ធាតុដែរ)

## កំណត់សម្គាល់

**ឯយ្យ** វិភត្តិនិយមផ្លាស់ជា **ឯ** ។ ចំពោះធាតុក្នុងពួក **រុធ** និង **ជិរ** ធាតុត្រូវអនុវត្តតាមវិធីចុះនិគ្គហិត និងវិធីផ្លាស់ទីបំផុតធាតុជាមួយ **យ** បច្ច័យសិនរួចទើបចុះសត្តមីវិភត្តិដូចជា **ជិញ្ញេយ្យ, មុញ្ចេយ្យ** ជាដើម ។

## វិធីបំបែក **អស** ធាតុជាមួយសត្តមីវិភត្តិ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | សិយា, អស្ស | សិយុំ, អស្សុំ |
| ម.បុ. | អស្ស | អស្សត្ថ |
| ឧ.បុ. | អស្សាមិ | អស្សាម |

(ប្រែថា គប្បីមាន, គប្បីជា)

## បរិកប្បនិបាត

ប្រយោគដែលមានប្រើកិរិយាស័ព្ទពួកសត្តមីវិភត្តិនេះ និយមប្រើបរិកប្បនិបាតនៅផ្នែកខាងដើម ។ ការប្រែជាភាសាខ្មែរ និបាតពួកនេះអាចលើកឡើងប្រែមុនបទប្រធានបានដែលមាន ៦ ស័ព្ទគឺ

**ស័ព្ទបាលី** **ពាក្យប្រែ**

**ចេ** បើ (ត្រូវតែរៀងដាក់ទី ២ បន្ទាប់ពីស័ព្ទឯទៀត) ។

**សចេ** បើ, ប្រសិនបើ ។

**យទិ** បើ, ប្រសិនបើ, ប្រសិនបើជា, ទោះបី, លុះតែ, បើថា ។

**អថ** បើ, បើជា ។

**អប្បេវនាម** ធ្វើម្ដេចហ្ន៎, គិតដូចម្ដេចហ្ន៎ ។

**យន្នូន** បើដូច្នោះ, បើដូច្នោះមានតែ, ដូចម្ដេចហ្ន៎ ។

(ចាប់ពី **សចេ** ដល់ **យន្នូន** អាចរៀងដាក់នៅដើមប្រយោគបាន)

# ឧទាហរណ៍នៃការប្រើ

១. *ប្រើប្រាប់សេចក្ដីយល់ឃើញ* (**អនុមតិ** Potential)

១. **គាមំ គច្ឆេយ្យាម** ។ (*យើង*) *គួរតែទៅ កាន់ផ្ទះ* ។

២. **<u>ន</u> ភជេ បាបកេ មិត្តេ** ។ (*ឯង*) *<u>មិន</u>គួរគប់រក មិត្រ.ទ. អាក្រក់<u>ទេ</u>* (*បាបមិត្ត*) ។

២. *ប្រើប្រាប់សេចក្ដីកំណត់* (**បរិកប្ប** Conditional)

១. **យន្នូនាហំ** < ( **យន្នូន** + **អហំ** ) **បព្វជេយ្យំ** ។

*បើដូច្នោះ ខ្ញុំ គប្បីបួស* ។

☸ **បព្វជេយ្យំ** *ជាឧត្តមបុរិសឯកវចនៈខាងអត្តនោបទ* ។

២. **សចេ បុគ្គលោ បុញ្ញំ ករេយ្យ, សោ សុគតឹ គច្ឆតិ** ។

*ប្រសិនបើ បុគ្គល គួរតែធ្វើ នូវបុណ្យ, គេ(បុគ្គលនោះ) រមែងទៅ កាន់សុគតិ* ។

៣. **យទិ មយំ នគរេ វិហរេយ្យាម តេបិ នគរំ អាគច្ឆេយ្យុំ** ។

*ប្រសិនបើ យើង រស់នៅ ក្នុងទីក្រុង គេ.ទ. នឹងមក ទីក្រុងដែរ* ។

☸ *ប្រសិនបើប្រយោគណាផ្ដើមជាមួយ* **សចេ** *ឬ* **យទិ** *ជួនកាលគប្បីប្រែប្រយោគសង្កាត់ខាងដើមជាបច្ចុប្បន្នកាល និងសង្កាត់ខាងចុងជាអនាគតកាលដូចឧទាហរណ៍លេខ ២ និង ៣ ខាងលើ* ។

# បដិសេធវិធី

*វិធីធ្វើការបដិសេធប្រយោគក្នុងភាសាបាលីត្រូវប្រើ* **ន** *ស័ព្ទប្រែថា "មិន......ទេ" ដាក់ខាងដើមកិរិយាស័ព្ទឬខាងដើមនៃប្រយោគ ដូចក្នុងឧទាហរណ៍ទី ២ ខាងលើ ។* **ន** *ស័ព្ទអាចប្រើបដិសេធសេចក្ដីបានជាទូទៅដូចជា* **កសកោ ខេត្តំ ន កសតិ ។** *រីកសិករ មិនភ្ជួររាស់ នូវស្រែទេ ។*

*នៅមាននិបាតបដិសេធខ្លះទៀតដែលអាចប្រើដូច* **ន** *ស័ព្ទបាន ។*

## វិភត្តិសម្រេចរូបរបស់ ឥ ការន្តឥត្ថីលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ឥ | ឥយោ, ឦ |
| *ទុ.* | ឥំ | ឥយោ, ឦ |
| *ត.* | ឥយា | ឦហិ, ឦភិ |
| *ច.* | ឥយា | ឦនំ |
| *បញ្ច.* | ឥយា, អ្យា | ឦហិ, ឦភិ |
| *ឆ.* | ឥយា | ឦនំ |
| *ស.* | ឥយា, ឥយំ, អ្យំ | ឦសុ |
| *អា.* | ឥ | ឥយោ, ឦ |

## កំណាត់សម្គាល់

*ស្រៈដូចគ្នាពីរតួនៅជាប់គ្នាត្រូវលុបមួយតួចេញ ឧ.* (**ភូមិ** + **ឥ**) > **ភូមិ** *។ ចំពោះបឋមា, ទុតិយានិងអាលបនវិភត្តិពហុវចនៈត្រូវលុបស្រៈ* **ឥ** *នៃនាមស័ព្ទចេញ ឧ.* (**ភូមិ** + **ឥយោ**) > **ភូមិយោ** *។ ចំពោះ* **អ្យា** *និង* **អ្យំ** *រាល់ពេលផ្សំជាមួយនាមស័ព្ទ ត្រូវស្រៈទីបំផុតនាមនិងលុបតួ* **អ** *ចេញ ឧ.* (**ភូមិ** + **អ្យា**) > **ភូម្យា** *។*

## វិធីបំបែក ភូមិ =ផែនដី, ឥ ការន្តឥត្ថីលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ភូមិ | ភូមិយោ, ភូមី |
| *ទុ.* | ភូមឹ | ភូមិយោ, ភូមី |
| *ត.* | ភូមិយា | ភូមីហិ, ភូមីភិ |
| *ច.* | ភូមិយា | ភូមីនំ, |
| *បញ្ច.* | ភូមិយា, ភូម្យា | ភូមីហិ, ភូមីភិ |
| *ឆ.* | ភូមិយា | ភូមីនំ |
| *ស.* | ភូមិយា, ភូមិយំ, ភូម្យំ | ភូមីសុ |
| *អា.* | ភូមិ | ភូមិយោ, ភូមី |

## នាមសព្ទ ឥ ការន្តឥត្ថីលិង្គ

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| សតិ | សតិ | មតិ | ការដឹង, មតិ |
| កិត្តិ | ល្បីល្បាញ, កេរ្តិ៍ | ធរិ | សម្បុរស្បែក |
| រតិ | ភាពរីករាយ | សត្តិ | ភ្លៅ |
| រត្តិ | យប់, រាត្រី | កដិ | ចង្កេះ |
| កុដិ | ខ្ទម, កុដិ | ខន្តិ | ការអត់ធ្មត់, ខន្តី |
| គណ្ឋិ | ពគាំង | វតិ | របង |
| ឩមិ | រលក | ជល្លិ | កំទេចឈើ |
| តន្តិ | សណ្ឋាន, បែប | ជឡិ | ភាពភ្លើតភ្លើន |
| លទ្ធិ | ទំនៀម, លទ្ធិ | សន្ធិ | ការត |
| បញ្ហិ | កែងជើង | អាណិ | ស្នឹង |
| ឥទ្ធិ | ឫទ្ធិ | ឦតិ | ចង្រៃ, អន្តរាយ |
| ឧក្ខលិ | ឆ្នាំងបាយ | យដ្ឋិ | ឈើច្រត់ |

## ធាតុគណៈទី ១ (ត)

| ធាតុ | ពាក្យប្រែ | ធាតុ | ពាក្យប្រែ |
|---|---|---|---|
| សិក្ខ | រៀន, សិក្សា | ផុស | ប៉ះ, ស្ទាប |

| | | | |
|---|---|---|---|
| វហ | នាំទៅ | ឆមស្ស | ថ្វាយបង្គំ |
| អាគម | មក | វាយម | ព្យាយាម |
| វន្ទ | សំពះ, ថ្វាយបង្គំ | កីឡ | លេង |
| អនុ+សាសុ | បង្រៀន | ជារ | រត់ |
| ឱ + វទ | ទូន្មាន, ប្រដៅ | ពន្ធ | ចង |
| រុប | ដាំ, បណ្ដុះ | អាសីស | ប៉ុនប៉ង, ប្រាថ្នា |
| ជីវ | រស់នៅ | បត | ធ្លាក់ |
| គេ | ច្រៀង | រក្ខ | រក្សា, ថែទាំ |

## លំហាត់នៃមេរៀនទី ៥

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើពួក **ជិរ** ធាតុមានអ្វីជាបច្ច័យហើយមានអំណាចដូចម្ដេចខ្លះ ?

២. បើចុះបច្ច័យជាមួយធាតុទោលឬធាតុមួយព្យាង្គតើត្រូវធ្វើដូចម្ដេច ?

៣. បើទីបំផុតធាតុជា **ច** និងចុះ **យ** បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?

៤. បើទីបំផុតធាតុជា **ជ** និងចុះ **យ** បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?

៥. បើទីបំផុតធាតុជា **ឆ** និងចុះ **យ** បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?

៦. បើទីបំផុតធាតុជា **ឆ** និងចុះ **យ** បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?

៧. បើទីបំផុតធាតុជា **ប** និងចុះ **យ** បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?

៨. បើទីបំផុតជាតុជា វ និងចុះ យ បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?
៩. បើទីបំផុតជាតុជា ស និងចុះ យ បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?
១០. បើទីបំផុតជាតុជា ហ និងចុះ យ បច្ច័យមកតើត្រូវធ្វើដូចម្ដេច ?
១១. តើសត្តមីវិភត្តិអាខ្យាតខាងបរស្សបទមានអ្វីខ្លះ ?
១២. តើ ឯយ្យ វិភត្តិអាចផ្លាស់ជា ឯ បានឬទេ ? សូមឱ្យឧទាហរណ៍ ។
១៣. សត្តមីវិភត្តិជាអនុត្តកាលមានវិធីប្រើ ២ យ៉ាងតើមានឈ្មោះហៅ ដូចម្ដេចខ្លះ ?
១៤. តើសត្តមីវិភត្តិមានកិរិយានុគ្រោះសម្រាប់ប្រែដូចម្ដេចខ្លះ ?
១៥. តើប្រយោគដែលប្រើសត្តមីវិភត្តិនិយមប្រើជាមួយនិបាតពួកណា, មានប៉ុន្មានស័ព្ទ, គឺអ្វីខ្លះ ?

**ខ. ចូរបំបែកជាតុស័ព្ទទាំងឡាយខាងក្រោមនេះជាមួយសត្តមីវិភត្តិខាងបរស្សបទទាំង ៣ បុរិសៈ**

១. បច, ២. ភុជ, ៣. កុជ, ៤. មុច, ៥. លភ ។

**គ. ចូរបំបែកនាមស័ព្ទខាងក្រោមនេះជាមួយវិភត្តិនានាទាំងពីរវចនៈឱ្យត្រូវតាមលិង្គនោះៗ**

១. សតិ, ២. រត្តិ, ៣. មតិ, ៤. កុដិ, ៥. ខន្តិ ។

**ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ**

១. ឧបាសកា បសាទេន ធម្មំ សិក្ខេយ្យុំ ។
២. កុមារា ច កុមារិយោ ច រត្តិយំ ឃរស្មឹ វសេយ្យុំ ។

៣. យទិ កុមារោ ចាបំ ចរេយ្យ តំ(វា) ឱវទេយ្យ ។

៤. សចេ ត្វំ(អ្នក) ឱទនំ បចេយ្យាសិ អហំ(ខ្ញុំ) តំ (បាយនោះ) កុញ្ជេយ្យាមិ ។

៥. សចេ មយំ(យើង) សប្បុរិសា ភវេយ្យាម បុត្តាបិ(ដែរ) សប្បុរិសា ភវេយ្យុំ ។

៦. សចេ សោ យានំ លភេយ្យ, នគរំ គច្ឆេ ។

៧. តុម្ហេ(អ្នក.ទ.) ចាបេ មិត្តេ មា ភជេថ, បណ្ឌិតំ ភជេថ ។

៨. យទិ អហំ សប្បី បស្សេយ្យាមិ, ទារកស្ស ទេយ្យាមិ ។

៩. សប្បុរិសា ទីឃជីវន្តោ(មានអាយុវែង) ហោន្តុ, បុត្តា សុខិនោ ភវន្តុ ។

១០. អាចរិយោ សិស្សេ ឱវទតិ ច អនុសាសតិ ច ។

១១. អហំ តារវេន ពុទ្ធញ្ច ធម្មំ សង្ឃំ នមស្សាមិ ។

១២. បុរិសា ទារិយា សទ្ធឹ ចរន្តិ ។

១៣. តុម្ហេ ព្យាធយោ មា ហោថ ។

១៤. ន ភជេ ចាបកោ មិត្តេ ។

១៥. សចេ តុម្ហេ រុក្ខេ រោបេយ្យថ ទារកា ផលានិ កុញ្ជេយ្យុំ ។

*ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ឯង មិនគួរទៅ ជាមួយ គេទេ ។*

*២. អ្នក មិនគួរធ្វើ កម្ម ដែលអាក្រក់ទេ ។*

៣. អ្នក.ទ. គប្បីសិក្សា នូវភាសាបាលី ។
៤. សូមអ្នក.ទ. ទទួលទាន នូវអាហារ ក្នុងផ្ទះ របស់ខ្ញុំ (**មម**) ។
៥. ប្រសិនបើ នាង(=**សា**) ចម្អិន នូវនូវបាយ, ខ្ញុំ នឹងបរិភោគ ។
៦. ប្រសិនបើ ឯង ព្យាយាម, ឯង នឹងជា បណ្ឌិត ក្នុងពេលឆាប់ ៗ
(**ខិប្បំ**) ។
៧. ប្រសិនបើ អ្នក មាន មតិ, សូម និយាយចុះ ។
៨. ចូរឯង ញ៉ាំ នូវបាយ ក្នុងផ្ទះ ។
៩. អ្នក.ទ. សូមឱ្យ នូវកម្រងផ្កា ដល់កញ្ញា ។
១០. ប្រសិនបើ អ្នក សុំ ខ្ញុំ នឹងឱ្យ ។
១១. ប្រសិនបើ យើង មើល ជាមួយភ្នែក, យើង នឹងឃើញ នូវរូប ។
១២. ប្រសិនបើ អ្នក ច្រៀង កុមារ.ទ. នឹងច្រៀង ។
១៣. នៃកុមារ.ទ. កុំ គប្បីលេង ក្នុងទឹក ។

**(ចប់មេរៀនទី ៥)**

# មេរៀនទី ៦

## អធិប្បាយអំពីអាខ្យាតកិរិយា, សព្វនាម និងនាមស័ព្ទ (ត)

## វិធីបំបែកធាតុពួកទី ៤ (ពួក សុ ធាតុ)

*ធាតុស័ព្ទពួកទី ៤ គឺពួក សុ ធាតុ* (Forth conjugation) *។ ធាតុពួកនេះមានវិធីរូបសិទ្ធិដូចពួក ក្វ ធាតុដែរ ដែលមាន* ណា, ណុ, ឧណា *ជាបច្ច័យ ។*

## វិធីរូបសិទ្ធិជាកិរិយាកត្តុវាចក:

*ការប្រកបរូបជាកិរិយាកត្តុវាចក:ត្រូវធ្វើតាមរូបមន្តដូច្នេះ*

(*ធាតុ* + ណា, ណុ *បច្ច័យ* + *វិភត្តិ*) > *កិរិយាស័ព្ទ*

សុ *ធាតុប្រែថា "ស្តាប់" និង* វត្តមានាវិភត្តិ

| *បុរិស:* | *ឯកវចន:* | *ពហុវចន:* |
|---|---|---|
| *ប.បុ.* | សុណាតិ, សុណោតិ | សុណន្តិ, សុណោន្តិ |
| *ម.បុ.* | សុណាសិ, សុណោសិ | សុណាថ, សុណោថ |
| *ឧ.បុ.* | សុណាមិ, សុណោមិ | សុណាម, សុណោម |

# កំណត់សម្គាល់

១. **ណា** បច្ច័យត្រូវទុកឱ្យគង់រូបដើមពុំចាំបាច់ផ្លាស់ប្តូរទេ ដូចជា **សុណាតិ, សុណាសិ, សុណាមិ, សុណាម, សុណាតុ** ។ល។

២. **ណា** បច្ច័យបើផ្សំជាមួយ **អន្តិ, អន្តុ** វិភត្តិត្រូវរស្សៈស្រៈ **អា** នៃ **ណា** ជា **អ** ទៅជា **ណ** ហើយត្រូវលុប **អ** នៃ **អន្តិ, អន្តុ** (បញ្ចមីវិភត្តិ) ឱ្យសល់ត្រឹមតែ **ន្តិ, ន្តុ** ដូចជា (**សុ** + **ណា** + **អន្តិ**) > **សុណន្តិ**, (**សុ** + **ណា** + **អន្តុ**) > **សុណន្តុ** ។

៣. បើចុះសត្តមីវិភត្តិក៏ត្រូវរស្សៈដែរដូចជា (**សុ** + **ណា** + **ឯយ្យ**) > **សុណេយ្យ** ។ល។

៤. **ណុ** បច្ច័យត្រូវព្រឹទ្ធិ **ឧ** នៃ **ណុ** ជា **ឱ** ទៅជា **ណោ** ដូចជា (**សុ** + **ណុ** + **តិ**) > **សុណោតិ**, (**សុ** + **ណុ** + **អន្តិ**) > **សុណោន្តិ** ។

៥. រីឯ **ឧណា** ឃើញនិយមប្រើជាមួយធាតុណាដែលច្រើនព្យាង្គ ដូចជា (**សក** + **ឧណា**) > **សក្កុណាតិ** ត្រូវតម្រួតទីបំផុតធាតុ **ក** > **ក្ក**) =អាច, អង់អាច ។ (**ប** + **អប** + **ឧណា**) > **ចាបុណាតិ** =ដល់ ។

៦. ចំពោះ **សុ** ធាតុដែលប្រែថា "ស្តាប់" បើចុះបច្ច័យផ្សេងទៀត មានអត្ថនិងវិធីផ្លាស់ប្តូរច្រើនទៀត ។ ធាតុក្នុងពួកនេះក៏អាចជាធាតុពួកឯទៀតផងដែរ គឺអាស្រ័យតែការចុះបច្ច័យទេ ។

ខាងក្រោមនេះជាធាតុខ្លះដែលបំបែកដូច **សុ** ធាតុ ។ ធាតុពួកនេះពុំសូវមានច្រើនទេ ។

# ធាតុស័ព្ទក្នុងពួកទី ៨ (ពួកសុធាតុ)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| វុ | ក្រង | សិ | ចង |
| ខិប | បោះបោល | ខី | អស់, អស់ទៅ |
| តិ | ច្រៀង, បំពេរ | អសុ | ហូរទៅ |
| សម្ភ | សម្រេច, ដល់ | សក | អាច, អង់អាច |
| អាប | ជ្រាបចូល | ប + អប | ដល់ |

# វិធីបំបែកធាតុពួកទី ៥ (ពួក ក៏ ធាតុ)

*ធាតុស័ព្ទពួកទី ៥ គឺពួក* **ក៏** *ធាតុ* (Fifth conjugation) *។ ធាតុពួកនេះមានវិធីរូបសិទ្ធិដូចពួក* **ភូ** *ធាតុដែរ មាន* **ណា** *ជាបច្ច័យ ។*

# វិធីរូបសិទ្ធិកិរិយាជាកត្តុវាចក:

*ការប្រកបរូបជាកិរិយាកត្តុវាចក:ត្រូវធ្វើតាមរូបមន្តដូច្នេះ*

*(ធាតុ +* **ណា** *បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ*

**ជិ** *ធាតុប្រែថា "ឈ្នះ" និង* **វត្តមានាវិភត្តិ**

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | **ជិនាតិ** | **ជិនន្តិ** |
| ម.បុ. | **ជិនាសិ** | **ជិនាថ** |
| ឧ.បុ. | **ជិនាមិ** | **ជិនាម** |

## កំណត់សម្គាល់

១. **នា** បច្ច័យត្រូវទុកឱ្យគង់រូបដើមគឺពុំចាំបាច់ផ្លាស់ប្តូរទេ ដូចជា **ជិនាតិ, ជិនាសិ, ជិនាតុ** ។ល។

២. **នា** បច្ច័យបើផ្សំជាមួយ **អន្តិ, អន្តុ** វិភត្តិត្រូវរស្សៈស្រៈ **អា** នៃ **នា** ជា អ ទៅជា ន រួចត្រូវលុប អ នៃ **អន្តិ, អន្តុ** ឱ្យសល់ត្រឹមតែ **ន្តិ, ន្តុ** ដូចជា (**ជិ** + **នា** + **អន្តិ**) > **ជិនន្តិ**, (**ជិ** + **នា** + **អន្តុ**) > **ជិនន្តុ** ។

៣. បើចុះសត្តមីវិភត្តិក៏ត្រូវរស្សៈដែរដូចជា (**ជិ** + **នា** + **ឯយ្យ**) > **ជិនេយ្យ** ។

៤. ចំពោះ **គី** ធាតុត្រូវផ្លាស់ **នា** បច្ច័យជា **ណា** ហើយអាចអនុវត្តតាម **ណា** បច្ច័យនៃពួក **សុ** ធាតុដែរដូចជា (**គី** + **នា** > **ណា** + **តិ**) > **គីណាតិ** ជាដើម ។ ការណ៍ដែលឱ្យផ្លាស់ **នា** > **ណា** ដូច្នេះ គឺចំពោះតែធាតុណាដែលមានទីបំផុតជា រ ប៉ុណ្ណោះ ។ បើតាមរូបស័ព្ទដើមខាងសំស្ក្រឹត **គី** ធាតុមានរូបជា **ក្រី** តែត្រូវលុបតួ រ ចេញទើបឱ្យផ្លាស់ **នា** > **ណា** ។ សូមចំណាំ **វិក្កីណាតិ** ក៏សម្រេចមកពី **គី**

ធាតុដែរដោយចុះ វិ ឧបសគ្គខាងដើម ។ ធាតុក្នុងពួកនេះក៏អាចជាធាតុក្នុងពួកឯទៀតដែរ គឺអាស្រ័យតែការចុះបច្ច័យប៉ុណ្ណោះ ។

ខាងក្រោមនេះជាធាតុខ្លះដែលបំបែកដូច ជិ ធាតុ គឺមានពុំសូវច្រើនទេ ។

## ធាតុសព្ទក្នុងពួកទី ៨ (កីធាតុ)

| ធាតុសព្ទ | ពាក្យប្រែ | ធាតុសព្ទ | ពាក្យប្រែ |
|---|---|---|---|
| កី | ទិញ | ជិ | ឈ្នះ |
| ថុ | សរសើរ,ស្ញើច | លុ | ច្រូតកាត់ |
| ចិ | សន្សំ, បេះ | ធុ | រោយ, ប្រោះ(ទឹក) |
| ញា > ជា | ដឹង, បេះ | វិ + កី | លក់ |

## សព្វនាម (Pronouns)

ពាក្យថា "សព្វនាម" តាមរូបសព្ទប្រែថា "ឈ្មោះទាំងពួង, ឈ្មោះគ្រប់យ៉ាង" ជាពាក្យមួយប្រភេទក្នុងវេយ្យាករណ៍ បានដល់ ពាក្យប្រើជំនួសឈ្មោះមនុស្ស, សត្វនិងវត្ថុផ្សេង ៗ ទូទៅ ។ ក្នុងភាសាខ្មែរយើង ដូចជាពាក្យថា "ព្រះអង្គ, លោក, នាង, គេ, គាត់, វា, ឯង, អា, ហង, ខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំបាទ, អញ, អាត្មា, អាត្មាភាព, យើង" ជាដើម ហៅថា **សព្វនាម** សម្រាប់ប្រើជំនួសអ្នកដែលគេនិយាយដល់ និងនិយាយខ្លួន

ឯង ត្រូវលើកស័ព្ទណាមួយមកប្រើឱ្យសមតាមឋានៈឬកម្រិតវណ្ណៈរបស់បុគ្គលនោះ ៗ ដែលជាពាក្យទាប, ពាក្យកណ្ដាលឬពាក្យខ្ពស់, ជារាជស័ព្ទ ឬជាសាមញ្ញស័ព្ទប្រើជំនួសឈ្មោះដែលគេបានពោលរួចម្ដងហើយ ឧទាហរណ៍ "ពូសុខ ទើបមក ពីស្រែ, ពីព្រោះ គាត់ ភ្ជួររួចហើយ" ។

ពាក្យថា **គាត់** ក្នុងប្រយោគក្រោយជាសព្វនាមប្រើជំនួសពាក្យថា "ពូសុខ" ។ បើនិយាយថា "ពូសុខ ទើបមក ពីស្រែ, ពីព្រោះ ពូសុខ ភ្ជួររួចហើយ" ។ ដូច្នេះឃើញថាពោលពាក្យ "ពូសុខ" ផ្ទួនគ្នាពីរដងស្ដាប់ពុំសូវពិរោះត្រចៀកដូចប្រើសព្វនាមទេ ។ ចំណែកសព្វនាមខាងភាសាបាលីវិញមិនមានពាក្យជារាជស័ព្ទឬសាមញ្ញ ឬជាពាក្យទាប, កណ្ដាល ឬក៏ពាក្យខ្ពស់ទេ ។

សព្វនាមភាសាបាលីមាន ២ ប្រភេទគឺ **បុរិសសព្វនាម** (Personal pronoun) និង **វិសេសនសព្វនាម** (Indefinite pronoun) ។

## ១. បុរិសសព្វនាម

## (Personal pronouns)

បុរិសសព្វនាមមាន ៣ ស័ព្ទគឺ **ត**, **តុម្ហ**, **អម្ហ** ចែកជា ៣ បុរិសៈ ដូច្នេះ

១. **ត** (He, she, it, they) ស័ព្ទប្រែថា "ព្រះអង្គ, លោក, នាង, គេ,

គាត់, វា" ជាដើម ប្រើជំនួសជនដែលមិននៅក្នុងការសន្ទនាគឺជា **បឋម-បុរិសសព្វនាម** ត្រូវនឹង (Third personal pronoun) របស់អង់គ្លេស ។

២. **តុម្ហ** (You) ស័ព្ទប្រែថា "ព្រះអង្គ, លោក, អ្នក, នាង, ឯង, អា, ហង" ជាដើម ប្រើជំនួសជនដែលកំពុងចូលរួមក្នុងការសន្ទនាគឺ **មជ្ឈិម-បុរិសសព្វនាម** ត្រូវនឹង (Second personal pronoun) របស់អង់គ្លេស ។

៣. **អម្ហ** (I, we) ស័ព្ទប្រែថា "ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំម្ចាស់, ខ្ញុំបាទ, នាងខ្ញុំ, ខ្ញុំ, អាត្មាភាព, អាត្មា, អញ, យើង, យើងខ្ញុំ" ជាដើម ប្រើជំនួសឈ្មោះជនដែលនិយាយខ្លួនឯងជា **ឧត្តមបុរិសសព្វនាម** ត្រូវនឹង (First personal pronoun) របស់អង់គ្លេស ។

(ចំពោះវិសេសនសព្វនាមនឹងមានអធិប្បាយនៅខាងមុខ)

## វិធីបំបែកបុរិសសព្វនាម

(Declension of personal pronoun)

## វិធីបំបែក ត សព្វនាម

(Declension of Third personal pronoun)

ត សព្វនាមអាចបំបែកបានទាំង ៣ លិង្គ ។ ក្នុងលិង្គខ្លះមានវិភត្តិសម្រេចរូបប្លែកពីវិភត្តិសម្រេចរូបនៃនាមស័ព្ទបន្តិច ដូចខាងក្រោមនេះ

## វិភត្តិសម្រេចរូបរបស់ ត សព្វនាមជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឱ | ឯ |
| ទុ. | អំ | ឯ |
| ត. | ឯន | ឯហិ, ឯភិ |
| ច. | អស្ស | ឯសំ, ឯសានំ |
| បញ្ច. | អស្មា, អម្ហា | ឯហិ, ឯភិ |
| ឆ. | អស្ស | ឯសំ, ឯសានំ |
| ស. | អស្មឹ, អម្ហិ | ឯសុ |

## វិធីបំបែក ត សព្វនាមជាបុំលិង្គ

(Ta as Masculine)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សោ | តេ |
| ទុ. | តំ, នំ | តេ, នេ |
| ត. | តេន | តេហិ, តេភិ |
| ច. | តស្ស, អស្ស | តេសំ, តេសានំ, នេសំ, នេសានំ |
| បញ្ច. | តស្មា, តម្ហា, អស្មា | តេហិ, តេភិ |

| | | |
|---|---|---|
| ឆ. | តស្ស, អស្ស | តេសំ, តេសានំ, ឯសំ, ឯសានំ |
| ស. | តស្មិំ, តម្ហិ, អស្មិំ | តេសុ |

## កំណត់សម្គាល់

*សព្វនាមទាំងអស់មិនមាន អាលបនវិភត្តិ ទេ ។ កាលបើយក ត ស័ព្ទមកផ្សំជាមួយវិភត្តិសម្រេចរូបខាងលើនេះអាចផ្លាស់ ត > ស ដូចជា សោ, ត > អ ដូចជា អស្ស, ត > ឯ ដូចជា ឯ ជាដើម ។*

## វិភត្តិសម្រេចរូបរបស់ ត សព្វនាមជាឥត្ថីលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | *អា* | *អា* |
| *ទុ.* | *អំ* | *អា* |
| *ត.* | *អាយ* | *អាហិ, អាភិ* |
| *ច.* | *អស្សា, ឥស្សា, ឥស្សាយ* | *អាសំ, អាសានំ* |
| *បញ្ច.* | *អាយ* | *អាហិ, អាភិ* |
| *ឆ.* | *អស្សា, ឥស្សា, ឥស្សាយ* | *អាសំ, អាសានំ* |
| *ស.* | *អាយំ, អស្សំ, ឥស្សំ* | *អាសុ* |

# វិធីបំបែក ត សព្វនាមជាឥត្ថីលិង្គ

(Ta as Feminine)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សា | តា |
| ទុ. | តំ, នំ | តា |
| ត. | តាយ | តាហិ, តាភិ |
| ច. | តស្សា, តិស្សា, តិស្សាយ, អស្សា | តាសំ, តាសានំ |
| បញ្ច. | តាយ | តាហិ, តាភិ |
| ឆ. | តស្សា, តិស្សា, តិស្សាយ, អស្សា | តាសំ, តាសានំ |
| ស. | តាយំ, តស្សំ, តិស្សំ, អស្សំ | តាសុ |

## កំណត់សម្គាល់

*កាលបើយក ត ស័ព្ទមកផ្សំជាមួយវិភត្តិសម្រេចរូបខាងលើនេះ អាចផ្លាស់ ត > ស, ត > អ, ត > ន បានដូចក្នុងបុំលិង្គដែរ ។*

# វិធីបំបែក ត សព្វនាមជានបុំសកលិង្គ

(Ta as Neuter)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | តំ < ( ត + អំ ) | តានិ < ( ត + អានិ ) |
| ទុ. | តំ < ( ត + អំ ) | តានិ < ( ត + អានិ ) |

ចាប់ពីតតិយាវិភត្តិដល់សត្តមីវិភត្តិមានរូបដូចបុំលិង្គទាំងអស់ ។

# វិធីបំបែក តុម្ហ សព្វនាម

( Declension of Second personal pronoun )

តុម្ហ ស័ព្ទមានវិធីបំបែកតែមួយបែបដូចគ្នាទាំងបីលិង្គដូចខាងក្រោម

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ត្វំ, តុវំ | តុម្ហេ, តុម្ហំ, តុម្ហានំ, វោ |
| ទុ. | តំ, ត្វំ, តុវំ | តុម្ហេ,តុម្ហំ,តុម្ហានំ,តុម្ហាកំ,វោ |
| ត. | តយា, ត្វយា, តេ | តុម្ហេហិ, វោ |
| ច. | តុយ្ហំ, តុម្ហំ, តវ, តេ | តុម្ហាកំ, វោ |
| បញ្ច. | តយា | តុម្ហេហិ, វោ |
| ឆ. | តុយ្ហំ, តុម្ហំ, តវ, តេ | តុម្ហាកំ, វោ |
| ស. | តយិ, ត្វយិ | តុម្ហេសុ |

## កំណត់សម្គាល់

*តាមការបំបែកខាងលើនេះឃើញថា តុម្ហ ស័ព្ទបានប្រែផ្លាស់រូបទៅជាផ្សេង ៗ ចាកពីរូបដើមយ៉ាងច្រើន ជាពិសេសខាងឯកវចនៈ។ តេ, វោ ស័ព្ទមិនអាចរៀងដាក់ខាងដើមនៃប្រយោគបានទេ ត្រូវតែរៀងទី ២ បន្ទាប់ពីស័ព្ទដទៃជានិច្ច ។*

## វិធីបំបែក អម្ហ សព្វនាម

( Declension of First personal pronoun )

*ដូច តុម្ហ ស័ព្ទដែរ អម្ហ មានវិធីបំបែកតែមួយបែបដូចគ្នាទាំងបីលិង្គដូចខាងក្រោមនេះ*

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | អហំ | មយំ,អម្ហេ,អម្ហំ,អម្ហាកំ,នោ |
| *ទុ.* | មំ, មមំ | អម្ហេ,អម្ហំ,អម្ហាកំ,អម្ហាកំ,នោ |
| *ត.* | មយា, មេ | អម្ហេហិ, នោ |
| *ច.* | មយ្ហំ,អម្ហំ,មម,មមំ,មេ | អម្ហាកំ, អស្មាកំ, នោ |
| *បញ្ច.* | មយា | អម្ហេហិ, នោ |
| *ឆ.* | មយ្ហំ,អម្ហំ,មម,មមំ,មេ | អម្ហាកំ, អស្មាកំ, នោ |
| *ស.* | មយិ | អម្ហេសុ |

## កំណត់សម្គាល់

តាមការបំបែកខាងលើនេះឃើញថា អម្ហ សព្វនាមប្រែផ្លាស់រូបទៅជាផ្សេង ៗ ចាកពីរូបដើមយ៉ាងច្រើនខាងឯកវចនៈ ។ មេ, នោ សព្វនាមមិនអាចរៀងនៅខាងដើមនៃប្រយោគបានទេ ត្រូវតែរៀងទី ២ ជានិច្ច ។

មូលហេតុដែល តេ, វោ, មេ, នោ មិនអាចរៀងខាងដើមនៃប្រយោគបាននោះ ពីព្រោះកុំឱ្យច្រឡំនឹង ៣ សព្វនាមខាងក្រោមនេះ

តេ ប្រែថា គេ (ជាបឋមបុរិសសព្វនាមប្រើជាបទប្រធាន) ។

វោ ប្រែថា វ៉ឺយ (អាលបននិបាត) ។

នោ ប្រែថា មិន......ទេ (បដិសេធនិបាត) ។

## វិធីប្រើនិងប្រែសព្វនាម

១. អាចរិយោ$_{១}$ សិស្សានំ$_{៤}$ ឱវាទំ$_{២}$ ទេតិ$_{៣}$, តេ$_{១}$ តស្ស$_{៤}$ ឱវាទេ$_{២}$ តិដ្ឋន្តិ$_{៣}$។ រីអាចារ្យ$_{១}$ កំពុងឱ្យ$_{៣}$ នូវឱវាទ$_{២}$ ដល់សិស្ស.ទ.$_{៤}$., រីសិស្ស.ទ.$_{១}$ កំពុងតាំងនៅ$_{៣}$ ក្នុងឱវាទ$_{២}$ របស់គាត់$_{៤}$ ។

២. សចេ ត្វំ$_{១}$ តស្ស$_{៤}$ រថំ$_{២}$ វិក្កិណេយ្យាសិ$_{៣}$, អហំ$_{១}$ តំ$_{២}$ កិណាមិ$_{៣}$។ ប្រសិនបើ អ្នក$_{១}$ គប្បីលក់$_{៣}$ នូវរថ$_{២}$ របស់អ្នក$_{៤}$, ខ្ញុំ$_{១}$ នឹងទិញ$_{៣}$ នូវវា$_{២}$ ។

៣. តុម្ហេ$_{១}$ បុញ្ញំ$_{២}$ ចិនេយ្យាថ$_{៣}$, សុគតឹ$_{២}$ គច្ឆថ$_{៣}$។ អ្នក.ទ.$_{១}$

*គប្បីសន្សំ₃ នូវបុណ្យ₆, (អ្នក.ទ.)₁ នឹងទៅ₃ កាន់សុគតិ₆ ។*

**៤. ត្វំ₁ កញ្ញាយ₄ ឧក្ខលឹ₆ ហរ₃, សា₁ ឱទនំ₆ បចតិ₃។** *ឯង₁ ចូរនាំទៅ₃ នូវឆ្នាំង₆ ដល់កញ្ញា₄, នាង₁ នឹងចម្អិន₃ នូវបាយ₆ ។*

## វិធីបំបែកនាមស័ព្ទ (គ)

## វិធីបំបែកនាមស័ព្ទ ឦ ការន្ត

(Declension of noun in ī-stem)

*នាមស័ព្ទ ឦ ការន្តមានក្នុងលិង្គពីរគឺ បុំលិង្គនិងឥត្ថីលិង្គ មានវិធីបំបែកដូចតទៅនេះ*

### វិភត្តិសម្រេចរូបរបស់ ឦ ការន្តបុំលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ឦ | ឥនោ, ឦ |
| *ទុ.* | ឥំ, ឥនំ | ឥនោ, ឦ |
| *ត.* | ឥនា | ឦហិ, ឦភិ |
| *ច.* | ឥស្ស, ឥនោ | ឦនំ |
| *បញ្ច.* | ឥស្មា, ឥម្ហា | ឦហិ, ឦភិ |

| | | |
|---|---|---|
| ឆ. | ឥស្ស, ឥនោ | ឦនំ |
| ស. | ឥស្មឹ, ឥម្ហិ | ឦសុ |
| អា. | ឥ | ឥនោ, ឦ |

## វិធីបំបែក សេដ្ឋី =សេដ្ឋី ឦ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សេដ្ឋី | សេដ្ឋិនោ, សេដ្ឋី |
| ទុ. | សេដ្ឋឹ, សេដ្ឋិនំ | សេដ្ឋិនោ, សេដ្ឋី |
| ត. | សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ |
| ច. | សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |
| បញ្ច. | សេដ្ឋិស្មា, សេដ្ឋិម្ហា | សេដ្ឋីហិ, សេដ្ឋីភិ |
| ឆ. | សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |
| ស. | សេដ្ឋិស្មឹ, សេដ្ឋិម្ហិ | សេដ្ឋីសុ |
| អា. | សេដ្ឋិ | សេដ្ឋិនោ, សេដ្ឋី |

## កំណត់សម្គាល់

*ការបំបែកនាមស័ព្ទ ឦ ការន្តបុំលិង្គមានគតិដូច ឥ ការន្តបុំលិង្គ ស្មើរតែទាំងអស់ មានប្លែកគ្នាតែត្រង់ បឋមា, ទុតិយា និង អាលបនវិភត្តិ*

*ពហុវចនៈប៉ុណ្ណោះដែលជា* **ឥនោ** *និង អាលបនវិភត្តិឯកវចនៈជា* **ឦ** *។ មានវិធីផ្សំដូច្នេះ (***សេដ្ឋី + ឦ***) >* **សេដ្ឋី***, (***សេដ្ឋី + ឥនោ***) >* **សេដ្ឋិនោ** *ស្រៈពីរតួដូចគ្នាត្រូវលុបមួយតួចេញ ។*

## នាមសព្ទ ឦ ការន្តបុំលិង្គ

| បាលី | ពាក្យប្រែ | បាលី | ពាក្យប្រែ |
|---|---|---|---|
| **ករី** | *ដាង* | **ភាណី** | *អ្នកពោល, អ្នកសូត្រ* |
| **មន្តី** | *អ្នកមានការគិត, មន្ត្រី* | **មេធាវី** | *អ្នកមានបញ្ញា* |
| **ហត្ថី** | *ដំរី* | **ភោគី** | *អ្នកមានភោគ* |
| **សុខី** | *អ្នកមានសេចក្តីសុខ* | **តបសី** | *អ្នកមានតបៈ* |
| **ឆណ្ឌី** | *អ្នកកាន់ឈើច្រត់* | **សិខី** | *ក្ងោក* |
| **សាមី** | *ប្តី, ម្ចាស់* | **កេកី** | *ក្ងោក* |
| **បក្ខី** | *សត្វស្លាប, បក្សី* | **វឌ្ឍកី** | *ជាងឈើ* |
| **សសី** | *ដួងចន្ទ* | **សារថី** | *អ្នកបររទេះ* |
| **ចាណី** | *សត្វលោក* | **បាបការី** | *អ្នកធ្វើអំពើបាប* |
| **ធាឋី** | *សត្វមានចង្កូម* | **ឆត្តី** | *អ្នកកាន់ឆ័ត្រ* |
| **ទីឃជីវី** | *អ្នកមានអាយុវែង* | **កុដ្ឋី** | *អ្នកកើតឃ្លង់* |
| **ពលី** | *អ្នកមានកំលាំង* | **មាលី** | *អ្នកមានកម្រងផ្កា* |

## វិភត្តិសម្រេចរូបរបស់ ឦ ការន្តឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឦ | ឥយោ, ឦ |
| ទុ. | ឥំ, ឥយំ | ឥយោ, ឦ |
| ត. | ឥយា | ឦហិ, |
| ច. | ឥយា | ឦនំ |
| បញ្ច. | ឥយា | ឦហិ, ឦភិ |
| ឆ. | ឥយា | ឦនំ |
| ស. | ឥយា, ឥយំ | ឦសុ |
| អា. | ឥ | ឥយោ, ឦ |

## កំណត់សម្គាល់

*សូមមើលការបំបែកខាងក្រោមឃើញថាមានដំណើរដូច* ឥ *ការន្តឥត្ថីលិង្គស្ទើរតែទាំងអស់ មានប្លែកគ្នាតែត្រង់បឋមាវិភត្តិឯកវចនៈជា* ឦ *ប៉ុណ្ណោះ ។ ស្រៈពីរតួស្មើគ្នាត្រូវលុបមួយតួចេញ ។ មានវិធីផ្សំដូច្នេះ ឧ.* (**នារី** + **ឦ**) > **នារី**, ( **នារី** + **ឥយោ** ) > **នារិយោ** ។

*នាមសព្ទជា* ឦ *ការន្តមានតែក្នុងពីរលិង្គទេ គឺបុំលិង្គ និង ឥត្ថីលិង្គ ។*

## វិធីបំបែក ជារី =ស្រី, នារី ក្នុង ការន្តឥត្ថីលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ជារី | ជារិយោ, ជារី |
| *ទុ.* | ជារឹ, ជារិយំ | ជារិយោ, ជារី |
| *ត.* | ជារិយា | ជារីហិ, ជារីភិ |
| *ច.* | ជារិយា | ជារីនំ |
| *បញ្ច.* | ជារិយា | ជារីហិ, ជារីភិ |
| *ឆ.* | ជារិយា | ជារីនំ |
| *ស.* | ជារិយា, ជារិយំ | ជារីសុ |
| *អា.* | ជារិ | ជារិយោ, ជារី |

## នាមស័ព្ទ ក្នុង ការន្តឥត្ថីលិង្គ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| ជី | *ស្រី* | នទី | *ស្ទឹង, ទន្លេ* |
| ឥត្ថី | *ស្រី* | ឃរណី | *ស្រីមេផ្ទះ* |
| តរុណី | *ស្រីក្មេង* | វាបី | *បឹង* |
| បឋវី | *ដី* | កណ្ឌី | *រគាំង* |
| សិម្ពលី | *ដើមរកា* | បោក្ខរណី | *ស្រះ, ត្រពាំង* |

| | | | |
|---|---|---|---|
| កុមារី | *ក្មេងស្រី* | មាតុលានី | *មីង (ខាងម្ដាយ)* |
| កាឡលី | *ចេក* | ជានី | *ទីក្រុង* |
| ព្រាហ្មណី | *ព្រាហ្មណ៍ស្រី* | ភិក្ខុនី | *ភិក្ខុនី* |
| ជននី | *ម្ដាយ* | វិជនី | *ផ្លិត* |
| មហី | *ផែនដី* | រាជិនី | *ស្ដេចស្រី* |
| គាវី | *គោញី* | មាណវី | *ស្រីក្រមុំ* |

## លំហាត់នៃមេរៀនទី ៦

***ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ***

*១. តើពួក* **សុ** *ធាតុមានបច្ច័យអ្វីខ្លះ ?*

*២. តើពួក* **កី** *ធាតុមានបច្ច័យអ្វីខ្លះ ?*

*៣. តើ* **សព្វនាម** *មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?*

*៤. តើ* **បុរិសសព្វនាម** *មានប៉ុន្មានស័ព្ទ ? គឺអ្វីខ្លះ ?*

*៥. តើ* **បុរិសសព្វនាម** *មានបទអាលបនវិភត្តិឬទេ ?*

*៦. ចូរបំបែក* ត, តុម្ហ និង អម្ហ *សព្វនាមជាបុំលិង្គ ។*

***ខ. ចូរបំបែកធាតុស័ព្ទទាំងឡាយខាងក្រោមនេះជាមួយបញ្ចមីនិង សត្តមីវិភត្តិខាងបរស្សបទទាំងបីបុរិសនិងទាំងពីរវចនៈ***

១. សុ, ២. ជិ, ៣. កី, ៤. ញា ។

*គ. ចូរបំបែកនាមស័ព្ទខាងក្រោមនេះជាមួយវិភត្តិនានាទាំងពីរវចនៈ ឱ្យត្រូវតាមលិង្គនោះ ៗ*

១. បក្ខី, ២. មន្តី, ៣. កុមារី, ៤. កិត្តុជី, ៥. ឥត្ថី ។

*ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. សចេ កស្សកោ វីហិយោ វិក្កិណេយ្យ, វាណិជោ តំ កិណេយ្យ ។

២. សចេ តុម្ហេ បព្វតំ អារុហេយ្យាថ, ឧទកំ ច បទុមានិ ច សិលាយោ ច បស្សេយ្យាថ ។

៣. សចេ ត្វំ បត្តេ ចានីយំ( *ទឹកផឹក*) អានេយ្យាសិ, សោ បិវេយ្យ ។

៤. សចេ សោ វេជ្ជោ ភវេយ្យ អហំ តំ អានេយ្យាមិ ។

៥. តុម្ហេ បទុមានិ ឱចិនេយ្យាថ, តេហិ ពុទ្ធំ បូជេថ ។

៦. យទិ ត្វំ ធម្មំ សុណេយ្យាសិ អទ្ធា( *ពិតៗ*),ត្វំ ពុទ្ធស្ស សាវកោ ភវេយ្យាសិ ។

៧. មា មនុស្សេ ភាយតុ, សចេ សោ សច្ចំ ជានាតិ, ភាសតុ ។

៨. បុត្ត, មា ត្វំ ចាបមិត្តេ ឧបសង្កម( *ចូលទៅជិត*) ។

៩. មា ជារកោ ចានីយំ បត្តំ ភិន្ទ ។

១០. ឧបាសកា, មា បុត្តេ អក្កោសថ( *ជេរ*), សមណេហិ សទ្ធឹ តេ អនុសាសថ ។

១១. តេ វាណិជានំ កត្តំ បចន្តុ ។

១២. តុម្ហេ រថេន នគរំ គច្ឆថ ។

១៣. មយំ ធម្មំ សិក្ខាម ។

១៤. មា តេ ឧយ្យានម្ហិ(សួន) បុប្ផានិ ឱចិន្តុ ។

១៥. តុម្ហេ សច្ចំ ភាសថ ។

## ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. មនុស្ស.ទ. ក្នុងលោក កុំគប្បីប្រព្រឹត្ត នូវអំពើអាក្រក់ ។

២. ទឹក ធ្លាក់ ពីភ្នំ, បក្សី.ទ. ហើរ ចេញពីដើមឈើ ។

៣. ខ្ញុំ ឃើញ កំណប់ នៃទ្រព្យ ក្នុងព្រៃ ។

៤. ប្រសិនបើ មនុស្ស.ទ. ក្នុងលោក ប្រព្រឹត្ត នូវអំពើល្អ គេ.ទ. រមែង រួច ចាកទុក្ខ ។

៥. រស្មី នៃបញ្ញា រមែងភ្លឺ ជាងរស្មី នៃព្រះអាទិត្យ ។

៦. គេ.ទ. គប្បីរៀន ភាសាបាលី ។

៧. សូមឱ្យអ្នកប្រាជ្ញ ពោល នូវធម៌ ដល់ឧបាសក.ទ. ។

៨. សូមឱ្យខ្ញុំ និយាយ នូវមតិ របស់ខ្ញុំ ។

៩. តសី.ទ. កំពុងរស់នៅ ក្នុងព្រៃ ។

១០. គ្រូពេទ្យ កំពុងរក្សា នូវអ្នកជំងឺ ។

១១. ព្រះសង្ឃ.ទ. គប្បីរក្សា សីល.ទ. ។

១២. កាយ នៃមនុស្ស.ទ. រមែងស្លាប់ ។

១៣. ប្រសិនបើ ជន.ទ. មិន ប្រព្រឹត្ត នូវអំពើល្អ ទេ, គេ.ទ. នឹងធ្លាក់ក្នុងអន្ទង់ ។

១៤. អ្នកបរទេះ ចូរអ្នក នាំយក ស្រូវ (ទៅ)កាន់ផ្ទះ របស់ខ្ញុំ ។

១៥. ផ្កាយ.ទ. រះ ឰដ៏អាកាស ។

(ចប់មេរៀនទី ៦)

# មេរៀនទី ៧

## អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត)

### (៤.) ហីយត្តនីវិភត្តិ

### (Indefinite Past endings)

| | បរស្សបទ | | | អត្តនោបទ | |
|---|---|---|---|---|---|
| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* | *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
| *ប.បុ.* | អា | ឩ | *ប.បុ.* | ត្ថ | ត្ថុំ |
| *ម.បុ.* | ឱ | ត្ថ | *ម.បុ.* | សេ | វ្ហំ |
| *ឧ.បុ.* | អំ | ម្ហ, ម្ហា | *ឧ.ប.* | ឥំ | ម្ហសេ |

## កំណត់សម្គាល់

*វិភត្តិណាមានតួ* **អ** *វេលាផ្សំជាមួយធាតុត្រូវលុបតួ* **អ** *ចេញនិង ស្រៈពេញតួត្រូវផ្លាស់ជាស្រៈនិស្ស័យវិញ ។* **ហីយត្តនី** *ប្រែថា "***មាន ហើយក្នុងថ្ងៃម្សិល***" ។ វិភត្តិពួកនេះប្រើប្រាប់អំពើដែលកើតមានហើយ ក្នុងថ្ងៃម្សិល មានកិរិយានុគ្រោះប្រែថា "...ហើយ" ។ វិភត្តិពួកនេះនិយម ចុះ* **អ** *អាគមខាងដើមធាតុ ។ ប្រសិនបើមាន* **អ** *អាគមប្រែថា "បាន... ហើយ" ។ ម្យ៉ាងទៀតបើមាន* **មា** *ស័ព្ទដែលប្រែថា "កុំ" យោគចូលផង*

ត្រូវផ្លាស់ពាក្យប្រែថា "...ហើយ" ទៅជា "កុំ.......ឡើយ" វិញ ។

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

ការប្រកបរូបកិរិយាជាមួយហីយត្តនីវិភត្តិ មានទំនងដូចវត្តមានាវិភត្តិដែរ ប្រើធាតុណាមួយក៏បាន តែត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយជានិច្ច ដូចមានរូបមន្តខាងក្រោមនេះ

(អ អាគម) + ធាតុ + បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ

សៀវភៅរៀនភាសាបាលីជាភាសាអង់គ្លេសប្រាប់ថាហីយត្តនីវិភត្តិនេះ មិនសូវមានប្រើទេគឺនិយមប្រើ អជ្ជត្តនីវិភត្តិ វិញ ។ ដូច្នេះជាការល្អប្រសិនបើអ្នកសិក្សាប្រាថ្នាប្រើកិរិយាស័ព្ទប្រាប់អំពើនានា ដែលកើតក្នុងអតីតកាល សូមប្រើ អជ្ជត្តនីវិភត្តិ ដែលមានអធិប្បាយនៅខាងមុខ ។

ចូរមើលវិធីបំបែក វច ធាតុ (ពោល, និយាយ), អ បច្ច័យជាមួយហីយត្តនីវិភត្តិខាងបរស្សបទកត្តុវាចកៈទាំងបីបុរិសៈដូចខាងក្រោមនេះ

## ធាតុវិភាគឬវិធីបំបែកធាតុ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ | អវចា, អវច, អវចោ | អវចូ |
| ម.បុ | អវចោ, | អវចត្ថ |
| ឧ.បុ | អវចំ | អវចម្ហ, អវចម្ហា |

(ប្រែថា បានពោលហើយ)

## កំណត់សម្គាល់

១. ធាតុដទៃទៀតគប្បីធ្វើតាមវិធី **វច** ធាតុនេះ ។ ប៉ុន្តែបើជាពួក **រុធ** ធាតុ ត្រូវចុះនិគ្គហិតអាគមសិន រួចទើបផ្លាស់និគ្គហិតនោះដូចក្នុងវគ្គមានាវិភត្តិដែរ ដូចជា **កុធ** > **អកុញ្ជា** ជាដើម ។

២. បច្ច័យណាដែលជាស្រៈឬមានទីបំផុតជាស្រៈ ប្រសិនបើផ្សំជាមួយវិភត្តិដែលផ្ដើមដោយស្រៈ ត្រូវលុបស្រៈនៃបច្ច័យចោល ឧ. (**អ** + **វច** + **អ** + **អា** ) > **អវចា** ប្រែថា (គេ)បានពោលហើយ ។

៣. **អា** ហីយត្តនីវិភត្តិបឋមបុរិសឯកវចនៈនិយមវស្សៈជា **អ** ឧ. (**អ** + [**ភូ** > **ភវ**] + **អ** + **អា** ) > **អភវ**,. (**អ** + **វច** + **អ** + **អា** ) > **អវច**, **អវោច** (វស្សៈ **អា** ជា **អ**,. យក **អ** នៃ **វ** របស់ **វច** ជា **ឧ** រួចផ្លាស់ជា **ឱ** ទៅជា **អវោច** ។

៤. ចំពោះ **ម្ហ** វិភត្តិពហុវចនៈក៏មានទីឃៈជា **ម្ហា** ដែរដូច **អបច្ចម្ហា** ជាដើម ។

៥. មានធាតុស័ព្ទខ្លះអាចមានរូបច្រើនយ៉ាងដូចជា **គម** ធាតុក្នុងបឋមបុរិសៈអាចមានរូបជា **អគច្ឆា**, **អគមា**, **អគា** =បានទៅហើយ (**អ** + **គម** + **អ** + **អា** ) ។ **ទិស** ធាតុផ្លាស់រូបជា **អទ្ទសា** =បានឃើញហើយ (**អ** + **ទិស** + **អ** + **អា**) ។ **ហរ** លុបទីបំផុតធាតុទៅជា **អហា**

=បាននាំទៅហើយ (**អ** + **ហរ** + **អ** + **អា**) ។ **ករ** លុបទីបំផុតធាតុ និងបច្ច័យចោលដែរជា **អកា** =បានធ្វើហើយ (**អ** + **ករ** + **អ** + **អា**) ។

៦. កាលពីដើមហីយត្តនីវិភត្តិនេះប្រើប្រាប់អតីតកាលមិនកំណត់ ចំណែកអជ្ជត្តនីវិភត្តិប្រើប្រាប់អតីតកាលកន្លងហើយថ្មី ៗ ។ ប៉ុន្តែក្រោយមកក៏ប្រើអជ្ជតនីវិភត្តិប្រាប់អតីតកាលមិនកំណត់ផងដែរ ។

## ឧទាហរណ៍នៃការប្រើ

**១. ពុទ្ធោ₁ ឥមំ₄ សុភាសិតំ₂ អវោច₃។**

ព្រះពុទ្ធ₁ បានត្រាស់ហើយ₃ នូវសុភាសិត₂ នេះ₄ ។

**២. ខណោ₁ វោ₂ មា ឧបច្ចគា₃។**

ខណៈ₁ កុំកន្លងបង់₃ នូវអ្នក.ទ.₂ ឡើយ ។

**ឧបច្ចគា** មកពី (**ឧប** + **អតិ** + **អ** + **គម** + **អ** + **អា**) ផ្លាស់ **ឥ** នៃ **អតិ** ជា **យ** ទៅជា **អតយ** ហើយផ្លាស់ **តយ** ជា **ត្យ** ជា **ច្ច** តាមវិធីសន្ធិ ហើយលុប **ម** ទីបំផុតធាតុបានទៅជា **ឧបច្ចគា** ។

## វិធីបំបែកធាតុពួកទី ៦ (ពួក គហ ធាតុ)

ធាតុសព្ទពួកទី ៦ គឺពួក **គហ** ធាតុ (Sixth conjugation) ។ ធាតុពួកនេះមានវិធីរូបសិទ្ធិដូចពួក **ក្វ** ធាតុដែរនិងមាន **ណ្ហា**, **ប្ប** ជាបច្ច័យ ។

ធាតុក្នុងគណៈនេះមានតែមួយសព្ទគត់គឺ **គហ** ក្រៅពីនេះសុទ្ធតែចុះឧបសគ្គពីខាងដើម **គហ** ធាតុទាំងអស់ ។

## វិធីរូបសិទ្ធិកិរិយាជាកត្តុវាចកៈ

ការប្រកបរូបជាកិរិយាកត្តុវាចកត្រូវធ្វើតាមរូបមន្តដូច្នេះ

(ធាតុ + **ណ្ហា**, **ប្ប** បច្ច័យ + វិភត្តិ) > កិរិយាសព្ទ

**គហ** ធាតុប្រែថា "កាន់យក" និង

**វត្តមានាវិភត្តិ**ខាងបរស្សបទ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ | **គណ្ហាតិ** | **គណ្ហន្តិ** |
| ម.បុ | **គណ្ហាសិ** | **គណ្ហាថ** |
| ឧ.បុ | **គណ្ហាមិ** | **គណ្ហាម** |

## កំណត់សម្គាល់

១. **គហ** ធាតុកាលបើផ្សំជាមួយ **ណ្ហា** បច្ច័យត្រូវលុបទីបំផុតធាតុគឺ **ហ** ចេញ ទុកនៅតែ **គ** ដូច្នេះ (**គហ** > **គ**) + **ណ្ហា** + **តិ** > **គណ្ហាតិ** =កាន់យក ។ **គហ** ធាតុនេះបើចុះ **ប្ប** បច្ច័យត្រូវផ្លាស់ធាតុទាំងមូលជា **ឃេ** (**គហ** > **ឃេ**) + **ប្ប** + **តិ** > **ឃេប្បតិ** ប្រែដូចគ្នា ។

២. **ណ្ហា** *បច្ច័យបើផ្សំជាមួយវិកត្តិដែលជាស្រៈនៅខាងដើមដូចជា* **អន្តិ, អន្តុ, ឯយ្យ, ឯយ្យុំ** *ជាដើមគប្បីលុបស្រៈ* **អា** *នៃ* **ណ្ហា** *ចេញឱ្យសល់ត្រឹម* **ណ្ហ** *ហើយលុប* **អ** *នៃ* **អន្តិ, អន្តុ** *ចេញឱ្យនៅសល់ត្រឹមតែ* **ន្តិ, ន្តុ** *និងផ្លាស់* **ឯយ្យ, ឯយ្យុំ** *ជា* **េយ្យ, េយ្យុំ** *ដូចជា* **គណ្ហន្តិ, គណ្ហន្តុ, គណ្ហេយ្យ, គណ្ហេយ្យុំ** *ជាដើម ។*

## ធាតុសព្ទក្នុងពួកទី ៦ (គហធាតុ)

*ខាងក្រោមនេះជាធាតុខ្លះដែលបំបែកដូច* **គហ** *ធាតុនេះ ពុំសូវមានច្រើនទេ ។*

| *ធាតុសព្ទ* | *បំបែកជា* | *ពាក្យប្រែ* |
|---|---|---|
| **ឧ + គហ** | **ឧគ្គណ្ហាតិ** | *រៀន* |
| **អនុ + គហ** | **អនុគ្គណ្ហាតិ** | *អនុគ្រោះ* |
| **បដិ + គហ** | **បដិគ្គណ្ហាតិ** | *ទទួល* |
| **សំ + គហ** | **សង្គណ្ហាតិ** | *សង្គ្រោះ* |

*ចំណាំ* **គហ** *ធាតុនេះនៅក្នុងបករណ៍រៀនភាសាបាលីជាភាសាអង់គ្លេសមិនចាត់ជាពួកធាតុមួយដាច់តែឯងទេ គឺគេរាប់បញ្ចូលក្នុងពួក* **កី** *ធាតុដោយបែងចែកធាតុត្រឹមតែ ៧ ពួកប៉ុណ្ណោះ ។*

*កាលបើចុះឧបសគ្គខាងដើមហើយ និយមតម្រួតដើមធាតុជា* **គ្គ** *ដូចមានឧទាហរណ៍នៅខាងលើស្រាប់ ។*

# វិធីបំបែកធាតុពួកទី ៧ (ពួក តន ធាតុ)

# វិធីរូបសិទ្ធិជាកិរិយាកត្តុវាចកៈ

ធាតុសព្ទពួកទី ៧ គឺពួក **តន** ធាតុ (Seventh conjugation) ។ ធាតុពួកនេះមានវិធីរូបសិទ្ធិដូចពួក **ភូ** ធាតុដែរនិងមាន **ឱ, យិរ** ជាបច្ច័យ ។ ការប្រកបរូបជាកិរិយាកត្តុវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ

(ធាតុ + **ឱ, យិរ** បច្ច័យ + វិភត្តិ) > កិរិយាសព្ទ

**ករ** ធាតុប្រែថា "ធ្វើ" និង

វត្តមានាវិភត្តិខាងបរស្សបទ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | **ករោតិ** | **ករោន្តិ** |
| ម.បុ. | **ករោសិ** | **ករោថ** |
| ឧ.បុ. | **ករោមិ** | **ករោម** |

## កំណត់សម្គាល់

១. ធាតុពួកនេះ បើចុះវិភត្តិដែលមានស្រៈខាងដើមដូចជា **អន្តិ**, **អន្តុ** ត្រូវលុប **អ** ចេញដូចជា (**ករ** + **ឱ** + **អន្តិ** ) > **ករោន្តិ**, ( **ករ** + **ឱ** + **អន្តុ** ) > **ករោន្តុ** ។

២. បើចុះពួកសត្តមីវិភត្តិត្រូវលុប ឱ បច្ច័យចេញដូចជា (**ការ** + **ឱ** + **ឯយ្យ**) > **ការេយ្យ** ជាដើម ។

## ធាតុស័ព្ទក្នុងពួកទី ៧ (តនធាតុ)

ខាងក្រោមនេះជាធាតុខ្លះដែលបំបែកដូច **ការ** ធាតុនេះ ពុំសូវមានច្រើនទេ ។

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| **តង** | ផ្សាយ, ត្រដាង | **ជាគរ** | ដាស់តឿន |
| **ការ** | ធ្វើ | **វិ+អា+ការ > ព្យាការ** | ទាយ |
| **សក្ក** | អាច, ហ៊ាន | **ប + អប** | ដល់, សម្រេច |

## វិធីបំបែកធាតុពួកទី ៨ (ពួក ចុរ ធាតុ)

ធាតុសព្ទ័ពួកទី ៨ គឺពួក **ចុរ** ជាតុ (Eighth cojugation) ។ ធាតុពួកនេះមានវិធីរូបសិទ្ធិដូចពួក **ភូ** ធាតុដែរនិងមាន **ណេ**, **ណយ** ជាបច្ច័យ ។ បច្ច័យណាមានតួ **ណ** មានអំណាចឱ្យទីឃៈស្រៈដើមធាតុបានដូចមានវិធីផ្សំខាងក្រោមនេះ

## វិធីរូបសិទ្ធិជាកិរិយាកត្តុវាចក:

ការប្រកបរូបជាកិរិយាកត្តុវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ

(ធាតុ + ណេ, ណយ បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ

ចុរ ធាតុប្រែថា "លួច" និង

វត្តមានាវិភត្តិខាងបរស្សបទ

| បុរិសៈ | ឯកវចនៈ | | ពហុវចនៈ | |
|---|---|---|---|---|
| ប.បុ. | ចោរេតិ | ចោរយតិ | ចោរេន្តិ | ចោរយន្តិ |
| ម.បុ. | ចោរេសិ | ចោរយសិ | ចោរេថ | ចោរយថ |
| ឧ.បុ. | ចោរេមិ | ចោរយាមិ | ចោរេម | ចោរយាម |

## កំណត់សម្គាល់

ការបំបែកធាតុស័ព្ទពួកទី ៨ នេះគឺមានវិធីផ្លាស់ប្តូរ ៣ បែបគឺ

១. បច្ច័យណាដែលជាប់ដោយតួ ណ គឺជាណានុពន្ធបច្ច័យដូចជា ណេ, ណយ បើចុះក្នុងធាតុណាត្រូវតែលុបតួ ណ ចេញឱ្យសល់នៅត្រឹមតែស្រៈ េ- និង យ ដូចជា (ចុរ + ណេ + តិ) > ចោរេតិ,. (ចុរ + ណយ + តិ) > ចោរយតិ ។

២. កាលបើលុបតួ ណ ហើយ ប្រសិនបើស្រៈដើមធាតុជាស្រៈរស្សៈ គឺស្រៈ អ, ឥ, ឧ និងប្រសិនបើគ្មានព្យញ្ជនៈពីរតួឬសំយោគនៅខាងចុងធាតុទេ គឺត្រូវទីឃៈឬព្រឹទ្ធិ ស្រៈដើមធាតុដូចខាងក្រោមនេះ

## ១. វិធីទីឃៈស្រៈ

អ > អា ដូចជា (វច + ណោ + តិ) > វាចេតិ ពោល, និយាយ ។

ឥ > ឦ ដូចជា ( ឥជិ + ណោ + តិ ) > ឦជេតិ ខ្លាច ។

ឧ > ឩ ដូចជា (គុប + ណាយ + តិ ) > គូបយតិ គ្រប់គ្រង ។

## ២. វិធីព្រឹទ្ធិស្រៈ

ឥ > ឯ ដូចជា (ទិស + ណោ + តិ ) > ទេសេតិ សំដែង ។

ឧ > ឱ ដូចជា (ចុរ + ណោ + តិ ) > ចោរេតិ លួច ។

## ៣. វិធីពុំចាំបាច់ទីឃៈដើមធាតុ

ដូចជា (មន្ត + ណោ + តិ ) > មន្តេតិ ជជែក, ពិភាក្សា ។

ដូចជា (វញ្ច + ណោ + តិ ) > វញ្ចោតិ ប្រវញ្ចន៍, បោក ។

៣. ប្រសិនបើខាងដើមធាតុជាស្រៈទីឃៈស្រាប់ពុំចាំបាច់ធ្វើអ្វីទេដូច

( តីរ + ណោ + តិ ) > តីរេតិ គិតសាឡើងវិញ ។

( បូជ + ណោ + តិ ) > បូជេតិ ថ្វាយ, បូជា ។

( ចាល + ណោ + តិ ) > ចាលេតិ រក្សា, ការពារ ។

## ធាតុស័ព្ទក្នុងពួកទី ៨ (ចុរធាតុ)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| តក្ក | ត្រិះរិះ | ឆឌ្ឌ | ចោល, បោះចោល |
| ចាល | រក្សា, ថែទាំ | ជល | ដុត |
| បូជ | បូជា | ឆទ | គ្រប, ប្រក |
| គុហ | លាក់, បិទបាំង | លក្ខ | កំណត់ |
| ឱ+លោក | មើល | និ+មន្ត | អញ្ជើញ |
| ចិន្ត | គិត | បុរ | បំពេញ, ពេញ |
| ទិស | សំដែង | ធរ | ទ្រទ្រង់ |
| បីឡ | បៀតបៀន | កថ | ពោល, ប្រាប់ |
| វច | ពោល | ឧ + ឌី | ហើរ, ហោះ |
| មរ | ស្លាប់ | ឧ + ឥ | រះឡើង |

**❁ ឧ + ឥ > ឧទេតិ ។ ឧ + ឌិ ឬ ឌី > ឧឌ្ឌេតិ ។**

*វិធីប្រើនិងសរសេរឧបសគ្គចូររកមើលត្រង់កន្លែងដែលអធិប្បាយពីឧបសគ្គនៅខាងមុខ ។*

*ធាតុទាំងឡាយដែលបានពោលហើយនេះគឺពួក* **ភូ** *ធាតុមានធាតុច្រើនជាងគេបង្អស់ បន្ទាប់មកគឺពួក* **ចុរ** *ធាតុ ក្រៅពីនេះពុំសូវមានធាតុទេ ។ ចូររកអានសាឡើងវិញ ដើម្បីឱ្យមានជំនាញក្នុងការប្រកបរូបជាអាខ្យាតកិរិយាដើម្បីឱ្យរាល់ពេលបានជួបអាខ្យាតស័ព្ទណាមួយនាពេល*

ខាងមុខនឹងអាចយល់បានភ្លាមថាស័ព្ទអាខ្យាតនោះ ៗ សម្រេចមកពីធាតុ, បច្ច័យ, វិភត្តិអ្វី ។ រឿងវិភត្តិអាខ្យាតនេះនៅមានពោលក្នុងពេលខាងមុខទៀត ។

(វិធីបំបែកធាតុទាំង ៨ ពួកចប់ត្រឹមនេះ)

## វិធីបំបែកនាមស័ព្ទ ឧ ការន្ត

(Declension of noun ending in u-stem)

នាមស័ព្ទ ឧ ការន្តមានក្នុងបីលិង្គគឺ បុំលិង្គ, ឥត្ថីលិង្គនិងនបុំសកលិង្គ មានវិធីបំបែកដូចតទៅនេះ

### វិភត្តិសម្រេចរូបរបស់ ឧ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឧ | អវោ, ឩ |
| ទុ. | ឧំ | អវោ, ឩ |
| ត. | ឧនា | ឩហិ, ឩភិ |
| ប. | ឧស្ស, ឧនោ | ឩនំ |

| | | |
|---|---|---|
| បញ្ច | ឧស្មា, ឧម្ហា | ឩហិ, ឩភិ |
| .ឆ. | ឧស្ស, ឧនោ | ឩនំ |
| ស. | ឧស្មឹ, ឧម្ហិ | ឩសុ |
| អា. | ឧ | អវោ, អវេ |

## វិធីបំបែក គរុ =គ្រូ ឧ ការន្តបុំលិង្គ

(U stem as Masculine)

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| ប. | គរុ | គរវោ, គរូ |
| ទុ. | គរុំ | គរវោ, គរូ |
| ត. | គរុនា | គរូហិ, គរូភិ |
| ច. | គរុស្ស, គរុនោ | គរូនំ |
| បញ្ច. | គរុស្មា, គរុម្ហា | គរូហិ, គរូភិ |
| ឆ. | គរុស្ស, គរុនោ | គរូនំ |
| ស. | គរុស្មឹ, គរុម្ហិ | គរូសុ |
| អា. | គរុ | គរវោ, គរវេ |

*ចំពោះ បឋមា,ទុតិយានិងអាលបនវិភត្តិពហុវចនៈត្រូវលុបស្រៈ* ឧ *នៃនាមស័ព្ទចេញដូច្នេះ* (ភិក្ខុ + ឧ) > ភិក្ខវោ, *នេះផ្លាស់* ឧ *ជា* អវ ។

## នាមស័ព្ទ ឧ ការន្តបុំលិង្គ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| កេតុ | *ទង់* | ភិក្ខុ | *ភិក្ខុ, អ្នកបួស* |
| បសុ | *សត្វចិញ្ចឹម* | ពន្ធុ | *ញាតិសន្តាន* |
| រិបុ | *សត្រូវ* | សត្តុ | *សត្រូវ* |
| សេតុ | *ស្ពាន* | ហេតុ | *ហេតុ* |
| វេឡុ | *ដើមឫស្សី* | ផរសុ | *ពូថៅ, ដឹង* |
| ជន្តុ | *អ្នកកើត(គឺសត្វ)* | ពព្វុ | *ឆ្មា, ខ្លាត្រី* |

## វិភត្តិសម្រេចរូបរបស់ ឧ ការន្តឥត្ថីលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ឧ | ឧយោ, ឩ |
| *ទុ.* | ឧំ | ឧយោ, ឩ |
| *ត.* | ឧយា | ឩហិ, ឩភិ |
| *ច.* | ឧយា | ឩនំ |
| *បញ្ច.* | ឧយា | ឩហិ, ឩភិ |
| *ឆ.* | ឧយា | ឩនំ |
| *ស.* | ឧយា, ឧយំ | ឩសុ |
| *អា.* | ឧ | ឧយោ, ឩ |

# វិធីបំបែក យាគុ =បបរ ឧ ការន្តឥត្ថីលិង្គ

## (U stem as Feminine)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | យាគុ | យាគុយោ, យាគូ |
| ទុ. | យាគុំ | យាគុយោ, យាគូ |
| ត. | យាគុយា | យាគូហិ, យាគូភិ |
| ច. | យាគុយា | យាគូនំ |
| បញ្ច. | យាគុយា | យាគូហិ, យាគូភិ |
| ឆ. | យាគុយា | យាគូនំ |
| ស. | យាគុយា, យាគុយំ | យាគូសុ |
| អា. | យាគុ | យាគុយោ, យាគូ |

## នាមស័ព្ទ ឧ ការន្តឥត្ថីលិង្គ

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ឧរុ | ខ្សាច់ | វិជ្ជុ | ផ្លេកបន្ទោរ |
| ធេនុ | មេគោ | កាសុ | រណ្ដៅ |
| លាវុ | ឃ្លោក | រជ្ជុ | ខ្សែ |
| ធាតុ | ឆ្អឹង, ធាតុ | សស្សុ | ម៉ែក្មេក |

## វិភត្តិសម្រេចរូបរបស់ ឧ ការន្តនបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឧ | ឩនិ, ឩ |
| ទុ. | ឧំ | ឩនិ, ឩ |
| ត. | ឧនា | ឩហិ, ឩភិ |
| ច. | ឧស្ស, ឧនោ | ឩនំ |
| បញ្ច. | ឧស្មា, ឧម្ហា | ឩហិ, ឩភិ |
| ឆ. | ឧស្ស, ឧនោ | ឩនំ |
| ស. | ឧស្មឹ, ឧម្ហិ | ឩសុ |
| អា. | ឧ | ឩនិ, ឩ |

## វិធីបំបែក វត្ថុ=វត្ថុ ឧ ការន្តនបុំសកលិង្គ

(U stem as Neuter)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | វត្ថុ | វត្ថូនិ, វត្ថូ |
| ទុ. | វត្ថុំ | វត្ថូនិ, វត្ថូ |
| ត. | វត្ថុនា | វត្ថូហិ, វត្ថូភិ |
| ច. | វត្ថុស្ស, វត្ថុនោ | វត្ថូនំ |

| | | |
|---|---|---|
| បញ្ច. | វត្ថុស្មា, វត្ថុម្ហា | វត្ថូហិ, វត្ថូភិ |
| ឆ. | វត្ថុស្ស, វត្ថុនោ | វត្ថូនំ |
| ស. | វត្ថុស្មឹ, វត្ថុម្ហិ | វត្ថូសុ |
| អា. | វត្ថុ | វត្ថូនិ, វត្ថូ |

## កំណត់សម្គាល់

សូមសង្កេតមើលវិភត្តិសម្រេចខាងលើនេះគឺស្មើរតែដូច ឧ ការន្ត បុំលិង្គទាំងអស់ ។ មានប្លែកតែត្រង់ បឋមា, ទុតិយា និងអាលបនវិភត្តិពហុវចនៈជា ឧនិ ប៉ុណ្ណោះ ។

កាលបើយកនាមស័ព្ទ ឧ ការន្តនបុំសកលិង្គមកផ្សំជាមួយវិភត្តិសម្រេចខាងលើនេះ មានរបៀបដូច្នេះ (ចក្ខុ + ឧ) > ចក្ខុ, (ចក្ខុ + ឧនិ) > ចក្ខូនិ ។ ស្រៈពីរតួស្មើគ្នានៅជាប់គ្នាត្រូវលុបមួយតួចេញ ។

## នាមស័ព្ទ ឧ ការន្តនបុំសកបុំលិង្គ

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អម្ពុ | ទឹក | អស្សុ | ទឹកភ្នែក |
| អាយុ | អាយុ | មធុ | ទឹកឃ្មុំ |
| មស្សុ | ពុកមាត់ | ចក្ខុ | ភ្នែក, ចក្ខុ |

| | | | |
|---|---|---|---|
| ជតុ | ជ័រ, ល័ក្ខ | ជន្តុ | ជ្ជូ |
| សជ្ឈុ | ប្រាក់ | តិបុ | សំណ |
| អរុ | ដំបៅ | វបុ | អត្តភាព, រាងកាយ |
| ធាតុ | ឈើ, ឧស | ចារុ | មាស |

## កំណត់សម្គាល់

មាននាមសព្ទ ឧ ការន្តមួយពួកមិនអាចបំបែកតាមវិភត្តិសម្រេចរូបទាំងឡាយខាងលើនេះបានទេ គឺមានវិធីបំបែកដោយឡែកដែលនឹងអធិប្បាយនៅខាងមុខ ។

## នាមសព្ទ អ ការន្តបុំលិង្គ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អម្ព | ផ្លែស្វាយ | បណ្ណាការ | អំណោយ |
| អាបណ | ផ្សារ, ហាង | សិស្ស | សិស្ស |
| អារាម | អារាម, សួន | តឡាក | ត្រពាំង, ស្រះ |
| មាតុល | មា(ខាងម្ដាយ) | អាកាស | អាកាស |
| ឱរាន | ឱរាទ | ចន្ទ | ព្រះចន្ទ |
| មច្ឆ | ត្រី | សុរិយ | ព្រះសូរិយា |
| មញ្ច | គ្រែ | មគ្គិក | អ្នកដំណើរ |

# លំហាត់នៃមេរៀនទី ៧

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើ* ហីយត្តនី *ប្រែដូចម្ដេច ?*

*២. តើកិរិយាស័ព្ទដែលប្រកបនឹងហីយត្តនីវិភត្តិប្រើប្រាប់កាលអ្វី ?*

*៣. តើពួក* គហ *ធាតុមានអ្វីជាបច្ច័យ ?*

*៤. តើពួក* តន *ធាតុមានអ្វីជាបច្ច័យ ?*

*៥. តើពួក* ចុរ *ធាតុពេលចុះបច្ច័យមកត្រូវធ្វើដូចម្ដេច ?*

*ខ.ចូរបំបែកធាតុស័ព្ទទាំងឡាយនេះជាមួយ បញ្ចមី, សត្តមី និង ហីយត្តនីវិភត្តិខាងបរស្សបទទាំងបីបុរិសនិងទាំងពីរវចនៈ*

១. គហ, ២. ការ ។

*គ. ចូរបំបែកនាមស័ព្ទទាំងឡាយខាងក្រោមនេះជាមួយវិភត្តិនានា ទាំងពីរវចនៈឱ្យត្រូវតាមលិង្គនោះ ៗ*

១. ភិក្ខុ, ២. សត្តុ, ៣. ជេន្តុ, ៤. ធាតុ, ៥. ចក្ខុ ។

*ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. មយំ ពុទ្ធស្ស ធម្មំ អសុណាម្ហា ។

២. បុរិសា ច នារិយោ ច ឧបាសិកា ច មគ្គេន អចរុំ ។

៣. អហំ គហាបតិនោ ធនំ អលភំ ។

៤. ពុទ្ធោ លោកេ ឧប្បជ្ជិ ។

៥. មុនយោ មញ្ចេ សុ និសីទ ។

៦. អធិបតិ ភាណិជម្ហា មណយោ អកិណា ។

៧. កាបយោ គិរិម្ហា រុក្ខំ ជាវ ។

៨. តុម្ហេ ចាបកម្មំ ករោថ ។

៩. ពុទ្ធោ ឯវំ អាហ ។

១០. អាចរិយោ តំ ឥត្ថឹ អាហ ។

(អាហ =បានពោលហើយ)

ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. ព្រះពុទ្ធ បានសំដែងហើយ យ៉ាងនេះ ។

២. ផ្លៃឈើ បានធ្លាក់ហើយ ពីដើម លើដី ។

៣. មេគោ.ទ. មិនបានផឹក ទឹក ក្នុងស្រះ ទេ ។

៤. កូន.ទ. របស់កសិករ បានឱ្យហើយ នូវស្មៅ.ទ. ដល់មេគោ.ទ. ។

៥. ទឹកដោះ ក្នុងផ្ទាំង មិនមានទេ ។

៦. ម្នាលសំឡាញ់.ទ. ចូរអ្នក.ទ. ប្រគេន បបរ ដល់ភិក្ខុ.ទ. ។

៧. ឧបាសក.ទ. បានស្តាប់ហើយ នូវធម៌ ពីភិក្ខុ.ទ. ក្នុងសាលា ។

៨. ប្រសិនបើ ឯង ស្តាប់ នូវឱវាទ របស់ខ្ញុំ, ខ្ញុំ នឹងទៅ ជាមួយឯង ។

៩. នៃកុមារី.ទ. ចូរកុំផឹក នូវទឹកឃ្មុំ ។

១០. យើង.ទ. បានស្តាប់ហើយ នូវធម៌ ដោយគោរព ផង ដោយសេចក្តី

ជ្រះថ្លា ផង ។

(ចប់មេរៀនទី ៧)

# កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| រៀនបានចេះ | ចំណេះកើន | ចម្រើនហើយ |
| កុំកន្តើយ | ព្រងើយថា | គ្មានការភ្លេច |
| ត្រូវរក្សា | ការចាំចេះ | កុំឱ្យរេច |
| កុំឱ្យរិល | រិលជាភ្លេច | បាត់វិជ្ជា ។ |
| មិនភ្លេចបាន | គ្មានអ្វីជាង | ការសរសេរ |
| ការរិះរេ | និយាយស្ដី | សន្ទនា |
| ការជួញចិត្ត | គិតចង់ចេះ | រាល់វេលា |
| ការស្ដាយវា | ដែលបានរៀន | រួចមកហើយ ។ |

(មិនដឹងច្បាប់ដើម)

# មេរៀនទី ៨

## អធិប្បាយអំពីអាខ្យាតកិរិយានិងនាមស័ព្ទ (ត)

### ៤. អជ្ជតនីវិភត្តិ

(Definite Past endings)

| បរស្សបទ | | | អត្តនោបទ | | |
|---|---|---|---|---|---|
| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* | *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
| *ប.បុ.* | ឦ | ឩំ | *ប.បុ.* | អា | ឩ |
| *ម.បុ.* | ឱ | ត្ថ | *ម.បុ.* | សេ | វ្ហំ |
| *ឧ.បុ.* | តំ | ម្ហា | *ឧ.បុ.* | អំ | ម្ហេ |

*អជ្ជតនី ប្រែថា "មានក្នុងថ្ងៃនេះ" ។ វិភត្តិពួកនេះប្រើប្រាប់អំពើដែលកើតមានហើយក្នុងថ្ងៃនេះ មានពាក្យប្រែថា "...ហើយ" ។ ប្រសិនបើមាន អ អាគម ប្រែថា "បាន...ហើយ" ។*

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

*ការប្រកបរូបកិរិយាជាមួយអជ្ជតនីវិភត្តិ មានគតិដូចវត្តមានាវិភត្តិដែរ គឺប្រើធាតុណាមួយក៏បាន តែត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយជានិច្ច ។ វិភត្តិនេះមានវិធីបំបែកបាន ៣ បែប ។ ខាងក្រោមនេះជាគំរូបំបែកខាងបរស្សបទ ។*

# វិធីបំបែកបែបទី ១

របៀបទីមួយនេះគឺចុះវិភត្តិផ្ទាល់ជាមួយនឹងធាតុនិងជួនកាលមានចុះ អ អាគមផង ។ បើមានឧបសគ្គនាំមុខធាតុត្រូវចុះ អ អាគមត្រង់ចន្លោះឧបសគ្គនិងធាតុ ។ ខាងក្រោមនេះជាការបំបែក **បច** និង **គម** ធាតុ (**បច** + *អ* + **ឦ**) > **បចី** ។

## របៀបមិនមាន អ អាគម

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **បចី, បចិ** | **បចុំ, បចឹសុ** |
| *ម.បុ.* | **បចោ, បចិ** | **បចិត្ថ** |
| *ឧ.បុ.* | **បចឹ** | **បចិម្ហា** |

(*ប្រែថា ចម្អិនហើយ*)

## របៀបមាន អ អាគម

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **អគមី, អគមិ** | **អគមុំ, អគមឹសុ** |
| *ម.បុ.* | **អគមោ, អគមិ** | **អគមិត្ថ** |
| *ឧ.បុ.* | **អគមឹ** | **អគមិម្ហា** |

(*ប្រែថា ទៅហើយ*)

# របៀបបំបែក សុ ធាតុ

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | សុណី, អសុណី, សុណិ, អសុណិ | សុណឹសុ, អសុណឹសុ |
| *ម.បុ.* | សុណោ, អសុណោ, សុណិ, អសុណិ | សុណិត្ថ, អសុណិត្ថ |
| *ឧ.បុ.* | សុណឹ, អសុណឹ | សុណិម្ហា, អសុណិម្ហា |

(*ប្រែថា ស្តាប់ហើយ*)

## កំណត់សម្គាល់

*១. ធាតុណាមួយក៏ដោយត្រូវមានបច្ច័យប្រចាំពួកជាប់មកជាមួយជានិច្ច ។ ប៉ុន្តែបច្ច័យដែលជាស្រៈឬមានទីបំផុតជាស្រៈ វេលាផ្សំជាមួយវិភត្តិដែលផ្តើមដោយស្រៈ ត្រូវលុបបច្ច័យដែលជាស្រៈឬស្រៈនៃបច្ច័យចោលដូចជា* (**បច** + **អ** + **ឦ**) > **បចី** *។* **សុ** *ធាតុមាន* **ណា** *ជាបច្ច័យត្រូវលុប* **អា** *នៃ* **ណា** *ចេញ* (**សុ** + **ណា** + **ឦ**) > **សុណី** *។*

*២.* **ឦ** *បឋមបុរិសឯកវចនៈនិយមរស្សៈជា* **ឥ** *ដូច* **អគមិ** *។ បឋមបុរិសពហុវចនៈច្រើនផ្លាស់ជា* **ឥំសុ** *ដូចជា* **បចឹសុ** *ជាដើម ។*

*៣. មជ្ឈិមបុរិសឯកវចនៈ* **ឱ** *និយមផ្លាស់ជា* **ឥ** *ដូចជា* **អបចិ** *ជា*

ដើម ។

៤. មជ្ឈិមបុរិសពហុវចនៈនិងឧត្តមបុរិសពហុវចនៈត្រូវចុះ ឥ អាគមដូចជា **បចិត្ថ**, **អគមិម្ហា** ជាដើម ។

៥. អ អាគមមិនកំណត់ថាត្រូវតែចុះទេ ប៉ុន្តែសូមកុំច្រឡំជាមួយនឹង អ ដែលផ្លាស់មកពី ឍ អព្យយស័ព្ទ (មានវិធីផ្លាស់និងប្រើនៅខាងមុខ) ប្រែថា "មិន" ឱ្យសោះ ។

៦. ប្រសិនបើមានឧបសគ្គនាំមុខធាតុត្រូវចុះ អ អាគមត្រង់ចន្លោះឧបសគ្គនិងធាតុទាំង អជ្ជតនី និង ហីយត្តនី ដូច្នេះ

(**ប** + <u>**អ**</u> + **វិស** + **អ** + **ឡ**) > **ចាវិសិ** =ចូលទៅហើយ (អជ្ជ.) ។

(**អតិ** + <u>**អ**</u> + **គម** + **អ** + **អា**) > **អច្ចគា** =បានកន្លងទៅហើយ (ហី.) ។

❁ (**អតិ** > **អត្យ** > **អច្ច**) + **គម** ។

# វិធីបំបែកបែបទី ២

ការបំបែករបៀបពួកទីពីរនេះ គឺអនុវត្តចំពោះធាតុពួក **ចុរ** ធាតុដែលមានវិធី ២ បែបទៀតផង ។ ប្រសិនបើប្រើ **ណេ** បច្ច័យត្រូវចុះ **ស** អាគមចុងធាតុ ។ តែបើប្រើ **ណាយ** បច្ច័យមិនបាច់ចុះ **ស** អាគមទេ ដូចមានឧទាហរណ៍ខាងក្រោមនេះ

## របៀបបំបែក ចុរ ធាតុនឹង ណេ បច្ច័យ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | ចោរេសិ | ចោរេសុំ |
| ម.បុ. | ចោរេសិ | ចោរេសិត្ថ |
| ឧ.បុ. | ចោរេសី | ចោរេសិម្ហា |

## របៀបបំបែក ចុរ ធាតុនឹង ណយ បច្ច័យ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | ចោរយិ | ចោរយុំ, ចោរយឹសុ |
| ម.បុ. | ចោរយោ | ចោរយិត្ថ |
| ឧ.បុ. | ចោរយឹ | ចោរយិម្ហ, ចោរយិម្ហា |

(ប្រែថា លួចហើយ)

## វិធីបំបែកបែបទី ៣

ការបំបែករបៀបទី ៣ នេះគឺអនុវត្តចំពោះធាតុណាដែលមានទីបំផុតជាស្រៈ **អា** ដូចជា **ឌា**, **ហា** ជាដើម ។ ពួកនេះក៏ត្រូវចុះ **ស** អាគមដូចពួក **ចុរ** ធាតុដែរ ។

## របៀបបំបែក ឈា, ហា ធាតុ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អឈាសិ អជ្ឈាសិ | អឈំសុ អជ្ឈំសុ |
| ម.បុ. | អឈាសិ អជ្ឈាសិ | អឈត្ថ អជ្ឈត្ថ |
| ឧ.បុ. | អឈាសឹ អជ្ឈាសឹ | អឈម្ហា អជ្ឈម្ហា |

## កំណត់សម្គាល់

១. ចំពោះ **ការ** ធាតុប្រសិនបើចុះអជ្ជតនីវិភត្តិអាចផ្លាស់ជា **កាស** បានដូចជា **អកាសិ**, **អកំសុ** តែក៏អាចបំបែកតាមបែបទីមួយបានដែរ ដូចជា **ការិ** =ធ្វើហើយ ជាដើម ។

២. បឋមបុរិសពហុវចនៈមិនមែន **ឧំ** ឬ **ឥំសុ** ទេតែជា **អំសុ** ។

៣. មជ្ឈិមបុរិសៈនិងឧត្តមបុរិសពហុវចនៈឥតមានចុះ **ឥ** អាគមទេ ។

៤. ចំពោះ **ហា** ធាតុកាលបើចុះ **អ** អាគមខាងដើមធាតុហើយត្រូវធ្វើសំយោគជា **ជ្ឈា** សិនគឺ (**អ** + **ហា**) > **អជ្ឈា** ។

៥. រីឯ **ហុ** ឬ **ហូ** ធាតុមានវិធីបំបែកជាអជ្ជតនីប្លែកពីខាងលើ គឺបំបែកដូចខាងក្រោមនេះ

## របៀបបំបែក ហុ ធាតុជាមួយអជ្ជតនីវិភត្តិ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អហោសិ, អហុ | អហោសុំ, អហុំ |
| ម.បុ. | អហោសិ, អហុវោ | អហោសិត្ថ, អហុវត្ថ |
| ឧ.បុ. | អហោសឹ, អហុំ, អហុវាសឹ | អហោសិម្ហ, អហុម្ហា |

ចំពោះ ភូ ធាតុក៏មានរបៀបបំបែកដោយចុះ អ អាគមដូច ហុ ធាតុដែរជា អភវិ ជាដើម ។

## របៀបបំបែក អស ធាតុជាមួយអជ្ជតនីវិភត្តិ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អាសិ | អាសុំ, អាសឹសុ |
| ម.បុ. | អាសិ | អាសិត្ថ |
| ឧ.បុ. | អាសឹ | អាសិម្ហ, អាសិម្ហា |

អស ធាតុដែលបំបែកជាមួយអត្តនោបទនិងជាមួយវិភត្តិដទៃទៀត មិនឃើញមានទេ ។

## អាគមរបស់អាខ្យាត

ខាងក្រោមនេះនឹងអធិប្បាយពីការចុះអាគម ។

**អាគម** បានដល់ ស្រៈឬព្យញ្ជនៈដែលថែមចូលមកថ្មី ។ អាគមដែលសម្រាប់ចុះក្នុងអាខ្យាតកិរិយាមាន ៥ អាគមគឺ **អ**, **ឥ**, **ស**, **ហ**, ំ ។ **អ** អាគមប្រែថា "បាន" រីឯ **ឥ**, **ស**, **ហ** មិនមានពាក្យប្រែទេ ។ អាគមនីមួយ ៗ ប្រើដូចខាងក្រោមនេះ

១. **អ** អាគមប្រើសម្រាប់ចុះត្រង់ខាងដើមធាតុដែលបំបែកជាមួយអជ្ជតនី, ហីយត្តនី និង (កាលាតិបត្តិ នឹងមានអធិប្បាយនៅខាងមុខ) ។

## ឧទាហរណ៍

១.១ **អវចំ** < (អ + **វច** + **អ** + **អំ**) (ខ្ញុំ)បានពោលហើយ (ហីយត្តនី) ។

១.២ **អបចឹ** < (អ + **បច** + **អ** + **ឥំ**) (ខ្ញុំ)បានចំអិនហើយ (អជ្ជតនី) ។

១.៣ **អបចិស្សា** < (អ + **បច** + **អ** + **ឥ** + **ស្សា**) (ខ្ញុំ)នឹងបានចម្អិនហើយ (កាលាតិបត្តិ) ។

២. **ឥ** អាគមប្រើសម្រាប់ចុះនឹងធាតុបច្ច័យដែលបំបែកជាមួយវិភត្តិពួក អជ្ជតនី, (ភវិស្សន្តិ និងកាលាតិបត្តិ នឹងមានអធិប្បាយនៅខាងមុខ)។

## ឧទាហរណ៍

២.១ **បចិត្ថ** < (**បច** + **អ** + **ឥ** + **ត្ថ**) =(អ្នក.ទ.)ចម្អិនហើយ (អជ្ជត្តនី)។

២.២ **វសិម្ហា** < (**វស** + **អ** + **ឥ** + **ម្ហា**) =(យើង)នៅហើយ (អជ្ជត្តនី) ។

២.៣ **បចិស្សតិ** < (**បច** + **អ** + **ឥ** + **ស្សតិ**)=(គេ)នឹងចម្អិន (ភវិស្សន្តិ)។

២.៤ **អបចិស្សា** < (**អ** + **បច** + **អ** + **ឥ** + **ស្សា**) (គេ)នឹងបានចម្អិន

ហើយ កាលាតិបត្តិ ។

៣. ស អាគមប្រើចុះជាមួយធាតុដែលបំបែកជាមួយអជ្ជតនីវិភត្តិ ដូចបានពោលរួចហើយខាងដើម ។

៤. ហ អាគមមិនពិតប្រាកដថាសម្រាប់ប្រើជាមួយវិភត្តិពួកណាជាកំណត់ទេ ហើយក៏ឃើញប្រើតែជាមួយធាតុមួយចំនួនប៉ុណ្ណោះដូចជា ហា ធាតុជាដើម ឧ.

៤.១ បតិដ្ឋហិ < (ប + ឋា > បតិដ្ឋ) + អ + ហ + ឦ (អជ្ជត្តនី) = តាំងនៅចំពោះហើយ ឬ ឋិតនៅចំពោះហើយ, ចុះ ហ អាគមនិងរស្សៈ ឦ ជា ឥ ។

៤.២ បតិដ្ឋហន្តិ < (ប + ឋា > បតិដ្ឋ) + អ + ហ + អន្តិ (វត្តមានា) =តាំងឬឋិតនៅចំពោះ ។

៤.៣ បតិដ្ឋហេយ្យ < (ប + ឋា > បតិដ្ឋ)+ អ + ហ + ឯយ្យ (សត្តមីវិភត្តិ) ។

៤.៤ បតិដ្ឋហិស្សតិ < (ប + ឋា > បតិដ្ឋ) + អ + ហ + ឥ + ស្សតិ (ភវិស្សន្តិ) ។

៤.៥ បតិដ្ឋហិស្សា < (ប + ឋា > បតិដ្ឋ) + អ + ហ + ឥ + ស្សា (កាលាតិបត្តិវិភត្តិ) ។

ហ អាគមក្រៅពីចុះក្នុងកិរិយាអាខ្យាត នៅមានចុះជាមួយកិតនាមឬកិតកិរិយាផងដែរដូចជា ឧបដ្ឋហនំ, ឧបដ្ឋហន្តោ ជាដើម ។

៥. (ំ) និគ្គហិតសម្រាប់ចុះជាមួយពួក រុជ ជាតុតែម៉្យាង(ចូរមើលពួក រុជ ជាតុក្នុងមេរៀនទី ៤ ខាងដើម) ។

តាមសេចក្ដីអធិប្បាយខាងលើនេះឃើញថា អជ្ជតនីវិភត្តិ មានប្រើអាគមស្ទើរតែគ្រប់តួ ។ វៀរតែ អ អាគមដែលចុះខាងដើមធាតុប៉ុណ្ណោះ ដែលមានក៏បានឬមិនមានក៏បានដែរ ។

វិភត្តិខាងអត្តនោបទចូរធ្វើតាមរបៀបខាងលើនេះដូចគ្នា ប្រសិនបើជាកម្មវាចកៈ គឺត្រូវផ្លាស់បច្ច័យឱ្យទៅជាកម្មវាចកបច្ច័យ ដែលមានអធិប្បាយនៅខាងមុខ ។ រឿងសំខាន់គឺត្រូវចាំវិធីទាំងឡាយដូចបានពោលរួចហើយនេះឱ្យបានល្អ ដើម្បីឱ្យងាយស្រួលក្នុងការបំបែកធាតុនៅពេលខាងមុខ ។

<u>បញ្ជាក់</u> ៖ អាគមដែលសម្រាប់ចុះក្នុងអាខ្យាតនៅមានច្រើនទៀត ឧ. **អហុវត្ថ** កិរិយានេះចុះ វ អាគម ។ **ឧច្ចេតិ** កិរិយានេះចុះ ច អាគម ។

## ឧទាហរណ៍នៃការប្រើ

**១. មា សុ ត្វំ អការិ ចាបំ ។**

(លោក) កុំ បានធ្វើ នូវបាបឡើយ ណា ។

**២. មា ឯវមកាសិ < (ឯវំ + អកាសិ) ។**

(លោក) កុំ បានធ្វើ យ៉ាងនេះ ឡើយ ។

**៣. សាវត្ថិយំ <u>កិរ</u> អឌ្ឍិនបុព្វកោ នាម ព្រាហ្មណោ អហោសិ ។**

*<u>បានឮថា</u> ក្នុងក្រុងសាវត្ថី ព្រាហ្មណ៍ ឈ្មោះ អទិន្នបុព្វកៈ បានមានហើយ ។*

៤. **ឥសយោ វនំ ផលានំ គមឹសុ ។**

*ឥសី.ទ. ទៅហើយ កាន់ព្រៃ ដើម្បីផ្លែឈើ.ទ. ។*

៥. **តុម្ហេ សព្វានិ កល្យាណានិ កម្មានិ អការិត្ថ ។**

*អ្នក.ទ. បានធ្វើហើយ នូវអំពើ.ទ. ដែលល្អ គ្រប់យ៉ាង ។*

*ម៉្យាងទៀត អជ្ជតនីវិភត្តិនេះនិយមប្រើ* **មា** *សព្ទដែលជានិបាតប្រាប់សេចក្ដីហាមឃាត់ប្រែថា "កុំ" ដូចបញ្ចមីវិភត្តិដែរ ក្នុងករណីដែលជាអតីតកាល ឧ.*

៦. **តុម្ហេ ចាបំ កម្មំ មា អការិត្ថ ។**

*អ្នក.ទ. កុំ បានធ្វើ នូវកម្ម ដែលអាក្រក់ ឡើយ ។*

*វេលាប្រែត្រូវអាន* **មា** *សព្ទគួបនឹងកិរិយាថា* **មា-អការិត្ថ** *ដូច្នេះ ។ បើប្រើនៅខាងដើមនៃប្រយោគបដិសេធ ប្រយោគនោះ ៗ វេលាប្រែក៏ត្រូវអានគួបជាមួយកិរិយាសព្ទដែរដូចលេខ ១* **មា---អការិ** *។*

## វិធីបំបែកនាមសព្ទ (តចប់)

## វិធីបំបែកនាមសព្ទ ឩ ការន្ត

(Declension of noun in ū-stem)

នាមសព្ទ ឩ ការន្តមានក្នុងពីរលិង្គគឺបុំលិង្គនិងឥត្ថីលិង្គ មានវិធីបំបែកដូចតទៅនេះ

## វិភត្តិសម្រេចរូបរបស់ ឩ ការន្តបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឩ | ឧវោ, ឩ |
| ទុ. | ឧំ | ឧវោ, ឩ |
| ត. | ឧនា | ឩហិ, ឩភិ |
| ច. | ឧស្ស, ឧនោ | ឩនំ |
| បញ្ច. | ឧស្មា, ឧម្හා | ឩហិ, ឩភិ |
| ឆ. | ឧស្ស, ឧនោ | ឩនំ |
| ស. | ឧស្មឹ, ឧម្ហិ | ឩសុ |
| អា. | ឧ | ឧវោ, ឩ |

## វិធីបំបែក វេទគូ =អ្នកដល់នូវវេទ ឩ ការន្តបុំលិង្គ

(ū stem as masculine)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | វេទគូ | វេទគុវោ, វេទគូ |
| ទុ. | វេទគុំ | វេទគុវោ, វេទគូ |

| | | |
|---|---|---|
| ត. | វេទគុនា | វេទគូហិ, វេទគូភិ |
| ច. | វេទគុស្ស, វេទគុនោ | វេទគូនំ |
| បញ្ច. | វេទគុស្មា, វេទគុម្ហា | វេទគូហិ, វេទគូភិ |
| ឆ. | វេទគុស្ស, វេទគុនោ | វេទគូនំ |
| ស. | វេទគុស្មឹ, វេទគុម្ហិ | វេទគូសុ |
| អា. | វេទគុ | វេទគុនោ, វេទគូ |

## កំណាត់សម្គាល់

*ស្រៈស្មើគ្នាពីរតួត្រូវលុបមួយតួចេញដូចជា*

( វេទគូ + ឩ ) > វេទគូ ។ ( វេទគូ + ឧនោ ) > វេទគុនោ ។

## នាមស័ព្ទ ឩ ការន្តបុំលិង្គ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| កតញ្ញូ | *អ្នកដឹងនូវគុណ* | មត្តញ្ញូ | *អ្នកដឹងនូវប្រមាណ* |
| វេទញ្ញូ | *អ្នកដឹងនូវពាក្យសំដី* | បរិសញ្ញូ | *អ្នកដឹងនូវប្រជុំជន* |
| កាលញ្ញូ | *អ្នកដឹងនូវកាល* | ចារគូ | *អ្នកដល់នូវត្រើយ* |
| បុគ្គលញ្ញូ | *អ្នកដឹងនូវបុគ្គល* | អទ្ធគូ | *អ្នកដើរដំណើរឆ្ងាយ* |
| សយម្ភូ | *ព្រះសយម្ភូ* | អភិភូ | *ព្រះអភិភូ, ព្រះពុទ្ធ* |
| សព្វញ្ញូ | *អ្នកដឹងសព្វ* | វិញ្ញូ | *អ្នកចេះ, អ្នកប្រាជ្ញ* |

# វិភត្តិសម្រេចរូបរបស់ ឩ ការន្តឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឩ | ឧយោ, ឩ |
| ទុ. | ឧំ | ឧយោ, ឩ |
| ត. | ឧយា | ឩហិ, ឩភិ |
| ច. | ឧយា | ឩនំ |
| បញ្ច. | ឧយា | ឩហិ, ឩភិ |
| ឆ. | ឧយា | ឩនំ |
| ស. | ឧយា, ឧយំ | ឩសុ |
| អា. | ឧ | ឧយោ, ឩ |

# វិធីបំបែក វធូ=ស្រីមានគូស្រករ ឩ ការន្តឥត្ថីលិង្គ

(ū stem as feminine)

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | វធូ | វធុយោ, វធូ |
| ទុ. | វធុំ | វធូយោ, វធូ |
| ត. | វធុយា | វធូហិ, វធូភិ |
| ច. | វធុយា | វធូនំ |

| | | |
|---|---|---|
| បញ្ច. | វត្ថុយា | វត្ថូហិ, វត្ថូភិ |
| ឆ. | វត្ថុយា | វត្ថូនំ |
| ស. | វត្ថុយា, វត្ថុយំ | វត្ថូសុ |
| អា. | វត្ថុ | វត្ថុយោ, វត្ថូ |

## នាមសព្ទ ឩ ការន្តឥត្ថីលិង្គ

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ចមូ | កងទ័ព, សេនា | ជម្ពូ | ដើមព្រីង |
| សិន្ធូ | ទន្លេសិន្ធុ | ភូ | ផែនដី, លោក |
| វិរូ | សណ្តែក | សរភូ | សត្វតុកកែ |

*វិភត្តិសម្រេចរូបនិងវិធីបំបែកនាមសព្ទទាំង ៦ ការន្តនៃលិង្គទាំង ៣ ចប់ត្រឹមនេះ ។ ចំពោះអ្នកសិក្សាដំបូង គប្បីមើលសាឡើងវិញដើម្បីឱ្យមានភាពស្ទាត់ជំនាញក្នុងការបំបែក ។*

## ធាតុសព្ទពួក ភូ ធាតុ (ត)

| ធាតុសព្ទ | ពាក្យប្រែ | ធាតុសព្ទ | ពាក្យប្រែ |
|---|---|---|---|
| ជល | រុងរឿង | ហស | សើច |
| អា + ហរ | នាំមក | កថ | ពោល, និយាយ |

| | | | |
|---|---|---|---|
| ពន្ធ | ចង | រម | រីករាយ |
| តរហ | តិះដៀល | ប + សំស | សរសើរ |
| ភជ | សេពគប់ | ឆម | ឱនទៅ, ថ្វាយបង្គំ |
| វិ + ចរ | ត្រាច់ចរ | អា + រុហ | ឡើង |

## និបាតស័ព្ទដែលមានប្រើញឹកញាប់

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អជ្ជ | ក្នុងថ្ងៃនេះ | កទា | ក្នុងកាលណា |
| អាម | ចាស, បាទ | កស្មា | ហេតុអ្វី |
| ឥទានិ | ក្នុងឥឡូវនេះ | កុហឹ | ក្នុងទីណា |
| ឥធ | ក្នុងទីនេះ | កុតោ | អំពីទីណា |
| បុព្វណ្ហេ | ក្នុងពេលព្រឹក | សព្វទា | សព្វកាល |
| ស្វេ | ក្នុងថ្ងៃស្អែក | សាយំ | ក្នុងវេលាល្ងាច |
| ហីយោ | ម្សិលមិញ | ចិរំ | យូរ, អស់កាលយូរ |
| បាតោ | ក្នុងពេលព្រឹក | បុរតោ | ខាងមុខ, អំពីមុខ |
| អបរណ្ហេ | ក្នុងពេលរសៀល | បច្ឆា | ក្នុងវេលាក្រោយ |

## លំហាត់នៃមេរៀនទី ៨

**ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ**

១. តើ **អជ្ជតនី** ប្រែថាដូចម្តេច ?

២. តើកិរិយាស័ព្ទដែលប្រកបនឹងអជ្ជតនីវិភត្តិប្រើប្រាប់កាលអ្វី ?

៣. តើអជ្ជតនីមានវិធីបំបែកប៉ុន្មានបែប ?

៤. តើបែបទី ១ ជាវិធីដូចម្តេច ?

៥. ប្រសិនបើបច្ច័យរបស់ធាតុនោះ ៗ ជាស្រៈឬមានទីបំផុតជាស្រៈ តើត្រូវធ្វើដូចម្តេច ?

៦. បែបទី ២ សម្រាប់ប្រើចំពោះ ចុរ ធាតុ ប្រសិនបើចុះ ណេ បច្ច័យតើត្រូវធ្វើដូចម្តេច ? ប្រសិនបើចុះ ណយ បច្ច័យតើត្រូវធ្វើដូចម្តេច ?

៧. តើបែបទី ៣ សម្រាប់ប្រើជាមួយធាតុប្រភេទណា ?

៨. តើ ឱំ វិភត្តិ បឋមបុរិសពហុវចនៈនិយមផ្លាស់ជាអ្វី ? សូមឱ្យឧទា. ។

៩. តើអាគមមានប៉ុន្មាន ? គឺអ្វីខ្លះ ?

១០. តើអជ្ជតនីអាចប្រើអាគមអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

**ខ. ចូរបំបែកធាតុស័ព្ទទាំងឡាយនេះជាមួយអជ្ជតនីវិភត្តិខាងបរស្សបទទាំងបីបុរិសៈនិងទាំងពីរវចនៈ**

១. ទិស, ២. ករ, ៣. កី. ៤. កុធ ។

**គ. ចូរបំបែកនាមស័ព្ទខាងក្រោមនេះជាមួយវិភត្តិនានាទាំងពីរវចនៈឱ្យត្រូវតាមលិង្គនោះ ៗ** ១. កតញ្ញូ, ២. ចម្ូ ។

ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. មយំ ពុទ្ធស្ស ធម្មំ អសុណិម្ហា ។

២. បុរិសា ច នារិយោ ច ឧបាសិកា ច មគ្គេន អចរឹសុ ។

៣. អហំ គហបតិនា ធនំ អលភឹ ។

៤. ពុទ្ធោ លោកេ ឧប្បជ្ជិ ។

៥. ហិយោ សមណោ ធម្មំ ទេសេសិ ។

៦. អាចរិយា តេសំ សិស្សានំ បុព្វណ្ហេ ឱវាទំ អទំសុ ។

៧. ចិរំ តេ អម្ហាកំ ឃរំ ន អគមឹសុ ។

៨. ទារិកា តាសំ ជនកស្ស បុរតោ អដ្ឋំសុ ។

៩. ត្វំ តស្មា ហត្ថេ ចោត្តកំ បស្សោ ។

១០. កុហឹ តុម្ហេ តុម្ហាកំ មិត្តេហិ សទ្ធឹ អបរណ្ហេ អគមិត្ថ ?

១១. ត្វំ អជ្ជ បាតរាសំ (អាហារពេលព្រឹក) ន ភុញ្ជោ ។

១២. កស្មា តុម្ហេ មម អាចរិយស្ស លេខនានិ ន លិខិត្ថ ?

១៣. តុម្ហេ ចិរំ មយ្ហំ បុត្តេ ន បស្សិត្ថ ។

១៤. អហំ តុយ្ហំ បណ្ណាការេ ហិយោ ន អលភឹ ។

ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. ខ្ញុំ អង្គុយហើយ លើគ្រែ របស់ខ្ញុំ ។

២. ខ្ញុំ ឈរហើយ ក្នុងសួន របស់គេ.ទ. ក្នុងពេលរសៀល ។

៣. យើង.ទ. បានរស់នៅ ក្នុងផ្ទះ របស់ឪពុកមា ក្នុងក្រុង យូរហើយ ។

៤. នៃកុមារ ហេតុអ្វី អ្នកឈរ ពីមុខ លោកគ្រូ របស់អ្នក ?
៥. នៃកូន អ្នក បានទៅ កាន់ទីណា កាលពីម្សិលមិញ ?
៦. ហេតុអ្វី អ្នក មិនស្តាប់ នូវធម៌ ?
៧. សំឡាញ់ របស់ខ្ញុំ មិនបានទិញ ផ្កា.ទ. ពីហាង ឯផ្សារ យូរហើយ ។
៨. ម្សិលមិញ ក្មេងប្រុស.ទ. ផង ក្មេងស្រី.ទ. ផង មិនបានយកមក នូវសៀវភៅ កាន់សាលា ។
៩. ស្វា.ទ. កំពុងស៊ី នូវផ្លែស្វាយ ។
១០. អ្នក.ទ. បានទទួល អំណោយ ពីគ្រូ របស់អ្នក.ទ. ពីកាលណា ?
១១. យើង.ទ. មួយអន្លើដោយ គហបតី នាំមកហើយ នូវទឹក ពីស្ទឹង ។
១២. ខ្ញុំ រស់នៅហើយ ឯផ្ទះ របស់ញាតិ របស់ខ្ញុំ យូរហើយ ។
១៣. គហបតី ស្តាប់ហើយ នូវធម៌, គាត់ កើតហើយ នូវសទ្ធា ក្នុងព្រះ-ពុទ្ធ ។

**(ចប់មេរៀនទី ៨)**

# មេរៀនទី ៩

## អធិប្បាយអំពីអាខ្យាតកិរិយានិងសព្វនាម (ត)

### (៧) ភវិស្សន្តីវិភត្តិ

(Future endings)

| | បរស្សបទ | | | អត្តនោបទ | |
|---|---|---|---|---|---|
| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* | *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
| *ប.បុ.* | ស្សតិ | ស្សន្តិ | *ប.បុ.* | ស្សតេ | ស្សន្តេ |
| *ម.បុ.* | ស្សសិ | ស្សថ | *ម.បុ.* | ស្សសេ | ស្សវ្ហេ |
| *ឧ.បុ.* | ស្សាមិ | ស្សាម | *ឧ.បុ.* | ស្សំ | ស្សាម្ហេ |

*ភវិស្សន្តិ ប្រែថា "នឹងមាន, នឹងកើត" ជាវិភត្តិប្រាប់ថាអំពើនោះ ៗ នឹងកើតមានក្នុងពេលអនាគត មានកិរិយានុគ្រោះប្រែថា "នឹង..." ។*

**ភវិស្សន្តិ** *តាមរូបស័ព្ទសម្រេចមកពី* **ភូ** *ធាតុ* (=មាន, *ជា*) *ជាតុពួកទី ១, ផ្លាស់* **ឩ** *នៃ* **ភូ** *ជា* **ឱ** *ហើយផ្លាស់* **ឱ** *ជា* **អវ** ( **ភវ** + **អ** + **ឥ** *អា.* + **ស្សន្តិ** ) > **ភវិស្សន្តិ** *ប្រែថា "នឹងមាន" ។*

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

*ការប្រកបរូបជាកិរិយាស័ព្ទជាមួយភវិស្សន្តិវិភត្តិមានវិធី ៣ យ៉ាង*

១. ត្រូវចុះ ឥ អាគមលើទីបំផុតធាតុនិងបច្ច័យ ។ ភាគច្រើនគឺ ប្រើតាមបែបចុះ ឥ អាគមនេះ ។

២. មិនបាច់ចុះ ឥ អាគមលើទីបំផុតធាតុនិងបច្ច័យទេ ។

៣. ដោយការធ្វើសមានកម្មទីបំផុតធាតុជាមួយ -ស្ស ឱ្យទៅជារូបផ្សេង ។

ប្រើធាតុណាមួយក៏ដោយត្រូវតែមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយ ដូចមានរូបមន្តខាងក្រោមនេះ

## របៀបទី ១ (ចុះ ឥ អាគម)

(ធាតុ + បច្ច័យ + ឥ អា. + វិភត្តិ) > កិរិយាស័ព្ទ

## វិធីបំបែក គម ធាតុ ប្រែថា "ទៅ"

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | គមិស្សតិ | គមិស្សន្តិ |
| ម.បុ. | គមិស្សសិ | គមិស្សថ |
| ឧ.បុ. | គមិស្សាមិ | គមិស្សាម |

ប្រែថា "នឹងទៅ"

## កំណាត់សម្គាល់

១. វិភត្តិខាងអត្តនោបទក៏មានវិធីប្រកបរូបជាកិរិយាដូចគ្នា ។

២. ពួក រុជ និង ជិរ ធាតុត្រូវធ្វើតាមវត្តមានាវិភត្តិសិន ទើបចុះ **ភវិស្សន្តិវិភត្តិ** ដូចជា **កុញ្ជិស្សតិ** ប្រែថា នឹងស៊ី, នឹងបរិភោគ (ពួក រុជ ធាតុ) ។ **កាញ្ឈិស្សតិ** ប្រែថា "នឹងក្រោធ" (ពួកជិរ ធាតុ) ជាដើម ។

៣. ធាតុក្នុងពួកដទៃទៀតត្រូវមានបច្ច័យជាប់មកជាមួយដែរ ដូចជា **ជិនិស្សតិ** ប្រែថា "នឹងឈ្នះ" (ពួកកី ធាតុរស្សៈស្រៈ **អា** នៃ **នា** បច្ច័យទៅជា **ន**),. **សុណិស្សតិ** ប្រែថា "នឹងស្តាប់" (ពួកសុ ធាតុរស្សៈស្រៈ **អា** នៃ **ណា** បច្ច័យទៅជា **ណ**),. **ការិស្សតិ** ប្រែថា "នឹងធ្វើ" (ពួក ក្វ ធាតុលុប អ បច្ច័យ),. **គណ្ហិស្សតិ** ប្រែថា "នឹងកាន់យក" (ពួក **គហ** ធាតុ **ណ្ហា** បច្ច័យ, លុបទីបំផុតធាតុចេញនិងរស្សៈស្រៈ **អា** នៃ **ណ្ហា** > **ណ្ហ**) ជាដើម ។ ពួក **ក្វ** ធាតុក៏លុបបច្ច័យចេញដែរដូច **គម** ខាងលើ ។ រីឯពួក **ចុរ** ធាតុមានអធិប្បាយនៅខាងក្រោមនេះ

## របៀបទី ២ (ពុំចាំបាច់ចុះ ឥ អាគម)

(ធាតុ + បច្ច័យ + វិភត្តិ) > កិរិយាស័ព្ទ

## វិធីបំបែក ចុរ ធាតុ ប្រែថា "លួច"

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | ចោរេស្សតិ | ចោរេស្សន្តិ |
| ម.បុ. | ចោរេស្សសិ | ចោរេស្សថ |
| ឧ.បុ. | ចោរេស្សាមិ | ចោរេស្សាម |

ប្រែថា "នឹងលួច"

## កំណត់សម្គាល់

១. វិធីបំបែករបៀបទី ២ នេះអនុវត្តចំពោះពួក **ចុរ** ធាតុដែលចុះ **ណេ** បច្ច័យប៉ុណ្ណោះ ។ កាលបើលុប **ណ** ចេញទៅនៅសល់ស្រៈ េ ទើបពុំបាច់ចុះ **ឥ** អាគមដូចរបៀបទី ១ ខាងលើ ។ ប្រសិនបើជា **ណយ** បច្ច័យវិញ ត្រូវបំបែកតាមបែបទី ១ ដូចជា **ចោរយិស្សតិ** ជាដើម ។

២. ធាតុខ្លះដែលត្រូវព្រឹទ្ធិស្រៈ **ឥ > ឯ** ក៏មិនបាច់ចុះ **ឥ** អាគមដូចគ្នាដែរដូចជា **នេស្សតិ** =នឹងនាំទៅ, មកពី ( **នី > នេ + អ + ស្សតិ** ),. **ឯស្សតិ** =នឹងទៅ, មកពី ( **ឥ > ឯ + អ + ស្សតិ** ) ជាដើម ។

៣. រស្សៈស្រៈ **អា** នៃធាតុជា **អ** ដូចជា **ឋា** ធាតុ, (**ឋា + អ + ស្សតិ**) > **ឋស្សតិ** =នឹងឈរ, នឹងតាំងនៅ ។ **ទា** ធាតុ, (**ទា + អ + ស្សតិ**) > **ទស្សតិ** =នឹងឱ្យ, បើជា **ទទា** ធាតុទៅជា **ទទិស្សតិ** ។

## របៀបទី ៣

របៀបបំបែកទី ៣ នេះប្រើបានចំពោះតែធាតុខ្លះ ៗ ប៉ុណ្ណោះ គឺប្រកបរូបជាកិរិយាស័ព្ទដោយការធ្វើអាទេស ស្ស របស់ភវិស្សន្តិវិភត្តិជា ១ ដូចជា (កុជ > កោជ > កោក) + អ + ស្សតិ > កោក្ខតិ =នឹងស៊ី ។ សក ធាតុមានរូបជា សក្ខតិ (សក + អ + ស្សតិ) > សក្ខតិ =នឹងអាច ។ សក ធាតុនេះមានរូបមួយបែបទៀតជា សក្ខិស្សតិ (សក + ខ + ឥ អា. + ស្សតិ) > សក្ខិស្សតិ ប្រែថា "ប្រាថ្នានឹងអាច" ដែលច្បាប់ភាសាអង់គ្លេសហៅថា Double Future ។

ចំពោះ ទិស អាចមានរូបជា ទក្ខតិ ដោយផ្លាស់ ទិស ជាតុជា ទក្ខ (ទក្ខ + អ + ស្សតិ) =នឹងឃើញ, លុប ស្ស ចេញ ។

ចំពោះ ហុ ធាតុអាចមានរូបច្រើនយ៉ាងគឺជា ហេតិ, ហេហិតិ, ហោហិតិ, ហេស្សតិ, ហេហិស្សតិ, ហោហិស្សតិ =នឹងកើត, នឹងមាន ។

រីឯ អស ធាតុមិនមានរូបជាភវិស្សន្តិទេ គឺប្រើ ភូ ធាតុជំនួសវិញជា ភវិស្សតិ ។

## ប្រយោគឧទាហរណ៍

១. កុហឹ ត្វំ ស្វេ គមិស្សសិ ។

ក្នុងថ្ងៃស្អែក ឯង នឹងទៅ ឯណា ?

២. **គហបតយោ វិហារស្មឹ ធម្មំ សុណិស្សន្តិ ។**

*គហបតី.ទ. នឹងស្ដាប់ នូវធម៌ ក្នុងវិហារ ។*

៣. **សចេ តុម្ហេ ជហាយិស្សថ, អហម្បិ** < (អហំ + បិ) **ជហា-យិស្សាមិ ។**

*ប្រសិនបើ អ្នក.ទ. នឹងផ្ញួតទឹក, ខ្ញុំ ក៏ នឹងផ្ញួត (ដែរ) ។*

៤. **សចាហំ** < (សចេ + អហំ) **បិយំ បុត្តំ លភិស្សាមិ, អហន្តំ** < (អហំ + តំ) **ចោសេស្សាមិ ។**

*ប្រសិនបើ ខ្ញុំ នឹងបាន នូវកូនប្រុស ដែលជាទីស្រឡាញ់, ខ្ញុំ នឹងចិញ្ចឹម នូវគេ(កូននោះ) ។*

## ប្រយោគការវាចក:

*ប្រយោគការវាចក:មានស័ព្ទសំខាន់ខ្វះមិនបាន ២ ប្រភេទគឺ*

១. **បទអនភិហិតកត្តា** *(មានរូបជាតតិយាវិភត្តិ) ។*

២. **ការវាចកកិរិយា** *(កិរិយាស័ព្ទ) ។*

*__បញ្ជាក់__៖ បុព្វាចារ្យខ្មែរយើងបានប្រាប់ថា ប្រយោគការវាចក:នេះមានបទប្រធានតែជាតតិយាវិភត្តិប៉ុណ្ណោះ ដែលជាកត្តា (អ្នកធ្វើ) និងដែលមានអាយតនិបាតប្រែថា "គឺ, ដែល" ខាងសម្ពន្ធថា* **អនភិហិតកត្តា** *។ ប៉ុន្តែបើតាមមតិរបស់សទ្ទនីតិថា បទប្រធានគួរតែមានរូបជាបឋមាវិភត្តិ ដូចដែលលោកបានឱ្យឧទាហរណ៍ថា* **សោ ភូយតេ** *ដូច្នេះជាដើម ។*

# វិធីរូបសិទ្ធិជាភាវវាចកកិរិយា

*ការប្រកបរូបជាកិរិយាភាវវាចកៈត្រូវធ្វើតាមរូបមន្តដូច្នេះ*

*(ធាតុ +* **យ** *បច្ច័យ +* **តេ** *វិភត្តិ) > កិរិយាស័ព្ទ*

*ភាវវាចកកិរិយាមានគ្រឿងសំខាន់ ៗ សម្រាប់សម្គាល់ ៣ ប្រភេទគឺ*

*១. ប្រើបានតែធាតុណាដែលជា* **អកម្មធាតុ** *ប៉ុណ្ណោះ ។*

*២. ត្រូវចុះ* **យ** *បច្ច័យ (តែក៏អាចចុះ* **ឥ** *អាគមបានខ្លះ) ។*

*៣. ប្រើតែ* **តេ** *វត្តមានាវិភត្តិឯកវចនបឋមបុរិសៈ ខាងអត្តនោបទ ប៉ុណ្ណោះ (ប៉ុន្តែក៏ឃើញមានប្រើជាបុរិសៈនិងវិភត្តិដទៃទៀតផងដែរ) ដូចមានឧទាហរណ៍ខាងក្រោមនេះ*

**១. តេន₁ មរយតេ₂។** *គឺគេ₁ ស្លាប់₂ ។*

**២. ជនេហិ₁ ភូយតេ₂។** *គឺជន.ទ.₁ កើត(រស់)₂ ។*

**៣. តេហិ ភូយតេ ។** *គេ កើត (សទ្ទនីតិបទមាលា) ។*

**៤. តេហិ បហីយិស្សតិ ។** *(សេចក្តីភ័យខ្លាយ)នោះនឹងសាបសូន្យ (ធជគ្គសូត្រ) ។*

**៥. មយំ អជុភូយម្ហេ ។** *យើង.ទ. រមែងសោយ (បទរូបសិទ្ធិ)។*

*ប្រសិនបើមានបទវិសេសនៈនៅផងត្រូវថែមវិធីប្រែទៀតដូច្នេះ*

*១. បទ* **អនភិហិតកត្តា** *ប្រែទី ១ ។*

*២. បទវិសេសនៈនៃបទអនភិហិតកត្តា (បើមាន) ប្រែទី ២ ។*

*៣. បទកិរិយាគ្រប់គ្រង (ភាវវាចកកិរិយា) ប្រែទី ៣ ។*

## ឧទាហរណ៍

**សព្វេហិ₂ សត្តេហិ₁ មរយតេ₃។**

*គឺសត្វ.ទ.₁ ទាំងពួង₂ រមែងស្លាប់₃ ។*

*ប្រយោគខាងលើនេះ អាចផ្លាស់ជាប្រយោគកត្តុវាចកៈវិញក៏បាន ដោយគ្រាន់តែផ្លាស់តួកត្តាពីតតិយាវិភត្តិមកជាបឋមាវិភត្តិ និងផ្លាស់កិរិយាស័ព្ទជាកត្តុវាចកកិរិយា ដូច្នេះ*

**សព្វេ₂ សត្តា₁ មរន្តិ₃។**

*រីសត្វ.ទ.₁ ទាំងពួង₂ រមែងស្លាប់₃ ។*

*សូមចាំថា បទអនភិហិតកត្តាអាចជាឯកវចនៈក៏បានជាពហុវចនៈក៏បាន ។*

## ២. វិសេសនសព្វនាម

(Pronominal Adjectives)

*សព្វនាមមាន ២ យ៉ាងគឺ បុរិសសព្វនាម និង វិសេសនសព្វនាម ។* **បុរិសព្វនាម** *បានអធិប្បាយរួចហើយក្នុងមេរៀនទី ៦ ។ ខាងក្រោមនេះជាការអធិប្បាយអំពីវិសេសនសព្វនាម ។*

**វិសេសនសព្វនាម** *ជាគុណស័ព្ទសម្រាប់ប្រើខាងដើមនាមស័ព្ទ*

ដើម្បីប្រាប់ឱ្យដឹងថា **ច្បាស់លាស់** ឬ **មិនច្បាស់លាស់** និងដែលចែកជា ២ យ៉ាងគឺ **និយមសព្វនាម** និង **អនិយមសព្វនាម** ។

## ២.១ និយមសព្វនាម

(Demonstrative Pronouns)

**និយម** ប្រែថា "ច្បាស់លាស់" ជាសព្វនាមប្រាប់សេចក្ដីច្បាស់លាស់ មាន ៥ ស័ព្ទគឺ

| | |
|---|---|
| **ត** | នោះ |
| **ឯត** | នេះ, ហ្នឹង, នុ៎ះ, នុ៎ះហ្ន៎ |
| **ឥម** | នេះ |
| **អមុ** | ឯនោះ, ឯណោះ |
| **ឥតរ** | មួយទៀត, ម្នាក់ទៀត |

## កំណត់សម្គាល់

ទាំង ៥ ស័ព្ទនេះសម្រាប់ប្រើពីខាងដើមនាមស័ព្ទ គឺប្រើបានទាំង ៣ លិង្គ ។ កាលបើមានបទនាមជាប្រធានបំបែកក្នុង លិង្គ, វិភត្តិនិង វចនៈណា និយមសព្វនាមត្រូវតែបំបែកឱ្យមាន លិង្គ, វចន និងវិភត្តិស្មើ នឹងនាមស័ព្ទនោះ ៗ ជានិច្ច ។

*ត វិសេសននិយមសព្វនាមមានវិធីបំបែកដូច ត បុរិសសព្វនាមទាំងអស់ ប៉ុន្តែមានវិធីប្រើខុសគ្នា ។ រីឯ* **ឯត** *ក៏មានវិធីបំបែកដូច ត បុរិសសព្វនាមដែរ ដោយគ្រាន់តែថែម ឯ ពីខាងដើមប៉ុណ្ណោះ ។ វិធីបំបែកនិយមសព្វនាមមានគតិដូចបំបែកនាមនាម* **អ** *ការន្តបុំលិង្គ, នបុំសកលិង្គនិង* **អា** *ការន្តឥត្ថីលិង្គដែរ (ចូរមើលវិភត្តិសម្រេចរបស់* **បុរិស, កុល** *និង* **កញ្ញា** *ក្នុងមេរៀនខាងដើម) ។*

## វិធីបំបែកនិយមសព្វនាម

## (Declension of Demonstrative Pronouns)

## វិធីបំបែក ឯត ស័ព្ទជាបុំលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | ឯសោ | ឯតេ |
| *ទុ.* | ឯតំ, ឯនំ | ឯតេ |
| *ត.* | ឯតេន | ឯតេហិ, ឯតេភិ |
| *ច.* | ឯតស្ស | ឯតេសំ, ឯតេសានំ |
| *បញ្ច.* | ឯតស្មា, ឯតម្ហា | ឯតេហិ, ឯតេភិ |
| *ឆ.* | ឯតស្ស | ឯតេសំ, ឯតេសានំ |
| *ស.* | ឯតស្មឹ, ឯតម្ហិ | ឯតេសុ |

# វិធីបំបែក ឃត ស័ព្ទជាឝបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមា. | ឃតំ | ឃតានិ |
| ទុតិយា. | ឃតំ | ឃតានិ |

ឃត វិសេសនសព្ទនាមដែលបំបែកជានបុំសកលិង្គ ចាប់ពីតតិយា រហូតដល់សត្តមីវិភត្តិទាំងឯកវចនៈនិងពហុវចនៈ មានរូបដូចបុំលិង្គទាំងអស់ ។

# វិធីបំបែក ឃត ស័ព្ទជាឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឃតា | ឃតា |
| ទុ. | ឃតំ, ឃតំ | ឃតា |
| ត. | ឃតាយ | ឃតាហិ, ឃតាភិ |
| ច. | ឃតស្សា, ឃតិស្សា, ឃតិស្សាយ | ឃតាសំ, ឃតាសានំ |
| បញ្ច. | ឃតាយ | ឃតាហិ, ឃតាភិ |
| ឆ. | ឃតស្សា, ឃតិស្សា, ឃតិស្សាយ | ឃតាសំ, ឃតាសានំ |
| ស. | ឃតស្សំ, ឃតិស្សំ, ឃតាយំ | ឃតាសុ |

## វិធីបំបែក ឥម ស័ព្ទជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អយំ | ឥមេ |
| ទុ. | ឥមំ | ឥមេ |
| ត. | ឥមិនា, ឥមេន, អនេន | ឥមេហិ, ឥមេភិ |
| ច. | ឥមស្ស, អស្ស | ឥមេសំ, ឥមេសានំ |
| បញ្ច. | ឥមស្មា, ឥមម្ហា, អស្មា | ឥមេហិ, ឥមេភិ |
| ឆ. | ឥមស្ស, អស្ស | ឥមេសំ, ឥមេសានំ |
| ស. | ឥមស្មឹ, ឥមម្ហិ, អស្មឹ | ឥមេសុ |

## វិធីបំបែក ឥម ស័ព្ទជានបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមា. | ឥទំ | ឥមានិ |
| ទុតិយា. | ឥទំ | ឥមានិ |

ឥម វិសេសនសព្ទនាមដែលបំបែកជានបុំសកលិង្គ ចាប់ពីតតិយា ដល់សត្តមីវិភត្តិទាំងឯកវចនៈនិងពហុវចនៈ មានរូបដូចបុំលិង្គដែរ ។

## វិធីបំបែក ឥម ស័ព្ទជាឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អយំ | ឥមា |
| ទុ. | ឥមំ | ឥមា |
| ត. | ឥមាយ | ឥមាហិ, ឥមាភិ |
| ច. | ឥមិស្សា, ឥមិស្សាយ, អស្សា | ឥមាសំ, ឥមាសានំ |
| បញ្ច. | ឥមាយ | ឥមាហិ, ឥមាភិ |
| ឆ. | ឥមិស្សា, ឥមិស្សាយ, អស្សា | ឥមាសំ, ឥមាសានំ |
| ស. | ឥមិស្សំ, ឥមាយំ, អស្សំ | ឥមាសុ |

## វិធីបំបែក អមុ ស័ព្ទជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អមុ, អសុ | អមូ |
| ទុ. | អមុំ | អមូ |
| ត. | អមុនា | អមូហិ, អមូភិ |
| ច. | អមុស្ស, អមុនោ | អមូសំ, អមូសានំ |
| បញ្ច. | អមុស្មា, អមុម្ហា | អមូហិ, អមូភិ |
| ឆ. | អមុស្ស, អមុនោ | អមូសំ, អមូសានំ |
| ស. | អមុស្មឹ, អមុម្ហិ | អមូសុ |

## វិធីបំបែក អមុ ស័ព្ទជានបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមា. | អទុំ | អមូនិ |
| ទុតិយា. | អទុំ | អមូនិ |

អមុ វិសេសនសព្ទនាមដែលបំបែកជានបុំសកលិង្គ ចាប់ពីតតិយា រហូតដល់សត្តមីវិភត្តិទាំងឯកវចនៈនិងពហុវចនៈ មានរូបដូចបុំលិង្គទាំងអស់ ។

## វិធីបំបែក អមុ ស័ព្ទជាឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អមុ, អសុ | អមូ |
| ទុ. | អមុំ | អមូ |
| ត. | អមុយា | អមូហិ, អមូភិ |
| ច. | អមុស្សា | អមូសំ, អមូសានំ |
| បញ្ច. | អមុស្សា | អមូហិ, អមូភិ |
| ឆ. | អមុស្សា | អមូសំ, អមូសានំ |
| ស. | អមុស្សំ, អមុយំ | អមូសុ |

## កំណត់សម្គាល់

១. សព្វនាមទាំង ២ យ៉ាងគឺបុរិសសព្វនាមនិងវិសេសនសព្វនាម មិនមានជាអាលបនៈវិភត្តិទេ ។

២. **និយមសព្វនាម** កាលបើបំបែកជាមួយវិភត្តិផ្សេង ៗ ហើយ វេលាប្រែជាភាសាខ្មែរ ពុំចាំបាច់ប្រើអាយតនិបាតឬពាក្យប្រែរបស់វិភត្តិ ថែមពីមុខដូចនាមនាមទេគឺ ប្រែតែស័ព្ទទេ ៗ ប៉ុណ្ណោះ ឧ. **តំ ចិត្តំ**=ចិត្ត នោះ, **សោ បុរិសោ**=ប្រុសនោះ, **ឯតំ ខេត្តំ**=ស្រែនុ៎ះ, **ឥមំ** =នេះ, **អមុ** = ឯនោះ ជាដើម ។ ប្រសិនបើជាពហុវចនៈវិញក៏ពុំចាំបាច់ថែមពាក្យថា "...ទាំងឡាយ" នៅខាងចុងដូចនាមនាមទេ ដើម្បីឱ្យសមតាមភាសា និយមដូចជា **តេ បុរិសា** =ប្រុសទាំងឡាយនោះ, **ឯតេ កុមារេ** =ក្មេង ប្រុសទាំងឡាយនុ៎ះ ជាដើម ។

៣. **អមុ** ស័ព្ទអាចផ្លាស់ជា **អសុ** បានខ្លះ, ទាំង **អមុ** និង **អសុ** និយមចុះ **ក** នៅខាងចុងជា **អមុក**, **អសុក** មានវិធីបំបែកជាមួយ វិភត្តិផ្សេង ៗ បានទាំងបីលិង្គ តាមបែប **យ** ស័ព្ទដែលនឹងមានអធិប្បាយ នៅខាងមុខ ។ **អមុក** និង **អសុក** មានប្រើច្រើនជាង **អមុ** និង **អសុ** ។

## វិធីប្រើនិងប្រែនិយមសព្វនាម

និយមសព្វនាមជាវិសេសនសព្វនាម សម្រាប់ប្រើអធិប្បាយនាម

*ដែលមានលក្ខណៈដូចជាគុណស័ព្ទ ។ បើប្រើអធិប្បាយនាមបទណា ត្រូវរៀងដាក់ខាងដើមនាមបទនោះ ៗ និងត្រូវឱ្យមានលិង្គ, វចននិងវិភត្តិ ស្មើគ្នាជានិច្ច ។*

## ប្រយោគឧទាហរណ៍

១. ឯសោ២ បុរិសោ១ ធម្មំ៤ សុណាតិ៣។

*រីបុរស១ នុ៎ះ២ កំពុងស្ដាប់៣ នូវធម៌៤ ។*

២. សា២ ភរិយា១ ឯតាសានំ៥ បុត្តានំ៥ អាហារេ៤ ទេតិ៣។

*រីភរិយា១ នោះ២ កំពុងឱ្យ៣ នូវអាហារ.ទ.៤ ដល់បុត្រ.ទ.៥ នុ៎ះ៥។*

៣. អយំ២ កសកោ១ ឥមានិ៥ កម្មានិ៤ ករោតិ៣។

*រីអ្នកស្រែ១ នេះ២ កំពុងធ្វើ៣ នូវការងារ.ទ.៤ នេះ៥ ។*

៤. ត្វំ១ មយ្ហំ៥ អទុំ៥ វត្ថុំ៤ ទេហិ៣។

*ឯង១ សូមឱ្យ៣ នូវសំពត់៤ (ដុំ)នោះ៥ ដល់ខ្ញុំ៥ ។*

៥. សេដ្ឋី១ អមុំ៥ នារឹ៤ បស្សតិ៣។

*រីសេដ្ឋី១ កំពុងមើល៣ នូវនារី៤ ឯនោះ៥ ។*

៦. សោ២ ភិក្ខុ១ អមុស្សំ៥ ឧបាសកានំ៥ ធម្មំ៤ ទេសេយ្យ៣។

*រីភិក្ខុ១ នោះ២ គប្បីសំដែង៣ នូវធម៌៤ ដល់ឧបាសក.ទ.៥ ឯនោះ៥ ។*

៧. អាចរិយោ១ សិស្សានំ៥ ឱវាទំ៤ ទេតិ៣, តេ១ តស្ស៥ ឱវាទេ៤ តិដ្ឋន្តិ៣។

វីគ្រូ₁ កំពុងឱ្យ₃ នូវឱវាទ₂ ដល់សិស្ស.ទ.₄, គេ.ទ.(សិស្ស.ទ)₁ កំពុងតាំងនៅ₃ ក្នុងឱវាទ₂ របស់គាត់₄ ។

ក្នុងឧទាហរណ៍ទី ៧ ខាងលើនេះមានប្រយោគពីរសង្កាត់គឺ

**អាចរិយោ---ទេតិ និង តេ---តិដ្ឋន្តិ ។**

ពាក្យថា **តេ** នេះអាចប្រែមួយបែបទៀតបានគឺប្រែយោគស័ព្ទជា "វីសិស្សទាំងឡាយ នោះ= **តេ សិស្សា**" ។ បើប្រែដូច្នេះ **តេ** មិនមែនជាបុរិសសព្វនាមទៀតទេ គឺក្លាយជាវិសេសនសព្វនាមវិញហើយ ពីព្រោះមាន **សិស្សា** ជាប្រធាន ចំពោះ **តស្ស** ក៏ដូចគ្នាដែរ អាចប្រែថា "របស់អាចារ្យ នោះ= **តស្ស អាចរិយស្ស**" ។ បើប្រែដូច្នេះ **តស្ស** ក្លាយជាវិសេសនសព្វនាមវិញដែរ ។

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| **កុទ្ទាល** បុំ. | ចប, ប៉ែល | **នរបតិ** បុំ. | ស្ដេច |
| **កូប** បុំ. | អណ្ដូង | **មុត្តិ** ឥ. | ការរួចផុត |
| **អដវិ** ឥ. | ព្រៃ | **វិសិខា** ឥ. | ផ្លូវ, ថ្នល់ |
| **ចាសាទ** បុំ. | ប្រាសាទ | **គង្គា** ឥ. | ទន្លេ |
| **មូល** នបុំ. | គល់, ប្រាក់ | **នោណិ** ឥ. | ទូក |

# លំហាត់នៃមេរៀនទី ៩

**ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ**

១. តើ **ករិស្សន្តិ** ប្រែថាដូចម្តេច ?

២. តើកិរិយាស័ព្ទដែលប្រកបនឹងករិស្សន្តិវិភត្តិប្រើប្រាប់កាលអ្វី ?

៣. តើករិស្សន្តិមានវិធីបំបែកប៉ុន្មានបែប ?

៤. តើបែបទី ១ ជាវិធីដូចម្តេច ?

៥. ប្រសិនបើបច្ច័យរបស់ធាតុនោះ ៗ ជាស្រះឬមានទីបំផុតជាស្រះ តើត្រូវធ្វើដូចម្តេច ?

៦. បែបទី ២ សម្រាប់ប្រើចំពោះ **ចុរ** ធាតុ ប្រសិនបើចុះ **ណេ** បច្ច័យ តើត្រូវធ្វើដូចម្តេច ? ប្រសិនបើចុះ **ណយ** បច្ច័យតើត្រូវធ្វើដូចម្តេច ?

៧. តើបែបទី ៣ សម្រាប់ប្រើជាមួយធាតុទូទៅបានដែរឬទេ ?

៨. ប្រសិនបើជា **អស** ធាតុតើនិយមប្រើអ្វីជំនួស ?

៩. តើកិរិយាស័ព្ទជាភាវវេចកៈមានវិធីប្រកបរូបដូចម្តេចខ្លះ ? សូមឱ្យឧទាហរណ៍ ។

១០. តើវិសេសនសព្វនាមមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ខ. ចូរបំបែកធាតុស័ព្ទទាំងឡាយនេះជាមួយអជ្ជតនីវិភត្តិខាងបរស្សបទទាំងបីបុរិសៈនិងទាំងពីរវចនៈ**

១. ជិស, ២. ការ, ៣. កី. ៤. កុជ ។

គ. ចូរបំបែកសព្វនាមទាំងឡាយខាងក្រោមនេះជាមួយវិភត្តិនានា ជាបុំលិង្គទាំងពីរវចនៈ

១. ឯត, ២. ឥម, ៣. អមុ ។

ឃ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. កស្សកោ កុទ្ទាលេន ភូមិយំ កូបំ ខនិស្សតិ ។

២. មយំ ភគិនិយា គេហំ គមិស្សាម ។

៣. រត្តិយំ តេ អដវីសុ ន វសិស្សន្តិ ។

៤. នរបតិនោ បុត្តា អដវិយំ នគរំ ការិស្សន្តិ ។

៥. សចេ ត្វំ មុត្តឹ លភ, ពុទ្ធោ ភវិស្សសិ ។

៦. អហំ ជនកស្ស បណ្ណាការំ ទទិស្សាមិ ។

៧. កុហឹ ត្វំ ស្វេ គមិស្សសិ ?

៨. តុម្ហេ រត្តិយំ វិសិខាសុ ន វិចរិស្សថ ។

៩. អហំ អស្សម្ហា ភូមិយំ ន បតិស្សាមិ ។

១០. អហំ មយ្ហំ អង្គុលីហិ មណឹ គណ្ហិស្សាមិ ។

១១. វាណិជោ បាសាទំ អារុហិស្សតិ សោ ចន្ទំ បស្សិស្សតិ ។

១២. ជនា សាលាយំ ធម្មំ សុណិស្សន្តិ ។

១៣. កទា មយំ នទឹ បាបុណិស្សាម ?

១៤. មយំ អជ្ជ បុព្វណ្ហេ ន ឧគ្គណ្ហិម្ហា ។

១៥. ភគិនី តស្សាយ សាមិនា សទ្ធឹ ជនកស្ស គេហំ ស្វេ គមិស្សន្តិ។

### ង. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. ប្រសិនបើ អ្នក ឡើង លើភ្នំ អ្នក នឹងឃើញ នូវទន្លេ ។
២. ជន.ទ. នោះ ក្នុងស្រុក នោះ នឹងស្តាប់ នូវធម៌ ក្នុងសាលា នេះ ។
៣. ស្វា នឹងស៊ី ផ្លែ.ទ. ដោយដៃ.ទ. របស់វា ។
៤. កុមារ.ទ. ផង កុមារី.ទ. ផង នឹងទៅ កាន់សួន ឯនោះ ។
៥. យើង នឹងឃើញ នូវព្រះច័ន្ទ ក្នុងរាត្រី ។
៦. សេចក្តីសុខ កើតឡើង ព្រោះបុណ្យ ។
៧. បុរស.ទ. ផង នារី.ទ. ផង ទៅ កាន់វត្ត រាល់ថ្ងៃ មួយអន្លើដោយ ផ្កា.ទ. ក្នុងដៃ.ទ. ។
៨. ស្តេច មួយអន្លើដោយ ស្តេចស្រី នឹងមក កាន់នគរ ក្នុងថ្ងៃស្អែក ។
៩. ប្រសិនបើ គេ ប្រព្រឹត្ត នូវអំពើ ល្អ គេ នឹងមិនកើត ក្នុងទុគតិភព ឡើយ ។
១០. ពពែ.ទ. បានរត់ចេញ ពីដំរី ព្រោះសេចក្តីខ្លាច ។

(ចប់មេរៀនទី ៩)

# កំណាព្យដាស់តឿនស្មារតី

រៀនទៅមុខ ! រៀនទៅមុខ ! កុំថយក្រោយ
រៀនកុំឱ្យ ស្ទាក់ស្ទើរចិត្ត គិតស្មុគស្មាញ
ព្យាយាមរៀន មានវិរិយៈ មានះក្រាញ
រៀនឱ្យស្ទាត់ មាត់ឱ្យស្ទាញ ជំនាញល្អ ។
ចិត្តឱ្យនឹង ប្រឹងឱ្យធំ កុំឡេះឡោះ
រិះចាប់នេះ រិះចាប់នោះ ស្មុះខ្សែឡ
ចេះមួយសិន ឆ្អិនប្រាកដ ស្ទាត់គ្រប់ខ
សឹមបន្ត ជាបន្ទាប់ ទៅមុខអើយ !

(មិនដឹងប្រភពដើម)

# មេរៀនទី ១០

## អធិប្បាយអំពីអាខ្យាតកិរិយានិងគុណនាម

### (៨) កាលាតិបត្តិវិភត្តិ

(Conditional endings)

| | បរស្សបទ | | | អត្តនោបទ | |
|---|---|---|---|---|---|
| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* | *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
| *ប.បុ.* | ស្សា | ស្សំសុ | *ប.បុ.* | ស្សថ | ស្សឹសុ |
| *ម.បុ.* | ស្សេ | ស្សថ | *ម.បុ.* | ស្សសេ | ស្សវ្ហេ |
| *ឧ.បុ.* | ស្សំ | ស្សាម្ហា | *ឧ.បុ.* | ស្សំ | ស្សាម្ហសេ |

**កាលាតិបត្តិ** *ប្រែថា "កាលកន្លងហើយ" ជាវិភត្តិប្រាប់ថាអំពើនោះ ៗ នឹងកើតមាននាពេលអនាគតតែជាអនាគតក្នុងអតីតកាល មានកិរិយានុគ្រោះថា "នឹង...ហើយ" ។ ប្រសិនបើមាន អ អាគមនៅខាងដើមធាតុប្រែថា "នឹងបាន......ហើយ" ។*

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

*ការប្រកបរូបជាកិរិយាស័ព្ទជាមួយកាលាតិបត្តិវិភត្តិ មានដំណើរដូច*

ពួកកវិស្សន្តិវិភត្តិដែរ ។ ប៉ុន្តែត្រូវចុះ អ អាគមខាងដើមធាតុ និងជាពិសេស ឥ អាគមខ្លះមិនបានទេ ដូចពួកកវិស្សន្តិដែរ ។ ប៉ុន្តែបើធាតុមានឧបសគ្គខាងដើមធាតុមិនគប្បីចុះ អ អាគមទេ ។ ដូច្នេះត្រូវមានរូបមន្តពីរគឺមាន អ អាគមនិងមិនមាន អ អាគម ។

## ១. បែបចុះ អ អាគម

(អ អា. + ធាតុ + បច្ច័យ + ឥ អា. + វិភត្តិ) > កិរិយាស័ព្ទ

## វិធីបំបែក គម ធាតុ

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អគច្ឆិស្ស, អគច្ឆិស្សា | អគច្ឆិស្សំសុ |
| ម.បុ. | អគច្ឆិស្សេ | អគច្ឆិស្សថ |
| ឧ.បុ. | អគច្ឆិស្សំ | អគច្ឆិស្សាម្ហា, អគច្ឆិស្សម្ហា |

ប្រែថា "នឹងបានទៅហើយ"

## ២. បែបមិនមានចុះ អ អាគម

(ឧបសគ្គ + ធាតុ + បច្ច័យ + ឥ អា. + វិភត្តិ) > កិរិយាស័ព្ទ

## វិធីបំបែក ឧ + បជ ធាតុ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.ប. | ឧប្បជ្ជិស្ស, ឧប្បជ្ជិស្សា | ឧប្បជ្ជិស្សំសុ |
| ម.ប. | ឧប្បជ្ជិស្សេ | ឧប្បជ្ជិស្សថ |
| ឧ.ប. | ឧប្បជ្ជិស្សំ | ឧប្បជ្ជិស្សាម្ហា, ឧប្បជ្ជិស្សម្ហា |

*ប្រែថា "នឹងបានកើតហើយ"*

## កំណត់សម្គាល់

*១. ប្រើធាតុណាក៏ដោយត្រូវតែមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយជានិច្ច ។*

*២. វិភត្តិខាងអត្តនោបទក៏មានវិធីប្រកបរូបកិរិយាដូចគ្នានេះដែរ ។*

*៣. បច្ច័យដែលជាស្រៈឬទីបំផុតជាស្រៈ អ កាលបើចុះ ឥ អាគម ហើយត្រូវលុបបច្ច័យនោះ ៗ ចេញ ឧ.* (អ + គច្ឆ + អ + ឥ *អា.* + ស្សា ) > អគច្ឆិស្សា ។

*៤.* ស្សា *វិភត្តិបឋមបុរិសឯកវចនៈនិយមរស្សៈជា* ស្ស (អ + គច្ឆ + អ + ឥ + ស្សា ) > អគច្ឆិស្ស (*មានគតិដូច* អា *ហើយត្តនីផងដែរ*) ។ ស្សាម្ហា *ឧត្តមបុរិសពហុវចនៈក៏និយមរស្សៈដែរដូចជា* អគច្ឆិស្សាម្ហ ។

៦. កាលាតិបត្តិវិភត្តិមិនសូវមានប្រើទេ ហើយអ្វីដែលអ្នកពោលនាំយកមកនិយាយនោះមិនបានកើតមានឡើងទេ គឺគ្រាន់តែជាការនឹកគិតប៉ុណ្ណោះ ។ រីឯការប្រើវិញសោតច្រើនតែជាប្រយោគចម្រុះ គឺប្រយោគនោះ ៗ ត្រូវមានពីរសង្កាត់ ។ ក្នុងករណីនេះ នៅខាងដើមនៃប្រយោគទីមួយច្រើនតែមានបរិកប្បនិបាតពីរស័ព្ទគឺ **ចេ** =បើ, **សចេ** =ប្រសិនបើ, ស័ព្ទណាមួយជានិច្ច ។

## ប្រយោគឧទាហរណ៍

**សោ$_២$ ចេ$_១$ យានំ$_៤$ លភិស្សា$_៣$, អគច្ឆិស្សា$_៣$។**

*ប្រសិនបើ$_១$ គេ$_២$ នឹងបានហើយ$_៣$ នូវយាន$_៤$, (គេ)$_១$ នឹងបានទៅហើយ$_៣$ ។*

ឧទាហរណ៍ខាងលើនេះចាប់ពី **សោ** ដល់ **លភិស្សា** ជាប្រយោគសង្កាត់ទី ១ ។ ដូច្នេះនៅសល់តែ **អគច្ឆិស្សា** មួយបទគត់ជាប្រយោគសង្កាត់ទី ២។ ទោះបីជាពាក្យតែមួយបទក៏ដោយក៏អាចជាប្រយោគមួយបានដែរ ពីព្រោះកិរិយាស័ព្ទក្នុងភាសាបាលីជួនកាលមិនមានបទប្រធានប្រាកដរូបឱ្យឃើញទេ ។ ប៉ុន្តែគេអាចដឹងបទប្រធានថាជាអ្វីដោយសារវិភត្តិជាអ្នកប្រាប់ ។ អាស្រ័យហេតុនេះ **អគច្ឆិស្សា** មានបទប្រធានជា **សោ** =គេ ។

**(វិភត្តិអាខ្យាតកិរិយាចប់ត្រឹមនេះ)**

## គុណនាម (Adjective)

គុណនាមជាស័ព្ទមួយប្រភេទប្រើសម្រាប់អធិប្បាយបទនាមនាមឬសព្វនាមឱ្យមានលក្ខណៈប្លែកខុសពីធម្មតាដូចជាពាក្យថា **កាឡ**=ខ្មៅ, **សេត** =ស, **ទីឃ** =វែង, **រស្ស** =ខ្លី, **នវ** =ថ្មី, **បុរាណ** =ចាស់ ជាដើម ។

## គុណនាមបំបែកបានទាំងបីលិង្គ

គុណនាមភាគច្រើនជា អ ការន្ត ប៉ុន្តែក៏មានគុណនាមជា **ឥ**, **ឦ**, **ឧ** និង **ឩ** ការន្តផងដែរ ។

១. គុណនាមពួក **អ** ការន្តមានវិធីបំបែកក្នុងបុំលិង្គតាមបែប **បុរិស** ក្នុងនបុំសកលិង្គបំបែកតាមបែប **កុល**, ក្នុងឥត្ថីលិង្គត្រូវចុះ **អា** បច្ច័យសិនទើបបំបែកតាមបែប **កញ្ញា** គ្រប់វិភត្តិទាំងអស់ ។

២. គុណនាមពួក **ឥ** ការន្តមានវិធីបំបែកក្នុងបុំលិង្គតាមបែប **មុនិ** ក្នុងនបុំសកលិង្គបំបែកតាមបែប **អក្ខិ**, ក្នុងឥត្ថីលិង្គត្រូវចុះ **ឥនី** បច្ច័យសិនទើបបំបែកតាមបែប **នារី** គ្រប់វិភត្តិទាំងអស់ ។ វេលាចុះ **ឥនី** បច្ច័យមកត្រូវលុបស្រៈទីបំផុតរបស់គុណនាមចេញ ។

៣. គុណនាមពួក **ឦ** ការន្តមានវិធីបំបែកក្នុងបុំលិង្គតាមបែប **សេដ្ឋី** ក្នុងនបុំសកលិង្គត្រូវរស្សៈ **ឦ** > **ឥ** ទើបបំបែកតាមបែប **អក្ខិ** មេ

និងក្នុងឥត្ថីលិង្គត្រូវចុះ **ឥនី** បច្ច័យសិនទើបបំបែកតាមបែប **នារី** គ្រប់វិភត្តិទាំងអស់ ។ វេលាចុះ **ឥនី** បច្ច័យមកក៏ត្រូវលុបស្រៈទីបំផុតរបស់គុណនាមចេញដែរ ។

៤. គុណនាមពួក **ឧ** ការន្តមានវិធីបំបែកក្នុងបុំលិង្គតាមបែប **គរុ** និងក្នុងនបុំសកលិង្គបំបែកតាមបែប **វត្ថុ**, ក្នុងឥត្ថីលិង្គត្រូវចុះ **ឥនី** បច្ច័យសិនទើបបំបែកតាមបែប **នារី** គ្រប់វិភត្តិទាំងអស់, វេលាចុះ **ឥនី** បច្ច័យមកត្រូវលុបស្រៈ **ឥ** របស់ **ឥនី** បច្ច័យចេញ ។

៥. គុណនាមពួក **ឩ** ការន្តមានវិធីបំបែកក្នុងបុំលិង្គតាមបែប **វេទគូ** និងក្នុងនបុំសកលិង្គត្រូវរស្សៈជា **ឧ** សិនទើបបំបែកតាមបែប **វត្ថុ**, ក្នុងឥត្ថីលិង្គត្រូវចុះ **ឥនី** បច្ច័យសិនទើបបំបែកតាមបែប **នារី** គ្រប់វិភត្តិទាំងអស់ ។ វេលាចុះ **ឥនី** បច្ច័យមកត្រូវរស្សៈ **ឩ** ជា **ឧ** និងលុបស្រៈ **ឥ** របស់ **ឥនី** បច្ច័យចេញ ។

មានគុណនាមមួយពួកទៀតមានទីបំផុតជា **វន្តុ** និង **មន្តុ** ។ គុណ-នាមប្រភេទនេះកើតពីការចុះបច្ច័យពីរតួនេះ **វន្តុ**, **មន្តុ** (មានអធិប្បាយក្នុងមេរៀនទី ២៤) ក្នុងចុងនាមស័ព្ទនោះ ៗ និងដែលមានវិធីបំបែកប្លែកពីគុណនាមដូចបានពោលហើយខាងលើ ។

គុណនាមទាំងឡាយក្នុងមួយស័ព្ទអាចបំបែកបានទាំង ៣ លិង្គ និងគ្រប់វិភត្តិទាំងអស់ ខាងក្រោមនេះជាឧទាហរណ៍ក្នុងរូបជាបឋមានិងទុតិយាវិភត្តិ ។

| | ឯកវចនៈ | | | ពហុវចនៈ | | |
|---|---|---|---|---|---|---|
| វិ. | បុំលិង្គ | ឥត្ថី. | នបុំ. | បុំលិង្គ | ឥត្ថី. | នបុំ. |
| ប. | ពាលោ | ពាលា | ពាលំ | ពាលា | ពាលាយោ | ពាលានិ |
| ទុ. | ពាលំ | ពាលំ | ពាលំ | ពាលេ | ពាលាយោ | ពាលានិ |
| ប. | ភូរិ | ភូរិនី | ភូរិ | ភូរយោ | ភូរិនិយោ | ភូរីនិ |
| ទុ. | ភូរឹ | ភូរិនឹ | ភូរឹ | ភូរយោ | ភូរិនិយោ | ភូរីនិ |
| ប. | ចារី | ចារិនី | ចារិ | ចារិនោ | ចារិនិយោ | ចារីនិ |
| ទុ. | ចារឹ | ចារិនឹ | ចារឹ | ចារិនោ | ចារិនិយោ | ចារីនិ |
| ប. | គរុ | គរុនី | គរុ | គរវោ | គរុនិយោ | គរូនិ |
| ទុ. | គរុំ | គរុនឹ | គរុំ | គរវោ | គរុនិយោ | គរូនិ |
| ប. | វិញ្ញូ | វិញ្ញុនី | វិញ្ញូ | វិញ្ញុនោ | វិញ្ញុនិយោ | វិញ្ញូនិ |
| ទុ. | វិញ្ញុំ | វិញ្ញុនឹ | វិញ្ញុំ | វិញ្ញុនោ | វិញ្ញុនិយោ | វិញ្ញូនិ |

## វិធីប្រើគុណនាម

*គុណនាមដែលប្រើអធិប្បាយនាមនាមឬសព្វនាម ត្រូវតែបំបែកឱ្យមានលិង្គ, វចនៈ និង វិភត្តិស្មើនឹងនាមស័ព្ទដែលជាប្រធានជានិច្ច គឺថា បើនាមស័ព្ទមានរូបក្នុងវិភត្តិនិងវចនៈណា គុណនាមក៏ត្រូវមានរូបក្នុងវិភត្តិនិងវចនៈនោះដែរ ។ គុណនាមនឹងមានរូបជាវិភត្តិអ្វីក៏ដោយ វេលា*

ប្រែពុំចាំបាច់ប្រែចេញពាក្យប្រែឬអាយតនិបាតដូចនាមនាមទេ គឺប្រែទទេ ៗ ឬមានពាក្យដូចជា "ដ៏....,ឬ ដែល...." ពីខាងដើមក៏បាន ។ គុណ-នាមត្រូវរៀងនៅខាងដើមនាមជាប្រធានដូចមានឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ **ឧច្ច** ប្រែថា "ខ្ពស់" និង **រុក្ខ** ប្រែថា "ដើមឈើ" ។

វេលារៀងចូលជាវាក្យាង្សឬកន្សោមពាក្យត្រូវតែបំបែកឱ្យមាន លិង្គ, វចនៈ និង វិភត្តិឱ្យស្មើគ្នាដូច្នេះ **ឧច្ចោ រុក្ខោ** ប្រែថា ដើមឈើខ្ពស់ ។

ខាងក្រោមនេះជាឧទាហរណ៍ក្នុងលិង្គទីមួយ ៗ

| | | |
|---|---|---|
| **ជរក្ខោ បុរិសោ** | ប្រុស(ដែល)ឈ្លាស | (បឋមា. បុំ.) |
| **ជរក្ខា កញ្ញា** | កញ្ញា(ដែល)ឈ្លាស | (បឋមា. ឥ.) |
| **ជរក្ខំ កុលំ** | ត្រកូល(ដែល)ឈ្លាស | (បឋមា. នបុំ.) |
| **ជរក្ខេន បុរិសេន** | ដោយប្រុស(ដែល)ឈ្លាស | (តតិយា. បុំ.) |
| **ជរក្ខាយ កញ្ញាយ** | ដោយកញ្ញា(ដែល)ឈ្លាស | (តតិយា. ឥ.) |
| **ជរក្ខេន កុលេន** | ដោយត្រកូល(ដែល)ឈ្លាស | (តតិយា. នបុំ.) |

## ការប្រៀបធៀបគុណនាម

(Comparison of Adjectives)

គុណនាមពោលហើយខាងលើនេះ ជាគុណនាមធម្មតា ៗ គឺមិន

ប្រាប់ឱ្យដឹងនូវកម្រិតរបស់ស័ព្ទនីមួយ ៗ ទេ ។ ដើម្បីធ្វើការប្រៀបធៀបអ្វីមួយជាមួយនឹងអ្វីមួយទៀតដូចប្រយោគថា "ផ្ទះនេះខ្ពស់ជាងផ្ទះនោះ" ត្រូវប្រើពាក្យថា ខ្ពស់=**ឧច្ច** គុណនាម និងត្រូវថែមពាក្យថា "ជាង" ដែលជានិបាតស័ព្ទក្នុងភាសាខ្មែរចូលមក ដើម្បីប្រាប់ឱ្យដឹងថាគុណនាមនោះ ៗ មានកម្រិតយ៉ាងណា ។ ដូច្នេះពាក្យថា **ឧច្ច**=ខ្ពស់ ត្រូវមានពាក្យថា ខ្ពស់ជាង ឬ ខ្ពស់បំផុត ដើម្បីប្រៀបធៀបគ្នា ។

គុណនាមទាំងឡាយចែកជា ៣ កម្រិតគឺ **បកតិគុណនាម**, **វិសេសគុណនាម** និង **អតិវិសេសគុណនាម** ។

១. **បកតិគុណនាម** (Positive Adjectives) បានដល់ គុណនាមដែលសំដែងលក្ខណៈឱ្យនាមនាមតាមធម្មតាដូច **ចាប**=អាក្រក់, **សុន្ទរ** = ល្អ, **កាឡ**=ខ្មៅ, **ឱទាត**=ស, **ទីឃ**=វែង, **រស្ស**=ខ្លី ។ល។

២. **វិសេសគុណនាម** (Comparative Adjectives) បានដល់គុណ-នាមដែលសំដែងលក្ខណៈនៃនាមនាមឱ្យវិសេស គឺប្លែកជាងប្រក្រតី ឧ. ល្អ > ល្អជាង, ខ្លី > ខ្លីជាង, វែង > វែងជាង ជាដើម ។

យោងតាមឧទាហរណ៍ខាងលើនេះ ក្នុងភាសាខ្មែរគេអាចសង្កេតឃើញមានពាក្យថា **ជាង** ។ ប៉ុន្តែក្នុងភាសាបាលីវិញត្រូវប្រើបច្ច័យក្នុងតទ្ធិត (មានអធិប្បាយនៅខាងមុខ) គឺ **តរ** និង **ឥយ្យ** ចុះចុងបកតិគុណនាមហើយត្រូវប្រែថា "ជាង" ឧ. (**រស្ស** + **តរ**) > **រស្សតរ** = ខ្លីជាង (**ឱទាត** + **តរ**) > **ឱទាតតរ** =សជាង, (**ចាប** + **ឥយ្យ**) > **ចាបិយ្យ** ឬ

ចាបីយ =អាក្រក់ជាង បែបនេះហៅថា វិសេសគុណនាម ។

៣. **អតិវិសេសគុណនាម** (Superlative Adjectives) បានដល់គុណនាមណាមួយដែលសំដែងលក្ខណៈរបស់នាមឱ្យវិសេសថ្លៃថ្លាជាងបកតិនិងវិសេសគុណនាម ឧ. ល្អបំផុត, ខ្ចីបំផុត, វែងបំផុត, ល្អបំផុត ។ នៅក្នុងភាសាខ្មែរឃើញមានប្រើពាក្យថា "បំផុត" ជាដើម ។ រីឯក្នុងភាសាបាលីវិញគឺប្រើបច្ច័យក្នុងតទ្ធិតគឺ **តម** និង **ឥដ្ឋ** ឬ **ឥស្សក** ណាមួយជាគ្រឿងសំគាល់ ឧ. (**ចាប** + **តម**) > **ចាបតម**, (**ចាប** + **ឥដ្ឋ**) > **ចាបិដ្ឋ**, (**ចាប** + **ឥស្សក**) > **ចាបិស្សក** ប្រែថា "បាបបំផុត" ។ ឬមួយក៏ចុះឧបសគ្គគឺ **អតិ** ពីមុខដូចជា (**អតិ** + **សុន្ទរ**) > **អតិសុន្ទរ** =ល្អបំផុត ។ បែបនេះហៅថា **អតិវិសេសគុណនាម** ។

| បកតិ | វិសេសគុណនាម | អតិវិសេសគុណនាម |
|---|---|---|
| ចាប | ចាបតរ, | ចាបតម, |
| | ចាបិយ្យ, | ចាបិដ្ឋ, |
| | ចាបីយ | ចាបិស្សក |
| សុន្ទរ | សុន្ទរតរ, | សុន្ទរតម, |
| | សុន្ទរិយ្យ, | សុន្ទរិដ្ឋ, |
| | សុន្ទរីយ | សុន្ទរិស្សក, |
| | | អតិសុន្ទរ |

មានគុណនាមខ្លះមានរូបប្រែប្រួល

| បកតិគុណនាម | វិសេសគុណនាម | អតិវិសេសគុណនាម |
|---|---|---|
| អន្តិក =ជិត | នេទិយ | នេទិដ្ឋ |
| ពាឡ្ហ =ខ្លាំង | សាធិយ, សាធិយ្យ | សាធិដ្ឋ |
| អប្ប =តិច | កណិយ | កណិដ្ឋ |
| យុវ =ក្មេង | កណិយ | កណិដ្ឋ |
| វុឌ្ឍ =ចាស់ | ជេយ្យ | ជេដ្ឋ |
| បសដ្ឋ = ប្រសើរ | សេយ្យ | សេដ្ឋ |
| គរុ = ធ្ងន់ | គរិយ | គរិដ្ឋ |

## វិធីប្រើគុណនាមក្នុងប្រយោគ

គុណនាមមានរបៀបប្រើបានច្រើនយ៉ាងដូចខាងក្រោមនេះ

ក. ប្រើជា **បទវិសេសន** ដើម្បីអធិប្បាយនាមបទត្រូវរៀងខាងដើមនៃនាមបទនោះ ដោយត្រូវបំបែកឱ្យមាន លិង្គ, វចនៈ និងវិភត្តិស្មើគ្នាដូចខាងក្រោមនេះ

១. **<u>ពហុកា</u>២ សកុណា១ គាមស្មា៤ បព្វតំ៥ ឧឌ្ឌេន្តិ៣។**

បក្សី.ទ.១ <u>ដ៏ច្រើន</u>២ កំពុងហើរទៅ៣ កាន់ភ្នំ៥ ចាកស្រុក៤ ។

២. មនុស្សា₁ សុន្ទរំ₄ អាហារំ₂ ភុញ្ជន្តិ₃។

មនុស្ស.ទ.₁ កំពុងបរិភោគ₃ នូវអាហារ₂ ដែលល្អ₄ ។

៣. អរិយោ₁ អគ្គស្មឹ₆ ពុទ្ធេ₆ បសាទេន₄ ព្រហ្មចរិយំ₂ ចរតិ₃។

ព្រះអរិយៈ₁ រមែងប្រព្រឹត្ត₃ នូវព្រហ្មចរិយធម៌₂ ដោយសេចក្តី ជ្រះថ្លា₄ ក្នុងព្រះពុទ្ធ₆ ដ៏ប្រសើរ₆ ។

៤. ពហូ₂ ជនា₁ អគ្គស្ស₄ ពុទ្ធស្ស₄ ធម្មំ₂ បស្សន្តិ₃។

ជន.ទ.₁ ដ៏ច្រើន₂ ឃើញ₃ នូវធម៌₂ របស់ព្រះពុទ្ធ₄ ដ៏ប្រសើរ₄ ។

សូមសង្កេតមើលបទគុណនាមដែលប្រើជាបទវិសេសនៈ ដើម្បីអធិប្បាយបទនាមក្នុងឧទាហរណ៍ខាងលើនេះ មិនអធិប្បាយត្រឹមតែបទនាមជាប្រធានប៉ុណ្ណោះទេ សូម្បីបទនាមជាបទកម្មឬមានរូបជាវិភត្តិអ្វីក៏អាចអធិប្បាយបានដែរ ។

ខ. ប្រើជា **បទវិកតិកត្តា** (Subjective Complements) ប្រើក្នុងប្រយោគដែលមានកិរិយាស័ព្ទថា "ជា, មាន, កើត" ដែលត្រូវនឹងស័ព្ទបាលីថា "ភូ, ហុ, អស" ធាតុជាកិរិយាធំ ។ ត្រូវរៀងតួវិកតិកត្តាខាងក្រោយបទប្រធានជានិច្ច ដោយត្រូវបំបែកតួវិកតិកត្តា (គុណនាម) ឱ្យមានលិង្គ, វចនៈនិងវិភត្តិឱ្យស្មើគ្នានឹងបទប្រធាននិងត្រូវរៀងដាក់ពីខាងដើមកិរិយាស័ព្ទប្រែថា "មាន, ជា, កើត" ដូច្នេះ

១. អាចរិយស្ស₂ សិស្សោ₁ កុសលោ₂ ហោតិ₃។

សិស្ស₁ របស់អាចារ្យ₂ ជាអ្នកឆ្លាត₂ ។

# កំណត់សម្គាល់

*ការប្រែគុណនាមដែលជាវិកតិកត្តានៅពីខាងដើមកិរិយាស័ព្ទ ថា "ជា, មាន, កើត" ត្រូវប្រែមុនបទកិរិយានិងត្រូវថែមពាក្យថា "ជាអ្នក, ជាប្រុស, ជាស្រី, ជាវត្ថុ, ជាធម៌" ។ល។ ជួនកាលក្នុងប្រយោគគ្មានកិរិយាស័ព្ទថា "ជា, មាន, កើត" គ្រប់គ្រងទេ ។ ប៉ុន្តែទោះបីជាគ្មានកិរិយាស័ព្ទក៏ដោយ ក៏គប្បីជ្រាបថាកិរិយាស័ព្ទបង្កប់នៅក្នុងប្រយោគនោះ ។ ពេលប្រែត្រូវថែមកិរិយាស័ព្ទថា "មាន" ពីព្រោះភាសាបាលីប្រើដូច្នេះបាន ។ ប៉ុន្តែពុំចាំបាច់មានកិរិយាស័ព្ទក៏បាន ឱ.*

**២. អាចរិយស្ស₂ សិស្សោ₁ <u>កុសលោ</u>₂ ។**

*សិស្ស₁ របស់អាចារ្យ₂ <u>ជាអ្នកឆ្លាត</u>₂ ។*

*ប្រសិនបើជាពហុវចនៈគឺដូច្នេះ*

**៣. អាចរិយស្ស₂ សិស្សា₁ <u>កុសលា</u>₂ (ហោន្តិ)។**

*សិស្ស.ទ.₁ របស់អាចារ្យ₂ <u>ជាអ្នកឆ្លាត</u>₂ ។*

**គ. គុណនាមមានច្រើនបទ**

*ប្រសិនបើមានបទវិកតិកត្តាច្រើនបទគឺរាប់ចាប់ពី ២ បទឡើងទៅតាមក្រិត្យត្រូវរៀងបទវិកតិកត្តានោះ ៗ ដាក់ខាងក្រោយបទប្រធាននិងពីខាងដើមបទកិរិយាស័ព្ទថា "ជា, មាន,..." តែមួយបទប៉ុណ្ណោះ សល់ពីនោះត្រូវរៀងដាក់ខាងក្រោយបទកិរិយាស័ព្ទ ឱ.*

**១. ពុទ្ធស្ស២ ធម្មោ១ កល្យាណោ២ ហោតិ គម្ភីរោ២។**

ធម៌១ របស់ព្រះពុទ្ធ២ ជាធម៌ល្អ២ ជាធម៌ជ្រៅ២ ។

**២. ទារិកា១ អភិរូបា២ ហោតិ ធនិកា២ មហាភោគា២ ទក្ខា២។**

ក្មេងស្រី១ ជាស្រីមានរូបស្អាត២ ជាអ្នកមានទ្រព្យ២ ជាអ្នកមាន-ភោគច្រើន២ ជាក្មេងស្រីវាងវៃ២ ។

បើតាមភាសាខ្មែរថា "ក្មេងស្រីមានរូបស្អាតសំបូរទ្រព្យមានភោគច្រើននិងជាអ្នកវាងវៃ" ។

☸ ប្រសិនបើមិនមែនជាកិរិយាស័ព្ទថា "ជា, មាន, កើត" ទេ ភាគច្រើនត្រូវរៀងតាមធម្មតាគឺពីខាងដើមនិងខាងចុងនាមជាប្រធាន ប៉ុន្តែមិនរៀងខាងចុងកិរិយាស័ព្ទទេ ដូចឧទាហរណ៍ខាងក្រោមនេះ

**ទក្ខា ទារិកា មហាភោគា ធនិកា អភិរូបា ចរតិ ។**

ក្មេងស្រី ដែលវាងវៃ មានភោគច្រើន មានទ្រព្យ និងមានរូបស្អាត កំពុងត្រាច់ទៅ ។

## បទគុណឬបទវិសេសនៈ

ស័ព្ទដែលអាចប្រើជាបទគុណឬបទវិសេសនៈ និងមានលក្ខណៈដូចជាគុណនាមបានដែរគឺ នាមនាម, វិសេសនសព្វនាម, សំខ្យាស័ព្ទ, កិតស័ព្ទ, តទ្ធិតស័ព្ទ និង សមាសស័ព្ទ ។ ចាប់ពីសំខ្យាស័ព្ទដល់សមាស

*ស័ព្ទនឹងមានអធិប្បាយនៅខាងមុខ ។ ក្នុងទីនេះ សូមលើកយកនាមនាម និងវិសេសនសព្វនាមមកអធិប្បាយបញ្ជាក់ខ្លះថែមទៀត ត្បិតអ្នកសិក្សាបានជួបរួចហើយ ។*

*ក. នាមនាមប្រើជា**បទវិសេសនៈ** បានដល់ នាមដែលមានរូបជាតតិយាវិភត្តិ, ឆដ្ឋីវិភត្តិ ឬ សត្តមីវិភត្តិនិងដែលនិយមរៀងពីខាងដើមនាមជាប្រធានរួមគ្នាមានលក្ខណៈជាវាក្យាង្គប្រកបនឡ្យាមពាក្យដូចឧទាហរណ៍ខាងក្រោមនេះ*

១. **តប<u>សា</u> ឧត្តមោ** ។ *(ឥសី) ប្រសើរដោយតបៈ ។*

២. **ពុទ្ធ<u>ស្ស</u>$_{២}$ សាវកា$_{១}$ កិលេសំ$_{៤}$ ភិន្ទន្តិ$_{៣}$**។

*សាវ័ក.ទ.$_{១}$ <u>របស់</u>ព្រះពុទ្ធ$_{២}$ រមែងទំលាយ$_{៣}$ នូវកិលេស$_{៤}$ ។*

៣. **សាវ<u>កានំ</u>$_{២}$ សង្ឃោ$_{១}$ មហន្តេ$_{៥}$ វិហារេ$_{៤}$ វសតិ$_{៣}$**។

*ក្រុមបុគ្គណៈ$_{១}$ <u>របស់</u>សាវ័ក.ទ.$_{២}$ កំពុងនៅ$_{៣}$ ក្នុងវិហារ$_{៤}$ ដ៏ធំ$_{៥}$ ។*

៤. **កុមារា$_{១}$ រុក្ខ<u>ស្មឹ</u>$_{៥}$ សកុណោ$_{៤}$ បស្សន្តិ$_{៣}$**។

*កុមារ.ទ.$_{១}$ កំពុងមើល$_{៣}$ សត្វស្លាប.ទ.$_{៤}$ <u>លើ</u>ដើមឈើ$_{៥}$ ។*

៥. **សេដ្ឋិ<u>នោ</u>$_{៤}$ ទាសេហិ$_{៣}$ រុក្ខោ$_{១}$ ឆិន្ទីយន្តិ$_{៥}$**។

*ដើមឈើ$_{១}$ គឺខ្ញុំបំរើ.ទ.$_{៣}$ <u>របស់</u>សេដ្ឋី$_{៤}$ កំពុងកាត់$_{៥}$ ។*

*ខ. នាមនាមប្រើជា**បទវិកតិកត្តា** បានដល់ នាមដែលបំបែកជាបឋមាវិភត្តិ តាមក្រិត្យឱ្យរៀងដាក់ក្រោយបទប្រធាន ប៉ុន្តែពីខាងដើមកិរិយា-ស័ព្ទថា "មាន, ជា, កើត" ដូច្នេះ*

១. សិទ្ធត្ថោ១ សក្កេ២ សុទ្ធោទនស្ស២ <u>បុត្តោ</u>២ ហោតិ ។

ព្រះសិទ្ធត្ថ១ <u>ជាព្រះឱរស</u>២ របស់ព្រះបាទសុទ្ធោទនៈ២ ក្នុងដែនសក្កៈ២ ។

២. ឯសោ២ បុរិសោ១ <u>សមណោ</u>២ ហោតិ៣។

បុរស១ នុ៎ះ២ <u>ជាអ្នកបួស</u>២ ។

រីឯរឿងការន្តនិងលិង្គអាចផ្សេងគ្នាក៏បាន គឺស័ព្ទណាមានការន្តនិងលិង្គយ៉ាងណា ទុកឱ្យគង់ជាយ៉ាងនោះចុះ ប៉ុន្តែត្រូវតែមានវិភត្តិនិងវចនៈស្មើគ្នាជានិច្ច ឧ.

១. ពុទ្ធោ១ លោកស្ស២ សរណំ២ ហោតិ៣។

ព្រះពុទ្ធ១ ព្រះអង្គជាទីពឹង២ របស់លោក២(=សត្វលោក) ។

២. បញ្ញា១ នរានំ២ រតនំ២។

បញ្ញា១ ជាកែវ(រតនៈ)២ របស់នរជន(=មនុស្ស)២ ។

៣. បមាទោ១ មច្ចុនោ២ បទំ២។

សេចក្តីប្រមាទ១ ជាផ្លូវ២ នៃសេចក្តីស្លាប់២ ។

តាមឧទាហរណ៍ខាងលើនេះបទថា **ពុទ្ធោ** ជា អ ការន្តបុំលិង្គ, រីឯ **សរណំ** ជា អ ការន្តនបុំសកលិង្គ ។ បទថា **បញ្ញា** ជា អា ការន្តឥត្ថីលិង្គ, រីឯ **រតន** ជា អ ការន្តនបុំសកលិង្គ ។ បទថា **បមាទោ** ជា អ ការន្តបុំលិង្គ, រីឯ **បទំ** ជា អ ការន្តនបុំសកលិង្គ ។ គឺផ្សេងគ្នាតែលិង្គប៉ុណ្ណោះ ចំណែកវិភត្តិជាបឋមាវិភត្តិដូចគ្នាទាំងអស់ ហើយចំណែកឯកិរិយាស័ព្ទ

*វិញមានក៏បានមិនមានក៏បាន ។*

*គ. នាមនាមក៏អាចប្រើជាបទវិសេសនៈរបស់បទកម្មបានដែរ ក្នុងករណីដូច្នេះបទមួយត្រូវតែជាបទវិសេសនៈនៃបទមួយទៀត ឧ.*

**ខត្តិយោ១ ព្រាហ្មណំ៤ មហាមត្តំ៤ បស្សតិ៣ ។**

*ក្សត្រិយ៍១ ឃើញ៣ នូវមហាមាត្យ៤ ដែលជាព្រាហ្មណ៍៤ ។*

*ប៉ុន្តែកុំច្រឡំនឹងប្រយោគខាងក្រោមដែលមានកិរិយាសព្ទជាទ្វិកម្មធាតុ ឧ.* **អជបាលោ អជំ គាមំ នេតិ ។**

*អ្នកឃ្វាលពពែ នាំ ពពែ (ទៅ)កាន់ភូមិ ។*

*ឃ. វិសេសនសព្ទនាមប្រើជាបទវិសេសនៈ ។ វិសេសនសព្ទនាមទាំងនិយមនិងអនិយម វេលាប្រើជាបទវិសេសនៈត្រូវបំបែកឱ្យមានលិង្គនិង វិភត្តិស្មើបទនាមជាប្រធានជានិច្ច ឧ.*

**១. អញ្ញស្មា៧ គាមស្មា៦ តេន៣ បុរិសេន៣ តេជានិ២ ភណ្ឌានិ១ អាហរតិ៤។** *រីអីវ៉ាន់.ទ.១នេះ២ គឺបុរស៣ នោះ៣ នាំមក៤ ពីស្រុក៦ ដទៃ៧។*

**២. សព្វេ២ សត្តា១ សុខំ៤ ឥច្ឆន្តិ៣។**

*សត្វ.ទ.១ ទាំងពួង២ តែងប្រាថ្នា៣ នូវសេចក្តីសុខ៤ ។*

## វិធីធ្វើបដិសេធគុណនាម

*របៀបធ្វើបដិសេធគុណនាមគឺត្រូវប្រើ ន ដែលត្រូវផ្លាស់ជា អ ឬ*

អន ។ បើចុះខាងដើមស័ព្ទដែលផ្ដើមដោយស្រៈត្រូវប្រើ អន តែបើស័ព្ទនោះ ៗ ផ្ដើមដោយព្យញ្ជនៈ ត្រូវប្រើ អ ដូចជា

(ន + អាកុល) > អនាកុល = មិនល្អក់ ។

(ន + អរិយ) > អនារិយ = មិនប្រសើរ ។

(ន + ទីឃ) > អទីឃ = មិនវែង ។

(ន + កុសល) > អកុសល = មិនឆ្លាត ។

## គុណនាមដែលប្រើញឹកញាប់

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ខុទ្ទក | តូប | សេត | ស |
| មហន្ត | ធំ | នីល | ខៀវ |
| ទីឃ | វែង | រត្ត | ក្រហម |
| រស្ស | ខ្លី | កាឡ | ខ្មៅ |
| ឧច្ច | ខ្ពស់ | បីត | លឿង |
| នីច | ទាប, ថោក | ឧត្តាន | រាក់ |
| មជ្ឈិម | កណ្ដាល | គម្ភីរ | ជ្រៅ |
| អប្បក | តិច | ខរ | គ្រាត, គ្រើម |
| ពហុ, ពហុក | ច្រើន | មុទុ | ទន់ |

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អាម | ខ្ចី | ពាល | ល្ងង់, ក្មេង |
| បណ្ណ | ទុំ | បណ្ឌិត | ឆ្លាត |
| ទហរ | ក្មេង | ពលវន្តុ | ខ្លាំង |
| មហល្លក | ចាស់(អាយុ) | ទុព្វល | ខ្សោយ |
| ចណ្ឌ | កាច | ឋិរ | មាំមួន |
| នាថ | ជាទីពឹង | ភោគី | មានភោគ |
| ធាប | អាក្រក់ | លាភី | មានលាភ |
| វិវិត្ត | ស្ងាត់ | អគ្គ | ប្រសើរ |
| សុរូប | មានរូបស្អាត | កិស | ស្គម |
| ទស្សនីយ | គួររមិលមើល | ថុល្ល | ធាត់ |
| ឧណ្ហ | ក្តៅ | បវរ | ប្រសើរ,បវរ |
| សីត | ត្រជាក់ | ឆាត | ឃ្លាស |
| នវ | ថ្មី | បណីត | ប្រណិត |
| ជិណ្ណ | ចាស់ | ទក្ខ | ប្រសប់ |

## លំហាត់នៃមេរៀនទី ១០

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

១. តើ **កាលាតិបត្តិ** ប្រែថាយ៉ាងម៉េច ?
២. តើកាលាតិបត្តិមានវិធីប្រកបរូបជាកិរិយាស័ព្ទប៉ុន្មានយ៉ាង ?
៣. តើ **គុណនាម** ជាស័ព្ទប្រភេទដូចម្ដេច ?
៤. តើគុណនាមអាចប្រព្រឹត្តទៅបានប៉ុន្មានលិង្គ ?
៥. តើបកតិគុណនាមជាគុណនាមដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។
៦. តើវិសេសគុណនាមជាគុណនាមដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។
៧. តើអតិវិសេសគុណនាមជាគុណនាមដូចម្ដេច ? សូមឱ្យឧទា.។
៨. តើគុណនាមអាចប្រើបានប៉ុន្មានបែប ? សូមឱ្យឧទាហរណ៍ ។
៩. ប្រសិនបើមានគុណនាមច្រើនបទតើត្រូវរៀងគុណនាមយ៉ាងម៉េច ? សូមឱ្យឧទាហរណ៍ ។
១០. ចូរបំបែកគុណនាមទាំងនេះ មុទុ, ពាល ជាបុំលិង្គគ្រប់វិភត្តិ ។

**ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ**

១. អយំ សេតោ អស្សោ ខិប្បំ ធាវតិ ។
២. ឥធំ ពេ ញាតីនំ ហោតុ, សុខិតា ហោន្តុ ញាតយោ ។
៣. ត្វំ ឯតស្មិំ បព្វតេ វស អហំ ឥមស្មិំ បព្វតេ វស្សាមិ ។
៤. អសុខាយ ធាម វិសិខាយ អសុកស្មិំ ឃរេ អយំ តរុណោ វេជ្ជោ វសតិ ។
៥. ឥមេហិ បុប្ផេហិ ពុទ្ធំ បូជេថ ។
៦. មយំ ឥមស្មិំ អារាមេ មហន្តានិ រុក្ខានិ បស្សាម ។

៧. ឥមស្ស គិលានស្ស ឧណ្ហំ ឧទកំ ទេយ្យាសិ ។

៨. ជនកោ ឧច្ចេ អាសនេ និសីតិ, បុត្តោ នីចេ អាសនេ និសីតិ ។

៩. ឥមេសុ បុប្ផេសុ សេតានិ ច រត្តានិ ច បីតានិ ច បុប្ផានិ
គណ្ហាហិ ។

១០. ឥមានិ ខុទ្ទកានិ ផលានិ មយំ ន កីណាម ។

១១. ឥមិនា ទីឃេន មគ្គេន តេ គមិស្សន្តិ ។

១២. តេ ភិក្ខូ វិវិត្តេសុ អរញ្ញេសុ រមន្តិ ។

១៣. កុសលា បណ្ឌិតា ពុទ្ធស្ស សន្តិកំ គច្ឆន្តិ ។

១៤. រត្តា គាវិយោ មហន្តេ ខេត្តេ ពហុំ តិណំ ខាទឹសុ ។

១៥. ឧច្ចា នារី នីលំ វត្ថំ បរិទហតិ (*ស្លៀកពាក់*) ។

១៦. ពហវោ មនុស្សា ទីឃាហិ រជ្ជូហិ សេតា ធេនុយោ ពន្ធន្តិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. អ្នកឈឺ មិនគួរផឹក នូវទឹក ត្រជាក់ទេ ។*

*២. មាន គ្រូពេទ្យ ក្មេង ម្នាក់ ក្នុងផ្ទះ នោះ ។*

*៣. តើឯង បានឃើញ គាត់(ប្រុស) អង្គុយ លើអាសន ខ្ពស់ ឬ ?*

*៤. ចូរឯង យក ដំបង វែង នេះ ។*

*៥. សូមឱ្យ សត្វ.ទ. ទាំងពួង មាន សេចក្តីសុខ ។*

*៦. ចូរឱ្យ សៀវភៅ.ទ. តូច នេះ ដល់សិស្ស.ទ. ។*

*៧. ខ្ញុំ ចង់បាន សេះ សម្បុរសបំផុត នេះ ។*

៨. លោក គប្បីលាង មុខ របស់លោក ជាមួយ ទឹកក្ដៅ នេះ ។
៩. មាន ដើមឈើ.ទ. តូច ផង ធំ ផង ទាប ផង ខ្ពស់ ផង ក្នុងសួន នោះ។
១០. ក្មេង.ទ. តូច កំពុងលេង ជាមួយ ឆ្កែ តូច មួយ ។
១១. បញ្ញា ជាគ្រឿងប្រសើរ ជាងទ្រព្យ ។
១២. បុគ្គល ដែលឆ្លាត តែងប្រកប នូវធម៌ ដែលជាកុសល, គេ រមែងទៅ
កាន់សុគតិ ។
១៣. យើង.ទ. តែងសំពះ លោកគ្រូ ដោយសេចក្ដីគោរព ។
១៤. ផ្កាកុលាប មានក្លិនក្រអូប ឋិតនៅ ក្នុងដៃ របស់យើង ។
១៥. អ្នក.ទ. កំពុងចង នូវមេគោ.ទ. របស់អ្នក.ទ. ដោយខ្សែ.ទ. ។
១៦. ជន.ទ. តែងកាត់ នូវដើមឫស្សី.ទ.(វេឡុ) របស់អ្នក ដោយពូថៅ ។

**(ចប់មេរៀនទី ១០)**

# មេរៀនទី ១១

## អធិប្បាយអំពីវិសេសនសព្វនាម (ត) និង កឹ ស័ព្ទ

## ២.២ អនិយមសព្វនាម

*អនិយម ប្រែថា "មិនច្បាស់លាស់" ជាសព្វនាមមួយប្រភេទដែលប្រាប់សេចក្ដីមិនច្បាស់លាស់ឬពិតប្រាកដ សម្រាប់ប្រើពីខាងដើមនាមស័ព្ទដូចនិយមសព្វនាមដែលបានពោលរួចហើយក្នុងមេរៀនទី ៩ ដែរ ។*

### អនិយមសព្វនាមមាន ១៣ ស័ព្ទ

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| យ | *... ឯណា* | អញ្ញ | *... ដទៃ, ... ឯទៀត* |
| អញ្ញតរ | *... ដទៃទៀត* | អញ្ញតម | *... មួយដទៃទៀត* |
| បរ | *... ដទៃ* | អបរ | *... ដទៃទៀត* |
| កតរ | *ដូចម្ដេច* | កតម | *ដូចម្ដេចខ្លះ, អ្វីខ្លះ* |
| ឯក | *មួយ* | ឯកច្ច | *ពួកខ្លះ* |
| ឧភយ | *ទាំងពីរ* | សព្វ | *ទាំងពួង, ទាំងអស់* |

**កឹ** (ក) *ណា, អ្នកណា, អ្វី, ឬ (ដូចគ្នានឹងបុច្ឆនត្ថនិបាត និបាតប្រាប់សំនួរ មានអធិប្បាយនៅខាងមុខ) ។*

## វិធីបំបែកអនិយមសព្វនាម

អនិយមសព្វនាមដែលពោលរួចហើយនេះ អាចបំបែកតាមវិភត្តិទាំង ៧ ដូចនិយមសព្វនាមដែរ ។ តាមរូបស័ព្ទឃើញថាមានទីបំផុតជា អ ការន្តដូចគ្នាទាំងអស់ (វៀរតែ **កឹ** ស័ព្ទចេញដែលប្លែកនិងពិសេសជាងគេមានពោលនៅខាងមុខ) ដែលប្រើបានទាំងពីរលិង្គ គឺបុំលិង្គនិងនបុំសកលិង្គ ។ ចំណែកឯឥត្ថីលិង្គត្រូវថែមស្រៈ **អា** ខាងចុងស័ព្ទសិន ។ កាលបើប្រើអធិប្បាយនាមបទណាត្រូវបំបែកឱ្យមានលិង្គ,វចនៈនិងវិភត្តិស្មើគ្នាដោយប្រើវិភត្តិសម្រេចរបស់ **អ** និង **អា** ការន្តរបស់លិង្គនោះ ។ (ចូរមើលការបំបែក **បុរិស**, **កុល**និង**កញ្ញា** នៅក្នុងមេរៀនខាងដើម)។

បើតាមសៀវភៅរៀនបាលីជាភាសាអង់គ្លេស បណ្ដាអនិយមសព្វនាមទាំងនេះ មាន ២ ស័ព្ទគឺ **យ** និង **កឹ** ឱ្យឈ្មោះដូច្នេះ ។

**យ** (Relative pronoun) សម្ពន្ធសព្វនាម ។

**កឹ** (Interrogative pronoun) បុច្ឆនសព្វនាម ។

ក្រៅពី ២ ស័ព្ទនេះ ហៅថា (Pronominal adjectives) សព្វនាមដែលប្រើជាគុណនាម ព្រោះប្រើអធិប្បាយនាមដូចគុណនាមដែរ ។

## វិធីបំបែក យ ស័ព្ទ

(Declension of a Relative Pronoun)

## វិធីបំបែក យ ស័ព្ទជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | យោ | យេ |
| ទុ. | យំ | យេ |
| ត. | យេន | យេហិ, យេភិ |
| ច. | យស្ស | យេសំ, យេសានំ |
| បញ្ច. | យស្មា, យម្ហា | យេហិ, យេភិ |
| ឆ. | យស្ស | យេសំ, យេសានំ |
| ស. | យស្មឹ, យម្ហិ | យេសុ |

*សូមសង្កេតមើលការបំបែកខាងលើនេះ ឃើញថាមានវិធីបំបែកដូច ត ស័ព្ទដែរ គឺមានវិភត្តិសម្រេចដូចគ្នា ។*

## វិធីបំបែក យ ស័ព្ទជានបុំសកលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | យំ | យានិ |
| ទុ. | យំ | យានិ |

*ក្រៅពីនេះគឺចាប់ពី តតិយាវិភត្តិដល់សត្តមីវិភត្តិ មានវិធីបំបែកដូច*

យ សព្ទបុំលិង្គដែរ ។ មានខុសតែត្រង់បឋមាឯកវចនៈនិងទុតិយាវិភត្តិ ឯកវចនៈនិងពហុវចនៈដូចខាងលើនេះប៉ុណ្ណោះ ។

## វិធីបំបែក យ សព្ទជាឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | យា | យា, យាយោ |
| ទុ. | យំ | យា, យាយោ |
| ត. | យាយ | យាហិ, យាភិ |
| ច. | យស្សា, យាយ | យាសំ, យាសានំ |
| បញ្ច. | យាយ | យាហិ, យាភិ |
| ឆ. | យស្សា, យាយ | យាសំ, យាសានំ |
| ស. | យស្សំ, យាយំ | យាសុ |

## កំណាត់សម្គាល់

១. ប្រសិនបើបំបែកជាឥត្ថីលិង្គត្រូវចុះ អា បច្ច័យឱ្យទៅជា យា សិនទើបបំបែកតាមបែប តា ។

២. អនិយមសព្វនាមដទៃទៀតចាប់ពី អញ្ញ ដល់ សព្វ មានវិធីបំបែកដូច យ សព្ទដែរ ។ រីឯ កឹ សព្ទត្រូវផ្លាស់ជា ក សិនទើបបំបែក

*តាមបែប យ សព្វទាំងបីលិង្គ ដែលនឹងមានអធិប្បាយនៅខាងមុខ ពីព្រោះ កឹ សព្វមានរបៀបប្រើពិសេសជាងគេ ។*

## វិធីប្រើនិងប្រែអនិយមសព្វនាម

*វិធីប្រែអនិយមសព្វនាមជាពិសេស យ សព្វដែលបំបែកជាបឋមាវិភត្តិ ហើយដែលជាប្រធាននៃប្រយោគ បើមានតែឯងជាឯកវចនៈប្រែថា "ណា, ឯណា" បើជាពហុវចនៈត្រូវថែមពាក្យថា "ទាំងឡាយ" ពីខាងដើមពាក្យប្រែនោះ ៗ ។ ប្រសិនបើមាន ត សព្វនៅក្នុងប្រយោគសង្កាត់ខាងក្រោយ នោះ យ សព្វក្លាយជានិយមសព្វនាមវិញ ។ ដូច្នេះឃើញថា យ សព្វអាចជាអនិយមសព្វនាមផង និងនិយមសព្វនាមផងដូច ត សព្វដែរ ពីព្រោះថា យ និង ត ទាំងពីរសព្វនេះច្រើនតែមាននៅក្នុងប្រយោគរួមគ្នាជានិច្ច ដែលអាចហៅថា យ-ត ប្រយោគផងក៏បាន ។ កាលណាមាន យ ត្រូវតែមាន ត មកទទួលដែលមានវិធីប្រើ ២ យ៉ាងគឺ*

*ក. ប្រើជា**សព្វនាម** ដោយរៀង យ សព្វតែឯកឯងនិងបំបែកជាបឋមាវិភត្តិឬទុតិយាវិភត្តិជាឯកវចនៈក៏បានឬជាពហុវចនៈក៏បាន ឧ.*

**១. យោ$_{១}$ ធម្មំ$_{៤}$ បស្សតិ$_{៣}$ សោ$_{១}$ មំ$_{៤}$ បស្សតិ$_{៣}$។**

*អ្នកណា$_{១}$ ឃើញ$_{៣}$ នូវធម៌$_{៤}$ គេ(នោះ)$_{១}$ ឃើញ$_{៣}$ យើង(តថាគត)$_{៤}$ ។*

**២. យោ$_{១}$ ពុទ្ធំ$_{៤}$ បស្សតិ$_{៣}$ សោ$_{១}$ ធម្មំ$_{៤}$ បស្សតិ$_{៣}$។**

*អ្នកណា$_{១}$ ឃើញ$_{៣}$ ព្រះពុទ្ធ$_{៤}$ គេ(នោះ)$_{១}$ ឃើញ$_{៣}$ នូវធម៌$_{៤}$ ។*

**៣. យំ$_{៤}$ អហំ$_{១}$ អាកង្ខាមិ$_{៣}$ សោ$_{១}$ ឥធ$_{៤}$ អាគមិ$_{៣}$។**

*ខ្ញុំ$_{១}$ កំពុងរង់ចាំ$_{៣}$ អ្នកណា$_{៤}$ គេ(នោះ)$_{១}$ មកហើយ$_{៣}$ កាន់ទីនេះ$_{៤}$ ។*

*ខ. ប្រើជា**បទវិសេសនៈ** មានលក្ខណៈដូចជាគុណនាមដែរ (បានអធិប្បាយរួចហើយក្នុងមេរៀនទី ១០) វេលាប្រែជាភាសាខ្មែរពុំចាំបាច់ប្រើពាក្យអាយតនិបាតទេ ។ បើប្រើអធិប្បាយនាមបទណាត្រូវរៀង យ ដាក់ខាងដើមនាមបទនោះ ៗ និងត្រូវបំបែកឱ្យមាន លិង្គ, វចន, វិភត្តិស្មើគ្នាជាឯកវចនៈឬពហុវចនៈក៏បាន ឧ.*

**១.យោ បុរិសោ គង្គាយំ នហាយតិ សោ មយ្ហំ អាចរិយោ ហោតិ។**

*បុរស ណា កំពុងងូត(ទឹក) ក្នុងទន្លេ, គាត់ ជាគ្រូ របស់ខ្ញុំ ។*

**២. យេន បុគ្គលេន ធម្មោ សុណីយតេ តេន សុខំ វិន្ទីយតិ ។**

*ធម៌ ដែលបុគ្គល ណា ស្តាប់, សេចក្តីសុខ គឺបុគ្គលនោះ រមែងទទួលបាន ។*

**៣. យស្ស សា ភរិយា ហោតិ, សោ បតិ បណ្ណាការំ ឧទិ ។**

*នាង ជាភរិយា របស់អ្នកណា, ប្តី នោះ ឱ្យហើយ នូវអំណោយ ។*

**៤. យាសំ ឥត្ថីនំ មញ្ជូសាសុ សុវណ្ណំ អត្ថិ, តាយោ ទ្វារានិ ថកេសិំសុ ។**

*មាស មាន ក្នុងប្រអប់ របស់ស្រី.ទ. ឯណា, ស្រីទាំងនោះ បិទហើយនូវទ្វារ.ទ.។*

៥. <u>យស្មឹ</u> <u>ហត្ថេ</u> ធនុ អត្ថិ, <u>តេន</u> <u>ហត្ថេន</u> បត្តោ ន តណ្ហោយ្យ ។

*ពាគរមាស់ មាន ក្នុងដៃ ណា, បាត្រ មិនគប្បីយក ដោយដៃ នោះទេ។*

៦. <u>យានិ</u> <u>កម្មានិ</u> សុខំ អាវហន្តិ, តានិ បុញ្ញានិ ហោន្តិ ។

*អំពើ.ទ. ឯណា នាំមក នូវសេចក្តីសុខ, អំពើ.ទ.នោះ ជាបុណ្យ.ទ. ។*

៧. <u>យស្មា</u> បិតារោ រុក្ខេ រោបេសុំ, <u>តស្មា</u> មយំ ផលានិ ភុញ្ជាម ។

*បិតា.ទ. ដាំហើយ នូវដើមឈើ.ទ. <u>ព្រោះហេតុណា</u>, <u>ហេតុនោះ</u> យើងនឹងស៊ី នូវផ្លែ.ទ.។*

*សូមសង្កេតមើលការប្រែប្រយោគទី ១ ចាប់ពី* **សោ មយ្ហំ អាចរិយោ ហោតិ** ។ *ឃើញថាកិរិយាស័ព្ទ* **ហោតិ** *ដែលជាកត្តុវាចកៈត្រូវប្រែទី ៥ ទៅវិញឬពុំចាំបាច់ប្រែក៏បានដែរ ។ រឿងនេះប្រព្រឹត្តទៅបានចំពោះតែ* **ហុ, អស** *និង* **ភូ** *ធាតុប៉ុណ្ណោះ ពីព្រោះធាតុនេះមានសេចក្តីមិនគ្រប់គ្រាន់ តោងហៅរកបទវិកតិកត្តា (ដែលបានអធិប្បាយរួចហើយក្នុងមេរៀនទី ១០) គឺ* **អាចរិយោ** *មកបំពេញ ។ រីឯប្រយោគទី ៧ វិញ* **យស្មា** *មិនប្រែដូចក្នុងវិភត្តិឯទៀតទេ ត្រូវប្រែថា "ព្រោះហេតុណា" និង* **តស្មា** *ក៏ដូចគ្នាដែរត្រូវប្រែថា "ហេតុនោះ" ។ ចំពោះប្រយោគទី ២ និងទី ៥ ជាប្រយោគកម្មវាចកៈមានអធិប្បាយនៅខាងមុខ ។*

## វិធីប្រែ ឯក ស័ព្ទ

**ឯក** ជាបកតិសំខ្យាស័ព្ទ (មានអធិប្បាយនៅខាងមុខ) ត្រូវយកមកប្រើជាវិសេសនសព្វនាមប្រភេទអនិយម ។ បើបំបែកជាឯកវចនៈប្រែថា "មួយ", បើជាពហុវចនៈប្រែថា "ពួកមួយ" ដែលមានវិធីបំបែកទាំងពីរវចនៈដូច **យ** ស័ព្ទទាំងបីលិង្គ ។ ក្នុងឥត្ថីលិង្គមានប្លែកត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិឯកវចនៈអាចបំបែកជា **ឯកិស្សា**, សត្តមីវិភត្តិជា **ឯកិស្សំ** បាន (ចូររកមើលការបំបែក **យ** ស័ព្ទដែលពោលរួចហើយនៅខាងលើ) ។

## វិធីបំបែក កឹ ស័ព្ទ

## (Declension of an Interrogative Pronoun)

**កឹ** ស័ព្ទដែលប្រែថា "ណា, អ្នកណា, អ្វី, ដូចម្ដេច, ...ឬ" ដូចគ្នានឹង **កឹ** ស័ព្ទក្នុងបុច្ឆនត្ថនិបាតដែរ (អធិប្បាយនៅខាងមុខ) យកមកប្រើក្នុងវិសេសនសព្វនាមប្រភេទអនិយម ។ **កឹ** ស័ព្ទអាចបំបែកបានទាំងបីលិង្គ ប៉ុន្តែត្រូវផ្លាស់ **កឹ** ជា **ក** សិនទើបបំបែកតាមបែប **យ** ស័ព្ទ ។

### វិធីបំបែក កឹ ស័ព្ទជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កោ | កេ |
| ទុ. | កំ | កេ |

| | | |
|---|---|---|
| *ត.* | កោន | កោហិ, កោភិ |
| *ប.* | កស្ស, កិស្ស | កេសំ, កេសានំ |
| *បញ្ច.* | កស្មា, កិស្មា, កម្ហា, កិម្ហា | កេហិ, កេភិ |
| *ឆ.* | កស្ស, កិស្ស | កេសំ, កេសានំ |
| *ស.* | កស្មឹ, កិស្មឹ, កម្ហិ, កិម្ហិ | កេសុ |

## កំណត់សម្គាល់

*កាលបើផ្លាស់* កឹ *ជា* ក *គឺក្លាយទៅជា* អ *ការន្តហើយ ដូច្នេះទើបមានវិធីបំបែកតាមបែប* យ *គ្រប់វិភត្តិ ។ ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិឯកវចនៈមានរូបជា* កិស្ស, *ត្រង់បញ្ចមីវិភត្តិឯកវចនៈមានរូបជា* កិស្មា, កិម្ហា *និងសត្តមីវិភត្តិឯកវចនៈមានរូបជា* កិស្មឹ, កិម្ហិ *ផងដែរ ។*

## វិធីបំបែក កឹ ស័ព្ទជានបុំសកលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | កឹ, កំ | កានិ |
| *ទុ.* | កឹ, កំ | កានិ |

*ការបំបែក* កឹ *ជានបុំសកលិង្គចាប់ពីតតិយាវហូតដល់សត្តមីវិភត្តិទាំង ២ វចនៈមានរូបដូចបុំលិង្គទាំងអស់ ។*

## វិធីបំបែក កឹំ ស័ព្ទជាឥត្ថីលិង្គ

ប្រសិនបើជាឥត្ថីលិង្គត្រូវចុះ អា បច្ច័យឱ្យទៅជា កា សិនទើប បំបែកតាមបែប យា ។

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កា | កា, កាយោ |
| ទុ. | កំ | កា, កាយោ |
| ត. | កាយ | កាហិ, កាភិ |
| ច. | កស្សា, កាយ | កាសំ, កាសានំ |
| បញ្ច. | កាយ | កាហិ, កាភិ |
| ឆ. | កស្សា, កាយ | កាសំ, កាសានំ |
| ស. | កស្សំ, កាយំ | កាសុ |

## វិធីប្រើនិងប្រែ កឹំ ស័ព្ទ

កឹំ ស័ព្ទមានលក្ខណៈពិសេសនិងមានវិធីប្រើក្នុងប្រយោគផ្សេង ៗ បាន ៦ យ៉ាងគឺ

ក. ប្រើជា **បុច្ឆាសព្វនាម** (Interrogative pronoun) គឺប្រើដោយ រៀងដាក់ កឹំ ស័ព្ទតែឯកឯងគ្មាននាមបទជាប្រធាននៅផងទេ ។ វេលា ប្រែត្រូវប្រើអាយតនិបាតដូចនាមនាមដែរ ដូចខាងក្រោមនេះ

១. <u>កោ</u>១ តស្មឹ៥ កុដិយំ៤ និសីទតិ៣។

*តើ<u>អ្នកណា</u>១ អង្គុយ៣ ក្នុងកុដិ៤ នោះ៥ ?*

២. <u>កោ</u>១ តេ៤ អាចរិយោ៣ (ហោតិ)។

*តើ<u>អ្នកណា</u>១ ជាគ្រូ៣ របស់អ្នក៤ ?*

៣. <u>កេ</u>៣ តុម្ហេ១ ហោថ២ ?

*តើអ្នក.ទ.១ ជា២ <u>នរណា</u>៣ ?*

៤. <u>កេន</u>២ ធេនុ១ អដវិយា៤ អានីយតេ៣ ?

*តើមេគោ១ <u>គឺអ្នកណា</u>២ នាំមក៣ ពីព្រៃ៤ ?*

៥. កស្ស៤ ភូបតិនោ២ បាសាទំ១ ករិស្សតិ៣ ?

*តើស្តេច នឹងកសាង នូវប្រាសាទ <u>ដើម្បីអ្នកណា</u> ?*

៦. <u>កស្មា</u>៤ អម្ហេ១ សច្ចំ៣ ភាសេយ្យាម២?

*យើង១ និយាយ២ សច្ចៈ៣ ព្រោះ<u>ហេតុអ្វី</u>៤?*

៧. <u>កស្មឹ</u> ធនុ អត្ថិ ?

*តើរមាស់ មាន <u>ក្នុងអ្នកណា</u> ?*

*សូមសង្កេតមើល ប្រយោគខាងលើទាំងអស់ជាបុច្ឆនត្ថប្រយោគ គឺប្រយោគសំណួរ ទើបមានវិធីប្រែខុសពីវិធីប្រែមុន ៗ ។ រីប្រយោគទី ៤ ជាប្រយោគកម្មវាចកៈ មានអធិប្បាយនៅខាងមុខ ។ ចំពោះ* **កឹ** *ដែលបំបែកជាបញ្ចមីវិភត្តិបើប្រើជាសព្វនាមដូចខាងលើនេះ មិនប្រែថា "ពី ឬ ចាកអ្នកណា" ទេ ត្រូវប្រែថា "ព្រោះហេតុអ្វី" វិញ ។*

ខ. ប្រើជា **បុច្ឆាសព្វនាម** (Interrogative pronoun) ប៉ុន្តែជាការប្រើដែលមានដំណើរដូចគុណនាម គឺមាននាមបទជាប្រធាននៅជាមួយផងដែរ ។ វេលាប្រែពុំចាំបាច់ប្រើអាយតនិបាតទេ គឺប្រែទទេ ៗ ថា "ណា" ។ ប៉ុន្តែបើជាឆដ្ឋីវិភត្តិត្រូវប្រែថា "របស់អ្នកណា" ទោះជាលិង្គអ្វីក៏ដោយ ។ បើប្រើអធិប្បាយនាមណាត្រូវបំបែកឱ្យមាន លិង្គ, វចនៈនិងវិភត្តិស្មើគ្នា ហើយរៀងដាក់ខាងដើមនាមជាប្រធាន ឧ.

១. <u>កស្ស</u> បុគ្គលស្ស បុត្តោសិ ត្វំ?

តើឯង ជាកូន <u>របស់បុគ្គលណា</u> ?

២. <u>កស្សា</u> ឥត្ថិយា ហត្ថេ បុប្ផានិ សន្តិ?

តើបុប្ផា.ទ. មាន ក្នុងដៃ របស់ស្រី <u>ណា</u> ?

៣. <u>កោ</u> បុគ្គលោ ធម្មំ សុណាតិ?

តើធម៌ គឺបុគ្គល <u>ណា</u> កំពុងស្តាប់ ?

គ. ប្រើដោយមាន ចិ ដែលជាអសាកល្យត្ថវាចកនិបាតស័ព្ទនៅខាងចុង **គឺ** ស័ព្ទជានិច្ច ដែលអាចប្រើជាសព្វនាមក៏បានឬជាគុណនាមក៏បាន ។ បើជាឯកវចនៈប្រែថា "ណាមួយ, ណា ៗ, អ្នកណា ៗ, នីមួយ, អ្វីមួយ, អ្វី ៗ, តិចតួច" ។ បើជាពហុវចនៈប្រែថា "ពួកមួយ, ពួកខ្លះ, អ្នកខ្លះ, ...ខ្លះ" ជាដើម ឧ.

<u>កោចិ</u> មម គេហំ ន អាគច្ឆតិ ។

តើ<u>អ្នកណា</u> មិនមក កាន់ផ្ទះ របស់ខ្ញុំ ?

<u>កិញ្ចិ</u>បិ កាតុំ សោ ន ជានាតិ ។

*គេ មិនដឹង ដើម្បីធ្វើ <u>នូវអ្វីមួយ</u>ទេ ។*

**កោចិ បុរិសោ** = *ប្រុសណាមួយ (បុំ. ឯក.) ។*

**កេចិ បុរិសា** = *ប្រុស.ទ.ពួកមួយ (បុំ. ពហុ.) ។*

**កាចិ ឥត្ថី** = *ស្រីណាមួយ (ឥ. ឯក.) ។*

**កាចិ ឥត្ថិយោ** = *ស្រី.ទ.ពួកមួយ (ឥ. ពហុ.) ។*

**កិញ្ចិ កុលំ** = *ត្រកូលណាមួយ (នបុំ. ឯក.) ។*

**កានិចិ កុលានិ** = *ត្រកូល.ទ.ពួកមួយ (នបុំ. ពហុ.) ។*

*ឃ. ប្រើបែបមាន* **យ** *ស័ព្ទនៅខាងដើមនិងមាន* **ចិ** *នៅខាងចុង* **កឹ** *។* **កឹ** *ស័ព្ទត្រូវបំបែកឱ្យមានវចនៈនិងវិភត្តិស្មើគ្នានិង* **យ** *ស័ព្ទនៅខាងដើមដែលមានដំណើរដូចគុណនាម ។ វេលាប្រែជាភាសាខ្មែរពុំចាំបាច់ប្រែចេញអាយតនិបាតទេ ។ ប្រសិនបើជាឯកវចនៈប្រែថា "ឯណាមួយ, ឯណានីមួយ, អ្នកណាមួយ" ឧ.*

**យោ₂ កោចិ₂ ទេវោ₁ មម₆ គេហស្ស₅ ទ្វារកោដ្ឋកេ₄ អធិវសតិ₃។** *ទេវតា₁ ឯណាមួយ₂ អាស្រ័យនៅ₃ ក្នុងខ្លោងទ្វារ₄ នៃផ្ទះ₅ របស់ខ្ញុំ₆ ។*

*វេលាប្រែត្រូវអានគួបគ្នាថា* **យោ-កោចិ** *។*

**យា កាចិ វេទនា ......** = *រីវេទនាឯណាមួយ...... (ឥ.) ។*

**យង្កិញ្ចិ វិត្តំ ......** = *រីទ្រព្យជាគ្រឿងល្បួងចិត្តឯណានីមួយ ... ។*

ប្រសិនបើជាពហុវចនប្រែថា "ពួកណាមួយ" ឧ.

**យេ កេចិ ជនា** ...... = វិជម៌.ទ.ពួកណានីមួយ ...... ។

## កំណត់សម្គាល់

សូមសង្កេតមើល **ចិ** ស័ព្ទដែលចុះភ្ជាប់ជាមួយ **កឹ** ស័ព្ទឥតបំបែកទេ ពីព្រោះជាអព្យយស័ព្ទ រីឯ **យ** និង **កឹ** ស័ព្ទត្រូវបំបែកទៅតាមលិង្គរៀង ៗ ខ្លួន ។ ប៉ុន្តែ **កឹ** ស័ព្ទដែលមាន **ចិ** នៅខាងចុងនោះ ជាពិសេសត្រង់ដែលមាននិគ្គហិត (ំ) នៅខាងលើដូចជា **កឹ, កំ, កេសំ, កស្មឹ, កេសានំ** ។ល។ ត្រូវផ្លាស់និគ្គហិតទៅជា **ញ** សិនរួចទើបនាំយកមកសរសេរចូលគ្នាតាមវិធីសន្ធិដូច្នេះ

**កឹ** + **ចិ** ទៅជា **កិញ** + **ចិ** > **កិញ្ចិ** ។

ឧ. **យង្កិញ្ចិ វិត្តំ ឥធ វា ហុរំ វា**...... វិទ្រព្យជាគ្រឿងរីករាយចិត្ត អ្វីឯណាមួយ ក្នុងលោកនេះ ក្តី ក្នុងលោកដទៃ ក្តី...... ។

**យង្កិញ្ចិ** < ( **យំ** + **កឹ** + **ចិ** ) ។

**យ** និង **កឹ** ត្រូវបំបែកឱ្យមានលិង្គនិងវិភត្តិស្មើគ្នា ខាងក្រោមនេះជាឧទាហរណ៍ខ្វះក្នុងបុំលិង្គ ។

**យោ កោចិ** (ប. ឯក.),.

**យេ កេចិ** (ប. ពហុ.),.

**យំ កិញ្ចិ** > **យង្កិញ្ចិ** (ទុ. ឯក.),.

យេ កោចិ (*ទុ. ពហុ.*),.

យេន កេនចិ (*ត. ឯក.*),.

យេហិ កេហិចិ (*ត. ពហុ.*),.

យស្ស កស្សចិ (*ច. ឯក.*),.

យេសំ កេសំចិ > យេសង្កេសញ្ចិ (*ច. ពហុ.*) ។ល។

*ង. ប្រើជាបុច្ឆនត្ថនិបាត ក្នុងប្រយោគសំនួរ ។ បើប្រើដូច្នេះ* **កឹ** *ឬ* **កំ** *ពុំចាំបាច់បំបែកតាមវិភត្តិទេប្រែថា "ឬ, អ្វី, ហេតុអ្វី, ព្រោះអ្វី, ដូចម្តេច" ដែលច្រើនមាន* **បន** *និបាតស័ព្ទ ប្រែថា "ក៏" នៅខាងចុងដែលត្រូវរៀង* **កឹ** *នៅខាងដើមប្រយោគនិងរៀង* **បន** *ដាក់នៅទី ២ ប៉ុន្តែបើគ្មាន* **បន** *ទេរៀង* **កឹ** *ដាក់ត្រង់ណាក៏បានដូចខាងក្រោមនេះ*

## ប្រយោគសំនួរក្នុងភាសាបាលី

*ប្រយោគសំនួរក្នុងភាសាបាលីមាន ៤ បែបដូចខាងក្រោមនេះ*

*ក. ប្រើ* **កឹ** *ស័ព្ទ*

១. <u>កឹ</u> បន គាមំ បិណ្ឌាយ ចរសិ ?

*ក៏(លោក) ដើរទៅ កាន់ភូមិ ដើម្បីដុំបាយ <u>ឬ</u>?*

២. <u>កឹ</u> តុម្ហេ អជ្ជ វិហារំ ន គច្ឆិត្ថ ?

*ក្នុងថ្ងៃនេះ អ្នក.ទ. មិនទៅ វិហារទេ <u>ឬ</u>?*

៣. អហំ ឥទ ជម្ពុំ ឧក្កណ្ហាមិ តុម្ហេ <u>អត្រ</u> កឹ ការោថ ?

ខ្ញុំ កំពុងរៀន ធម៌ ទីនេះ ។ តើអ្នក.ទ. កំពុងធ្វើ អ្វី ទីនោះ ?

៤. **កឹំ ចាលិត បមជ្ជសិ ។**

ម្នាលបាលិត (ឯង) ប្រមាទ ព្រោះអ្វី ?

ខ. ធ្វើ **វិលោមកម្ម** បានដល់ ការលើកយកអាខ្យាតកិរិយាស័ព្ទមកដាក់នៅខាងដើមប្រយោគ ដូចខាងក្រោមនេះ

**គច្ឆសិ គាមំ** ? (លោក) ទៅ កាន់ផ្ទះ ឬ ?

**ខមតិ តេ ឥទំ** ? តើនេះ គួរ ដល់អ្នក ឬទេ ?

**ឥទំ មេ ខមតិ ។** នេះ គួរ ដល់ខ្ញុំ ។

**បរិបុណ្ណាន្តេ** < (**បរិបុណ្ណំ** + **តេ**) **បត្តចីវរំ** ?

បាត្រនិងចីវរ របស់អ្នក គ្រប់ហើយ ឬ ?

☸ ប៉ុន្តែជួនកាលគ្មានកិរិយាស័ព្ទក្នុងប្រយោគក៏បាន ឧ.

**អយន្តេ** (**អយំ** + **តេ**) **បត្តោ** ?

តើនេះ ជាបាត្ររបស់លោក ឬ ?

(ចូរមើលវិធីប្រើវិកតិកត្តាត្រង់គុណនាមក្នុងមេរៀនទី ១០)

គ. ប្រើ **អព្យយស័ព្ទ** ដូចជា **កទា** =ក្នុងកាលណា, **កុហឹ** = ក្នុងទីណា **កុតោ** =អំពី...ឯណា,” ជាដើម ជាពាក្យសម្រាប់សួរដែលត្រូវរៀងដាក់នៅខាងដើម និងនិយមរៀងតួកិរិយាស័ព្ទដាក់ខាងចុងបំផុតនៃប្រយោគ ឧ.

**កទា ចាលិកាសំ ឧគណ្ហាថ** ?

*តើអ្នក.ទ. រៀន ភាសាបាលី ពីអង្កាល ?*

**កុតោ អាគច្ឆសិ ?**

*តើឯង មក ពីណា, ឬ ឯង ទើបមក ពីឯណា ?*

*ឃ. ប្រើ អបិ ឬ អបិ នុ នៅខាងដើមប្រយោគបែប* **កឹ** *ស័ព្ទ ឌ.*

**អបិ គច្ឆសិ ? អបិ នុ គច្ឆសិ ?** *តើលោក ទៅ ឬ ?*

**អបិ ត្វំ យក្ខំ ទិស្វា ភាយិ ?**

*តើឯង ភ័យ ព្រោះឃើញ យក្ស ឬ ?*

**អបិ នុ តុម្ហេ តត្រ អហឹ បស្សថ ?**

*តើអ្នក.ទ. ឃើញ ពស់ ក្នុងទីនោះ ឬ ?*

## លំហាត់នៃមេរៀនទី ១១

### *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើអនិយមសព្វនាមប្រែថាដូចម្ដេច ?*

*២. ចូរបំបែក* **សព្វ** *ស័ព្ទជាបុំលិង្គនិងគ្រប់វិភត្តិ ។*

*៣. តើអនិយមសព្វនាមប្រើបានប៉ុន្មានយ៉ាង ? សូមឱ្យឧទាហរណ៍ ។*

*៤. តើ* **កឹ** *ស័ព្ទប្រែថាដូចម្ដេចខ្លះ ?*

*៥. ចូរបំបែក* **កឹ** *ស័ព្ទជាបុំលិង្គនិងគ្រប់វិភត្តិ ។*

៦. តើ កឹ សព្ទប្រើបានប៉ុន្មានយ៉ាង? សូមឱ្យឧទាហរណ៍ ។

៧. តើប្រយោគសំនួរមានប៉ុន្មានបែប? សូមឱ្យឧទាហរណ៍ ។

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. កោ នាមោ ត្វំ ?

២. កោ នាមោ ឯសោ ?

៣. កោ នាមោ តេ អាចរិយោ ?

៤. ឥទានិ ឯសោ កឹ ករិស្សតិ ?

៥. កឹ ត្វំ ឯតំ បុច្ឆសិ ?

៦. ឯសា នារី តេ កឹ ហោតិ ?

៧. ស្វេ កិមេតេ ករិស្សន្តិ ?

៨. កស្ស ភិក្ខុស្ស តំ ចោត្តកំ បេសេស្សាម ?

៩. តេសំ ជនេន មេ កឹ បយោជនំ ?

១០. កិស្ស ផលំ នាម ឯតំ ?

១១. កាយំ ទិសាយំ តស្សា ជននី ឥទានិ វសតិ ?

១២. យោ ធម្មំ បស្សតិ សោ ពុទ្ធំ បស្សតិ ។

១៣. យោ ពុទ្ធំ បស្សតិ សោ ធម្មំ បស្សតិ ។

១៤. យំ តេ ករោន្តិ តំ បរំ លោកំ គណ្ហិស្សន្តិ ។

១៥. ឯតានិ ផលានិ មា តស្ស សកុណស្ស ទេថ ។

១៦. ឯតស្មឹ នគរេ សព្វេ នរា អបរំ នគរំ អគមឹសុ ។

## គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. តើនាង ជា អ្នកណា ?

២. តើគាត់ ឈ្មោះ អ្វី ?

៣. តើឯង បានទៅ កាន់ទិស ណា ?

៤. តើគេ ជាញាតិ របស់អ្នក ឬ ?

៥. តើផ្ទៃ នេះ ឈ្មោះ អ្វី ?

៦. តើឯង បានទិញ សៀវភៅ នេះ ពីអ្នកណា ?

៧. តើក្មេងប្រុស និង ក្មេងស្រី ទាំងអស់នោះ កំពុងលេង ក្នុងសួន របស់អ្នកណា ?

៨. តើគាត់(ស្រី) បានឱ្យ នូវអំណោយ ទាំងអស់នេះ ចំពោះអ្នកណា ?

៩. អ្នកទាំងឡាយណា រមែងធ្វើ នូវបុណ្យ រឿយ ៗ អ្នកទាំងឡាយនោះ នឹងទៅ កាន់សុគតិ ។

១០. យើង មិនបានសរសេរ នូវសំបុត្រ ទាំងអស់ នោះទេ ។

១១. ប្រសិនបើ គាត់ ចង់ សូមឱ្យគាត់ និយាយចុះ ។

១២. អ្វីដែល អ្នក បានឃើញ ដោយភ្នែក របស់អ្នក, អ្នក មិនគួរប្រាប់ អ្នកដទៃទេ ។

១៣. កាលណា(**យទា**) អ្នក ទៅ កាន់លោក ដទៃ, អ្នក មិនយក នូវអ្វី (ទៅ)ជាមួយឡើយ ។

១៤. លោកសេដ្ឋី តើទ្រព្យធន ទាំងនេះ មាន ប្រយោជន៍ អ្វី ?

(ចប់មេរៀនទី ១១)

# កំណាព្យដាស់តឿនស្មារតី

កុំអៀនខ្មាស់ ខុសភ្ជាត់ខ្លះ មិនជាអ្វី
និយាយស្តី រឿយ ៗ ទៅ គង់ត្រូវបាន
រៀននិយាយ ឱ្យបានញយ ទើបចំណាន
ចំណេះមាន បានចំណេញ ផលល្អអឺយ ។

ដកស្រង់ពីសៀវភៅ
"រៀនភាសាអង់គ្លេស ៦៣ ម៉ោងដោយខ្លួនឯង"
ទំព័រ៦៨ ដោយលោក **ឱម ណាត្រី**

# មេរៀនទី ១២

## អធិប្បាយអំពីសំខ្យាស័ព្ទពី ១-១០០

## សំខ្យាស័ព្ទ (Numerals)

***សំខ្យា*** *ប្រែថា "ការរាប់" មានពីរប្រភេទគឺ* ***បកតិសំខ្យា*** *និង* ***បូរណសំខ្យា*** *។*

*១. ការរាប់វត្ថុតាមប្រក្រតីដូចជារាប់ថា មួយ, ពីរ, បី, បួន, ប្រាំ ជាដើមរហូតដល់ ដប់, រយ, ពាន់, ម៉ឺន, សែន, លាន ។ល។ ហៅថា* ***បកតិសំខ្យា*** (Cardinal numbers) ។

*២. ការរាប់វត្ថុតាមជាន់ថ្នាក់ដូចជារាប់ថា ទី១, ទី២, ទី៣, ទី៤, ទី៥ ជាដើមឬក៏រាប់ថា ជាដំបូង, ជាគម្រប់ពីរ, ជាគម្រប់បី, ជាគម្រប់បួន ជាដើមហៅថា* ***បូរណសំខ្យា*** (Ordinal Numbers) (*មានអធិប្បាយនៅខាងមុខ*) ។

## ១. បកតិសំខ្យា

## (Cardinal numbers)

*ការរាប់ចំនួនក្នុងភាសាខ្មែរមានប្រើលេខ ។ រីឯក្នុងភាសាបាលីមិនមានតួលេខទេ គឺប្រើតែតួអក្សរ ។ អាស្រ័យហេតុនេះឃើញថាមានការលំបាកបន្តិចដែរ ។ ដើម្បីឱ្យមានការងាយស្រួលខ្លះ គឺត្រូវចែកការរាប់*

នេះជាចំណែក ៗ ។ ដំបូងនេះត្រូវរៀនរាប់ពី ១ ដល់ ១០ សិនគឺ

| បាលី | លេខខ្មែរ | បាលី | លេខខ្មែរ | បាលី | លេខខ្មែរ |
|---|---|---|---|---|---|
| ឯក | = ១ | ចតុ | = ៤ | សត្ត | = ៧ |
| ទ្វិ | = ២ | បញ្ច | = ៥ | អដ្ឋ | = ៨ |
| តិ | = ៣ | ឆ | = ៦ | នវ | = ៩ |
| | | | | ទស | = ១០ |

## កំណត់សម្គាល់

សូមរៀនរាប់ចុះឡើង ៗ ឱ្យបានច្រើនដងដើម្បីឱ្យរត់មាត់ដូចកាលដែលយើងរៀនរាប់លេខខ្មែរបារាំងអង់គ្លេសដូច្នោះដែរ គឺរាប់ពី ឯក, ទ្វិ, តិ ដល់ ទស ។

កាលបើចាំរត់មាត់ល្អហើយ ត្រូវរៀនឱ្យចាំនូវចំនួនគត់ដប់តទៅទៀតគឺ ១០, ២០, ៣០, ៤០, ៥០ ជាដើម ។

| ស័ព្ទបាលី | លេខខ្មែរ | ស័ព្ទបាលី | លេខខ្មែរ |
|---|---|---|---|
| ទស | = ១០ | សដ្ឋី | = ៦០ |
| វីស, វីសតិ | = ២០ | សត្តតិ, សត្តរិ | = ៧០ |
| តឹស, តឹសតិ | = ៣០ | អសីតិ | = ៨០ |
| ចត្តាឡីស, តាឡីស | = ៤០ | នវុតិ | = ៩០ |
| បញ្ញាស, បណ្ណាស | = ៥០ | សត | = ១០០ |

*រីឯការរាប់ចំនួនដែលលើសពីចំនួនគត់ដប់ ៗ ដូចជា ១១, ២៣, ៤៥, ៧៦, ៨៩, ៩២ ជាដើម មានវិធីធ្វើដូច្នេះ គឺត្រូវនាំយកចំនួនតិចគឺចំនួនសេសឬលើសមកដាក់ខាងមុខឬខាងដើម និងដាក់ចំនួនច្រើនគឺចំនួនគត់ដប់ ៗ នៅខាងចុងឬខាងក្រោយដែលផ្ទុយពីរបៀបខ្មែរយើង ។ សូមមើលតារាងខាងក្រោមនេះ*

*បែបបាលី*

| ចំនួនតិច | ចំនួនច្រើន | សម្រេចជា | បែបខ្មែរ |
|---|---|---|---|
| ឯក | + ទស > | ឯកាទស, ឯការស | ១០ + ១ = ១១ |
| ទ្វិ | + ទស > | ទ្វាទស, ពារស | ១០ + ២ = ១២ |
| តិ | + ទស > | តេរស, តេឡស | ១០ + ៣ = ១៣ |
| ចតុ | + ទស > | ចតុទ្ទស, ចុទ្ទស | ១០ + ៤ = ១៤ |
| បញ្ច | + ទស > | បញ្ចទស, បណ្ណរស | ១០ + ៥ = ១៥ |
| ឆ | + ទស > | សោឡស | ១០ + ៦ = ១៦ |
| សត្ត | + ទស > | សត្តទស, សត្តរស | ១០ + ៧ = ១៧ |
| អដ្ឋ | + ទស > | អដ្ឋាទស, អដ្ឋារស | ១០ + ៨ = ១៨ |

**ឯកាទស** ឬ **ឯការស** *ប្រែថា "មួយនិងដប់" ៗ ប៉ុន្តែក្នុងភាសាខ្មែរថា "មួយដន់ដប់" ទៅវិញគឺផ្លាស់ (និង > ដន់) ឬក៏ថា "ដប់មួយ" តាមធម្មតាក៏បាន ។*

*ការផ្សំពីខ្ទង់ ២០ ដល់ខ្ទង់ ៩០ ក៏ធ្វើដូច្នេះទាំងអស់ ឧទាហរណ៍*

ឧ. ២១ (**ឯក** + **វីស**) > **ឯកវីស**, ឬ (**ឯក** + **វីសតិ**) > **ឯកវីសតិ** ។

ឧ. ៤៥ (**បញ្ច** + **ចត្តាឡីស**) > **បញ្ចចត្តាឡីស**, ឬ (**បញ្ច** + **តាឡី-ស**) > **បញ្ចត្តាឡីស** ។

*សូមសង្កេតមើលការរាប់ខាងលើនៅមិនទាន់មានលេខ ១៩ ទេ ។ ការផ្សំចំនួនណាដែលមានលេខ ៩ ខាងចុងដូចជា ១៩, ២៩, ៣៩, ៤៩, ៥៩, ៦៩, ៧៩, ៨៩, ៩៩ មិនអាចធ្វើតាមវិធីខាងលើដែលយក* **នវ** *=៩ មកដាក់ខាងដើមនិងដាក់* **ទស** *=១០ ខាងចុងឱ្យទៅជា* **នវទស** *ដូច្នេះបានទេ គឺត្រូវប្រើពាក្យថា* **ឩន** *ប្រែថា "ខ្វះ" ឬ* **ឯកូន** *ប្រែថា "ខ្វះមួយ" ដាក់ខាងដើមចំនួនគត់ជប់ ៗ ដូច្នេះ ។*

ឧ. ១៩ (**ឯកូន** + **វីស**) > **ឯកូនវីស** ឬ (**ឩន** + **វីស**) > **ឩនវីស** ។

ឧ. ១៩ (**ឯកូន** + **វីសតិ**) > **ឯកូនវីសតិ**, ឬ (**ឩន** + **វីសតិ**) > **ឩនវីសតិ** *ប្រែថា "ម្ភៃខ្វះមួយ ឬ ម្ភៃខ្វះ" គឺ ១៩ ។*

*ខាងក្រោមនេះជាការរាប់ពី ១៩ ដល់ ១០០*

**ឯកូនវីស, ឩនវីស, ឯកូនវីសតិ, ឩនវីសតិ**.................. = ១៩

**វីស, វីសតិ**.......................................................................... = ២០

**ឯកវីស, ឯកវីសតិ**................................................................ = ២១

**ទ្វាវីស, ពាវីស, ទ្វាវីសតិ, ពាវីសតិ**................................. = ២២

**តេវីស, តេវីសតិ**.................................................................. = ២៣

ចតុវីស, ចតុវីសតិ........................................................... = ២៤

បញ្ចវីស, បញ្ចវីសតិ......................................................... = ២៥

ឆព្វីស, ឆព្វីសតិ.............................................................. = ២៦

សត្តវីស, សត្តវីសតិ......................................................... = ២៧

អដ្ឋវីស, អដ្ឋវីសតិ........................................................... = ២៨

ឯកូនត្តឹស, ឩនត្តឹស, ឯកូនត្តឹសតិ, ឩនត្តឹសតិ............. = ២៩

តឹស, តឹសតិ....................................................................... = ៣០

ឯកត្តឹស, ឯកត្តឹសតិ........................................................ = ៣១

ទ្វត្តឹស, ទ្វត្តឹសតិ, ពត្តឹស, ពត្តឹសតិ.................................. = ៣២

តេត្តឹស, តេត្តឹសតិ........................................................... = ៣៣

ចតុត្តឹស, ចតុត្តឹសតិ......................................................... = ៣៤

បញ្ចត្តឹស, បញ្ចត្តឹសតិ...................................................... = ៣៥

ឆត្តឹស, ឆត្តឹសតិ.............................................................. = ៣៦

សត្តត្តឹស, សត្តត្តឹសតិ...................................................... = ៣៧

អដ្ឋត្តឹស, អដ្ឋត្តឹសតិ........................................................ = ៣៨

ឯកូនចត្តាឡីស, ឩនចត្តាឡីស, ឯកូនតាឡីស,

ឩនតាឡីស............ = ៣៩

ចត្តាឡីស, តាឡីស........................................................... = ៤០

ឯកចត្តាឡីស, ឯកត្តាឡីស.............................................. = ៤១

ទ្វេចត្តាឡីស, ទ្វេតាឡីស................................................... = ៤២
តេចត្តាឡីស, តេតាឡីស.................................................... = ៤៣
ចតុចត្តាឡីស, ចតុត្តាឡីស.............................................. = ៤៤
បញ្ចចត្តាឡីស, បញ្ចត្តាឡីស........................................... = ៤៥
ឆចត្តាឡីស, ឆត្តាឡីស..................................................... = ៤៦
សត្តចត្តាឡីស, សត្តត្តាឡីស........................................... = ៤៧
អដ្ឋចត្តាឡីស, អដ្ឋត្តាឡីស.............................................. = ៤៨
ឯកូនបញ្ញាស, ឩនបញ្ញាស, ឯកូនបណ្ណាស,
ឩនបណ្ណាស.............. = ៤៩
បញ្ញាស, បណ្ណាស............................................................ = ៥០
ទ្វេបញ្ញាស, ទ្វេបណ្ណាស.................................................... = ៥២
អដ្ឋបញ្ញាស, អដ្ឋបណ្ណាស................................................. = ៥៨
ឯកូនសដ្ឋី, ឩនសដ្ឋី.......................................................... = ៥៩
សដ្ឋី.................................................................................. = ៦០
ទ្វេសដ្ឋី, ទ្វាសដ្ឋី............................................................. = ៦២
ចតុស្សដ្ឋី.......................................................................... = ៦៤
ឆស្សដ្ឋី............................................................................ = ៦៦
ឯកូនសត្តតិ, ឩនសត្តតិ, ឯកូនសត្តរិ, ឩនសត្តរិ......... = ៦៩
សត្តតិ............................................................................... = ៧០

ទ្វេសត្តតិ, ទ្វាសត្តតិ, ទ្វេសត្តរិ, ទ្វាសត្តរិ.......................... = ៧២

ឯកូនអសីតិ, ឩនអសីតិ, ឯកូនាសីតិ, ឩនាសីតិ......... = ៧៩

អសីតិ........................................................................ = ៨០

ឯកអសីតិ, ឯកាសីតិ.................................................... = ៨១

ទ្វេអសីតិ, ទ្វាសីតិ ........................................................ = ៨២

តេអសីតិ, ត្យាសីតិ......................................................... = ៨៣

ចតុអសីតិ, ចតុរាសីតិ..................................................... = ៨៤

បញ្ចអសីតិ, បញ្ចាសីតិ.................................................... = ៨៥

ឆអសីតិ, ឆាសីតិ, ឆរាសីតិ, ឆឡាសីតិ.......................... = ៨៦

សត្តអសីតិ, សត្តាសីតិ.................................................... = ៨៧

អដ្ឋអសីតិ, អដ្ឋាសីតិ...................................................... = ៨៨

ឯកូននវុតិ, ឩននវុតិ........................................................ = ៨៩

ទ្វេនវុតិ, ទ្វានវុតិ............................................................ = ៩២

ឆនវុតិ, ឆន្នវុតិ................................................................ = ៩៦

ឯកូនសត, ឩនសត......................................................... = ៩៩

សត............................................................................ = ១០០

*ការរាប់ចំនួនខាងលើនេះមិនបានរាប់ឱ្យគ្រប់ទាំងអស់ទេ គឺរាប់តែចំនួនណាដែលមានរូបប្រែប្រួលប៉ុណ្ណោះ ។ រីឯចំនួនទាំងឡាយណា*

ដែលមិនបានរាប់ក្នុងទីនេះ គឺមានរូបដើមយ៉ាងណា វេលាផ្សំគឺនៅមានរូបយ៉ាងនោះដដែល មិនមានផ្លាស់ប្ដូរទៅជាអ្វីឡើយ ដូចជា **ឆ** ស័ព្ទក្នុង ៦៧ គឺ (**សត្ត** + **សដ្ឋី**) > **សត្តសដ្ឋី** ។ តាមហេតុផលដូចបានពោលរួចមកហើយនេះ គឺហ្វឹកហាត់ឱ្យចាំតែក្នុងចិត្ត ពុំចាំបាច់ទន្ទេញណាស់ណាពេកទេក៏បាន ចាំតែពី ១ ដល់ ១០ ក៏គ្រប់ល្មមហើយ ។

ចំពោះការសរសេរវិញសូមសង្កេតមើល និងត្រូវចំណាំទុកនូវការតម្រួតអក្សរជាពិសេសក្នុងខ្ទង់ ៣០ គឺ **តឹស** ។

ការយកចំនួនរាយមកផ្សំជាមួយចំនួនគត់ដប់ ៗ ដូចពោលហើយនេះ ឃើញថាមានសំខ្យាស័ព្ទខ្លះផ្លាស់ប្ដូររូបទៅជាដទៃគឺ **ឯក**, **ទ្វិ**, **តិ**, **ចតុ**, **បញ្ច**, **ឆ**, **ទស**, **វីស**, **តឹស** ។

១. **ឯក** ក្នុងខ្ទង់ ១០ ទីយៈជា **ឯកា** គឺ **ឯកាទស**, **ឯការស** ។ ក្រៅពីនេះគង់រូបជា **ឯក** ដូចដើម ។

២. **ទ្វិ** ក្នុងខ្ទង់ ១០ និង ២០ ផ្លាស់ទៅជា **ទ្វា**, **ពា** ដូចជា **ទ្វាទស**, **ពារស**, **ទ្វាវីស**, **ពាវីស** ជាដើម ។ ក្នុងខ្ទង់ ៣០ ផ្លាស់ជា **ទ្វ**, **ព** ដូចជា **ទ្វត្តឹស**, **ពត្តឹស** ជាដើម ។ ចាប់ពីខ្ទង់ ៤០-៧០ និងខ្ទង់ ៩០ ផ្លាស់ជា **ទ្វេ** ដូចជា **ទ្វេចត្តាឡីស**, **ទ្វេនវុតិ** ។ល។ ។ ក្រៅពីនេះមានផ្លាស់ **ទ្វិ** ជា **ទិ** ដូចជា **ទិជ** =សត្វកើតពីរដង (មានពួកបក្សីជាដើម) ។ ផ្លាស់ជា **ទុ** ដូចជា **ទុតិយ** =ទី២, គំរប់២ (ចូរមើលក្នុងបូរណសំខ្យាមានអធិប្បាយនៅខាងមុខ) ឬផ្លាស់ទៅជា **ទោ** ខ្មែរប្រើជាបូរណសំខ្យាដូចជា ថ្នាក់ទោ,

អនុសេនីទោ ជាដើម ។

៣. តិ ផ្លាស់ជា តេ គ្រប់ខ្ទង់ទាំងអស់ដូចជា តេវស, តេបញ្ញាស តេអសីតិ ជាដើម ។ នៅក្នុងខ្ទង់ ៨០ អាចផ្លាស់ ត ទៅជា យ ដូចជា ត្យាសីតិ ។

៤. ចតុ ក្នុងខ្ទង់ ១០ ផ្លាស់ជា ចុ ឬ ចោ គឺ ចុទ្ទស, ចោទ្ទស ។ ក្រៅពីនេះគង់រូបជា ចតុ ទាំងអស់ ។ ក្នុងខ្ទង់ ៨០ មានចុះ រ អាគមដូចជា ចតុរាសីតិ ជាដើម ។

៥. បញ្ច ក្នុងខ្ទង់ ១០ ផ្លាស់ជា បណ្ណ គឺ បណ្ណរស ។ ក្រៅពីនេះគង់រូបជា បញ្ច ដូចដើម ។

៦. ឆ ក្នុងខ្ទង់ ១០ ផ្លាស់ជា សោ គឺ សោឡស ។ ក្នុងខ្ទង់ ៨០ មានចុះ រ ឬ ឡ អាគមជា ឆរាសីតិ, ឆឡាសីតិ ។ ត្រង់ ៦០ ទៅជា សដ្ឋី ។ ក្រៅពីនេះគង់រូបជា ឆ ដូចដើម ។

៧. សត្ត នៅគង់រូបដើមគ្រប់ខ្ទង់ទាំងអស់ ។

៨. អដ្ឋ ក្នុងខ្ទង់ ១០ ទីឃៈជា អដ្ឋា គឺ អដ្ឋារស ។

៩. នវ មិនមានប្រើជាចំនួនតិចផ្សំនឹងចំនួនគត់ដប់ ៗ ទេ ។

១០. ទស ក្នុងខ្ទង់ ១០ ផ្លាស់ជា រស, ឡស ដូចជា តេរស, សោឡស ។

១១. វីស ក្នុងខ្ទង់ ២០ ផ្លាស់ជា ពីស គឺ ឆព្វីស តំរួតជា ព្វ ។

១២. វីស, តឹស អាចចុះ តិ ខាងចុងបានដូចជា វីសតិ, តឹសតិ ។

១៣. **ចត្តាឡីស** ផ្លាស់ជា **តាឡីស** ។

១៤. **បញ្ញាស** ផ្លាស់ជា **បណ្ណាស** ។

១៥. **សត្តតិ** ផ្លាស់ជា **សត្តរិ** ។

ប្រសិនបើផ្សំផ្ទាល់ជាមួយនាមនាម ត្រូវទុកសំខ្យាស័ព្ទឱ្យគង់រូបដើម ដូចជា **ឯកាបត្ត** =បាត្រមួយ, **ទ្វិចាគា** =សត្វជើងពីរ, **ទ្វិសត** =រយពីរ (ពីររយ), **តិយោជន** =យោជន៍បី (បីយោជន៍), **តិលោក** =លោកបី, ត្រៃលោក, **ចតុទ្ទិស** =ទិសបួន, **ឆសមាស** =ដប់ខែ, **អសីតិកប្ប** = កប្បប៉ែតសិប, **នវកោដិ** =កោដិប្រាំបួន ជាដើម។

**សត** ជាសំខ្យាស័ព្ទមែនពិត ប៉ុន្តែក្នុងភាសាបាលីលោកចាត់ជានាម ទៅវិញ សូមមើលការអធិប្បាយនៅខាងក្រោម ។

## ប្រភេទរបស់បកតិសំខ្យា

បកតិសំខ្យាក្នុងភាសាបាលីលោកបានចាត់ជាប្រភេទដូចតទៅនេះ

១. ពី **ឯក** ដល់ **ចតុ** ចាត់ជា **សព្វនាម** ហៅថា **សំខ្យាសព្វនាម** ។

២. ពី **បញ្ច** ដល់ **អដ្ឋនវុតិ**=៩៨ ចាត់ជា **គុណនាម** ហៅថា **សំខ្យា-គុណនាម** ។

៣. ពី **ឯកូនសត** =៩៩ ឡើងទៅជួនប្រើជា **គុណនាម** ហៅថា **សំខ្យាគុណនាម** ជួនកាលប្រើជា នាមនាម ហៅថា **សំខ្យានាម** ។

៤. ពី **ឯក** ដល់ **អដ្ឋារស** (១៨) អាចបំបែកបានទាំង ៣ លិង្គ ។

បកតិសំខ្យាទាំងឡាយពោលហើយនេះនៅពុំទាន់បំបែកទេ ។ កាលបើចង់ប្រើដើម្បីរាប់នាមនាមណាមួយនោះ ត្រូវបំបែកតាមវិភត្តិផ្សេង ៗ ដូចនាមសព្ទដែរ ។

## វិធីបំបែកបកតិសំខ្យាសព្ទ

(Declension of Cardinal numbers)

## វិធីបំបែក ឯក សព្ទ

| វិភត្តិ | បុំលិង្គ | នបុំសកលិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ប. | ឯកោ | ឯកំ | ឯកា |
| ទុ. | ឯកំ | ឯកំ | ឯកា |
| ត. | ឯកេន | ឯកេន | ឯកាយ |
| ច. | ឯកស្ស | ឯកស្ស | ឯកាយ |
| បញ្ច. | ឯកស្មា, ឯកម្ហា | ឯកស្មា, ឯកម្ហា | ឯកាយ |
| ឆ. | ឯកស្ស | ឯកស្ស | ឯកាយ |
| ស. | ឯកស្មឹ, ឯកម្ហិ | ឯកស្មឹ, ឯកម្ហិ | ឯកាយ |

# កំណត់សម្គាល់

១. បកតិសំខ្យាទាំងអស់គ្មានអាលបនវិភត្តិទេ ។

២. បកតិសំខ្យាពី **ឯក** ដល់ **អដ្ឋារស** (១៨) ជាត្រៃលិង្គ ។ បើនាម-នាមនោះ ៗ មានរូបជាលិង្គនិងវិភត្តិអ្វី បកតិសំខ្យាត្រូវបំបែកឱ្យមានលិង្គនិងវិភត្តិឱ្យស្មើគ្នាជានិច្ច ។

៣. **ឯក** ជា អ ការន្តបំបែកដូច **បុរិស** ក្នុងបុំលិង្គនិង **កុល** ក្នុងនបុំសកលិង្គ ។ ក្នុងឥត្ថីលិង្គត្រូវថែមស្រៈ **អា** ទៅជា **ឯកា** សិនទើបបំបែកដូច **កញ្ញា** ។ ប៉ុន្តែ **ឯក** ជាឯកវចនៈតែម៉្យាងប៉ុណ្ណោះ មិនមានរូបជាពហុវចនៈទេ ។

៤. **ឯក** ជាសំខ្យាផ្សេងគ្នាពី **ឯក** ជាសព្វនាមគឺថា **ឯក** សំខ្យាបំបែកជាឯកវចនៈតែម៉្យាង ។ រីឯ **ឯក** សព្វនាមមាន ២ វចនៈដូច **យ** សព្ទ័ដែរ ។

៥. **ឯក** ជាសំខ្យាប្រែជាខ្មែរតាមបែប **បុរិស** គ្រប់ប្រការ ប៉ុន្តែពុំចាំបាច់ប្រែចេញពាក្យអាយតនិបាតទេ ព្រោះមានលក្ខណៈជាគុណ-នាមសម្រាប់អធិប្បាយនាមប៉ុណ្ណោះ ឬត្រូវថែមពាក្យសង្ខ្យានុគ្រោះដូចជា "នាក់, រូប, សន្ទឹក, បន្ទះ, ខ្នង, ខ្សែ, ក្បាល, កណ្ដ" ជាដើម ឧ. **ឯកោ បុរិសោ** =បុរសមួយរូប, ប្រុសមួយនាក់, **ឯកំ ឃរំ** =ផ្ទះ មួយខ្នង, **ឯកា គាវី** =គោមេមួយក្បាល **ឯកំ លេខនំ** =សំបុត្រមួយច្បាប់

ដូច្នេះជាដើម (ចូរមើលប្រយោគគំរូនៅខាងមុខ) ។

## វិធីបំបែក ទ្វិ និង ឧភ ស័ព្ទ

| ទ្វិ = ២ | | ឧភ = ទាំងពីរ | |
|---|---|---|---|
| វិភត្តិ | ពហុវចនៈ | វិភត្តិ | ពហុវចនៈ |
| ប. | ទ្វេ, ទុវេ | ប. | ឧភោ |
| ទុ. | ទ្វេ, ទុវេ | ទុ. | ឧភោ |
| ត. | ទ្វីហិ | ត. | ឧភោហិ |
| ច. | ទ្វិន្នំ, ទុវិន្នំ | ច. | ឧភិន្នំ |
| បញ្ច. | ទ្វីហិ | បញ្ច. | ឧភោហិ |
| ឆ. | ទ្វិន្នំ, ទុវិន្នំ | ឆ. | ឧភិន្នំ |
| ស. | ទ្វីសុ | ស. | ឧភោសុ |

## កំណត់សម្គាល់

១. ទ្វិ និង ឧភ ជាពហុវចនតែម៉្យាងនិងបំបែកដូចគ្នាទាំងបីលិង្គ ។

២. ទ្វិ ត្រង់បឋមានិងទុតិយាវិភត្តិផ្លាស់ទៅជា ទ្វេ, ទុវេ ។

៣. ទ្វិ ត្រង់តតិយា, បញ្ចមីនិងសត្តមីវិភត្តិត្រូវទីឃៈស្រៈ ឥ នៃ ទ្វិ

ជា ឡៀ បានរូបជាទៅជា ទ្វីហិ, ទ្វីសុ ។

៤. ទ្វិ ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិត្រូវបុះ ន អាគមផង (ទ្វិ + នំ + ន) > ទ្វិន្នំ ។

៥. ទាំង ទ្វិ និង ឧភ ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិអាចផ្លាស់ នំ ទៅជា ឥន្នំបានរូបជា ទុវិន្នំ, ឧភិន្នំ ។

# វិធីបំបែក តិ ស័ព្ទ

| វិភត្តិ | បុំលិង្គ ពហុ. | នបុំ. ពហុ. | ឥត្ថី. ពហុ. |
|---|---|---|---|
| ប. | តយោ | តីណិ | តិស្សោ |
| ទុ. | តយោ | តីណិ | តិស្សោ |
| ត. | តីហិ | តីហិ | តីហិ |
| ច. | តិណ្ណំ, តិណ្ណន្នំ | តិណ្ណំ, តិណ្ណន្នំ | តិស្សន្នំ |
| បញ្ច. | តីហិ | តីហិ | តីហិ |
| ឆ. | តិណ្ណំ, តិណ្ណន្នំ | តិណ្ណំ, តិណ្ណន្នំ | តិស្សន្នំ |
| ស. | តីសុ | តីសុ | តីសុ |

## កំណាត់សម្គាល់

១. តិ ជា ឥ ការន្ត ប៉ុន្តែមិនបំបែកដូចនាមនាមទេ  ជាពហុវចនៈ តែម្យ៉ាងនិងអាចបំបែកបានទាំងបីលិង្គ ។

២. ត្រង់បឋមានិងទុតិយាវិភត្តិបុំលិង្គបំបែកជា តយោ(តិ + យោ > តយោ) ដោយផ្លាស់ តិ និង យោ ជា តយោ ។ នបុំសកលិង្គជា តីណិ (តិ + យោ > តីណិ) ដោយផ្លាស់ តិ និង យោ ជា តីណិ ។ ឥត្ថីលិង្គជា តិស្សោ (តិ + យោ > តិស្សោ) ដោយផ្លាស់ តិ និង យោ ជា តិស្សោ ។ ត្រង់តតិយានិងបញ្ចមីវិភត្តិត្រូវ ទីឃៈស្រៈ ឥ នៃ តិ ជា ឦ ទៅជា តី បានរូបជា តីហិ ទាំងបីលិង្គ ។ ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិក្នុងនបុំសកលិង្គបំបែកជា តិណ្ណំ, តិណ្ណន្នំ (តិ + ណំ) ដោយលុប ឥ នៃ តិ និងផ្លាស់ ណំ វិភត្តិជា ឥណ្ណំ, ឥណ្ណន្នំ ។

៣. ក្នុងឥត្ថីលិង្គត្រង់បឋមានិងទុតិយាវិភត្តិបំបែកជា តិស្សោ គឺផ្លាស់ តិ និង យោ ឱ្យមានរូបជា តិស្សោ ។ ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិបំបែកជា តិស្សន្នំ ដោយចុះ ស្ស និង ន អាគម ។ ត្រង់សត្តមីវិភត្តិត្រូវទីឃៈស្រៈ ឥ នៃ តិ ជា ឦ ទៅជា តី បានរូបជា តីសុ មានរូបដូចគ្នាទាំងបីលិង្គ ។

## វិធីបំបែក ចតុ សព្ទ

| វិភត្តិ | បុំលិង្គ ពហុ. | នបុំ. ពហុ. | ឥត្ថី. ពហុ. |
|---|---|---|---|
| ប. | ចត្តារោ, ចតុរោ | ចត្តារិ | ចតស្សោ |
| ទុ. | ចត្តារោ, ចតុរោ | ចត្តារិ | ចតស្សោ |
| ត. | ចតូហិ | ចតូហិ | ចតូហិ |
| ច. | ចតុន្នំ | ចតុន្នំ | ចតស្សន្នំ |
| បញ្ច. | ចតូហិ | ចតូហិ | ចតូហិ |
| ឆ. | ចតុន្នំ | ចតុន្នំ | ចតស្សន្នំ |
| ស. | ចតូសុ | ចតូសុ | ចតូសុ |

## កំណត់សម្គាល់

១. **ចតុ** *ជា* **ឧ** *ការន្តក៏ពិតមែនតែមិនបំបែកដូចនាមនាម* **ឧ** *ការន្តទេ និងជាពហុវចនៈតែម្យ៉ាង តែអាចបំបែកបានទាំង ៣ លិង្គ ។*

២. *ត្រង់បឋមានិងទុតិយាវិភត្តិបុំលិង្គផ្លាស់* **ចតុ** *និង* **យោ** (**ចតុ** + **យោ**) *ជា* **ចត្តារោ, ចតុរោ** *។ ក្នុងនបុំសកលិង្គផ្លាស់* **ចតុ** *និង* **យោ** *ជា* **ចត្តារិ** *។ ក្នុងឥត្ថីលិង្គផ្លាស់* **ចតុ** *និង* **យោ** *ជា* **ចតស្សោ** *។*

៣. *ត្រង់តតិយានិងបញ្ចមីវិភត្តិត្រូវទីឃៈស្រៈ* **ឧ** *នៃ* **ចតុ** *ជា* **ឩ** *បានរូបជា* **ចតូហិ** *ទាំងបីលិង្គ ។*

៤. *ត្រង់ចតុត្ថីនិងឆដ្ឋីវិភត្តិបុំលិង្គនិងនបុំសកលិង្គត្រូវចុះ* **ន** *អាគម* (**ចតុ** + **នំ** + **ន**) *បានរូបជា* **ចតុន្នំ** *។ ក្នុងឥត្ថីលិង្គត្រូវចុះ* **ស្ស** *និង* **ន**

*អាគម* (**ចតុ** + **ស្ស** + **នំ** + **ន**) *បានរូបជា* **ចតុស្សន្នំ** ។

*៥. ត្រង់សត្តមីវិភត្តិត្រូវទីឃៈស្រៈ* **ឧ** *នៃ* **ចតុ** *ជា* **ឩ** *បានរូបជា* **ចតូសុ** *ទាំងបីលិង្គ* ។

# វិធីបំបែក បញ្ច ស័ព្ទ

| *វិភត្តិ* | *ពហុវចនៈ* | | |
|---|---|---|---|
| *ប.* | **បញ្ច** | *ច.* | **បញ្ចន្នំ** |
| *ទុ.* | **បញ្ច** | *បញ្ច.* | **បញ្ចហិ** |
| *ត.* | **បញ្ចហិ** | *ឆ.* | **បញ្ចន្នំ** |
| | | *ស.* | **បញ្ចសុ** |

# កំណត់សម្គាល់

*១. ចាប់ពី* **ឆ** *ដល់* **អដ្ឋារស** *=១៨ មានវិធីបំបែកដូច* **បញ្ច** *ដែរនិងជាពហុវចនៈតែម៉្យាង ហើយមានរូបដូចគ្នាទាំងបីលិង្គ* ។

*២. ត្រង់បឋមានិងទុតិយាវិភត្តិផ្លាស់* **យោ** *វិភត្តិនិងស្រៈ* **អ** *នៃ* **បញ្ច** *ជាដើមទៅជា* **អ** *បានរូបជា* **បញ្ច**, **ឆ**, **សត្ត**, **នវ**, **អដ្ឋារស** ។ល។

*៣. ត្រង់តតិយានិងបញ្ចមីបំបែកជា* **បញ្ចហិ** (**បញ្ច** + **ហិ**) ។

*៤. ត្រង់បតុត្ថីនិងឆដ្ឋីវិភត្តិត្រូវបុះ* **ន** *អាគម* (**បញ្ច** + **នំ** + **ន**) *បានរូបជា* **បញ្ចន្នំ** ។

*៥. ត្រង់សត្តមីវិភត្តិបំបែកជា* **បញ្ចសុ** (**បញ្ច** + **សុ**) ។

# វិធីប្រើនិងប្រែបកតិសំខ្យា

*បកតិសំខ្យាចាប់ពី* **ឯក** *ដល់* **អដ្ឋារស** *ប្រើជាបទវិសេសនៈរាប់នាមនាមបានទាំងបីលិង្គ មានលក្ខណៈជាគុណស័ព្ទ ។ បើប្រើអធិប្បាយនាមបទណាត្រូវបំបែកឱ្យមានលិង្គ, វចនៈនិងវិភត្តិស្មើគ្នាហើយនឹងរៀងដាក់ខាងដើមនាមបទជាប្រធាននោះ ៗ ដូចឧទាហរណ៍ខាងក្រោមនេះ*

**១. ឯកោ$_{២}$ បុរិសោ$_{១}$ ចតស្សន្នំ$_{៧}$ ឥត្ថីនំ$_{៦}$ ចត្តារិ$_{៥}$ បុប្ផានិ$_{៤}$ ទទាតិ$_{៣}$។**

*បុរស មួយនាក់ កំពុងឱ្យ នូវបុប្ផា.ទ. បួនទង ដល់ស្រី.ទ. បួននាក់ ។*

**២. បញ្ច$_{២}$ ភិក្ខូ$_{១}$ តស្មឹ$_{៥}$ អាវាសេ$_{៤}$ វសន្តិ$_{៣}$។**

*ភិក្ខុ ប្រាំរូប កំពុងនៅ ក្នុងអាវាស នេះ ។*

**៣. អហំ$_{១}$ បណ្ណរសហិ$_{៦}$ បុរិសេហិ$_{៦}$ សទ្ធឹ$_{៦}$ តំ$_{៥}$ នគរំ$_{៤}$ អគមឹ$_{៣}$។**

*ខ្ញុំ មួយអន្លើ ដោយបុរស ដប់ប្រាំនាក់ បានទៅហើយ កាន់នគរ នោះ ។*

## វិធីបំបែក ឯកូនវីស =១៩

| វិភត្តិ | ឯកវចនៈ | | |
|---|---|---|---|
| ប. | ឯកូនវីសា | ច. | ឯកូនវីសាយ |
| ទុ. | ឯកូនវីសំ | បញ្ច. | ឯកូនវីសាយ |
| ត. | ឯកូនវីសាយ | ឆ. | ឯកូនវីសាយ |
| | | ស. | ឯកូនវីសាយ |

# កំណត់សម្គាល់

១. បកតិសំខ្យាចាប់ពី ១៩ ដល់ ៩៩ ជាឥត្ថីលិង្គតែម៉្យាង ។ ដូច្នេះ សំខ្យាស័ព្ទណាដែលមានទីបំផុតជា អ ការន្តដូចជា **ឯកូនវីស** វេលាបំបែកត្រូវចុះ **អា** បច្ច័យឱ្យទៅជា **ឯកូនវីសា** សិនទើបបំបែកជាឯក-វចនៈតាមវិភត្តិសម្រេចរបស់ **អា** ការន្តឥត្ថីលិង្គតាមបែប **កញ្ញា** ដូចមាននៅខាងលើស្រាប់ ។ ត្រង់បឋមាវិភត្តិអាចរស្សៈជា អ វិញក៏បាន ដូចជា **ឯកូនវីស** កន្លែងខ្លះឃើញមានរូបជា **ឯកូនវីសំ** ទៀតផង ។

២. បកតិសំខ្យាចាប់ពី **វីស** ដល់ **អដ្ឋបញ្ញាស** =៥៨ ដែលមានទីបំផុតជា **ស** ត្រូវបំបែកតែជាឯកវចនៈដូច **ឯកូនវីស** ដែរដូចជា

**បញ្ញាសាយ កុមារីហិ** =ដោយក្មេងស្រី.ទ. ៥០នាក់ ។

## វិធីបំបែក ឯកូនវីសតិ =១៩

| វិភត្តិ | ឯកវចនៈ | វិភត្តិ | ឯកវចនៈ |
|---|---|---|---|
| ប. | ឯកូនវីសតិ | បញ្ច. | ឯកូនវីសតិយា |
| ទុ. | ឯកូនវីសឹ | ឆ. | ឯកូនវីសតិយា |
| ត. | ឯកូនវីសតិយា | ស. | ឯកូនវីសតិយា, |
| ច. | ឯកូនវីសតិយា | | ឯកូនវីសតិយំ |

## កំណត់សម្គាល់

បកតិសំខ្យាដែលមានទីបំផុតជាស្រៈ ឥ គឺចាប់ពី **ឯកូនវីសតិ** =១៩ រហូតដល់ **អដ្ឋត្តឹសតិ** =៣៨ និងចាប់ពី **ឯកូនសត្តតិ** =៦៩ ដល់ **អដ្ឋនវុតិ** =៩៨ ជា ឥ ការន្តឥត្ថីលិង្គមានវិធីបំបែកជាឯកវចនៈតាមវិភត្តិសម្រេចរបស់នាម ឥ ការន្តឥត្ថីលិង្គដូច **ភូមិ** ដែរ ដូចជា

**សត្តតិយា ភណិតេហិ** = អំពីឈ្នួញ.ទ. ៧០នាក់ ជាដើម ។

## វិធីបំបែក ឯកូនសដ្ឋី =៥៩

| វិភត្តិ | ឯកវចនៈ | វិភត្តិ | ឯកវចនៈ |
|---|---|---|---|
| ប. | ឯកូនសដ្ឋី | បញ្ច. | ឯកូនសដ្ឋិយា |
| ទុ. | ឯកូនសដ្ឋី | ឆ. | ឯកូនសដ្ឋិយា |
| ត. | ឯកូនសដ្ឋិយា | ស | ឯកូនសដ្ឋិយា, |
| ច. | ឯកូនសដ្ឋិយា | | ឯកូនសដ្ឋិយំ |

## កំណត់សម្គាល់

បកតិសំខ្យាដែលមានទីបំផុតជា ឦ គឺចាប់ពី **ឯកូនសដ្ឋី** =៥៩ ដល់ **អដ្ឋសដ្ឋី** =៦៨ ជា ឦ ការន្តឥត្ថីលិង្គបំបែកជាឯកវចនៈតាមវិភត្តិសម្រេចរបស់នាម ឦ ការន្តដូច **នារី** ដែរដូចជា

ឆសដ្ឋិយា នារិយា = *ដោយនារី.ទ. ៦៦នាក់ ជាដើម ។*

## ប្រយោគគំរូ

១. <u>**តឹសតិ**</u>$_{២}$ **ភិក្ខូ**$_{១}$ **ឥមស្មឹ**$_{៤}$ **អាវាសេ**$_{៥}$ **វសន្តិ**$_{៣}$។

*ភិក្ខុ.ទ. ៣០រូប កំពុងនៅ ក្នុងអាវាស នេះ ។*

២. **អហំ**$_{១}$ <u>**បញ្ចវីសតិយា**</u>$_{៧}$ **បុរិសានំ**$_{៦}$ **បញ្ចវីសំ**$_{៤}$ **វត្ថានិ**$_{៥}$ **ទេមិ**$_{៣}$។

*ខ្ញុំ នឹងឱ្យ នូវសំពត់.ទ. ២៥ដុំ ដល់បុរស.ទ. ២៥នាក់ ។*

## កំណត់សម្គាល់

*សំខ្យាស័ព្ទដែលបានអធិប្បាយរួចហើយនេះ ជាសំខ្យាសព្វនាម និងសំខ្យាគុណនាម ខ្លះបំបែកបានទាំងបីលិង្គ ខ្លះបំបែកបានតែម្យ៉ាង ប៉ុន្តែប្រើបានទាំងបីលិង្គ ។ ខ្លះបំបែកបានតែជាឯកវចនៈ និងខ្លះទៀត បំបែកបានតែជាពហុវចនៈ និងខ្លះកំណត់ថាជាឥត្ថីលិង្គតែម្យ៉ាង ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ វេលាប្រើជាបទវិសេសនៈរបស់នាមណាត្រូវ បំបែកឱ្យមានវិភត្តិស្មើគ្នាជាដាច់ខាត ។ រីឯរឿងលិង្គគឺស្រេចតែសេចក្តី ក្នុងទីនោះៗ ។*

*សូមសង្កេតមើលប្រយោគខាងលើ* **តឹសតិ** *និង* **បញ្ចវីសតិ** *ជា ឥត្ថីលិង្គ តែប្រើជាបទវិសេសនៈឱ្យ* **ភិក្ខុ** *និង* **បុរិស** *ដែលជាបុំលិង្គបាន ប៉ុន្តែសូមចាំថាការប្រើដូច្នេះបានតែ សំខ្យាស័ព្ទប៉ុណ្ណោះ ។ ប្រសិនបើបទ*

វិសេសនៈនោះ ៗ មានរូបស័ព្ទដើមជា នាមនាម, គុណនាម ឬក៏សព្វនាមវិញប្រើដូច្នេះមិនបានឡើយ គឺត្រូវតែមាន លិង្គ, វចនៈ និង វិភត្តិស្មើគ្នាជានិច្ចទើបបាន ។ សូមអ្នកសិក្សាគប្បីព្យាយាមរៀនបំបែក នាមនាម គុណនាម សព្វនាមឬបកតិសំខ្យាសាឡើងវិញដើម្បីឱ្យមានជំនាញ ត្បិតកាលបើយកទៅប្រើក្នុងប្រយោគចាំបាច់ត្រូវតែបំបែកក្នុងរូបវិភត្តិនានាជា ដាច់ខាត ។

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| សច្ច នបុំ. | សេចក្ដីពិត | កព្ភ បុំ. | ពោះ, ផ្ទៃ, បន្ទប់ |
| វស្ស បុំ.,នបុំ. | រដូវភ្លៀង, ឆ្នាំ | វិរិយ នបុំ. | សេចក្ដីព្យាយាម |
| អាវាស បុំ. | វត្ត, អាវាស | វត្ថ បុំ. | សំពត់ |
| សរណ នបុំ. | ទីពឹង | សម្បត្តិ ឥ. | ទ្រព្យ, សម្បត្តិ |
| អាលិង្គ បុំ. | របៀង | ធម្មកាថិក បុំ. | អ្នកសំដែងធម៌ |
| ព្រហ្មចរិយ នបុំ. | ការប្រព្រឹត្តដ៏ប្រសើរ | បុព្វ អព្យ. | គ្រាមុន, |
| អរិយសច្ច នបុំ. | សេចក្ដីពិតដ៏ប្រសើរ | | កាលមុន |
| ទុក្ខនិរោធ បុំ. | សេចក្ដីរំលត់ទុក្ខ | ឯវ អព្យ. | ពិត, តែ- |
| ទុក្ខសមុទយ បុំ. | ហេតុនាំឱ្យកើតទុក្ខ | | ប៉ុណ្ណោះ |
| បឋមយាម បុំ. | យាមទី១, បឋមយាម | វ អព្យ. | ប៉ុណ្ណោះ |

# លំហាត់នៃមេរៀនទី ១២

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ ។

១. តើ **សំខ្យា** ប្រែថាដូចម្តេច ?

២. តើសំខ្យាមានប៉ុន្មានយ៉ាង ?

៣. ចូររាប់បកតិសំខ្យាពី ១ ដល់ ១០ ជាបាលី ។

៤. ចូររាប់បកតិសំខ្យាចំនួនគត់ដប់ ៗ ពី ១០ ដល់ ១០០ ជាបាលី ។

៥. ចូររាប់បកតិសំខ្យាចំនួនពី ១១ ដល់ ២០ ជាបាលី ។

៦. តើបកតិសំខ្យាពី **ឯក** ដល់ **ចតុ** ចាត់ជាស័ព្ទប្រភេទអ្វី ?

៧. តើបកតិសំខ្យាពី **បញ្ច** ដល់ **អដ្ឋនវុតិ** ចាត់ជាស័ព្ទប្រភេទអ្វី ?

៨. តើបកតិសំខ្យាពី **ឯកូនសត** ឡើងទៅចាត់ជាស័ព្ទប្រភេទអ្វី ?

៩. តើពី **ឯក** ដល់ **អដ្ឋារស** បំបែកបានប៉ុន្មានលិង្គ ?

១០. តើចាប់ពី **ឯកូនវីស** ដល់ **អដ្ឋនវុតិ** និង **កោដិ** ចាត់ជាលិង្គអ្វី និងប៉ុន្មានវចនៈ ?

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. ចត្តារិមានិ ភិក្ខវេ សច្ចានិ ។

២. ឯកំ ញាម កិំ ?

៣. តីសុ លោកេសុ សត្តា ឧប្បជ្ជន្តិ ។

៤. ឯកស្មឹ ហត្ថេ បញ្ច អង្គុលិយោ ហោន្តិ ។

៥. សត្តេ និវាសេ អហំ គមិស្សាមិ ។

៦. មយំ តីណិ វស្សានិ ឥមស្មឹ គាមេ វសិម្ហា ។

៧. សោ តស្ស តិណ្ណំ បុត្តានំ ចត្តារិ ចត្តារិ កត្វា ទ្វាទស ផលានិ អទាសិ ។

៨. ឯតស្មឹ ឃរេ ចតស្សោ ឥត្ថិយោ វសន្តិ ។

៩. យោ អាគច្ឆេយ្យ សោ បណ្ណាការំ លភេយ្យ ។

១០. ឯកស្មឹ មាសេ តឹស ទិវសា ហោន្តិ ។

១១. បញ្ញាស ភិក្ខូ បុព្វេ ឥមស្មឹ អាវាសេ អហេសុំ ។

១២. អញ្ញំ សរណំ អម្ហាកំ នត្ថិ ពុទ្ធោ នោ សរណំ ហោតិ ។

១៣. ឯកា នារី អាលិន្ទេ និសីទិ ទ្វេ បន ទារកា គព្ភេ និបជ្ជឹសុ ។

១៤. អហំ អមុកស្មឹ ឋានេ បញ្ច ទារកេ អបស្សំ តេ ឯកំ សប្បំ បហរឹសុ ។

១៥. ធម្មកថិកោ ឯកតឹសតិយា ឥត្ថីនញ្ច វីសតិយា បុរិសានញ្ច ធម្មំ ទេសេតុ ។

☸ ( កត្វា=*ធ្វើហើយ*)

***គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី***

*១. ព្រះពុទ្ធ របស់យើង.ទ. ត្រាស់ដឹងហើយ នូវអរិយសច្ច ៤ ។*

*២. អរិយសច្ច បួន គឺ ទុក្ខ, ហេតុឱ្យកើតទុក្ខ, ការរំលត់ទុក្ខ ផ្លូវនាំឱ្យដល់ ការរំលត់ទុក្ខ ។*

៣. ស្រី ម្នាក់ អង្គុយហើយ ឯរបៀង ប៉ុន្តែ ក្មេងស្រី ពីរនាក់ ដេកហើយ លើគ្រែ ។

៤. កសិករ.ទ. ២១នាក់ កំពុងទៅ កាន់ព្រៃ ធំ ជិតភ្នំ ខ្ពស់ ។

៥. ឈ្មួញ.ទ. ២៩នាក់ កំពុងលក់ នូវសំពត់.ទ. ៣០ដុំ ដល់កសិករ.ទ. ២៥នាក់ ។

៦. ទីពឹង ដទៃ របស់ពួកយើង មិនមាន, ព្រះពុទ្ធ ប៉ុណ្ណោះ ជាទីពឹង របស់យើង ។

៧. លោកគ្រូ កំពុងឱ្យ ឱវាទ ដល់សិស្ស.ទ. ២៨នាក់ ។

៨. ប្រសិនបើ សេដ្ឋី នោះ បានឱ្យហើយ នូវទាន ក្នុងបឋមយាម គាត់ នឹងបានទទួលហើយ នូវសម្បត្តិ ច្រើន ។

១០. បណ្ឌិត មិនត្រូវ គប់រក មិត្ត អាក្រក់ ទេ ត្រូវគប់រក មិត្ត ល្អ តែប៉ុណ្ណោះ ។

**(ចប់មេរៀនទី ១២)**

# មេរៀនទី ១៣

## អធិប្បាយអំពីសំខ្យាស័ព្ទពី ១០០ ឡើង

*នៅក្នុងមេរៀនទី ១២ បានអធិប្បាយហើយពី* **ឯក** *ដល់* **សត** *។ តទៅទៀតនេះនឹងអធិប្បាយពី* **សត** *បន្តទៅទៀត ។ បកតិសំខ្យាចាប់ពី* **ឯកូនសត** *=៩៩ ដល់* **កោដិ** *=កោដិ មានរូបដូចខាងក្រោមនេះ*

| *ស័ព្ទបាលី* | *លេខខ្មែរ* | *ស័ព្ទបាលី* | *លេខខ្មែរ* |
|---|---|---|---|
| ឯកូនសត | = ៩៩ | សតសហស្ស, លក្ខ | = ១០០,០០០ |
| សត | = ១០០ | ទសសតសហស្ស | = ១,០០០,០០០ |
| សហស្ស | = ១,០០០ | កោដិ | = ១០,០០០,០០០ |
| ទសសហស្ស | =១០,០០០ | ។បេ។ | = ។ល។ |

*ដើម្បីឱ្យងាយចាំត្រូវរៀនរាប់ជាចំនួនគត់រយគត់ពាន់សិន ដូច្នេះ*

| *ស័ព្ទបាលី* | *លេខខ្មែរ* | *ស័ព្ទបាលី* | *លេខខ្មែរ* |
|---|---|---|---|
| សត | = ១០០ | សហស្ស | = ១,០០០ |
| ទ្វិសត | = ២០០ | ទ្វិសហស្ស | = ២,០០០ |
| តិសត | = ៣០០ | តិសហស្ស | = ៣,០០០ |
| ចតុសត | = ៤០០ | ចតុសហស្ស | = ៤,០០០ |
| បញ្ចសត | = ៥០០ | បញ្ចសហស្ស | = ៥,០០០ |

| | | | |
|---|---|---|---|
| **ឆសត** | = ៦០០ | **ឆសហស្ស** | = ៦,០០០ |
| **សត្តសត** | = ៧០០ | **សត្តសហស្ស** | = ៧,០០០ |
| **អដ្ឋសត** | = ៨០០ | **អដ្ឋសហស្ស** | = ៨,០០០ |
| **នវសត** | = ៩០០ | **នវសហស្ស** | = ៩,០០០ |

តាមវិធីរាប់ខាងលើនេះឃើញថាមិនមានអ្វីជាការលំបាកពេកទេ គឺគ្រាន់តែយកស័ព្ទបាលីពី **ទ្វិ** ដល់ **នវ** មកដាក់ផ្សំពីខាងដើម **សត** ឬ **សហស្ស** ជាការស្រេច ដែលមានដំណើរផ្សំបែបខ្មែរដែរ ។

សូមសង្កេតមើលស័ព្ទបាលីពី **ទ្វិ** ដល់ **នវ** មិនមានផ្លាស់ប្តូររូបដូចនៅក្នុងខ្ទង់ដប់ទេ គឺមានរូបយ៉ាងណាគង់រូបនៅជាយ៉ាងនោះដូចដើម ។ ចំពោះចំនួនជាម៉ឺនជាសែនឡើងទៅក៏មានវិធីផ្សំដូចខាងលើនេះដែរ ឧ. **តិទសសហស្ស**=៣០,០០០ ឬ **ទ្វិទសសតសហស្ស**=២,០០០,០០០ ជាដើម ។ រឿងដែលបកតិសំខ្យាចាប់ពី **ទ្វិ** ដល់ **នវ** មិនផ្លាស់ប្តូររូបនេះក៏ព្រោះតែបកតិសំខ្យាចាប់ពី **ឯកូនសត** ឡើងទៅចាត់ជានាមនាម ។

## វិធីផ្សំសំខ្យាស័ព្ទដោយប្រើ ឧត្តរ និង អធិក

បកតិសំខ្យាដែលមានចំនួនលើសពីចំនួនគត់រយគត់ពាន់ ដូចបានរាប់ហើយខាងលើ មានដូចជា ១០១, ១០២ ឬក៏ ១០០៣ ជាដើម មិនអាចផ្សំផ្ទាល់គ្នាដូចក្នុងខ្ទង់ដប់ជា (**ឯក** + **សត**) > **ឯកសត** បានទេ

បើផ្សំដូច្នេះត្រូវប្រែថា "មួយរយ" ឬ (**ទ្វិ** + **សត**) > **ទ្វិសត** ត្រូវប្រែថា "ពីររយ" ដូចខាងលើ ។

បើចង់រាប់ជា ១០១, ១០២ ត្រូវប្រើ **ឧត្តរ** ប្រែថា "លើស" (**ឧត្តរ** មកពី **ឧ** =ឡើង + **តរ** ជាបច្ច័យក្នុងតទ្ធិតប្រែថា "ជាង", ត្រូវតម្រួតជា **ត្ត** តាមវិធីសំយោគ ពីព្រោះ **ឧ** នៅខាងដើមបង្អាប់) ឬប្រើ **អធិក** ប្រែថា "ក្រៃលែង" ដាក់រាំងត្រង់ចន្លោះដោយដាក់ចំនួនតិចខាងដើម និងដាក់ចំនួនច្រើនខាងចុងដូចមានឧទាហរណ៍តទៅនេះ

## វិធីផ្សំសំខ្យាសព្ទដោយប្រើ ឧត្តរ

ឧទាហរណ៍ ១០១

**១ + ឧត្តរ + ១០០ = ១០១**

**(ឯក + ឧត្តរ + សត) > ឯកុត្តរសត**

ប្រែថា "មួយរយលើសដោយមួយ = ១០១"

ឧទាហរណ៍ ១០២

**២ + ឧត្តរ + ១០០ = ១០២**

**(ទ្វិ + ឧត្តរ + សត) > ទ្វយុត្តរសត**

ប្រែថា "មួយរយលើសដោយពីរ = ១០២"

ឧទាហរណ៍ ១០០៣

៣ + ឧត្តរ + ១០០០ = ១០០៣

(តិ + ឧត្តរ + សហស្ស) > ត្យុត្តរសហស្ស

ប្រែថា "មួយពាន់លើសដោយបី = ១០០៣"

## កំណត់សម្គាល់

១. សំខ្យានាមនាមដែលជា អ ការន្ត បើជានបុំសកលិង្គត្រូវបំបែកដូច កុល ។

២. សំខ្យាសព្វនាមនិងសំខ្យាគុណនាមដែលមានទីបំផុតជា ឥ, ឦ ការន្ត វេលាយកទៅផ្សំដោយប្រើ ឧត្តរ ចំបាច់ត្រូវព្រឹទ្ធិ ឥ, ឦ ទៅជា យ ឬក៏លុបស្រះ ឥ, ឦ ចេញក៏បានខ្លះដូចឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ ១០៨០

៨០ + ឧត្តរ + ១០០០ = ១០៨០

(អសីតិ + ឧត្តរ + សហស្ស) > អសីត្យុត្តរសហស្ស ឬ

(អសីតិ + ឧត្តរ + សហស្ស) > អសីតុត្តរសហស្ស

ប្រែថា "មួយពាន់លើសដោយប៉ែតសិប = ១០៨០"

៣. ឬក៏ផ្លាស់ស្រះ ឥ ជា យ ក៏បានខ្លះដូចឧទាហរណ៍ខាងក្រោម

ឧទាហរណ៍ ៥០៣

៣ + ឧត្តរ + ៥០០ = ៥០៣

(តិ + ឧត្តរ + បញ្ចសត) > តយុត្តរបញ្ចសត

ប្រែថា "ប្រាំរយលើសដោយបី"

៤. ប្រសិនបើសំខ្យាឬជានាមស័ព្ទនៅខាងដើមមានទីបំផុតជាស្រៈ អា, ឧ, ឩ ត្រូវលុបស្រៈនោះ ៗ ចេញដូចឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ ៣០៤

៤ + ឧត្តរ + ៣០០ = ៣០៤

(ចតុ + ឧត្តរ + តិសត) > ចតុត្តរតិសត

ប្រែថា "បីរយលើសដោយបួន"

៥. ឬក៏ចុះ រ អាគមខាងដើម ឧត្តរ ក៏បានខ្លះដូចជាឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ ៣០៥

៥ + ឧត្តរ + ៣០០ = ៣០៥

(បញ្ច + ឧត្តរ + សត) > បញ្ចរុត្តរសត

ប្រែថា "មួយរយលើសដោយប្រាំ"

## វិធីផ្សំសំខ្យាស័ព្ទដោយប្រើ អធិកា

សូមបញ្ជាក់ថា កាលបើចំនួនតិចនៅខាងដើមជាសំខ្យាសព្វនាម ឬជាសំខ្យាគុណនាម ត្រូវផ្សំជាមួយនឹងចំនួនច្រើននៅខាងចុងជាសំខ្យានាមនាម ត្រូវប្រើ **ឧត្តរ** ស័ព្ទរាំងត្រង់ចន្លោះ ។ ប៉ុន្តែបើផ្សំសំខ្យានាម-នាមជាមួយនឹងសំខ្យានាមនាមដូចគ្នា នោះមិនអាចប្រើ **ឧត្តរ** បានទេគឺត្រូវប្រើ **អធិក** វិញ ។ ពេលប្រើត្រូវទីឃៈ **អ** នៃ **អធិក** ជា **អា** ទៅជា **អាធិក** ដូចឧទាហរណ៍តទៅនេះ

ឧទាហរណ៍ ២៥០០

**៥០០ + អធិក + ២០០០ = ២៥០០**

**(បញ្ចសត + អាធិក + ទ្វិសហស្ស) > បញ្ចសតាធិកទ្វិសហស្ស**

ប្រែថា "ពីរពាន់ក្រៃលែងដោយប្រាំរយ"

ឧទាហរណ៍ ៣៣០,០០០

**៣០,០០០ + អធិក + ៣០០,០០០= ៣៣០,០០០**

**(តិំសសហស្ស + អាធិក + តិសតសហស្ស) > តិំសសហ-ស្សាធិកតិសតសហស្ស**

ប្រែថា "បីរយពាន់ក្រៃលែងដោយសាមសិបពាន់"

## វិធីផ្សំសំខ្យាស័ព្ទដោយប្រើ ឧត្តរ និង អធិក រួមគ្នា

ប្រសិនបើចង់ផ្សំសំខ្យាខ្ទង់ពាន់ឡើងទៅជាមួយនឹងខ្ទង់រយ ដែលលើសដោយខ្ទង់ដប់និងខ្ទង់រាយផងត្រូវប្រើ **ឧត្តរ** និង **អធិក** លាយគ្នាដោយត្រូវដាក់រាំងដូច្នេះគឺ **ឧត្តរ** ថា "លើស" ដាក់ខាងដើមរាំងសំខ្យាសព្ទនាមឬសំខ្យាគុណនាមពីសំខ្យានាមនាម និងដាក់ **អធិក** ដែលប្រែថា "ក្រៃលែង"ខាងចុងរាំងសំខ្យានាមពីសំខ្យានាមដូចគ្នាដូចឧទាហរណ៍ខាងក្រោមនេះ

ឧទាហរណ៍ ២៥៥២

**៥២ + ឧត្តរ + ៥០០ + អាធិក + ២០០០**

**ទ្វេបញ្ញាស + ឧត្តរ + បញ្ចសត + អាធិក + ទ្វិសហស្ស**

ទៅជា **ទ្វេបញ្ញាសុត្តរបញ្ចសតាធិកទ្វិសហស្ស**

ប្រែថា "ពីរពាន់ក្រៃលែងដោយប្រាំរយលើសដោយហាសិបពីរ"

ឧទាហរណ៍ ១៩៧៥[1]

**៧៥ + ឧត្តរ + ៩០០ + អាធិក + ១០០០**

**បញ្ចសត្តិ + ឧត្តរ + នវសត + អាធិក + សហស្ស**

ទៅជា **បញ្ចសត្តុត្តរនវសតាធិកសហស្ស**

ប្រែថា "មួយពាន់ក្រៃលែងដោយប្រាំបួនរយលើសដោយចិតសិបប្រាំ"

១. ការដាក់ឧទាហរណ៍ ១៩៧៥ នេះគឺចង់រំលឹកដល់ឆ្នាំដែលប្រទេសខ្មែរយើងត្រូវពពកខ្មៅងងឹតបាំងបិទលើផ្ទៃប្រទេស និងឧទាហរណ៍ ២៥៥២ នេះជាឆ្នាំដែលខ្ញុំបាទសរសេរចូលក្នុងខំព្យូទ័រ ។

ឧទាហរណ៍ទាំងឡាយខាងលើនេះមិនទាន់បំបែកនៅឡើយទេ ។ បើចង់បំបែកត្រូវបំបែកតាមបែប **កុល** ទាំងពីរវចនៈដូចឧទាហរណ៍ថា

**បញ្ចសតាធិកទ្វិសហស្សំ** ឯកវចនៈ

**បញ្ចសតាធិកទ្វិសហស្សានិ** ពហុវចនៈ,

**ឯកុត្តរសតំ** ឯកវចនៈ,

**ឯកុត្តរសតានិ** ពហុវចនៈ ។

## វិធីផ្សំបកតិសំខ្យាសព្ទរួមគ្នាជាមួយនាមសព្ទ

ការផ្សំបកតិសំខ្យាដូចមានឧទាហរណ៍ពោលរួចហើយនេះ ជាការផ្សំបកតិសំខ្យានិងបកតិសំខ្យាដូចគ្នា មិនមាននាមសព្ទចូលជាមួយផងទេ ។ បើមាននាមសព្ទផ្សំជាមួយផងត្រូវប្រើវិធីផ្សំដូចតទៅនេះ

ក. បកតិសំខ្យាចាប់ពី **ឯក** ដល់ **អដ្ឋនវុតិ** =៩៨ បើប្រើរាប់នាម-នាមបទណា ត្រូវរៀងដាក់ពីខាងដើមនិងត្រូវបំបែកឱ្យមានវចនៈ និងវិភត្តិស្មើគ្នានឹងនាមនោះ ៗ ដូចឧទាហរណ៍ខាងក្រោមនេះ

**ឯកោ បុរិសោ** = បុរសមួយរូប (ម្នាក់) ។

**បញ្ចហិ ភិក្ខូហិ** = ដោយភិក្ខុ ឬ ពីភិក្ខុ.ទ. ប្រាំរូប ។

ខ. បកតិសំខ្យាចាប់ពី **ឯកូនសត** =៩៩ ឡើងទៅ បើប្រើរាប់នាមនាមបទណាត្រូវរៀងដាក់ខាងក្រោយនាមបទនោះ ៗ ។ បទនាម

ដែលនៅខាងដើមត្រូវបំបែកជាឆដ្ឋីវិភត្តិ ដោយយកតាមការន្តនោះ ៗ ជានិច្ច ។ ប្រសិនបើនាមសព្ទនោះជាស្រៈ អ, **អា** ការន្តត្រូវបំបែកជា **អានំ** ។ បើជាស្រៈ ឥ, **ឦ** ការន្ត ត្រូវបំបែកជា **ឦនំ** និងបើជាស្រៈ ឧ, **ឩ** ការន្តត្រូវបំបែកជា **ឩនំ** ដែលប្រែថា "នៃ.......ទាំងឡាយ" ដូចមានឧទាហរណ៍ខាងក្រោមនេះ

| ភាសាខ្មែរ | រៀងជា | ពាក្យប្រែ |
|---|---|---|
| ១. ប្រុស ២០០ រូប | **បុរិសានំ ទ្វិសតំ** | = រីពីររយនៃបុរស.ទ. |
| ២. ទូក ៣០០ គ្រឿង | **នាវានំ តិសតំ** | = រីបីរយនៃទូក.ទ. |
| ៣. ជាងឈើ ១០០ នាក់ | **ថបតីនំ សតំ** | = រីរយនៃជាងឈើ.ទ. |
| ៤. ស្រី ២០០ នាក់ | **ឥត្ថីនំ ទ្វិសតំ** | = រីពីររយនៃស្រី.ទ. |
| ៥. គ្រូ ៥០០ នាក់ | **គរូនំ បញ្ចសតំ** | = រីប្រាំរយនៃគ្រូ.ទ. |
| ៦. ស្រី ១០០០ នាក់ | **វធូនំ សហស្សំ** | = រីពាន់នៃស្រី.ទ. |

គ. រូបបកតិសំខ្យាក្នុងឧទាហរណ៍ខាងលើនៅអាចប្រើបានម៉្យាងទៀតគឺ ញែកចេញពីគ្នាដោយកាត់យកសំខ្យាគុណនាមទៅរៀងដាក់ពីខាងដើមនាមនាម និងទុកសំខ្យានាមនាមនៅខាងចុងដែលត្រូវបំបែកជាពហុវចនៈជានិច្ច ។ រីឯសំខ្យាគុណនាមក៏ត្រូវបំបែកឱ្យមានវិភត្តិស្មើនឹងសំខ្យានាមនាមដូចមានឧទាហរណ៍ខាងក្រោមនេះ

ជន ២០០ រូប **ទ្វេ ជនានំ សតានិ** = រីរយ.ទ. នៃជន.ទ. ពីរ ។

ទូក ៣០០ គ្រឿង **តីណិ នាវានំ សតានិ** = រយ.ទ. នៃទូក.ទ. បី ។
ឈើ ៤០០ ដើម **ចត្តារិ រុក្ខានំ សតានិ** = រយ.ទ. នៃដងឈើ.ទ. បួន
គ្រូ ៥០០ នាក់ **បញ្ច គរូនំ សតានិ** = រយ.ទ. នៃគ្រូ.ទ. ប្រាំ ។
ប្រុស ៧០០ នាក់ **សត្ត បុរិសានំ សតានិ** = រយ.ទ. នៃប្រុស.ទ. ប្រាំពីរ

សូមអ្នកសិក្សាគប្បីជ្រាបថាពាក្យថា **ទ្វេ** =ពីរ, **តីណិ** =បី ជាដើម មិនមែនប្រើសម្រាប់រាប់នាមនាមដូចជា **ឥត្ថីនំ ឬ នារីនំ** ទេ ។ ប៉ុន្តែប្រើរាប់ពាក្យថា **សតានិ** =រយ ទើបត្រូវចុះវិភត្តិឱ្យស្មើគ្នាជា **ទ្វេសតានិ, តីណិសតានិ** ។

ក្នុងឧទាហរណ៍ខាងលើនេះឃើញថា សំខ្យានាមនាមសុទ្ធតែជាបឋមាវិភត្តិទាំងអស់ រីឯសំខ្យានៅខាងដើមក៏ជាបឋមាវិភត្តិដូចគ្នាដែរ ។

សូមមើលឧទាហរណ៍ក្នុងរូបជាវិភត្តិដទៃទៀតខាងក្រោមនេះ

នូវនរៈ២០០នាក់ **ទ្វេ នរានំ សតានិ** នូវរយ.ទ. នៃនរៈ.ទ. ពីរ, ទុ.វិ.
ដោយនរៈ២០០នាក់ **ទ្វីហិ នរានំ សតេហិ** ដោយរយ.ទ. នៃនរៈ.ទ. ពីរ
ដល់នរៈ២០០នាក់ **ទ្វិន្នំ នរានំ សតានំ** ដល់រយ.ទ. នៃនរៈ.ទ. ពីរ, ច.វិ.
អំពីនរៈ២០០នាក់ **ទ្វីហិ នរានំ សតេហិ** ពីរយ.ទ. នៃនរៈ.ទ. ពីរ,បញ្ច.វិ.
នៃនរៈ២០០នាក់ **ទ្វិន្នំ នរានំ សតានំ** នៃរយ.ទ. នៃនរៈ.ទ. ពីរ, ឆ.វិ.
ក្នុងនរៈ២០០នាក់ **ទ្វីសុ នរានំ សតេសុ** ក្នុងរយ.ទ. នៃនរៈ.ទ. ពីរ, ស.វិ.

ដូច្នេះចំនួនឯទៀត ៗ គប្បីជ្រាបតាមសេចក្តីនេះផងចុះ ។

ឃ. ប្រសិនបើមានសំខ្យាគុណនាមដែលប្រើ **ឧត្តរ** និងសំខ្យានាម-នាមដែលប្រើ **អធិក** រួមជាមួយផង ត្រូវយកសំខ្យាគុណនាមដែលប្រើ **ឧត្តរ** រៀងដាក់លេខ ១, សំខ្យានាមដែលប្រើ **អធិក** រៀងដាក់លេខ ២, នាមនាមដែលបំបែកជាឆដ្ឋីវិភត្តិពហុវចនៈរៀងដាក់ទី ៣, សំខ្យានាមចំនួនច្រើនដាក់ទី ៤ ដូចឧទាហរណ៍ខាងក្រោមនេះ ។

ឧទាហរណ៍ បុរស ១២២០

| ១ | | ២ | | ៣ | ៤ |
|---|---|---|---|---|---|
| វីស + ឧត្តរ | + | ទ្វិសត + អាធិក | + | បុរិស | + សហស្ស |
| វីសុត្តរ | + | ទ្វិសតាធិក | + | បុរិស | + សហស្ស |

សំខ្យាស័ព្ទដែលមាន **ឧត្តរ** និង **អធិក** ជាប់ជាមួយនោះចាំបាច់ត្រូវបំបែកឱ្យមានវចនៈនិងវិភត្តិស្មើគ្នានឹងសំខ្យានាមចំនួនច្រើន ដែលនៅទីបំផុតនិងដែលជាប្រធានដូច្នេះ

**វីសុត្តរានិ ទ្វិសតាធិកានិ បុរិសានំ សហស្សានិ**

វីពាន់.ទ. នៃបុរស.ទ. ក្រៃលែងដោយពីររយ លើសដោយម្ភៃ

=ប្រុស ១២២០ នាក់ ។

ត្រង់សំខ្យាគុណនាមដែលជាប់ដោយ **ឧត្តរ** អាចយកនាមនាមដែលបំបែកជាឆដ្ឋីវិភត្តិពហុវចនៈនោះមកដាក់ជ្រែកពីមុខ **ឧត្តរ** ដោយ

ពុំចាំបាច់បំបែកក៏បានដែរ សូមមើលឧទាហរណ៍ខាងក្រោមនេះ

**វីសបុរិសុត្តរទ្វិសតាធិកានិ បុរិសានំ សហស្សានិ**

ឬក៏ញែកចេញត្រង់ **ឧត្តរ** ដោយបំបែកឱ្យស្មើនឹង **អធិក** ក៏បានដូច្នេះ

**វីសបុរិសុត្តរានិ ទ្វិសតាធិកានិ បុរិសានំ សហស្សានិ**

៥. ការផ្សំបកតិសំខ្យាដែលជាប់ដោយ **ឧត្តរ** និង **អធិក** ដូចបានពោលរួចហើយទាំងប៉ុន្មានខាងលើនេះ បើប្រាថ្នាចង់ញែក **ឧត្តរ** និង **អធិក** ចេញពីសំខ្យាស័ព្ទក៏បាន ។ កាលបើញែកចេញហើយ **ឧត្តរ** និង **អធិក** ស័ព្ទត្រូវបំបែកឱ្យមានវចនៈនិងវិភត្តិស្មើគ្នានឹងសំខ្យាចំនួនច្រើនដែលនៅទីបំផុត ។ រីឯសំខ្យាចំនួនគត់រយគត់ពាន់ជាដើមដែលនៅពីមុខ **អធិក** ត្រូវបំបែកជាតតិយាវិភត្តិពហុវចនៈជានិច្ច ។

ឧទាហរណ៍នៃ ២៥៥២

**ទ្វេបញ្ញាសុត្តរានិ បញ្ចសតេហិ អធិកានិ ទ្វិសហស្សានិ**

ប្រែថា "វីពាន់.ទ. ក្រៃលែង ដោយប្រាំរយ.ទ. លើសដោយហាសិបពីរ"

៦. ប្រសិនបើមាននាមនាមនៅរួមជាមួយផង នោះសំខ្យាគុណ-នាមដែលបំបែកនៅខាងដើម **ឧត្តរ** ក្តី សំខ្យានាមនាមដែលនៅខាងដើម **អធិក** ក្តីត្រូវបំបែកជាតតិយាវិភត្តិពហុវចនៈជានិច្ច ។

*ឧទាហរណ៍ បុរស ៤៣៥៦ នាក់*

**ឆបញ្ញាសាយ បុរិសេហិ ឧត្តរានិ តីហិ បុរិសានំ សតេហិ អធិកានិ ចត្តារិ បុរិសានំ សហស្សានិ ។**

*ប្រែថា វីពាន់.ទ. នៃបុរស.ទ. បួន ក្រៃលែង ដោយរយ.ទ. បី លើស ដោយបុរស.ទ. ហាសិបប្រាំមួយ ។*

*ឬនឹងយកមកបំប្រួញតាមវិធីសមាសក៏បាន ប៉ុន្តែនាមស័ព្ទដែលជ្រែកត្រង់ចន្លោះ* **ឧត្តរ** *និង* **អធិក** *ហើយនឹងសំខ្យានាមចំនួនច្រើនដែលនៅទីបំផុត ពុំចាំបាច់បំបែកតាមវិភត្តិផ្សេង ៗ ដូចឧទាហរណ៍ខាងលើទេ វេលាបំប្រួញតាមវិធីសមាសនឹងបានរូបដូចខាងក្រោមនេះ*

ឆបញ្ញាសបុរិសុត្តរតិសតាធិកានិ ចតុបុរិសសហស្សានិ

*ប្រែថា "វីពាន់នៃបុរសបួន.ទ. ក្រៃលែងដោយបីរយលើសដោយបុរសហាសិបប្រាំមួយ" ។*

*ឧទាហរណ៍នៃ បុរស ៨៧៦៣៧៣ នាក់*

**តេសត្តតិបុរិសុត្តរតិសតាធិកានិ ឆបុរិសសហស្សានិ សត្តបុរិសទសសហស្សានិ អដ្ឋបុរិសសតសហស្សានិ**

*ប្រែថា វីសែននៃបុរសប្រាំបី.ទ. ក្រៃលែងដោយប្រាំពីរម៉ឺន ក្រៃលែងដោយប្រាំមួយពាន់ ក្រៃលែងដោយបីរយលើសដោយចិតសិបបី ។*

*ការផ្សំបកតិសំខ្យាដូចបានរៀបរាប់ខាងលើឃើញថា មានលក្ខណៈវែង ៗ ។ ដើម្បីឱ្យងាយស្រួលជាងនេះត្រូវប្រើវិធីសមាស (មានអធិប្បាយនៅខាងមុខ) ដែលអាចបំប្រួញឱ្យខ្លីដូចឧទាហរណ៍ខាងក្រោមនេះ ។*

*១៩៥៤ បំប្រួញជា* **ចតុបញ្ញាសុត្តរនវសតាធិកសហស្សំ ។**

*២៥៦៩ បំប្រួញជា* **ឯកូនសត្តត្យុត្តរបញ្ចសតាធិកទ្វិសហស្សានិ**

*៩៩៩៩ បំប្រួញជា* **ឯកូនសតុត្តរនវសតាធិកនវសហស្សានិ ។**

*សូមល្បងប្រែតាមឧទាហរណ៍ដែលប្រែខាងលើ ត្រូវប្រែត្រឡប់ពីខាងចុងទៅខាងដើមវិញ វេលាប្រែបទសមាសហាមប្រែថា "ទាំងឡាយ" កណ្តាលបទសមាស ។ ការផ្សំបកតិសំខ្យាសុទ្ធ ៗ ទោះជាចំនួនប៉ុន្មានពាន់ក៏ដោយ ក៏អាចបំប្រួញតាមវិធីសមាសបានដែរ ។*

## វិធីផ្សំជា សករាជ

*ប្រសិនបើចង់ផ្សំជាសករាជ ត្រូវប្រើពាក្យថា* **សំវច្ឆរ** *ប្រែថា "ឆ្នាំ" ដូចខាងក្រោមនេះ*

*ឧទាហរណ៍នៃសករាជ ២៥៥២ (ព.ស.)*

## របៀបរាយ

**ទ្វេបញ្ញាសាយ សំវច្ឆរេហិ ឧត្តរានិ បញ្ចហិ <u>សំវច្ឆរានំ</u> សតេហិ អធិកានិ ទ្វេ សំវច្ឆរានំ សហស្សានិ ។**

ប្រែថា រីពាន់.ទ. នៃឆ្នាំ.ទ. ពីរ ក្រៃលែង ដោយរយ.ទ. នៃឆ្នាំ.ទ. ប្រាំ លើស ដោយឆ្នាំ.ទ. ហាសិបពីរ ។

## របៀបសមាស

**ទ្វេបញ្ញាសសំវច្ឆរុត្តរបញ្ចសតាធិកានិ ទ្វេសំវច្ឆរសហស្សានិ**

ប្រែថា រីពាន់នៃឆ្នាំ.ទ.ពីរ ក្រៃលែងដោយប្រាំរយលើសដោយឆ្នាំ ហាសិបពីរ ។

ឬចង់ថែមពាក្យថា **ឥទានិ**=ឥឡូវនេះ ដាក់នៅខាងដើមប្រយោគ និងថែមកិរិយាថា **អតិក្កន្តានិ**=កន្លងហើយ នៅទីបំផុតដូចខាងក្រោមនេះក៏បាន

**ឥទានិ ទ្វេបញ្ញាសសំវច្ឆរុត្តរបញ្ចសតាធិកានិ ទ្វេសំវច្ឆរ-សហស្សានិ អតិក្កន្តានិ ។**

ប្រែថា រីពាន់នៃឆ្នាំ.ទ.ពីរ ក្រៃលែងដោយប្រាំរយ លើសដោយឆ្នាំ ហាសិបពីរ កន្លងទៅហើយ ឥឡូវនេះ ។ គឺថា ២៥៥២ ឆ្នាំបានកន្លងទៅហើយ ។

ឧទាហរណ៍នៃសករាជ ២០០៨ (គ.ស.)

## របៀបរាយ

**អដ្ឋហិ សំវច្ឆរេហិ ឧត្តរានិ ទ្វេ <u>សំវច្ឆរានំ</u> សហស្សានិ**

# របៀបសមាស

## អដ្ឋសំវច្ឆរុត្តរានិ ទ្វេសំវច្ឆរសហស្សានិ

(បើ ព.ស. ឬ គ.ស. ឯទៀត ៗ ក៏មានគតិដូចគ្នានេះដែរ)

## វិធីផ្សំបកតិសំខ្យាជាមួយ អឌ្ឍ សព្ទ

ប្រសិនបើចង់រាប់ចំនួនជាកន្ទះដូចជា មួយកន្ទះ, ពីរកន្ទះ, មួយ-រយកន្ទះ, មួយពាន់កន្ទះ ជាដើមចាំបាច់ត្រូវការប្រើពាក្យថា **អឌ្ឍ** ប្រែថា "កន្ទះ" ដាក់ខាងដើម ។ សំខ្យាដែលលើសជាកន្ទះឬពាក់កណ្ដាលនៃសំខ្យាគត់រយគត់ពាន់គត់ម៉ឺន ត្រូវដាក់នៅកណ្ដាល និងសំខ្យាគត់រយគត់ពាន់គត់ម៉ឺនដាក់នៅខាងចុង ដូចឧទាហរណ៍ខាងក្រោមនេះ

**(អឌ្ឍ + បញ្ចម + សត) > អឌ្ឍបញ្ចមសត**

ប្រែថា "រយជាគម្រប់ ៥ ដោយកន្ទះ" គឺ (បួនរយកន្ទះ =៤៥០) ។

សំខ្យាដែលជាចំនួនលើសនៅក្រោយ **អឌ្ឍ** ត្រូវប្រកបរូបស័ព្ទជាបូរណសំខ្យាដែលចុះបច្ច័យក្នុងបូរណតទ្ធិត ៥ តួគឺ **តិយ, ថ, ឋ, ម, ឦ** តួណាមួយខាងចុង ។ ការរាប់បកតិសំខ្យាដូចពោលហើយនេះ គឺសំដៅដល់ការរាប់ចំនួនទីបំផុត រាប់ជាគម្រប់រយ, ពាន់, ម៉ឺន ។ល។

ឧទាហរណ៍ "ប្រុស ១៥០ រូប" ត្រូវរាប់ថា "ប្រុសរយជាគម្រប់ ២ ដោយកន្លះ" ក្នុងសេចក្ដីថាមនុស្សក្នុងរយទី ១ មានចំនួនពេញ ១០០ នាក់ ប៉ុន្តែមនុស្សក្នុងរយទី ២ មានតែពាក់កណ្ដាលទេគឺ ៥០ នាក់ ប៉ុណ្ណោះ ។ ការរាប់បែបនេះមានគតិដូចការរាប់ បូរណសំខ្យា (នឹងមានអធិប្បាយនៅខាងមុខ) ដែរ ។

ការប្រកបរូបបូរណសំខ្យាត្រង់ **ទុតិយ** =ទី២, **តតិយ** =ទី៣ និង **ចតុត្ថ** =ទី៤ ជាមួយ **អឌ្ឍ** មានរូបផ្លាស់ប្ដូរយ៉ាងច្រើនដូចខាងក្រោមនេះ

(**ទុតិយ** + **អឌ្ឍ**) > **ទិយឌ្ឍ**, **ទិវឌ្ឍ** ប្រែថា ជាគម្រប់ពីរដោយកន្លះ គឺ មួយកន្លះ ។

(**តតិយ** + **អឌ្ឍ**) > **អឌ្ឍតេយ្យ**, **អឌ្ឍតិយ** ប្រែថា ជាគម្រប់បីដោយកន្លះគឺ ពីរកន្លះ ។

(**ចតុត្ថ** + **អឌ្ឍ**) > **អឌ្ឍុឌ្ឍ** ប្រែថា ជាគម្រប់បួនដោយកន្លះគឺបីកន្លះ ។

ចាប់ពី **បញ្ចម** ទី ៥ តទៅមិនមានផ្លាស់ប្ដូរទេ ត្រូវប្រើ **អឌ្ឍ** ស័ព្ទដាក់នៅខាងចុងជាការស្រេចដូចខាងក្រោមនេះ

(**អឌ្ឍ** + **បញ្ចម**) > **អឌ្ឍបញ្ចម** ប្រែថា ជាគម្រប់ ៥ ដោយកន្លះ, បួនកន្លះ ។

(**អឌ្ឍ** + **ឆដ្ឋ**) > **អឌ្ឍឆដ្ឋ** ប្រែថា ជាគម្រប់ ៦ ដោយកន្លះ, ប្រាំកន្លះ ។

កាលបើបានយល់ពីការផ្សំបូរណសំខ្យាជាមួយ **អឌ្ឍ** ស័ព្ទហើយ គឺអាចផ្សំសំខ្យាចំនួនគត់ ៗ ដូចជា **សត**, **សហស្ស**, **ទសសហស្ស**,

**សតសហស្ស** ឬ **លក្ខ**, **ទសសតសហស្ស** តទៅទៀតផងដែរ ដោយដាក់សំខ្យាចំនួនទាំងនេះខាងចុងដូចខាងក្រោមនេះ ។

**ទិយឌ្ឍសត** ប្រែថា រយជាគម្រប់ពីរដោយកន្លះ (១៥០) ។

**អឌ្ឍតេយ្យសត** ប្រែថា រយជាគម្រប់បីដោយកន្លះ (២៥០) ។

**អឌ្ឍុឌ្ឍសត** ប្រែថា រយជាគម្រប់បួនដោយកន្លះ (៣៥០) ។

**អឌ្ឍបញ្ចសត** ប្រែថា រយជាគម្រប់ប្រាំដោយកន្លះ (៤៥០) ។

**អឌ្ឍឆដ្ឋសត** ប្រែថា រយជាគម្រប់ប្រាំមួយដោយកន្លះ (៥៥០) ។

**ទិយឌ្ឍសហស្ស** ប្រែថា ពាន់ជាគម្រប់ពីរដោយកន្លះ (១៥០០) ។ល។

**អឌ្ឍ** ស័ព្ទមិនកំណត់ថាត្រូវតែប្រើជាមួយបូរណសំខ្យាទេ បកតិសំខ្យាក៏អាចប្រើជាមួយបានដែរដោយដាក់ **អឌ្ឍ** នៅខាងដើមដដែល និងដាក់សំខ្យានាមគត់ ៗ នៅខាងចុងដូចខាងក្រោមនេះ

**អឌ្ឍតេរសានិ ភិក្ខុសតានិ** =រយ.ទ.នៃភិក្ខុ.ទ. ជាគម្រប់ដប់បីដោយកន្លះ គឺ ភិក្ខុ ១២៥០ រូប ។ ស្មើនឹង **បញ្ញាសុត្តរានិទ្វិសតានិក-ភិក្ខុសហស្សំ** =១២៥០ ។

**ទិយឌ្ឍានិ សតានិ** =រយ.ទ. ជាគម្រប់ ២ ដោយកន្លះ =១៥០ ។

**ទិយឌ្ឍានិ សហស្សានិ** =ពាន់.ទ. ជាគម្រប់ ២ ដោយកន្លះ = ១៥០០ ។ល។

ពាក្យថា **ទិយឌ្ឍ**, **អឌ្ឍតេយ្យ** និង **អឌ្ឍុឌ្ឍ** ជាស័ព្ទសម្រេចមកពីតតិយាតប្បុរិសសមាស (មានអធិប្បាយនៅខាងមុខ) ដែលមានវិធីចងជា

វិគ្គហៈនៃសមាសដូច្នេះ **អឌ្ឍ** សព្ទត្រូវបំបែកជា **អឌ្ឍេន** ក្នុងរូបជាតតិយាវិភត្តិជានិច្ចប្រែថា "ដោយកន្លះ" រៀងដាក់ខាងដើមសព្ទបូរណសំខ្យាចាប់ពីចំនួនទី ២ ដល់ទី ៤ ដោយបំបែកឱ្យមានវចនៈនិងវិភត្តិស្មើនឹងសំខ្យានាមជាចំនួនគត់រយគត់ពាន់ដែលនៅខាងចុងដូចខាងក្រោមនេះ

១. **អឌ្ឍេន ទុតិយំ សតំ > ទិយឌ្ឍសតំ** ប្រែថា រយជាគម្រប់ពីរដោយកន្លះ ឈ្មោះថា **ទិយឌ្ឍសតំ, ទិយឌ្ឍសតំ** =រយជាគម្រប់ពីរដោយកន្លះ គឺ ១៥០ ។

២. **អឌ្ឍេន តតិយំ សតំ > អឌ្ឍតេយ្យសតំ** ប្រែថា រយជាគម្រប់បីដោយកន្លះ ឈ្មោះថា **អឌ្ឍតេយ្យសតំ, អឌ្ឍតេយ្យសតំ** =រយជាគម្រប់បីដោយកន្លះ គឺ ២៥០ ។

៣. **អឌ្ឍេន ចតុត្ថំ សតំ > អឌ្ឍុឌ្ឍសតំ** ប្រែថា រយជាគម្រប់បួនដោយកន្លះ ឈ្មោះថា **អឌ្ឍុឌ្ឍសតំ, អឌ្ឍុឌ្ឍសតំ** =រយជាគម្រប់បួនដោយកន្លះ គឺ ៣៥០ ។

៤. **អឌ្ឍេន បញ្ចមំ សតំ > អឌ្ឍបញ្ចមសតំ** រយជាគម្រប់ប្រាំដោយកន្លះ ឈ្មោះថា **អឌ្ឍបញ្ចមសតំ, អឌ្ឍបញ្ចមសតំ** =រយជាគម្រប់ប្រាំដោយកន្លះ គឺ ៤៥០ ។

ព្រោះហេតុនេះហើយទើបប្រែថា "ដោយកន្លះ = **អឌ្ឍេន**" ។

ប្រសិនបើជាសំខ្យាចំនួនគត់ពាន់គត់ម៉ឺន ក៏គ្រាន់តែផ្លាស់ពាក្យថា **សតំ > សហស្សំ** ឬជា **ទសសហស្សំ** ជាការស្រេច ទោះបីជាចំនួន

ប៉ុន្មានក៏ដោយគឺអនុវត្តដូចគ្នាដែរ ។

**ទិយឌ្ឍ**, **អឌ្ឍតេយ្យ** និង **អឌ្ឍុឌ្ឍ** អាចបំបែកបានក្នុងលិង្គបី ។ សូមមើល **ទិយឌ្ឍ** =មួយកន្លះ បំបែកដូច្នេះ **ទិយឌ្ឍោ**, **ទិវឌ្ឍោ** (បុំ.), **ទិយឌ្ឍា**, **ទិវឌ្ឍា** (ឥ.), **ទិយឌ្ឍំ**, **ទិវឌ្ឍំ** ( នបុំ.)ៗលៗ ស្ដីពីវិធីចងវិគ្គហៈ អ្នកសិក្សានឹងបានជ្រាបក្នុងពេលសិក្សាអំពីនាមកិតកៈនៅខាងមុខ ។

## វិធីផ្សំ អឌ្ឍ ស័ព្ទរួមជាមួយនាមស័ព្ទ

ការផ្សំ អឌ្ឍ ស័ព្ទជាមួយនាមស័ព្ទក៏មានគតិដូចការផ្សំបកតិសំខ្យារួមជាមួយនាមស័ព្ទដែរ ។ ចំពោះនាមស័ព្ទដែលជ្រែកចូលមកនោះ ត្រូវបំបែកជាឆដ្ឋីវិភត្តិពហុវចនៈជានិច្ច ហើយរៀងដាក់ខាងដើមសំខ្យានាមចំនួនគត់រយគត់ពាន់ (ចូរមើលវិធីផ្សំបកតិសំខ្យារួមជាមួយនាមស័ព្ទក្នុងខាងដើមនៃមេរៀននេះ) ។

១. ប្រុស ១៥០ នាក់

**អឌ្ឍេន ទុតិយំ បុរិសានំ សតំ** > **ទិយឌ្ឍបុរិសសតំ** =រយនៃប្រុស.ទ. ជាគំរប់ ពីរ ដោយកន្ទះ ឈ្មោះថា **ទិយឌ្ឍបុរិសសតំ**, **ទិយឌ្ឍបុរិសសតំ** =រយនៃប្រុសជាគម្រប់ពីរដោយកន្ទះ ។

២. ស្រី ២៥០ នាក់

**អឌ្ឍេន តតិយំ ឥត្ថីនំ សតំ** > **អឌ្ឍតេយ្យឥត្ថីសតំ** ។

៣. ប្រុស ៣៥០ នាក់ =

**អឌ្ឍេន ចតុត្ថំ បុរិសានំ សតំ > អឌ្ឍុឌ្ឍបុរិសសតំ ។**

៤. ស្រី ៤៥០ នាក់

**អឌ្ឍេន បញ្ចមំ ឥត្ថីនំ សតំ > អឌ្ឍបញ្ចមឥត្ថីសតំ ។**

៥. ប្រុស ១,៥០០នាក់

**អឌ្ឍេន ទុតិយំ បុរិសានំ សហស្សំ > ទិយឌ្ឍបុរិសសហស្សំ ។**

៦. ស្រី ៤,៥០០ នាក់

**អឌ្ឍេន បញ្ចមំ ឥត្ថីនំ សហស្សំ > អឌ្ឍបញ្ចមឥត្ថីសហស្សំ ។**

*ចាប់ពីលេខ ២-៦ មានវិធីប្រែដូចលេខ ១ ដែរដោយគ្រាន់តែផ្លាស់ចំនួនប៉ុណ្ណោះ។ ការផ្សំជាមួយចំនួនឯទៀត ៗ គប្បីយកតាមវិធីនេះចុះ។*

## កំណត់សម្គាល់

*សំខ្យាដទៃ ៗ ទៀតគប្បីផ្សំតាមវិធីដូចបានរៀបរាប់រួចហើយខាងលើនេះ ឃើញថាមានវិធីច្រើនយ៉ាង ។ ចំណុចសំខាន់ដែលត្រូវដឹងគឺថា ចាប់ពីចំនួនប៉ុន្មានដល់ទៅប៉ុន្មានជា គុណនាម និងចាប់ពីចំនួនប៉ុន្មានដល់ទៅប៉ុន្មានជា នាមនាម ពីព្រោះការផ្សំបកតិសំខ្យា ចាំបាច់ត្រូវដឹងនូវក្រិត្យក្រមដូចបានពោលរួចហើយនេះ ។*

ត្រូវចាំថាពី **ឯក** រហូតដល់ **អដ្ឋនវុតិ**=៩៨ ជាសង្ខ្យាគុណនាម ពី **ឯកូនសត** =៩៩ ឡើងទៅគឺជាសង្ខ្យានាម ។

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| **វិបស្សនា** ឥ. | ការឃើញច្បាស់ | **បរិសា** ឥ. | បរិស័ទ |
| **សិក្ខា** ឥ. | ការសិក្សា | **និរយ** នបុំ. | នរក |
| **សុគតិ** ឥ. | ដំណើរល្អ,សុគតិ | **គរុ** បុំ. | គ្រូ, អាចារ្យ |
| **សន្តិក** នបុំ. | សំណាក់,ទីជិត | **វេជ្ជ** បុំ. | ឫស្សី |
| **អរញ្ញ** នបុំ. | ព្រៃ | **កុសល** នបុំ. | សេចក្តីល្អ |
| **រដ្ឋ** បុំ. | ដែន, រដ្ឋ | **រាជភដ** បុំ. | ទាហាន |

**ចាបសាលា** ឥ. សាលារៀន

**រាជភដ** បុំ. អាមាត្យរបស់ស្តេច

**ពុទ្ធសាសន** នបុំ. ពុទ្ធសាសនា

**មាឃបុណ្ណមីទិវស** បុំ,នបុំ. ថ្ងៃពេញបូណ៌មីខែមាឃ

**វិសាខបុណ្ណមីទិវស** នបុំ. ថ្ងៃពេញបូណ៌មីខែវិសាខ

**សិក្ខាកាម** គុ. អ្នកស្រឡាញ់ការសិក្សា

**អាម** និ. បាទ, ចាស

# លំហាត់នៃមេរៀនទី ១៣

## *ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. ការផ្សំបកតិសំខ្យាក្នុងខ្ទង់គត់រយនិងខ្ទង់គត់ពាន់ដូចជា ២០០ ជាដើមឡើងទៅ តើផ្សំដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។*

*២. ចំពោះបកតិសំខ្យាក្នុងខ្ទង់រយនិងខ្ទង់ពាន់ដែលមានលើសដូចជា ២០១, ១០០២ ជាដើម តើផ្សំដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។*

*៣. បកតិសំខ្យាចាប់ពី* **ឯក** *ដល់* **អដ្ឋនវុតិ** *បើប្រើជាបទវិសេសនៈឱ្យនាមនាមណាមួយ តើត្រូវរៀងដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។*

*៤. បកតិសំខ្យាចាប់ពី* **ឯកូនសត** *ឡើងទៅ បើប្រើជាបទវិសេសនៈឱ្យនាមនាមណាមួយ តើត្រូវរៀងដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។*

*៥. សូមឱ្យឧទាហរណ៍នៃរបៀបប្រើ* **ឧត្តរ** *និង* **អធិក** *រួមគ្នា ។*

*៦. វិធីផ្សំបកតិសំខ្យាជាមួយ* **អឌ្ឍ** *តើរៀងដូចម្ដេច ?សូមឱ្យឧទា. ។*

## *ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. បញ្ញាស សិក្ខាកាមា ហិយ្យោ ឥមស្មឹ គព្ភេ វិបស្សនំ ឧគ្គណ្ហឹសុ ។

២. បញ្ច ភិក្ខូនំ សតានិ វិហារេ ពុទ្ធំ ឧបសង្កមឹសុ ។

៣. សចេ តេ តឹសតិ ភិក្ខូ ឥមិនា មគ្គេន អចរិស្សំសុ, តេ ពុទ្ធំ អបស្សិស្សំសុ ។

៤. ឯកោ វ ភិក្ខុ សង្ឃិយាបិ ឥត្ថីហិ សទ្ធឹ ន និសីទេយ្យ ។

៥. បញ្ញាសាយ សាវកេហិ ឧត្តរំ ទ្វីហិ សាវកានំ សតេហិ អធិកំ សាវកានំ សហស្សំ មាឃបុណ្ណមីទិវសេ សន្និបតិ ។

៦. បុព្វេ បញ្ចសហស្សាធិកានិ វេ ជនានំ សតសហស្សានិ ឥមស្មឹ មហន្តេ នគរេ អហេសុំ, ឥទានិ បន ចតុទ្ទសសហស្សានិ ហោន្តិ ។

៧. បញ្ញាសសាវកុត្តរទ្វិសតាធិកំ សាវកានំ សហស្សំ មាឃបុណ្ណមីទិវសេ សន្និបតិ ។

៨. តិសតាធិកំ សិក្ខាកាមានំ សហស្សំ ឥមស្មឹ មហាវិទ្យាលយេ ហោតិ ។

៩. កឹ បន ត្វំ កសកោសិ (កសកោ + អសិ)?
អាម កសកោម្ហិ (កសកោ + អម្ហិ),
អហំ ន រាជភដោម្ហិ (រាជភដោ + អម្ហិ) ។

១០. ភិក្ខូ ទ្វិសតានិ សត្តវីសតិ សិក្ខាបទានិ រក្ខន្តិ ។

១១. ឯកស្មឹ វស្សេ បន តិសតានិ បញ្ចសដ្ឋី ទិវសា ហោន្តិ ។

១២. ឥមាយ ធាបសាលាយ បញ្ចសតានិ សិស្សា ឧគ្គណ្ហន្តិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ភិក្ខុ ៥០០រូប ចូលទៅជិតហើយ នូវព្រះពុទ្ធអង្គ ក្នុងវិហារ ធំ ។*

*២. ក្មេងប្រុស ១៥៩នាក់ និង ក្មេងស្រី ១៤០នាក់ ក្នុងសាលារៀន ។*

៣. ថ្ងៃស្អែក សិស្ស.ទ. ៥នាក់ នោះ នឹងទៅ កាន់វិទ្យាល័យ ឬ ?

៤. ២៥០៩ ឆ្នាំ ។

៥. ឥឡូវនេះ កន្លងហើយ ២៥១៩ ឆ្នាំ ។

៦. ភិក្ខុ ១២៥០រូប ប្រជុំគ្នាហើយ ក្នុងថ្ងៃពេញបូណ៌មីខែមាឃ ។

៧. ស្រីម្នាក់ឯងគត់ ចូរកុំដើរទៅឡើយ ក្នុងវេលារាត្រី ។

៨. បញ្ញា ជាគ្រឿងប្រសើរ ជាងទ្រព្យ ។

៩. បុគ្គល ដែលឆ្លាត តែងប្រកប នូវធម៌ ដែលជាកុសល, គេ រមែងទៅ
កាន់សុគតិ ។

១០. យើង.ទ. តែងសំពះ នូវលោកគ្រូ ដោយសេចក្ដីគោរព ។

១១. ផ្កាកុលាប មានក្លិនក្រអូប បិតនៅ ក្នុងដៃ របស់យើង.ទ. ។

១២. អ្នក.ទ. កំពុងចង នូវមេគោ.ទ. របស់អ្នក.ទ. ដោយខ្សែ.ទ. ។

១៣. ជន.ទ. តែងកាត់ នូវដើមឫស្សី.ទ. របស់គេ ដោយពូថៅ ។

**(ចប់មេរៀនទី ១៣)**

# មេរៀនទី ១៨

## អធិប្បាយអំពីវិធីរូបសិទ្ធិកិរិយាជាកម្មវាចក:

(Formation of verbs in Passive Voice)

*ការប្រកបរូបកិរិយាជាកម្មវាចកត្រូវធ្វើតាមរូបមន្តដូច្នេះ*

(*ធាតុ* +*បច្ច័យពួក*)+ **ឥ** *អា.* + **យ** *កម្ម.បច្ច័យ* + *វិភត្តិ*) > *កិរិយាស័ព្ទ*

*វិធីរូបសិទ្ធិកិរិយាជាកម្មវាចក:មានរបៀបធ្វើដូចខាងក្រោមនេះ*

*១. ប្រើធាតុណាមួយក៏បានក្នុងធាតុទាំង ៨ ពួក ប៉ុន្តែបានតែធាតុណាដែលជា* **សកម្មធាតុ** (*ធាតុដែលហៅរកកម្ម*) *និងត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយផង ។*

*២. ត្រូវចុះ* **យ** *បច្ច័យនិងមាន* **ឥ** *អាគមជាគ្រឿងសំគាល់ដែលច្រើនតែទីឃៈជា* **ឦ** *ឬមិនបាច់ចុះ* **ឥ** *អាគមក៏បាន ។*

*៣. ប្រើវិភត្តិអាខ្យាតខាង អត្តនោបទ* (*ខាងបរស្សបទក៏មានប្រើដែរ*) *។*

☸ *នេះប្រាប់ក្នុងសៀវភៅរៀនភាសាបាលីជាភាសាខ្មែរនិងភាសាថៃ តែសៀវភៅជាភាសាអង់គ្លេសវិញឃើញច្រើនប្រើខាងបរស្សបទវិភត្តិ ។*

## វិធីបំបែក បច ធាតុជាកម្មវាចក:

(Declension of paca in Passive voice)

| បរស្សបទ | | | អត្តនោបទ | | |
|---|---|---|---|---|---|
| បុរិសៈ | ឯកវចនៈ | ពហុវចនៈ | បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
| ប.បុ. | បចីយតិ | បចីយន្តិ | ប.បុ. | បចីយតេ | បចីយន្តេ |
| ម.បុ. | បចីយសិ | បចីយថ | ម.បុ. | បចីយសេ | បចីយវ្ហេ |
| ឧ.បុ. | បចីយាមិ | បចីយាម | ឧ.បុ. | បចីយេ | បចីយម្ហេ |

## កំណត់សម្គាល់

*ចំពោះវិភត្តិអាខ្យាតដទៃទៀតមានគតិដូចគ្នាដែរ គឺគ្រាន់តែផ្លាស់វិភត្តិចេញទៅជាការស្រេចដូចខាងក្រោមនេះ ។*

បញ្ចមីវិភត្តិ

បចីយតុ, បចីយន្តុ, បចីយាហិ, បចីយាថ, បចីយាមិ, បចីយាម ។

សត្តមីវិភត្តិ

បចីយេយ្យ, បចីយេយ្យុំ, បចីយេយ្យាសិ, បចីយេយ្យាថ ។ល។

អជ្ជតនីវិភត្តិ

អបចីយិ, អបចីយឹសុ, អបចីយោ, អបចីយិត្ថ ។ល។

ភវិស្សន្តីវិភត្តិ

បចីយិស្សតិ, បចីយិស្សន្តិ, បចីយិស្សសិ, បចីយិស្សថ ។ល។

# ១. វិធីចុះ យ បច្ច័យនិង ឥ អាគម

*ក.* **បច** *ប្រែថា "ចម្អិន" ពួក* **ភូ** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

(**បច** + **អ** + **ឥ** + **យ** + **តេ** ) > **បចីយតេ** (*លុប* **អ** *បច្ច័យចេញ*) ។

( **បច** + **អ** + **ឥ** + **យ** + **អន្តេ** ) > **បចីយន្តេ** (*លុប* **អ** *បច្ច័យចេញ*) ។

*ខ.* **ភុជ** *ប្រែថា "ស៊ី" ពួក* **រុធ** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកបឋមបុរិសៈដូច្នេះ*

(**ភុជ** > **ភុំជ** + **អ** + **ឥ** + **យ** + **តេ** ) > **ភុញ្ជីយតេ** (*លុប* **អ** *បច្ច័យចេញ*) ។

(**ភុជ** > **ភុំជ** + **អ** + **ឥ** + **យ** + **អន្តេ** ) > **ភុញ្ជីយន្តេ** (*លុប* **អ** *បច្ច័យចេញ*) ។

*គ.* **ពុធ** *ប្រែថា "ចេះ" ពួក* **ទិវ** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

(**ពុធ** + **យ** + **ឥ** + **យ** + **តេ** ) > **ពុជ្ឈីយតេ** ។

(**ពុធ** + **យ** + **ឥ** + **យ** + **អន្តេ** ) > **ពុជ្ឈីយន្តេ** ។

*ឃ.* **សុ** *ប្រែថា "ស្ដាប់" ពួក* **សុ** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

( **សុ** + **ណា** + **ឥ** + **យ** + **តេ** ) > **សុណីយតេ** ។

( សុ + ណា + ឥ + យ + អន្តេ ) > **សុណីយន្តេ** ។

*ង.* **កី** *ប្រែថា "ទិញ" ពួក* **កី** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

( កី + ជា > ណា + ឥ + យ + តេ ) > **កិណីយតេ** ។

( កី + ជា > ណា + ឥ + យ + អន្តេ ) > **កិណីយន្តេ** ។

*ច.* **គហ** *ប្រែថា "កាន់យក" ពួក* **គហ** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

( គហ + ណ្ហា + ឥ + យ + តេ ) > **គណ្ហីយតេ** (*លុប* ហ *ទីបំផុតធាតុចេញរស្សៈស្រៈ* អា *នៃ* ណ្ហា > ណ្ហ ) ។

( គហ + ណ្ហា + ឥ + យ + អន្តេ ) > **គណ្ហីយន្តេ** (*លុប* ហ *ទីបំផុតធាតុចេញរស្សៈស្រៈ* អា *នៃ* ណ្ហា > ណ្ហ) ។

*ឆ.* **ការ** *ប្រែថា "ធ្វើ" ពួក* **តន** *ធាតុជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

( ការ + ឥ + យ + តេ ) > **ការីយតេ, ការិយ្យតេ** ។

( ការ + ឥ + យ + អន្តេ ) > **ការីយន្តេ, ការិយ្យតេ** ។

*ជ.* **ចុរ** *ប្រែថា "លួច" ពួក* **ចុរ** *ធាតុ (ត្រូវលុបបច្ច័យប្រចាំពួកធាតុចេញ) ជាសកម្មធាតុប្រកបរូបកិរិយាជាកម្មវាចកៈបឋមបុរិសៈដូច្នេះ*

( ចុរ + ឥ + យ + តេ ) > **ចុរីយតេ** ។

( ចុរ + ឥ + យ + អន្តេ )> **ចុរីយន្តេ** ។

## ២. វិធីមិនបាច់ចុះ ឥ អាគម

*ចំពោះធាតុខ្លះមិនបាច់ចុះ ឥ អាគមក៏បានដែរ ។ ប្រសិនបើមិនប្រើ ឥ អាគមទេ រូបរបស់ធាតុនោះ ៗ នឹងប្រែប្រួលដោយការធ្វើសមានកម្មព្យញ្ជនៈទីបំផុតធាតុជាមួយនឹង យ បច្ច័យដូចខាងក្រោមនេះ*

(បច + យ + តេ) > បច្ចតេ
(ពជ + យ + តេ) > ពជ្ឈតេ
(ភណ + យ + តេ) > ភញ្ញតេ
(លភ + យ + តេ) > លព្ភតេ
(ខាទ + យ + តេ) > ខជ្ជតេ
(សិវ + យ + តេ) > សិព្វតេ
(ហន + យ + តេ) > ហញ្ញតេ
(ទិស + យ + តេ) > ទិស្សតេ
(យុជ + យ + តេ) > យុជ្ឈតេ
(ឧហ + យ + តេ) > ឧយ្ហតេ

*ចំពោះធាតុណាដែលមានទីបំផុតជាព្យញ្ជនសំយោគ(តម្រួត)ឬ រ, ស, ហ ដែលមិននិយមប្រើតម្រួត មិនត្រូវធ្វើសមានកម្មទេ ប៉ុន្តែត្រូវចុះ ឥ អាគមដូចខាងក្រោមនេះ*

(បុច្ឆ + ឥ + យ + តេ) > បុច្ឆីយតេ,
(សរ + ឥ + យ + តេ) > សរីយតេ,
(ការ + ឥ + យ + តេ) > ការីយតេ,
(ហាស + ឥ + យ + តេ) > ហាសីយតេ,
(វស + ឥ + យ + តេ) > វសីយតេ,
(មហ + ឥ + យ + តេ) > មហីយតេ,

## ៣. ចំពោះធាតុឯកព្យាង្គ

ចំពោះធាតុឯកព្យាង្គអាចចុះ យ បច្ច័យផ្ទាល់ដោយពុំចាំបាច់ចុះ ឥ អាគមបានដូចខាងក្រោមនេះ

៣.១ បើស្រៈនៃធាតុជា អា ផ្លាស់ស្រៈ អា > ឦ ដូចជា

(ធា + យ + តេ) > ធីយតេ,. (ឋា + យ + តេ) > ឋីយតេ,.

(ជា + យ + តេ) > ជីយតេ., (មា + យ + តេ) > មីយតេ,.

(វា + យ + តេ) > វីយតេ ជាដើម ។

៣.២ បើស្រៈនៃធាតុជា ឥ អាចទីឃៈជា ឦ និងអាចទីឃៈស្រៈ ឧ ទៅជា ឩ ដូចជា

(ជិ + យ + តេ) > ជីយតេ,. (ចិ + យ + តេ) > ចីយតេ,.

(កុ + យ + តេ) > កូយតេ,. (សុ + យ + តេ) > សូយតេ ។

៣.៣ បើធាតុជាស្រៈទីឃៈមិនមានការផ្លាស់ប្តូរទេ ដូចជា

(ភូ + យ + តេ) > ភូយតេ,. (ដី + យ + តេ) > ដីយតេ ជាដើម ។

៣.៤ បើមិនទីឃៈ ឥ អាគមនិងស្រៈនៃធាតុទេ ត្រូវតម្រួត យ បច្ច័យជា យ្យ ដូចជា បចីយតេ > បចិយ្យតេ, ចុរីយតេ > ចុរិយ្យតេ, សូយតេ > សុយ្យតេ, ជីយតេ > ជិយ្យតេ, ដីយតេ > ដិយ្យត, ជីយតេ > ជិយ្យតេ, ភូយតេ > កុយ្យតេ ។ល។

ចំពោះធាតុខ្លះដែលមាន វ នៅដើមធាតុនិយមផ្លាស់ វ ជា ឧ ដូចជា វច > ឧច រួចចុះ វ អាគមមកវិញបានរូបជា វុច ដូចឧទាហរណ៍ខាងក្រោមនេះ

(វច > វុច + យ + តេ) > វុច្ចតេ,. (វស > វុស + យ + តេ) > វុស្សតេ,. (វហ > វុហ + យ + តេ) > វុយ្ហតេ., (វប > វុប + យ + តេ) > វុប្បតេ.

ដូច្នេះឃើញថា កម្មវាចកកិរិយាស័ព្ទក្នុងមួយធាតុអាចមានរូបច្រើនយ៉ាង ដូចមានឧទាហរណ៍ខាងក្រោមនេះ

ការ មានរូបជា ការីយតេ, ការិយ្យតេ, កាយិរតេ, កាយ្យតេ ។

គម មានរូបជា គមីយតេ, គច្ឆីយតេ, គម្យតេ, គម្មតេ ។

គហ មានរូបជា គណ្ហីយតេ, គហិយតេ, គយ្ហតេ, ឃេប្បតេ ។

ហា មានរូបជា ហាយតេ, ហីយតេ ជាដើម ។

ចំណាំ ចំពោះ ញា ធាតុអាចរក្សាទុកតាមរូបដើមជា

(ញា + យ + តេ) > ញាយតេ ។

ចំពោះ ឥ អាគមដែលទីឃៈជា ឦ អាចរក្សាទុកជា ឥ ដដែលក៏បានដូចជា បចិយតេ ។

រីឯការប្រើវិភត្តិអាខ្យាតចំពោះកម្មវាចកកិរិយានេះ ក្នុងសៀវភៅរៀនបាលីសរសេរជាភាសាអង់គ្លេស ច្រើនប្រើវិភត្តិខាងបរស្សបទដូចជា បច + យ + តិ > បច្ចតិ ។ ប៉ុន្តែក្នុងសៀវភៅជាភាសាខ្មែរយើងច្រើនឃើញប្រើវិភត្តិខាងអត្តនោបទវិញ ។

# វិធីធ្វើសមានកម្ម យ បច្ច័យជាមួយព្យញ្ជនៈទីបំផុតធាតុ

## (The Assimilation of Ya suffix)

| បើទីបំផុតធាតុជា | + បច្ច័យ | បានជា | សម្រេចជា |
|---|---|---|---|
| ក | + យ | > ក្យ | > ក្ក |
| ខ | + យ | > ខ្យ | > ក្ខ |
| គ | + យ | > គ្យ | > គ្គ |
| ឃ | + យ | > ឃ្យ | > គ្ឃ |
| ច ឬ ត | + យ | > ច្យ, ត្យ | > ច្ច |
| ឆ ឬ ថ | + យ | > ឆ្យ, ថ្យ | > ច្ឆ |
| ជ ឬ ទ | + យ | > ជ្យ, ទ្យ | > ជ្ជ |
| ឈ ឬ ធ | + យ | > ឈ្យ, ធ្យ | > ជ្ឈ |
| ឌ | + យ | > ឌ្យ | > ឌ្ឌ |
| ឍ | + យ | > ឍ្យ | > ឌ្ឍ |
| ណ ឬ ន | + យ | > ន្យ, ណ្យ | > ញ្ញ |
| ប | + យ | > ប្យ | > ប្ប |
| ផ | + យ | > ផ្យ | > ប្ផ |
| ព ឬ វ | + យ | > ព្យ, វ្យ | > ព្វ |
| ភ | + យ | > ភ្យ | > ព្ភ |

| *បើទីបំផុតធាតុជា* | + *បច្ច័យ* | *បានជា* | *សម្រេចជា* |
|---|---|---|---|
| ម | + យ | > ម្យ | > ម្ម |
| រ | + យ | > រ្យ | > យ្យ |
| ល | + យ | > ល្យ | > ល្ល |
| ស | + យ | > ស្យ | > ស្ស |
| ហ | + យ | > ហ្យ | > យ្ហ |

## វិធីប្រែប្រយោគកម្មវាចក:

### បែបទី ១

*ប្រយោគកម្មវាចក:ត្រូវមានស័ព្ទសំខាន់ ៣ យ៉ាងគឺ*

១. **បទប្រធាន** (*មានរូបជា បឋមាវិភត្តិ*)...*ប្រែទី ១ ។*

២. **បទអនភិហិតកត្តា** (*មានរូបជាតតិយាវិភត្តិជាតួកត្តា*)...*ប្រែទី ២ ។*

៣. **បទកិរិយាស័ព្ទ** ( *មានរូបជាកម្មវាចកកិរិយា*)...*ប្រែទី ៣ ។*

១. **បទប្រធាន** *បានដល់ ស័ព្ទនាមណាដែលបំបែកជាបឋមវិភត្តិ ប្រែថា វី ជាឯកវចនៈឬពហុវចនៈក៏បាន ប្រែទី ១ ។*

*ស័ព្ទដែលអាចប្រើជាបទប្រធានបានមាន ៨ យ៉ាងគឺ* **នាមនាម**, **សព្វនាម**, **សំខ្យានាម**, **សមាសនាម**, **តទ្ធិតនាម**, **កិតនាម**, **កិតកិរិយា***ខ្វះ*, *កិរិយាប្រកប* **តុំ** *បច្ច័យ និងថែមនិបាត ៣ តួគឺ* **ឯវំ**,

**តថា**, អលំ។ ចាប់ពីសមាសនាមដល់និបាតនឹងអធិប្បាយនៅខាងមុខ ។

២. **បទអនភិហិតកត្តា** បានដល់ នាមស័ព្ទណាដែលបំបែកជា **តតិយាវិភត្តិ** ប៉ុណ្ណោះ ។ ហៅតាមសម្ពន្ធថា **អនភិហិតកត្តា** ជាឯក-វចនៈឬពហុវចនៈក៏បានចាត់ជា **តួកត្តា** (អ្នកធ្វើនូវអំពើ) ប្រែថា "ដែល, គឺ" ភាគច្រើននិយមប្រើពាក្យថា "គឺ" ។ បើជាពហុវចនៈត្រូវថែមពាក្យថា "ទាំងឡាយ" នៅខាងចុង ឧ. **ទាសេហិ** =គឺអ្នកបម្រើទាំងឡាយ ។ បទអនភិហិតកត្តានេះត្រូវប្រែទី ២ បន្ទាប់ពីបទប្រធាន ។

៣. **បទកិរិយាស័ព្ទ** បានដល់ កិរិយាស័ព្ទណាដែលប្រើគ្រប់-គ្រងប្រយោគមាន ២ ប្រភេទគឺ **អាខ្យាតកិរិយា** និង **កិតកិរិយា** (មានអធិប្បាយនៅខាងមុខ) ។ ក្នុងទីនេះសំដៅយកអាខ្យាតកិរិយាដែលមានធាតុ, បច្ច័យក្នុងកម្មវាចកៈជាគ្រឿងសំគាល់ និងវិភត្តិពួកវត្តមានាបច្ចុប្បន្នកាលខាងអត្តនោបទក៏មានឬបរស្សបទក៏មាន (ចូរមើលវិធីប្រ-កបរូបជាកិរិយាស័ព្ទនៅខាងលើ) ហើយជាពិសេសស័ព្ទកិរិយាត្រូវមានវចនៈស្មើបទប្រធានជានិច្ច, កិរិយាស័ព្ទត្រូវប្រែទី ៣ ដូចខាងក្រោមនេះ

### ឧ. សិស្សេហ សិប្បំ សិក្ខីយតេ ។

| | | | |
|---|---|---|---|
| បទប្រធាន | **សិប្បំ** | = វិសិល្បៈ | ប្រែទី ១ |
| បទអនភិហិតកត្តា | **សិស្សេហ** | = គឺសិស្ស | ប្រែទី ២ |
| បទកិរិយាស័ព្ទ | **សិក្ខីយតេ** | = កំពុងសិក្សា | ប្រែទី ៣ |

*ការរៀងប្រយោគកម្មវាចកៈនេះ នឹងរៀងដាក់បទប្រធាននៅខាងដើម និងដាក់តួកត្តានៅខាងចុងក៏បាន ។ រីឯកិរិយាស័ព្ទដាក់ចុងបង្អស់ដូច្នេះ* **សិប្បំ សិស្សេន សិក្ខីយតេ ។**

*បានសេចក្តីថាស្រេចតែសេចក្តីក្នុងប្រយោគជារឿងសំខាន់ ។ ជួនកាលតួកត្តាដែលមានរូបជាតតិយាវិភត្តិមិនមានក្នុងប្រយោគទេ តែដល់វេលាប្រែគប្បីរកស័ព្ទ (អញ្ញបទ) ណាមួយដែលមានន័យសមតាមសេចក្តីរបស់ប្រយោគមកបំពេញដូចខាងក្រោមនេះ*

**សិប្បំ សិក្ខីយតេ ។** *រីសិល្បៈ (គឺបុគ្គល) កំពុងសិក្សា ។*

## វិធីផ្លាស់ប្រយោគពីកត្តុវាចកៈទៅជាកម្មវាចកៈ

១. *<u>កត្តុវាចកៈ</u>* **កញ្ញា$_{១}$ ឱទនំ$_{៤}$ បចតិ$_{៣}$។**

*កញ្ញា$_{១}$ កំពុងចម្អិន$_{៣}$ នូវបាយ$_{៤}$ ។*

២. *<u>កម្មវាចកៈ</u>* **កញ្ញាយ$_{២}$ ឱទនោ$_{១}$ បច្ចតេ$_{៣}$។**

*បាយ$_{១}$ គឺកញ្ញា$_{២}$ កំពុងចម្អិន$_{៣}$ ។*

៣. *<u>កម្មវាចកៈ</u>* **ជនេហិ$_{២}$ ធម្មោ$_{១}$ សុយ្យន្តេ$_{៣}$។**

*ធម៌$_{១}$ គឺជន.ទ.$_{២}$ កំពុងស្តាប់$_{៣}$ ។*

៤. *<u>កត្តុវាចកៈ</u>* **ជនា$_{១}$ ធម្មំ$_{៤}$ សុណន្តិ$_{៣}$។**

*ជន.ទ.$_{១}$ កំពុងស្តាប់$_{៣}$ នូវធម៌$_{៤}$ ។*

បើតាមឧទាហរណ៍ខាងលើនេះឃើញថា បើចង់ផ្លាស់ពីកត្តុវាចកៈទៅជាកម្មវាចកៈគឺត្រូវផ្លាស់កិរិយាស័ព្ទពីកត្តុវាចកៈទៅជាកម្មវាចកៈ និងត្រូវផ្លាស់បទប្រធានពីបឋមាវិភត្តិទៅជាបទអនភិហិតកត្តា ឱ្យមានរូបជាតតិយាវិភត្តិ និងផ្លាស់បទកម្មដែលមានរូបជាទុតិយាវិភត្តិឱ្យទៅជាបទប្រធានមានរូបជាបឋមាវិភត្តិវិញ ។

រីឯការផ្លាស់ពីកម្មវាចកៈទៅជាកត្តុវាចកៈ គឺត្រូវធ្វើផ្ទុយគ្នាដូចឧទាហរណ៍ទី ៣ និងទី ៤ ។ សូមអ្នកសិក្សាជ្រាបតាមន័យនេះផងចុះ ។

ឧទាហរណ៍ខាងលើនេះជាប្រយោគខ្លី ៗ គឺមានតែស័ព្ទសំខាន់ ៗ ខ្វះមិនបាន ៣ យ៉ាងប៉ុណ្ណោះ ។ ប្រសិនបើជាប្រយោគវែង គឺត្រូវថែមរបៀបប្រែទៀត ។

## វិធីប្រែប្រយោគកម្មវាចកៈ បែបទី ២

១. **បទប្រធាន** (*មានរូបជា បឋមាវិភត្តិ*)... *ប្រែទី ១ ។*

២. **បទវិសេសនៈ** *នៃបទប្រធាន (បើមាន)... ប្រែទី ២ ។*

៣. **បទអនភិហិតកត្តា** (*មានរូបជាតតិយាវិភត្តិជាតួកត្តា*)...*ប្រែទី ៣។*

៤. **បទវិសេសនៈ** *នៃបទអនភិហិតកត្តា (បើមាន)... ប្រែទី ៤ ។*

៥. **បទកិរិយាស័ព្ទ** (*មានរូបជាកម្មវាចកកិរិយា*)... *ប្រែទី ៥ ។*

៦. **បទកិរិយាវិសេសនៈ** *នៃកិរិយាស័ព្ទ (បើមាន)... ប្រែទី ៦ ។*

# ប្រយោគឧទាហរណ៍

**ឯតេន$_{៤}$ ភិក្ខុនា$_{៣}$ ពុទ្ធស្ស$_{២}$ ធម្មោ$_{១}$ សាលាយំ$_{៦}$ ជនានំ$_{៦}$ ទិស្សតិ$_{៥}$។**

*ប្រែតាមលំដាប់លេខ ១-៦ ដូច្នេះ*

*ធម៌$_{១}$ របស់ព្រះពុទ្ធ$_{២}$ គឺភិក្ខុ$_{៣}$ នុ៎ះ$_{៤}$ កំពុងសំដែង$_{៥}$ ដល់ជន.ទ.$_{៦}$ ក្នុងសាលា$_{៦}$ ។*

*បើចង់ផ្លាស់ប្រយោគនេះឱ្យទៅជាកត្តុវាចកៈវិញ ត្រូវផ្លាស់កិរិយាស័ព្ទជាកត្តុវាចក និងផ្លាស់បទប្រធានជាបទកម្ម ហើយនឹងផ្លាស់តួកត្តាពីអនភិហិតកត្តាតតិយាវិភត្តិទៅជាបឋមាវិភត្តិវិញដូច្នេះ*

**ឯសោ$_{២}$ ភិក្ខុ$_{១}$ ពុទ្ធស្ស$_{៤}$ ធម្មំ$_{៥}$ សាលាយំ$_{៦}$ ជនានំ$_{៦}$ ទេសេតិ$_{៣}$។**

*ភិក្ខុ$_{១}$ នុ៎ះ$_{២}$ កំពុងសំដែង$_{៣}$ នូវធម៌$_{៤}$ របស់ព្រះពុទ្ធ$_{៥}$ ដល់ជន.ទ.$_{៦}$ ក្នុងសាលា$_{៦}$ ។*

*សូមសង្កេតមើលឱ្យបានច្បាស់លាស់ថា តើប្រយោគកត្តុវាចកៈ និងប្រយោគកម្មវាចកៈខុសប្លែកគ្នាដូចម្តេចខ្លះ ? ចំណុចសំខាន់គឺត្រូវមើលនាមស័ព្ទដើម្បីឱ្យឃើញថានាមស័ព្ទណាជា ការន្ត, លិង្គ, វចនៈនិងវិភត្តិអ្វី ប្រែជាភាសាខ្មែរថាយ៉ាងម៉េច ។*

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ឱក នបុំ. | ទឹក, ផ្ទះ | អាហារ បុំ. | អាហារ |
| អរិយ បុំ. | ព្រះអរិយៈ | សស្ស នបុំ. | សំណាប |
| ឧចាធាន នបុំ. | សេចក្តីប្រកាន់ | សត្ត បុំ. | សត្វ |
| គោណ បុំ. | គោឈ្មោល | ហិត បុំ.,នបុំ. | ប្រយោជន៍ |
| កិលេស នបុំ. | កិលេស | សុខ បុំ.,នបុំ. | សេចក្តីសុខ |
| គេហ នបុំ. | ផ្ទះ | បុញ្ញ បុំ. | បុណ្យ, សេ.ល្អ |
| ភាជន នបុំ. | ក្អម,ឆ្នាំង,ភាជន៍ | វិរិយ នបុំ. | សេចក្តីព្យាយាម |
| ចារ នបុំ. | ប្រាំង | កម្ម នបុំ. | កម្ម, ការងារ |
| មូល នបុំ. | គល់ឈើ, ឫស | ពោធិរុក្ខ បុំ. | ដើមពោធិ |
| ចោរ បុំ. | ចោរ | តិណ នបុំ. | ស្មៅ |
| ថេន បុំ. | ចោរ | វន នបុំ. | ព្រៃ |
| សូករ បុំ. | ជ្រូក | អង្គុលិ ឥ. | ម្រាមដៃ |
| រស្មិ ឥ. | រស្មី | នាវា ឥ. | ទូក |
| សម្មជ្ជនិ ឥ. | អំបោស | យុវតិ ឥ. | យុវតី |
| តរុណី ឥ. | ស្រីក្មេង | អសនិ ឥ. | រន្ទះ |
| ចោក្ខរណី ឥ. | ស្រះ, ត្រពាំង | ជាឡិ ឥ. | នាឡិ (រង្វាស់) |
| គាវី ឥ. | គោញី | មិគ បុំ. | សត្វម្រឹគ |

## ធាតុសព្ទក្នុងពួកទី ១ (ត)

| | | | |
|---|---|---|---|
| គរហ | តិះដៀល | វិ + ចរ > វិចរ | ដើរទៅ |
| មាន | រាប់អាន | ឧ + ឋា > ឧដ្ឋា | ក្រោក, រះឡើង |
| រម | រីករាយ | សំ+ឈេ>សជ្ឈាយ | សូត្រ, ទន្ទេញ |
| រុទ | យំ | អនុ + ភូ > អនុភូ | សោយ, ទទួល |
| រុច | រុងរឿង, គាប់ចិត្ត | ប + ហារ > បហារ | វាយ, ប្រហារ |
| វឌ្ឍ | ចំរើន | អសឹស | សង្ឃឹម, ប៉ង |
| ធោវ | បោកគក់, លាង | ភាស | ពោល, និយាយ |
| ឌហ | ឆេះ, រលាក, ដុត | វហ | ទាញទៅ,អូសទៅ |
| វា | បក់, ផាត់ | វប | សាប, ព្រោះ |

## លំហាត់នៃមេរៀនទី ១៨

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើវិធីប្រកបរូបជាកម្មវាចកកិរិយាស័ព្ទត្រូវប្រើអ្វីខ្លះ ?

២. តើវិធីប្រកបរូបជាកម្មវាចកកិរិយាស័ព្ទមានប៉ុន្មានយ៉ាង ? សូមឱ្យឧទាហរណ៍ខ្លះ

៣. តើប្រយោគកម្មវាចកៈត្រូវមានស័ព្ទសំខាន់ ៗ អ្វីខ្លះ ?

៤. តើ **បទអនភិហិតកត្តា** បានដល់នាមស័ព្ទប្រភេទណា ?

៥. តើកិរិយាស័ព្ទដែលប្រើគ្រប់គ្រង់ប្រយោគកម្មវាចកៈមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

៦. តើស័ព្ទដែលអាចប្រើជាបទប្រធានបានមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ**

១. កញ្ញាយ ឱទនោ បចីយតេ ។

២. តេ គោណា ទាសេហិ បហរីយន្តិ ។

៣. ត្វំ ពលិនា បុរិសេន អកឌ្ឍីយសេ ។

៤. អម្ហាកំ មិត្តា អរីហិ មរីយន្តេ ។

៥. តេ មិគា តាយ ទាសិយា ពន្ធីយន្តិ ។

៦. ឥមិនា វឌ្ឍកិនា ឥមស្មឹ គាមេ ពហូនិ គេហានិ ការីយន្តិ ។

៧. តុម្ហេ តស្មឹ គាមេ មនុស្សេហិ ពន្ធីយថ ។

៨. អម្ហាកំ ភណ្ឌានិ តេសំ ទាសេហិ គាមំ ហរីយន្តេ ។

៩. វាណិជេហិ ចត្តារោ អស្សា នគរំ អាហរីយន្តិ ។

១០. ពុទ្ធេន ទេវានំ មនុស្សានញ្ច ធម្មោ ភាសីយតេ ។

១១. តំ មហន្តំ ខេត្តំ បញ្ចហិ កស្សកេហិ កសីយតេ ។

១២. វនិតាយ ពហូនិ វត្ថានិ តស្សំ បោក្ខរណិយំ ធោវីយន្តេ ។

១៣. សេដ្ឋិនា ពហុន្នំ យាចកានំ ទានំ ទីយតេ ។

១៤. តស្មឹ អារាមេ អដ្ឋវសេហិ ភិក្ខូហិ សីលានិ រក្ខីយន្តិ ។

១៥. ឆហិ ភិក្ខូហិ បញ្ចសតានំ មនុស្សានំ ធម្មោ ទេសីយតិ ។

១៦. បញ្ញាសាយ មនុស្សេហិ តស្មឹ អាបណេ ពហូនិ ភណ្ឌានិ កិណីយន្តេ ។

១៧. ទសហិ វនិតាហិ ទ្វិសតានិ អម្ពានិ អម្ហាកំ វិក្កិណីយតិ ។

១៨. ទាសិយា បក្កោ(=*ចម្អិនហើយ*) ឱទនោ គហបតិនា ភុញ្ជីយតេ ។

១៩. មគ្គេ ឋិតោ ជារកោ តស្ស មាតុយា ហត្ថេហិ គណ្ហីយតិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. វីព្រះពុទ្ធ គឺជន.ទ. កំពុងបូជា ។*

*២. ព្រះធម៌ ដ៏ល្អ របស់ព្រះពុទ្ធ គឺជន.ទ. កំពុងស្តាប់ ។*

*៣. វីភាសាបាលី គឺសិស្ស.ទ. ដែលឧស្សាហ៍ កំពុងរៀន ។*

*៤. វីគោ.ទ. នោះ គឺក្មេងប្រុស នេះ វាយ ។*

*៥. វីអីវ៉ាន់.ទ. របស់ខ្ញុំ គឺខ្ញុំ បំរើ.ទ. នាំយកទៅហើយ កាន់ផ្ទះ ។*

*៦. វីផ្ទះ នេះ គឺជាងឈើ ៨នាក់ កំពុងធ្វើ ។*

*៧. វីឥវ៉ាន់.ទ. គឺឈ្មួញ.ទ. ពីរនាក់ នេះ នឹងលក់ ក្នុងភូមិ នោះ ។*

*៨. វីព្រះធម៌ គឺធម្មកថិក លើអាសនៈ កំពុងសំដែង ដល់មនុស្ស.ទ. ក្នុងវិហារ នោះ ។*

*៩. សំពត់ ក្រហម ច្រើន គឺស្រី.ទ. នោះ បោកគក់ ក្នុងទន្លេ ជ្រៅ ។*

*១០. ផ្លែស្វាយ បីរយ គឺកសិករ ៦នាក់ លក់ហើយ ឯផ្សារ ។*

១១. រីស្មៅ ទាំងអស់ ក្នុងស្រែ នេះ គឺមេគោ.ទ. ៨ក្បាល ស៊ីហើយ ។
១២. សេះ ខ្មៅ ពីរក្បាល គឺបុរស ខ្ពស់ ពីររូប ទិញ ។
១៣. ព្រះពុទ្ធ រមែងសំដែង នូវធម៌ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់មនុស្ស.ទ. ក្នុងលោក ។

(ចប់មេរៀនទី ១៤)

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| កើតជាអង្គ | ពង្សជាមនុស្ស | ប្រុសឬស្រី |
| មានសំដី | ប្ញីគំនិត | គិតគ្រប់ប្រាណ |
| ត្រូវប្រឹងរៀន | រៀនឱ្យចេះ | ចេះចំណាន |
| ទើបជាតិបាន | បានខ្ពង់ខ្ពស់ | យសថ្កុំថ្កើង ។ |

(ដកស្រង់ពីទស្សនាវដ្ដី "កម្ពុជសុរិយា" លេខ ១ គ.ស ១៩៩៤ ទំព័រ៦០)

# មេរៀនទី ១៨

## អធិប្បាយអំពីអាខ្យាតកិរិយានិងវិធីអព្ភាស

### (៦) បរោក្ខាវិភត្តិ

### (Indefinite Past endings)

| | បរស្សបទ | | | អត្តនោបទ | |
|---|---|---|---|---|---|
| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* | *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
| *ប.បុ.* | អ | ឧ | *ប.បុ.* | ត្ថ | រេ |
| *ម.បុ.* | ឯ | ត្ថ | *ម.បុ.* | ត្ថោ | ភ្ហោ |
| *ឧ.បុ.* | អំ | ម្ហ | *ឧ.បុ.* | ត្ថំ | ម្ហេ |

*ពាក្យថា* **បរោក្ខា** *ប្រែថា "ពោលដល់អ្វីដែលកើតមានក្នុងកាលកន្លង" បានដល់ អំពើណាដែលកើតមានក្នុងអតីតកាលកន្លងទៅហើយមិនកំណត់ មានពាក្យប្រែថា "......ហើយ" ដូចជា* **ពោលហើយ** *ជាដើម ។ បរោក្ខាវិភត្តិមិនសូវមានប្រើច្រើនទេ ឃើញមានប្រើតែ ២ ធាតុញឹកញយជាងគេហើយដែលតែងតែផ្លាស់ជា* **អាហ** *ប្រែថា "ពោលហើយ" កិរិយាស័ព្ទដែលប្រើបរោក្ខាវិភត្តិនេះច្រើនតែបឋមបុរិសៈប៉ុណ្ណោះ ។*

*ការប្រកបរូបជាកិរិយាស័ព្ទជាមួយបរោក្ខាវិភត្តិ ត្រូវធ្វើអព្ភាសដើមធាតុ គឺធ្វើស្រៈឬព្យញ្ជនៈខាងដើមធាតុជាពីរតួ (មានពោលនៅខាងមុខ)*

ឧទាហរណ៍ បច ធាតុធ្វើអព្ភាសជា បបច ជាដើម ។

## វិធីរូបសិទ្ធិជាកិរិយាសព្ទ

ការប្រកបរូបកិរិយាសព្ទជាមួយបរោក្ខាវិភត្តិ មានគតិដូចវត្តមានាវិភត្តិដែរ ប្រើធាតុណាមួយក៏បាន តែត្រូវមានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយជានិច្ច ដូចមានរូបមន្តខាងក្រោមនេះ

(អក្ខរអព្ភាស + ធាតុ + បច្ច័យ + វិភត្តិ) > កិរិយាសព្ទ

## វិធីបំបែក បច ធាតុ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | បបច | បបចុ |
| ម.បុ. | បបចេ | បបចិត្ថ |
| ឧ.បុ. | បបចំ | បបចិម្ហ |

## វិធីបំបែក ព្រូ ធាតុ

| បុរិសៈ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | អាហ | អាហុ |
| ម.បុ. | ព្រវេ | ព្រវិត្ថ |
| ឧ.បុ. | ព្រវំ | ព្រវិម្ហ |

ខាងក្រោមនេះ ព្រូ ធាតុប្រែថា "ពោល" ជាមួយវិភត្តិនានាខាងបរស្សបទ ។

វត្តមានា ព្រូតិ, ព្រូវីតិ, ព្រុវីតិ, ព្រូសិ, ព្រូមិ, ព្រុវន្តិ, ព្រូថ, ព្រូម ។

បញ្ចមី ព្រុវតុ, ព្រូហិ, ព្រូមិ, ព្រុវន្តុ, ព្រូថ, ព្រូម ។

សត្តមី ព្រុវេ, ព្រុវេយ្យ, ព្រុវេយ្យាសិ, ព្រុវេយ្យាមិ, ព្រុវេយ្យុំ, ព្រុវេយ្យាថ ។

ហីយត្តនី អព្រវា, អព្រវោ, អព្រវំ, អព្រវូ, អព្រវិត្ថ, អព្រវម្ហា ។

អជ្ជតនី អព្រវិ, អព្រវោ, អព្រវី, អព្រវុំ, អព្រវិត្ថ, អព្រវម្ហា ។

ភវិស្សន្តិ ព្រវិស្សតិ, ព្រវិស្សសិ, ព្រវិស្សាមិ, ព្រវិស្សន្តិ, ព្រវិស្សថ, ព្រវិស្សាម ។

កាលាតិបត្តិ អព្រវិស្សា, អព្រវិស្សេ, អព្រវិស្សំ, អព្រវិស្សំសុ, អព្រវិស្សថ, អព្រវិស្សម្ហា ។

## ប្រយោគគំរូ

១. តេនាហ < (តេន + អាហ) ភគវា... ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយ... ។

២. សេដ្ឋី ឯវមាហ < (ឯវំ + អាហ)... ។

សេដ្ឋី ពោលហើយ យ៉ាងនេះ... ។

៣. តេជាហុ < (តេជ + អាហុ) ចោរណា... ។
ព្រោះហេតុនោះ អាចារ្យក្នុងកាលមុន.ទ. ពោលហើយ ។

# វិធីធ្វើអព្ភាស

ពាក្យថា **អព្ភាស** នេះ វចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត ប្រែថា "ការដាក់ថែម" ដូចជាពាក្យថា **គ្រើម** ថែម **គ** មួយទៀតពីខាងដើមទៅជា **គគ្រើម, ត្រុន > តត្រុន, ពើម > ពពើម** ជាដើម ។

នៅក្នុងភាសាបាលីនិងសំស្ក្រឹតក៏បានដល់ការថែមឬតម្រួតតួអក្សរមួយតួទៀតពីខាងដើមដូចគ្នា ។ ការធ្វើអព្ភាសនេះ គឺធ្វើចំពោះអក្សរដើមធាតុតែប៉ុណ្ណោះ ដែលមាន ២ យ៉ាងគឺ ធ្វើអព្ភាសស្រៈនិងធ្វើអព្ភាសព្យញ្ជនៈ ដូចមានវិធីធ្វើតទៅនេះ

## ១. វិធីធ្វើអព្ភាសស្រៈ

ប្រសិនបើអក្សរដើមធាតុជាស្រៈ ត្រូវធ្វើអព្ភាសតែស្រៈប៉ុណ្ណោះ ដូចជា ព្រូ ធាតុដែលផ្លាស់ជា **អាហា** ធ្វើអព្ភាសស្រៈដើមធាតុគឺថែមស្រៈ អ មួយទៀតដូចខាងក្រោមនេះ

អា-អាហា > អាហា (អា + អា > អា)

## ២. វិធីធ្វើអព្ភាសព្យញ្ជនៈ

១. បើព្យញ្ជនៈដើមធាតុមានស្រៈអាស្រ័យជាមួយផង នោះត្រូវធ្វើអព្ភាសទាំងស្រៈផងដែរ តែមិនមែនថែមស្រៈមួយតួទៀតទេ ។ បើស្រៈរបស់ព្យញ្ជនៈអព្ភាសដែលជាស្រៈទីឃៈត្រូវរស្សៈគឺ **អា** > **អ**, **ឦ** > **ឥ**, **ឩ** > **ឧ** ឬ **អ** ។ ជួនកាលស្រៈ **ឥ** > **ឯ**, **ឧ** > **ឱ** ។ ស្រៈរបស់ដើមធាតុដែលជាស្រៈ **អ** ជួនកាលទីឃៈជា **អា** ។

២. ព្យញ្ជនៈដែលថែមចូលមកខាងដើមធាតុ ប្រសិនបើជាព្យញ្ជនៈក្នុងវគ្គទី ១ គឺ **ក** វគ្គត្រូវផ្លាស់ជាព្យញ្ជនៈក្នុងវគ្គទី ២ គឺ **ច** វគ្គ ដូចខាងក្រោមនេះ

| | | | | | | |
|---|---|---|---|---|---|---|
| ក | ជាតួទី ១ | វគ្គទី ១ | ផ្លាស់ជា | ច | តួទី ១ | វគ្គទី ២ |
| ខ | .. ដ.. ២ | .... ដ .... | ... ដ ... | ឆ | .. ដ .. ២ | .... ដ .... |
| គ | .. ដ.. ៣ | .... ដ .... | ... ដ ... | ជ | .. ដ .. ៣ | .... ដ .... |
| ឃ | .. ដ.. ៤ | .... ដ .... | ... ដ ... | ឈ | .. ដ .. ៤ | .... ដ .... |
| ង | .. ដ.. ៥ | .... ដ .... | ... ដ ... | ញ | .. ដ .. ៥ | .... ដ .... |

( **ក** > **ច**, **ខ** > **ឆ**, **គ** > **ជ**, **ឃ** > **ឈ**, **ង** > **ញ** )

## ឧទាហរណ៍

**កម** ធាតុប្រែថា (ឈានទៅ) ធ្វើអព្ភាសជា **ក-កម** > **កក**

ប៉ុន្តែត្រូវផ្លាស់ **ក** ព្យញ្ជនៈអព្ភាសជា **ច** ទៅជា **ចកម** ហើយចុះនិគ្គហិតតាមពួក វុឌ ធាតុទៅជា (**ចំកម** > **ចង្កម** + **អ** + **តិ**) > **ចង្កមតិ** ប្រែថា ដើរទៅដើរមក (=ចង្រ្កម) ។

**គម** ធាតុប្រែថា "ទៅ" ធ្វើអព្ភាសជា **គ-គម** > **គគម** តែត្រូវផ្លាស់ **គ** ព្យញ្ជនៈអព្ភាសជា **ជ** ទៅជា **ជគម** ហើយចុះនិគ្គហិតតាមពួក វុឌ ធាតុទៅជា (**ជំគម** > **ជង្គម** + **អ** + **តិ**) > **ជង្គមតិ** ប្រែថា ទៅ, ដើរទៅ។

៣. ព្យញ្ជនៈដែលធ្វើអព្ភាសខាងដើមធាតុនោះ បើជាព្យញ្ជនៈក្នុងវគ្គដទៃក្រៅពី **ក** វគ្គត្រូវធ្វើដូច្នេះ បើជាព្យញ្ជនៈតួទី ១ និងតួទី ៣ ត្រូវធ្វើអព្ភាសតាមរូបនោះ ៗ ។ បើជាតួទី ២ ត្រូវផ្លាស់ជាតួទី ១ និងបើជាព្យញ្ជនៈតួទី ៤ ត្រូវផ្លាស់ជាតួទី ៣ និងបើជាព្យញ្ជនៈនៃ **អ** វគ្គធ្វើអព្ភាសតាមរូបដើមនោះ ៗ សូមមើល **ច** វគ្គទី ២ ខាងក្រោមនេះ

| | | | | | |
|---|---|---|---|---|---|
| ច | អក្សរតួទី ១ | អព្ភាសជា | ច | តួទី ១ | ក្នុងវគ្គផងគ្នា |
| ឆ | ..... ដ ..... ២ | ..... ដ ..... | ច | .. ដ .. ១ | ....... ដ ....... |
| ជ | ..... ដ ..... ៣ | ..... ដ ..... | ជ | .. ដ .. ៣ | ....... ដ ....... |
| ឈ | ..... ដ ..... ៤ | ..... ដ ..... | ជ | .. ដ .. ៣ | ....... ដ ....... |
| ល | អវគ្គព្យញ្ជនៈ | ..... ដ ..... | ល | រូបដើម | ....... ដ ....... |
| វ | អវគ្គព្យញ្ជនៈ | ..... ដ ..... | វ | ..... ដ ..... | ....... ដ ....... |

ព្យញ្ជនៈក្នុងវគ្គដទៃទៀតក៏ធ្វើដូចក្នុង **ច** វគ្គនេះដែរ ។

# ឧទាហរណ៍

**ឆិទ** *ប្រែថា "កាត់, ដាច់" ធ្វើអព្ភាសជា* **ឆិ-ឆិទ > ឆិឆិទ** *តែត្រូវផ្លាស់* **ឆិ** *ព្យញ្ជនៈអព្ភាសជា* **ចិ** *ទៅជា* (**ចិឆិទ > ចិឆេទ + អ + តិ**) > **ចិឆេទតិ** ។ *ឬក៏លុប* **ទ** *ទីបំផុតធាតុនិងផ្លាស់ស្រៈ* **ឯ** *នៃធាតុជា* **អ** *និងតម្រួតជា* **ច្ឆ** *ទៅជា* **ចិច្ឆតិ** =*កាត់* ។ *បើជាបរោក្ខាវិភត្តិជា* ( **ឆិ-ឆិទ + អ + អ**) > **ចច្ឆេទ** *ផ្លាស់* **ឆិ** *អព្ភាសជា* **ចិ** *ផ្លាស់ស្រៈ* **ឥ** *ជា* **អ**, *ព្រឹទ្ធិស្រៈ* **ឥ** *នៃធាតុជា* **ឯ** *និងតម្រួតជា* **ច្ឆ** ។

**បច** *ធាតុប្រែថា "ចម្អិន" ធ្វើអព្ភាសជា* (**ប-បច > បបច + អ + អ**) > **បបច** =*ចម្អិនហើយ (បរោក្ខា)* ។

**ទា** *ធាតុប្រែថា "ឱ្យ" ធ្វើអព្ភាសជា* **ទា-ទា > ទាទា** *តែត្រូវរស្សៈ* **ទា** *ព្យញ្ជនៈអព្ភាសជា* **ទ** *ទៅជា* (**ទទា + អ + តិ**) > **ទទាតិ** =*ឱ្យ* ។

**ធា** *ធាតុប្រែថា "ទ្រទ្រង់" ធ្វើអព្ភាសជា* **ធា-ធា > ធាធា** *តែត្រូវផ្លាស់* **ធា** *ព្យញ្ជនៈអព្ភាសជា* **ទា** *ហើយរស្សៈជា* **ទ** *ទៅជា* (**ទធា + អ + តិ**) > **ទធាតិ** = *ទ្រទ្រង់ (វត្តមានា)* ។

**បត** *ធាតុប្រែថា "ធ្លាក់, ជ្រុះ" ធ្វើអព្ភាសជា* (**ប-បត > បបត + អ + តិ**) > **បបតិ** =*ធ្លាក់ចុះ (វត្តមានា)* ។

**ចល** *ធាតុប្រែថា "កំរើក, រំជួល, ញ័រ" ធ្វើអព្ភាសជា* **ច-ចល > ចចល** *ចុះនិគ្គហិតតាមពួក* **រុធ** *ធាតុទៅជា* (**ចំចល > ចញ្ចល + អ + តិ**) > **ចញ្ចលតិ** =*កំរើក, រំជួល, ញ័រ (វត្តមានា)* ។

ភូ ធាតុប្រែថា "កើត, មាន, ជា" ធ្វើអព្ភាសជា ភូ-ភូ > ភូភូ តែត្រូវផ្លាស់ ភូ ព្យញ្ជនៈអព្ភាសជា ពូ ផ្លាស់ស្រៈ ឩ នៃ ពូ ជា អ ទៅជា ព រួចផ្លាស់ ភូ ធាតុជា ភូវ (ភូវ + អ + អ) > ពភូវ (បរោក្ខា) ។

ពុធ ធាតុប្រែថា "បេះ, ដឹង" ធ្វើអព្ភាសជា ពុ-ពុធ > ពុពុធ តែត្រូវព្រឹទ្ធិ ឧ នៃ ពុធ ធាតុជា ឱ ទៅជា ពុពោធ (ពុពោធ + អ + តិ) > ពុពោធតិ =បេះ, (វត្តមានា) ។

លប ធាតុប្រែថា "និយាយរអ៊ូ" ធ្វើអព្ភាសជា ល-លប > លលប ទៅជា (លលប + អ + តិ) > លាលបតិ, លាលប្បតិ =និយាយរអ៊ូ, ទីឃៈព្យញ្ជនៈអព្ភាសជា លា ទាំងពីរស័ព្ទ (វត្តមានា) ។

រិធ ធាតុប្រែថា "ចង់បាន" ធ្វើអព្ភាសជា រិ-រិធ > រិរិធ ទៅជា (រិរិធ + ឆ + តិ > រិរិធឆតិ) > រិរិច្ឆតិ =ចង់បាន ។ ដោយអំណាចនៃ ឆ បច្ច័យ (មានពោលនៅនៅខាងមុខ) ឱ្យផ្លាស់ ធ ទីបំផុតធាតុទៅជា ច បាន (វត្តមានា) ។

៤. ប្រសិនបើជា ហ ត្រូវអព្ភាសជា ជ ក៏ព្រោះ ហ ជាកណ្ឋជ-ឃោសៈដូចគ្នានិង ក ដែរតែត្រូវផ្លាស់ ក > ជ ទៀតតាមវិធីទីពីរខាងលើដូចតទៅនេះ

ហរ ធាតុប្រែថា "នាំទៅ" ធ្វើអព្ភាសជា ហ-ហរ > ហហរ តែត្រូវផ្លាស់ ហ ព្យញ្ជនៈអព្ភាសជា ជហរ, (ជហរ + អ + តិ) > ជហារតិ = នាំទៅ, ទីឃៈដើមធាតុជា អា ។

*ហស ធាតុប្រែថា "សើច" ធ្វើអព្ភាសជា* **ហ-ហស** > **ហហស** *តែត្រូវផ្លាស់* **ហ** *ព្យញ្ជនៈអព្ភាសជា* **ជ** *ទៅជា* **ជហស**, (**ជហស** + **អ** + **តិ**) > **ជហាសតិ** =*សើច, ទីឃៈដើមធាតុជា* **អា** *(វត្តមានា)* ។

*ហា ធាតុប្រែថា "លះបង់" ធ្វើអព្ភាសជា* **ហា-ហា** > **ហាហា** *តែត្រូវផ្លាស់* **ហា** *ព្យញ្ជនៈអព្ភាសជា* **ជា** *ហើយត្រូវរស្សៈជា* **ជ** *ទៅជា* **ជហា**, (**ជហា** + **អ** + **តិ**) > **ជហាតិ** = *លះបង់ ឬ* (**ជហ** + **អ** + **តិ**) > **ជហតិ** *ក៏បាន* ។

*ហុ ធាតុប្រែថា "បូជា" ធ្វើអព្ភាសជា* **ហុ-ហុ** > **ហុហុ** *តែត្រូវផ្លាស់* **ហុ** *ព្យញ្ជនៈអព្ភាសជា* **ជុ** > **ជុហុ** *ព្រឹទ្ធិ* **ឧ** *នៃ* **ហុ** *ជា* **ឱ** *ទៅជា* **ជុហោ**, (**ជុហោ** + **អ** + **តិ**) > **ជុហោតិ**, *ឬផ្លាស់* **ឱ** > **អវ** *ទៀតទៅជា* **ជុហវតិ**, *ឬក៏ផ្លាស់* **ឧ** *នៃ* **ហុ** *ធាតុជា* **អ** *ហើយទីឃៈជា* **អា** *ទៅជា* **ជហា**, (**ជហា** + **អ** + **តិ**) > **ជហាតិ** =*បូជា* ។

*៥. ប្រសិនបើដើមធាតុជាឧបសគ្គ ស័ព្ទឧបសគ្គនោះ ៗ មិនត្រូវធ្វើអព្ភាសទេ គឺធ្វើអព្ភាសតែព្យញ្ជនដើមធាតុប៉ុណ្ណោះ ឧទាហរណ៍*

(**វិ** + **កិត**) *ធាតុប្រែថា "សង្ស័យ" ធ្វើអព្ភាសជា* (**វិ** + **កិ-កិត**) > (**វិ** + **ចិ-កិត**) > **វិចិកិត** *ចុះ* **ឆ** *បច្ច័យទៀតទៅជា* (**វិចិកិត** + **ឆ** + **តិ**) > **វិចិកិច្ឆតិ** =*សង្ស័យ ។ ដោយអំណាចនៃ* **ឆ** *បច្ច័យ (មានពោលនៅខាងក្រោមនេះ) ឱ្យផ្លាស់* **ត** *ទី បំផុតធាតុទៅជា* **ច** *បាន (វត្តមានា)* ។

# បច្ចេកបច្ច័យក្នុងអាខ្យាតកិរិយា

*បច្ច័យពិសេសមាន ៥ តួគឺ* **ខ, ឆ, ស, អាយ, ឡិយ** *។ បច្ច័យទាំងប្រាំតួនេះសម្រាប់ចុះក្នុងកត្តុវាចកៈតែម៉្យាងទេ ។ ចំពោះបច្ច័យបីតួគឺ* **ខ, ឆ, ស** *កាលណាយកមកចុះក្នុងធាតុហើយ ត្រូវតែធ្វើអព្ភាសដើមធាតុនោះ ៗ ជានិច្ច ។ ធាតុខ្លះប្រែប្រួលចាករូបដើមយ៉ាងខ្លាំង ខ្លះមានការប្រែពិសេសទៀតផង គឺថាកាលបើចុះមកហើយត្រូវប្រែថា "ប្រាថ្នា-ដើម្បី ឬ ចង់" ។ បច្ច័យទាំងប្រាំតួនេះមានប្រើតិចតួចទេ និងមានប្រើតែជាមួយធាតុខ្លះ ៗ ដូចនឹងអធិប្បាយតទៅនេះ*

១. **កុជ** *ធាតុប្រែថា "ស៊ី, បរិភោគ" ធ្វើអព្ភាសជា* (**កុ-កុជ + ខ + តិ** > **កុកុជខតិ**) > **ពុកុក្ខតិ** *។ គឺត្រូវផ្លាស់ព្យញ្ជនៈអព្ភាស* **កុ** > **ពុ** *និងដោយអំណាចនៃ* **ខ** *បច្ច័យដែលនៅខាងចុងទើបត្រូវផ្លាស់ទីបំផុតធាតុពី* **ជ** > **គ** *ហើយផ្លាស់ពី* **គ** > **ក** *ទៀតដើម្បីឱ្យត្រូវតាមវិធីព្យញ្ជនៈសំយោគទៅជា* **ពុកុក្ខតិ** *ប្រែ "ប្រាថ្នាដើម្បីស៊ី, ចង់ស៊ី" ។*

២. **ឃស** *ធាតុប្រែថា "ស៊ី" ធ្វើអព្ភាសជា* (**ឃ-ឃស + ឆ + តិ** > **ឃឃសឆតិ**) > **ជិឃច្ឆតិ** *គឺត្រូវផ្លាស់ព្យញ្ជនៈអព្ភាស* **ឃ** > **គ** > **ជ** *រួចផ្លាស់ស្រៈ អ នៃព្យញ្ជនៈអព្ភាសជា* **ឥ** *។ ដោយអំណាចនៃ* **ឆ** *បច្ច័យនៅខាងចុងទើបត្រូវផ្លាស់ទីបំផុតធាតុពី* **ស** > **ច** *ទៅជា* **ជិឃច្ឆតិ** *ប្រែថា "ប្រាថ្នាដើម្បីស៊ី, ចង់ស៊ី" ។*

៣. **ហរ** ធាតុប្រែថា "នាំទៅ" ធ្វើអព្ភាសជា (**ហ-ហរ** + **ស** + **តិ** > **ហហរសតិ**) > **ជិគឹសតិ**, **ជិគីសតិ** គឺត្រូវផ្លាស់ព្យញ្ជនៈអព្ភាស **ហ** > **ជ**, រូបផ្លាស់ស្រៈ **អ** នៃព្យញ្ជនៈអព្ភាសជា **ឥ** ។ ដោយអំណាចនៃ **ស** បច្ច័យនៅខាងចុងទើបត្រូវផ្លាស់ធាតុទាំងមូលពី **ហរ** > **គឹ**, **គី** បានរូបជា **ជិគឹសតិ**, **ជិគីសតិ** ប្រែថា "ប្រាថ្នាដើម្បីនាំទៅ, ចង់បាន" ។

តែក្នុងសៀវភៅខ្លះថាជា **ជិ** ធាតុប្រែថា "ឈ្នះ" ធ្វើអព្ភាសជា (**ជិ-ជិ** + **ស** + **តិ** > **ជិជិសតិ**) > **ជិគឹសតិ**, ប្រែថា "ប្រាថ្នាដើម្បីឈ្នះ, ចង់ឈ្នះ" ។

៤. (**វិ** + **ជិ**) ធាតុប្រែថា "ឈ្នះ" ធ្វើអព្ភាសជា (**វិ** + **ជិ-ជិ** + **ស** + **តិ** > **វិជិជិសតិ**) > **វិជិគឹសតិ**, **វិជិគីសតិ** ។ ដោយអំណាចនៃ **ស** បច្ច័យនៅខាងចុងទើបត្រូវផ្លាស់ធាតុទាំងមូលពី **ជិ** > **គឹ**, **គី** ប្រែថា "ប្រាថ្នាដើម្បីឈ្នះ, ចង់ឈ្នះ" ។

៥. **សុ** ធាតុប្រែថា "ស្តាប់" ធ្វើអព្ភាសជា (**សុ-សុ** + **ស** + **តិ** > **សុសុសតិ**) > **សុស្សូសតិ** ។ មិនត្រូវផ្លាស់ព្យញ្ជនៈអព្ភាសទេ តែត្រូវតម្រួត **ស** បច្ច័យមួយតួទៀតទៅជា **ស្ស**, ដោយអំណាចនៃ **ស** បច្ច័យនៅខាងចុងត្រូវទីឃៈ **ឧ** នៃ **សុ** ធាតុជា **ឩ** ទៅជា **សុស្សូសតិ** ប្រែថា "ប្រាថ្នាដើម្បីស្តាប់, ចង់ស្តាប់" ។

៦. **បា** ធាតុប្រែថា "ផឹក" ធ្វើអព្ភាសជា (**បា-បា** + **ស** + **តិ** > **បាបាសតិ**) > **បិបាសតិ** ឬ **បិវាសតិ** ។ ត្រូវផ្លាស់ស្រៈ **អា** នៃព្យញ្ជនៈ

អព្ភាសជា ឥ, ដោយអំណាចនៃ ស បច្ច័យនៅខាងចុងអាចផ្លាស់ធាតុទាំងមូលពី ចា > វា បានរូបជា **បិវាសតិ** ប្រែថា "ប្រាថ្នាដើម្បីផឹក, ចង់ផឹក" ។

៧. **វច** ធាតុប្រែថា "ពោល" ធ្វើអព្ភាសជា (**វ-វច** + **ខ** + **តិ** > **វវចខតិ**) > **វវក្ខតិ**, ដោយអំណាចនៃ **ខ** បច្ច័យនៅខាងចុងត្រូវផ្លាស់ **ច** ទីបំផុតធាតុជា **ក** ឱ្យត្រូវតាមវិធីសំយោគទៅជា **វវក្ខតិ** ប្រែថា "ប្រាថ្នាដើម្បីពោល, ចង់ពោល" ។

៨. **ទា** ធាតុប្រែថា "ឱ្យ" ធ្វើអព្ភាសជា (**ទា-ទា** + **ឆ** + **តិ** > **ទាទាឆតិ**) > **ទិច្ឆតិ**, ត្រូវផ្លាស់ស្រៈនៃព្យញ្ជនៈអព្ភាសជា ឥ, ដោយអំណាចនៃ **ឆ** បច្ច័យនៅខាងចុងត្រូវផ្លាស់ធាតុទាំងមូលជា **ច** ឱ្យត្រូវតាមវិធីសំយោគទៅជា **ទិច្ឆតិ** ប្រែថា "ប្រាថ្នាដើម្បីឱ្យ, ចង់ឱ្យ" ។

៩. **វិទ** ធាតុ "ចង់បាន" ធ្វើអព្ភាសជា (**វិ-វិទ** + **ឆ** + **តិ** > **វិវិទឆតិ**) > **វិវិច្ឆតិ**, ដោយអំណាចនៃ **ឆ** បច្ច័យនៅខាងចុងត្រូវផ្លាស់ **ទ** ទីបំផុតធាតុជា **ច** ឱ្យត្រូវតាមវិធីសំយោគទៅជា **វិវិច្ឆតិ** ប្រែថា "ប្រាថ្នាចង់បាន" ។

១០. **តិជ** ធាតុប្រែថា "អត់ទ្រាំ" ធ្វើអព្ភាសជា (**តិ-តិជ** + **ខ** + **តិ** > **តិតិជខតិ**) > **តិតិក្ខតិ**, ដោយអំណាចនៃ **ខ** បច្ច័យនៅខាងចុងត្រូវផ្លាស់ទីបំផុតធាតុពី **ជ** > **គ** > **ក** ឱ្យត្រូវតាមវិធីព្យញ្ជនសំយោគទៅជា **តិតិក្ខតិ** =អត់ទ្រាំ ។

១១. **គុប** ធាតុប្រែថា "គ្រប់គ្រង, រក្សា" ធ្វើអព្ភាសជា (**គុ-គុប + ឆ + តិ > គុគុបឆតិ**) > **ជិគុច្ឆតិ**, ត្រូវផ្លាស់ព្យញ្ជនអព្ភាស **គុ > ជុ** រួចផ្លាស់ស្រៈ ឧ នៃព្យញ្ជនៈអព្ភាសជា ឥ, ដោយអំណាចនៃ **ឆ** បច្ច័យនៅខាងចុងត្រូវផ្លាស់ទីបំផុតធាតុ **ប > ច** ទៅជា **ជិគុច្ឆតិ** ប្រែថា "ខ្ពើម, ឆ្អើម" ។

១២. **កិត** ធាតុប្រែថា "រក្សា" ធ្វើអព្ភាសជា (**កិ-កិត + ឆ + តិ > កិកិតឆតិ**) > **ចិកិច្ឆតិ**, ត្រូវផ្លាស់ព្យញ្ជនៈអព្ភាស **កិ > ចិ**, ដោយអំណាចនៃ **ឆ** បច្ច័យនៅខាងចុងត្រូវផ្លាស់ទីបំផុតធាតុ **ត > ច** ឱ្យត្រូវតាមវិធីព្យញ្ជនៈសំយោគហើយតម្រួតជា **ច្ឆ** ទៅជា **ចិកិច្ឆតិ** ឬផ្លាស់ **ចិ > តិ** ទៅជា **តិកិច្ឆតិ** ប្រែថា "រក្សា, ព្យាបាល" ។

ប៉ុន្តែបើមាន **វិ** ឧបសគ្គនៅខាងដើមផង ត្រូវផ្លាស់ព្យញ្ជនៈអព្ភាស **កិ > ចិ** តាមវិធីទី ២ ទៅជា (**វិ + ចិកិច្ឆ + តិ**) > **វិចិកិច្ឆតិ** ប្រែថា "សង្ស័យ" ។

១៣. **មាន** ធាតុប្រែ "ល្បង, ពិចារណា" ធ្វើអព្ភាសជា (**មា-មាន + ស + តិ > មាមានសតិ**) > **មិមំសតិ** ឬ **វិមំសតិ**, អាចផ្លាស់ព្យញ្ជនៈអព្ភាស **មា > មិ** ឬ **វា** និងផ្លាស់ស្រៈ **អា** នៃព្យញ្ជនៈអព្ភាសជា **ឥ** និងដោយអំណាចនៃ **ស** បច្ច័យនៅខាងចុងត្រូវផ្លាស់ធាតុ **មាន > មម** រួចផ្លាស់ **ម** ដើមធាតុទៅជានិគ្គហិតសម្រេចជា **វិមំសតិ** ប្រែថា "ល្បង, ពិចារណា" ។

កិរិយាស័ព្ទខាងលើនេះគឺពី ១-៨ ហៅថា **ឥច្ឆិតុមត្ថកិរិយា** ក៏

បាន និងកិរិយាស័ព្ទចាប់ពី ៩-១៣ ពុំចាំបាច់ប្រែថា "ប្រាថ្នាដើម្បី, ចង់" ទេ គឺប្រែទទេ ៗ តាមធាតុនោះ ៗ ដូចជាកិរិយាស័ព្ទធម្មតាដែរ ។

កិរិយាស័ព្ទប្រភេទនេះអាចនៅមានទៀត សូមអ្នកសិក្សាស្វែងយល់ដោយខ្លួនឯងថែមទៀតផងចុះ ។

## វិធីប្រើ អាយ និង ឡៀយ បច្ច័យ

បច្ច័យទាំងឡាយដែលប្រើប្រចាំពួកធាតុទាំង ៨ ដូចបានសិក្សារួចមកហើយក្នុងមេរៀនខាងដើមនោះ មាននាទីប្រកបជាមួយធាតុតែម៉្យាងប៉ុណ្ណោះ ។ ចំពោះ **អាយ** និង **ឡៀយ** បច្ច័យពីរតួនេះសម្រាប់ប្រើប្រកបជាមួយនាមនាមឬគុណនាមឬនិបាត ដើម្បីធ្វើស័ព្ទនោះ ៗ ឱ្យក្លាយទៅជាកិរិយាស័ព្ទដែលអាចហៅថា **ធាតុរូបកាសទ្ធ** ក៏បាន ។ ដូច្នេះកិរិយាអាខ្យាតអាចសម្រេចមកពីមូលស័ព្ទរបស់ពាក្យ ២ ប្រភេទគឺ ធាតុស័ព្ទ និង នាមស័ព្ទ ។

## វិធីរូបសិទ្ធិជាកិរិយាស័ព្ទ

(នាមនាមឬគុណនាម + **អាយ** ឬ **ឡៀយ** + វិភត្តិ) > កិរិយាអាខ្យាត

កិរិយាអាខ្យាតពួកនេះមានវិធីប្រែប្លែកបន្តិច ។ បើសិនចុះ **អាយ**

*បច្ច័យប្រែបាន ២ យ៉ាងគឺប្រែថា "ប្រព្រឹត្ត...." ឬ "ប្រព្រឹត្ត...ឱ្យដូចជា, ប្រព្រឹត្ត...ថាដូចជា" ។ បើសិនចុះ ឦយ បច្ច័យក៏ប្រែបានពីរយ៉ាងដែរគឺ "ប្រព្រឹត្ត...ឱ្យដូចជា, ប្រព្រឹត្ត...ថាដូចជា" ឬ "ប្រាថ្នា...ដើម្បីខ្លួន, ចង់បាន ...ដើម្បីខ្លួន" ។*

## ១. ប្រែថា "ប្រព្រឹត្ត..."

(**បិយ** *គុ.* + **អាយ** + **តិ**) > **បិយាយតិ** =*ប្រព្រឹត្តឱ្យជាទីស្រឡាញ់ ។*

(**សុខ** *ន.* + **អាយ** + **តិ**) > **សុខាយតិ** =*ប្រព្រឹត្តនូវសេចក្ដីសុខ ។*

(**ចិរ** *គុ.* + **អាយ** + **តិ**) > **ចិរាយតិ** =*ប្រព្រឹត្តយូរ ។*

(**មច្ឆរ** *ន.* + **អាយ** + **តិ**) > **មច្ឆរាយតិ** =*ប្រព្រឹត្តនូវសេចក្ដីកំណាញ់ ។*

## ២. ប្រែថា "ប្រាថ្នា...ដើម្បីខ្លួន, ចង់បាន...ដើម្បីខ្លួន"

(**ធន** *ន.* + **ឦយ** + **តិ**) > **ធនីយតិ** =*ប្រាថ្នានូវទ្រព្យដើម្បីខ្លួន ។*

(**បត្ត** *ន.* + **ឦយ** + **តិ**) > **បត្តីយតិ** =*ចង់បាននូវបាត្រដើម្បីខ្លួន ។*

(**ចីវរ** *ន.* + **ឦយ** + **តិ**) > **ចីវរីយតិ** =*ចង់បាននូវចីវរដើម្បីខ្លួន ។*

## ៣. "ប្រព្រឹត្ត...ឱ្យដូចជា, ប្រព្រឹត្ត...ថាដូចជា"

(**បព្វត** + **អាយ** + **តិ**) > **បព្វតាយតិ** =*ប្រព្រឹត្តថាដូចជាភ្នំ ។*

(**សមុទ្ទ** + **អាយ** + **តិ**) > **សមុទ្ទាយតិ** =*ប្រព្រឹត្តថាដូចជាសមុទ្រ ។*

(**ពុទ្ធ** + **អាយ** + **តិ**) > **ពុទ្ធាយតិ** =*ប្រព្រឹត្តឱ្យដូចជាព្រះពុទ្ធ ។*

(**អរញ្ញ** + **ឦយ** + **តិ**) > **អរញ្ញីយតិ** =*ប្រព្រឹត្តថាដូចជាព្រៃ ។*

(**ឆត្ត** + **ឦយ** + **តិ**) > **ឆត្តីយតិ** =*ប្រព្រឹត្តថាដូចជាឆ័ត្រ ។*

(**បុត្ត** + **ឦយ** + **តិ**) > **បុត្តីយតិ** =*ប្រព្រឹត្តថាដូចជាកូន ។*

*ពាក្យប្រែថា "ប្រព្រឹត្តដូចជា" ក្នុងទីនេះមានសេចក្តីថា ឧបមានូវវត្ថុមួយថាជាវត្ថុមួយទៀតដូចជាថា "ប្រព្រឹត្តថាដូចជាឆ័ត្រ" គឺបុគ្គលនោះ ៗ មិនមានឆ័ត្រទេ តែយកអ្វីមួយមកប្រើធ្វើដូចជាឆ័ត្រ ដូចជាយកស្លឹកចេកមកទទូរនៅពេលមានភ្លៀងជាដើម ។ ពាក្យប្រែឯទៀត ៗ ក៏មានដំណើរដូចគ្នានេះដែរ ។*

*មានកិរិយាស័ព្ទប្រភេទនេះម៉្យាងទៀតដែលយកសូរស័ព្ទនៃអ្វីមួយមកផ្សំជាមួយបច្ច័យធ្វើឱ្យទៅជាកិរិយាស័ព្ទ ដែលឃើញមានចុះ* **អាយ** *បច្ច័យដូចឧទាហរណ៍ខាងក្រោមនេះ*

(**ឃុរុឃុរុ** + **អាយ** + **តិ**) > **ឃុរុឃុរាយតិ** =*ប្រព្រឹត្តនូវសូរឃូរ ៗ ។*

(**តជតជ** + **អាយ** + **តិ**) > **តជតជាយតិ** =*ប្រព្រឹត្តនូវសូរតជៈតជៈ ។*

(**គរគរ** + **អាយ** + **តិ**) > **គគ្គរាយតិ** =*ប្រព្រឹត្តនូវសូរពោទ៍ ។*

*ពាក្យថា ប្រព្រឹត្តនូវសូរឃូរ ៗ មានន័យថា ស្រមុក, ប្រព្រឹត្តនូវសូរ*

តជៈតជៈ មានន័យថា មានសំលេងគ្រឹក ៗ, ប្រព្រឹត្តនូវសូរពោទ៍ មានន័យថា ស្រែកពោទ៍ ។

កិរិយាស័ព្ទប្រភេទនេះហៅថា **អនុករណត្ថកិរិយាស័ព្ទ** ក៏សឹងបាន ។

សូមជ្រាបថា ការយកសំឡេងអ្វីមួយមកធ្វើត្រាប់សំឡេងនោះ ៗ ពីភាសាមួយទៅភាសាមួយទៀតមិនដូចគ្នាទេ ដូចមាននៅខាងលើនេះ ។ សំឡេងស្រមុកខ្មែរយើងថា "ឃូរៗ" តែបាលីថា "ឃុរុឃុរុ" ។ សំឡេងសត្វទាស្រែក ខ្មែរថា "កាប ៗ" អង់គ្លេសថា "ឃ្វាក់ ៗ" ដូច្នេះសូមអ្នកសិក្សាស្វែងយល់ខ្លួនឯងថែមផង់ចុះ ។

នៅក្នុងបករណ៍ខ្លះមិនកំណត់ថា បច្ច័យណាត្រូវប្រែថាយ៉ាងដូចម្តេចទេ ខ្លះថាបច្ច័យពីរតួនេះអាចប្រើផ្លាស់ប្តូរគ្នាបានដូចជា **ពុត្តាយតិ** ឬ **ពុត្តីយតិ** ។ កន្លែងខ្លះប្រាប់ថាជា **ឥយ** បច្ច័យដូចជា **ពុត្តិយតិ** ។

វិធីបន្ទាប់នេះប្លែកពីខាងលើបន្តិច គឺព្យញ្ជនៈព្យាង្គទី ១, ឬទី ២, ឬក៏ទី ៣ ត្រូវធ្វើអព្ភាសដោយចុះ **ឦសិយ** ឬ **យិស** បច្ច័យនិងចុះ **ឧ** ឬ **ឥ** អាគមត្រង់ចន្លោះនៃព្យញ្ជនៈអព្ភាស ដូចឧទាហរណ៍ខាងក្រោមនេះ

(បុ + បុត្ត + ឦយស + តិ) > **បុប្បុត្តីយិសតិ** =ប្រព្រឹត្តឱ្យដូចជាកូន ។

(បុត្ត + ត្ត + ឥ + ត្ត + ឦយិស) > **បុត្តិត្តយិសតិ** =ប្រព្រឹត្តឱ្យដូចជាកូន ឬ ប្រាថ្នាធ្វើជាកូន ។

**កមល** (*ផ្កាឈូក*)

(**កមល** + **យិស** + **តិ**) > **កកមលាយិសតិ** ។

(**កម** + **មល** + **យិស** + **តិ**) > **កមមលាយិសតិ** ។

(**កម** + **ល** + **ល** + **យិស** + **តិ**) > **កមលលាយិសតិ** ។

*ប្រែថា ប្រព្រឹត្តឱ្យដូចជាផ្កាឈូក, ចង់ក្លាយជាផ្កាឈូក ។*

*មានវិធីប្រកបនាមស័ព្ទឱ្យក្លាយទៅជាកិរិយាស័ព្ទមួយបែបទៀត គឺចុះ* **ណេ**, **ណយ** *បច្ច័យដែលបំបែកតាមពួក* **ចុរ** *ធាតុដូចឧទាហរណ៍ក្រោមនេះ*

(**ទុក្ខ** *សេចក្តីទុក្ខ* + **ណេ** + **តិ**) > **ទុក្ខេតិ** = *ឱ្យសេចក្តីទុក្ខ ។*

(**តុល** *ជញ្ជីង* + **ណេ** + **តិ**) > **តុលេតិ** = *ថ្លឹង ។*

(**តីរ** *ច្រាំង,ត្រើយ* + **ណេ** + **តិ**) > **តីរេតិ** = *ដល់ត្រើយ ។*

(**ឧជាន** *ឧទាន* + **ណេ** + **តិ**) > **ឧជានេតិ** = *ឧទានឡើង ។*

(**សុខ** *សេចក្តីសុខ* + **ណេ** + **តិ**) > **សុខេតិ** = *ឱ្យសេចក្តីសុខ ។*

*នៅមានវិធីប្រកបរូបមួយបែបទៀតដែលចុះ* **អ** *បច្ច័យនិងបំបែកតាមបែប* **ភូ** *ធាតុដែរដូចឧទាហរណ៍ក្រោមនេះ*

(**មគ្គ** *ផ្លូវ* + **អ** + **តិ**) > **មគ្គតិ** = *ស្វែងរក ។*

(**ឥស្សា** *ប្រណែន* + **អ** + **តិ**) > **ឥស្សតិ** = *ប្រណែន ។*

(**តាជ** *តាំងនៅ* + **អ** + **តិ**) > **តាជតិ** = *តាំងនៅមាំ ។*

# បច្ចេកបច្ច័យ (ត)

ពាក្យថា "បច្ចេកបច្ច័យ" ប្រែថា "បច្ច័យដោយឡែក" បានដល់បច្ច័យពិសេសឯទៀតដែលគប្បីដឹង ពីព្រោះបច្ច័យទាំងនេះ ខ្លះមានប្រើនៅក្នុងធម្មបទរឿយ ៗ មាន ១០ តួគឺ **អល**, **អារ**, **អាល**, **ឥ**, **ណី**, **ឯ**, **ឱ** **ឱណា**, **ប្ប**, **ឃិរ** ។ បច្ច័យទាំងនេះចាត់ចូលក្នុងពួកធាតុដូចតទៅនេះ

១. **អល**, **អារ**, **អាល** បច្ច័យ ៣ តួនេះមិនចាត់ចូលក្នុងធាតុពួកណាទេ ឧ.

(**ជុត** > **ជោត** + **អល** + **តិ**) > **ជោតលតិ** =រុងរឿង ។

(**សំ** + **តរ** + **អារ** + **តិ**) > **សន្តារតិ** =ឆ្លងដោយប្រពៃ ។

(**ឧប** + **កម** + **អាល** + **តិ**) > **ឧបក្កមាលតិ** =ឈានចូលទៅរក ។

(បច្ច័យបីតួនេះមានប្រើតិចតួចទេ)

២. **ឥ**, **ណី**, **ឯ**, **ឱ**, **ឱណា**, **ប្ប**, **ឃិរ** បច្ច័យ ៦ តួនេះចាត់ចូលក្នុងពួកធាតុដូចតទៅនេះ

២.១ **ឥ**, **ណី**, **ឯ**, **ឱ** បច្ច័យចាត់ចូលក្នុងពួក **រុធ** ធាតុដូចខាងក្រោមនេះ

(**រុធ**+ **ឥ** + **តិ**) > **រុន្ធិតិ** =បិទ, រាំង ។

(**រុធ**+ **ណី** + **តិ**) > **រុន្ធីតិ** =បិទ, រាំង ។

(**រុធ**+ **ឯ** + **តិ**) > **រុន្ធេតិ** =បិទ, រាំង ។

(**សុភ** + **ឱ** + **តិ**) > **សុម្ភោតិ** =វាយ, សម្លាប់ ។

២.២ ឧណា បច្ច័យចាត់ចូលក្នុងពួក សុ ធាតុ ឱ.

(ប + អប + ឧណា + តិ) > ធាបុណាតិ =ដល់, សម្រេច ។

២.៣ ប្ប បច្ច័យចាត់ចូលក្នុងពួក គហ ធាតុ ឱ.

(គហ > ឃេ + ប្ប + តិ) > ឃេប្បតិ =កាន់យក ។

២.៤ យិរ បច្ច័យចាត់ចូលក្នុងពួក តន ធាតុ ឱ.

(ករ + យិរ + តិ) > កយិរតិ =ធ្វើ ។

(ករ + យិរ + ឯយ្យ) > កយិរា =គប្បីធ្វើ ។

☸ ឧណា និង យិរ មានប្រើរឿយ ៗ ក្នុងធម្មបទដូចជា កយិរា, ធាបុណាតិ, ធាបុណឹសុ) ។

## សព្ទដែលប្រើកិរិយាវិសេសន៍

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| វិសុំ | មួយផ្នែក, ដោយឡែក | ទ្វិក្ខត្តុំ | ពីរដង |
| ទុក្ខំ | ដោយកម្រ | សកឹ | មួយដង, ម្តង |
| សមំ | ដោយស្មើ | សាធុកំ | ប្រពៃហើយ |
| សីឃំ | ដោយរួសរាន់ | អភិណ្ហំ | រឿយៗ, ញយៗ |
| សហសា | ដោយប្រញាប់ | សណិកំ | យឺត ៗ |
| ជជ្ឈំ | មាំមួន, ខ្លាំង | ឯកមន្តំ | ក្នុងកន្លែងមួយ |

# នាមស័ព្ទនិងគុណនាម (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ធញ្ញ បុំ. | ស្រូវ,ធញ្ញជាតិ | សោរវារ បុំ. | ថ្ងៃសៅរ៍ |
| ធនិក បុំ. | កំណប់ទ្រព្យ | ជនក បុំ. | ឪពុក, បិតា |
| គុណ បុំ. | គុណ | ជនិកា ឥ. | ម្ដាយ,ម៉ែ,មាតា |
| អាបណ បុំ. | ផ្សារ, ហាង | ជនបទ បុំ. | ប្រទេស |
| អាទិច្ចវារ បុំ. | ថ្ងៃអាទិត្យ | បរិសា ឥ. | បរិស័ទ |
| មជ្ឈ នបុំ. | ទីកណ្ដាល | ចាឋសាលា ឥ. | សាលារៀន |
| ធម្មកថិក បុំ. | អ្នកទេសនា | មហទ្ធន គុ. | មានទ្រព្យច្រើន |
| វាបិ ឥ. | អាងទឹក | មហន្ត គុ. | ធំ, ប្រសើរ |
| វិទេស បុំ. | ប្រទេសដ៏ទៃ | កល្យាណ គុ. | ល្អ |

## លំហាត់នៃមេរៀនទី ១៥

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើ បពោក្ខា ប្រែថាដូចម្ដេច ?

២. តើវិធីធ្វើអព្ភាសមានប៉ុន្មានយ៉ាង គឺដូចម្ដេចខ្លះ ?

៣. បើតួព្យញ្ជនអក្ខរាសជាពួកកា វគ្គទីមួយ តើត្រូវផ្លាស់ទៅជាវគ្គណា ?
សូមឱ្យឧទាហរណ៍ ។
៤. ប្រសិនបើតួព្យញ្ជនអក្ខរាសមិនមែនជា ក វគ្គ តើត្រូវផ្លាស់ដូចម្តេច ?
សូមឱ្យឧទាហរណ៍ ។
៥. ប្រសិនបើតួព្យញ្ជនអក្ខរាសជា ហ តើត្រូវផ្លាស់ដូចម្តេច ?
សូមឱ្យឧទាហរណ៍ ។
៦. ប្រសិនបើតួព្យញ្ជនអក្ខរាសជា រ តើត្រូវផ្លាស់ដូចម្តេច ?
សូមឱ្យឧទាហរណ៍ ។
៧. តើ អាយ និង ឡិយ បច្ច័យសម្រាប់ចុះជាមួយស័ព្ទប្រភេទណា ?
សូមឱ្យឧទាហរណ៍ ។
៨. តើបច្ចេកបច្ច័យមានប៉ុន្មានតួ និងប្រើដូចម្តេចខ្លះ ?
សូមឱ្យឧទាហរណ៍ ។

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. អាចរិយោ ឯវមាហ ។
២. អត្តំ ហិ ធាថោ សរណំ អហោច ។
៣. ឯកោ បុគ្គលោ វនេ ចង្កមតិ ។
៤. ភិក្ខុ ទ្វិសត សត្តវីសតិ សិក្ខាបទានិ រក្ខន្តិ ។
៥. កញ្ញា ឯកា តារី វាបី នេសិ ។
៦. ឥមេ បញ្ច ធារកា អភិណ្ហំ មគ្គេ គីឡន្តិ ។

៧. ឥមេសុ សិស្សេសុ សត្តមោ( ទី៧) សាធុកំ ឧគ្គណ្ហាតិ ។

៨. តាយ ជីតុយា មម បុត្តោ ទ្វិក្ខត្តុំ ឥមំ នគរំ អាគច្ឆិ ។

៩. តា តិស្សោ ឥត្ថិយោ ឥមេហិ តីហិ មគ្គេហិ តំ អដវឹ ចរិត្វា(ត្រាច់ទៅហើយ) តិស្សន្នំ កញ្ញានំ តីណិ ផលានិ អទំសុ ។

១០. ឯកិស្សំ សាលាយំ សតំ បុរិសា បញ្ញាសាយ ឥត្ថិយោ ច និសីទិស្សន្តិ ។

១១. មយំ ឥតោ(ពី...នេះ) នវហិ ទិវសេហិ បញ្ចហិ កុមារេហិ សទ្ធឹ អាបណំ គមិស្សាម ។

១២. ឯកស្មឹ វស្សេ បន តិសត បញ្ចសដ្ឋី ទិវសា ហោន្តិ ។

១៣. ឥមាយ ចាបសាលាយ បញ្ចសតានិ សិស្សា ឧគ្គណ្ហន្តិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. សូមឱ្យសត្វ.ទ. ទាំងពួង ក្នុងលោក នេះ រស់នៅ ដោយសេចក្តីសុខ។*

*២. បុគ្គល ឯណា ធ្វើ នូវកម្ម អាក្រក់ គេ រមែងបាន នូវវិបាក របស់គេ ។*

*៣. ដូច្នេះ(ហិ) បុគ្គល កុំធ្វើ នូវកម្ម អាក្រក់ឡើយ គប្បីធ្វើ នូវកម្ម ល្អ ។*

*៤. អ្នកណា មិនឃើញ នូវធម៌ គេ មិនឃើញ នូវតថាគត ទេ ។*

*៥. ស្រី ដែលមានរូបស្អាត កំពុងសើច ក្នុងផ្ទះ របស់នាង ។*

*៦. ប្រសិនបើ ធម្មកថិក នោះ ប្រាថ្នាពោល នូវធម៌ ដល់យើង.ទ., យើង.ទ. នឹងស្តាប់ នូវធម៌ របស់លោក ។*

*៧. លោកគ្រូ ដែលឈ្លាស រមែងពោល នូវឱវាទ ដល់សិស្ស.ទ.*

ដើម្បីសេចក្ដីចំរើន ។

៨. ជន.ទ. តែងឱ្យ នូវអាហារ ដល់ស្មូម ដែលស្គម ។

៩. តើហេតុអ្វី ឯង មិនទៅ សាលារៀន ?

១០. ថ្ងៃនេះ ខ្ញុំ ឃើញ នូវទោស របស់បុគ្គល ដទៃ ម្នាក់ ។

១១. ឧបាសក.ទ. កំពុងចង្ក្រម ក្នុងព្រៃឫស្សី ក្បែរភ្នំ ។

១២. ខ្លា ធំ នោះ ប្រាថ្នាដើម្បីស៊ី នូវគោ ខ្មៅ ។

រមែងបាន=(**វិជ្ជតិ**)

**(ចប់មេរៀនទី ១៥)**

# មេរៀនទី ១៦

## អធិប្បាយអំពីហេតុវាចកកិរិយាស័ព្ទ

## (Causative Verbs)

*ហេតុវាចកកិរិយាស័ព្ទមាន ២ យ៉ាងគឺ* **ហេតុកត្តុវាចក** (Causal Active voice) *និង* **ហេតុកម្មវាចក** (Causal Passive voice) *។ ខាងក្រោមនេះនឹងអធិប្បាយពីហេតុកត្តុវាចកមុន ។*

## វិធីរូបសិទ្ធិជាហេតុកត្តុវាចកកិរិយាស័ព្ទ

## (Formation of Causal Active verbs)

*វិធីប្រកបរូបកិរិយាជាហេតុកត្តុវាចក: មានវិធីធ្វើដូចគ្នានឹងកត្តុវាចក:ដែរគឺត្រូវមាន* **ធាតុ, បច្ច័យ, វិភត្តិ** *។*

(*ធាតុ* + **ហេតុប្បច្ច័យ** + *វិភត្តិ*) > *កិរិយាស័ព្ទ*

១. **ធាតុ** *ប្រើធាតុណាមួយក៏បាននៃធាតុទាំង ៨ ពួក មិនថាជាសកម្មធាតុឬជាអកម្មធាតុទេ ។*

២. **បច្ច័យ** *មិនដូចបច្ច័យក្នុងកត្តុវាចក:ទេ ។ ហេតុកត្តុវាចក:មានបច្ច័យដោយឡែក ៤ តួគឺ* **ណេ**, **ណយ**, **ណាបេ**, **ណាបយ** *ហៅថា* **ហេតុប្បច្ច័យ** *។ បច្ច័យណាមានព្យញ្ជនៈតួ* **ណ** *ជាអនុព័ន្ធ ហៅថា*

**ឈាទុព័ន្ធបច្ច័យ** ។ បច្ច័យទាំងបួនតួនេះ នៅពេលផ្សំជាមួយធាតុត្រូវលុបតួ **ឈា** ចេញឱ្យនៅសល់ត្រឹមតែ **ឯ, យ, អាបេ, អាបយ** ។ កាលបើយកទៅចុះក្នុងធាតុណាក៏ដោយ មានអំណាចឱ្យទីឃៈស្រៈដើមធាតុបានខ្លះ ឬផ្លាស់រូបទៅជាដទៃបានខ្លះ ។

៣. **វិភត្តិ** អាចប្រើវិភត្តិពួកណាក៏បានស្រេចតែសេចក្ដីក្នុងទីនោះៗ រឿងសំខាន់គឺវិភត្តិត្រូវតែស្មើគ្នាជាមួយនឹងបទប្រធានជានិច្ច ។

## វិធីបំបែក បច ធាតុជាហេតុកត្តុវាចក:

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | **ចាចេតិ, ចាចយតិ** | **ចាចេន្តិ, ចាចយន្តិ** |
| | **ចាចាបេតិ, ចាចាបយតិ** | **ចាចាបេន្តិ, ចាចាបយន្តិ** |
| ម.បុ. | **ចាចេសិ, ចាចយសិ** | **ចាចេថ, ចាចយថ** |
| | **ចាចាបេសិ, ចាចាបយសិ** | **ចាចាបេថ, ចាចាបយថ** |
| ឧ.បុ. | **ចាចេមិ, ចាចយាមិ** | **ចាចេម, ចាចយាម** |
| | **ចាចាបេមិ, ចាចបយាមិ** | **ចាចាបេម, ចាចាបយាម** |

ចូរចំណាំការប្រែកិរិយាហេតុវាចក:ថា វេលាប្រែត្រូវថែមពាក្យថា "ឱ្យ" ខាងដើមកិរិយាស័ព្ទដូចជា "ឱ្យចម្អិន", "ឱ្យលួច", "ឱ្យធ្វើ", "ឱ្យទៅ" ជាដើម ។ ចំពោះធាតុពួកទី ៨ គឺ **ចុរ** ធាតុ បើប្រកបជាហេតុកត្តុវាចក:

ជាមួយតែបច្ច័យ ២ តួទេគឺ **ណាបេ** និង **ណាបយ** ប៉ុណ្ណោះ ។ រីឯ **ណេ**, **ណយ** មិនប្រើទេ ដើម្បីកុំឱ្យច្រឡំគ្នាជាមួយនឹងរូបដែលជាកត្តុ-វាចកៈ ដូចឧទាហរណ៍ខាងក្រោមនេះ

## ហេតុកត្តុវាចកៈនៃធាតុពួកទី ៨

(**ចុរ** + **ណាបេ** + **តិ**) > **ចោរាបេតិ** =ឱ្យលួច ។

(**ចុរ** + **ណាបយ** + **តិ**) > **ចោរាបយតិ** =ឱ្យលួច ។

ដើម្បីឱ្យងាយយល់ការប្រកបរូបកិរិយាជាហេតុកត្តុវាចកៈជាមួយវិភត្តិដទៃទៀត សូមមើលវិធីបំបែក **ការ** ធាតុជាមួយនឹងវិភត្តិនានាខាងបរស្សបទដូចតទៅនេះ

## ៣.១ បញ្ចមីវិភត្តិ

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | **ការេតុ**, **ការាបេតុ** | **ការេន្តុ**, **ការាបេន្តុ** |
| *ម.បុ.* | **ការេហិ**, **ការាបេហិ** | **ការេថ**, **ការាបេថ** |
| *ឧ.បុ.* | **ការេមិ**, **ការាបេមិ** | **ការេម**, **ការាបេម** |

*ប្រែថា "ចូរឱ្យធ្វើ"*

## ៣.២ សត្តមីវិភត្តិ

| បុរិស: | ឯកវចនៈ |
|---|---|
| ប.បុ. | ការេយ្យ, ការាបេយ្យ |
| ម.បុ. | ការេយ្យាសិ, ការាបេយ្យាសិ |
| ឧ.បុ. | ការេយ្យាមិ, ការាបេយ្យាមិ |
| | ពហុវចនៈ |
| ប.បុ. | ការេយ្យុំ, ការាបេយ្យុំ |
| ម.បុ. | ការេយ្យាថ, ការាបេយ្យាថ |
| ឧ.បុ. | ការេយ្យាម, ការាបេយ្យាម |

*ប្រែថា "គប្បីឱ្យធ្វើ"*

## ៣.៣ អជ្ជតនីវិភត្តិ

| បុរិស: | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប.បុ. | ការាបេសិ | ការាបេសុំ |
| ម.បុ. | ការាបេសិ* | ការយិត្ថ |
| ឧ.បុ. | ការាបេសឹ | ការយិម្ហា |

*ប្រែថា "ឱ្យធ្វើហើយ"*

* (*បករណ៍ខ្លះប្រាប់ថាមិននិយមប្រើ*)

*កាលបើចុះ* ណោ *ចាំបាច់ត្រូវចុះ* ស *អាគមដូចអជ្ជតនីវិភត្តិក្នុងកត្តុវាចកៈនៃពួក* ចុរ *ធាតុដែរ ។ ប៉ុន្តែចំពោះ* ណាយ, ណាបយ *បច្ច័យ គឺអនុវត្តតាមបែបអជ្ជតនីធម្មតា ។ រីឯ* អ *អាគមក៏អាចចុះបានដែរដូចជា* អការាបេសិ *ជាដើម ។*

## ៣.៨ ភវិស្សន្តីវិភត្តិ

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | ការាបេស្សតិ | ការាបេស្សន្តិ |
| *ម.បុ.* | ការាបេស្សសិ | ការាបេស្សថ |
| *ឧ.បុ.* | ការាបេស្សាមិ | ការាបេស្សាម |

*ប្រែថា "នឹងឱ្យធ្វើ"*

## ៣.៩ កាលាតិបត្តិវិភត្តិ

| *បុរិសៈ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.បុ.* | អការាបេស្សា | អការាបេស្សំសុ |
| *ម.បុ.* | អការាបេស្ស | អការាបេស្សថ |
| *ឧ.បុ.* | អការាបេស្សំ | អការាបេស្សាម្ហា |

*ប្រែថា "នឹងបានឱ្យធ្វើហើយ"*

សូមសង្កេតមើលក្នុងរូបជាកវិស្សន្តិនិងកាលាតិបត្តិវិកត្តិមិនមានចុះ ឥ អាគមដូចក្នុងកត្តុវាចកៈទេ ។ ធាតុដទៃ ៗ ទៀតគប្បីយកតាមវិធីនេះដូចគ្នា ។

## វិធីផ្លាស់រូបរបស់ធាតុក្នុងហេតុកត្តុវាចកៈ

១. បើស្រៈដើមធាតុជាស្រៈ អ ត្រូវទីឃៈជា អា ដូចជា (ការ + ណោ + តិ) > ការេតិ, (មរ + ណោ + តិ) > មារេតិ, (បត + ណោ + តិ) > បាតេតិ, (គហ + ណោ + តិ) > គាហេតិ ជាដើម ។

២. បើស្រៈដើមធាតុជាស្រៈ ឥ ព្រឹទ្ធិជា ឯ ដូចជា (ឆិទ + ណោ + តិ) > ឆេទេតិ, (ប + វិស + ណោ + តិ) > បវេសេតិ ជាដើម ។

៣. បើស្រៈដើមធាតុជាស្រៈ ឧ ព្រឹទ្ធិជា ឱ ដូចជា (កុជ + ណោ + តិ) > កោជេតិ, (រុទ + ណោ + តិ) > រោទេតិ, (យុជ + ណោ + តិ) > យោជេតិ ។

៤. បើស្រៈដើមធាតុជាស្រៈ ឧ, ឩ អាចព្រឹទ្ធិជា ឱ > អវ បន្តទៀតបានដូចជា (សុ > សោ > សវ + ណោ + តិ) > សាវេតិ, (ហុ > ហោ > ហវ + ណោ + តិ) > ហាវេតិ, (ភូ > ភវ + ណោ + តិ) > ភាវេតិ ។ល។

៥. ប្រសិនបើទីបំផុតធាតុជាព្យញ្ជនៈសំយោគ ពុំចាំបាច់ធ្វើអ្វីទេ ដូច (វឌ្ឍ + ណោ + តិ) > វឌ្ឍេតិ, (ប + វត្ត + ណោ + តិ) > បវត្តេតិ,

( លគ្គ + ណេ + តិ ) > លគ្គេតិ="ឱ្យជាប់, ស្អិត" ជាដើម ។

៦. ធាតុខ្លះជាស្រៈ ឦ អាចផ្លាស់ជា អាយ បានដូចជា (ភី > ភាយ + ណេ + តិ) > ភាយេតិ, (ធី > ធាយ + ណេ + តិ) > ធាយេតិ, ( សី > សាយ + ណេ + តិ ) > សាយេតិ ជាដើម ។

៧. ធាតុទោលជាស្រៈ អា និយមចុះ ណាបេ បច្ច័យដោយរស្សៈស្រៈ អា នៃធាតុជា អ ដូចជា (បិ + ធា + ណាបេ + តិ ) > បិធាបេតិ, បិទធាបេតិ, បិទហាបេតិ, ( យា + ណាបេ + តិ ) > យាបេតិ, (ហា + ណាបេ + តិ ) > ហាបេតិ, ( ធា + ណាបេ + តិ ) > ធាបេតិ ។ល។

ប៉ុន្តែ ចា ធាតុ ( ចា + ណេ + តិ ) > ចាយេតិ ( ផ្លាស់ស្រៈ អា នៃធាតុជា អាយ ) និង ឋា ធាតុ ( ឋា + ណាបេ + តិ ) > ឋបេតិ ។

៨. ធាតុខ្លះមានស្រៈដើមធាតុជាស្រៈ អ ដែរតែមិនបាច់ទីឃៈបានដូចជា ( គម + ណេ + តិ ) > គមេតិ, ( ទម + ណេ + តិ ) > ទមេតិ, ( ជន + ណេ + តិ ) > ជនេតិ, ( ធម + ណេ + តិ ) > ធមេតិ, ធាមេតិ ជាដើម ។

៩. បើ ហន ធាតុតែងផ្លាស់ជា ឃាត ( ឃាត + ណេ + តិ ) > ឃាតេតិ និង រុហ ធាតុតែងផ្លាស់ជា រោ ( រោ + ណាបេ + តិ ) > > រោបេតិ ។

ចំពោះធាតុពួកទី ២, ៣, ៤, ៥, ៦, ៧ អាចចុះបច្ច័យក្នុងកត្តុវាចកៈមុនសិនទើបចុះហេតុប្បច្ច័យក៏បាន តែនិយមប្រើ ណាបេ បច្ច័យដូចជា

**( ធិឌ + -ំ + ណាបេ + តិ ) > ធិដ្ឋាបេតិ, ( សិវ + យ + ណាបេ + តិ ) > សិព្វាបេតិ, ( ជា + ជា + ណាបេ + តិ ) > ជាជាបេតិ, ( គហ + ណ្ហា + ណាបេ + តិ ) > គណ្ហាបេតិ, ( សុ + ណា + ណាបេ + តិ ) > សុណាបេតិ, ( កិត + ឆ + ណាបេ + តិ ) > តិកិច្ឆាបេតិ ។ល។**

*ឧទាហរណ៍ទាំងឡាយខាងលើមិនមាន* **ណយ, ណាបយ** *បច្ច័យទេ តែសង្ឃឹមថាអ្នកសិក្សាគង់ជ្រាបមិនខាន ពីព្រោះគ្រាន់តែប្ដូរបច្ច័យទៅជាការស្រេច សូមមើលត្រង់* **បច** *ធាតុខាងលើ ។ ដូច្នេះឃើញថា កិរិយាហេតុកត្តុវាចកៈអាចមានរូបច្រើនយ៉ាង សូម្បីតែកិរិយាកិតកៈ (មានអធិប្បាយនៅខាងមុខ) ក៏មានរូបជាហេតុកត្តុវាចកៈដែរ ។*

## វិធីប្រែប្រយោគហេតុកត្តុវាចកៈ

### បែបទី ១

*ប្រយោគហេតុកត្តុវាចកៈ បានដល់ ប្រយោគដែលមានបទប្រធាន (តួកត្តា)ជាអ្នកប្រើគេដទៃឱ្យធ្វើអ្វីមួយនិងមានកិរិយាស័ព្ទដែលចុះបច្ច័យបួនតួ(ហេតុប្បច្ច័យ)ជាគ្រឿងសម្គាល់ដូចបានពោលរួចហើយខាងលើ ។*

*ពាក្យថា ហេតុវាចកៈ ប្រែថា "ពោលដល់អ្នកធ្វើជាហេតុ" ។ នៅក្នុងប្រយោគហេតុកត្តុវាចកៈមានស័ព្ទសំខាន់ខ្វះមិនបាន ៤ ប្រភេទគឺ*

១. បទប្រធាន.........................................................ប្រែទី ១ ។

២. បទការីតកម្ម.....................................................ប្រែទី ២ ។

៣. បទកិរិយាស័ព្ទ *ជាអាខ្យាតកិរិយាហេតុកត្តុវាចកៈ*.......ប្រែទី ៣ ។

៤. បទអវុត្តកម្ម.....................................................ប្រែទី ៤ ។

១. **បទប្រធាន** ក្នុងទីនេះបានដល់ **អ្នកប្រើគេឱ្យធ្វើនូវកិច្ច** មានរូបជា **បឋមាវិភត្តិ** ជាឯកវចនៈឬពហុវចនៈក៏បាន ។

២. **បទការីតកម្ម** បានដល់ **អ្នកទទួលធ្វើនូវអំពើ** គឺអ្នកដែលគេប្រើឱ្យសម្រេចនូវអំពើ មានរូបជាទុតិយាវិភត្តិខ្លះ, ជាតតិយាវិភត្តិខ្លះ ប្រែថា "ញុំាង..." ជានិច្ច ។

៣. **បទកិរិយាស័ព្ទ** មានរូបជា **ហេតុកត្តុវាចកៈ** ដូចបានពោលហើយខាងលើ ត្រូវប្រែថា "ឱ្យ..." ។

៤. **បទអវុត្តកម្ម** បានដល់ **បទកម្មដែលរងអំពើ** ត្រូវមានរូបជា **ទុតិយាវិភត្តិ** ប្រែថា "នូវ..." ។

## ប្រយោគគំរូ

១. ភិក្ខុ$_{១}$ មនុស្សេ$_{២}$ ធម្មំ$_{៤}$ សុណាបេតិ$_{៣}$។

*ភិក្ខុ$_{១}$ ញុំាងមនុស្ស.ទ.$_{២}$ ឱ្យស្តាប់$_{៣}$ នូវធម៌$_{៤}$ ។*

២. មាតុលានិ$_{១}$ ការិនា$_{២}$ គេហំ$_{៤}$ ការាបេតិ$_{៣}$។

*ម្តាយមីង$_{១}$ ញុំាងជាង$_{២}$ ឱ្យធ្វើ$_{៣}$ នូវផ្ទះ$_{៤}$ ។*

ប្រសិនបើមានបទដទៃចូលមកអធិប្បាយបទនីមួយ ៗ ក្នុងឧទាហរណ៍ខាងលើនេះ ត្រូវថែមវិធីប្រែទៀតគឺ

## វិធីប្រែប្រយោគហេតុកត្តុវាចក:
## បែបទី ២

១. បទប្រធាន..........ប្រែទី ១ ។
២. បទវិសេសនៃបទប្រធាន..........ប្រែទី ២ ។
៣. បទការីតកម្ម..........ប្រែទី ៣ ។
៤. បទវិសេសនៃបទការីតកម្ម..........ប្រែទី ៤ ។
៥. បទកិរិយាស័ព្ទ..........ប្រែទី ៥ ។
៦. បទអវុត្តកម្ម..........ប្រែទី ៦ ។
៧. បទវិសេសនៃបទអវុត្តកម្ម..........ប្រែទី ៧ ។

## ប្រយោគគំរូ

១. អភិរូបា$_{២}$ កញ្ញា$_{១}$ ឯកា$_{៤}$ ទាសី$_{៣}$ ភត្តំ$_{៦}$ បាចាបេតិ$_{៥}$។

*កញ្ញា ដែលមានរូបល្អ ញុាំងទាសី ម្នាក់ ឱ្យចម្អិន នូវបាយ ។*

២. ឯស$_{២}$ សេដ្ឋី$_{១}$ តស្ស$_{៤}$ បុត្តេន$_{៣}$ រត្តានិ$_{៧}$ បុប្ផានិ$_{៦}$ ឱចិនាបេតិ$_{៥}$។

*សេដ្ឋី នុ៎ះ ញុាំងបុត្រ របស់គាត់ ឱ្យបេះ នូវផ្កាឈើ.ទ. ក្រហម ។*

*តាមការសង្កេតមើលក្នុងឧទាហរណ៍ខាងលើនេះឃើញថាកិរិយាស័ព្ទប្រកបរូបពីធាតុដែលជាសកម្មធាតុតែម្យ៉ាង ។ កិរិយាស័ព្ទជាហេតុកត្តុវាចកៈដែលសម្រេចរូបពីសកម្មធាតុដូច្នេះ ត្រូវមានកម្ម ២ គឺ* **បធការីតកម្ម** *និង* **បធអវុត្តកម្ម** *។*

*ចំពោះធាតុដែលជាអកម្មធាតុ ក៏អាចប្រើជាហេតុកត្តុវាចកៈបានដែរ ។ វេលាប្រើជាហេតុវាចកៈ ធាតុនោះ ៗ ក៏ក្លាយជាសកម្មធាតុវិញ ពីព្រោះត្រូវប្រកបដោយកម្មមួយគឺ* **បធការីតកម្ម** *ដូចឧទាហរណ៍ខាងក្រោមនេះ*

១. **ទារកោ សយតិ** (*កត្តុវាចកៈ*) ។
*ទារក កំពុងដេក ។*

២. **មាតា ទារកំ សយាបេតិ** (*ហេតុកត្តុវាចកៈ*) ។
*ម្តាយ ញ៉ាំងទារក ឱ្យដេក ។*

៣. **រុក្ខោ បតតិ** (*កត្តុវាចកៈ*) ។
*ដើមឈើ ដួល ។*

៤. **កសកោ រុក្ខំ បាតេតិ** (*ហេតុកត្តុវាចកៈ*) ។
*កសិករ ញ៉ាំងដើមឈើ ឱ្យដួល (រំលំ) ។*

៥. **ទាសោ សុនខំ ធាវេតិ** (*ហេតុកត្តុវាចកៈ*) ។
*ខ្ញុំបំរើ ញ៉ាំងឆ្កែ ឱ្យរត់ (ដេញ) ។*

*រីឯធាតុខ្លះទៀតដែលត្រូវការបទអវុត្តកម្មពីរ ហៅថា* **ទ្វិកម្មធាតុ**

នោះ ចាំបាច់ត្រូវមានកម្ម ៣ គឺ **បទការិតកម្ម**, **បទអវុត្តកម្ម** (បធានកម្ម) និង **បទសម្បាបុណីយកម្ម**(អបធានកម្ម)មានរូបជាទុតិយាវិភត្តិ សម្រាប់ប្រាប់ទីដៅ ។ សូមមើលឧទាហរណ៍ខាងក្រោមនេះ

**សេដ្ឋី ទាសំ នគរំ អស្សំ នាយេតិ ។** ឬ

**សេដ្ឋី ទាសេន នគរំ អស្សំ នាយេតិ ។**

សេដ្ឋី ញ៉ាំងខ្ញុំបំរើ ឱ្យនាំយក នូវសេះ (ទៅ)កាន់នគរ(ក្រុង) ។

ក្នុងឧទាហរណ៍ខាងលើនេះ បទថា **ទាសំ** និង **ទាសេន** ជាបទ **ការិតកម្ម**, បទថា **អស្សំ** ជាបទ**អវុត្តកម្ម**(បធានកម្ម), បទថា **នគរំ** ជាបទ **សម្បាបុណីយកម្ម** (អបធានកម្ម) ។

❁មានហេតុកត្តុកិរិយានេះមួយបែបទៀតដែលចុះហេតុប្បច្ច័យផ្ទួន (**ណាបេ** + **ណាបេ** ឬ **ណាបយ**) > **ណាបាបេ**, **ណាបាបយ** ។ សូមមើល **បច** ធាតុ (**បច** + **ណាបេ** + **ណាបេ** ឬ **ណាបយ** + **តិ**) > **បាចាបាបេតិ**, **បាចាបាបយតិ** ។ ខាងក្រោមនេះជាប្រយោគឧ.

**សេដ្ឋី បុរិសំ ឬ បុរិសេន ទាសំ ឱទនំ បាចាបាបេតិ ។** ប្រែថា សេដ្ឋី ឱ្យបុរស ញ៉ាំងខ្ញុំបំរើ ឱ្យចម្អិន នូវបាយ ។

## វិធីផ្លាស់ប្រយោគពីកត្តុវាចកៈទៅជាហេតុកត្តុវាចកៈ

១. ត្រូវផ្លាស់កិរិយាស័ព្ទពីកត្តុវាចកៈទៅជាហេតុកត្តុវាចកៈ ។

២. ត្រូវផ្លាស់បទប្រធានពីបឋមាវិភត្តិទៅជាទុតិយាវិភត្តិ ឬតតិយា-

*វិភត្តិដូចឧទាហរណ៍ខាងក្រោមនេះ*

**សូទោ ឱទនំ បចតិ ។** *ទៅជា*

**សាមិកោ សូទំ/សូទេន ឱទនំ ចាចេតិ ។**

## វិធីរូបសិទ្ធិហេតុកម្មវាចកកិរិយាស័ព្ទ

(Formation of Causal Passive verbs)

*វិធីប្រកបរូបកិរិយាជាហេតុកម្មវាចក:មានវិធីប្លែកពីហេតុកត្តុវាចក: បន្តិច គឺត្រូវប្រើបច្ច័យរបស់ហេតុកត្តុវាចក:និង* **យ** *បច្ច័យក្នុងកម្មវាចក: ព្រមទាំង* **ឥ** *អាគមផង ។*

(*ធាតុ* + *ហេតុប្បច្ច័យ* + **ឥ** + **យ** + *វិភត្តិ*) > *កិរិយាស័ព្ទ*

*សូមមើលគំរូ* **បច** *ធាតុដែលបំបែកជាមួយវត្តមានាវិភត្តិខាងក្រោម នេះ*

## វិធីបំបែក បច ជាហេតុកម្មវាចក:

| *បុរិស:* | *ឯកវចន:* | *ពហុវចន:* |
|---|---|---|
| *ប.បុ.* | ចាចាបិយតេ | ចាចាបិយន្តេ |
| *ម.បុ.* | ចាចាបិយសេ | ចាចាបិយវ្ហេ |
| *ឧ.បុ.* | ចាចាបិយេ | ចាចាបិយម្ហេ |

*ចំពោះវិភត្តិដទៃទៀតក៏មានដំណើរដូចវត្តមានាវិភត្តិដែរ គឺគ្រាន់តែ*

ផ្លាស់ប្តូរវិកត្តិចេញប៉ុណ្ណោះ ។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះទៀត មានរូបជាបឋមបុរិសឯកវចនៈ ។

**តិដ្ឋាបិយតេ** (ឋា ធាតុ) **កុញ្ជាបិយតេ** (កុជ ធាតុ)
**វជ្ជាបិយតេ** (វជ ធាតុ) **សុណាបិយតេ** (សុ ធាតុ)
**ជាជាបិយតេ** (ញា ធាតុ) **គណ្ហាបិយតេ** (គហ ធាតុ)
**សក្កាបិយតេ** (សក ធាតុ) **ចិន្តាបិយតេ** (ចិន្ត ធាតុ)

ប្រយោគកម្មវាចកៈជាប្រយោគដែលមានបទប្រធានជាវត្ថុឬកិច្ចអ្វីមួយដែលត្រូវបទ **ហេតុកត្តា** ញុំាងបទ **អនភិហិតកត្តា** ឱ្យធ្វើនូវវត្ថុឬសម្រេចនូវកិច្ចនោះ ៗ ។ ប្រយោគដូច្នេះមានឈ្មោះថា **ហេតុកម្ម-វាចក** ប្រែថា "ពោលដល់វត្ថុឬកិច្ចត្រូវគេបង្គាប់ឱ្យធ្វើ" ។

នៅក្នុងប្រយោគហេតុកម្មវាចកៈមានសព្ទសំខាន់ ៗ ខ្វះមិនបាន ៤ យ៉ាងគឺ បទប្រធាន, បទអនភិហិតកត្តា, បទការីតកម្ម, បទកិរិយាសព្ទ ។

## វិធីប្រែប្រយោគហេតុកម្មវាចកៈ

## បែបទី ១

១. **បទប្រធាន**.......................................................ប្រែទី ១ ។
២. **បទអនភិហិតកត្តា**.............................................ប្រែទី ២ ។
៣. **បទការីតកម្ម**....................................................ប្រែទី ៣ ។
៤. **បទកិរិយាសព្ទ** ជាអាខ្យាតកិរិយាហេតុកម្មវាចកៈ ....ប្រែទី ៤ ។

## កំណត់សម្គាល់

១. **បទប្រធាន** បានដល់ វត្ថុឬកិច្ចដែលត្រូវធ្វើឬឱ្យសម្រេច មានរូបជាបឋមាវិភត្តិជាឯកវចនៈឬពហុវចនៈក៏បាន ។

២. **បទអនភិហិតកត្តា** បានដល់ អ្នកត្រូវគេបង្គាប់ឱ្យធ្វើនូវអំពើ មានរូបជាតតិយាវិភត្តិជាឯកវចនៈឬពហុវចនៈក៏បាន មានពាក្យប្រែថា "គឺ... ឬ ដែល..." ។

៣. **បទការិតកម្ម** បានដល់ អ្នកទទួលការបង្គាប់ឱ្យធ្វើនូវអំពើឬកិច្ច មានរូបជាទុតិយាវិភត្តិខ្លះ ជាតតិយាវិភត្តិខ្លះ ជាឯកវចនៈឬពហុវចនៈក៏បាន មានពាក្យប្រែប្រកបថា "ញុំាង......." ជានិច្ច ។

៤. **បទកិរិយាស័ព្ទ** មានរូបជា **ហេតុកម្មវាចកៈ** និងត្រូវប្រែថា "ឱ្យ..." ពីខាងដើមកិរិយាស័ព្ទនោះ ៗ ។

## ប្រយោគគំរូ

**១. តិណាជិ₁ ទាសេន₂ គោណំ₃ កុញ្ជាបិយតេ₄។**

ស្មៅ.ទ.₁ គឺខ្ញុំបំរើ₂ ញុំាងគោ₃ ឱ្យស៊ី₄ ។

**២. សាមិកេន₂ សូទេន₃ ឱទនោ₁ ចាចាបិយតេ₄។**

បាយ₁ គឺម្ចាស់₂ ញុំាងអ្នកគ្រួ₃ ឱ្យចម្អិន₄ ។

ប្រសិនបើមានបទដទៃចូលមកអធិប្បាយបទនីមួយ ៗ ក្នុងឧទា-

*ហរណ៍ខាងលើនេះ ត្រូវថែមវិធីប្រែទៀត ។*

## វិធីប្រែប្រយោគហេតុកម្មវាចក:
## បែបទី ២

១. **បទប្រធាន**................................................................*ប្រែទី ១ ។*

២. **បទវិសេសន***នៃបទប្រធាន*........................................*ប្រែទី ២ ។*

៣. **បទអនភិហិតកត្តា**..................................................*ប្រែទី ៣ ។*

៤. **បទវិសេសន***នៃបទអនភិហិតកត្តា*...............................*ប្រែទី ៤ ។*

៥ .**បទការិតកម្ម**.........................................................*ប្រែទី ៥ ។*

៦. **បទវិសេសន***នៃបទការិតកម្ម*.......................................*ប្រែទី ៦ ។*

៧. **បទកិរិយាស័ព្ទ** *មានរូបជាហេតុកម្មវាចក:* .................*ប្រែទី ៧ ។*

## ប្រយោគគំរូ

១. **ពាលេន$_{៤}$ កុមារេន$_{៣}$ តស្ស$_{៦}$ មិត្តំ$_{៥}$ សេដ្ឋិនោ$_{២}$ វាជេ$_{១}$ ហឹសាបេតេ$_{៧}$។** *វីស្វា របស់សេដ្ឋី គឺកុមារ ល្ងង់ ញ៉ាំងមិត្ត របស់វា ឱ្យបៀតបៀន ។*

២. **ឆេកោន$_{៤}$ អាចរិយេន$_{៣}$ សិស្សំ$_{៥}$ សុន្ទរំ$_{២}$ សិប្បំ$_{១}$ សិក្ខាបិយតេ$_{៧}$។** *វីសិល្បៈ ដែលល្អ គឺអាចារ្យ(គ្រូ) ដែលឈ្លាស ញ៉ាំងសិស្ស ឱ្យសិក្សា ។*

# នាមនាមនិងគុណនាម (ត)

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| ចីវរ *នបុំ.* | *សំពត់ចីវរ* | ឧបជ្ឈាយ *បុំ.* | *ឧបជ្ឈាយ៍* |
| ទាយក *បុំ.* | *អ្នកឱ្យ,ទាយក* | បាបការី *បុំ.* | *អ្នកធ្វើអំពើបាប* |
| ទាយិកា *ឥ.* | *អ្នកឱ្យ,ទាយិកា* | ទារុ *នបុំ.* | *ឧស, ឈើ* |
| យាចក *បុំ.* | *អ្នកសុំ,យាចក* | តថាគត *បុំ.* | *ព្រះតថាគត* |
| វិជ្ជា *ឥ.* | *ចំណេះ, វិជ្ជា* | សារថី *បុំ.* | *អ្នកបររទេះ* |
| អយ្យិក *បុំ.* | *ជីតា, តា* | សប្បុរិស *បុំ.* | *សប្បុរស* |
| អយ្យិកា *ឥ.* | *ជីដូន, យាយ* | ភវ *បុំ.* | *ភព* |
| ចេតិយ *នបុំ.* | *ចេតីយ៍* | ទូត *បុំ.* | *ទូត* |
| ឧយ្យាន *នបុំ.* | *សួន, ឧទ្យាន* | យុវ *បុំ.* | *ប្រុសកម្លោះ* |
| គណ *បុំ.* | *ក្រុម, ពួក* | អភិរូប *គុ.* | *មានរូបស្អាត* |
| តុរគ *បុំ.* | *សេះ* | ខរ *គុ.* | *ខ្លាំង,រឹង,ហ៊ាន* |
| ទារក *បុំ.* | *ក្មេង* | កុសីត *គុ.* | *ខ្ជិល, ប្រអូស* |
| ពក *បុំ* | *សត្វកុក* | អរោគ *គុ.* | *មិនមានរោគ* |

## លំហាត់នៃមេរៀនទី ១៦

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើកិរិយាស័ព្ទហេតុវាចកៈមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?
២. តើបច្ច័យក្នុងហេតុកត្តុវាចកៈមានប៉ុន្មានតួ គឺបច្ច័យអ្វីខ្លះ ?
៣. តើបច្ច័យដែលមានតួ ណា វេលាចុះផ្សំជាមួយធាតុត្រូវធ្វើដូចម្ដេច ?
៤. ចូរបំបែក ករ ធាតុជាមួយវត្តមានាវិភត្តិក្នុងរូបជាហេតុកត្តុវាចកៈ ទាំងពីរវចនៈ ។
៥. ធាតុក្នុង ចុរ ធាតុតើគប្បីប្រើបច្ច័យណាខ្លះ ព្រោះហេតុអ្វី ?
៦. តើប្រយោគហេតុកត្តុវាចកៈមានស័ព្ទសំខាន់ ៗ ខ្លះមិនបាន ជាស័ព្ទ អ្វីខ្លះ ?
៧. តើបទប្រធានក្នុងប្រយោគហេតុកត្តុវាចកៈបានដល់អ្វី ?
៨. តើបទការិតកម្មបានដល់អ្វី មានរូបជាវិភត្តិណាខ្លះ ?
៩. តើបទអវុត្តកម្មបានដល់អ្វី មានរូបជាវិភត្តិណា ?
១០. តើវិធីប្រកបរូបកិរិយាស័ព្ទជាហេតុកម្មវាចកៈធ្វើដូចម្ដេចខ្លះ ?
១១. តើប្រយោគហេតុកម្មវាចកៈមានស័ព្ទសំខាន់ ៗ ខ្លះមិនបានជាស័ព្ទ អ្វីខ្លះ ?

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. សេដ្ឋី វឌ្ឍកឹ គេហំ ការាបេស្សតិ ។
២. ចាបការិកា ជាសេហិ ពហូ មិគា មារាបិយន្តេ ។
៣. ជនិកា បុត្តំ ចោគ្គារណិយំ ឧហាបយិស្សតិ ។

៤. អម្ហាកំ ជនកោ ភិក្ខូ ភត្តំ ភោជាបេសុំ ។

៥. ភត្តំ វនិតាយ ទាសី បាចាបិយឹសុ ។

៦. គហបតិនា បុរិសេហិ ទារូនិ គណ្ហាបិយន្តិ ។

៧. គរុនា ធម្មោ សិស្សេ ឧគ្គណ្ហាបិយតេ ។

៨. អធិបតិ បុរិសេហិ រុក្ខេ ឆិន្ទាបេស្សតិ ។

៩. អហំ កញ្ញាហិ ភណ្ឌានិ អាហរាបេស្សាមិ។

១០. អម្ហាកំ ទាសេហិ គោណោ ឯតំ ខេត្តំ កាសាបិយតេ ។

១១. ទាយកោ បុគ្គលំ វិហារេ សង្ឃស្ស ទានំ ទាបេស្សតិ ។

១២. ឯកោ ភិក្ខុ ឧបាសកោ ច ឧបាសិកាយោ ច តថាគតស្ស ធម្មំ សុណាបេតិ ។

១៣. វនិតា សហាយេន រុក្ខស្ស សាខាយោ តេហិ អាកឌ្ឍាបិយន្តេ ។

១៤. អាចរិយោ កុមារិយោ កុមារេ ច ធម្មំ ឧគ្គណ្ហាបេសិ ។

១៥. ទារិកា សុនខំ បោក្ខរណឹ ឱតរាបេសិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. លោកសេដ្ឋី ញុាំងខ្ញុំប្រុស ឱ្យ-ឱ្យ នូវអាហារ ដល់ស្មូម ស្គម ម្នាក់ ។*

*២. អ្នកធ្វើអំពើបាប ញុាំងក្មេងប្រុស ម្នាក់ ឱ្យសម្លាប់ បក្សី.ទ. បីក្បាល ។*

*៣. ផ្ទះ នេះ គឺគហបតី ញុាំងជាងឈើ ឱ្យធ្វើហើយ ។*

*៤. រទេះ ថ្មី មួយ នោះ គឺសេដ្ឋី ញុាំងអ្នកបររទេះ ឱ្យយកទៅ កាន់ក្រុង ។*

៥. លោកគ្រូ ញុាំងសិស្ស.ទ. ឱ្យរៀន ភាសាបាលី ក្នុងសាលារៀន ។
៦. គេ.ទ. ញុាំងគោ.ទ. ២០ក្បាល នឹងឱ្យភ្ជួរ នូវស្រែ.ទ. នោះ ។
៧. គេ ញុាំងក្មេងប្រុស ផង ក្មេងស្រី ផង មិនគប្បីឱ្យលេង ក្នុងទឹក ជ្រៅ ទេ ។
៨. កសិករ មួយរូប ញុាំងកសិករ ពីរនាក់ ដទៃទៀត ឱ្យកាត់ ដើមឈើ ក្នុងសួន ជិតផ្ទះ របស់គាត់ ។
៩. កញ្ញា ឯណា មានរូបស្អាត កញ្ញា នោះ ញុាំងទាសី ឱ្យបេះ ផ្កា.ទ. ក្រហម ប្រាំទង ។
១០. អាហារ.ទ. ណា សប្បុរស នឹងថ្វាយ ដល់ភិក្ខុ.ទ. គេ មិនគប្បី បរិភោគឡើយ ។

**(ចប់មេរៀនទី ១៦)**

# មេរៀនទី ១៧

## អធិប្បាយអំពីបូរណសំខ្យា និង
## វិធីសង្កេតកាលនៃអាខ្យាតកិរិយា

*ពាក្យថា* **បូរណ** *ប្រែថា "ដែលពេញគ្រប់គ្រាន់" ផ្សំជាមួយនឹង* **សំខ្យា** *ប្រែថា "ការរាប់" រួមគ្នាជាបទសមាសទៅជា* **បូរណសំខ្យា** *ប្រែថា "ការរាប់ចំនួនដែលពេញគ្រប់គ្រាន់ ឬ ជាជាន់ថ្នាក់" ដូចជា ទី ១, ទី ២, ទី ៣ ជាដើម ។* **បូរណសំខ្យា** *ប្រកបរូបឡើងពីបកតិសំខ្យាដូចដែលបានពោលរួចហើយដោយការចុះបច្ច័យ ៥ តួគឺ* **តិយ, ថ, ឋ, ម, ឦ** *(បូរណតទ្ធិតបច្ច័យដែលនឹងអធិប្បាយនៅខាងមុខ) ។ បច្ច័យប្រាំតួនេះសម្រាប់ចុះក្នុងបកតិសំខ្យាដើម្បីធ្វើសំខ្យានោះ ៗ ឱ្យទៅជាបូរណសំខ្យា កាលបើចុះបច្ច័យទាំងនេះហើយត្រូវប្រែថា "ជាគម្រប់ ឬ ទី..." ឧ.* **បឋម** *ប្រែថា ទី ១,* **ទុតិយ** *ប្រែថា "ទី ២ ឬ ជាគម្រប់២" ជាដើម ។*

## វិធីចុះបច្ច័យក្នុងទីបំផុតនៃបកតិសំខ្យា

*១.* **តិយ** *បច្ច័យសម្រាប់ចុះក្នុងបកតិសំខ្យាពីរស័ព្ទគឺ* **ទ្វិ**=២, **តិ**=៣ *ដូចខាងក្រោមនេះ*

( **ទ្វិ** > **ទុ** + **តិយ** ) > **ទុតិយ** *ប្រែថា ទី ២ (ផ្លាស់* **ទ្វិ** *ទៅជា* **ទុ**) ។

( **តិ** > **ត** + **តិយ** ) > **តតិយ** *ប្រែថា ទី ៣ (ផ្លាស់* **តិ** *ទៅជា* **ត**) ។

២. ថ បច្ច័យសបម្រាប់ចុះក្នុងបកតិសំខ្យាមួយស័ព្ទគត់គឺ **ចតុ**=៤ ដូចខាងក្រោមនេះ

( **ចតុ** + **ថ** ) > **ចតុត្ថ** ប្រែថា ទី ៤ (តម្រូត **ថ** ជា **ត្ថ** តាមវិធីសំយោគ) ។

៣. **ឋ** បច្ច័យសម្រាប់ចុះក្នុងបកតិសំខ្យាតែមួយស័ព្ទគត់គឺ **ឆ**=៦ ដូចខាងក្រោមនេះ

( **ឆ** + **ឋ** ) > **ឆដ្ឋ** ប្រែថា ទី ៦ (ត្រូវតម្រូត **ឋ** ជា **ដ្ឋ** តាមវិធីសំយោគ) ។

៤. **ម** បច្ច័យសម្រាប់ចុះក្នុងបកតិសំខ្យាបានច្រើនស័ព្ទគឺ **ឯក**=១, **បញ្ច**=៥ និងចាប់ពី **សត្ត**=៧ ឡើងទៅរហូតដល់ **អសង្ខេយ្យ** ។ ប៉ុន្តែត្រង់ ទី ១ មានវិធីផ្សំពិសេស គឺត្រូវប្រើ **បឋ** ប្រែថា "តាំងដំបូង ឬ តាំងនៅមុន" ដែលសម្រេចមកពី **ប** ឧបសគ្គ ប្រែថា "ដំបូង" និង **ឋា** ធាតុប្រែថា "តាំង, ស្ថិត" ជំនួស **ឯក** ដូចខាងក្រោមនេះ

( **ឯក** > **បឋ** + **ម** ) > **បឋម** ប្រែថា ទី ១, ដំបូង, ជាដំបូង ។

( **បញ្ច** + **ម** ) > **បញ្ចម** ប្រែថា ទី ៥ ។

( **សត្ត** + **ម** ) > **សត្តម** ប្រែថា ទី ៧ ។

( **អដ្ឋ** + **ម** ) > **អដ្ឋម** ប្រែថា ទី ៨ ។

( **នវ** + **ម** ) > **នវម** ប្រែថា ទី ៩ ។

( **ទស** + **ម** ) > **ទសម** ប្រែថា ទី ១០ ។

( **វីសតិ** + **ម** ) > **វីសតិម** ប្រែថា ទី ២០ ។

( **តឹសតិ** + **ម** ) > **តឹសតិម** ប្រែថា ទី ៣០ ។

(**ចត្តាឡីស** + ម) > **ចត្តាឡីសម** ប្រែថា ទី ៤០ ។

(**បញ្ញាស** + ម) > **បញ្ញាសម** ប្រែថា ទី ៥០ ។

(**សដ្ឋី** + ម) > **សដ្ឋីម** ប្រែថា ទី ៦០ ។

(**សត្តតិ** + ម) > **សត្តតិម** ប្រែថា ទី ៧០ ។

(**អសីតិ** + ម) > **អសីតិម** ប្រែថា ទី ៨០ ។

(**នវុតិ** + ម) > **នវុតិម** ប្រែថា ទី ៩០ ។

(**សត** + ម) > **សតម** ប្រែថា ទី ១០០ ។

(**សហស្ស** + ម) > **សហស្សម** ប្រែថា ទី ១០០០ ។

(**កោដិ** + ម) > **កោដិម** ប្រែថា ទី ១ កោដិ ។

៥. **ឦ** បច្ច័យសម្រាប់ចុះក្នុងបកតិសំខ្យាចាប់ពី **ឯកាទស**=១១ ដល់ **អដ្ឋរស**=១៨ ចំពោះតែជាឥត្ថីលិង្គប៉ុណ្ណោះ ពីព្រោះ **ឦ** ជាគ្រឿងសំគាល់ឥត្ថីលិង្គ ។ សំខ្យាទាំងនេះមិនបាច់ចុះ **ម** បច្ច័យទេ ឧ.

**ឯកាទសី** =ទី ១១, **ទ្វាទសី** =ទី ១២, **អដ្ឋរសី** =ទី ១៨ ជាដើម ។

ស័ព្ទបូរណសំខ្យាដែលពោលរួចហើយនេះ មិនទាន់បំបែកជាមួយវិភត្តិនានានៅឡើយទេ ។ ប្រសិនបើប្រើរាប់នាមនាមណាត្រូវបំបែកឱ្យមានវិភត្តិនិងលិង្គស្មើគ្នា ។ បូរណសំខ្យាទាំងអស់ជា**គុណនាម**តែម៉្យាងមានវិធីបំបែកបានទាំងបីលិង្គ គឺក្នុងបុំលិង្គបំបែកតាមបែប **បុរិស**, ក្នុងឥត្ថីលិង្គត្រូវចុះស្រៈ **អា** ឬ **ឦ** ដែលជាគ្រឿងសំគាល់ឥត្ថីលិង្គសិនទើបបំបែកតាមបែប **កញ្ញា**, **នារី**, ក្នុងនបុំសកលិង្គបំបែកតាមបែប **កុល**

ដូចឧទាហរណ៍ខាងក្រោមនេះ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| បឋមោ | បឋមា | បឋមំ |
| ទុតិយោ | ទុតិយា | ទុតិយំ |
| តតិយោ | តតិយា | តតិយំ |
| ចតុត្ថោ | ចតុត្ថី, ចតុត្ថា | ចតុត្ថំ |
| បញ្ចមោ | បញ្ចមី, បញ្ចមា | បញ្ចមំ |
| ឆដ្ឋោ | ឆដ្ឋី, ឆដ្ឋា | ឆដ្ឋំ |
| សត្តមោ | សត្តមី, សត្តមា | សត្តមំ |
| អដ្ឋមោ | អដ្ឋមី, អដ្ឋមា | អដ្ឋមំ |
| នវមោ | នវមី, នវមា | នវមំ |
| ទសមោ | ទសមី, ទសមា | ទសមំ |
| ឯកាទសមោ | ឯកាទសី | ឯកាទសមំ |
| ទ្វាទសមោ, ពារសមោ | ទ្វាទសី, ពារសី | ទ្វាទសមំ, ពារសមំ |
| អដ្ឋារសមោ | អដ្ឋារសី | អដ្ឋារសមំ |
| ឯកូនវីសតិមោ | ឯកូនវីសតិមា | ឯកូនវីសតិមំ |
| វីសតិមោ | វីសតិមា | វីសតិមំ |
| ។បេ។ | ។បេ។ | ។បេ។ |

សព្វ័បូរណសំខ្យាដែលបានរៀបរាប់ខាងលើនេះ ជាបឋមាវិភត្តិតែម៉្យាង ។ ចំពោះវិភត្តិដទៃទៀត សូមអ្នកសិក្សាល្បងបំបែកខ្លួនឯងដើម្បីឱ្យមានជំនាញ ។ ចូរចំណាំថាចាប់ពី **ឯកាទស**=១១ ដល់ **អដ្ឋារស**=១៨ បើជាឥត្ថីលិង្គមិនមានចុះ **ម** បច្ច័យទេគឺចុះ **ឦ** បច្ច័យជាមួយសំខ្យាផ្ទាល់តែម្តង ។ ខាងក្រោមនេះជាឧទាហរណ៍នៃការប្រើជាបទវិសេសនៈឱ្យនាមសព្ទដោយបំបែកឱ្យស្មើគ្នា ។

| | | |
|---|---|---|
| **បុរិស** បុំ. | **បឋមោ បុរិសោ ។** | *ប្រែថា "ប្រុសទី ១" ជាដើម ។* |
| **កុល** នបុំ. | **បឋមំ កុលំ ។** | *ប្រែថា "ត្រកូលទី ១" ជាដើម ។* |
| **ភរិយា** ឥ. | **ទុតិយា ភរិយា ។** | *ប្រែថា "ភរិយាទី ២" ជាដើម ។* |
| **នារី** ឥ. | **បញ្ចមី នារី ។** | *ប្រែថា "ស្រីទី ៥" ជាដើម ។* |

## វិធីប្រើនិងប្រែបូរណសំខ្យាក្នុងប្រយោគ

បូរណសំខ្យា កាលណាយកមករៀងក្នុងប្រយោគ ដើម្បីប្រើអធិប្បាយនាមបទណា ត្រូវរៀងដាក់ខាងដើមនាមដែលជាប្រធាននោះ ៗ ដោយបំបែកឱ្យមាន លិង្គ, វចនៈ និងវិភត្តិ ស្មើគ្នា ។ វេលាប្រែជាភាសាខ្មែរពុំចាំបាច់ប្រែចេញពាក្យអាយតនិបាតទេ គឺប្រែដូចគុណនាមដែរ ដូចឧទាហរណ៍ខាងក្រោមនេះ

**១. មម <u>បឋមោ</u> បុត្តោ វីសតិវស្សោ ហោតិ ។**

បុត្រ ទី ១ របស់ខ្ញុំ ជាអ្នកមានវស្សាម្ភៃ(=អាយុម្ភៃឆ្នាំ) ។

**២. កា តវ ទុតិយា ភរិយា ហោតិ ។**

នាងណា ជាភរិយា ទី ២ របស់លោក ?

## វិធីប្រើបកតិសំខ្យាក្នុងបែបផ្សេង ៗ ទៀត

វិធីប្រើ **អឌ្ឍ** ប្រែថា "កន្លះ" ជាមួយបូរណសំខ្យា សូមរកមើលក្នុងមេរៀនទី ១៣ ។ ខាងក្រោមនេះជារបៀបប្រើបកតិសំខ្យាជាបែបផ្សេង ៗ ទៀត ។

១. បើចុះ **ធា** បច្ច័យក្នុងចុងបកតិសំខ្យា ប្រែថា "ដោយចំណែក" ដូចជា **ឯកធា** =ដោយចំណែកមួយ, **ទ្វិធា**, **ទ្វេធា** =ដោយចំណែកពីរ, **តិធា** =ដោយចំណែកបី, **សត្តធា** =ដោយចំណែក៧, **សហស្សធា** = ដោយចំណែកមួយពាន់, **ចតុធា**, **ចតុទ្ធា** =ដោយចំណែក៤ ជាដើម ។

២. បើចុះ **ខត្តុំ** បច្ច័យក្នុងចុងបកតិសំខ្យាដោយត្រូវតម្រួតជា **ក្ខត្តុំ** ប្រែថា "វារៈ...ដង", "អស់វារៈ...ដង", "...លើក", "...គ្រា" ដូចជា **ឯកក្ខត្តុំ** =វារៈមួយដង, ម្ដង, **ទ្វិក្ខត្តុំ** =វារៈពីរដង, ពីរលើក, **តិក្ខត្តុំ** =វារៈបីដង, បីគ្រា, **ចតុក្ខត្តុំ** =វារៈបួនដង, **សតក្ខត្តុំ** =វារៈមួយរយដង, **កតិក្ខត្តុំ** =វារៈប៉ុន្មានដង ជាដើម ។

បើមានបកតិសំខ្យាពីរស័ព្ទដូចជា **ទ្វិ** + **តិ** + **ខត្តុំ** > **ទ្វិត្តិក្ខត្តុំ** ត្រូវ

ប្រែដូច្នេះ =វារៈពីរបីដង, ពីរបីលើក ។

៣. បើចុះ **ក** បច្ច័យក្នុងចុងបកតិសំខ្យាប្រែថា "មានប្រមាណ...", "ពួក..." ដូចជា **ទ្វិក** =មានប្រមាណពីរ,ពួកពីរ, **តិក** =មានប្រមាណបី, ពួកបី, **ឆក្ក** =មានប្រមាណ៦, ពួក៦, **ចតុក្ក** =មានប្រមាណបួន, ពួកបួន ជាដើម ។

៤. បើចុះ **សោ** បច្ច័យក្នុងចុងបកតិសំខ្យាប្រែថា "ម្តង..." ដូចជា **ឯកសោ**=ម្តងមួយ, **បញ្ចសោ**=ម្តងប្រាំ, **សត្តសោ**=ម្តង៧ ជាដើម ។

៥. បើចុះ **វិធ** ស័ព្ទក្នុងចុងបកតិសំខ្យាឱ្យប្រែថា "មានប្រការ...", "...យ៉ាង" ដូចជា **បញ្ចវិធ** =មានប្រការ៥, ប្រាំយ៉ាង, **ទសវិធ** =មានប្រការ ១០, ដប់យ៉ាង, **ទុព្វិធ**, **ទុវិធ** =មានប្រការពីរ, ពីរយ៉ាង, **ចតុព្វិធ** =មានប្រការបួន, បួនយ៉ាង ជាដើម ។

៦. បើចុះ **ភាគ** ស័ព្ទក្នុងចុងបូរណសំខ្យាប្រែថា "មានចំណែក..." ដូចជា **ចតុត្ថភាគ** =មានចំណែកបួន ។ បើចុះជាមួយបកតិសំខ្យាក៏ប្រែថា "មានចំណែក..." ដែរដូចជា **ចតុព្ភាគ** =មានចំណែក ៤ ។ល។

៧. បើបំបែកក្នុងរូបជាទុតិយាវិភត្តិនបុំសកលិង្គវិញប្រែថា "លើកទី......" ដូចជា **បឋមំ** =លើកទី ១, **ទុតិយំ** =លើកទី ២ ជាដើម ។

## ការប្រើបកតិសំខ្យាផ្ទួនគ្នា

ឧ. អដ្ឋ អដ្ឋ ថេរេ អមច្ចេ ច បេសយិ ។

ប្រែថា (ព្រះរាជា) បញ្ជូនហើយ នូវព្រះថេរនិងអាមាត្យ ប្រាំបី ៗ រូប ។

ឧ. ទ្វេ ជនា បញ្ច បញ្ច មាណវកេ សតបរិវារា ហោន្តិ ។

ជន.ទ. ពីរនាក់ មាន បរិវាជាមនុស្សកម្លោះ ៗ ប្រាំរយ ៗ រូប ។

❁ ការប្រើដូច្នេះវេលាប្រែ ត្រូវប្រែសំខ្យាស័ព្ទឱ្យផ្ទួនផងដែរ ។

ប្រសិនបើចង់និយាយដោយញែកចេញនូវវត្ថុអ្វីមួយពីបណ្តាវត្ថុអ្វីមួយចំនួនទៀត ត្រូវរៀងប្រយោគដូចខាងក្រោមនេះ

អដ្ឋសុ បុរិសេសុ បឋមោ បុរិសោ ព្រាហ្មណោ ហោតិ ។

ឬជា អដ្ឋន្នំ បុរិសានំ បឋមោ បុរិសោ ព្រាហ្មណោ ហោតិ ។

ប្រែថា បណ្តា បុរស.ទ. ប្រាំបីនាក់ បុរសទី ១ ជាព្រាហ្មណ៍ ។

សូមចំណាំរបៀបរៀងខាងលើនេះឱ្យបានល្អផង ។ នៅមានរបៀបប្រើបកតិនិងបូរណសំខ្យាតាមបែបផ្សេង ៗ ទៀត ប៉ុន្តែឧទាហរណ៍ខាងលើនេះឃើញថាច្រើនល្មមសមគួរហើយដែរ ។

## វិធីសង្កេតកាលនៃអាខ្យាតកិរិយា

រឿងកាលមានសារៈសំខាន់ណាស់ក្នុងការនិយាយឬសរសេរសៀវភៅ ។ ប្រសិនបើនិយាយឬសរសេរខុសកាល អាចធ្វើឱ្យខុសឃ្លាតចាក

*សេចក្តីទៅបាន ព្រោះហេតុនេះទើបទាំងភាសាបាលីឬសំស្រ្កឹតនិងទាំងភាសាខ្មែរយើងផងដែរ លោកបានកំណត់ឱ្យមានកាលជា ៣ កាលធំ ៗ ដូចគ្នាគឺ ១. **បច្ចុប្បន្នកាល** ២. **អតីតកាល** ៣. **អនាគតកាល** ។*

*វិធីសង្កេតកាលនៃអាខ្យាតកិរិយាក្នុងភាសាបាលី* មិនមានអ្វីជាការ*លំបាកទេ ។ ពីព្រោះអាខ្យាតកិរិយាត្រូវតែបំបែកជាមួយវិភត្តិណាមួយនៃវិភត្តិទាំង ៨ ពួក ហើយវិភត្តិមួយពួក ៗ តែងតែប្រាប់ឱ្យដឹងកាលជានិច្ច ។ លោកបានចាត់វិភត្តិនីមួយ ៗ ឱ្យមានកាលដូចតទៅនេះ*

១. **វត្តមានាវិភត្តិ** *គឺ* **តិ, អន្តិ, សិ, ថ, មិ, ម** *ចាត់ជា***បច្ចុប្បន្នកាល** *ដែលមានកិរិយានុគ្រោះប្រែថា "កំពុង..., កំពុងតែ..., ទើប..., តែងតែ..., រមែង..., គង់..., គង់តែ..., នឹង...* ។

២. **បញ្ចមីវិភត្តិ** *គឺ* **តុ, អន្តុ, ហិ, ថ, មិ, ម** *ចាត់ជា***អនុត្តកាល** *ដែលមានកិរិយានុគ្រោះប្រែថា "ចូរ..., ចូរ...ចុះ, សូម..., សូមឱ្យ...ចុះ"* ។

៣. **សត្តមីវិភត្តិ** *គឺ* **ឯយ្យ, ឯយ្យុំ, ឯយ្យាសិ, ឯយ្យាថ, ឯយ្យាមិ, ឯយ្យាម** *ក៏ជា***អនុត្តកាល***ដែរ* មានកិរិយានុគ្រោះប្រែថា *"គួរ..., គួរតែ..., គប្បី..., ត្រូវ..."* ។

៤. **អជ្ជតនីវិភត្តិ** *គឺ* **ឦ, ឧំ, ឱ, ត្ថ, ត្ថំ, ម្ហា** *និង* **ហីយត្តនីវិភត្តិ** *គឺ* **អា, ឩ, ឱ, ត្ថ, អំ, ម្ហា** *និង* **បរោក្ខាវិភត្តិ** *គឺ* **អ, ឧ, ឯ, ត្ថ, អំ, ម្ហ** *ទាំងបីវិភត្តិ នេះចាត់ជា***អតីតកាល***មានកិរិយានុគ្រោះប្រែថា "...ហើយ, បាន...ហើយ, ...ឡើយ"*។

៥. **ភវិស្សន្តិវិភត្តិ** *គឺ* **ស្សតិ, ស្សន្តិ, ស្សសិ, ស្សថ, ស្សាមិ, ស្សាម** *ចាត់ជា***អនាគតកាល** មានកិរិយានុក្រោះប្រែថា "នឹង..." ។

៦. **កាលាតិបត្តិវិភត្តិ** *គឺ* **ស្សា, សំសុ, ស្សេ, ស្សថ, ស្សំ, ស្សាម្ហា** *ចាត់ជា***អនាគតកាល***ដែរ ប៉ុន្តែរបស់អតីតកាលមានកិរិយានុក្រោះប្រែថា "នឹង...ហើយ, នឹងបាន ...ហើយ"* ។

*វិភត្តិទាំងឡាយខាងលើនេះជាបរស្សបទតែម្យ៉ាងទេ ។ រឿងកាលនេះបានអធិប្បាយក្នុងមេរៀនទី ៣ រួចម្ដងហើយ ចូររកមើលថែមទៀតផងចុះ ។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះ ៗ*

## ១. វត្តមានាវិភត្តិ

១. ឯស ភិក្ខុ ជនានំ ធម្មំ ទេសេតិ ។

*ភិក្ខុ នុ៎ះ កំពុងសំដែង នូវធម៌ ដល់ជន.ទ.* ។

២. កុតោ ត្វំ អាគច្ឆាសិ ?

*ចុះឯង ទើបមក ពីទីណា ?*

៣. អហំ ស្វេ នគរំ គច្ឆាមិ ។

*ខ្ញុំ នឹងទៅ កាន់ទីក្រុង ក្នុងថ្ងៃស្អែក ។*

## ២. បញ្ចមីវិភត្តិ

១. (ត្វំ) មម ឱទនំ អាហរ (អាហរិ) ។

*(ឯង) ចូរនាំមក នូវបាយ សម្រាប់ខ្ញុំ ។*

២. អហំ ធម្មំ សុណាមិ ។

*សូមឱ្យខ្ញុំ ស្តាប់ នូវធម៌ ។*

៣. មា តុម្ហេ សទ្ទំ ករោថ ។

*សូមអ្នក.ទ. កុំធ្វើ នូវសំឡេង (=សូមស្ងាត់) ។*

## ៣. សត្តមីវិភត្តិ

១. ជនា បុញ្ញំ កយិរា ។

*ជន.ទ. គួរធ្វើ នូវបុណ្យ រឿយ ៗ ។*

២. ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ ។

*(ជន) មិនគួរគប់រក មិត្រអាក្រក់, មិនគួរគប់រក បុរសថោកទាប ។*

៣. សចេ ជនោ បុញ្ញំ កយិរា សោ សុគតឹ គច្ឆតិ ។

*ប្រសិនបើ ជន គប្បីធ្វើ នូវបុណ្យ គេ រមែងទៅ កាន់សុគតិ ។*

## ៤. អជ្ជតនីវិភត្តិ

១. មុនយោ មញ្ចេសុ និសីទីសុ ។

*អ្នកប្រាជ្ញ.ទ. អង្គុយហើយ លើគ្រែ ។*

២. អធិបតិ វាណិជម្ហា មណយោ កីណិ ។

*អធិបតី ទិញហើយ នូវកែវមណី.ទ. ពីពាណិជ ។*

៣. តុម្ហេ ភិក្ខូនំ ភត្តានិ អទទិត្ថ ។

*អ្នក.ទ. ប្រគេនហើយ នូវភត្ត.ទ. ដល់ភិក្ខុ.ទ. ។*

## ៥. ហីយត្តនីវិភត្តិ

១. ពុទ្ធោ ឥមំ សុភាសិតំ អវោច ។

*ព្រះពុទ្ធ បានត្រាស់ហើយ នូវសុភាសិត នេះ ។*

២. ខណោ វោ មា ឧបច្ចគា ។

*ខណៈ កុំ កន្លងបង់ នូវអ្នក.ទ. ឡើយ ។*

៣. វាណិជោ នគរំ ភណ្ឌានិ អហរិ ។

*ឈ្មួញ បាននាំទៅហើយ នូវអីវ៉ាន់ កាន់នគរ ។*

## ៦. បរោក្ខាវិភត្តិ

១. តេនាហុ < ( តេន + អហុ ) ពោរាណា ។

*ព្រោះហេតុនោះ អាចារ្យដែលមានក្នុងកាលមុន.ទ. បានពោលហើយ ។*

២. តេនាហ < ( តេន + អាហ ) ភគវា......។

*ព្រោះហេតុនោះ ព្រះមានព្រះភាគ ត្រាស់ហើយ...... ។*

៣. សេដ្ឋី ឃរមាហ < ( ឃរំ + អាហ ).... ។

*សេដ្ឋី ពោលហើយ យ៉ាងនេះ... ។*

## ៧. តរិស្សន្តីវិភត្តិ

១. ឧបាសកា សាលាយំ ធម្មំ សុណិស្សន្តិ ។

*ឧបាសក.ទ. នឹងស្តាប់ នូវធម៌ ក្នុងសាលា ។*

២. អហំ បឋមស្ស យាចកស្ស ទានំ ទទិស្សាមិ ។

*ខ្ញុំ នឹងឱ្យ នូវទាន ដល់ស្មូម ទី ១ ។*

៣. ឯស ភិក្ខុ ជនានំ ធម្មំ ទេសេស្សតិ ។

*ភិក្ខុ នុ៎ះ នឹងសំដែង នូវធម៌ ដល់ជន.ទ. ។*

## ៨. កាលាតិបត្តិវិភត្តិ

១. សោ ចេ យានំ លភិស្សា អគច្ឆិស្សា ។

*បើ គេ នឹងបានហើយ នូវយាន (គេ) នឹងបានទៅហើយ ។*

២. សចេ ត្វំ ឱទនំ អបចិស្សេ អហំ អភុញ្ជិស្សំ ។

*ប្រសិនបើ អ្នក នឹងចម្អិនហើយ នូវបាយ ខ្ញុំ នឹងបានទទួលទាន ហើយ ។*

*ឧទាហរណ៍ខាងលើនេះមានសុទ្ធតែជាកត្តុវាចកៈ មិនមានជាវាចកៈ ដទៃទេ សូមអ្នកសិក្សាស្វែងយល់ខ្លួនឯងផងចុះ ។*

# វិភត្តិអាខ្យាតផ្លាស់ប្តូររូប

វិភត្តិអាខ្យាតទាំងប្រាំបីពួកនេះ មានវិភត្តិខ្លះអាចផ្លាស់ប្តូររូបទៅជាដទៃបាន ។ ដូច្នេះអ្នកសិក្សាដំបូងគប្បីតែយល់ដឹង ដូចមានអធិប្បាយខាងក្រោមនេះ

## ១. ពួកវត្តមានាវិភត្តិ

១.១ **តិ**, **អន្តិ** វិភត្តិផ្លាស់ជា **ឞ** ដូចជា **ជាយឞ**, **វុច្ចឞ** ។ **ជាយឞ** "ដឹង" មកពី **ញា** ធាតុបុះ **ណា** បច្ច័យនិង **តិ** ឬ **អន្តិ** វិភត្តិ, ផ្លាស់ **ញា** > **ជា** និងផ្លាស់ **ណា** បច្ច័យជា **យ** និងផ្លាស់ **តិ** ឬ **អន្តិ** ទៅជា **ឞ** ។ **វុច្ចឞ** "ពោល" មកពី **វច** ធាតុបុះ **យ** បច្ច័យ, ផ្លាស់ **វ** ជា **ឧ** ទៅជា **ឧច** រួចបុះ **វ** អាគមនិងផ្លាស់ទីបំផុតធាតុ **ច្ច** ទៅជា **វុច្ច** ,ផ្លាស់ **តិ** ឬ **អន្តិ** ទៅជា **ឞ** ។

១.២ **ថ** វិភត្តិផ្លាស់ជា **ត្ថ** ។ **ថ** វិភត្តិកាលបើបុះជាមួយ **អស** ធាតុត្រូវផ្លាស់ជា **ត្ថ** (**អស** + **ថ**) > **អត្ថ** ។

១.៣ **មិ**, **ម** វិភត្តិផ្លាស់ជា **ម្ហិ**, **ម្ហ** ។ **មិ** ផ្លាស់ជា **ម្ហិ** កាលបើបុះជាមួយ **អស** ធាតុ (**អស** + **មិ**) > **អម្ហិ** ។ ចំណែកឯ **ម** ផ្លាស់ជា **ម្ហ** (**អស** + **ម**) > **អម្ហ** ។ បើបុះជាមួយ **ទា** ធាតុប្រែថា "ឱ្យ" មានអំណាចឱ្យផ្លាស់ស្រៈ **អា** នៃ **ទា** ជានិគ្គហិត ំ ហើយផ្លាស់និគ្គហិតនោះជា **ម** (**ទា** > **ទំ** > **ទម** + **មិ** ឬ **ម**) > **ទម្មិ** ឬ **ទម្ម** ។

## ២. ពួកបញ្ចមីវិភត្តិ

តុ វិភត្តិកាលបើចុះជាមួយ អស ធាតុត្រូវផ្លាស់ជា ត្ថុ, (អស + តុ) > អត្ថុ ។

## ៣. ពួកសត្តមីវិភត្តិ

ឯយ្យ វិភត្តិផ្លាស់បានបីយ៉ាងគឺ

៣.១ ឯយ្យ វិភត្តិអាចផ្លាស់ ជា អា ដូចជា (ការ + យិរ + ឯយ្យ) > កាយិរា =(គេ) គប្បីធ្វើ (លុបទីបំផុតធាតុចេញ) ។

៣.២ ឯយ្យ វិភត្តិអាចផ្លាស់ជា ញ្ញា ដូចជា (ញា > ជំ + នា + ឯយ្យ) > ជញ្ញា =(គេ) គប្បីដឹង (ផ្លាស់និគ្គហិតលើ ជ ជា ញ និងលុប នា បច្ច័យចេញ) ។

៣.៣ ឯយ្យ វិភត្តិអាចផ្លាស់ជា ឥយា ដូចជា (ញា > ជា + នា + ឯយ្យ) > ជានិយា =(គេ) គប្បីដឹង (លុបស្រៈ អា នៃបច្ច័យចេញ) ។

## ៤. ពួកបរោក្ខាវិភត្តិ និង
## ៥ ហិយត្តនីវិភត្តិ

វិភត្តិពួកនេះមិនមានផ្លាស់ប្តូរទេ ។

# ៦. ពួកអជ្ជតនីវិភត្តិ

ឦ វិភត្តិផ្លាស់បានពីរយ៉ាងគឺ

៦.១ ឦ វិភត្តិអាចផ្លាស់ជា ច្ឆិ ដូចជា (អ អា. + កុស + អ + ឦ) > អក្កោច្ឆិ ឬ អក្កោច្ឆិ =(គេ) បានជេរហើយ (អក្កោច្ឆិ ផ្លាស់ ឦ ជា ច្ឆិ, ព្រឹទ្ធិ ឧ នៃ កុស ជា ឱ, លុបទីបំផុតធាតុចេញ ។ អក្កោច្ឆិ ផ្លាស់ ឦ > ឆិ, ផ្លាស់ ស > ច, ព្រឹទ្ធិ ឧ នៃ កុស ជា ឱ និងតម្រួតដើមធាតុជា ក្ក ។

៦.២ ឦ វិភត្តិអាចផ្លាស់ជា ត្ថ, ត្ថុំ ចំពោះ លភ ធាតុដូចជា (អ អា. + លភ + អ + ឦ) > អលត្ថ, អលត្ថុំ =(គេ) បានទទួលហើយ, ដោយលុបទីបំផុតធាតុចេញ ។

# ៧. ពួកកាលាតិបត្តិវិភត្តិ

ស្សតិ, ស្សន្តិ, ស្សសិ, ស្សថ, ស្សាមិ, ស្សាម វិភត្តិទាំង ៦ តួនេះកាល បើផ្សំជាមួយ ករ ធាតុដែលផ្លាស់ ករ ជាតុនិង អ បច្ច័យជា កាហ, លុប ស្ស ចេញឱ្យសល់ត្រឹមតែ តិ, ន្តិ, សិ, ថ, មិ, ម ដូចជា (ករ > កាហ + ស្សតិ)> កាហតិ, កាហន្តិ, កាហសិ, កាហថ, កាហាមិ, កាហាម =នឹងធ្វើ ។ ឬក៏ចុះ ឥ អាគមថែមក៏បានទៅជា កាហិតិ =នឹងធ្វើ ។

ចំពោះ **ស្បាមិ**, **ស្បាម** ២ តួនេះអាចផ្លាស់ជា **ឆាមិ**, **ខាមិ**, **ឆាម**, **ខាម** បានដូចជា **វច្ឆាមិ**, **វច្ឆាម** មកពី (**វស** + **អ** + **ឆាមិ**) > **វច្ឆាមិ**, (**វស** + **អ** + **ឆាម**) > **វច្ឆាម** ។ ពីព្រោះមាន **ឆ** នៅខាងចុងទើបត្រូវផ្លាស់ **ស** ទីបំផុតធាតុជា **ច** តាមវិធីព្យញ្ជនសំយោគទៅជា **វច្ឆាមិ** =(ខ្ញុំ) នឹងទៅ ។ **វច្ឆាម** ក៏ដូចគ្នាដែរ ខុសតែវិភត្តិប៉ុណ្ណោះ ។

ប្រសិនបើប្រកបជាមួយ **វច** ធាតុដែលប្រែថា "ពោល" អាចផ្លាស់ **ស្បាមិ** > **ខាមិ**, **ស្បាម** > **ខាម** ទៅជា **វក្ខាមិ**, **វក្ខាម** ។ **វក្ខាមិ** មកពី (**វច** + **អ** + **ខាមិ**) > **វក្ខាមិ** ។ **វក្ខាម** មកពី (**វច** + **អ** + **ខាម**) > **វក្ខាម** ។ ពីព្រោះមាន **ខ** អក្សរនៅខាងចុងត្រូវផ្លាស់ទីបំផុតធាតុ **ច** > **ក** ឱ្យត្រូវតាមវិធីព្យញ្ជនសំយោគទៅជា **វក្ខាមិ** =(ខ្ញុំ) នឹងពោល និង **វក្ខាម** ក៏ដូចគ្នាដែរ ខុសតែវិភត្តិប៉ុណ្ណោះ ។

## ៨. ពួកកាលាតិបត្តិវិភត្តិ

វិភត្តិពួកនេះមិនមានផ្លាស់ប្តូរទេ ។

## កំណត់សម្គាល់

**អស** ធាតុមានវិធីបំបែកប្លែកពីគេ រីឯវិធីប្រើក៏ប្លែកដែរ ។

ក. ត្រង់ **អត្ថិ** =មាន, បើប្រើបដិសេធត្រូវប្រើ **ន** ខាងដើមដោយធ្វើសន្ធិជា (**ន** + **អត្ថិ**) > **នត្ថិ** =មិនមាន ។ ទាំងពីរស័ព្ទនេះជាឯកវចនៈ តែក៏អាចប្រើជាមួយបទប្រធានជាពហុវចនៈបានដែរ ដូចឧទាហរណ៍ខាងក្រោមនេះ

**១. យេ$_{២}$ សត្តា$_{១}$ សញ្ញិនោ$_{៣}$ អត្ថិ$_{៤}$។**

សត្វ.ទ.$_{១}$ ឯណា$_{២}$ ជាសត្វមានសញ្ញា$_{៣}$ ។

**២. សង្ខារា$_{១}$ សស្សតា$_{៣}$ នត្ថិ$_{៤}$។**

សង្ខារ.ទ.$_{១}$ ជាសភាវៈទៀង$_{៣}$ មិនមាន$_{៤}$ ។

នៅក្នុងគាថានិយមធ្វើសន្ធិ **អត្ថិ** ជាមួយស័ព្ទដទៃដើម្បីកាត់បទឱ្យខ្លីជាងធម្មតា ដូចជា

**បុត្តាមត្ថិ**, **ធន្មត្ថិ** វេលាប្រែត្រូវញែកជាប្រយោគដូច្នេះ

**បុត្តាមត្ថិ** ទៅជា **បុត្តា មេ អត្ថិ** =រីបុត្រ របស់ខ្ញុំ មាន ។

**ធន្មត្ថិ** ទៅជា **ធនំ មេ អត្ថិ** =រីទ្រព្យ របស់ខ្ញុំ មាន ។

ក្រៅពីនេះ **អត្ថិ** និង **នត្ថិ** មានប្រើជាបទសមាសជាមួយស័ព្ទដទៃក៏បាន ដោយមានបទក្រោយជានាមហើយដែលបំបែកជាវិភត្តិផ្សេង ៗ ដូចនាមស័ព្ទទូទៅដែរ ដូចជា

**អត្ថិភាវោ** =រីភាវៈមាន, **នត្ថិភាវោ** =រីភាវៈមិនមាន, **នត្ថិបូវោ** =រីភាវៈនៃនំមិនមាន ជាដើម ។

ខ. ត្រង់ **អសិ** ដែលមានបទវិកតិកត្តាជាបទអធិប្បាយរៀងពីខាងដើមតែងនិយមប្រើជាបទសន្ធិដូចជា

១. (**មនុស្សោ** + **អសិ**) > **មនុស្សោសិ** ? ឯងជាមនុស្សឬ ?

២. (**បុរិសោ** + **អសិ**) > **បុរិសោសិ** ? ឯងជាប្រុសឬ ?

៣. **កុតោ** (**អាគតោ** + **អសិ**) > **អាគតោសិ** ? ឯង ទើបមក ពីណា ?

ក្នុងទីខ្លះលុប **អសិ** ចោលមានត្រឹមតែបទប្រធាននិងបទវិកតិកត្តា ក៏បានឧទាហរណ៍

**ត្វំ កស្ស បុត្តោ** ? ឯង ជាបុត្រ របស់អ្នកណា ?

វេលាប្រែលោតប្រយោគត្រូវថែមកិរិយាស័ព្ទជា **អសិ** ព្រោះមានបទប្រធាន ត្រូវតែមានបទកិរិយាគ្រប់គ្រងប្រយោគជានិច្ច ។ **ត្វំ** =រីឯង **បុត្តោ អសិ** =ជាកូន **កស្ស** = របស់អ្នកណា ?

គ. ត្រង់ **អម្ហិ** មានគតិដូច **អសិ** ដែរគឺថា **អម្ហិ** ជាកិរិយាស័ព្ទមានបទប្រធានជា **អហំ** មានបទវិកតិកត្តាជាបទគុណហើយធ្វើសន្ធិចូលគ្នា

ឧ. **ប្វំ** (**ខាទិតុកាមោ** + **អម្ហិ**) > **ខាទិតុកាមោម្ហិ** =ខ្ញុំ ជាអ្នកប្រាថ្នាដើម្បីស៊ី នូវនំ ។

ឃ. **តុ** បញ្ចមីវិភត្តិបើផ្សំជាមួយនឹង **អស** ធាតុទៅជា **អត្ថុ** =សូមមាន ។ កិរិយាស័ព្ទនេះនិយមប្រើក្នុងប្រយោគមានការបួងសួង, សេចក្តីប្រាថ្នា, សំដែងការគោរព ក្នុងដំណើរសំពះថ្វាយបង្គំគ្រូបុព្វាចារ្យមុននឹងធ្វើពីធីការនោះ ៗ ។

ឱ. **នមត្ថុ សម្ពុទ្ធស្ស** មានសេចក្តីថា "សូមក្រាបថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធ" ។

វេលាប្រែលោតប្រយោគត្រូវញែកចេញជាប្រយោគដូច្នេះ

**នមោ អត្ថុ សម្ពុទ្ធស្ស** ។

រីកិរិយាថ្វាយបង្គំ សូមមាន ចំពោះព្រះសម្ពុទ្ធ ។

ប្រយោគថា **នមត្ថុ សុគតស្ស** មានសេចក្តីថា "សូមក្រាបថ្វាយបង្គំ ចំពោះព្រះសុគត" និងប្រយោគថា **នមត្ថុ រតនត្តយស្ស** មានសេចក្តីថា "សូមក្រាបថ្វាយបង្គំ ចំពោះព្រះរតនត្រៃ" ។

ង. កិរិយាស័ព្ទដែលសម្រេចមកពី **អស** ធាតុមានចំណុចសង្កេត ២ យ៉ាងគឺ

ង.១. ប្រសិនបើលុបដើមធាតុចេញនិងជាកិរិយាដែលផ្តើមដោយព្យញ្ជនៈ វេលារៀងក្នុងប្រយោគពុំចាំបាច់ធ្វើសន្ធិជាមួយបទឯទៀតទេ **សន្តិ** =មាន, **សិយា**, **សិយុំ** = គប្បីមាន, គប្បីជា ។

ង.២. បើត្រូវលុបទីបំផុតធាតុចេញក៏ក្លាយជាកិរិយាស័ព្ទដែលផ្តើមដោយស្រៈ **អ** ឬស្រៈ **អា** ក្តី វេលារៀងដាក់ក្នុងប្រយោគតោងធ្វើសន្ធិជាមួយបទដទៃជានិច្ច ហើយតួ អ ក៏បាត់រូបទៅ ឱ.

(**បុរិសោ** + **អសិ**) > **បុរិសោសិ** =ឯងជាប្រុស ។

(**កម្មស្សកោ** + **អម្ហិ**) > **កម្មស្សកោម្ហិ** =យើងមានកម្មជារបស់ខ្លួន, ដូច្នេះជាដើម ។

វិភត្តិតួឯទៀត ៗ គប្បីផ្ទៀបតាមវិធីនេះ ។ **អស** ធាតុដែលបំបែកជា **អត្ថិ** និង **ឧត្ថិ** និយមប្រើដាក់ខាងដើមនៃប្រយោគដូចជា **ឧត្ថិ មេ សរណំ**....... មិនមាន ទីពឹងឯណា សម្រាប់ខ្ញុំ.......... ។

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| **យុវតី** ឥ. | ស្រីក្មេង | **កនិដ្ឋ** បុំ. | ប្អូនប្រុស |
| **មាស** បុំ. | ខែ, សណ្ដែក | **សង្គាម** បុំ. | សង្គ្រាម |
| **វស្ស** បុំ.,នបុំ. | ភ្លៀង, ឆ្នាំ | **សុរា** ឥ. | ស្រា, សុរា |
| **កាល** បុំ. | កាល, សម័យ | **អាចរិយានី** ឥ. | អ្នកគ្រូ |
| **ភោគី** បុំ. | អ្នកមានទ្រព្យ | **អន្តិម** គុ. | ទីបំផុត, ចុង |
| **ភោគ** បុំ. | ទ្រព្យ | **ឥតោ** អព្យ. | អំពី...នេះ |

## លំហាត់នៃមេរៀនទី ១៧

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើ **បូរណសំខ្យា** ប្រែថាដូចម្ដេច ?

២. តើបច្ច័យសម្រាប់ធ្វើបកតិសំខ្យាឱ្យទៅជាបូរណសំខ្យាមានប៉ុន្មានតួ គឺអ្វីខ្លះ ?

៣. តើបច្ច័យអ្វីសម្រាប់ចុះជាមួយ **ទ្វិ** និង **តិ** ឱ្យទៅជាបូរណសំខ្យា ?

៤. តើបច្ច័យអ្វីសម្រាប់ចុះជាមួយ **ចតុ** ឱ្យទៅជាបូរណសំខ្យា ?

៥. តើបច្ច័យអ្វីសម្រាប់ចុះជាមួយ **ឆ** ឱ្យទៅជាបូរណសំខ្យា ?

៦. តើបច្ច័យអ្វីសម្រាប់ចុះជាមួយ **ឯក**, **បញ្ច** និងចាប់ពី **សត្ត** ឡើងទៅឱ្យទៅជាបូរណសំខ្យា ?

៧. តើបច្ច័យអ្វីសម្រាប់ចុះពី **ឯកាទស** ដល់ **អដ្ឋារស** ឱ្យទៅជាបូរណសំខ្យាឥត្ថីលិង្គ ?

៨. តើ **តិ** និង **អដ្ឋ** វត្តមានាវិភត្តិអាចផ្លាស់ជាអ្វី ? សូមឱ្យឧទាហរណ៍ ។

៩. តើ **ឆ** អជ្ជត្តនីវិភត្តិអាចផ្លាស់ជាអ្វី ? សូមឱ្យឧទាហរណ៍ ។

១០. តើភវិស្សន្តិវិភត្តិខាងបរស្សបទអាចផ្លាស់ជាអ្វីខ្លះ ? សូមឱ្យឧទាហរណ៍ ។

### ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. ទសសុ បុរិសេសុ សត្តមោ វាណិជោ ហោតិ ។

២. សោ សត្តមោ បុរិសោ ភារិយា អដ្ឋមាយ ឯកំ វត្ថុំ អទាសិ ។

៣. ចតស្សន្នំ យុវតីនំ តតិយា កញ្ញា បញ្ច អស្សេ អានេសិ ។

៤. មយ្ហំ គរុ សត្តតិមេ វស្សេ បញ្ចមេ មាសេ កាលំ អកាសិ ។

៥. មយំ ឥតោ ឆដ្ឋេ ទិវសេ ចតូហិ បុរិសេហិ សទ្ធឹ ទុតិយំ នគរំ គមិស្សាម ។

៦. ទ្វិសុ ចាបសាលាសុ បឋមាយ តិសតំ សិស្សា ឧគ្គណ្ហន្តិ ។

៧. ទ្វិន្នំ ភោគីនំ ទុតិយោ តីសតិយា យាចកានំ ធានំ អទាសិ ។

៨. បញ្ចសុ ធារីសុ តតិយា អាចរិយានី ហោតិ ។

៩. សោ បឋមោ ភិក្ខុ ពហុន្នំ មនុស្សានំ ធម្មំ ទេសេសិ ។

១០. យោ បឋមំ អាគច្ឆេយ្យ សោ បណ្ណាការំ លភេយ្យ ។

១១. អគ្គិមេធ គហបតិនា បញ្ច សីលានិ រក្ខិយេរំ ។

១២. អហំ វីសតិយា តរុណីនំ វត្ថានិ បុច្ឆានិ ធនិស្សាមិ ។

១៣. ភិក្ខូនំ ឯកូនសតំ មម គេហំ អាគមិ ឯស ភិក្ខុ
បញ្ចវីសតិមោ អហោសិ ។

១៤. សោ តរុណោ មម បញ្ចមោ កានិដ្ឋោ ហោតិ ។

១៥. ឧត្តោ បុរិសោ ឥមស្ស គេហស្ស បញ្ចមេ គព្ភេ និបជ្ជិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ឈ្មួញ ទី ៥ បណ្ដាឈ្មួញ.ទ. ដប់នាក់ នឹងទិញ នូវកែវមណី ។*

*២. ក្នុងថ្ងៃ ទី ៣ អ្នកមានទ្រព្យ បួននាក់ នឹងឱ្យ នូវបិណ្ឌ.ទ. ដល់ស្មូម ១០០នាក់ ។*

*៣. ក្នុងសាលារៀន ទី ១ មាន សិស្ស.ទ. ៣០០នាក់ ។*

*៤. ឯង ជាសិស្ស ទី ១២ របស់ លោកគ្រូ នោះ ឬ?*

*៥. ភិក្ខុ.ទ. ៩៩រូប មកហើយ កាន់ផ្ទះ របស់ខ្ញុំ, ភិក្ខុ នុ៎ះ ជាអង្គ ទី ២៥ ។*

*៦. ខ្ញុំ នឹងឱ្យ នូវផ្កា.ទ. ពណ៌ក្រហម ដល់កញ្ញា ទី ២០ ។*

៧. តើនរណា ជាគ្រូ ទី ១ របស់អ្នក ?

៨. សិស្ស របស់ខ្ញុំ ទី ១ នឹងមក ជាមួយ សិស្ស ទី ២ ។

៩. សេនាបតី ទី ២ ស្លាប់ហើយ ក្នុងសង្គ្រាម ។

១០. ប្រសិនបើ ភិក្ខុ.ទ. ៣០រូប នោះ នឹងបានមកហើយ តាមផ្លូវ នេះ ភិក្ខុ.ទ.នោះ នឹងបានឃើញ នូវព្រះពុទ្ធ ។

១១. មាន សិក្ខាកាម ១៣០០នាក់ ក្នុងមហាវិទ្យាល័យ នេះ ។

១២. បណ្ដាភិក្ខុ.ទ. ៥០រូប ភិក្ខុ ទី ៥ ទៅហើយ កាន់វិហារ ។

**(ចប់មេរៀនទី ១៧)**

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| អ្នកសិក្សា | ប្រាជ្ញាចេះ | ចំណេះអ្វី |
| ត្រូវឃ្នាតខ្មី | ព្យាយាមរៀន | កុំអៀនអន់ |
| រៀនហើយរៀន | ហើយរៀនទៀត | ជានិរន្ដ៍ |
| រៀនទាល់តែ | ចេះគ្រប់គ្រាន់ | ប្រាកដអើយ! |

ដកស្រង់ពីសៀវភៅ "រៀនភាសាអង់គ្លេស ៦៣ ម៉ោងដោយខ្លួនឯង"
ទំព័រ១១៧ ដោយលោក **ឱម ណារត្រី**

# មេរៀនទី ១៨

## អធិប្បាយអំពីកិតកិរិយា

## (Participles)

*ពាក្យថា* **កិត** *សម្រេចមកពី* (**កិរ** *ធាតុ* + **ត**) *មានវិគ្គហៈថា* **ការិតំ កិរតិ អបនេតីតិ កិតំ** *ប្រែថា* (*បច្ច័យឯណា*) *រមែងកម្ចាត់នូវសេចក្តីសង្ស័យ(របស់សិស្ស)* *ព្រោះហេតុនោះ* (*បច្ច័យនោះ*) *ឈ្មោះថា* **កិត** *។ បើចុះ* **ក** *សកត្ថបច្ច័យមកទៀតបានរូបជា* **កិតក** *ដែលមាន ២ ប្រភេទគឺ*

១. *បើជា* **នាម** *ហៅថា* **នាមកិតក** *ឬ* **កិតនាម** (Derivative noun) ។

២. *បើជា* **កិរិយាស័ព្ទ** *ហៅថា* **កិរិយាកិតក** *ឬ* **កិតកិរិយា** (Participles) ។

## កិរិយាស័ព្ទមាន ៣ យ៉ាងគឺ

១. *អាខ្យាតកិរិយា ឬ កិរិយាអាខ្យាត* (Finite verbs)

២. *កិតកិរិយា ឬ កិរិយាកិតក* (Participles)

៣. *អព្យយកិតកិរិយា* (Indeclinable participles or Absolutive)

*អាខ្យាតកិរិយាបានអធិប្បាយចប់ហើយ សូមរកមើលសាឡើងវិញក្នុងមេរៀនខាងដើម ។ ក្នុងទីនេះនឹងអធិប្បាយអំពីកិរិយាកិតកបន្តិចម្តង ៗ ដូចមានតទៅនេះ*

# កិតកិរិយា ឬ កិរិយាកិតក

## គ្រឿងប្រកបរបស់កិតកិរិយា

(Elements of Participles)

*កិតកិរិយាមានគ្រឿងប្រកបសំខាន់ ៗ ៦ យ៉ាងគឺ* **ធាតុ, វិភត្តិ, វចន, កាល, វាចក, បច្ច័យ** ។

## អធិប្បាយគ្រឿងប្រកបដោយសង្ខេប

១. **ធាតុ** (Roots) *គឺដូចគ្នានឹងធាតុរបស់អាខ្យាតកិរិយាដែរដូចជា* **ឋា** *=ឈរ,* **គម** *=ទៅ,* **ចរ** *=ត្រាច់, ដើរ,* **សី** *=ដេក,* **ភុជ** *=ស៊ី,* **ធា***=ផឹក,* **ករ** *=ធ្វើ,* **ភាស** *=និយាយ,* **ចិន្ត** *=គិត ជាដើម ។*

២. **វិភត្តិ** (case endings) *ត្រូវប្រើវិភត្តិរបស់នាមទាំង ៨ វិភត្តិដូចបានពោលរួចហើយក្នុងមេរៀនខាងដើម ពីព្រោះកិតកិរិយាមិនមាន*

វិកត្តិដោយឡែកជារបស់ខ្លួនទេ ។ ប៉ុន្តែដល់ពេលប្រែមិនមានប្រើពាក្យអាយតនិបាតដូចនាមនាមទេ គឺប្រែទទេ ៗ ដូចគុណនាមដែរ ។

៣. **វចន** (Numbers) មាន ២ ដូចកិរិយាអាខ្យាតដែរគឺ ឯកវចនៈ និង ពហុវចនៈ ។

៤. **កាល** (Tenses) របស់កិរិយាកិតកមាន ៤ គឺ បច្ចុប្បន្នកាល, អតីតកាល, អនាអតកាល(មិនសូវមានទេ) ដូចកិរិយាអាខ្យាតដែរ និង អនុត្តកាល ។

៤.ក **បច្ចុប្បន្នកាល** (Present tense) ចែកជាពីរគឺ បច្ចុប្បន្នសុទ្ធ, បច្ចុប្បន្នជិតអនាគត ។

៤.ក.១ បច្ចុប្បន្នសុទ្ធ ត្រូវប្រែថា "កំពុង..., កំពុងតែ..." ដូចជា "កំពុងអង្គុយ, កំពុងតែស៊ី" ជាដើម ។

៤.ក.២ បច្ចុប្បន្នជិតអនាគត ត្រូវប្រែថា "កាល..., កាលនឹង..." ដូចជា "កាលធ្វើ, កាលនឹងពោល" ជាដើម ។

៤.ខ **អតីតកាល** (Past tense) ចែកជាពីរគឺ អតីតកាលកន្លងហើយមិនកំណត់ និង អតីតកាលកន្លងស្រេចហើយ ។

៤.ខ.១ អតីតកាលកន្លងហើយមិនកំណត់ ត្រូវប្រែថា "...ហើយ" ដូចជា "ទៅហើយ, ស៊ីហើយ" ជាដើម ។

៤.ខ.២ អតីតកាលកន្លងស្រេចហើយ ត្រូវប្រែថា "លុះ...ហើយ" ដូចជា "លុះចូលទៅជិតហើយ" ជាដើម ។

៤.គ **អនុត្តកាល** (Imperative tense) ចែកជាពីរគឺ អនុមតិ ១, បរិកប្ប ១ ។

៤.គ.១ **អនុមតិ** ត្រូវប្រែថា "គួរ..., គួរតែ..." ដូចជា "គួរស៊ី, គួរទៅ" ជាដើម ។

៤.គ.២ **បរិកប្ប** ត្រូវប្រែថា "គប្បី..., ត្រូវ..." ដូចជា "គប្បីស្ដាប់, ត្រូវធ្វើ" ។ល។

៤.ឃ រីឯ **អនាគតកាល** (Future tense) មានរូបដែរតែមិនសូវមានច្រើនទេ សូមមើលឧទាហរណ៍នៅខាងមុខ ។

៥. **វាចក** (Voices) មាន ៥ ដូចកិរិយាអាខ្យាតដែរគឺ កត្តុវាចក, កម្មវាចក, ភាវវាចក, ហេតុកត្តុវាចក, ហេតុកម្មវាចក ។

៦. **បច្ច័យ** (Suffixes) របស់កិតកិរិយាមាន ១០ តួចែកចេញជា ៣ ពួកដូចនេះ

ពួកទី ១ ហៅថា **កិតប្បច្ច័យ** មាន ៣ តួគឺ **អន្ត**, **តវន្តុ**, **តាវី** ។

ពួកទី ២ ហៅថា **កិច្ចប្បច្ច័យ** មាន ២ តួគឺ **តព្វ**, **អនីយ** ។

ពួកទី ៣ ហៅថា **កិតកិច្ចប្បច្ច័យ** មាន ៥ តួគឺ **មាន**, **ត**, **តូន**, **ត្វា**, **ត្វាន** ។

## ការចែកបច្ច័យតាមកាលនីមួយ ៗ

១. **អន្ត** និង **មាន** បច្ច័យប្រាប់ឱ្យដឹងថាជា **បច្ចុប្បន្នកាល** អាចហៅថា **បច្ចុប្បន្នកិតកិរិយា** (Present participles) ដូចជា **គច្ឆន្ត** = កំពុងទៅ, កាលទៅ, **បចមាន** =កំពុងចម្អិន, កាលចម្អិន ។

២. **អនីយ** និង **តព្វ** បច្ច័យប្រាប់ឱ្យដឹងថាជា **អនុត្តកាល** អាចហៅថា **អនុមត្តិកិតកិរិយា** (Potential participles) ដូចជា **ទាតព្វ** = គប្បីឱ្យ, គួរឱ្យ, **ករណីយ** =គប្បីធ្វើ, គួរធ្វើ, **ចានីយ** =គប្បីផឹក, គួរផឹក ។

៣. **ត**, **តវន្តុ**, **តាវី**, **តូន**, **ត្វា** និង **ត្វាន** បច្ច័យប្រាប់ឱ្យដឹងថាជា **អតីតកាល** ។ បច្ច័យ ៣ តួ **ត**, **តវន្តុ**, **តាវី** អាចហៅថា **អតីតកិត-កិរិយា** (Past participles) ដូចជា **គត** =ទៅហើយ, **សុតវន្តុ** =ស្តាប់ហើយ, **សុតាវី** =ស្តាប់ហើយ ។ បច្ច័យ ៣ តួទៀត **តូន**, **ត្វា**, **ត្វាន** អាចហៅថា **អព្យយកិតកិរិយា** (Indeclinable participles or Absolutive) ដូចជា **លភិត្វា** =បានហើយ, **កុញ្ជិត្វា** =ស៊ីហើយ, **កត្វាន** =ធ្វើហើយ, ជាដើម ។

## ការចែកបច្ច័យតាមវាចក:

១. **កិតប្បច្ច័យ** ៣ តួគឺ **អន្ត**, **តវន្តុ**, **តាវី** ជាគ្រឿងសម្គាល់ក្នុងវាចក:ពីរគឺ **កត្តុវាចក** និង **ហេតុកត្តុវាចក** ។

២. **កិច្ចប្បច្ច័យ** ២ តួគឺ **អនីយ, តព្វ** ជាគ្រឿងសម្គាល់ក្នុងវាចកៈបីគឺ **កម្មវាចក, ភាវវាចក** និង **ហេតុកម្មវាចក** ។

៣. **កិតកិច្ចប្បច្ច័យ** ៥ តួគឺ **មាន, ត, តវន្តុ, តុន, ត្វា, ត្វាន** ប្រើបានទាំងប្រាំវាចកៈ ។

អ្នកសិក្សាគប្បីចំណាំឱ្យបានច្បាស់លាស់ថា តើបច្ច័យណាជាវាចកៈអ្វី លុះដល់វេលាប្រែទើបប្រែបានល្អត្រឹមត្រូវ ។ រីឯវិធីប្រែរបស់វាចកៈនីមួយ ៗ គឺមានដំណើរដូចវាចកៈក្នុងអាខ្យាតកិរិយាដែរ ។

បច្ច័យនៃកិតកិរិយាទាំង ១០ តួនេះ បច្ច័យមួយ ៗ តួមានវិធីប្រកបរូបជាកិរិយាផ្សេង ៗ គ្នា ។ ក្នុងទីនេះនឹងអធិប្បាយអំពី **អន្ត, មាន** បច្ច័យមុនគេ ។ បច្ច័យពីរតួនេះអាចចុះជាមួយសកម្មធាតុក៏បានជាមួយអកម្មធាតុក៏បានដែរ ។

## បច្ចុប្បន្នកិតកិរិយា

( Present participles )

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ អន្ត បច្ច័យ

**អន្ត** បច្ច័យប្រើក្នុងវាចកៈ ២ គឺ **កត្តុវាចក** និង **ហេតុកត្តុវាចក** ដូចនឹងពោលតទៅនេះ

## ១. ចុះក្នុងកត្តុវាចក:

១.១ អន្ត បើចុះក្នុងកត្តុវាចក: ត្រូវតែចុះបច្ច័យប្រចាំពួកធាតុក្នុងអាខ្យាតកិរិយាសិនទើបចុះ អន្ត បច្ច័យ ដូចឧទាហរណ៍ខាងក្រោមនេះ

| ពួក | ធាតុ | +បច្ច័យ | + អន្ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|
| ១ | លភ | + អ | + អន្ត | > លភន្ត | កំពុងឬកាលបាន |
| ២ | ភុជ | + អ | + អន្ត | > ភុញ្ជន្ត | កំពុងឬកាលស៊ី |
| ៣ | ទិវ | + យ | + អន្ត | > ទិព្វន្ត | កំពុងឬកាលលេង |
| ៤ | សុ | + ណា | + អន្ត | > សុណន្ត | កំពុងឬកាលស្ដាប់ |
| ៥ | ចិ | + នា | + អន្ត | > ចិនន្ត | កំពុងឬកាលសន្សំ |
| ៦ | គហ | + ណ្ហា | + អន្ត | > គណ្ហន្ត | កំពុងឬកាលយក |
| ៧ | ករ | + ឱ | + អន្ត | > ករោន្ត | កំពុងឬកាលធ្វើ |

សូមចំណាំថា ចំពោះធាតុពួកទី ២ ត្រូវចុះនិគ្គហិតអាគមសិនទើបចុះបច្ច័យ និងធាតុពួកទី ៤, ៥, ៦ ត្រូវរស្សៈស្រៈ អា នៃបច្ច័យជា អ ។

១.២ ចំពោះធាតុខ្លះដែលជាស្រៈ ឥ, ឦ ត្រូវផ្លាស់ជា ឯ និងធាតុក្នុងពួកខ្លះដែលចុះ ឯ បច្ច័យ (ពួកនេះមិនបាច់ចុះបច្ច័យប្រចាំពួកទេ) ហើយនឹងធាតុពួកទី ៨ គឺពួក ចុរ ធាតុដែលចុះ ណេ បច្ច័យអាចមានរូបពីរយ៉ាងដូចខាងក្រោមនេះ

| ពួក | ធាតុ | +បច្ច័យ | +អន្ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|
| ១ | នី > នេ | + អ | + អន្ត | > នេន្ត | កំពុងឬកាលនាំទៅ |
| ៤ | ជិ > ជេ | + អ | + អន្ត | > ជេន្ត | កំពុងឬកាលឈ្នះ |
| ៨ | កាថ | + ឯ | + អន្ត | > កាថេន្ត | កំពុងឬកាលពោល |
| ២ | ធិន | + ឯ | + អន្ត | > ធិន្វេន្ត | កំពុងឬកាលកាត់ |
| ៨ | ចិន្ត | + ណេ | + អន្ត | > ចិន្តេន្ត | កំពុងឬកាលគិត |

(នេន្ត=នយន្ត, ជេន្ត=ជយន្ត, កាថេន្ត=កាថយន្ត, ធិន្វេន្ត=ធិន្វយន្ត, ចិន្តេន្ត=ចិន្តយន្ត) ។

១.៣ បំពោះធាតុខ្លះដែលជាស្រៈ ឧ, ឩ ត្រូវព្រឹទ្ធិជា អវ ដូចជា

| ធាតុ | +បច្ច័យ | សំរេចជា | ពាក្យប្រែ |
|---|---|---|---|
| ភូ > ភវ | + អ + អន្ត | > ភវន្ត | កំពុងឬកាលកើត |
| ចុ > ចវ | + អ + អន្ត | > ចវន្ត | កំពុងឬកាលស្លាប់ |
| មុ > មវ | + អ + អន្ត | > មវន្ត | កំពុងឬកាលចង់ |

១.៤ មានធាតុខ្លះប្រកបរូបតាមទំនើងខ្លួនដូចជា

| ធាតុ | ទៅជា | + បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ឋា | > តិដ្ឋ | + អន្ត | > តិដ្ឋន្ត | កំពុងឬកាលឈរ |
| ចា | > បិវ | + អន្ត | > បិវន្ត | កំពុងឬកាលផឹក |
| ឥស | > ឥច្ឆ | + អន្ត | > ឥច្ឆន្ត | កំពុងឬកាលប្រាថ្នា |

| | | | | |
|---|---|---|---|---|
| គម | > គច្ឆ | + អន្ត | > គច្ឆន្ត | កំពុងឬកាលទៅ |
| អស | > ស | + អន្ត | > សន្ត | កំពុងឬកាលមាន |
| ឥ | > ឯ | + អន្ត | > ឯន្ត | កំពុងឬកាលទៅ |
| យា | > យាយ | + អន្ត | > យាយន្ត | កំពុងឬកាលទៅ |

១.៥ ពួកកិរិយាស័ព្ទដែលប្រកបរូបដោយធ្វើអព្ភាសនិងពួកកិរិយាដែលប្រកបរូបពីនាមឬគុណនាមដូចបានសិក្សាក្នុងមេរៀនទី ១៥ នោះ អាចចុះ អន្ត បច្ច័យផ្ទាល់ដោយគ្រាន់តែលុប តិ វិភត្តិចេញដូចមានខាងក្រោមនេះ ។

| ធាតុ | ទៅជា | + បច្ច. | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| កាម | > ចង្ក័ម | + អន្ត | > ចង្ក័មន្ត | កំពុងឬកាលចង្រ្កម |
| វិ+កិត | > វិចិកិច្ឆ | + អន្ត | > វិចិកិច្ឆន្ត | កំពុងឬកាលសង្ស័យ |
| កិត | > តិកិច្ឆ | + អន្ត | > តិកិច្ឆន្ត | កំពុងឬកាលរក្សា |
| ធុម | > ធូមាយ | + អន្ត | > ធូមាយន្ត | កំ.ឬកាលបង្ហុយផ្សែង |
| បុត្ត | > បុត្តីយ | + អន្ត | > បុត្តីយន្ត | កំពុងឬកាលប្រព្រឹត្តថាដូចជាកូន |

## ២. ចុះក្នុងហេតុកត្តុវាចក:

**អន្ត** បើចុះក្នុងហេតុកត្តុវាចកៈពុំចាំបាច់មានបច្ច័យប្រចាំពួកធាតុជាប់មកជាមួយផងទេ ។ ប៉ុន្តែត្រូវចុះការិតប្បច្ច័យក្នុងអាខ្យាតកិរិយា ៤ តួគឺ **ណេ, ណយ, ណាបេ, ណាបយ** តួណាមួយសិនទើបចុះ **អន្ត** បច្ច័យ ។ បច្ច័យណាដែលមានតួ **ណ** វេលាផ្សំត្រូវលុបតួ **ណ** នោះចេញគ្រប់ ៗ កាល ហើយត្រូវទីឃៈស្រៈដើមធាតុជានិច្ច ។ ចូររកមើលក្នុងអាខ្យាតកិរិយាហេតុកត្តុវាចកៈក្នុងមេរៀនទី ១៦ ។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះ

**មរ** + **ណេ** + **អន្ត** > **មារេន្ត** =កំពុងឬកាលឱ្យស្លាប់, សម្លាប់ ។

**សុ** + **ណេ** + **អន្ត** > **សាវេន្ត** =កំពុងឬកាលឱ្យស្តាប់ (**ឧ** > **ឱ** > **អវ**) ។

**ករ** + **ណាបេ** + **អន្ត** > **ការាបេន្ត** =កំពុងឬកាលឱ្យធ្វើ ។

**ចុរ** + **ណាបយ** + **អន្ត** > **ចោរាបយន្ត** =កំពុងឬកាលឱ្យលួច ។

ធាតុឯទៀត ៗ ក៏មានវិធីផ្សំបែបនេះដែរ ។

## ៣. ចុះក្នុងកម្មវាចកៈ

ដូចបានពោលរួចហើយថា **អន្ត** បច្ច័យចុះបានតែក្នុងរូបជាកត្តុវាចកៈនិងហេតុកត្តុវាចកៈប៉ុណ្ណោះ តែក៏ឃើញមានប្រើជាកម្មវាចកៈខ្លះដែរដែលត្រូវចុះ **យ** បច្ច័យនិង **ឥ** អាគមផងដូចខាងក្រោមនេះ

| ធាតុ | អា. + | យ | + អន្ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|
| គហ | + ឥ + | យ | + អន្ត | > គណ្ហិយន្ត | កំពុងឬកាលយក |
| គម | + ឥ + | យ | + អន្ត | > គមិយន្ត | កំពុងឬកាលទៅ |
| ធា | + ឦ + | យ | + អន្ត | > ធីយន្ត | កំពុងឬកាលឱ្យ |
| យាច | + ឥ + | យ | + អន្ត | > យាចិយន្ត | កំពុងឬកាលសុំ |

## វិធីបំបែកកិរិយាកិតក:

សូមសង្កេតមើលកិតកិរិយាដែលសម្រេចហើយទាំងនេះ មានរូបស្រដៀងគ្នានឹងអាខ្យាតកិរិយាត្រង់បឋមបុរិសពហុវចនៈដែរ ខុសគ្នាតែត្រង់អាខ្យាតកិរិយាជា ន្តិ រីឯកិតកិរិយាជា ន្ត ប៉ុណ្ណោះ ។ កិរិយាស័ព្ទទាំងនេះមិនទាន់បំបែកជាមួយវិភត្តិនៅឡើយទេ ។

កិរិយាកិតកដែលប្រកបដោយ **អន្ត** បច្ច័យដូចពោលហើយនេះ មានទីបំផុតជា អ ការន្តដូច **បុរិស** និង **កុល** ហើយដែលជាបុំលិង្គនិងនបុំសកលិង្គ ។

១. បើប្រាថ្នាបំបែកជាបុំលិង្គត្រូវបំបែកតាមបែប **បុរិស** ឬ (**ភវន្ត** មានអធិប្បាយនៅខាងមុខ) គ្រប់វិភត្តិ ។

២. បើប្រាថ្នាបំបែកជានបុំសកលិង្គត្រូវបំបែកតាមបែប **កុល** គ្រប់វិភត្តិ ។

៣. បើប្រាថ្នាបំបែកជាឥត្ថីលិង្គត្រូវថែមស្រៈ ឦ ដែលជាគ្រឿងសម្គាល់ឥត្ថីលិង្គទៅជា **អន្តី** សិនទើបបំបែកតាមបែប **នារី** គ្រប់វិភត្តិ ។ ចូរមើលគំរូ **គច្ឆន្ត** =កំពុងទៅ, កាលទៅ ។

សូមសង្កេតមើលវិធីបំបែកខាងក្រោមនេះ

# វិធីបំបែក គច្ឆន្ត ជាបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គច្ឆន្តោ, (គច្ឆំ) | គច្ឆន្តា, (គច្ឆន្តោ) |
| ទុ. | គច្ឆន្តំ | គច្ឆន្តេ |
| ត. | គច្ឆន្តេន, (គច្ឆតា) | គច្ឆន្តេហិ, គច្ឆន្តេភិ |
| ច. | គច្ឆន្តស្ស, (គច្ឆតោ) | គច្ឆន្តានំ, (គច្ឆតំ) |
| បញ្ច. | គច្ឆន្តស្មា, គច្ឆន្តម្ហា, គច្ឆន្តា, (គច្ឆតា) | គច្ឆន្តេហិ, គច្ឆន្តេភិ |
| ឆ. | គច្ឆន្តស្ស, (គច្ឆតោ) | គច្ឆន្តានំ, (គច្ឆតំ) |
| ស. | គច្ឆន្តស្មឹ, គច្ឆន្តម្ហិ, គច្ឆន្តេ, (គច្ឆតិ) | គច្ឆន្តេសុ |
| អា. | គច្ឆន្ត, (គច្ឆំ, គច្ឆ, គច្ឆា) | គច្ឆន្តា, (គច្ឆន្តោ) |

## កំណត់សម្គាល់

១. ការបំបែកខាងលើនេះជាបុំលិង្គតែម្យ៉ាងដែលបំបែកតាមបែប **បុរិស** និង **ភវន្ត** ។ កិតកិរិយាទាំងឡាយដែលនៅក្នុងវង់ក្រចកទាំងឯក-វចនៈនិងពហុវចនៈបំបែកតាមបែប **ភវន្ត** ក្រៅពីនោះបំបែកតាមបែប **បុរិស** ។

២. ប្រសិនបើជានបុំសកលិង្គត្រូវបំបែកតាមបែប **កុល** គ្រប់វិភត្តិដែលមានរូបដូចក្នុងបុំលិង្គដែរ មានប្លែកតែត្រង់បឋមានិងទុតិយាវិភត្តិពហុវចនៈប៉ុណ្ណោះ ។

## វិធីបំបែក គច្ឆន្ត ជានបុំសកបុំលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គច្ឆំ | គច្ឆន្តានិ, គច្ឆន្តា |
| ទុ. | គច្ឆន្តំ | គច្ឆន្តានិ, គច្ឆន្តា |

៣. បើជាឥត្ថីលិង្គត្រូវថែមស្រៈ ឦ ឱ្យទៅជា **គច្ឆន្តី** សិនទើបបំ-បែកតាមបែប **នារី** ។

## វិធីបំបែក គច្ឆន្តី ជាឥត្ថីលិង្គ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គច្ឆន្តី | គច្ឆន្តិយោ, គច្ឆន្តី |
| ទុ. | គច្ឆន្តី | គច្ឆន្តិយោ, គច្ឆន្តី |
| ត. | គច្ឆន្តិយា | គច្ឆន្តីហិ, គច្ឆន្តីភិ |

(សល់ពីខាងលើនេះបំបែកតាមបែប **នារី** ទាំងអស់)

៤. កិតកិរិយាទាំងឡាយកាលបើប្រើជាសេចក្ដីបដិសេធត្រូវប្រើ **ន** និបាតស័ព្ទប្រាប់សេចក្ដីបដិសេធដែលប្រែថា "មិន" ដែរ តែមិនប្រើដូចអាខ្យាតកិរិយាដែលដាក់ **ន** នៅដាច់ដោយឡែកទេ គឺត្រូវសរសេរចូលគ្នាឬធ្វើសមាសជាមួយកិតកិរិយាដូចឧទាហរណ៍ខាងក្រោមនេះ

៤.១ កិតកិរិយាណាមានព្យញ្ជនៈនៅខាងដើមជាត្រូវផ្លាស់ **ន** > **អ** ដូចខាងក្រោមនេះ

**ករោន្តោ** ធ្វើបដិសេធទៅជា (**ន** > **អ** + **ករោន្តោ**) > **អករោន្តោ** ប្រែថា "កាលមិនធ្វើ ឬ មិនកំពុងធ្វើ" ។

**សុណន្តោ** ធ្វើបដិសេធទៅជា (**ន** > **អ** + **សុណន្តោ**) > **អសុណន្តោ** ប្រែថា "កាលមិនស្ដាប់ ឬ មិនកំពុងស្ដាប់" យ៉ាងនេះជាដើម ។

៤.២ កិតកិរិយាណាមានស្រៈនៅខាងដើមជា ត្រូវផ្លាស់ **ន** > **អន** ដូចខាងក្រោមនេះ

**ឥច្ឆន្តោ** ធ្វើបដិសេធទៅជា (**ន** > **អន** + **ឥច្ឆន្តោ**) > **អនិច្ឆន្តោ** ប្រែថា

"កាលមិនប្រាថ្នា ឬ មិនកំពុងប្រាថ្នា" យ៉ាងនេះជាដើម ។

## មហាកិរិយាស័ព្ទ និង អនុកិរិយាស័ព្ទ

១. **មហាកិរិយាស័ព្ទ** បានដល់កិរិយាស័ព្ទណាដែលនិយមរៀងដាក់នៅខាងចុងប្រយោគដើម្បីធ្វើការគ្រប់គ្រងប្រយោគ និងដែលធ្វើឱ្យប្រយោគនោះមានសេចក្ដីពេញលេញបាន គឺពួកអាខ្យាតកិរិយាគ្រប់វាចកៈដូចបានអធិប្បាយរួចហើយខាងដើម និងកិតកិរិយាខ្លះផងដែរ ដែលមានអធិប្បាយនៅខាងមុខដូចឧទាហរណ៍ខាងក្រោមនេះ

**អជ្ជ ឯកោ ជេកោ កសកោ ឯកំ មហន្តំ ខេត្តំ <u>កសតិ</u> ។**
ប្រែថា ក្នុងថ្ងៃនេះ កសិករ ដែលឈ្លាស មួយរូប <u>ភ្ជួរ</u> នូវស្រែ ធំ មួយ ។

ឧទាហរណ៍ខាងលើនេះបទថា **កសតិ** ជាអាខ្យាតកិរិយាមាននាទីគ្រប់គ្រងប្រយោគ ។

២. **អនុកិរិយាស័ព្ទ** បានដល់កិតកិរិយានានា លើកតែកិតកិរិយាណាដែលចុះ ត, តព្វ បច្ច័យដែលមានវិធីប្រើពិសេសមានអធិប្បាយនៅខាងមុខ ។ ហេតុដែលហៅថា អនុកិរិយាស័ព្ទ ពីព្រោះកិរិយាពួកនេះមិនអាចគ្រប់គ្រងប្រយោគបានទេ និងនិយមរៀងដាក់នៅទីណាមួយខាងក្នុងនៃប្រយោគប៉ុណ្ណោះ មិនអាចរៀងនៅចុងប្រយោគបានទេ ។ ដូច្នេះ វិធីលើកស័ព្ទប្រែត្រូវថែមលេខរៀងទៀតដូចតទៅនេះ

## ១. វិធីប្រែប្រយោគកត្តុវាចកៈ (ត)

*បទប្រធាន មានរូបជាបឋមាវិភត្តិ ........................................ប្រែទី ១ ។*
*បទវិសេសននៃបទប្រធាន.................................................ប្រែទី ២ ។*
**បទអនុកិរិយាស័ព្ទ** *មានរូបជាកិតកិរិយា ........................ប្រែទី ៣ ។*
*បទកម្មឬបទវិសេសនៈនៃអនុកិរិយាស័ព្ទ .............................ប្រែទី ៤ ។*
**បទមហាកិរិយាស័ព្ទ** *គឺអាខ្យាតកិរិយាកត្តុវាចកៈ ...........ប្រែទី ៥ ។*
*បទកម្មឬបទវិសេសននៃបទមហាកិរិយាស័ព្ទ ......................ប្រែទី ៦ ។*
*បទវិសេសននៃបទកម្ម ក្នុងរូបវិភត្តិនានា,គុណ,កិតកិរិយា ....ប្រែទី ៧ ។*

*ពាក្យថា "ក្នុងរូបវិភត្តិនានា" ទីនេះសំដៅដល់នាមស័ព្ទ ។*

## ឧទាហរណ៍នៃការប្រើជាអនុកិរិយាស័ព្ទ

**១. ពុទ្ធោ$_{១}$ ធម្មំ$_{៤}$ <u>ទេសេន្តោ</u>$_{៣}$ អនុបុព្វីកថំ$_{៦}$ កថេសិ$_{៥}$។**

*ព្រះពុទ្ធ <u>កាលសំដែង</u> នូវធម៌ (ទ្រង់)ត្រាស់ហើយ នូវអនុបុព្វីកថា ។*

**២. អហំ$_{១}$ មគ្គេ$_{៤}$ <u>ចរន្តោ</u>$_{៣}$ តស្មឹ$_{៧}$ រុក្ខេ$_{៧}$ <u>និសីទន្តំ</u>$_{៧}$ សកុណំ$_{៦}$ បស្សឹ$_{៥}$។** *ខ្ញុំ <u>កាលដើរ</u>$_{៣}$ តាមផ្លូវ$_{៤}$ ឃើញហើយ$_{៥}$ នូវបក្សី$_{៦}$ <u>កំពុងទុំ</u>$_{៧}$ លើដើមឈើ$_{៧}$ នោះ$_{៧}$ ។*

## កំណត់សម្គាល់

*១. បទកិតកិរិយាស័ព្ទវេលាប្រើក្នុងប្រយោគមានមុខងារ ២ យ៉ាង គឺ ជាគុណនាមក៏បាន ជាកិរិយាស័ព្ទក៏បាន ។ បើរៀងខាងក្រោយនាមបទជាប្រធានដូចក្នុងឧទាហរណ៍ទី ១ និងទី ២ នោះមាននាទីជាកិរិយាស័ព្ទឈ្មោះថា* **អនុកិរិយាស័ព្ទ** *ហៅតាមសម្ពន្ធថា* **អព្ភន្តរកិរិយា** *ប្រែថា* **កិរិយាក្នុងចន្លោះ** *ត្រូវប្រែបន្ទាប់បទនាមដែលជាបទប្រធាននិងប្រែមុនកិរិយាអាខ្យាតជានិច្ច ដូចមានក្នុងតារាងលើកស័ព្ទប្រែនៅខាងលើ ប៉ុន្តែមិនទៀតទាត់ជាដរាបទេ ។*

*២. ប៉ុន្តែបើរៀងខាងដើមបទនាមដែលជាម្ចាស់ដូចក្នុងប្រយោគទី ៣, ៤, ៥ នៅខាងក្រោម ទោះជាក្នុងរូបវិភត្តិអ្វីក៏ដោយ នោះមាននាទីជាគុណស័ព្ទវិញ ឈ្មោះថា* **គុណបទ** *ហៅតាមសម្ពន្ធថា* **បទវិសេសនៈ** *និងប្រសិនបើបំបែកក្នុងរូបវិភត្តិដទៃក្រៅពីបឋមាវិភត្តិ ច្រើនតែប្រែក្រោយកិរិយាអាខ្យាត ។*

*ម៉្យាងទៀត បទកិតកិរិយាក៏អាចមានបទកម្មឬបទដទៃទៀតជាបទវិសេសនៈផងដែរ ។*

## ឧទាហរណ៍នៃការប្រើជាគុណបទ

**៣. សោ$_{២}$ កុមារោ$_{១}$ រោទន្តិយា$_{៣}$ កុមារិយា$_{៣}$ ឯកំ$_{៦}$ បុប្ផំ$_{៦}$ ទទិ$_{៤}$។**

*កុមារ$_{១}$ នោះ$_{២}$ ឱ្យហើយ$_{៤}$ នូវផ្កា$_{៦}$ មួយទង$_{៦}$ ដល់កុមារី$_{៣}$ ដែលកំពុងយំ$_{៣}$។*

**៤. ឃរំ$_{២}$ <u>គច្ឆន្តោ</u>$_{២}$ កុមារោ$_{១}$ ឯកំ$_{៧}$ គោណំ$_{៦}$ អបស្សិ$_{៤}$។**

*ក្មេងប្រុស$_{១}$ <u>ដែលកំពុងដើរទៅ</u>$_{២}$ កាន់ផ្ទះ$_{២}$ បានឃើញហើយ$_{៤}$ នូវគោ$_{៦}$ មួយក្បាល$_{៧}$ ។*

**៥. វេជ្ជោ$_{១}$ ភត្តំ$_{៧}$ <u>បចេន្តេន</u>$_{៧}$ បុរិសេន$_{៦}$ សហ$_{៦}$ ភាសតិ$_{៤}$។**

*លោកគ្រូពេទ្យ$_{១}$ កំពុងនិយាយ$_{៤}$ ជាមួយ$_{៦}$ បុរស$_{៦}$ <u>ដែលកំពុងចម្អិន</u>$_{៧}$ នូវបាយ$_{៨}$ ។*

## ២. វិធីប្រែប្រយោគហេតុកត្តុវាចក: (ត)

*បទប្រធាន មានរូបជាបឋមាវិភត្តិ ........................................ ប្រែទី ១ ។*

*បទវិសេសន:នៃបទប្រធាន ................................................ ប្រែទី ២ ។*

**បទការិតកម្ម** *មានរូបជាទុតិយាឬតតិយាវិភត្តិ ................ ប្រែទី ៣ ។*

*បទវិសេសន.នៃបទការិតកម្ម................................................ ប្រែទី ៤ ។*

**បទអនុកិរិយាស័ព្ទ** *មានរូបជាកិតកិរិយា .......................... ប្រែទី ៥ ។*

*បទកម្មឬបទវិសេសននៃអនុកិរិយាស័ព្ទ ................................ ប្រែទី ៦ ។*

*បទមហាកិរិយាស័ព្ទ ជាអាខ្យាតកិរិយាហេតុកត្តុវាចក: ......... ប្រែទី ៧ ។*

**បទអវុត្តកម្ម** *មានរូបជាទុតិយាវិភត្តិ .................................. ប្រែទី ៨ ។*

*បទវិសេសន:នៃបទអវុត្តកម្ម................................................ ប្រែទី ៩ ។*

## ប្រយោគឧទាហរណ៍

**១. ភិក្ខុ$_{១}$ មហាជនំ$_{៣}$ ធម្មំ$_{៦}$ សាវេន្តោ$_{៥}$ តំ$_{៨}$ ទេសេតិ$_{៧}$។**

*វ.ភិក្ខុ ញុំាងមហាជន កាលឱ្យស្តាប់ នូវធម៌ ទើបសំដែង នូវធម៌នោះ ។*

**២. តយោ$_{២}$ បុរិសា$_{១}$ ឯកំ$_{៤}$ បុគ្គលំ$_{៣}$ កម្មំ$_{៦}$ ការេន្តំ$_{៥}$ មយ្ហំ$_{៩}$ ភោជនំ$_{៨}$ ភុញ្ជាបេសឹសុ$_{៧}$។**

*វ.ប្រុស.ទ. បីរូប ញុំាងបុគ្គល ម្នាក់ កាលធ្វើ នូវការងារ ឱ្យបរិភោគ នូវភោជន របស់ខ្ញុំ ។*

*បទថា* **ការេន្តំ** *ក្នុងប្រយោគទី ២ ដែលប្រែមុនកិរិយាអាខ្យាត ពីព្រោះជាអព្ភន្តរកិរិយារបស់បទការិតកម្ម* **បុគ្គលំ** *និងសូមជ្រាបថាវិធីលើកស័ព្ទប្រែដែលមានក្នុងតារាងខាងលើនេះ មិនកំណត់ថាត្រូវតែប្រែដូច្នេះគ្រប់ប្រយោគគ្រប់កន្លែងទេ ។ នេះគ្រាន់តែជាវិធីពិសេសក្នុងការរៀនប្រែប៉ុណ្ណោះ អាស្រ័យហេតុនេះសូមអ្នកសិក្សាស្វែងយល់ថែមពីលើនេះដោយខ្លួនឯងទៀតផង ។*

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ មាន បច្ច័យ

**មាន** *បច្ច័យនេះអាចចុះបានទាំង ៥ វាចកៈគឺ កត្តុវាចក, កម្មវាចក, ភាវវាចក, ហេតុកត្តុវាចក និង ហេតុកម្មវាចក ។ វាចកៈនីមួយ ៗ មានវិធីប្រកបដូចតទៅនេះ*

១. បើចុះក្នុងកត្តុវាចកៈត្រូវចុះបច្ច័យប្រចាំពួកធាតុក្នុងអាខ្យាតកិរិយាសិនទើបចុះ **មាន** ។ ធាតុខ្លះត្រូវផ្លាស់ប្តូរស្រៈស្រដៀងគ្នានឹង **អន្ត** បច្ច័យដែរ ។ សូមចំណាំថា ប្រសិនបើជា **ឯ** បច្ច័យនិងធាតុពួកទី ៨ និយមចុះ **អន្ត** ប្រើជាកត្តុវាចកៈដូចខាងក្រោមនេះ

(**កថ** + **ឯ** + **អន្ត**) > **កថេន្ត** =កំពុងឬកាលពោល ។

(**ចុរ** + **ណេ** + **អន្ត**) > **ចោរេន្ត** =កំពុងឬកាលលួច ។

| ធាតុ | + បច្ច័យ | + មាន | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ឆិទ | + (ំ) + អ | + មាន | > ឆិន្ទមាន | កំពុងឬកាលកាត់ |
| ទិវ | + យ | + មាន | > ទិព្វមាន | កំពុងឬកាលលេង |
| គហ | + ណ្ហា | + មាន | > គណ្ហាមាន | កំ.ឬកាលកាន់យក |
| សុ | + ណា | + មាន | > សុណាមាន | កំពុងឬកាលស្តាប់ |
| គុប | + ឆ | + មាន | > ជិគុច្ឆមាន | កំពុងឬកាលខ្ពើម |
| ករ | + ឱ | + មាន | > កុរុមាន | កំពុងឬកាលធ្វើ |
| ចុរ | + ណយ | + មាន | > ចោរយមាន | កំពុងឬកាលលួច |

(ចំពោះ **ករ** ធាតុផ្លាស់ **ឱ** > **ឧ** រួបផ្លាស់ **អ** នៃ **ក** ជា **ឧ** ទៅជា **កុរុ** + **មាន**) ។

២. ធាតុខ្លះមានរូបប្រែប្រួលដូចក្នុង **អន្ត** បច្ច័យដែរដូចខាងក្រោមនេះ

| ធាតុ | ទៅជា | + មាន | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| គេ | > គាយ | + មាន | > គាយមាន | កំពុងឬកាលច្រៀង |
| បា | > បិវ | + មាន | > បិវមាន | កំពុងឬកាលផឹក |
| ឥស | > ឥច្ឆ | + មាន | > ឥច្ឆមាន | កំពុងឬកាលប្រាថ្នា |
| គម | > គច្ឆ | + មាន | > គច្ឆមាន | កំពុងឬកាលទៅ |
| ហា | > តិដ្ឋ | + មាន | > តិដ្ឋមាន | កំពុងឬកាលឈរ |

៣. **មាន** បច្ច័យបើចុះក្នុងកម្មវាចកៈត្រូវចុះ **យ** បច្ច័យនិងចុះ **ឥ** អាគមលើទីបំផុតធាតុសិនទើបចុះ **មាន** បច្ច័យ ។ ចំពោះធាតុខ្លះកាលបើចុះ **យ** បច្ច័យហើយ ពុំចាំបាច់ចុះ **ឥ** អាគមក៏បាន ប៉ុន្តែត្រូវធ្វើសមានកម្មព្យញ្ជនៈទីបំផុតធាតុជាមួយនឹង **យ** បច្ច័យ (ចូររកមើលវិធីផ្លាស់ **យ** បច្ច័យនឹងទីបំផុតធាតុនៅក្នុងមេរៀនទី ១៤ ខាងដើម) ដូចមានឧទាហរណ៍តទៅនេះ

## ១. វិធីមានចុះ ឥ អាគម

| ធាតុ | + អា. | + យ | + មាន | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|
| ការ | + ឥ | + យ | + មាន | > ការិយមាន | កំពុងឬកាលធ្វើ |
| បូជ | + ឥ | + យ | + មាន | > បូជិយមាន | កំពុងឬកាលបូជា |
| ខណ | + ឥ | + យ | + មាន | > ខណិយមាន | កំពុងឬកាលជីក |
| ខាទ | + ឥ | + យ | + មាន | > ខាទិយមាន | កំពុងឬកាលស៊ី |

## ២. វិធីមិនមានចុះ ឥ អាគម

| | | | | |
|---|---|---|---|---|
| ធាតុ | + យ | + មាន | សម្រេចជា | ពាក្យប្រែ |
| បច | + យ | + មាន | > បច្ចមាន | កំពុងឬកាលចម្អិន |
| គម | + យ | + មាន | > គម្មមាន | កំពុងឬកាលទៅ |
| ទិស | + យ | + មាន | > ទិស្សមាន | កំពុងឬកាលឃើញ |
| ភណ | + យ | + មាន | > ភញ្ញមាន | កំពុងឬកាលពោល |

៤. មាន បច្ច័យមិននិយមប្រើជាភាវវាចក:ទេ ។

៥. មាន បច្ច័យបើចុះក្នុង ហេតុកត្តុវាចក: មានវិធីប្រកបរូបកិរិយាដូច អន្ត បច្ច័យដែលពោលរួចហើយខាងលើ ។ ធាតុខ្លះត្រូវចុះបច្ច័យប្រចាំពួកសិនទើបចុះការីតបច្ច័យ ប៉ុន្តែនិយមប្រើ **ណាយ**, **ណាបយ** ដោយច្រើនដូចខាងក្រោមនេះ

**បច + ណាយ + មាន > ចាចយមាន** =កំពុងឬកាលឱ្យចម្អិន ។

**វច + ណាយ + មាន > វាចយមាន** =កំពុងឬកាលឱ្យនិយាយ ។

**សុ + ណាយ + មាន > សាវយមាន** =កំពុងឬកាលឱ្យស្តាប់ ។

**ជិវ +យ+ណាបយ+មាន > ជិព្វាបយមាន** =កំពុងឬកាលឱ្យលេង ។

**យុជ+យ+ណាបយ+មាន > យុជ្ជាបយមាន**=កំពុងឬកាលឱ្យច្បាំង

**កី + ណាបយ + មាន > កីណាបយមាន**=កំពុងឬកាលឱ្យទិញ ។

ធាតុឯទៀត ៗ ក៏មានវិធីដូចគ្នានេះដែរ ។

៦. **មាន** បច្ច័យបើចុះក្នុង ហេតុកម្មវាចកៈ តោងចុះការីតបច្ច័យផងចុះ **យ** បច្ច័យនិង **ឥ** អាគមផងទើបចុះ **មាន** បច្ច័យ ។ មានធាតុខ្លះត្រូវចុះបច្ច័យប្រចាំពួកសិនទើបចុះការីតបច្ច័យ ដូចខាងក្រោមនេះ

**ភុជ+ ណាបេ + ឥ+ យ + មាន > ភុញ្ជាបិយមាន** កំពុងឬកាលឱ្យស៊ី
**រុធ+ ណាបេ + ឥ + យ + មាន > រុន្ធាបិយមាន** កំពុងឬកាលឱ្យបិទ
**ទិវ+ ណាបេ + ឥ + យ+ មាន> ទិព្វាបិយមាន** កំពុងឬកាលឱ្យលេង
**កី + ណាបេ + ឥ + យ + មាន > កីណាបិយមាន** កំពុងឬកាល-ឱ្យទិញ

ធាតុឯទៀត ៗ ក៏មានវិធីដូចគ្នានេះដែរ ។

ស្រៈ ឯ នៃ **ណាបេ** ត្រូវលុបចេញ ។

## កំណត់សម្គាល់

១. កិតកិរិយាដែលចុះ **មាន** បច្ច័យដូចបានរៀបរាប់នៅខាងលើនេះជា អ ការន្ត ។ មានវិធីបំបែកតាមវិភត្តិនានាដូច្នេះ បើជាបុំលិង្គបំបែកតាមបែប **បុរិស**, បើជានបុំសកលិង្គបំបែកតាមបែប **កុល**, បើជាឥត្ថីលិង្គត្រូវថែមស្រៈ **អា** សិនទៅជា **មានា** រួចទើបបំបែកតាមបែប **កញ្ញា** ។

២. កិតកិរិយាពួកនេះមានវិធីប្រើក្នុងប្រយោគដូច **អន្ត** បច្ច័យគ្រប់ប្រការ ។

*៣. បើប្រើក្នុងសេចក្តីបដិសេធត្រូវប្រើ* **ឧ** *ស័ព្ទដូច* **អន្ត** *បច្ច័យដែរ ប៉ុន្តែត្រូវផ្លាស់ជា* **អ** *ឬ* **អន** *តាមរបៀបដូចពោលហើយក្នុង* **អន្ត** *បច្ច័យ ដូចជា* **អភាសមាន** *=មិនកំពុងពោល, កាលមិនពោល,* **អនិច្ឆមាន** *= មិនកំពុងប្រាថ្នា, កាលមិនប្រាថ្នា យ៉ាងនេះជាដើម ។*

*៤. សូមចងចាំថាកិតកិរិយាដែលចុះ* **អន្ត** *និង* **មាន** *បច្ច័យនេះ ទោះបីជាមានរូបជាវិកត្តិអ្វីក៏ដោយ សូមប្រែថា "កំពុង..., កាល..." តែប៉ុណ្ណោះនិងអាចរៀងដាក់ខាងដើមឬខាងចុងបទប្រធានក៏បាន ។ បើរៀងដាក់ខាងដើមបទប្រធានក្នុងរូបជាគុណបទ ខាងសម្ពន្ធហៅថា បទវិសេសនៈ ។ វេលាប្រែជាភាសាខ្មែរពុំចាំបាច់ប្រែចេញអាយតនិបាតដូចនាមនាមទេ តាមភាសាសម័យបច្ចុប្បន្ននិយមនិយាយថា "ដែល..." ។ បើរៀងដាក់ខាងក្រោយនោះជា* **បទអនុកិរិយាស័ព្ទ** *ខាងសម្ពន្ធហៅថា* **អព្ភន្តរកិរិយា** *ត្រូវប្រែថា "កាល..." ។*

## ប្រយោគឧទាហរណ៍

១. កុមារា វនម្ហិ <u>កីឡមានា</u> បុប្ផានិ ឱចិនឹសុ ។

*កុមារ.ទ. <u>កាលលេង</u> ក្នុងព្រៃ បេះហើយ នូវផ្កាឈើ.ទ. ។*

២. តាយ កុមារិយា <u>វន្ទិយមានោ</u> បុរិសោ អាចរិយោ ហោតិ ។

*បុរស ដែលកុមារី នោះ <u>កំពុងសំពះ</u> ជាគ្រូ* (មាន) *។*

៣. **សេដ្ឋីនោ ភរិយា ទាសឹ អាហារំ <u>អាហរាបេតិ</u> មញ្ចេ និសីទតិ ។** *ភរិយា របស់សេដ្ឋី ញ៉ាំងទាសី <u>កាលឱ្យនាំមក</u> នូវអាហារ កំពុងអង្គុយ លើគ្រែ ។*

៤. **វាណិជេន ទាសេហិ អាបណម្ហា <u>កីណាបិយមានានិ</u> ភណ្ឌានិ ឥមស្មឹ អាគារេ តិដ្ឋន្តិ ។** *វីភ័ណ្ឌ.ទ. គឺពាណិជ ញ៉ាំងអ្នកបំរើ.ទ. <u>កាលឱ្យទិញ</u> ពីផ្សារ បិតនៅ ក្នុងអាគារ នេះ ។*

## សេចក្តីអធិប្បាយ

*១. សូមកុំច្រឡំរឿងវាចកៈរបស់ប្រយោគនិងវាចកៈរបស់កិតកិរិយា ។ ក្នុងឧទាហរណ៍ទាំង ៤ ខាងលើនេះមានកិរិយាអាខ្យាតជាកត្តុវាចកៈតែម៉្យាង រីឯកិតកិរិយាវិញខុស ៗ គ្នា គឺក្នុងប្រយោគទី ១ ជា* **កត្តុវាចកៈ** *។ ក្នុងប្រយោគទី ២ ជា* **កម្មវាចកៈ** *ពីព្រោះបទថា* **បុរិសោ** *រងនូវអំពើគឺកិច្ចសំពះរបស់កុមារី និងក្នុងប្រយោគទី ៣ ជា* **ហេតុកត្តុវាចកៈ** *ព្រោះបទថា* **ទាសី** *ត្រូវភរិយារបស់សេដ្ឋីបង្គាប់ឱ្យសម្រេចនូវកិច្ច ។ ចំណែកក្នុងប្រយោគទី ៤ ជា* **ហេតុកម្មវាចកៈ** *ពីព្រោះបទថា* **ភណ្ឌានិ** *ជាបទប្រធាននៃប្រយោគ បទថា* **ទាសេហិ** *ជាអ្នកសម្រេចនូវអំពើ ។ រីឯបទថា* **វាណិជេន** *គ្រាន់តែជាអ្នកបង្គាប់គេឱ្យធ្វើនូវកិច្ចការតែប៉ុណ្ណោះ ។*

*២.ចំណុចសំខាន់ដែលអ្នកសិក្សាគួរយល់ដឹងមួយទៀតគឺថាកិតកិរិយា*

ពួកនេះមិនមានបទប្រធានដោយឡែកទេ ដូចនៅក្នុងឧទាហរណ៍ទី ១ សឱ្យឃើញថា បទថា **កុមារា** មាននាទីជាបទប្រធាននៃបទកិតកិរិយា **កីឡមានា** ផងនិងមាននាទីជាបទប្រធានរបស់បទអាខ្យាតកិរិយាថា **ឧចិនឹសុ** ផងដែរ នេះចំពោះប្រយោគកត្តុវាចកៈ ។

៣. ប្រយោគដែលមានអនុកិរិយាស័ព្ទដូចជា **អន្ត**, **មាន** បច្ច័យតែងប្រើចំពោះអំពើណាដែលកើតមានក្នុងខណៈដំណាលគ្នា ។ ប្រយោគបែបនេះអាចចែកចេញជាពីរសង្កាត់គឺ **មហាប្រយោគ** ឬ ប្រយោគពេញន័យនិង អនុប្រយោគ ឬ ប្រយោគមិនពេញន័យ ដូចជាក្នុងឧទាហរណ៍ទី ១ **កុមារា វេឡុម្ហិ កីឡមានា បុប្ផានិ ឧចិនឹសុ** ។ អាចកាត់ញែកយក **កុមារា បុប្ផានិ ឧចិនឹសុ** ធ្វើជា **មហាប្រយោគ** និងយក **វេឡុម្ហិ កីឡមានា** ធ្វើជា **អនុប្រយោគ** ឬ **ប្រយោគជ្រែក** ។ ព្រោះហេតុដូច្នេះហើយទើបបទកិតកិរិយា **កីឡមានា** ត្រូវបានហៅ ថា **អនុកិរិយា** ឬ **កិរិយាជ្រែក** គឺជ្រែកចូលត្រង់ទីណាដែលគួរ ដើម្បីជួយអាខ្យាតកិរិយា និងធ្វើឱ្យប្រយោគមានសេចក្ដីវែងឆ្ងាយទៅបាន ។

៤. ម្យ៉ាងត្រូវចាំថាកិតកិរិយាពួក **អន្ត**, **មាន** បច្ច័យនេះមិនអាចតាំងនៅទីបំផុតនៃប្រយោគធ្វើជាមហាកិរិយាបានឡើយ សូមអ្នកសិក្សាជ្រាបតាមន័យខាងលើនេះផងចុះ ។

៥. ក្នុងសៀវភៅរៀនបាលីជាអង់គ្លេសហៅកិតកិរិយាដែលចុះ **អន្ត**, **មាន** នេះថា **បច្ចុប្បន្នកិតក** (Present participles) ដោយសារតែ

*បច្ច័យពីរតួនេះប្រើប្រាប់សេចក្ដីជាបច្ចុប្បន្នកាល ។*

*៦. ដូចបានពោលហើយថាកិតកិរិយាពួកនេះមិនសូវមានរូបជាអនាគតកាលទេ ។ ប៉ុន្តែមានប្រើខ្លះដែរដូចជា* **ជនោ កាម្មំ ការុមានោ** *ប្រែថា ជន កាលនឹងធ្វើ នូវការងារ* (**កាម្មំ ការុមានោ** = **កាម្មំ ការិស្សតិ**) ។ *ឬក៏ចុះ* **ស្សំ** *បច្ច័យក៏មានខ្លះដែលមានរូបស្រដៀងគ្នានឹងអាខ្យាតកិរិយាស័ព្ទដែរដូចឧទាហរណ៍ថា* **ភោជនំ កុញ្ជិស្សំ** *ប្រែថា កាលនឹងបរិភោគនូវភោជន ។*

| ធាតុ | + បច្ច័យ | កិតកិរិយា |
|---|---|---|
| បច | + ស្សំ | បចិស្សំ |
| មរ | + ស្សំ | មរិស្សំ |
| បច | + ស្សន្តុ | បចិស្សន្ត (*ផ្លាស់ ឧ ជា អ*) |
| មរ | + ស្សន្តុ | មរិស្សន្ត (*ផ្លាស់ ឧ ជា អ*) |

*៧. ជួនកាលស័ព្ទដែលចុះ* **អន្ត, មាន** *បច្ច័យក៏មានប្រើជានាមបានដែរដូចជា* **ន សមណោ ហោតិ បរំ <u>វិហេឋយន្តោ</u>** ។

*<u>អ្នកបៀនបៀន</u> អ្នកដទៃ មិនមែន ជាសមណៈទេ ។*

## នាមស័ព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ភេសជ្ជ នបុំ. | ថ្នាំ, ភេសជ្ជ | សប្បុរិស បុំ. | សប្បុរស |
| វេជ្ជ បុំ. | គ្រូពេទ្យ | មនុស្សលោក បុំ. | ឋានមនុស្ស |
| តុណ្ឌ នបុំ. | ចំពុះ | ទេវលោក បុំ. | ឋានសួគ៌ |
| សមណ បុំ. | អ្នកបួស | គីត នបុំ. | ការច្រៀង |
| លុទ្ទក បុំ. | ព្រានព្រៃ | អាលោក បុំ. | រស្មី, ពន្លឺ |
| សីហ បុំ. | តោ, សិង្ហ | លោចន នបុំ. | ភ្នែក, ចក្ខុ |
| សុនខ បុំ. | ឆ្កែ | រុក្ខមូល នបុំ. | គល់ឈើ |

## ធាតុសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| វិជ | បាញ់, ចាក់ | ឧប+សំ+កម | ចូលទៅជិត |
| យាច | សុំ | អា + កខ | ប្រាប្ទា |
| ឆិប | បោះចោល | ឧ + បជ | កើត |
| ភណ | និយាយ | ឧ + បត | ហើរ |
| បរិ+ឯស | ស្វែងរក | គេ > គាយ | ច្រៀង |
| អា+ហិឌ | ដើរត្រាច់ | ចុ > ចវ | ច្យុត, ស្លាប់ |
| បរិ + វរ | ហែហម | សី > សយ | ដេក |

## លំហាត់នៃមេរៀនទី ១៨

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើស័ព្ទដែលជាកិតក:មានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?
២. តើកិតកិរិយាមានបច្ច័យប៉ុន្មានតួ គឺអ្វីខ្លះ ?
៣. តើបច្ច័យណាខ្លះប្រើប្រាប់បច្ចុប្បន្នកាល ?
៤. តើបច្ច័យណាខ្លះប្រើប្រាប់អនុត្តកាល ?
៥. តើបច្ច័យណាខ្លះប្រើប្រាប់អតីតកាល ?
៦. តើ អន្ត, តវន្តុ, តាវី អាចប្រើក្នុងវាចក:អ្វីខ្លះ ?
៧. តើ អនីយ, តព្វ អាចប្រើក្នុងវាចកអ្វីខ្លះ ?
៨. តើ មាន, ត, តូន, ត្វា, ត្វាន អាចប្រើក្នុងវាចក:អ្វីខ្លះ ?
៩. តើអនុកិរិយាស័ព្ទជាកិរិយាដូចម្តេច ? សូមឱ្យឧទាហរណ៍ ។
១០. ប្រសិនបើចង់ធ្វើបដិសេធកិតកិរិយា តើត្រូវធ្វើដូចម្តេចខ្លះ ? សូមឱ្យឧទាហរណ៍ ។

### ខ. ចូរប្រែប្រយោគខាងក្រោមនេះជាភាសាខ្មែរ

១. កត្តំ បចន្តោ / បចមានោ បុរិសោ ហសតិ ។
២. វេជ្ជោ កត្តំ បចន្តំ / បចមានំ បុរិសំ បក្កោសតិ ។
៣. វេជ្ជោ កត្តំ បចន្តេន / បចមានេន បុរិសេន សហ ភាសតិ ។
៤. ពេនន្តោ ជារកោ កេសជ្ជំ បិវន្តោ មញ្ចម្ហា បតតិ ។
៥. វត្ថានិ ឥច្ឆន្តោ វាណិជោ អាបណំ គមិស្សតិ ។

៦. ឧបាសកា ឧបាសិកាយោ ច បទុមានិ អាហរន្តោ វិហារំ គច្ឆន្តោ ពុទ្ធំ បូជេន្តិ ។

៧. សកុណោ តុណ្ឌេន ផលំ ហរន្តោ រុក្ខម្ហា ឧប្បតតិ ។

៨. ចីវរំ បរិយេសន្តស្ស សមណស្ស អាចរិយោ ចីវរំ ទទាតិ ។

៩. អារញ្ញោ អាហិណ្ឌន្តោ លុទ្ទកោ សរេន ធាវន្តំ មិគំ វិជ្ឈតិ ។

១០. ឧយ្យានេ អហិណ្ឌមានម្ហា កុមារម្ហា ព្រាហ្មណោ បុប្ផានិ យាចតិ ។

១១. ធនានិ ទទមានា សីលានិ រក្ខមានា ច សគ្គេ ឧប្បជ្ជន្តិ ។

១២. ធញ្ញំ អាកង្ខន្តស្ស បុរិសស្ស ធនំ វាណិជោ ឥច្ឆតិ ។

១៣. វិហារំ ឧបសង្កមន្តោ ពុទ្ធោ ធម្មំ ភាសមានេ សាវកេ បស្សតិ ។

១៤. ឧទកំ ឥច្ឆន្តោ បរិយេសមានោ សីហោ វនម្ហិ ចរតិ ។

១៥. មគ្គេ សយន្តំ សុនខំ ឧទកេន សិញ្ចន្តោ ហសតិ ។

១៦. សីលំ រក្ខន្តា សប្បុរិសា មនុស្សលោកម្ហា ចវន្តា ទេវលោកេ ឧប្បជ្ជន្តិ ។

១៧. រុក្ខេសុ និសីទន្តា ផលានិ ភុញ្ជមានា កុមារា គីតំ គាយន្តិ ។

១៨. សុរិយស្ស អាលោកេន លោចនេហិ រូបានិ បស្សន្តា មនុស្សា លោកេ ជីវន្តិ ។

១៩. ខីរំ បិវន្តោ ហសមានោ ទារកោ បត្តំ មញ្ចស្មឹ ខិបតិ ។

២០. រុក្ខមូលេ និសីទន្តោ ចីវរំ សិព្វន្តេន សមណេន សទ្ធិំ
ឧបាសកោ ភាសតិ ។

គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. ក្មេង ដែលកំពុងទៅ កាន់ភូមិ ឃើញ និង ភ័យ ព្រោះគោ មួយ ។
២. ឈ្មួញ ដែលកំពុងលក់ នូវវត្ថុ.ទ. បានឃើញ មនុស្ស.ទ. កំពុងផ្ញួត
ទឹក ក្នុងទន្លេ ។
៣. កញ្ញា.ទ. ដែលកំពុងសើច ស្រែកហៅ ស្រី.ទ. ដែលកំពុងដើរ ។
៤. បុរស ដែលកំពុងស៊ី ផ្លែឈើ អង្គុយហើយ លើមែក ។
៥. ស្រី ដែលកំពុងយក នូវឱស ពីព្រៃ ផឹកហើយ នូវទឹក ។
៦. ខ្ញុំ កាលឈរ លើភ្នំ បានឃើញ សត្វចិញ្ចឹម.ទ. ដែលកំពុងស៊ី ស្មៅ
ក្នុងស្រែ ។
៧. បងស្រី របស់គេ កាលចម្អិន បាយ ច្រៀង នូវចម្រៀង ។
៨. សេដ្ឋី ដែលកំពុងឱ្យ នូវទាន ដល់ស្មូម.ទ. ឱ្យហើយ នូវទ្រព្យ របស់-
គាត់ ទាំងអស់ ។
៩. ក្មេងប្រុស ដែលកំពុងសើច ផង រត់ ផង កំពុងចូលទៅជិត ឪពុក ។
១០. កុមារ កាលលេង តាមផ្លូវ ឃើញហើយ នូវចោរ ដែលកំពុងរត់ ។

(ចប់មេរៀនទី ១៨)

# កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| ជាតិកូនប្រុស | ត្រូវប្រឹងប្រែង | ស្វែងតស៊ូ |
| មិនត្រូវថ្ងូរ | ឬនឿយណាយ | រសាយចិត្ត |
| យើងឃើញច្បាស់ | ដោយខ្លួនឯង | យ៉ាងតិច ៗ |
| គឺយើងគិត | ប៉ុនយ៉ាងណា | បានយ៉ាងនោះ ។ |
| ផលព្យាយាម | អាចសាងខ្លួន | ឱ្យរុងរោចន៍ |
| កើតប្រយោជន៍ | គឺលាភផល | ផ្តល់សក្តិយស |
| ចាំជួបជួន | នឹងជោគជ័យ | ល្បីកេរ្តិ៍ឈ្មោះ |
| កេរ្តិ៍ពិរោះ | រស់រីករាយ | សប្បាយអឺយ ។ |

ដកស្រង់ពីសៀវភៅ "រៀនភាសាអង់គ្លេស ៦៣ ម៉ោងដោយខ្លួនឯង"
ទំព័រ៣៩៣ ដោយលោក **ឌិម ណាត្រី**

# មេរៀនទី ១៩

## អធិប្បាយអំពីកិតកិរិយា (ត)

## អតីតកិតកិរិយា (Past participles)

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ ត បច្ច័យ

*ត បច្ច័យកាលបើចុះមកហើយ មានវិធីផ្លាស់ប្តូរធាតុពិស្តារជាង បច្ច័យឯទៀត ៗ ពីព្រោះវេលាចុះ ត បច្ច័យនៅទីបំផុតនៃធាតុណាមួយហើយ គឺមានអំណាចឱ្យផ្លាស់ទីបំផុតធាតុនោះទៅជារូបផ្សេង ៗ បាន ។ ប្រសិនបើចាំលទ្ធផលដែលសម្រេចរូបមកមិនបាន នឹងយកទៅប្រើមិនបានត្រឹមត្រូវទេ ធ្វើឱ្យមានមន្ទិលសង្ស័យ និងមិនដឹងថាមានន័យយ៉ាង-ម៉េច ។*

*ដំបូងបំផុតត្រូវចាំឱ្យបានច្បាស់ថា* ត *បច្ច័យបិតក្នុងពួកទី ៣ គឺ* ***កិច្ចប្បច្ច័យ*** *និងប្រើជា* ***អតីតកាល*** *តែម្យ៉ាងប្រែថា "......ហើយ" ។ ដូច្នេះ* ត *បច្ច័យអាចប្រើបានទាំង ៥ វាចកៈ វៀរតែហេតុកត្តុវាចកៈដែលមិនសូវមានប្រើ និងអាចប្រើជាអនុកិរិយាស័ព្ទ (កិរិយាស័ព្ទមិនពេញទី) ផងប្រើជាមហាកិរិយាស័ព្ទ(កិរិយាសព្ទ័ពេញទី)ដូចអាខ្យាតកិរិយាផងដែរ ។*

*ការប្រកបរូបជាកិតកិរិយាជាមួយ* ត *បច្ច័យពុំចាំបាច់ចុះបច្ច័យប្រចាំពួកធាតុដូច* **អ ន្ត**, **មាន** *បច្ច័យទេ ។*

*ការចុះ* ត *បច្ច័យជាមួយធាតុមានវិធីច្រើនយ៉ាងដូចនឹងអធិប្បាយ*

នៅខាងក្រោមនេះ ជាពិសេស **ត** បច្ច័យអាចប្រើបានទាំង ៥ វាចកៈ (វៀរតែហេតុកត្តុវាចកៈដែលពុំសូវមានប្រើ) ។ ចំពោះកត្តុវាចកៈឬកម្មវាចកៈនិងភាវវាចកៈមានរូបដូចគ្នា ។ យើងអាចសម្គាល់បានថាជាវាចកអ្វីនោះ គឺត្រូវមើលធាតុហើយនឹងសេចក្ដីក្នុងប្រយោគនោះ ៗ ដូចមានចំណុចសង្កេតតទៅនេះ ។

១. បើប្រកបរូបពី **អកម្មធាតុ** និង **សកម្មធាតុ**ខ្លះ ៗ ដែលអាចប្រើជាអកម្មធាតុ ដូចជា **គម, បត, ហា** នោះជា **កត្តុវាចកៈ** ។

២. បើប្រកបរូបពី **សកម្មធាតុ** នោះជា **កម្មវាចកៈ**និង**ហេតុកម្មវាចកៈ** ។ បើជា**កម្មវាចកៈ**មានចុះ **ឥ** អាគមជាគ្រឿងសម្គាល់ ។ រីឯជា**ហេតុកម្មវាចកៈ**ត្រូវចុះការីតបច្ច័យ ភាគច្រើននិយមប្រើ **ណាបេ** បច្ច័យនិងចុះ **ឥ** អាគមជាគ្រឿងសម្គាល់ ។

៣. បើជា **ភាវវាចកៈ** ប្រើតែជាមួយនឹងអកម្មធាតុនិងបំបែកជានបុំសកលិង្គតែប៉ុណ្ណោះ ។

៤. កិតកិរិយាដែលចុះ **ត** បច្ច័យនេះ មានន័យជាកម្មវាចកៈស្មើគ្នានឹងអាខ្យាតកិរិយាអតីតកាលកម្មវាចកៈដែរ ។ ដូច្នេះប្រសិនបើជាកត្តុវាចកៈត្រូវមានលិង្គ, វចនៈ, វិភត្តិ ដូចបទប្រធាន ។

**ត** បច្ច័យបើចុះក្នុងធាតុណាហើយមានការផ្លាស់ប្ដូររូបជាមួយនឹងទីបំផុតធាតុច្រើនយ៉ាង ។ ធាតុណាមួយក៏ដោយត្រូវតែយកទីបំផុតធាតុជាធំ ត្រូវមើលថាតើទីបំផុតធាតុនោះ ៗ ជាព្យញ្ជនៈអ្វី ត្រូវផ្លាស់ដូចម្ដេច

ដូចមានវិធីតទៅនេះ

១. ប្រភេទលុបទីបំផុតធាតុចេញ បើទីបំផុតធាតុជាអក្សរ ង ម រ បើចុះ ត បច្ច័យហើយត្រូវលុបទីបំផុតធាតុនោះ ៗ ចោលដូចខាងក្រោមនេះ

| ធាតុ + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ការ + ត | > កាត | ធ្វើហើយ |
| មរ + ត | > មត | ស្លាប់ហើយ |
| សរ + ត | > សត | រលឹកហើយ |
| ភរ + ត | > ភត | ចិញ្ចឹមហើយ |
| គម + ត | > គត | ទៅហើយ, ដល់ហើយ |
| រម + ត | > រត | រីករាយហើយ, ត្រេកអរហើយ |
| ខង + ត | > ខត | ជីកហើយ |
| ហាង + ត | > ហាត | សម្លាប់ហើយ |
| មង + ត | > មត | ដឹងហើយ |

❁ ធាតុខ្លះដែលមានទីបំផុតជា រ ក៏អាចផ្លាស់ ត > ដ បាន ហើយលុប រ ចេញដូចខាងក្រោមនេះ

| ធាតុ + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ហារ + ត | > ហាដ | នាំទៅហើយ |
| ការ + ត | > កាដ | ធ្វើហើយ |
| ភរ + ត | > ភដ | ចិញ្ចឹមហើយ |

២. ប្រភេទផ្លាស់ទីបំផុតធាតុជា ត

*បើទីបំផុតធាតុជាអក្សរ* ច ជ ទ ប *ត្រូវផ្លាស់ទីបំផុតធាតុនោះ ៗ ជា* ត *ហើយតម្រួតជា* ត្ត *ដូចខាងក្រោមនេះ*

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| វច | + ត | > វុត្ត | ពោលហើយ |
| វិ+វិច | + ត | > វិវិត្ត | ស្ងប់ហើយ |
| សិច | + ត | > សិត្ត | ស្រោចហើយ |
| ចជ | + ត | > ចត្ត | លះហើយ |
| កុជ | + ត | > កុត្ត | ស៊ីហើយ |
| បទ | + ត | > បត្ត | ដល់ហើយ |

៣. ប្រភេទផ្លាស់តួ ត ទៅជាព្យញ្ជនដទៃ*ហើយលុបទីបំផុតធាតុចេញដូចតទៅនេះ*

*៣.១ បើទីបំផុតធាតុជា* ទ *ត្រូវផ្លាស់* ត *បច្ច័យជា* ន្ន *ហើយលុប* ទ *ទីបំផុតធាតុចេញដូចខាងក្រោមនេះ*

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឆទ | + ត | > ឆន្ន | ប្រកហើយ, បាំងហើយ |
| ឆិទ | + ត | > ឆិន្ន | កាត់ហើយ |
| ភិទ | + ត | > ភិន្ន | បែកហើយ |
| រុទ | + ត | > រុន្ន | យំហើយ |

| | | | |
|---|---|---|---|
| សំ + សទ | + ត | > សំសន្ន | លិចហើយ |
| និ + សីទ | + ត | > និសិន្ន | អង្គុយចុះហើយ |

៣.២ បើទីបំផុតធាតុជាស្រៈក្រៅពី អ ត្រូវផ្លាស់ ត បច្ច័យទៅជា ណ ដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| លី | + ត | > លីណ | តោងហើយ |
| លុ | + ត | > លុណ | ច្រូតហើយ |
| ខី | + ត | > ខីណ | អស់ហើយ |
| ជី | + ត | > ជីណ | អស់ហើយ |

៣.៣ បើទីបំផុតធាតុជា រ ត្រូវផ្លាស់ ត បច្ច័យជា ឥណ្ណ ឬ ណ្ណ ហើយលុបទីបំផុតធាតុចេញដូចជាក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ជិរ | + ត | > ជិណ្ណ | ចាស់ហើយ |
| តរ | + ត | > តិណ្ណ | ឆ្លងហើយ |
| បូរ | + ត | > បុណ្ណ | ពេញហើយ |
| ចរ | + ត | > ចិណ្ណ | ត្រាច់ទៅហើយ |
| តុរ | + ត | > តុណ្ណ | ប្រញាប់ហើយ |
| ប + កិរ | + ត | > បកិណ្ណ | ពោយរាយហើយ |

៣.៤ បើទីបំផុតធាតុជា ធ ឬ ភ ត្រូវផ្លាស់ ត បច្ច័យជា ទ្ធ ហើយ លុប ធ ភ ទីបំផុតធាតុចេញដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| កុធ | + ត | > កុទ្ធ | ខឹងហើយ, ក្រោធហើយ |
| ពុធ | + ត | > ពុទ្ធ | ចេះហើយ, ដឹងហើយ |
| រុធ | + ត | > រុទ្ធ | បិទហើយ, បាំងហើយ |
| លភ | + ត | > លទ្ធ | បានហើយ |
| លុភ | + ត | > លុទ្ធ | លោភហើយ |
| អា+រភ | + ត | > អារទ្ធ | ប្រារព្ធហើយ |

៣.៥ បើទីបំផុតធាតុខ្លះជា ម ត្រូវផ្លាស់ ត បច្ច័យជា ន្ត ហើយ លុប ម ទីបំផុតធាតុចេញដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទម | + ត | > ទន្ត | ហ្វឹកហាត់ហើយ, ទូន្មានហើយ |
| ប+កាម | + ត | > បកាន្ត | ឈានហើយ, ចេញទៅហើយ |
| សម | + ត | > សន្ត | ស្ងប់ហើយ |
| ភម | + ត | > ភន្ត | វិលហើយ |

៣.៦ បើទីបំផុតធាតុជា ហ ត្រូវផ្លាស់ ត បច្ច័យជា ឡ្ហ ហើយ លុប ហ ទីបំផុតធាតុចេញដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| មុហ | + ត | > មុឡ្ហ | វង្វេងហើយ |
| រុហ | + ត | > រុឡ្ហ | ដុះឡើងហើយ |
| វុហ | + ត | > វុឡ្ហ | បណ្តែតហើយ, បន្សាត់ហើយ |
| លិហ | + ត | > លិឡ្ហ | លិឍហើយ |

៣.៧ បើទីបំផុតធាតុជា ស ត្រូវផ្លាស់ ត បច្ច័យជា ដ្ឋ ហើយលុប ស ទីបំផុតធាតុចេញដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| តុស | + ត | > តុដ្ឋ | ត្រេកអរហើយ |
| ទិស | + ត | > ទិដ្ឋ | ឃើញហើយ, |
| ប+វិស | + ត | > បវិដ្ឋ | ចូលទៅហើយ |
| ហស | + ត | > ហដ្ឋ | សើច, រីករាយហើយ |
| ឌស | + ត | > ឌដ្ឋ | ខាំហើយ, ទិចហើយ |
| កស | + ត | > កដ្ឋ | ភ្ជួរហើយ |
| រុស | + ត | > រុដ្ឋ | បៀតបៀនហើយ |
| ឃុស | + ត | > ឃុដ្ឋ | ប្រកាសហើយ |
| អា+កុស | + ត | > អក្កុដ្ឋ | ជេរ, បន្ទោសហើយ |
| ផុស | + ត | > ផុដ្ឋ | ប៉ះហើយ, ស្ទាបហើយ |
| ឥស | + ត | > ឥដ្ឋ | ចង់ហើយ, ប្រាថ្នាហើយ |

៣.៨ បើទីបំផុតធាតុជា ជ អាចផ្លាស់ ត បច្ច័យជា ដ្ឋ ខ្លះឬជា ក្ត ខ្លះហើយលុប ជ ទីបំផុតធាតុចេញដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| មជ | + ត | > មដ្ឋ | រំលីង, សម្អាតហើយ |
| ភជ, ភជ្ជ | + ត | > ភដ្ឋ | លីងហើយ |
| ភញ្ជ | + ត | > ភដ្ឋ | បាក់ឬបែកហើយ |
| ភញ្ជ | + ត | > ភក្ត | បាក់ឬបែកហើយ |
| សំ + វិជ | + ត | > សំវិក្ត | ស្ទុត, សង្វេកហើយ |
| សំ+មជ | + ត | > សមក្ត | ព្រមព្រៀងហើយ |

៨. ប្រភេទផ្លាស់ស្រៈ អា, អាចផ្លាស់ស្រៈ អា > ឥ ឬ ឦ បានដូចខាងក្រោមនេះ

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឋា | + ត | > ឋិត | ឈរហើយ, តាំងនៅហើយ |
| បា | + ត | > បិត, បីត | ផឹកហើយ |
| មា | + ត | > មិត | វាស់ហើយ |
| អភិ + ឈា | + ត | > អភិជ្ឈិត | សម្លឹងចំពោះហើយ(តម្រួត ជ្ឈ) |
| ហា | + ត | > ហីន | លះហើយ (ត > ន) |
| ទា | + ត | > ទិន្ន | ឱ្យហើយ (ត > ន្ន) |

៥. ប្រភេទផ្លាស់តាមទំនើង *គឺផ្លាស់ ត ទៅជារូបផ្សេង ៗ ដូចខាងក្រោម*

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| មុច | + ត | > មុត្ត | លែងហើយ |
| បច | + ត | > បត្ត | ចម្អិនហើយ |
| វស | + ត | > វុត្ថ | នៅហើយ |
| ជោរ | + ត | > ជោត | លាង, ជម្រះហើយ |
| បុច្ឆ | + ត | > បុដ្ឋ | សួរហើយ |
| វប | + ត | > វុត្ត | សាប, ព្រោះហើយ |

៦. ប្រភេទទុកទាំងស្រៈនិង ត បច្ច័យឱ្យគង់រូប *ទោះបីជាស្រៈអ្វីក៏ដោយដូចខាងក្រោមនេះ*

| ធាតុ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សុ | + ត | > សុត | ស្តាប់ហើយ |
| ជន > ជា | + ត | > ជាត | កើតហើយ |
| ញា | + ត | > ញាត | ដឹងហើយ |
| ភូ | + ត | > ភូត | កើតហើយ |
| ហុ | + ត | > ភូត | កើតហើយ |
| នី | + ត | > នីត | នាំទៅហើយ |
| ភី | + ត | > ភីត | ភ័យហើយ |

| | | | | |
|---|---|---|---|---|
| យា | + | ត | > យាត | ទៅហើយ |
| ជិ | + | ត | > ជិត | ឈ្នះហើយ |
| ចិ | + | ត | > ចិត | បេះហើយ |
| ឆហា, ឆ្ហា | + | ត | > ឆហាត, ឆ្ហាត | ង្វូតហើយ |
| ក្រី | + | ត | > ក្រីត | ទិញហើយ |
| ចុ | + | ត | > ចុត | ច្យុតហើយ, ស្លាប់ហើយ |

៧. ប្រភេទចុះ ឥ អាគមលើទីបំផុតធាតុនិងទុក ត ឱ្យគង់រូបដែលអាចចុះក្នុងធាតុណាមួយក៏បានដូចខាងក្រោមនេះ

| ធាតុ | + ឥ | + ត | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ភាស | + ឥ | + ត | > ភាសិត | ពោលហើយ |
| បច | + ឥ | + ត | > បចិត | ចម្អិនហើយ |
| កាស | + ឥ | + ត | > កាសិត | ក្អួរហើយ |
| បុច្ឆ | + ឥ | + ត | > បុច្ឆិត | សួរហើយ |
| កុជ | + ឥ | + ត | > កុញ្ជិត | ស៊ីហើយ |
| គហ | + ឥ | + ត | > គហិត | កាន់យកហើយ |
| ឃិស | + ឥ | + ត | > ឃេសិត | សំដែងហើយ |
| លិខ | + ឥ | + ត | > លិខិត | សរសេរហើយ |

## កំណត់សម្គាល់

១. ហុ ធាតុក្នុងន័យថា "កើតឬមាន" មិនមានកិតកិរិយាជារបស់ខ្លួនទេ ត្រូវប្រើ ភូត ដូច ភូ ធាតុដែរ ។

២. មានកិតកិរិយាខ្លះទៀត ផ្លាស់ប្តូររូបតាមទំនើងដែលមិនបាននាំមកបង្ហាញក្នុងទីនេះ ដូច្នេះសូមអ្នកសិក្សាមេត្តាកត់សម្គាល់ទុករាល់វេលាបានជួបខ្លួនឯងផងចុះ ។

៣. ស័ព្ទកិតកិរិយាដែលពោលហើយនេះ នៅពុំទាន់បំបែកតាមវិភត្តិនៅឡើយទេ ។ វេលាយកទៅប្រើក្នុងប្រយោគគប្បីបំបែកឱ្យមានលិង្គ, វចនៈនិងវិភត្តិស្មើនឹងនាមឬសព្វនាមដែលជាបទប្រធានជានិច្ច ។ បើជាបុំលិង្គត្រូវបំបែកតាមបែប **បុរិស** និងបើជានបុំសកលិង្គត្រូវបំបែកតាមបែប **កុល** ។ ប្រសិនបើជាឥត្ថីលិង្គត្រូវចុះស្រៈ **អា** សិនទើបបំបែកតាមបែប **កញ្ញា** ។

## រូបកិតកិរិយាក្នុងវាចកៈនីមួយ ៗ ទាំងបីលិង្គ

*កត្តុវាចកៈ* (រម + ត) > **រត** បុំ. **រតោ**, ឥ. **រតា**, នបុំ. **រតំ** =*រីករាយហើយ* ។

*កម្មវាចកៈ* (ជា + ត) > **ជិន្ន**, បុំ. **ជិន្នោ**, ឥ. **ជិន្នា**, នបុំ. **ជិន្នំ** =*ឱ្យហើយ*។

*ភាវវាចកៈ* (គម + ត) > **គត**, នបុំ. **គតំ** =*ទៅហើយ* ។

*ហេតុកម្មវាចកៈ* (ការ + ណាបេ + ត) > **ការាបិត**, បុំ. **ការាបិតោ**,
ឥ. **ការាបិតា**, នបុំ. **ការាបិតំ** =*ឱ្យធ្វើហើយ* ។

# វិធីប្រើកិតកិរិយា ត បច្ច័យក្នុងប្រយោគ

*កិតកិរិយាប្រកបនឹង ត បច្ច័យអាចប្រើបានច្រើនយ៉ាង*

*ក. ប្រើជាមហាកិរិយាស័ព្ទដូចអាខ្យាតកិរិយា ។*

*ខ. ប្រើជាបទវិកតិកត្តា ។*

*គ. ប្រើជាអនុកិរិយាស័ព្ទ ។*

*ឃ. ប្រើជាគុណបទឬបទវិសេសនៈ ។*

*ង. ប្រើជានាមនាម ។*

## ក. ប្រើជាមហាកិរិយាស័ព្ទ (កិរិយាពេញទី)

ក.១ ប្រើជាកត្តុវាចកកិរិយា

១. ឯកោ បុរិសោ នទឹ នហាណាយ គតោ ។

*បុរស មួយរូប ទៅហើយ កាន់ទន្លេ ដើម្បីងូត(ទឹក) ។*

២. អភិរូបា កញ្ញា អាគតា ។ *ស្រីក្រមុំ រូបស្អាត មកហើយ ។*

៣. អម្ពស្ស បុប្ផានិ បតិតានិ ។ *ផ្កា.ទ. នៃស្វាយ ជ្រុះហើយ ។*

ក.២ ប្រើជាកម្មវាចកកិរិយា

១. រាជា មហាជនេន មានិតោ។

*ព្រះរាជា គឺមហាជន រាប់អានហើយ ។*

២. ឯស មិគោ ព្យគ្ឃេន ភុញ្ជិតោ ។

*ម្រឹគ នុំះ គឺខ្លាធំ ស៊ីហើយ ។*

៣. ជម្មា ពុទ្ធេន <u>ទេសិតា</u> ។

*ធម៌.ទ. គឺព្រះពុទ្ធ សំដែងហើយ ។*

ក.៣ ប្រើជាតាវវាចកកិរិយា

១. បុគ្គលេន <u>គតំ</u> ។ *គឺបុគ្គល ទៅហើយ ។*

២. ជនកេន <u>មតំ</u> ។ *គឺឪពុក ស្លាប់ហើយ ។*

ក.៤ ប្រើជាហេតុកម្មវាចកកិរិយា

១. តេន បុរិសេន ទាសំ កម្មំ <u>ការាបិតំ</u> ។

*កម្ម គឺបុរស នោះ ញុាំងខ្ញុំបំរើ <u>ឱ្យធ្វើហើយ</u> ។*

២. កេនាយំ < (កេន + អយំ) ថូបោ <u>បតិដ្ឋាបិតោ</u> ។

*ស្តូប នេះ គឺអ្នកណា (ញុាំងបុគ្គល) ឱ្យប្រតិស្ឋានហើយ ?*

## ខ. ប្រើជាបទវិកតិកត្តា

*បើប្រើបែបនេះ និយមរៀងទុកខាងដើមនៃកិរិយាដែលជា "**អស, ហុ, ភូ**" ជាតុប្រែថា "មាន, ជា" នៅទីបំផុតនៃប្រយោគនិងជាកិរិយាស័ព្ទគ្រប់គ្រង ដោយគ្មានស័ព្ទរាំងត្រង់ចន្លោះ កិតកិរិយានេះទៀតសោតបានតែប្រកបរូបជា**បឋមា**និង**តតិយាវិភត្តិ**ប៉ុណ្ណោះ ដូចឧទាហរណ៍ខាងក្រោមនេះ*

**១. ឥទំ ធនំ បិតរា បុត្តស្ស <u>ទិន្នំ</u> ហោតិ ។**

*ទ្រព្យ នេះ (ជាវត្ថុ)គឺឪពុក<u>ឱ្យហើយ</u>ដល់បុត្រ ។*

**២. ឯតំ ទណ្ឌកម្មំ អាចរិយេន សិស្សានំ <u>កតំ</u> ហោតិ ។**

*ទណ្ឌកម្ម នុ៎ះ (ជាទោស)គឺគ្រូ<u>ធ្វើហើយ</u>ដល់សិស្ស.ទ. ។*

## កំណត់សម្គាល់

*វេលាប្រែកិតកិរិយាដែលប្រើជាវិកតិកត្តាត្រូវអានគួបជានិច្ច ។ ក្នុងឧទាហរណ៍ខាងលើនេះជាកម្មវាចកៈ ត្រូវអានគួបតាំងពីបទអនភិហិតកត្តារហូតដល់អាខ្យាតកិរិយា (អានគួបដូច្នេះបានតែក្នុងប្រយោគវិកតិកត្តានេះទេ) ។*

*ក្នុងឧទាហរណ៍ទី ១ ត្រូវអានគួបថា* **បិតរា-បុត្តស្ស-ទិន្នំ-ហោតិ** *(ប្រែថា) ជាវត្ថុដែលបិតាឱ្យហើយដល់បុត្រ ។*

*ឧទាហរណ៍ទី ២ ត្រូវអានគួបថា* **អាចរិយេន-សិស្សានំ-កតំ-ហោតិ** *(ប្រែថា) ជាទោសដែលគ្រូធ្វើហើយដល់សិស្ស.ទ. ។*

*ចំពោះអាខ្យាតកិរិយាមិនបាច់ប្រែក៏បានដែរ ។ ការប្រើពាក្យថា "ជាវត្ថុ, ជាទោស" នេះគឺអាស្រ័យពាក្យប្រែរបស់ធាតុថា "មាន ឬ ជា" គឺបញ្ចូលមកឱ្យត្រូវគ្នានឹងតួកត្តាក្នុងប្រយោគឱ្យសមទៅតាមរឿងនោះ ៗ ដើម្បីឱ្យមានសេចក្ដីជាប់ទាក់ទងគ្នាខាងសម្ពន្ធ ព្រោះអំណាចនៃវិកតិ-*

កត្តា ។ បើប្រែដាច់ពីគ្នាមួយបទ ៗ ដោយមិនអានគួបគ្នា សេចក្ដីក៏អាចនឹងបាត់ទៅមិនជាប់ទាក់ទងគ្នា ព្រោះថាមហាកិរិយាស័ព្ទគឺ **ហោតិ** ជាកិរិយាអាខ្យាតកត្តុវាចកប្រាប់បច្ចុប្បន្នកាល ។ រីឯកិតកិរិយា **ជិន្នំ**, **កាតំ** ជាវិកតិកត្តានិងជាកិតកិរិយាកម្មវាចកប្រាប់អតីតកាលទៅវិញ ករណីនេះហៅថា កម្មក្នុង-កត្តុក្រៅ ។

ការប្រើប្រយោគដូចបានពោលហើយនេះ ព្រោះតែកិរិយាអាខ្យាតកម្មវាចកៈមិននិយមប្រើជាអតីតកាល ច្រើនប្រើកិតកិរិយាជាកិរិយាមិនពេញទីជំនួសវិញ ។

សូមសង្កេតមើលក្នុងទីណាមានកិរិយាអាខ្យាតនៅផង កិរិយាអាខ្យាតនោះ ៗ ជាមហាកិរិយា គឺកិរិយាពេញទី ។ ចំណែកឯកិតកិរិយាវិញមាននាទីជាអនុកិរិយា គឺកិរិយាមិនពេញទី គ្រាន់តែជាកិរិយាជំនួយប៉ុណ្ណោះ ។ ប្រសិនបើក្នុងទីណាមិនមានអាខ្យាតកិរិយានៅផង គ្រានោះទើបកិតកិរិយាក្លាយជាមហាកិរិយា គឺកិរិយាគ្រប់គ្រងប្រយោគ ឧ.

**យោ$_{២}$ វោ$_{៦}$ អានន្ទ$_{០}$ ធម្មោ$_{១}$ ច វិនយោ$_{១}$ ច ទេសិតោ$_{៤}$ បញ្ញត្តោ$_{៤}$, សោ$_{១}$ វោ$_{៧}$ មមច្ចយេន$_{៨}$ សត្ថា$_{៦}$ (ភវិស្សតិ)$_{៤}$ ។**

ម្នាលអានន្ទ$_{០}$ ធម៌$_{១}$ ក្ដី វិន័យ$_{១}$ ក្ដី ឯណា$_{២}$ (គឺយើងតថាគត)$_{៣}$ សំដែងហើយ$_{៤}$ បញ្ញត្តហើយ$_{៤}$ ចំពោះអ្នក.ទ.$_{៦}$, (រីធម៌និងវិន័យ)នោះ$_{១}$ (នឹងជា$_{៤}$) សាស្ដា$_{៦}$ របស់អ្នក.ទ.$_{៧}$ ដោយកាលជាទីកន្លងទៅនៃយើង$_{៨}$ ។

(ម្នាលអានន្ទធម៌និងវិន័យដែលយើងតថាគតបានសំដែងនិងបញ្ញត្ត

*ទុកហើយ ធម៌និងវិន័យនោះនឹងជាសាស្តារបស់អ្នកទាំងឡាយក្នុងកាល ដែលអត់ពីតថាគតទៅ) ។*

*រឿងវិកតិកត្តាសូមរកមើលក្នុងមេរៀនទី ១០ សាឡើងវិញផង ។*

## គ. ប្រើជាអនុកិរិយាស័ព្ទ

១. ហីយោ អរញ្ញំ គតោ សោ បុរិសោ អហិនា ឌដ្ឋោ មរិ ។

*ម្សិលមិញ បុរស នោះ ទៅហើយ កាន់ព្រៃ គឺពស់ ចឹកហើយ ស្លាប់ហើយ ។*

២. បុរិសេន ផរសុនា ឆិន្នោ សោ រុក្ខោ តស្ស គេហស្ស ឧបរិ បតិ ។ *ដើមឈើ នោះ គឺបុរស កាត់ហើយ ដោយពូថៅ រលំហើយ លើ-ផ្ទះ របស់គាត់ ។*

*រឿងអនុកិរិយាស័ព្ទសូមរកមើលក្នុងមេរៀនទី ១៨ សាឡើងវិញផង ។*

## ឃ. ប្រើជាគុណបទឬបទវិសេសនៈ

១. តេ ពុទ្ធេន តេសិតំ ធម្មំ សុណឹសុ ។

*គេ.ទ. ស្តាប់ហើយ នូវព្រះធម៌ ដែលសំដែងហើយ ដោយព្រះពុទ្ធ ។*

២. ធារិយាយ អាហដានិ ភណ្ឌានិ អម្មា បិដកេសុ បក្ខិបិ ។

*ម្តាយ ដាក់ហើយ នូវអីវ៉ាន់ ក្នុងល្អី ដែលនាំមកហើយ ដោយកូនស្រី។*

៣. វាណិជា បតិតស្ស រុក្ខស្ស សាខាយោ ឆិន្ទិ ។

*ឈ្មួញ កាត់ហើយ នូវមែក នៃឈើ ដែលរលំហើយ ។*

**៤. ពុទ្ធោ អរហំ សម្មាសម្ពុទ្ធោ អហោសិ ។**

*ព្រះពុទ្ធ បានហើយ ជាព្រះអរហន្ត ជាអ្នកត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ។*

*ក្នុងឧទាហរណ៍ទី ៤ នេះ ពាក្យថា* **ពុទ្ធោ** *ប្រើជានាម ។*

## ង. ប្រើជានាមនាម

**១. សន្តំ តេសំ គតំ ឋិតំ ។**

*ការដើរ ការឈរ របស់គេ.ទ. ស្ងប់ហើយ ។*

**២. ភិក្ខុ អភិក្កន្តេ១ បដិក្កន្តេ២ សម្បជានការី ហោតិ អាលោកិតេ៣ វិលោកិតេ៤ សម្មិញ្ជិតេ៥ បសារិតេ៦ សង្ឃាដិបត្តចីវរធារណេ អសិតេ៧ បិតេ៨ ខាយតេ៩ សយតេ១០ ឧច្ចារបស្សាវកម្មេ គតេ១១ ឋិតេ១២ និសិន្នេ១៣ សុត្តេ១៤ ជាគរិតេ១៥ ភាសិតេ១៦ តុណ្ហីភាវេ ។**

*ភិក្ខុ ជាអ្នកធ្វើនូវការដឹងច្បាស់ ក្នុងការឈានទៅមុខ១ ក្នុងការឈានត្រឡប់២ ក្នុងការមើលនិងការមៀងមើល៤ ក្នុងការបំកោង៥ ក្នុងការសណ្ដូក៦ ក្នុងការទ្រទ្រង់នូវចីវរនិងបាត្រនិងសង្ឃាដី ក្នុងការស៊ី៧ ក្នុងការផឹក៨ ការទំពារស៊ី៩ ក្នុងការដេក១០ ក្នុងការបន្ទោរបង់នូវលាមកនិងមូត្រ ក្នុងការទៅ១១ ក្នុងការឈរ១២ ក្នុងការអង្គុយ១៣ ក្នុងការដេកលក់១៤ ក្នុងការភ្ញាក់១៥ ក្នុងការនិយាយ១៦ ហើយនឹងក្នុងការៈនៅ*

ស្បៀម ។

ក្នុងប្រយោគឧទាហរណ៍ទី ២ ខាងលើនេះ ពាក្យដែលគូសបន្ទាត់ខាងក្រោមជាកិតកិរិយាទាំងអស់ ប្រើក្នុងរូបជាសត្តមីវិភត្តិ ។

ពាក្យថា **សង្ឃាដិបត្តចីវរធរណេ** ជាកិតនាម រីឯ **ឧច្ចារបស្សាវកម្មេ** និង **តុណ្ហីភាវេ** ជាសមាសនាមដែលនឹងមានអធិប្បាយនៅខាងមុខ ។

## កំណាត់សម្គាល់

**ត** បច្ច័យបើប្រើក្នុងន័យបដិសេធគឺប្រើ **អ** ឬ **អន** ដូច **អន្ត** និងមាន បច្ច័យដែរដូចជា **អកត** =មិនធ្វើហើយ, **អជិច្ឆិត** =មិនប្រាថ្នាហើយ, ជាដើម ។

ក្នុងសៀវភៅសិក្សាបាលីជាភាសាអង់គ្លេសថាកិតកិរិយាដែលចុះ **ត** បច្ច័យនេះជា **អតីតកិតកិរិយា** (Past participles) ព្រោះតែបច្ច័យនេះប្រើប្រាប់សេចក្តីជាអតីតកាល ។

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| **សរណោ** នបុំ. | ទីពឹង, ទីរលឹក | **គាថា** ឥ. | គាថា |

| | | | |
|---|---|---|---|
| និរយ នបុំ. | នរក | ទ្វារកោដ្ឋកបុំ. | ក្លោងទ្វារ |
| មគធ បុំ | ដែនមគធៈ | សុចរិតនបុំ. | ការប្រព្រឹត្តល្អ |
| សក្ក បុំ. | ដែនសក្យៈ | មក្កដ បុំ. | ស្វា |
| អាពាធ បុំ. | ឈឺ, អាពាធ | កុក្កុដ បុំ. | មាន់ឈ្មោល |
| ធលិទ្ធ បុំ. | អ្នកក្រខ្សត់ | កុក្កុដី ឥ. | មាន់ញី |
| ចាដិ ឥ. | ក្អមទឹក, ផ្តាំង | ពិល នបុំ. | រន្ធ, រូង |
| បិចាសា ឥ. | ការស្រេក | សក្ខារា ឥ. | គ្រួស |
| សាសននបុំ. | ពាក្យប្រៀនប្រដៅ | ឆាយា ឥ. | ម្លប់,ស្រមោល |
| សុវច គុ. | ដែលប្រដៅងាយ | បច្ចយ បុំ. | បច្ច័យ |
| បិយ គុ. | ជាទីស្រឡាញ់ | ធណា បុំ. | មហោស្រប |

## លំហាត់នៃមេរៀនទី ១៩

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើកិតកិរិយាដែលចុះ ត បច្ច័យជាកាលអ្វីនិងប្រែដូចម្តេច ?

២. ប្រសិនបើប្រកបរូបពី អកម្មធាតុ តើជាវាចកៈអ្វី ?

៣. ប្រសិនបើប្រកបរូបពី សកម្មធាតុ តើជាវាចកៈអ្វីខ្លះ ?

៤. តើកិតកិរិយាដែលចុះ ត បច្ច័យអាចប្រើបានដូចម្តេចខ្លះ ? សូមឱ្យឧទាហរណ៍ ។

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. សោ តស្ស វណ្ណំ ភណមានោ មំ ឧបសង្កមិ ។

២. អហំ មគ្គេ គច្ឆន្តោ តស្មឹ រុក្ខេ និសិន្នំ សកុណំ បស្សឹ ។

៣. បរំ លោកំ គច្ឆន្តេន តយា កតំ បុញ្ញំ វា បាបំ វា តយា សទ្ធឹ គច្ឆតិ។

៤. ឋិតោ វា និសិន្នោ វា គច្ឆន្តោ វា សយន្តោ វា អហំ សព្វេសុ សត្តេសុ មេត្តំ ករោមិ ។

៥. រុក្ខស្មា ឱតិណ្ណា បក្ខី ទារកេន សក្ខរាហិ ហតា ហោន្តិ ។

៦. បុរិសេន ផរសុនា ឆិន្នោ សោ រុក្ខោ តស្ស គេហស្ស ឧបរិ បតិ។

៧. វាណិជេហិ នគរស្មា អាហដានិ ភណ្ឌានិ ឥមេសុ គាមេសុ មនុស្សេហិ កីតានិ ហោន្តិ ។

៨. ឯកេន ហត្ថិនា ឆិន្នំ សាខំ អញ្ញា ហត្ថិនិយោ តា គហិតា ខាទឹសុ ។

៩. កុតោ តុម្ហេហិ ឥមានិ វត្ថានិ តានិ បទុមានិ ច កីតានិ ?

១០. សប្បេន ទដ្ឋោ វាណិជស្ស បុត្តោ តស្ស ទាសេហិ ឯកស្ស វេជ្ជស្ស សន្តិកំ នីតោ ហោតិ ។

១១. ឥធ ឥមស្មឹ បីឋេ និសិន្នំ កុមារឹ គេហស្មា អាគតា អញ្ញា ទារិកា បហរិ ។

១២. តយា បហាជា សា កញ្ញា តស្សា មាតុយា សន្តិកំ គតា រោទន្តី អដ្ឋាសិ ។
១៣. មគ្គេ គច្ឆន្តា តេ បុរិសា តាយ ធេនុយា ភិន្នំ ឃដំ បស្សឹសុ ។
១៤. ពុទ្ធា ទេវេហិ ច មនុស្សេហិ ច បូជិតា ហោន្តិ ។
១៥. សាវកេហិ ច ឧបាសកេហិ ច បរិវារិតោ ពុទ្ធោ វិហារស្ស ឆាយាយ និសិន្នោ ហោតិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ស្វា ឡើងហើយ កាន់ដើមឈើ ភ័យហើយ ព្រោះព្រានព្រៃ ។*
*២. ក្មេង ប្រុស គឺពស់ ចឹកហើយ នាំទៅហើយ កាន់ផ្ទះ របស់គ្រូពេទ្យ ។*
*៣. បុរស ដែលមក អំពីស្រុក ដទៃ ទិញហើយ នូវអីវ៉ាន់ ពីផ្សារ នេះ ។*
*៤. ក្មេងប្រុស នោះ ស្ដាប់ហើយ នូវសំដី របស់ជីតា នឹងមិនទៅ កាន់ភ្នំ ទេ ។*
*៥. មេគោ.ទ. របស់មា ខ្ញុំ ចេញមកហើយ អំពីព្រៃ ទៅហើយ កាន់ផ្ទះ កំពុងស៊ី ស្មៅ.ទ. ។*
*៦. គហបតី ឃើញហើយ នូវបុរស ដែលកំពុងដេក ប្រាប់ហើយ ដល់-កូន របស់គាត់ កុំចូលទៅ ជិត ។*
*៧. បាយ គឺស្រីបំរើ ចម្អិនហើយ ឱ្យហើយ ដល់អ្នកក្រខ្សត់ ។*
*៨. អ្នកណា រមែងប្រព្រឹត្ត នូវអំពើល្អ គេ នឹងមិនទៅ កាន់នរក ទេ ។*

៩. កម្រងផ្កា គឺក្មេងស្រី បានហើយ ពីស្ដេចស្រី ឱ្យហើយ ដល់ស្រី ដទៃទៀត ។

១០. ព្រះពុទ្ធ យាងចូលហើយ កាន់វិហារ គឺឧបាសក.ទ. ឃើញហើយ។

១១. កសិករ កាត់ហើយ នូវមែក របស់ឈើ ដែលរលំហើយ ។

១២. ជ្រូក កំពុងដេក ក្នុងស្រែ ដែលភ្ជួរហើយ ដោយកសិករ ។

១៣. គេ.ទ. ស្ដាប់ហើយ នូវធម៌ ដែលព្រះពុទ្ធ សំដែងហើយ ។

១៤. យើង.ទ. បូជា ចំពោះព្រះពុទ្ធ ដោយបុប្ផា.ទ. ដែលប្រោះហើយ ដោយទឹក ។

១៥. ឥសី ចេញហើយ អំពីព្រៃ ទទួលហើយ នូវសំពត់ ពីសប្បុរស ទៅហើយ កាន់ភ្នំ ។

**(ចប់មេរៀនទី ១៩)**

# មេរៀនទី ២០

## អធិប្បាយអំពីកិតកិរិយា (ត)

## អព្យយកិតកិរិយា

(Indeclinable participles or Absolutive)

**អព្យយកិតកិរិយា** *បានដល់កិរិយាស័ព្ទដែលចុះអព្យយបច្ច័យ ៣ តួគឺ* **ត្វា ត្វាន តូន** *ហៅថា* **ត្វាទិបច្ច័យ** *ប្រែថាបច្ច័យមាន* **ត្វា** *ជាខាងដើម មកពី* **ត្វា** + (**អាទិ** =*ដើម*) *ទៅជា* **ត្វាទិ** ។

*បច្ច័យទាំង ៣ តួនេះសម្រាប់ចុះចុងធាតុរបស់អាខ្យាតទាំង ៨ ពួក ចុះជាមួយធាតុណាមួយក៏បាន ប្រែថា "....ហើយ" ដែរ (វៀរតែក្នុងករណីខ្លះដែលមានវិធីប្រែបានច្រើនយ៉ាង) និងជាកិរិយាប្រាប់អតីត-កាលតែម៉្យាង ប្រព្រឹត្តទៅបានពីរវាចកៈគឺកត្តុវាចកៈនិងហេតុកត្តុវាចកៈ (មានពោលនៅខាងមុខ) ។ ការហៅថាអព្យយកិតកិរិយានោះ ពីព្រោះកិរិយាដែលចុះត្វាទិបច្ច័យនេះ ពុំចាំបាច់បំបែកដូចនាមស័ព្ទឬកិរិយាអាខ្យាតឡើយគឺសម្រេចរូបបានមកយ៉ាងណាទុកឱ្យគង់រូបយ៉ាងនោះ ។ សូម្បីតែបទប្រធានមានវចនៈអ្វីក៏ដោយ ក៏អព្យយកិតកិរិយាគង់រូបដើមដដែល ខុសពី* **អន្ត មាន ត** *បច្ច័យដែលបានពោលរួចហើយ* ។

## ត្វាទិបច្ច័យ

**ត្វាទិបច្ច័យ** បានដល់បច្ច័យ ៣ តួក្នុងកិតកិច្ចប្បច្ច័យគឺ **ត្វា ត្វាន តូន** ប្រើចុះជាមួយធាតុណាក៏បាន សម្រេចបានជាអនុកិរិយានិងប្រាប់អតីតកាលតែម៉្យាង ត្រូវប្រែថា "...ហើយ" ជានិច្ច ។ បច្ច័យ ៣ តួនេះជាអព្យយបច្ច័យ ពីព្រោះពុំចាំបាច់បំបែកតាមវិភត្តិដូចបច្ច័យឯទៀតទេ ។ ត្វាទិបច្ច័យបីតួនេះអាចប្រើបានទាំងប្រាំវាចក: ប៉ុន្តែនិយមប្រើតែក្នុងពីរវាចក:គឺ កត្តុវាចក:និងហេតុកត្តុវាចក:ប៉ុណ្ណោះ ។

## វិធីចុះ ត្វាទិ បច្ច័យ

ការប្រកបរូបជាកិរិយាជាមួយត្វាទិបច្ច័យមានទំនងដូច **ត** បច្ច័យដែរ (ចូររកមើលក្នុងមេរៀនទី ១៩) ពីព្រោះជាបច្ច័យដែលជាប់ដោយតួ **ត** ដូចគ្នានិងមានអំណាចឱ្យផ្លាស់ធាតុទៅជារូបផ្សេង ៗ (**ប៉ុន្តែមិនដូចគ្នាសុទ្ធសាធទេ**) ។ ចំពោះ **តូន** មានប្រើតិចតួចទេ ។ រីឯ **ត្វា**, **ត្វាន** បច្ច័យពីរតួនេះមានប្រើជាច្រើន ក្នុងទីនេះសូមបង្ហាញតែ **ត្វា** បច្ច័យមួយទេ ដែលមានវិធីចុះបច្ច័យនេះក្នុងទីបំផុតធាតុដូចតទៅនេះ

### ក. អព្យយកិតកិរិយាជាកត្តុវាចក:

#### ក.១ ប្រភេទលុបទីបំផុតធាតុ,

បើធាតុ ២ តួ អាចលុបទីបំផុតធាតុចេញ, ខ្លះព្រឹទ្ធិស្រៈដើមធាតុផង(ពុំសូវមានទេ) ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ករ | + ត្វា | > កត្វា | ធ្វើហើយ |
| បទ | + ត្វា | > បត្វា | ដល់ហើយ |
| វទ | + ត្វា | > វត្វា | ពោលហើយ |
| ភុជ | + ត្វា | > ភោត្វា | ស៊ីហើយ |
| ឆិទ | + ត្វា | > ឆេត្វា | កាត់ហើយ |

ក.២ ប្រភេទព្រឹទ្ធិ ឬ រស្សៈស្រៈនៃធាតុមួយតួ *រួចទើបចុះ* ត្វា *បច្ច័យដូចឧទាហរណ៍ខាងក្រោមនេះ*

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| នី | + ត្វា | > នេត្វា | នាំទៅហើយ |
| ជិ | + ត្វា | > ជេត្វា | ឈ្នះហើយ |
| ទា | + ត្វា | > ទត្វា | ឱ្យហើយ |
| ឋា | + ត្វា | > ឋត្វា | ឈរហើយ |
| ញា | + ត្វា | > ញត្វា | ដឹងហើយ |
| ភី | + ត្វា | > ភិត្វា | ខ្លាចហើយ |
| សី | + ត្វា | > សយិត្វា | ដេកហើយ |
| ភូ | + ត្វា | > ភវិត្វា | មានហើយ |
| ឥ | + ត្វា | > ឯត្វា | ទៅហើយ |

**សយិត្វា** មកពីអាទេសៈស្រៈ ឦ នៃ **សី** ទៅជា ឯ > **អយ** សម្រេចជា **សយ** និងចុះ ឥ អាគម ។ រីឯ **ភវិត្វា** មកពីព្រឹទ្ធិស្រៈ ឩ នៃ **ភូ** ទៅជា ឱ > **អវ** សម្រេចជា **ភវ** និងចុះ ឥ អាគម ។

ក.៣ ប្រភេទផ្លាស់ស្រៈ **អា** ជា **ឥ** រួចទើបចុះ **ត្វា** បច្ច័យដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| **ចា** | + **ត្វា** | > **បិត្វា** | ផឹកហើយ |
| **ហា** | + **ត្វា** | > **ហិត្វា** | លះហើយ |

ក.៤ ប្រភេទចុះ ឥ អាគម, ធាតុភាគច្រើននិយមចុះ **ឥ** អាគម និង ធាតុខ្លះត្រូវចុះបច្ច័យប្រចាំពួកធាតុជាប់មកជាមួយផង ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ឥ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| **ការ** | + **ឥ** | + **ត្វា** | > **ការិត្វា** | ធ្វើហើយ |
| **លភ** | + **ឥ** | + **ត្វា** | > **លភិត្វា** | បានហើយ |
| **បច** | + **ឥ** | + **ត្វា** | > **បចិត្វា** | ចម្អិនហើយ |
| **គហ** | + **ឥ** | + **ត្វា** | > **គណ្ហិត្វា** | យកហើយ |
| **ភុជ** | + **ឥ** | + **ត្វា** | > **ភុញ្ជិត្វា** | ស៊ីហើយ |
| **កី** | + **ឥ** | + **ត្វា** | > **កីណិត្វា** | ទិញហើយ |

| | | | | |
|---|---|---|---|---|
| ជិ | + ឥ | + ត្វា | > ជិនិត្វា | ឈ្នះហើយ |
| ចិ | + ឥ | + ត្វា | > ចិនិត្វា | បេះហើយ |
| សុ | + ឥ | + ត្វា | > សុណិត្វា | ស្តាប់ហើយ |

ក.៥ ចំពោះធាតុពួក ចុរ ធាតុ ត្រូវចុះ ណេ បច្ច័យប្រចាំពួកសិនទើប ត្វាទិបច្ច័យ ពុំចាំបាច់ចុះ ឥ អាគមទេដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ណេ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ចិន្ត | + ណេ | + ត្វា | > ចិន្តេត្វា | គិតហើយ |
| ចុរ | + ណេ | + ត្វា | > ចោរេត្វា | លួចហើយ |
| មន្ត | + ណេ | + ត្វា | > មន្តេត្វា | ជ្រាបហើយ |
| និសិ | + ណេ | + ត្វា | > នេសេត្វា | សំដែងហើយ |
| កាថ | + ណេ | + ត្វា | > កាថេត្វា | ពោលហើយ |

ក.៦ ធាតុខ្លះអាចរក្សារូបដើមដដែល ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សុ | + ត្វា | > សុត្វា | ស្តាប់ហើយ |
| ហុ | + ត្វា | > ហុត្វា | កើតហើយ |
| ឆហា | + ត្វា | > ឆហាត្វា | ងូតហើយ |
| ហាន | + ត្វា | > ហន្ត្វា | សម្លាប់ហើយ |

ចំពោះ គម ធាតុផ្លាស់ទីបំផុតធាតុ ម > ង ដូច្នេះ

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| គម | + ត្វា | > គន្ត្វា | ទៅហើយ |

ចំពោះ ទិស ធាតុដែលប្រែថា "ឃើញ" ត្រូវផ្លាស់ ត្វា > ស្វា និង ត្វាន > ស្វាន ហើយលុបទីបំផុតធាតុចោលដូច្នេះ

| ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទិស | + ត្វា > ស្វា | > ទិស្វា | ឃើញហើយ |
| ទិស | + ត្វាន > ស្វាន | > ទិស្វាន | ឃើញហើយ |

## វិធីផ្លាស់ ត្វាទិបច្ច័យ ទៅជារូបផ្សេងៗ

ត្វាទិបច្ច័យក្នុងរូបជាកត្តុវាចក: អាចផ្លាស់ប្តូររូបទៅជារូបដទៃទៀតដោយច្រើនរូប ជាពិសេសចំពោះធាតុណាមានឧបសគ្គនាំមុខ ត្រូវផ្លាស់ ត្វាទិបច្ច័យជា យ (ក្នុងច្បាប់ខ្លះប្រាប់ថាជា យ បច្ច័យតែម្តង) ដូចតទៅនេះ

### ១. ប្រភេទផ្លាស់ ត្វា > យ

ធាតុណាមានឧបសគ្គនាំមុខត្រូវផ្លាស់ត្វាទិបច្ច័យជា យ ហើយ

ទុក យ ឱ្យគង់រូប ប្រសិនបើទីបំផុតធាតុជាស្រៈ អា ដូច ឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អា | + ធា | + ត្វា | > អាធាយ | យកហើយ |
| ប | + ហា | + ត្វា | > បហាយ | លះហើយ |
| អភិ | + ញា | + ត្វា | > អភិញ្ញាយ | ដឹងច្បាស់ហើយ |
| ឧ | + ឋា | + ត្វា | > ឧដ្ឋាយ | តាំងឡើងហើយ |
| និ | + សី | + ត្វា | > និស្សាយ | អាស្រ័យហើយ |
| ឧប + និ | + ធា | + ត្វា | > ឧបនិធាយ | ដំកល់មាំហើយ |
| បដិ + សំ | + ខា | + ត្វា | > បដិសង្ខាយ | ពិចារណាហើយ |

(និស្សាយ គឺផ្លាស់ស្រៈ ឦ នៃ សី ធាតុជា អា ហើយតម្រួត ស > ស្ស)

## ២. ប្រភេទធ្វើសមានកម្ម យ ជាមួយព្យញ្ជនៈទីបំផុតធាតុ

ជាតុដែលមានឧបសគ្គនាំមុខខ្លះ ឱ្យផ្លាស់ត្វាទិបច្ច័យជា យ សិនរួចទើបផ្លាស់ យ និងព្យញ្ជនៈផ្សេង ៗ នៃទីបំផុតធាតុឱ្យទៅជាដទៃដូចតទៅនេះ

២.១ បើទីបំផុតធាតុជា ឧ, អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ជ្ជ ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ឧ | + បទ | + ត្វា | > ឧប្បជ្ជ | កើតឡើងហើយ |
| ប | + មទ | + ត្វា | > បមជ្ជ | ប្រមាទហើយ |
| អា | + ឆិទ | + ត្វា | > អច្ឆិជ្ជ | ដណ្តើមយកហើយ |
| ឧ | + ភិទ | + ត្វា | > ឧព្ភិជ្ជ | បែកឡើងហើយ |
| និ | + សទ | + ត្វា | > និសជ្ជ | អង្គុយចុះហើយ |

២.២ ធាតុខ្លះមានទីបំផុតធាតុជា ជ អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ជ្ជ ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អា | + សជ | + ត្វា | > អាសជ្ជ | ជំពាក់ហើយ |
| វិ | + សជ | + ត្វា | > វិសជ្ជ | លះបង់ហើយ |

២.៣ បើទីបំផុតធាតុជា ក អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ក្ក ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អា | + រក | + ត្វា | > អារក្ក | ប្រារព្ធហើយ |
| | លក | + ត្វា | > លក្ក | បានហើយ |

២.៤ បើទីបំផុតធាតុជា ធ, ភ អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ទ្ធា ដោយពុំចាំបាច់មានឧបសគ្គទេ

(ពុំសូវមាន)ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + | ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| វិជ | + | ត្វា | > វិទ្ធា | ចោះហើយ |
| លភ | + | ត្វា | > លទ្ធា | បានហើយ |

❁ (វិជ និង លភ ធាតុ ២ តួនេះពុំចាំបាច់មានឧបសគ្គនាំមុខក៏អាចផ្លាស់ត្វាទិបច្ច័យជា យ បានដែរ) ។

២.៥ បើទីបំផុតធាតុជា ម អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ម្ម ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| អតិ | + កាម | + ត្វា | > អតិកាម្ម | ឈានទៅហើយ |
| អភិ | + រម | + ត្វា | > អភិរម្ម | រីករាយហើយ |
| អា | + គម | + ត្វា | > អាគម្ម | មកហើយ |
| និ | + ខម | + ត្វា | > និក្ខម្ម | ចេញទៅហើយ |
| ឧប | + គម | + ត្វា | > ឧបគម្ម | ចូលទៅហើយ |
| និ | + សម | + ត្វា | > និសម្ម | ពិចារណាហើយ |

២.៦ បើទីបំផុតធាតុជា ហ អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា យ្ហ ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| និ | + គហ | + ត្វា | > និគ្គយ្ហ | សង្កត់សង្កិនហើយ |
| ប | + គហ | + ត្វា | > បគ្គយ្ហ | ផ្គងហើយ |
| សំ | + នហ | + ត្វា | > សន្នយ្ហ | ចងហើយ |
| អា | + រុហ | + ត្វា | > អារុយ្ហ | ឡើងហើយ |

២.៧ បើទីបំផុតធាតុជា ច, ត អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ច្ច (ច្បាប់ខ្លះថាជា រច្ច បច្ច័យ, លុប រ ចេញទុកតែ ច្ច) ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| វិ | + វិច | + ត្វា | > វិវិច្ច | ស្ងាត់ហើយ |
| វិ | + បច | + ត្វា | > វិបច្ច | ឆ្អិនវិសេសហើយ |
| ឧ | + បត | + ត្វា | > ឧបច្ច | អណ្តែតទៅហើយ |
| សំ | + ចិត | + ត្វា | > សញ្ចិច្ច | ក្លែងហើយ |
| ឧប | + ឥ | + ត្វា | > ឧបេច្ច | ចូលមកជិតហើយ |
| អា | + ហន | + ត្វា | > អាហច្ច | ទង្គិចហើយ |
| សំ | + ករ | + ត្វា | > សក្កច្ច | ធ្វើល្អហើយ |

២.៨ ធាតុខ្លះ ៗ អាចផ្លាស់ ត្វា ទៅជា យ និងត្រូវតម្រួត យ ជា យ្យ ដូចឧទាហរណ៍ខាងក្រោមនេះ

| ឧបសគ្គ | + ធាតុ | + ត្វា | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| វិ | + នី | + ត្វា | > វិនេយ្យ | កំចាត់ហើយ |
| វិ | + ចិ | + ត្វា | > វិចេយ្យ | ពិនិត្យហើយ |
| អតិ | + សី | + ត្វា | > អតិសេយ្យ | ដេកហើយ |
| អភិ | + ភូ | + ត្វា | > អភិភុយ្យ | គ្របសង្កត់ហើយ |

២.៩ មានធាតុខ្លះផ្លាស់ប្តូរប្លែកពីធម្មតាដូចឧទាហរណ៍ខាងក្រោមនេះ

ឧ + កាតិ + ត្វា > ឧក្កាច្ច =ខ្វះហើយ (លុប តិ និង រ ចេញ)។

បដិ + មុច + ត្វា > បដិមុក្ក =ពាក់ហើយ (ច + យ > ក្យ) > ក្ក ។

វិ + លគ + ត្វា > វិលគ្គ =អាស្រ័យហើយ (គ + យ > គ្យ) > គ្គ ។

ប + អប្ប + ឱ + ត្វា > បប្បុយ្យ =ដល់ហើយ(ឱ > អ > ឧ, ត្រួត យ្យ)

បតិ + ខា + ត្វា > បច្ចក្ខាយ =ពោលលាហើយ (បតិ > បច្ច) ។

២.១០ ធាតុដែលមានទីបំផុតជា ស អាចផ្លាស់ ត្វា ទៅជា យ និងផ្លាស់ យ ជាមួយទីបំផុតធាតុទៅជា ស្ស ដូចឧទាហរណ៍ខាងក្រោមនេះ

ប + វិស + ត្វា > បវិស្ស = ចូលហើយ ។

ឧ + ទិស + ត្វា > ឧទ្ទិស្ស = ឧទ្ទិសហើយ ។

សូមរកមើលវិធីផ្លាស់ទីបំផុតធាតុជាមួយ យ បច្ច័យក្នុងមេរៀនទី ១៤ ថែមផង ។

## ខ. អព្យយកិតកិរិយាជាហេតុកត្តុវាចក:

*វិធីប្រកបរូបកិតកិរិយាជាហេតុកត្តុវាចក:ជាមួយត្វាទិបច្ច័យ ត្រូវចុះការិតបច្ច័យ ៤ តួគឺ* ណេ, ណយ, ណាបេ, ណាបយ *បច្ច័យណាមួយសិន ទើបចុះត្វាទិបច្ច័យនៅខាងចុង ។ ចំពោះ* ណយ, ណាបយ *ត្រូវចុះ* ឥ *អាគមលើ* យ *និងធាតុខ្លះត្រូវមានចុះបច្ច័យប្រចាំពួកធាតុផង ដូចខាងឧទាហរណ៍ក្រោមនេះ*

| *ធាតុ* | *+ការិតបច្ច័យ* | + ត្វា | *សម្រេចជា* | *ពាក្យប្រែ* |
|---|---|---|---|---|
| ករ | + ណេ | + ត្វា | > ការេត្វា | *ឱ្យធ្វើហើយ* |
| ករ | + ណាបេ | + ត្វា | > ការាបេត្វា | |
| ករ | + ណយ | + ត្វា | > ការយិត្វា | |
| ករ | + ណាបយ | + ត្វា | > ការាបយិត្វា | |
| ភុជ | + ណេ | + ត្វា | > ភោជេត្វា | *ឱ្យបរិភោគហើយ* |
| ភុជ | + ណាបេ | + ត្វា | > ភោជាបេត្វា | |
| ភុជ | + ណយ | + ត្វា | > ភោជយិត្វា | |
| ភុជ | + ណាបយ | + ត្វា | > ភោជាបយិត្វា | |
| សិវ | + ណេ | + ត្វា | > សិព្វេត្វា | *ឱ្យដេរហើយ* |
| សិវ | + ណាបេ | + ត្វា | > សិព្វាបេត្វា | |
| សិវ | + ណយ | + ត្វា | > សិព្វយិត្វា | |
| សិវ | + ណាបយ | + ត្វា | > សិព្វាបយិត្វា | |

| | | | | |
|---|---|---|---|---|
| គហ | + ណាបេ | + ត្វា | > គាហាបេត្វា | ឱ្យកាន់យកហើយ |
| គហ | + ណាបេ | + ត្វា | > គណ្ហាបេត្វា | |
| គហ | + ណាបយ | + ត្វា | > គាហាបយិត្វា | |
| គហ | + ណាបយ | + ត្វា | > គណ្ហាបយិត្វា | |
| សុ | + ណេ | + ត្វា | > សាវេត្វា | ឱ្យស្តាប់ហើយ (ព្រឹទ្ធិ ឧ នៃ សុ > ឱ > អវ) |
| សុ | + ណាបេ | + ត្វា | > សាវាបេត្វា | |
| សុ | + ណយ | + ត្វា | > សាវយិត្វា | |
| សុ | + ណាបយ | + ត្វា | > សាវាបយិត្វា | |

## កំណត់សម្គាល់

បច្ច័យដែលជាប់ដោយតួ ណ ត្រូវអនុវត្តដូចម្តេចខ្លះ សូមរកមើលក្នុងមេរៀនទី ១៦ ។ ធាតុឯទៀតគប្បីយកតាមលំនាំនេះដូចគ្នា ។

កិតកិរិយាដែលប្រកបឡើងដោយត្វាទិបច្ច័យនេះ ពុំចាំបាច់បំបែកតាមវិភត្តិណាមួយទេ គឺយកមកប្រើជាអនុកិរិយាបានតែម្តង ។

បើក្នុងសេចក្តីបដិសេធគឺប្រើ ន ប្រែថា "មិន" ដែលក្នុងករណីខ្លះត្រូវផ្លាស់ជា អ ឬ អន ដូចគ្នានឹងបច្ច័យនៃកិតកិរិយាឯទៀតដែលពោលរួចហើយនៅខាងដើមដែរ ដូចជា (ន > អ + កត្វា) > អកត្វា, (ន > អន + អាគម្ម) > អនាគម្ម ។ល។

# វិធីប្រើអព្យយកិតកិរិយាក្នុងប្រយោគ

ដូចបានសិក្សារួចមកហើយគឺថា  ប្រយោគនៃភាសាបាលីតែងតែរៀងកិរិយាស័ព្ទដែលជាអាខ្យាតកិរិយាឬកិតកិរិយា ដូចជា ត បច្ច័យនិងកិតបច្ច័យខ្លះទៀត(មានអធិប្បាយនៅខាងមុខ) ដែលជាកិរិយាគ្រប់គ្រង ដាក់នៅចុងនៃប្រយោគ ។

ប៉ុន្តែបើប្រយោគនោះ ៗ មានកិរិយាស័ព្ទច្រើនបទ គឺត្រូវប្រើកិត-កិរិយា ដែលជាអនុកិរិយាស័ព្ទដាក់ឱ្យជ្រែកចូលមកខាងក្នុងនៃប្រយោគ ត្រង់ទីណាមួយដែលគួរ  និងជាពិសេសអព្យយកិតកិរិយានោះមានប្រើច្រើនជាងគេ  ។  រីឯកិរិយាអាខ្យាតឬមហាកិរិយាវិញមានតែមួយបទទេ ដែលតែងតែឋិតនៅទីបំផុតនៃប្រយោគជានិច្ច ។

វិធីលើកស័ព្ទដើម្បីប្រែក្នុងប្រយោគដែលមានអនុកិរិយាស័ព្ទជ្រែកចូលមក សូមរកមើលក្នុងមេរៀនទី ១៨ ។

## ប្រយោគឧទាហរណ៍

១. កសកា$_{១}$ ខេត្តេ$_{៤}$ កម្មានិ$_{៤}$ ការិត្វា$_{៣}$ អត្តនោ$_{៧}$ គេហំ$_{៦}$ អគមឹសុ$_{៥}$។ កសិករ.ទ. ធ្វើហើយ នូវការងារ.ទ. ក្នុងស្រែ បានទៅហើយកាន់ផ្ទះ របស់ខ្លួន.ទ. ។

២. សព្វេ$_{២}$ សកុណា$_{១}$ បុព្វណ្ហេ$_{៤}$ អត្តនោ$_{៤}$ កុលាវកានិ$_{៤}$ និក្ខមិត្វា$_{៣}$ សកលំ$_{៤}$ ទិវសំ$_{៤}$ ចរិត្វា$_{៣}$ សាយណ្ហេ$_{៦}$ បដិនិវត្តន្តិ$_{៥}$។

*សត្វស្វាប.ទ. ទាំងពួង ចេញហើយ$_{៣}$ ចាកទ្រនំ.ទ. របស់ខ្លួន.ទ. ក្នុងវេលាព្រឹក ហើរទៅហើយ$_{៣}$ អស់ពេញមួយថ្ងៃ ទើបត្រឡប់មកវិញ ក្នុងពេលល្ងាច ។*

**៣. ឧបាសកា$_{១}$ អារាមំ$_{៤}$ គន្ត្វា$_{៣}$ ទានំ$_{៤}$ ទត្វា$_{៣}$ សីលំ$_{៤}$ សមាទយិត្វា$_{៣}$ សាលាយំ$_{៧}$ ធម្មំ$_{៦}$ សុណន្តិ$_{៨}$ ។** *ឧបាសក.ទ. ទៅហើយ កាន់វត្ត ប្រគេនហើយ នូវទាន សមាទានហើយ នូវសីល កំពុងស្តាប់ នូវធម៌ ក្នុងសាលា ។*

**៤. សោ$_{២}$ បុរិសោ$_{១}$ ទាសំ$_{៣}$ ខេត្តំ$_{៦}$ កសាបេត្វា$_{៥}$ តេន$_{៨}$ ទាសេន$_{៨}$ សទ្ធឹ អាគមិ$_{៧}$។** *បុរស នោះ ញ៉ាំងខ្ញុំបំរើ ឱ្យភ្ជួរហើយ$_{៥}$ នូវស្រែ មកហើយ$_{៧}$ ជាមួយ ខ្ញុំបំរើ នោះ ។*

## វិធីប្រែអព្យយកិតកិរិយាក្នុងករណីពិសេស

*កិតកិរិយាប្រកបដោយត្វាទិបច្ច័យជាទូទៅគឺប្រើជាអនុកិរិយាស័ព្ទ ប្រែថា "...ហើយ" និងត្រូវប្រែមុនអាខ្យាតកិរិយាជានិច្ច ដូចមានគំរូនៅខាងលើ ។ ប៉ុន្តែក្នុងករណីខ្លះ អាចប្រែក្រោយអាខ្យាតកិរិយាបាន ដែលលោកបានចាត់ជាវិធីប្រែមាន ៧ យ៉ាងគឺ បុព្វកាលកិរិយា, បរិយោសានកាលកិរិយា, សមានកាលកិរិយា, អបរកាលកិរិយា, ហេតុកាលកិរិយា, នាមវិសេសន និង កិរិយាវិសេសន ។*

១. ប្រើជា **បុព្វកាលកិរិយា** បានដល់បទកិរិយាដែលធ្វើនូវអំពើមួយរួចហើយទើបធ្វើអំពើដទៃទៀតបន្តបន្ទាប់គ្នា ត្រូវប្រែថា "...ហើយ" ត្រូវប្រែមុនអាខ្យាតកិរិយា ឧ.

**ឧបាសកោ ធម្មំ <u>សុត្វា</u> អត្តនោ គេហំ បច្ចាគច្ឆតិ ។**

ឧបាសក <u>ស្តាប់ហើយ</u> នូវធម៌ ត្រឡប់មកវិញ កាន់ផ្ទះ របស់ខ្លួន ។

(ចូរមើលប្រយោគគំរូខាងលើពីលេខ ១-៤ ក៏បាន)

២. ប្រើជា **បរិយោសានកាលកិរិយា** ត្រូវប្រែថា "លុះ...... ហើយ, លុះរួច......ហើយ" បានដល់បទកិរិយាដែលជាពាក្យច្រំដែលជាមួយនឹងអាខ្យាតកិរិយានៅខាងដើម ឧ.

**អានន្ទោ យេន ភគវា តេនុបសង្កមិ (តេន + ឧបសង្កមិ) <u>ឧបសង្កមិត្វា</u> ឯកមន្តំ និសីទិ ។**

ព្រះអានន្ទ គឺព្រះមានព្រះភាគ (ទ្រង់ប្រថាប់) ក្នុងទីណា ចូលទៅហើយកាន់ទីនោះ, <u>លុះចូលទៅជិតហើយ</u> អង្គុយហើយ ក្នុងទីដ៏សមគួរ។

៣. ប្រើជា **សមានកាលកិរិយា** បានដល់បទកិរិយាដែលធ្វើនូវអំពើព្រមពេលគ្នានឹងកិរិយាដទៃទៀត ពុំចាំបាច់ប្រែថា "......ហើយ" ទេ, ប្រែយកតែសេចក្តីរបស់ធាតុប៉ុណ្ណោះ ឧ.

**ឆត្តំ <u>គហេត្វា</u> គច្ឆតិ ។** (គេ) <u>កាន់</u>នូវឆ័ត្រដើរទៅ ។

លោកសំដៅដល់គេដើរកាន់ឆ័ត្របុដើរបាំងឆ័ត្រ ។

*វេលាប្រែត្រូវអានគួបអស់ទាំងប្រយោគរូបដោយអំណាចនៃអត្ថ។ បើប្រែថា "...ហើយ" សេចក្ដីក៏នឹងផ្លាស់ប្ដូរទៅជាបុព្វកាលកិរិយាតាមន័យរបស់លេខ ១ បានន័យថា (គេ)កាន់យកហើយ នូវឆ័ត្រ ទើបដើរទៅ ។*

*៤. ប្រើជា* **អបរកាលកិរិយា** *បានដល់បទកិរិយាដែលធ្វើអំពើក្រោយអាខ្យាតកិរិយា គឺប្រែក្រោយអាខ្យាតកិរិយាត្រូវប្រែថា "...ហើយ"*

**ឧ. ធម្មកថិកោ ធម្មាសនេ និសីទិ ចិត្តវីជនឹ <u>គហេត្វា</u> ។**

*ព្រះធម្មកថិក គង់ហើយ លើធម្មាសនៈ <u>កាន់យកហើយ</u> នូវផ្លិតដ៏វិចិត្រ ។*

*ឬដូចនៅក្នុងធម្មចក្កប្បវត្តនសូត្រត្រង់ទីបញ្ចប់ថា*

**..........អប្បមាណោ ច ឱឡារោ ឱភាសោ លោកេ បាតុរហោសិ <u>អតិក្កម្មេវ</u> ទេវានំ ទេវានុភាវំ ។** *ប្រែថា= ម៉្យាងទៀត ពន្លឺ ដ៏ក្រៃលែង* (**ឱឡារ**) *ដែលមិនមានប្រមាណ បានមានប្រាកដហើយ ក្នុងលោក <u>កន្លងហើយ</u> នូវទេវានុភាព នៃទេវតា.ទ. ។*

**(អតិ + កាម + ត្វា > អតិក្កម្ម) + ឯវ > អតិក្កម្មេវ**

*(ក្នុងទីនេះ* **ឯវ** *ស័ព្ទជាអដ្ឋានសម្បយុត្ត វេលាប្រែលោតប្រយោគត្រូវញែក* **ឯវ** *ស័ព្ទដាក់ខាងចុង* **ទេវានុភាវ** *ហើយត្រូវអានគួបគ្នាទាំងអស់ ហៅថាប្រែរូបដោយអំណាចនៃ* **ឯវ** *ស័ព្ទថា "ឈានកន្លងហើយ នូវទេវានុភាពនៃទេវតាទាំងឡាយ" ។*

៥. ប្រើជា **ហេតុកាលកិរិយា** បានដល់បទកិរិយាដែលមានបទប្រធានតួកត្តាទីទៃពីបទប្រធានរបស់មហាកិរិយាស័ព្ទដែលគ្រប់គ្រងប្រយោគនិងធ្វើនូវកិច្ចផ្សេងគ្នាពីអំពើរបស់បទប្រធាននៃប្រយោគហើយដែលមិនមែនជាអនុកិរិយាស័ព្ទរបស់ប្រធានផ្ទាល់ទេ ។ ក្នុងសេចក្ដីថាប្រយោគដូច្នេះ មានបទប្រធានពីរតួត្រូវប្រែថា "ព្រោះ..., ព្រោះតែ...." ប្រែក្រោយអាខ្យាតកិរិយា ។ កិរិយាគ្រប់គ្រងប្រយោគអាចជាអាខ្យាតកិរិយាឬកិតកិរិយាក៏បាន ឧ.

**សីហំ <u>ទិស្វា</u> ភយំ ឧប្បជ្ជតិ ។**

ភ័យ(សេចក្ដីខ្លាច) កើតឡើង <u>ព្រោះឃើញ</u> នូវសត្វសីហៈ ។

(ពាក្យថា "ឃើញ" ក្នុងទីនេះជាអំពើរបស់មនុស្ស) ។

**ឥទំ មេ ទុក្ខំ តុម្ហេ <u>និស្សាយ</u> ជាតំ ។**

សេចក្ដីព្រួយ នេះ កើតហើយ ដល់ខ្ញុំ <u>ព្រោះអាស្រ័យ</u> នូវអ្នក.ទ. ។

(**អព្យយកិតកិរិយាដែលប្រើដូច្នេះច្រើនជាភាវវាចកៈ**)

៦. ប្រើជា **នាមវិសេសន** សម្រាប់បំពេញសេចក្ដីឱ្យបទនាមមានលក្ខណៈជាគុណស័ព្ទ និងពុំចាំបាច់ប្រែថា "ហើយ" ទេ គឺប្រែត្រឹមតែសេចក្ដីរបស់ធាតុប៉ុណ្ណោះនិងប្រែក្រោយនាម ឧ.

**<u>បហេត្វា</u> ទ្វេ អគ្គសាវកេ អវសេសា អរហត្តំ បាបុណឹសុ ។**

ភិក្ខុដ៏សេស.ទ. <u>លើកទុក</u>(វៀរតែ) នូវអគ្គសាវក.ទ. ពីរូប ដល់ហើយ នូវអរហត្ត ។ (**បហេត្វា** ជានាមវិសេសនរបស់ **អវសេសា**) ។

**បបេត្វា អន្ន សរេ សេសា អក្ខរា កការាទយោ និគ្គហិ-តន្តា ព្យញ្ជនា នាម ហោន្តិ ។**

*អក្សរ.ទ. ដ៏សេស វៀរលែង នូវស្រៈ.ទ. ប្រាំបីតួ មានកអក្សរនៅខាងដើម មាននិគ្គហិតជាទីបំផុត ឈ្មោះថា ព្យញ្ជនៈ ។*

*៧. ប្រើជា* **កិរិយាវិសេសន** *សម្រាប់បំពេញសេចក្ដីឱ្យបទអាខ្យាតកិរិយា របៀបជាកិរិយាវិសេសន៍ ប្រែក្រោយអាខ្យាតកិរិយា និងពុំចាំបាច់ប្រែថា "ហើយ" ទេ ឧ.*

**តីណិ រតនានិ បបេត្វា អញ្ញំ មេ បដិសរណំ នត្ថិ ។**

*ទីពឹង ឯទៀត សម្រាប់ខ្ញុំ មិនមាន វៀរ នូវព្រះរតន.ទ. បី ។*

*ក្រៅពីនេះ* **អព្យយកិតកិរិយា** *នៅអាចប្រើជាមហាកិរិយាស័ព្ទគ្រប់គ្រងប្រយោគក៏បានដែរហៅថា* **កិរិយាបធានន័យ** *ដែលនឹងមានអធិប្បាយនៅខាងមុខ ។*

**នាមស័ព្ទ (ត)**

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| **អន្នទ** *បុំ.* | *អ្នកឱ្យនូវអាហារ* | **ខុទា** *ឥ.* | *សេចក្ដីឃ្លាន* |
| **អបវាទ** *បុំ.* | *ពាក្យតិទៀន* | **ជិឃ្ឆា** *ឥ.* | *អណ្ដាត* |
| **មហី** *ឥ.* | *ផែនដី, (ឈ្មោះ)* | **តុលា** *ឥ.* | *ជញ្ជីញ* |
| **វាលធិ** *បុំ.* | *កន្ទុយ* | **បទស** *បុំ.* | *ខ្ទុរ* |
| **អលិកវាទី** *បុំ.* | *អ្នកពោលពាក្យមិនពិត* | **ឧត្តាន** *គុ.* | *ផ្ងារ* |

## ធាតុស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ឱ + តរ | ចុះ, ឆ្លងចុះ | និ + ក្កម | ចេញទៅ |
| ឱ + រុហ | ចុះ | អា + រុហ | ឡើង |
| សំ + ហរ | បេះ(ផ្កា) | រវ | រង៉ាវ,ស្រែក |

## លំហាត់នៃមេរៀនទី ២០

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើអព្យយកិតកិរិយាប្រើបច្ច័យអ្វីខ្លះ ?

២. តើជាទូទៅកិរិយាដែលចុះត្វាទិបច្ច័យមានពាក្យប្រែដូចម្ដេច ?

៣. តើអព្យយកិរិយាមានវិធីប្រើបែបពិសេសប៉ុន្មានយ៉ាង ?

៤. បើប្រើជាបុព្វកាលកិរិយាត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

៥. បើប្រើជាហេតុកាលកិរិយាត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

៦. បើប្រើជាសមានកាលកិរិយាត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍។

៧. បើប្រើជាអបរកាលកិរិយាត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

៨. បើប្រើជាបរិយោសានកាលកិរិយាត្រូវប្រែដូចម្ដេច ?
សូមឱ្យទាហរណ៍ ។

៩. បើប្រើជានាមវិសេសនៈត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

១០. *បើប្រើជាកិរិយាវិសេសនៈត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។*

## *ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. គាមម្ហា និក្ខន្តា តា គាវិយោ ខេត្តេ តិណំ ខាទិត្វា វាបិម្ហា ជលំ បិវិស្សន្តិ ។

២. វានរា រុក្ខំ អារុយ្ហ ផលានិ ខាទន្តិ ។

៣. ទារកោ ភត្តំ យាចិត្វា រោទតិ ។

៤. សាវកោ អាសនម្ហិ និសីទិត្វា ចាទេ ធោវតិ ។

៥. ទារកា បុប្ផានិ សំហរិត្វា មាតុលស្ស ទត្វា ហសន្តិ ។

៦. យាចកា ឧយ្យានម្ហា អាគម្ម កស្សកម្ហា ឱទនំ យាចន្តិ ។

៧. លុទ្ទកោ ហត្ថេន សរេ អាទាយ អរញ្ញំ បវិសតិ ។

៨. ទារកោ អាវាដម្ហិ បតិត្វា រោទតិ ។

៩. បុត្តោ នហាត្វា ភត្តំ ភុត្វា មញ្ចេ អារុយ្ហ សយតិ ។

១០. អសប្បុរិសោ យាចកស្ស បត្តំ ភិន្ទិត្វា អក្កោសិត្វា គេហំ គច្ឆតិ ។

១១. ឯកស្មឹ សមយេ អញ្ញតរោ ទេវោ រត្តិយំ ពុទ្ធំ ឧបសង្កមិត្វា សទ្ធាយ វន្ទិត្វា ភូមិយំ អដ្ឋាសិ ។

១២. នារិយោ ឱទនំ បចិត្វា ភុញ្ជិត្វា កុក្កុដីនម្បិ អទំសុ ។

១៣. សីហី មិគី មារេត្វា សុសូនំ ទទិស្សតិ ។

១៤. កាកី តរុណោ សាខាសុ និសីទិត្វា រវិត្វា អាកាសំ

ឧគ្ឃោស្សន្តិ ។

១៥. សប្បុរិសោ កុមារស្ស កុក្កុរេន សទ្ធឹ កីឡិត្វា សមុទ្ទំ គន្ត្វា ជហាយន្តិ ។

១៦. ជារកោ គេហា និក្ខម្ម មាតុលា បក្កោសិត្វា គេហំ បវិសតិ ។

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ព្រះពុទ្ធ និង សាវ័ក.ទ. គឺទេវតា.ទ. និង មនុស្ស.ទ. បូជាហើយ ។*

*២. ឈ្មួញ លក់ហើយ នូវសំពត់.ទ. ដែលដេរហើយ ដោយស្រី.ទ. ។*

*៣. លោកគ្រូ ឃើញហើយ នូវអំពើមិនល្អ គឺក្មេងស្រី ប្រព្រឹត្តហើយ ឱ្យហើយ នូវឱវាទ ដល់នាង ។*

*៤. បុរស កាត់ហើយ នូវវល្លិ.ទ. ទាញហើយ ពីដើមឈើ ។*

*៥. វីបុរស ម្នាក់ នោះ លះបង់ហើយ នូវផ្ទះ របស់គាត់ បួសហើយ ។*

*៦. ភិក្ខុ គឺឧបាសក សួរហើយ នូវសំនួរ គង់ហើយ លើអាសនៈ ។*

*៧. ស្វា.ទ. ឡើងហើយ លើដើមឈើ អង្គុយហើយ លើមែក ស៊ីហើយ នូវផ្លែ.ទ. ដែលទុំ ។*

*៨. កូន.ទ. របស់កសិករ នោះ ចូលទៅហើយ កាន់អ្នកសំដែងធម៌ អង្គុយហើយ កំពុងស្តាប់ នូវឱវាទ ។*

*៩. សត្វម្រឹគ.ទ. កាលស៊ី ស្មៅ ក្នុងស្រែ រត់ហើយ ព្រោះឃើញ សិង្ហ ។*

*១០. ព្រះពុទ្ធ គឺទេវតា.ទ. ផង មនុស្ស.ទ. ផង បូជាហើយ ។*

១១. សំពត់.ទ. ដែលបោកហើយ គឺប្រពន្ធ យកហើយ ឡើងហើយ ពីទឹក ។

១២. វីក្អមទឹក ដែលពេញហើយ ដោយទឹក គឺស្រីក្មេង យកហើយ មកហើយ កាន់ផ្ទះ ។

១៣. ផ្លែឈើ ដែលទុំហើយ គឺសេក ពាំទៅហើយ ដោយចំពុះ ខ្ញុំ ឃើញហើយ ។

១៤. ព្រះសុរិយា ដែលកំពុងរះឡើង គឺព្រាហ្មណ៍.ទ. ថ្វាយបង្គំហើយ ។

**(ចប់មេរៀនទី ២០)**

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| ជាភិក្ខុ | មិនមានសីល (បរិសុទ្ធ) | ក៏អស់ល្អ |
| ជាគ្រហស្ថ | មិនមានទ្រព្យ (បរិសុទ្ធ) | ក៏អប្រិយ៍ |
| ជាស្ត្រី | មិនមានខ្មាស់ (លែងខ្លួន) | ក៏ខាតលក្ខណ៍ |
| ជាអត្ថ | មិនមានន័យ (ខ្លឹមសារ) | ក៏បិតប៉ាយទទេ ។ |

(ប្រែពីច្បាប់ដើមភាសាបរទេស)

# មេរៀនទី ២១

## អធិប្បាយអំពីកិតកិរិយា (ត)

## អនុត្តកាលកិតកិរិយា

## (Potential participles)

*__អនុត្តកាលកិតកិរិយា__ បានដល់ កិរិយាស័ព្ទដែលចុះបច្ច័យ ២ តួគឺ __អនីយ__ និង __តព្វ__ ។*

*__អនីយ__ និង __តព្វ__ បច្ច័យពីរតួនេះឋិតនៅក្នុងជំពូកកិតកិច្ចបច្ច័យ បើចុះហើយសម្រេចរូបបានជាកិរិយាស័ព្ទឬជាគុណនាមក៏បាន និងមានខ្លះអាចប្រើជានាមទៀតផង មានពាក្យប្រែថា "គួរ ឬ គប្បី" ជានិច្ច ។ នៅក្នុងក្បួនច្បាប់មិនបានប្រាប់ថាជាកាលអ្វីទេ ប៉ុន្តែអាស្រ័យលើពាក្យប្រែថា "គួរ ឬ គប្បី" គឺសំដៅដល់សេចក្ដីចាំបាច់ ឬ សេចក្ដីយល់ឃើញប្រហែលគ្នានឹងពាក្យប្រែរបស់សត្តមីវិភត្តិរបស់អាខ្យាតកិរិយាដែរ ដូច្នេះគួររាប់ជា __អនុត្តកាល__ (ច្បាប់រៀនជាភាសាអង់គ្លេសខ្លះហៅថា* Future Passive participle = *អនាគតកម្មវាចកកិតក:)* ។

*បច្ច័យទាំងអស់បើចែកតាមកាលគឺដូចខាងក្រោមនេះ*

១. ***បច្ចុប្បន្នកាល*** *មាន* **អន្ត** *និង* **មាន** *បច្ច័យ ។*

២. ***អតីតកាល*** *មាន* **ត, តវន្តុ, តាវី** *និង* **ត្វាន** *បច្ច័យ ។*

៣. ***អនុត្តកាល*** *មាន* **អនីយ** *និង* **តព្វ** *បច្ច័យ ។*

ចូររកមើលរឿងកាលនៃកិតកិរិយា ដែលបានពោលរួចហើយក្នុង មេរៀនទី ១៨ សាឡើងវិញ ពីព្រោះថាអ្នកដែលអាចប្រែភាសាបាលី បានតាមគន្លង គឺត្រូវចាំពាក្យប្រែរបស់បច្ច័យមួយតួ ៗ ឱ្យបានច្បាស់ល្អ ដូចជា **អន្ត**, **មាន** បច្ច័យត្រូវប្រែថា "កាលឬកំពុង" ជាដើម ។

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ អនីយ បច្ច័យ

ការប្រកបរូបជាកិរិយាជាមួយ **អនីយ** បច្ច័យមានគតិដូច **ត**, **អន្ត**, **មាន** បច្ច័យគ្រប់ប្រការ ។ **អនីយ**, **តព្វ** បច្ច័យពីរតួនេះអាចប្រើបានក្នុង ៣ វាចកៈ ប៉ុណ្ណោះគឺ កម្មវាចកៈ, ភាវវាចកៈ និង ហេតុកម្មវាចកៈ ដូចមានវិធីតទៅនេះ ។ ចំពោះ **អនីយ** បច្ច័យប្រាកដរូបឱ្យឃើញនៅចុងធាតុជានិច្ច ។

### ១. វិធីប្រកបរូប អនីយ បច្ច័យជាកម្មវាចកៈ

**អនីយ** បច្ច័យមិនមានវិធីផ្លាស់ប្តូរអ្វីច្រើនទេ គឺត្រូវលុប **អ** ចេញ ដូចតទៅនេះ

១.១ ធាតុទោលខ្លះអាចព្រឹទ្ធិស្រៈ **ឧ** > **ឱ** > **អវ** ដូចជា

| ធាតុ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| **ភូ** | + **អនីយ** | > **ភវនីយ** | គប្បីឬគួរកើត |
| **សុ** | + **អនីយ** | > **សវនីយ** | គប្បីឬគួរស្តាប់ |

១.២ ធាតុទោលខ្លះទៀតអាចព្រឹទ្ធិស្រៈ ឧ ស្រៈដើមធាតុជា ឱ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| កុជ + អនីយ | > កោជនីយ | គប្បីឬគួរបរិភោគ |
| អា + រុហ + អនីយ | > អារោហនីយ | គប្បីឬគួរយកឡើង |
| សំ + មុទ + អនីយ | > សម្មោទនីយ | គប្បីឬគួររីករាយព្រម |

១.៣ ធាតុទោលខ្លះទៀតអាចព្រឹទ្ធិស្រៈ ឥ ឬ ឦ > ឯ > អយ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ជិ + អនីយ | > ជយនីយ | គប្បីឬគួរឈ្នះ |
| សី + អនីយ | > សយនីយ | គប្បីឬគួរដេក |

១.៤ បើទីបំផុតធាតុជា រ, ហ, ម[១] ត្រូវផ្លាស់ ន នៃ អនីយ ជា ណ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ករ + អនីយ | > ករណីយ | គប្បីឬគួរធ្វើ |
| សរ + អនីយ | > សរណីយ | គប្បីឬគួររលឹក |
| គរហ + អនីយ | > គរហណីយ | គប្បីឬគួរតិះដៀល |
| រម + អនីយ | > រមណីយ | គប្បីឬគួរត្រេកអរ |

១. ធាតុដែលមាន ម ជាទីបំផុតនិងដែលត្រូវផ្លាស់ ន > ណ មានតិចតួចទេ ។

១.៥ ចំពោះ ឋា, ចា ធាតុត្រូវរក្សាទុកដូចដើម ដូចខាងក្រោមនេះ

| ធាតុ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឋា | + អនីយ | > ឋានីយ | គប្បីឬគួរស្ថិតនៅ |
| ចា | + អនីយ | > ចានីយ | គប្បីឬគួរផឹក |

១.៦ ធាតុខ្លះត្រូវចុះបច្ច័យប្រចាំពួកសិនផងដែរ ទើបចុះ អនីយ បច្ច័យដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុស័ព្ទ | + បច្ច័យ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| បដិ + បទ | + យ | + អនីយ | > បដិបជ្ជនីយ | បដិបត្តិ[១] |
| ពុធ | + យ | + អនីយ | > ពុជ្ឈនីយ | ដឹង |
| មន | + យ | + អនីយ | > មញ្ញនីយ | ដឹង |
| វិ + ញា | + ណា | + អនីយ | > វិជាននីយ | ដឹងច្បាស់ |
| សំ + គហ | + ណ្ហា | + អនីយ | > សង្គណ្ហានីយ | កាន់យក |
| យុជ | + -ំ | + អនីយ | > យុញ្ជនីយ | ប្រកប |

១.៧ ភាគច្រើននិយមចុះ អនីយ ផ្ទាល់នឹងធាតុតែម្ដងដូចជា

| ធាតុ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| គម | + អនីយ | > គមនីយ | គប្បីឬគួរទៅ |
| វច | + អនីយ | > វចនីយ | គប្បីឬគួរពោល |
| បូជ | + អនីយ | > បូជនីយ | គប្បីឬគួរបូជា |

[១]. ពាក្យប្រែទាំងអស់ត្រូវថែមពាក្យប្រែថា "គប្បីឬគួរ" ពីខាងដើម ។

១.៨ ចំពោះ ទិស ធាតុត្រូវផ្លាស់ស្រៈ ឥ នៃធាតុជា អ និងតម្រួតជា ទស្ស ដូចខាងក្រោមនេះ

| ធាតុ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទិស | + អនីយ | > ទស្សនីយ | គប្បីឬគួរមើល |

## ២. វិធីប្រកបរូប អនីយ បច្ច័យជាហេតុកម្មវាចក:

អនីយ បច្ច័យបើចុះខាងហេតុកម្មវាចកត្រូវចុះ**ហេតុប្បច្ច័យ** សិនហើយភាគច្រើនគឺ ណាបេ បច្ច័យប៉ុណ្ណោះ ។ ធាតុខ្លះមានចុះបច្ច័យប្រចាំពួកផងដែរដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + បច្ច័យ | + អនីយ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ករ | + ណាបេ | + អនីយ | > ការាបនីយ | គប្បីឬគួរឱ្យធ្វើ |
| វទ | + ណាបេ | + អនីយ | > វាទាបនីយ | គប្បីឬគួរឱ្យពោល |
| វន្ទ | + ណាបេ | + អនីយ | > វន្ទាបនីយ | គប្បីឬគួរឱ្យសំពះ |
| សិវ | + ណាបេ | + អនីយ | > សិព្វាបនីយ | គប្បីឬគួរឱ្យដេរ |

## កំណត់សម្គាល់

១. ណាបេ បច្ច័យកាលបើផ្សំជាមួយ អនីយ ត្រូវលុប ណា និងស្រៈ ឯ នៃ ណាបេ ហើយលុប អ នៃ អនីយ ចេញទៅជា អាប និង

**នីយ** ដូចជា **គាហាបនីយ** ធាតុឯទៀត ៗ ក៏ដូច្នេះដែរ ។ បច្ច័យដែលមានតួ **ណា** ដូច **ណាបេ** ត្រូវទីឃៈស្រៈដើមធាតុជានិច្ច ។

២. បើជាភាវវាចកៈនិយមប្រើអកម្មធាតុប៉ុណ្ណោះ ជាកិរិយាសព្ទដែលបំបែកតែក្នុងរូបជាបឋមាវិភត្តិនបុំសកលិង្គតែម្យ៉ាងដូចជា **វចនីយំ** និង **ខាទនីយំ** ជាដើម ។

៣. កិតកិរិយាដែលប្រកបដោយ **អនីយ** បច្ច័យនេះ វេលាប្រើក្នុងប្រយោគ ប្រសិនបើប្រើជាបទគុណឬបទកិរិយាចាំបាច់ត្រូវបំបែកឱ្យមានលិង្គ, វចនៈ និង វិភត្តិឱ្យស្មើគ្នានឹងបទនាមដែលជាប្រធានជានិច្ច ។ បើជាបុំលិង្គបំបែកតាមបែប **បុរិស**, បើជានបុំសកលិង្គត្រូវបំបែកតាមបែប **កុល** ហើយបើជាឥត្ថីលិង្គបំបែកតាមបែប **កញ្ញា** ។

ដូច្នេះសរុបមក **អនីយ** បច្ច័យអាចបំបែកបានទាំងបីលិង្គដូចឧទាហរណ៍ខាងក្រោមនេះ

| សព្ទដើម | បុំលិង្គ | នបុំសកលិង្គ | ឥត្ថីលិង្គ |
|---|---|---|---|
| ករណីយ | ករណីយោ | ករណីយំ | ករណីយា |
| គាហាបនីយ | គាហាបនីយោ | គាហាបនីយំ | គាហាបនីយា |
| ខាទនីយ | ខាទនីយោ | ខាទនីយំ | ខាទនីយា |

រីឯរូបវិភត្តិផ្សេង ៗ ទៀតគប្បីយកតាមលំនាំ បុរិស, កុល, កញ្ញា ។

៤. បើប្រើក្នុងសេចក្តីបដិសេធត្រូវចុះ ន ដែលផ្លាស់ជា អ ឬ អន

ដូចកិតកិរិយាចុះប្រើបច្ច័យឯទៀត ៗ ដែលបានពោលរួចហើយដូចជា **អករណីយ** =មិនគប្បីធ្វើ ។ល។

## វិធីប្រើក្នុងប្រយោគ

កិតកិរិយាដែលប្រកបដោយ **អនីយ** បច្ច័យអាចនាំយកមកប្រើក្នុងប្រយោគបាន ៣ បែបគឺ

១. ប្រើជានាមនាម ឧ.

**សេដ្ឋី <u>ខាទនីយេន</u> ចេវ <u>ភោជនីយេន</u> ច តំ ភិក្ខុំ បរិវិសិ ។**

សេដ្ឋី អង្គាសហើយ នូវភិក្ខុ រូបនោះ <u>ដោយរបស់គួរទំពារស៊ី</u> ផង មែនពិត <u>ដោយរបស់គួរបរិភោគ</u> ផង មែនពិត ។

**ខាទនីយេន** =ដោយរបស់គួរទំពារស៊ី(បង្អែម), **ភោជនីយេន** = ដោយរបស់គួរបរិភោគ(ចម្អាប) ។

២. ប្រើជាគុណនាម

ត្រូវបំបែកឱ្យមាន លិង្គ, វចនៈ និង វិភត្តិឱ្យស្មើគ្នានឹងនាមនាមឬសព្វនាមដែលជាប្រធាននិងរៀងដាក់ខាងដើមនាមឬសព្វនាមនោះៗ ឧ.

**អហំ មយា <u>ករណីយំ</u> កិច្ចំ ជានាមិ ។**

ខ្ញុំ រមែងដឹង នូវកិច្ច ដែលខ្ញុំ <u>គប្បីធ្វើ</u> ។

**កឹ បន ត្វំ កិច្ចំ សាមិកេន ធាសំ <u>កាតព្វនីយំ</u> ជានាសិ ។**

ក៏ អ្នក រមែងដឹង នូវកិច្ច ដែលម្ចាស់ ញុាំងទាសៈ ឱ្យគប្បីធ្វើ ឬ?
(មយា និង ការណីយំ វេលាប្រែត្រូវអានគួបគ្នាថា មយាការណីយំ =ដែលខ្ញុំគប្បីធ្វើ) ។

៣. ប្រើជាមហាកិរិយាសព្ទ ប្រើបាន ៣ វចកៈដូចខាងក្រោមនេះ
១. កម្មវាចកៈ. ជនេហិ កល្យាណំ កម្មំ ការណីយំ ។
អំពើ ល្អ គឺជន.ទ. គប្បីធ្វើ ។
២. ភាវវាចកៈ. តេហិ គមនីយំ ។ គឺគេ.ទ. គប្បីទៅ ។
៣. ហេតុវាចកៈ. សាមិកេន តំ កម្មំ ទាសំ ការាបនីយំ ។
កម្ម នោះ គឺម្ចាស់ ញុាំងទាសៈ ឱ្យធ្វើហើយ ។

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ តព្វ បច្ច័យ

តព្វ បច្ច័យពេលចុះក្នុងធាតុណាមានពាក្យប្រែនិងអាចប្រើបាន ៣ វាចកៈដូច អនីយ បច្ច័យដែរ ។ ប៉ុន្តែជាបច្ច័យមានតួ ត ដូច្នេះមានវិធីផ្លាស់ប្តូររូបប្រហែល ត បច្ច័យទៅវិញ ។

### ១. វិធីរូបសិទ្ធិ តព្វ បច្ច័យជាកម្មវាចកៈ

១.១ បើទីបំផុតធាតុជា ជ ត្រូវរក្សាទុករូបដើមដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ហន | + តព្វ | > ហន្តព្វ | គប្បីឬគួរសម្លាប់ |
| ខន | + តព្វ | > ខន្តព្វ | គប្បីឬគួរជីក |
| តន | + តព្វ | > តន្តព្វ | គប្បីឬគួរលាត |

១.២ បើទីបំផុតជា ច, ជ, ទ, ប, រ ដោយអំណាច តព្វ បច្ច័យត្រូវផ្លាស់ទីបំផុតធាតុទាំងឡាយនោះជា ត ឬលុបទីបំផុតធាតុចេញហើយតម្រួតជា ត្ត តាមវិធីព្យញ្ជនៈសំយោគដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សិច | + តព្វ | > សិត្តព្វ | គប្បីឬគួរស្រោច |
| ភុជ | + តព្វ | > ភុត្តព្វ | គប្បីឬគួរស៊ី |
| បទ | + តព្វ | > បត្តព្វ | គប្បីឬគួរដល់ |
| គុប | + តព្វ | > គុត្តព្វ | គប្បីឬគួរគ្រប់គ្រង |
| ការ | + តព្វ | > កាត្តព្វ | គប្បីឬគួរធ្វើ |

១.៣ បើទីបំផុតធាតុជា ម ត្រូវផ្លាស់ទីបំផុតធាតុជា ន ហើយតម្រួតជា -ន្តព្វ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សម | + តព្វ | > សន្តព្វ | គប្បីឬគួររម្ងាប់ |
| គម | + តព្វ | > គន្តព្វ | គប្បីឬគួរទៅ |

១.៤ បើទីបំផុតធាតុជា ជ ក, ត្រូវផ្លាស់ ជ ក ជាមួយនឹង ត របស់ តព្វ ជា ទ្ធ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| កុជ | + តព្វ | > កុទ្ធព្វ | គប្បីឬគួរក្រោធ |
| លភ | + តព្វ | > លទ្ធព្វ | គប្បីឬគួរបាន |

១.៥ បើទីបំផុតធាតុជា ស, ត្រូវផ្លាស់ ស ជាមួយនឹង ត របស់ តព្វ ជា ដ្ឋ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទិស | + តព្វ | > ទដ្ឋព្វ | គប្បីឬគួរឃើញ (លុប ឥ) |
| តុស | + តព្វ | > តុដ្ឋព្វ | គប្បីឬគួរត្រេកអរ |
| ផុស | + តព្វ | > ផោដ្ឋព្វ | គប្បីឬគួរពាល់ត្រូវ(ផ្លាស់ ឧ > ឱ ) |
| ប + មុស | + តព្វ | > បមុដ្ឋព្វ | គប្បីឬគួរភ្លេច |

១.៦ ចំពោះ ការ ធាតុអាចផ្លាស់ជា កា បានខ្លះ ដូចជា ការ + តព្វ > កាតព្វ គប្បីឬគួរធ្វើ ។

១.៧ បើទីបំផុតធាតុជាស្រៈ អា ត្រូវទុកស្រៈឱ្យគង់រូបដើម ។ ប៉ុន្តែ ធាតុខ្លះអាចផ្លាស់ស្រៈ អា > អាយ ហើយចុះ ឥ អាគមបានដូចឧទា-ហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ញា | + តព្វ | > ញាតព្វ | គប្បីឬគួរដឹង |
| ធា | + តព្វ | > ធាតព្វ | គប្បីឬគួរឱ្យ |
| ឋា | + តព្វ | > ឋាតព្វ | គប្បីឬគួរតាំងនៅ |
| ប + ហា | + តព្វ | > បហាតព្វ | គប្បីឬគួរលះ |
| ចា | + តព្វ | > ចាតព្វ, ចាយិតព្វ | គប្បីឬគួរផឹក |
| យា | + តព្វ | > យាយិតព្វ | គប្បីឬគួរទៅ |
| នហា | + តព្វ | > នហាយិតព្វ | គប្បីឬគួរងូត |

១.៨ បើទីបំផុតធាតុជាស្រៈ ឥ ឬ ឦ និយមផ្លាស់ ឥ ឬ ឦ > ឯ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| នី | + តព្វ | > នេតព្វ | គប្បីឬគួរនាំទៅ |
| ជិ | + តព្វ | > ជេតព្វ | គប្បីឬគួរឈ្នះ |
| ឥ | + តព្វ | > ឯតព្វ | គប្បីឬគួរទៅឬមក |
| សី | + តព្វ | > សេតព្វ | គប្បីឬគួរដេក |
| ចិ | + តព្វ | > ចេតព្វ | គប្បីឬគួរកសាង |

១.៩ បើទីបំផុតធាតុជាស្រៈ ឧ ឩ និយមផ្លាស់ជា ឱ > អវ និងចុះ ឥ អាគមដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ភូ + តព្វ | > ភវិតព្វ | គប្បីឬគួរកើត |
| ឝុ + តព្វ | > ឝវិតព្វ | គប្បីឬគួរបន្លឺសំឡេង |
| សុ + តព្វ | > សោតព្វ | គប្បីឬគួរស្តាប់ |

១.១០ ធាតុទោលខ្លះមានវិធីផ្លាស់ប្តូរតាមការគួរប្រកប ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| សី + តព្វ | > សយិតព្វ | គប្បីឬគួរដេក ( ឰ > ឯ > អយ ) |
| កី + តព្វ | > កាយិតព្វ | គប្បីឬគួរកយ័ ( ឰ > ឯ > អាយ ) |

១.១១ បើមិនផ្លាស់ទីបំផុតធាតុតាមន័យខាងលើទេ ត្រូវចុះ ឥ អាគមលើទីបំផុតធាតុដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + ឥ + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ករ + ឥ + តព្វ | > ករិតព្វ | គប្បីឬគួរធ្វើ |
| គម + ឥ + តព្វ | > គមិតព្វ | គប្បីឬគួរទៅ |
| ចជ + ឥ + តព្វ | > ចជិតព្វ | គប្បីឬគួរលះ |
| ភាស + ឥ + តព្វ | > ភាសិតព្វ | គប្បីឬគួរពោល |
| វស + ឥ + តព្វ | > វសិតព្វ | គប្បីឬគួរនៅ |
| វិទ + ឥ + តព្វ | > វេទិតព្វ | គប្បីឬគួរដឹង |

១.១២ ធាតុខ្លះត្រូវចុះបច្ច័យប្រចាំពួកធាតុផងដែរដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ឧ + បទ | + តព្វ | > ឧបជ្ជិតព្វ | គប្បីឬគួរកើតឡើង (យ បច្ច័យ) |
| ពុធ | + តព្វ | > ពុជ្ឈិតព្វ | គប្បីឬគួរដឹង (យ បច្ច័យ) |
| សុ | + តព្វ | > សុណិតព្វ | គប្បីឬគួរស្តាប់ ( ណា បច្ច័យ) |
| ញា | + តព្វ | > ជានិតព្វ | គប្បីឬគួរដឹង (នា បច្ច័យ) |
| គហ | + តព្វ | > គណ្ហិតព្វ | គប្បីឬគួរកាន់យក (ណ្ហា បច្ច័យ) |
| ចិន្ត | + តព្វ | > ចិន្តេតព្វ | គប្បីឬគួរគិត (ណេ បច្ច័យ) |

## ២. វិធីរូបសិទ្ធិ តព្វ បច្ច័យជាហេតុកម្មវាចក:

តព្វ បច្ច័យបើប្រើជាហេតុកម្មវាចកត្រូវចុះហេតុបច្ច័យនៃអាខ្យាតសិន ទើបចុះ តព្វ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + បច្ច័យ | + តព្វ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| បច | + ណេ | + តព្វ | > បាចេតព្វ | គប្បីឬគួរឱ្យចម្អិន |
| បច | + ណាបេ | + តព្វ | > បាចាបេតព្វ | គប្បីឬគួរឱ្យចម្អិន |
| ករ | + ណេ | + តព្វ | > ការេតព្វ | គប្បីឬគួរឱ្យធ្វើ |
| ករ | + ណាបេ | + តព្វ | > ការាបេតព្វ | គប្បីឬគួរឱ្យធ្វើ |

**ការ** + ឈាយ + ឥ + តព្វ > **ការយិតព្វ** គប្បីឬគួរឱ្យធ្វើ
**ការ** + ឈាបយ + ឥ + តព្វ > **ការាបយិតព្វ** គប្បីឬគួរឱ្យធ្វើ

**តព្វ** បច្ច័យមានវិធីបំបែកបានទាំងបីលិង្គនិងប្រើបានបីវាចក:ដូច **អនីយ** បច្ច័យដែរ (ចូររកមើលក្នុង **អនីយ** បច្ច័យនៅខាងលើ) ។ ប្រសិនបើប្រើជាភាវវាចក: ត្រូវបំបែកជាបឋមាវិភត្តិឯកវចននបុំសកលិង្គតែម៉្យាងប៉ុណ្ណោះដូចជា **គមិតព្វំ** = គប្បីទៅ ។

បើប្រើក្នុងសេចក្ដីបដិសេធត្រូវចុះ **ន** ដែលផ្លាស់ជា **អ** ឬ **អន** ថែមខាងដើមធាតុដូចកិតកិរិយាឯទៀត ៗ ដែរដូចជា **អគន្តព្វ** =មិនគប្បីទៅជាដើម ។

## វិធីប្រើ តព្វ បច្ច័យក្នុងប្រយោគ

កិតកិរិយាដែលប្រកបដោយ **តព្វ** បច្ច័យដូចពោលហើយនេះអាចនាំយកមកប្រើក្នុងប្រយោគនានាមានវិធីប្រើ ៣ បែបគឺ

**១. ប្រើជានាមនាម**

**សមណស្ស គោតមស្សេវ** (គោតមស្ស + ឯវ) <u>**កាត្តព្វំ**</u> **ការិស្សាមិ ។**

ខ្ញុំ នឹងធ្វើ <u>នូវកិច្ចដែលគប្បីធ្វើ</u> ចំពោះព្រះសមណគោតមប៉ុណ្ណោះ ។

២. ប្រើជាគុណនាម

អម្មា <u>បចិតព្វំ</u> តណ្ឌុលំ បិដកេ បចេសិ ។

*ម្ដាយ ដាក់ហើយ នូវអង្ករ <u>ដែលគប្បីចម្អិន</u> (នៅ)ក្នុងល្អី ។*

ជារិកាយ <u>ភុញ្ជិតព្វំ</u> ឱទនំ អហំ ន ភុញ្ជិស្សាមិ ។

*ខ្ញុំ នឹងមិនបរិភោគ នូវបាយ ដែលក្មេងស្រី <u>គប្បីបរិភោគ</u>ទេ ។*

៣. ប្រើជាកិរិយាស័ព្ទទាំង ៣ វាចក:

១. កម្មវាចក:. តយា កល្យាណំ កម្មំ <u>កាតព្វំ</u> ។

*អំពើ ល្អ គឺអ្នក <u>គប្បីធ្វើ</u> ។*

មនុស្សេហិ ធម្មោ <u>ឧគ្គណ្ហិតព្វោ</u> ។

*ព្រះធម៌ គឺមនុស្ស.ទ. គប្បីរៀន, ។*

២. ភាវវាចក:. តេហិ ជនេហិ <u>គមិតព្វំ</u> ។

*គឺជន.ទ. នោះ <u>គប្បីទៅ</u> ។*

៣. ហេតុវាចក:. តេន ឱទនោ បុគ្គលំ <u>ចាចេបេតព្វោ</u> ។

*បាយ គឺគេ ញុំាងបុគ្គល <u>គប្បីឱ្យចម្អិន</u> ។*

*ប្រសិនបើមាន* ហោតិ *នៅខាងចុងបទថា* កាតព្វំ, ឧគ្គណ្ហិតព្វោ *ក្លាយជាវិកតិកត្តាដូចក្នុង* ត *បច្ច័យដែរ ។*

## លំហាត់នៃមេរៀនទី ២១

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ ។*

*១. តើ* **អនីយ** *និង* **តព្វ** *បច្ច័យមានពាក្យប្រែប្រកបថាដូចម្ដេច ?*

*២. តើ* **អនីយ** *ប្រើបានប៉ុន្មានវាចកៈ ? សូមឱ្យឧទាហរណ៍ ។*

*៣. តើ* **តព្វ** *ប្រើបានប៉ុន្មានវាចកៈ ? សូមឱ្យឧទាហរណ៍ ។*

*៤. នៅក្នុងប្រយោគតើ* **អនីយ** *អាចប្រើដូចម្ដេចខ្លះ ? សូមឱ្យឧទា. ។*

*៥. នៅក្នុងប្រយោគតើ* **តព្វ** *អាចប្រើដូចម្ដេចខ្លះ ? សូមឱ្យឧទា. ។*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. កញ្ញា កុញ្ជិយមានំ កត្តំ សុនខស្ស ជាតព្វំ (ហោតិ) ។

២. បុរិសេន ជិន្ទិយមានោ រុក្ខោ គេហស្ស ឧបរិ អបតិតព្វំ ។

៣. បុរិសេហិ ខេត្តានិ កសិតព្វានិ, វនិតាហិ តេសំ ភត្តំ បចិតព្វំ។

៤. ជាសេន បហរីយមានោ អស្សោ វាណិជានំ វិក្កិណិតព្វោ ហោតិ ។

៥. ចោរេហិ បហរីយមានា បុរិសា អញ្ញំ កាតព្វំ អជិស្វា អជរី ជារីសុ ។

៦. សារថីនា បហរីយមានោ អស្សោ រថំ អាកឌ្ឍន្តោ សីឃំ ជាវតិ ។

៧. តុម្ហេហិ ជានានិ ជាតព្វានិ, សីលានិ រក្ខិតព្វានិ, បុញ្ញានិ កាតព្វានិ ហោតិ ។

៨. សិស្សេហិ ជម្មោ សោតព្វោ សត្ថានិ ឧគ្គណ្ហិតព្វានិ ។

៩. មយា ជីយមានំ កុញ្ជិតព្វំ កុញ្ជិតុំ ពហូ យាចកា អាគច្ឆន្តិ ។
១០. វនិតា ជោវិតញ្ញានិ វត្ថានិ អាទាយ វីរិត្តំ នទឹ គមិស្សតិ ។
១១. យុវតិយោ វឌ្ឍនិយានិ ចេតិយានិ ទិស្វា ឯកាយ កញ្ញាយ
ឱចិនិយាមានានិ បទុមានិ យាចឹសុ ។
១២. អម្មា ខាទនីយានិ ច ភោជនីយានិ ច បជិយាទេត្វា
ជារកានំ ទេតិ ។
១៣. មិគា ចាទីយំ ឧទកំ បរិយេសន្តា អដវិយំ អាហិណ្ឌឹសុ ។
១៤. សមណេហិ ឱវទិតព្វំ កុមារា វិហារំ ន គមឹសុ ។
១៥. កុសលំ អជានិត្វា ចាបំ ករោន្តា កុមារា ន អក្កោសិតញ្ញា,
តេ សមណេហិ ច បណ្ឌិតេហិ ច សប្បុរិសេហិ ច
អនុសាសិតញ្ញា ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. រូប.ទ. គប្បីឃើញ ដោយភ្នែក, រស.ទ. គប្បីរីករាយ ដោយអណ្តាត ។*
*២. ឯង.ទ. មិនគប្បីវាយ ឆ្កែ នោះ ដោយដំបង ឬ ថ្មទេ. ។*
*៣. ផ្កា.ទ. ក្នុងសួន ដ៏ស្អាត ឯវត្ត គឺគេ.ទ. គប្បីស្រោច នូវទឹក រឿយៗ ។*
*៤. វីស្រូវ.ទ. គឺកសិករ ជាមួយ ប្រពន្ធ របស់គាត់ គប្បីវាល់ ។*
*៥. មនុស្ស.ទ. ក្នុងលោក មិនគប្បីប្រព្រឹត្ត អំពើអាក្រក់ឡើយ, គេ.ទ.*
*គប្បីធ្វើ នូវបុណ្យ ។*
*៦. ជន.ទ. មិនគប្បីចូលទៅជិត គោ កំពុងដេក ក្នុងរូងភ្នំ នោះទេ ។*

៧. មនុស្ស.ទ. គប្បីរៀន នូវធម៌, គប្បីយល់ នូវសច្ចៈ ។

៨. គេ.ទ. មិនប្រាថ្នា ដើម្បីទិញ នូវឥវ៉ាន់ ដែលគប្បីលក់ ដែលតាំង-
ហើយ ក្នុងផ្សារ ។

៩. ក្មេងស្រី.ទ. កាលសើច យកហើយ នូវសំពត់ ដែលគួរបោក
ចុះហើយ ក្នុងបឹង ។

១០. ទាន.ទ. គឺមនុស្ស.ទ. គប្បីឱ្យ, សីល.ទ. គប្បីរក្សា, បុណ្យ.ទ.
គប្បីធ្វើ ។

១១. មនុស្សល្អ ដែលមិនចេះ គប្បីពោល ក្ដី មិនគប្បីពោល ក្ដី
ចូរកុំអង្គុយ ក្នុងទីប្រជុំ ។

១២. សំនួរ ដែលសួរហើយ ដោយឧបាសក រូបនោះ គឺបណ្ឌិត
គប្បីពន្យល់ ដល់គាត់ ។

១៣. កុមារ.ទ. ដែលធ្វើ នូវបាប មិនដឹង នូវកុសល មិនគប្បីដេរទេ គេ.ទ
គប្បីបង្រៀន ដោយសប្បុរស ផង បណ្ឌិត ផង អ្នកបួស ផង ។

១៤. មនុស្ស.ទ. ដែលកំពុងរស់នៅ ដោយធម៌ គឺទេវតា.ទ. គប្បីរក្សា ។

១៥. ស្រា មិនគប្បីផឹកទេ, ប្រសិនបើ អ្នក.ទ. ផឹក នឹងមាន នូវជំងឺ.ទ. ។

**(ចប់មេរៀនទី ២១)**

# មេរៀនទី ២២

## អធិប្បាយអំពីកិតកិរិយា (តចប់)

## តវន្តុ, តាវី បច្ច័យ

*តវន្តុ និង តាវី បច្ច័យពីរតួនេះមិនសូវមានប្រើច្រើនទេ ជាកិត-បច្ច័យអាចប្រើបានតែពីរវាចកៈគឺកត្តុវាចកៈនិងហេតុកត្តុវាចកៈប៉ុណ្ណោះ គឺជាអតីតកាលតែម៉្យាងដូច ត បច្ច័យដែរប្រែថា "...ហើយ" ។*

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ តវន្តុ បច្ច័យ

*ការប្រកបរូបជាកិរិយាជាមួយ តវន្តុ បច្ច័យមានគតិដូច ត បច្ច័យដែរដូចនឹងអធិប្បាយតទៅនេះ*

### ១. កត្តុវាចកៈ

*១.១ បើប្រកបជាមួយធាតុទោល ត្រូវទុកធាតុឱ្យគង់រូបដូចឧទា-ហរណ៍ខាងក្រោមនេះ ។*

| ធាតុ | + តវន្តុ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ជិ | + តវន្តុ | > ជិតវន្តុ | ឈ្នះហើយ |
| សុ | + តវន្តុ | > សុតវន្តុ | ស្តាប់ហើយ |
| ហុ | + តវន្តុ | > ហុតវន្តុ | បូជាហើយ |
| ចា | + តវន្តុ | > ចាតវន្តុ | ផឹកហើយ |

១.២ បើប្រកបជាមួយធាតុពីរតួដែលមានទីបំផុតជា ច, ជ, ប អាចផ្លាស់ជា ត ហើយតម្រួតជា ត្តវន្តុ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តវន្តុ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សិច | + តវន្តុ | > សិត្តវន្តុ | ស្រោចហើយ |
| ចជ | + តវន្តុ | > ចត្តវន្តុ | លះហើយ |
| គុប | + តវន្តុ | > គុត្តវន្តុ | គ្រប់គ្រងហើយ |
| ភុជ | + តវន្តុ | > ភុត្តវន្តុ | បរិភោគហើយ |

១.៣ បើមិនលុបទីបំផុតធាតុទេត្រូវចុះ ឥ អាគមលើទីបំផុតធាតុ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ឥ | + តវន្តុ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| កថ | + ឥ | + តវន្តុ | > កថិតវន្តុ | ពោលហើយ |
| ចជ | + ឥ | + តវន្តុ | > ចជិតវន្តុ | លះហើយ |
| បច | + ឥ | + តវន្តុ | > បចិតវន្តុ | ចម្អិនហើយ |
| ភុជ | + ឥ | + តវន្តុ | > ភុជិតវន្តុ | បរិភោគហើយ |
| វស | + ឥ | + តវន្តុ | > វុសិតវន្តុ | រស់នៅហើយ |

១.៤ ចំពោះ ការ ធាតុមានរូបដូច្នេះ ការ + តវន្តុ > កាតវន្តុ លុប រ ចេញ, ការ + ឱ + តវន្តុ > កាតុវន្តុ, ផ្លាស់ ការ និង ឱ ជា កាតុ ។

## ២. ហេតុកត្តុវាចក:

*ចំពោះ ណយ និង ណាបយ ត្រូវចុះ ឥ អាគមថែមលើ យ ផង ដូចឧទាហរណ៍ខាងក្រោមនេះ*

| | | | | |
|---|---|---|---|---|
| *ធាតុ* | + បច្ច័យ | + ឥ | + តវន្តុ | *សម្រេចជា* |
| សុ | + ណេ | | + តវន្តុ | > សាវេតវន្តុ |
| វស | + ណាបេ | | + តវន្តុ | > វាសាបេតវន្តុ |
| កុជ | + ណយ | + ឥ | + តវន្តុ | > កោជយិតវន្តុ |
| ការ | + ណាបយ | + ឥ | + តវន្តុ | > ការាបយិតវន្តុ |

## កំណត់សម្គាល់

*ស័ព្ទកិតកដែលប្រកបរូបជាមួយ* **តវន្តុ** *បច្ច័យនេះមានវិធីបំបែក បានទាំងបីលិង្គ ប៉ុន្តែមិនបំបែកតាមបែបពួកនាមដែលជា ឧ ការន្តទេ គឺ ដំបូងត្រូវលុបស្រៈ ឧ ចេញរួចបំបែកតាមបែបដូច្នេះ*

*១. បើប្រើជាកិរិយាក្តីឬជាគុណនាមក្តី ដែលជាបុំលិង្គអាចបំបែក បានពីរបែប គឺបំបែកតាមបែប* **បុរិស** *ឬបំបែកតាមបែប* **ភគវន្តុ** *(មាន អធិប្បាយនៅខាងមុខ) ក៏បានដូចជា* **សុតវា, សុតវន្តោ, សុតវន្តា** *ជា ដើម ៗ*

២. បើប្រើជាកិរិយាក្ដីឬជាគុណនាមក្ដីដែលជាឥត្ថីលិង្គត្រូវចុះគ្រឿងសំគាល់គឺ ឦ បច្ច័យសិនមានរូបជា វន្តី, វតី ដូចជា សុតវន្តី, សុតវតី, កុត្តវន្តី, កុត្តវតី, វុសិតវតី, វុសិតវន្តី គឺបំបែកតាមបែប ជារី គ្រប់វិភត្តិទាំងអស់ ។

៣. ប្រើជាកិរិយាក្ដីឬជាគុណនាមក្ដី ដែលជានបុំសកលិង្គអាចបំបែកបានពីរយ៉ាងដែរ គឺអាចបំបែកតាមបែប កុល ឬបំបែកតាមបែប គុណវន្តុ ក៏បាន ។

## វិធីបំបែក សុតវន្តុ ជាបុំលិង្គ

### តាមបែប បុរិស

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សុតវន្តោ | សុតវន្តា |
| ទុ. | សុតវន្តំ | សុតវន្តេ |
| ត. | សុតវន្តេន | សុតវន្តេហិ, សុតវន្តេភិ |
| ច. | សុតវន្តស្ស | សុតវន្តានំ |
| បញ្ច. | សុតវន្តម្ហា, សុតវន្តស្មា | សុតវន្តេហិ, សុតវន្តេភិ |
| ឆ. | សុតវន្តស្ស | សុតវន្តានំ |
| ស. | សុតវន្តស្មឹ, សុតវន្តម្ហិ | សុតវន្តេសុ |
| អា. | --- | សុតវន្តា |

# វិធីបំបែក សុតវន្តុ ជាបុំលិង្គ

## តាមបែប ភគវន្តុ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| ប. | សុតវា | សុតវន្តោ |
| ទុ. | សុតវន្តំ | សុតវន្តោ |
| ត. | សុតវតា | សុតវន្តេហិ, សុតវន្តេភិ |
| ច. | សុតវតោ | សុតវតំ, សុតវន្តានំ |
| បញ្ច. | សុតវតា | សុតវន្តេហិ, សុតវន្តេភិ |
| ឆ. | សុតវតោ | សុតវតំ, សុតវន្តានំ |
| ស. | សុតវតិ, -ស្មឹ, -ម្ហិ | សុតវន្តេសុ |
| អា. | សុតវ, សុតវំ, សុតវា | សុតវន្តោ |

# វិធីបំបែក សុតវន្តុ ជានបុំសកលិង្គ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| ប. | សុតវំ | សុតវន្តានិ, សុតវន្តា |
| ទុ. | សុតវន្តំ | សុតវន្តានិ, សុតវន្តា |
| អា. | សុតវ | សុតវន្តានិ |

*សល់ពីខាងលើនេះបំបែកដូចបុំលិង្គគ្រប់វិភត្តិទាំងអស់ ។*

# វិធីបំបែក សុតវន្តុ ជាឥត្ថីលិង្គ

## តាមបែប នារី

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សុតវន្តី | សុតវន្តិយោ, សុតវន្តី |
| ទុ. | សុតវន្តឹ | សុតវន្តិយោ, សុតវន្តី |
| ត. | សុតវន្តិយា | សុតវន្តីហិ, សុតវន្តីភិ |
| ច. | សុតវន្តិយា | សុតវន្តីនំ |
| បញ្ច. | សុតវន្តិយា | សុតវន្តីហិ, សុតវន្តីភិ |
| ឆ. | សុតវនិយា | សុតវន្តីនំ |
| ស. | សុតវន្តិយំ, សុតវន្តិយា | សុតវន្តីសុ |
| អា. | សុតវន្តិ | សុតវន្តិយោ, សុតវន្តី |

# វិធីប្រើ តវន្តុ បច្ច័យក្នុងប្រយោគ

១. ឧបាសកោ ធម្មំ សុតវា គេហំ អគមិ ។

*ឧបាសក ស្តាប់ហើយ នូវធម៌ បានទៅហើយ កាន់ផ្ទះ ។*

២. ជនោ ភិក្ខូ សាលាយំ វាសាបេតវា ភត្តានិ ទទឹសុ ។

*ជន ញុំាងភិក្ខុ.ទ. ឱ្យនៅហើយ ក្នុងសាលា ប្រគេនហើយ នូវភត្ត.ទ. ។*

បើប្រើក្នុងសេចក្ដីបដិសេធគឺប្រើ ន ផ្លាស់ អ ឬ អន ដាក់នៅពីមុខ ដូចគ្នានឹងកិតកិរិយាឯទៀតដែលបានពោលរួចហើយដែរ ។

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ តាវី បច្ច័យ

**តាវី** ជាកិតបច្ច័យអាចប្រើបានពីរវាចកៈ គឺកត្តុវាចកៈនិងហេតុកត្តុវាចកៈ គឺជាអតីតកាលតែម្យ៉ាងដូច **ត** បច្ច័យប្រែថា "...ហើយ" មានវិធីប្រកបរូបជាកិរិយាដូច **តវន្តុ** បច្ច័យពីព្រោះជាបច្ច័យមានតួ **ត** ដែរ ដូចតទៅនេះ

### ១. កត្តុវាចកៈ

| ធាតុ | + តាវី | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សុ | + តាវី | > សុតាវី | ស្ដាប់ហើយ |
| ហុ | + តាវី | > ហុតាវី | បូជាហើយ |
| សិច | + តាវី | > សិត្តាវី | ស្រោចហើយ |
| ភុជ | + តាវី | > ភុត្តាវី | ស៊ីហើយ |
| គុប | + តាវី | > គុត្តាវី | គ្រប់គ្រងហើយ |

### ២. ហេតុកត្តុវាចកៈ

ចំពោះ **ណាយ** និង **ណាបយ** បច្ច័យត្រូវចុះ **ឥ** អាគមថែមលើយ ផងដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + បច្ច័យ | + ឥ | + តាវី | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|
| ភុជ | + ណេ | | + តាវី | > ភោជេតាវី | ឱ្យស៊ី-ហើយ |
| ភុជ | + ណាបេ | | + តាវី | > ភោជាបេតាវី | |
| ភុជ | + ណាយ | + ឥ | + តាវី | > ភោជយិតាវី | |
| ភុជ | + ណាបយ | + ឥ | + តាវី | > ភោជាបយិតាវី | |

## កំណត់សម្គាល់

**តាវី** បច្ច័យបើប្រើជាបុំលិង្គត្រូវបំបែកតាមបែប **សេដ្ឋី** ។ បើជាឥត្ថីលិង្គត្រូវចុះ **ឥនី** > **តាវិនី** សិនហើយបំបែកតាមបែប **នារី** ដូចជា **សុតាវិនី** ។ បើជានបុំសកលិង្គត្រូវរស្សៈ **ឦ** > **ឥ** ទៅជា **តាវិ** រួចបំបែកតាមបែប **អក្ខិ** ដូចជា **សុតាវិ** ។ ទោះជាយ៉ាងណាក៏ដោយ **តវន្តុ** និង **តាវី** បច្ច័យពីរតួនេះមានប្រើតិចតួចទេ ។

## វិធីប្រើ តាវី ក្នុងប្រយោគ

១. ជនោ បុត្តេ ភោជិតាវី អចរិ ។

*ជន ពោលហើយ នឹងកូនប្រុស.ទ. បានត្រាច់ទៅហើយ ។*

២. មាតា បុត្តំ <u>ភោជេតាវិជី</u> និបជ្ជាបេសិ ។
ម្តាយ ញុំាងបុត្រ <u>ឱ្យស៊ីហើយ</u> ឱ្យដេកហើយ ។

## តុំ និង តវេ បច្ច័យ

(Infinitives)

បច្ច័យពីរតួនេះមាននៅក្នុងកិតនាម (មានអធិប្បាយនៅខាងមុខ) ឯណោះទេ ជាអព្យយបច្ច័យពីព្រោះពុំចាំបាច់បំបែកតាមវិភត្តិដូចត្វាទិបច្ច័យដែរ ជាពិសេស តុំ បច្ច័យមានប្រើច្រើនទើបនាំយកមកអធិប្បាយក្នុងទីនេះមុន ។ ពេលចុះជាមួយធាតុហើយ អាចប្រើក្នុងអត្ថរបស់វិភត្តិនាមបាន ២ វិភត្តិគឺ បឋមាវិភត្តិ និង ចតុត្ថីវិភត្តិ ។

១. បើប្រើក្នុងអត្ថរបស់បឋមាវិភត្តិ ប្រែថា "រីកិរិយា..., រីការ..." ។

២. បើប្រើក្នុងអត្ថរបស់ចតុត្ថីវិភត្តិប្រែថា "ដើម្បី......" ។

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ តុំ បច្ច័យ

តុំ បច្ច័យមានវិធីប្រកបរូបជាកិរិយាស័ព្ទច្រើនយ៉ាងដូច ត ព្រោះជាបច្ច័យមានតួ ត ដែរ ដូចមាននៅខាងក្រោមនេះ

## ១. វិធីចុះ តុំ បច្ច័យជាកត្តុវាចក:

១.១ បើទីបំផុតជាតុជា ច, ជ, ធ, ប, រ ត្រូវផ្លាស់ទីបំផុតជាតុជា ត ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| សិច | + តុំ | > សិត្តុំ | ដើម្បីស្រោច |
| ចជ | + តុំ | > ចត្តុំ | ដើម្បីលះ |
| បធ | + តុំ | > បត្តុំ | ដើម្បីដល់ |
| កុប | + តុំ | > កុត្តុំ | ដើម្បីគ្រប់គ្រង |
| ការ | + តុំ | > កាត្តុំ | ដើម្បីធ្វើ |

១.២ បើទីបំផុតជាតុជា ម ត្រូវផ្លាស់ទីបំផុតជាតុជា ន ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| គម | + តុំ | > គន្តុំ | ដើម្បីទៅ |
| សម | + តុំ | > សន្តុំ | ដើម្បីរម្ងាប់ |

១.៣ បើទីបំផុតជាតុជា ន ត្រូវផ្សំនឹង តុំ ជា ន្តុំ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ហន | + តុំ | > ហន្តុំ | ដើម្បីបៀតបៀន |
| តន | + តុំ | > តន្តុំ | ដើម្បីត្រដាង |

១.៤ បើទីបំផុតធាតុជា ធ, ភ ត្រូវផ្លាស់ទីបំផុតធាតុនិង តុំ បច្ច័យ ជា ទ្ធុំ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ពុធ | + តុំ | > ពុទ្ធុំ | ដើម្បីត្រាស់ដឹង |
| លភ | + តុំ | > លទ្ធុំ | ដើម្បីបាន |

១.៥ បើទីបំផុតធាតុជា ស ត្រូវផ្លាស់ទីបំផុតធាតុនិង តុំ ជា ដ្ឋុំ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| តុស | + តុំ | > តុដ្ឋុំ | ដើម្បីត្រេកអរ |
| ទិស | + តុំ | > ទដ្ឋុំ | ដើម្បីឃើញ |
| ផុស | + តុំ | > ផដ្ឋុំ | ដើម្បីពាល់ |

១.៦ បើទីបំផុតធាតុជាស្រៈ អា ត្រូវទុកឱ្យគង់រូបដើមដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| ទា | + តុំ | > ទាតុំ | ដើម្បីឱ្យ |
| ញា | + តុំ | > ញាតុំ | ដើម្បីដឹង |
| បា | + តុំ | > បាតុំ | ដើម្បីផឹក |

១.៧ បើទីបំផុតធាតុជាស្រៈ ឧ ឬ ឩ ត្រូវផ្លាស់ជា ឱ ដូចឧទា-

ហរណ៍ខាងក្រោមនេះ

| ធាតុ | + | តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| សុ | + | តុំ | > សោតុំ | ដើម្បីស្តាប់ |
| ហុ | + | តុំ | > ហោតុំ | ដើម្បីបូជា |

១.៨ បើទីបំផុតធាតុជាស្រៈ ឥ ឬ ឦ ត្រូវផ្លាស់ជា ឯ ដូចឧទា-ហរណ៍ខាងក្រោមនេះ

| ធាតុ | + | តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ជិ | + | តុំ | > ជេតុំ | ដើម្បីឈ្នះ |
| នី | + | តុំ | > នេតុំ | ដើម្បីនាំទៅ |
| សី | + | តុំ | > សេតុំ | ដើម្បីដេក |

១.៩ បើមិនអនុវត្តតាមឧទាហរណ៍ខាងលើទេ ត្រូវចុះ ឥ អាគម និងធាតុខ្លះមានចុះបច្ច័យប្រចាំពួកធាតុផង ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + | ឥ | + | បច្ច័យ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|---|---|
| ការ | + | ឥ | + | តុំ | > ការិតុំ | ដើម្បីធ្វើ |
| ចរ | + | ឥ | + | តុំ | > ចរិតុំ | ដើម្បីត្រាច់ទៅ |
| លភ | + | ឥ | + | តុំ | > លភិតុំ | ដើម្បីបាន |
| សម | + | ឥ | + | តុំ | > សមិតុំ | ដើម្បីរម្ងាប់ |

| | | | | | |
|---|---|---|---|---|---|
| បច | + ឥ | + តុំ | | > បចិតុំ | ដើម្បីចម្អិន |
| សុ | + ឥ | +ណា | + តុំ | > សុណិតុំ | ដើម្បីស្ដាប់ |
| ពុជ | + ឥ | + យ | + តុំ | > ពុជ្ឈិតុំ | ដើម្បីត្រាស់ដឹង |
| គហ | + ឥ | +ណ្ហា | + តុំ | > គណ្ហិតុំ | ដើម្បីកាន់យក |
| សិច | + ឥ | + -ំ | + តុំ | > សិញ្ចិតុំ | ដើម្បីស្រោច |
| ជិ | + ឥ | + នា | + តុំ | > ជិនិតុំ | ដើម្បីឈ្នះ |
| ឆិទ | + ឥ | + -ំ | + តុំ | > ឆិន្ទិតុំ | ដើម្បីកាត់ |
| កី | + ឥ | +ណា | + តុំ | > កីណិតុំ | ដើម្បីទិញ |

១.១០ ធាតុខ្លះមានវិធីផ្លាស់ជារូបផ្សេង ៗ ទៀតដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|
| បា | + តុំ | > បិវិតុំ | ដើម្បីផឹក |
| ករ | + តុំ | > កាតុំ | ដើម្បីធ្វើ (ករ > កា) |
| សី | + តុំ | > សយិតុំ | ដើម្បីដេក |
| ភូ | + តុំ | > ភវិតុំ | ដើម្បីកើត |

១.១១ ចំពោះពួក ចុរ ធាតុត្រូវចុះ ណោ បច្ច័យសិនទើបចុះ តុំ បច្ច័យដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ | + ណេ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ទិស | + ណេ | + តុំ | > ទេសេតុំ | ដើម្បីសំដែង |
| ចុរ | + ណេ | + តុំ | > ចោរេតុំ | ដើម្បីលួច |
| ចិន្ត | + ណេ | + តុំ | > ចិន្តេតុំ | ដើម្បីគិត |

## ២. វិធីចុះ តុំ បច្ច័យជាហេតុកត្តុវាចក:

*បើត្រូវប្រែកបរូបកិរិយាជាហេតុកត្តុវាចក: ត្រូវចុះហេតុប្បច្ច័យផង ដូចឧទាហរណ៍ខាងក្រោមនេះ*

| ធាតុ | + បច្ច័យ | + តុំ | សម្រេចជា | ពាក្យប្រែ |
|---|---|---|---|---|
| ករ | + ណេ | + តុំ | > ការេតុំ | ដើម្បីឱ្យធ្វើ |
| មរ | + ណេ | + តុំ | > មារេតុំ | ដើម្បីឱ្យស្លាប់ |
| រុជ | + ណាបេ | + តុំ | > រុជ្ឈាបេតុំ | ដើម្បីឱ្យបិទ |
| សិរ | + ណាបេ | + តុំ | > សិញ្ញាបតុំ | ដើម្បីឱ្យដេរ |
| កី | + ណាបេ | + តុំ | > កីណាបេតុំ | ដើម្បីឱ្យទិញ |
| សុ | + ណេ | + តុំ | > សាវេតុំ | ដើម្បីឱ្យស្តាប់ |
| គហ | + ណាបេ | + តុំ | > គាហាបេតុំ | ដើម្បីឱ្យកាន់យក |
| ចុរ | + ណេ | + តុំ | > ចោរេតុំ | ដើម្បីឱ្យលួច |

# កំណត់សម្គាល់

១. តុំ បច្ច័យមិនប្រាប់ឱ្យដឹងថាជាកត្តុវាចកៈឬកម្មវាចកៈទេ ប៉ុន្តែកាលណាបទប្រធានមានរូបជាតតិយាវិភត្តិ នោះជាកម្មវាចកៈ ។ បើបទប្រធានមានរូបជាបឋមាវិភត្តិ នោះជាកត្តុវាចកៈ ។ ប្រសិនបើប្រកបរូបពីសកម្មធាតុតែងតែមានបទកម្មក្នុងរូបជាទុតិយាវិភត្តិ ហើយវេលាប្រែត្រូវអានគួបស័ព្ទទាំងឡាយណាដែលនៅខាងដើម និងគួរចូលជាមួយ តុំ បច្ច័យស័ព្ទទាំងអស់ហៅថា "ប្រែរួប" បើពុំនោះទេសេចក្តីនៃប្រយោគនឹងមិនពេញលេញទេ ។

២. តុំ បច្ច័យបើប្រើក្នុងន័យបដិសេធគឺត្រូវប្រើ **ន** ផ្លាស់ជា **អ** ឬ **អន** ប្រកបខាងដើមដូចជា **អកាតុំ**=ដើម្បីមិនធ្វើ គឺមានគតិដូច **ត**, **អន្ត**, **មាន** បច្ច័យដែលពោលហើយដែរ ។

# វិធីប្រើនិងប្រែ តុំ បច្ច័យក្នុងប្រយោគ

១. ប្រើក្នុងអត្ថជា **ចតុត្ថីវិភត្តិ** មានពីរបែបដែលហៅតាមសម្ព័ន្ធថា **តុមត្ថសម្បទាន** ពីព្រោះប្រែថា "ដើម្បី..." ដូចចតុត្ថីវិភត្តិដែរ ។

១.១ និយមរៀងខាងដើមជាប់នឹងមហាកិរិយា និងត្រូវប្រែបន្ទាប់ពីមហាកិរិយានោះៗ ។ មហាកិរិយាដែលប្រើដូច្នេះបានមានតិចតួចទេដូចជា **ឥច្ឆតិ**, **សក្កោតិ**, **អរហតិ**, **ឧស្សហតិ**, **វាយាតិ**, **អារភតិ** ជាដើម

សូមមើលឧទាហរណ៍ខាងក្រោមនេះ

**១. កស្សកោ ខេត្តំ <u>កសិតុំ</u> ឥច្ឆតិ ។**

*កសិករ ចង់ <u>ដើម្បីភ្ជួរ</u> នូវស្រែ ។*

**២. ទានំ ទត្វា សីលំ រក្ខិត្វា សគ្គេ <u>និព្វត្តុំ</u> សក្កោន្តិ ។**

*(គេ.ទ.) ឱ្យហើយ នូវទាន រក្សាហើយ នូវសីល រមែងអាច <u>ដើម្បីកើត</u> ក្នុងឋានសួគ៌ ។*

**៣. សក្កោសិ ចាលិភាសំ <u>សល្លបិតុំ</u> ។**

*(លោក)អាច <u>ដើម្បីសន្ទនា</u> នូវភាសាបាលី ឬ ?*

*(លោកចេះនិយាយភាសាបាលីឬ ?) ។*

**៤. បណ្ឌិតោ បណ្ឌិតស្ស បិណ្ឌំ <u>បដិគ្គហេតុំ</u> អរហតិ ។**

*បណ្ឌិត គួរ <u>ដើម្បីទទួល</u> នូវដុំបាយ របស់បណ្ឌិត ។*

*១.២ ប៉ុន្តែបើមហាកិរិយាជាសកម្មកិរិយាស័ព្ទវិញ ត្រូវប្រែក្រោយបទនានាដូចជាបទកម្មជាដើម ដូចឧទាហរណ៍ខាងក្រោមនេះ*

**១. ទារកោ ផលានិ <u>ខាទិតុំ</u> រុក្ខំ អារុហតិ ។**

*ក្មេងប្រុស កំពុងឡើង ដើមឈើ <u>ដើម្បីស៊ី</u> នូវផ្លែ.ទ. ។*

**២. មនុស្សា សមណេហិ បញ្ហេ <u>បុច្ឆិតុំ</u> វិហារំ អាគច្ឆន្តិ ។**

*មនុស្ស.ទ. មក កាន់វិហារ <u>ដើម្បីសួរ</u> នូវបញ្ហា.ទ. ពីសមណៈ ។*

**៣. ព្រាហ្មណោ ចោរំ សច្ចំ <u>ភាសាបេតុំ</u> វាយាតិ ។**

*ព្រាហ្មណ៍ ព្យាយាម ញុំាងចោរ <u>ដើម្បីឱ្យនិយាយ</u> នូវការពិត ។*

២. ប្រើក្នុងអត្ថជា **បឋមាវិភត្តិ** ហៅតាមសម្ព័ន្ធថា **តុមត្ថកត្តា** ត្រូវប្រែថា "រីកិរិយា..." ដូចបឋមាវិភត្តិដែរ ច្រើនតែប្រើក្នុងប្រយោគដែលមានកិរិយាស័ព្ទថា **វដ្តតិ** =គួរ, ត្រូវ., និងនិបាតស័ព្ទ **អលំ** =គួរ, **សក្កា** អព្យយស័ព្ទប្រែថា "អាច" ប៉ុន្តែមិនមែនជា **តុមត្ថហេតុកត្តា** ឬ **តុមត្ថវុតកម្ម** ឡើយដូចឧទាហរណ៍ខាងក្រោមនេះ

**១. ផរុសំ វាចំ <u>វត្តុំ</u> ន វដ្តតិ ។**

<u>រីកិរិយាពោល</u>នូវវាចាដែលទ្រគោះ រមែងមិនគួរ ។

(ការនិយាយពាក្យអាក្រក់មិនសមគួរទេ)

**២. មយា តត្ថ <u>គន្តុំ</u> វដ្តតិ ។**

<u>រីកិរិយា</u>គឺអញ<u>ទៅ</u>ក្នុងទីនោះ ទើបគួរ ។

**៣. តុម្ហេហិ អជ្ជ ឧឡារំ ពុទ្ធសក្ការំ <u>កាតុំ</u> វដ្តតិ ។**

<u>រីកិរិយា</u>គឺអ្នក.ទ.<u>ធ្វើ</u>នូវសក្ការដល់ព្រះពុទ្ធដ៏លើសលុបក្នុងថ្ងៃនេះ ទើបគួរ ។

## វិធីរូបសិទ្ធិជាកិតកិរិយាជាមួយ តវេ បច្ច័យ

**តវេ** តាមរូបស័ព្ទប្រហែលគ្នានឹង **តាវេ** ដែរ ដូច្នេះវិធីប្រកបជាកិរិយាក៏មិនសូវខុសគ្នាទេ ។ ប៉ុន្តែនៅពេលចុះហើយមានដំណើរប្រែដូច តុំ ហើយនិងប្រើបានតែជាកិរិយាស័ព្ទប៉ុណ្ណោះ ។

កិតកិរិយាដែលប្រកបពី **តវេ** បច្ច័យពុំចាំបាច់បំបែកទេព្រោះជាអព្យយបច្ច័យ ។

១. បើទីបំផុតធាតុជា **ន** ទុក **ន** ឱ្យគង់រូបដើមនិងត្រូវតម្រួតជា **ន្តវេ** ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តវេ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ហន + តវេ | > ហន្តវេ | ដើម្បីសម្លាប់ |
| ខន + តវេ | > ខន្តវេ | ដើម្បីជីក |

២. បើទីបំផុតធាតុជា **ម** ត្រូវផ្លាស់ **ម** > **ន** និងត្រូវតម្រួតជា **ន្តវេ** ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តវេ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| គម + តវេ | > គន្តវេ | ដើម្បីទៅឬដល់ |
| សម + តវេ | > សន្តវេ | ដើម្បីរម្ងាប់ |

៣. បើទីបំផុតធាតុជា **ទ** ត្រូវផ្លាស់ **ទ** > **ត** និងត្រូវតម្រួតជា **ត្តវេ** ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តវេ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| បទ + តវេ | > បត្តវេ | ដើម្បីសម្រេច |

៤. បើទីបំផុតធាតុជាស្រៈ **អា**, ទុកស្រៈ **អា** ឱ្យគង់រូបដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តវេ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ទា + តវេ | > ទាតវេ | ដើម្បីឱ្យ |
| ញា + តវេ | > ញាតវេ | ដើម្បីដឹង |
| ប+ហា + តវេ | > បហាតវេ | ដើម្បីលះបង់ |
| ចា + តវេ | > ចាតវេ | ដើម្បីផឹក |

៥. បើទីបំផុតធាតុជាស្រៈ ឦ, ត្រូវព្រឹទ្ធិស្រៈ ឦ > ឯ ដូចឧទាហរណ៍ខាងក្រោមនេះ

| ធាតុ + តវេ | សម្រេចជា | ពាក្យប្រែ |
|---|---|---|
| ឌី + តវេ | > ឌេតវេ | ដើម្បីនាំទៅ |

៦. បើចុះជាមួយ ករ ធាតុត្រូវផ្លាស់ ករ > កា ដូចឧទាហរណ៍ខាងក្រោមនេះ

ករ > កា + តវេ > កាតវេ =ដើម្បីធ្វើ

(បើមិនផ្លាស់ជា កា ទេ អាចផ្លាស់ទីបំផុតធាតុជា ត ជា ត្ត ដូចខាងក្រោមនេះ ។)

(ករ + តវេ > កត្តវេ)

## វិធីប្រើនិងប្រែ តវេ បច្ច័យក្នុងប្រយោគ

១. មយំ កិលេសំ <u>បហាតវេ</u> ធម្មំ ចរាម ។

*យើង.ទ. កំពុងប្រព្រឹត្ត នូវធម៌ <u>ដើម្បីលះ</u> នូវកិលេស ។*

២. សោ បុញ្ញានិ <u>កាតវេ</u> ឥច្ឆតិ ។

*គាត់ ប្រាថ្នា <u>ដើម្បីធ្វើ</u> នូវបុណ្យ ។*

## ធាតុសព្ទ (ត)

| ធាតុសព្ទ | ពាក្យប្រែ | ធាតុសព្ទ | ពាក្យប្រែ |
|---|---|---|---|
| វិធ | បាញ់ | អធិ + គម | សម្រេច |
| អា + រភ | ប្រារព្ធ | សំ + លប | សន្ទនា |
| ឃា | ហិត, ស្រូប | វិ + អា + យម | ព្យាយាម |
| ជល | អុជ, ដុត | អា + កង្ខ | ប៉ុនប៉ង |
| វិទ | ដឹង | ឧ + សហ | ប្រឹងប្រែង |

## នាមសព្ទ (ត)

| សព្ទបាលី | ពាក្យប្រែ | សព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ធនវន្តុ ន. | អ្នកមានទ្រព្យ | បីឋ នបុំ. | កៅអី |
| អលាត នបុំ. | រងើកភ្លើង | លោចន នបុំ. | ភ្នែក |
| កូល នបុំ. | ប្រាំង | ធាតុ ឥ. | ឆ្អឹង, ធាតុ |

| | | | |
|---|---|---|---|
| វាបិ ឥ. | ត្រពាំង, បឹង | កុសុម នបុំ. | ផ្កាឈើ |
| បញ្ហា ឥ. | សំនួរ, បញ្ហា | សុវណ្ណ នបុំ. | មាស |
| មូល នបុំ. | គល់, ឫស | សោបាណ បុំ. | ជណ្តើរ |
| មរណ នបុំ. | សេចក្តីស្លាប់ | សិខី បុំ. | ក្ងោក |
| បុលិន នបុំ. | ខ្សាច់ | ឃាន នបុំ. | ច្រមុះ |
| សុវ បុំ. | សេក | អណ្ឌ នបុំ. | ពង, ស៊ុត |

# លំហាត់នៃមេរៀនទី ២២

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

១. *តើ* **តវន្តុ** *និង* **តាវី** *ប្រើក្នុងវាចកៈអ្វីខ្លះ ?*

២. *តើ* **តុំ** *និង* **តវេ** *ជាបច្ច័យប្រភេទអ្វី ?*

៣. *តើ* **តុំ** *បច្ច័យប្រើបានយ៉ាងដូចម្តេចខ្លះ ? សូមឱ្យឧទាហរណ៍ ។*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

១. ធនវន្តោ យាចកានំ ធនំ ទាតុំ ន ឥច្ឆន្តិ ។

២. ទានំ ទត្វា សីលា រក្ខិត្វា សគ្គេ និព្វត្តុំ សក្កោន្តិ ។

៣. កុមារី អលាតំ អានេត្វា ភត្តំ បចិតុំ អគ្គឹ ជាលេស្សតិ ។

៤. នារិយោ ឃរា និក្ខម្ម ឧទកំ បាតុំ វាបិយា កូលំ គច្ឆឹសុ ។

៥. កសកោ អរញ្ញា ផលានិ អាហរិត្វា ខាទិតុំ អារភឹសុ ។

៦. សីលវា ឥសិ ជម្មំ ទេសេតុំ បីឋេ និសីទិ ។
៧. មយំ លោចនេហិ រូបានិ បស្សិត្វា សុខំ ទុក្ខំ ច លភាម ។
៨. ត្វំ សោតេន សុណិតុំ ឃានេន ឃាយិតុំ ច សក្កោសិ ។
៩. កុក្កុដិយា អណ្ឌានិ រុក្ខស្ស មូលេ សន្តិ ។
១០. វិទុនោ អមតំ លភិត្វា មរណំ ន ភាយន្តិ ។
១១. មនុស្សា ចិត្តេន ចិន្តេត្វា បុញ្ញានិ ការិស្សន្តិ ។
១២. ជនវន្តោ សុវណ្ណំ ទត្វា ញាណំ លទ្ធុំ ន សក្កោន្តិ ។
១៣. ទារកោ ឆត្តំ គណ្ហិតុំ សោបាណំ អារុហិ ។
១៤. មម ភគិនី បុញ្ញំ លភិតុំ សីលំ រក្ខិស្សតិ ។
១៥. យុវតិយោ បទុមានិ ឱចិនិតុំ នទឹ គន្ត្វា កូលេ និសីទឹសុ ។
១៦. តុម្ហេ ជម្មំ សោតុំ អារាមំ គន្ត្វា បុលិនេ និសីទថ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. ពពែ.ទ. ដើរទៅ ក្នុងព្រៃ ដើម្បីស៊ី ស្មៅ ។*
*២. សំឡាញ់.ទ. ទៅហើយ កាន់សួន ដើម្បីលេង ជាមួយឆ្កែ របស់គេ.ទ. ។*
*៣. ក្មេងប្រុស.ទ. ឡើងហើយ ដើមឈើ ដើម្បីស៊ី ផ្លែ.ទ. ។*
*៤. ប្រសិនបើ ក្ងោក រស់នៅ ក្នុងភ្នំ ខ្ញុំ នឹងប្រឹងប្រែង ដើម្បីឡើង លើភ្នំ ដើម្បីឃើញ វា.ទ.(ក្ងោក) ។*
*៥. នារី.ទ. មួយអន្ទើ ដោយប្តី.ទ. ទៅហើយ កាន់ទន្លេ ប្រារព្ធហើយ*

ដើម្បីផ្ញួត(ទឹក) ។

៦. គេ ឡើង កាន់ភ្នំ ជាមួយព្រាន ដើម្បីមើល នូវបក្សី.ទ. ដែលកំពុងរស់នៅ លើភ្នំ ។

៧. គហបតី ចូលទៅជិតហើយ នូវឥសី ដែលប៉ុនប៉ង ដើម្បីសួរ នូវបញ្ហា.ទ. ។

៨. យើង.ទ. ទៅហើយ កាន់វិហារ ដើម្បីថ្វាយបង្គំ នូវព្រះធាតុ របស់ព្រះពុទ្ធ ។

១០. អ្នកប្រាជ្ញ រស់នៅ ក្នុងវិហារ ក្បែរស្រុក យល់ហើយ នូវសច្ចធម៌ ចុះហើយ ពីភ្នំ ដើម្បីសំដែង នូវព្រះធម៌ ដល់មនុស្ស.ទ. ។

១១. អ្នក.ទ. ចូរកុំធ្វើ អំពើអាក្រក់ ប្រសិនបើ ធ្វើ នឹងមិនបាន ដើម្បីប្រទះ នូវសេចក្តីសុខឡើយ ។

១២. គេ កំពុងបង្កាត់ នូវភ្លើង ដើម្បីចម្អិន បាយ ផង បបរ ផង សំរាប់ភ្ញៀវ.ទ. ដែលកំពុងមក ពីក្រុង ។

១៣. នារី.ទ. ដែលកំពុងទៅ ដើម្បីនាំមក នូវទឹក កាលសន្ទនា ឃើញហើយ នូវផ្កាឈើ.ទ. ធ្លាក់ហើយ ក្បែរគល់ឈើ.ទ. ។

១៤. ព្រានព្រៃ បាញ់ហើយ នូវសេក ដោយសរ ដែលកំពុងព្យាយាម ដើម្បីស៊ី នូវផ្លែ ដោយចំពុះ របស់វា ។

**(ចប់មេរៀនទី ២២)**

# មេរៀនទី ២៣

## អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ

(Special nouns)

*ពាក្យថា* **បកិណ្ណក** *ប្រែថា "រាត់រាយ, រាយរង, បន្ទាប់បន្សំ" ។* **បកិណ្ណកនាម** *ជានាមរាយរងដែលមានវិធីបំបែកប្លែកពីការបំបែកនាមនាមដូចបានពោលរួចហើយក្នុងមេរៀនខាងដើម មាន ១៣ ស័ព្ទ ដូចខាងក្រោមនេះ*

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អត្ត | ខ្លួន, អាត្មា | ព្រហ្ម | ព្រហ្ម |
| រាជ | ស្តេច, ព្រះរាជា | សខ | សំឡាញ់ |
| អរហន្ត | ព្រះអរហន្ត | ភគវន្តុ | ព្រះមានព្រះភាគ, ព្រះមានជោគ |
| ភវន្ត | អ្នកដ៏ចំរើន | | |
| សត្ថុ | គ្រូ, សាស្តា | មាតុ | ម្តាយ, មាតា |
| បិតុ | ឪពុក, បិតា | កម្ម | អំពើ, កម្ម |
| មន | ចិត្ត | គោ | គោ |

## កំណត់សម្គាល់

*សូមសង្កេតមើលស័ព្ទទាំងឡាយខាងលើនេះខ្លះជា* អ *ការន្តខ្លះជា* ឧ *ការន្តនិង* គោ *ជា* ឱ *ការន្តដែលមានតែមួយស័ព្ទគត់ក្នុងភាសា*

បាលី ។ ស័ព្ទខ្លះប្រើបានតែមួយលិង្គទេ ខ្លះបានពីរលិង្គនិងខ្លះមានរូបត្រឹមតែជាឯកវចនៈមិនមានរូបជាពហុវចនៈទេ ដូច្នេះស័ព្ទណាមានវិធីបំបែកយ៉ាងម៉េចនិងមានអធិប្បាយដូចតទៅនេះ ។

## វិធីបំបែកបកិណ្ណកនាមស័ព្ទ

ដូចបានពោលហើយថា ស័ព្ទពួកនេះមានវិធីបំបែកប្លែកពីនាមស័ព្ទទូទៅដែលអាចហៅថា វិធីបំបែកតាមព្យញ្ជនៈក៏បាន ពីព្រោះមានចុះព្យញ្ជនៈបន្ថែម ។ រីឯការបំបែកមុន ៗ អាចហៅថា វិធីបំបែកតាមស្រៈក៏បាន ។

ដូច្នេះដើម្បីឱ្យងាយស្រួលក្នុងការបំបែកត្រូវចែកស័ព្ទទាំងនេះជាពួក ៗ ទៀតគឺ **រាជ**, **អត្ត**, **ព្រហ្ម**, **សខ** ជាពួកទី ១, **ភគវន្តុ**, **អរហន្ត**, **ភវន្ត** ជាពួកទី ២, **សត្ថុ**, **បិតុ**, **មាតុ** ជាពួកទី ៣, **មន** ជាពួកទី ៤, ពួកឯកស័ព្ទមាន **កម្ម**, **គោ** ជាពួកទី ៥ ។

## វិធីបំបែកពួកទី ១ (រាជាទិគណៈ)

១. **រាជ** ស័ព្ទជា **អ** ការន្តបុំលិង្គ ។ ប្រសិនបើជាស្តេចស្រីជា **រាជិនី** ត្រូវចុះ **ឥនី** ខាងចុង **រាជ**, ជា **ឦ** ការន្តឥត្ថីលិង្គមានវិធីបំបែកដូច **នារី** ក្នុងទីនេះនឹងអធិប្បាយត្រឹមតែវិធីបំបែក **រាជ**, **អ** ការន្ត បុំលិង្គមួយទេ ។

# វិភត្តិសម្រេចរបស់ រាជ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | អានោ |
| ទុ. | អានំ | អានោ |
| ត. | អញ្ញា | ឩហិ, ឩភិ |
| ច. | អញ្ញោ, ឥនោ | អញ្ញំ, ឩនំ |
| បញ្ច. | អញ្ញា | ឩហិ, ឩភិ |
| ឆ. | អញ្ញោ, ឥនោ | អញ្ញំ, ឩនំ |
| ស. | អញ្ញោ, ឥនិ | ឩសុ |
| អា. | អ | អានោ |

# វិធីបំបែក រាជ =ព្រះរាជា

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | រាជា | រាជានោ |
| ទុ. | រាជានំ, រាជំ | រាជានោ |
| ត. | រញ្ញា | រាជូហិ, រាជូភិ |
| ច. | រញ្ញោ, រាជិនោ | រញ្ញំ, រាជូនំ |
| បញ្ច. | រញ្ញា | រាជូហិ, រាជូភិ |

| | | |
|---|---|---|
| ឆ. | រញ្ញោ, រាជិនោ | រញ្ញំ, រាជូនំ |
| ស. | រញ្ញោ, រាជិនិ | រាជូសុ |
| អា. | រាជ, រាជា | រាជានោ |

## កំណត់សម្គាល់

១. តាមការបំបែកខាងលើនេះ ឃើញថាមានរូបជាច្រើនចុះ **ណ** ព្យញ្ជនៈបន្ថែម អាស្រ័យហេតុនេះហើយទើបបានហៅថាជាការបំបែកតាមព្យញ្ជនៈក៏បាន ។

២. ពាក្យថា **រាជ** មកពី **រាជ** ធាតុប្រែថា "រុងរឿង, ភ្លឺស្វាង" ។

៣. ពាក្យថា **រញ្ញា** ក្នុងរូបតតិយាវិភត្តិនិងបញ្ចមីវិភត្តិឯកវចនៈត្រូវយក **រាជ** សព្ទមកផ្សំនឹង **អញ្ញា** ដូច្នេះ (**រាជ** + **អញ្ញា**) > **រញ្ញា** ។ រីឯវិភត្តិដទៃទៀតគឺ **រញ្ញោ**, **រញ្ញេ**, **រញ្ញំ** ក៏មានវិធីផ្សំដូចនេះដែរ ។

៤. នៅមានការបំបែកផ្សេងទៀតដូចជាក្នុង ទុ.វិ.ឯក. មានរូបជា **រាជំ** ។ ត.វិ.ឯក. ជា **រាជេន**, **រាជិនា** ។ ត.និងបញ្ច.វិ.ពហុ. ជា **រាជេហិ**, **រាជេភិ** ។ ច.និងឆ.វិ.ឯក. ជា **រញ្ញស្ស**, **រាជស្ស**., និងខាងពហុ. ជា **រាជានំ** ។ ស.វិ.ឯក. ជា **រាជស្មឹ**, **រាជម្ហិ**., និងពហុ. ជា **រាជេសុ** ។

៥. **រាជ** សព្ទបើមានសព្ទដទៃនាំមុខជាបទសមាសនិងមាន **រាជ** ជាបទចុងដូចពាក្យថា **មហារាជ**=ព្រះរាជាដ៏ប្រសើរ មានវិធីបំបែកបាន

*ពីរយ៉ាងគឺបំបែកតាមបែប បុរិស និងតាមបែប រាជ ដូចខាងក្រោមនេះ*

## វិធីបំបែក មហារាជ =ព្រះរាជាដ៏ប្រសើរ

## បំបែកតាមបែប បុរិស

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | មហារាជោ, -រាជា | មហារាជា |
| *ទុ.* | មហារាជំ | មហារាជេ |
| *ត.* | មហារាជេន | មហារាជេហិ, -រាជេភិ |
| *ច.* | មហារាជស្ស, -រាជាយ | មហារាជានំ |
| *បញ្ច.* | មហារាជស្មា, -រាជម្ហា, -រាជា | មហារាជេហិ, -រាជេភិ |
| *ឆ.* | មហារាជស្ស | មហារាជានំ |
| *ស.* | មហារាជស្មឹ, -រាជម្ហិ, -រាជេ | មហារាជេសុ |
| *អា.* | មហារាជ | មហារាជាណោ |

## វិធីបំបែក មហារាជ

## តាមបែប រាជ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មហារាជា | មហារាជា, -រាជានោ |
| ទុ. | មហារាជំ, -រាជានំ | មហារាជានោ |
| ត. | មហារញ្ញា, -រាជិនា | មហារាជូហិ, -រាជូភិ |
| ច. | មហារញ្ញោ, -រាជិនោ | មហារញ្ញំ, -រាជូនំ |
| បញ្ច. | មហារញ្ញា | មហារាជូហិ, -រាជូភិ |
| ឆ. | មហារញ្ញោ, -រាជិនោ | មហារញ្ញំ, មហារាជូនំ |
| ស. | មហារញ្ញេ, -រាជិនិ | មហារាជូសុ |
| អា. | មហារាជ | មហារាជានោ |

*ខាងក្រោមនេះជាស័ព្ទដែលមាន រាជ នៅខាងចុង*

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| អភិរាជ | ស្តេចដ៏ប្រសើរ | អនុរាជ | ស្តេចតូច |
| អធិរាជ | ស្តេចដ៏ប្រសើរ | ឧបរាជ | ឧបរាជ |
| ចក្កវត្តិរាជ | ស្តេចចក្រពត្តិ | ទេវរាជ | ស្តេចនៃទេវតា |
| មិគរាជ | ស្តេចម្រឹគ | ហំសរាជ | ស្តេចហង្ស |
| នាគរាជ | ស្តេចនាគ | ធម្មរាជ | ស្តេចដោយធម៌ |
| សុបណ្ណរាជ | ស្តេចគ្រុឌ | មច្ចុរាជ | មច្ចុរាជ |

## ឧទាហរណ៍នៃការប្រើ រាជ ស័ព្ទ

១. ពារាណសិយំ រញ្ញោ ហត្ថី អរញ្ញំ បវិសិ ។

*ដំរី របស់ស្ដេច ក្នុងក្រុងពារាណសី ចូលទៅហើយ កាន់ព្រៃ ។*

២. សាវត្ថិយំ ឥស្សរោ រាជា រាជបុរិសេ ឯកំ អមច្ចំ បក្កោសាបេតិ ។ *ស្ដេច ជាធំ ក្នុងក្រុងសាវត្ថី ញ៉ាំងរាជបុរស.ទ. ឱ្យហៅ នូវ អាមាត្យ ម្នាក់ ។*

៣. ពុទ្ធោ រាជូនំ ឱវាទំ ទេតិ ។

*ព្រះពុទ្ធ ទ្រង់ប្រទាន នូវឱវាទ ដល់ស្ដេច.ទ. ។*

៤. កោសម្ពិយំ ឥស្សរោ មហារាជា កាបិលវត្ថុស្មឹ រញ្ញោ គាមវរំ អទាសិ ។ *មហារាជ ជាធំ ក្នុងក្រុងកោសម្ពី បានប្រទានហើយ នូវស្រុក ដ៏ប្រសើរ ដល់ស្ដេច ក្នុងក្រុងកបិលវត្ថុ ។*

៥. ជាតិយា ថទ្ធោ រាជា មហាជនំ អវមញ្ញតិ ។

*ព្រះរាជា ជាអ្នករឹងត្អឹង ដោយជាតិ តែងមើលងាយ នូវមហាជន ។*

២. ព្រហ្ម ស័ព្ទប្រែថា "ព្រះព្រហ្ម ឬ ព្រហ្ម" ជានាមនាម អ ការន្ត និងជាបុំលិង្គតែម៉្យាង បំបែកបានទាំងពីរវចនៈមានរូបផ្សេង ៗ ដូចតទៅនេះ

## វិភត្តិសម្រេចរបស់ ព្រហ្ម ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | អានោ |
| ទុ. | អានំ, អំ | អានោ |
| ត. | ឧនា | ឯហិ, ឯភិ |
| ច. | ឧនោ, អស្ស | អានំ, ឩនំ |
| បញ្ច. | ឧនា | ឯហិ, ឯភិ |
| ឆ. | ឧនោ, អស្ស | អានំ, ឩនំ |
| ស. | អនិ | ឯសុ |
| អា. | អ, ឯ | អានោ |

មានវិធីផ្សំដូច្នេះ ( ព្រហ្ម + អា > ព្រហ្មា, ព្រហ្ម + អានោ > ព្រហ្មានោ ) ។

## វិធីបំបែក ព្រហ្ម =ព្រះព្រហ្ម

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ព្រហ្មា | ព្រហ្មានោ |
| ទុ. | ព្រហ្មានំ, ព្រហ្មំ | ព្រហ្មានោ |
| ត. | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |
| ច. | ព្រហ្មុនោ, ព្រហ្មស្ស | ព្រហ្មានំ, ព្រហ្មូនំ |

| | | |
|---|---|---|
| *បញ្ច.* | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |
| *ឆ.* | ព្រហ្មុនោ, ព្រហ្មស្ស | ព្រហ្មានំ, ព្រហ្មូនំ |
| *ស.* | ព្រហ្មនិ | ព្រហ្មេសុ |
| *អា.* | ព្រហ្ម, ព្រហ្មេ | ព្រហ្មានោ |

## កំណត់សម្គាល់

*ពាក្យថា* ព្រហ្ម *នេះប្រសិនបើមានសព្ទដទៃនាំមុខដូចជាពាក្យថា* មហាព្រហ្ម *ជាដើមក៏មានវិធីបំបែកដូច* ព្រហ្ម *គ្រប់វិភត្តិ ដូចការបំបែកនៅខាងលើ និងជាបុំលិង្គតែម្យ៉ាងប៉ុណ្ណោះ ។*

## ឧទាហរណ៍នៃការប្រើ ព្រហ្ម សព្ទ

១. ព្រហ្មា ពុទ្ធស្ស បរិវិត្តកំ អជានិ ។

*ព្រះព្រហ្ម បានជ្រាបហើយ នូវសេចក្តីត្រិះរិះ របស់ព្រះពុទ្ធអង្គ ។*

២. សេន វិមានេន <u>អសន្តុដ្ឋោ</u> ព្រហ្មា ទុក្ខំ អនុភវតិ ។

*ព្រហ្ម <u>ដែលមិនសន្តោស</u> ដោយវិមាន របស់ខ្លួន តែងសោយ នូវសេចក្តីទុក្ខ ។*

*មានសព្ទខ្លះទៀតដែលបំបែកដូច* ព្រហ្ម *ដែរគឺ* បុម *=ប្រុស,* យុវ *= កម្លោះ,* មុទ្ធ *=ក្បាល និង* អទ្ធ *=ផ្លូវ, ពេល, វេលា ។*

## វិធីបំបែក បុម =ប្រុស, ឈ្មោល

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | បុមា | បុមានោ, បុមា |
| *ទុ.* | បុមានំ, បុមំ | បុមានេ |
| *ត.* | បុមុនា, បុមានា, បុមេន | បុមានេហិ, បុមានេភិ |
| *ច.* | បុមុនោ, បុមស្ស | បុមានំ |
| *បញ្ច.* | បុមុនា, បុមានា | បុមានេហិ, បុមានេភិ |
| *ឆ.* | បុមុនោ, បុមស្ស | បុមានំ |
| *ស.* | បុមានេ, បុមេ | បុមានេសុ, បុមាសុ |
| *អា.* | បុម, បុមំ | បុមានោ |

## ប្រយោគឧទាហរណ៍

យថា ពលាកាយោនិម្ហិ ន វិជ្ជតិ បុមា សទា មេឃេសុ គជ្ជមានេសុ គព្ភំ គណ្ហន្តិ តា សទា ។ *វីឈ្មោល.ទ. មិនមាន ក្នុងហ្វូង ត្រដក់.ទ. ជានិច្ច ដោយប្រការ ណា កាលគ្រហឹម ក្នុងមេឃ ត្រដក់ញី.ទ.*

កាន់យក នូវគភ៌(មានផ្ទៃ) ជានិច្ច ។

**បុម** ស័ព្ទក្នុងសៀវភៅខ្លះប្រាប់ថាមានវិធីបំបែក ២ បែប គឺមួយបែបទៀតបំបែកតាមរបៀប **បុរិស** ។ **យុវ** =កម្លោះ ក៏មានវិធីបំបែកដូច **បុម** នេះដែរ ។

## វិធីបំបែក មុទ្ធ =ក្បាល

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | មុទ្ធា | មុទ្ធា, មុទ្ធានោ |
| *ទុ.* | មុទ្ធំ | មុទ្ធេ, មុទ្ធានេ |
| *ត.* | មុទ្ធានា | មុទ្ធេហិ, មុទ្ធេភិ |
| *ច.* | មុទ្ធស្ស | មុទ្ធានំ |
| *បញ្ច.* | មុទ្ធា, មុទ្ធានា | មុទ្ធេហិ, មុទ្ធេភិ |
| *ឆ.* | មុទ្ធស្ស | មុទ្ធានំ |
| *ស.* | មុទ្ធនិ | មុទ្ធានេសុ |
| *អា.* | មុទ្ធ | មុទ្ធា, មុទ្ធានោ |

## វិធីបំបែក អទ្ធ =ផ្លូវ, វេលា

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | អត្ថា | អត្ថា, អត្ថានោ |
| *ទុ.* | អត្ថានំ | អត្ថានេ |
| *ត.* | អត្តុនា | អត្ថានេហិ, អត្ថានេភិ |
| *ច.* | អត្តុនោ | អត្ថានំ |
| *បញ្ច.* | អត្តុនា | អត្ថានេហិ, អត្ថានេភិ |
| *ឆ.* | អត្តុនោ | អត្ថានំ |
| *ស.* | អត្តនិ, អត្ថានេ | អត្ថានេសុ |
| *អា.* | អត្ត, អត្ថា | អត្ថា, អត្ថានោ |

## ប្រយោគឧទាហរណ៍

១. តទហុ បព្វជិតោ សន្តោ ជាតិយា សត្តវស្សិកោ សោ បិ មំ អនុសាសេយ្យ សម្បដិច្ឆាមិ មុទ្ធានា ។

*ក្នុងថ្ងៃនោះ បព្វជិត ដែលមាន ឆ្នាំប្រាំពីរ ដោយកំណើត (កើតបាន៧ឆ្នាំ) ក៏ គាត់ គប្បីបង្រៀន នូវខ្ញុំ, ខ្ញុំ នឹងទទួលព្រម ដោយក្បាល (ឱនក្បាលគោរព) ។*

២. ឱយស្ស អត្តុនោ អច្ចយេន តស្ស មហានិរយស្ស បុរត្ថិមំ ទ្វារំ អវាបុរីយតិ ។ (*ទោស*) *នៃកាល ដ៏យូរ តែងបើក នូវទ្វារ ក្នុងទិសខាងកើត នៃមហានរក នោះ ដោយកាលជាទីកន្លងទៅ ។*

៣. **សខ** ប្រែថា "សំឡាញ់" ជា អ ការន្តបុំលិង្គដែរ ។ **សខ** អាចជាឥត្ថីលិង្គបានដែរដោយថែមស្រៈ **ឦ** ទៅជា **សខី** បំបែកដូច **ជាតី** គ្រប់វិភត្តិ ។ ខាងក្រោមនេះបំបែកតែ **សខ** ជាបុំលិង្គប៉ុណ្ណោះ ។

## វិធីបំបែក សខ =សំឡាញ់

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សខា | សខានោ, សខាយោ, សខិនោ |
| ទុ. | សខានំ, សខារំ, សខំ | សខានោ, សខាយោ, សខិនោ |
| ត. | សខិនា | សខារេហិ, សខេហិ, សខារេភិ, សខេភិ |
| ច. | សខិស្ស, សខិនោ | សខានំ, សខារានំ, សខិនំ |
| បញ្ច. | សខិនា, សខិស្មា, សខិម្ហា | សខារេហិ, សខេហិ, សខារេភិ, សខេភិ |
| ឆ. | សខិស្ស, សខិនោ | សខានំ, សខារានំ, សខិនំ |
| ស. | សខេ, សខិស្មឹ, សខិម្හិ | សខារេសុ, សខេសុ, សខិសុ |
| អា. | សខ, សខា, សខិ, សខេ | សខានោ, សខាយោ, សខិនោ |

## ឧទាហរណ៍នៃការប្រើ

**១. ភោគិនិយា គហបតានិយា សខី កោច្ឆេ និសីទិ ។**

*សំឡាញ់ស្រី របស់គហបតានី អ្នកមានភោគ អង្គុយហើយ លើកៅអី។*

**២. សខា ខុជ្ជកោ ទារកោ ឃរេ និបជ្ជាបេសិ ។**

*សំឡាញ់ ញុំាងទារក.ទ. តូច ឱ្យដេកហើយ ក្នុងផ្ទះ ។*

*៤. អត្ត ប្រែថា "ខ្លួន, អាត្មា" ជានាមនាម អ ការន្តបុំលិង្គមានវិភត្តិសម្រេចដូចខាងក្រោមនេះ*

## វិភត្តិសម្រេចរបស់ អត្ត សព្ទ

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | អា | អានោ, អា |
| *ទុ.* | អានំ, អនំ, អំ | អានោ, ឯ |
| *ត.* | អនា, ឯន | អនេហិ, អនេភិ |
| *ច.* | អនោ, អស្ស | អានំ |
| *បញ្ច.* | អនា, អស្មា | អនេហិ, អនេភិ |
| *ឆ.* | អនោ, អស្ស | អានំ |
| *ស.* | អនិ, អស្មឹ, អម្ហិ | អនេសុ, ឯសុ |
| *អា.* | អ, អា | អានោ, អា |

# វិធីបំបែក អត្ត =អាត្មា

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អត្តា | អត្តានោ, អត្តា |
| ទុ. | អត្តំ, អត្តានំ | អត្តានោ |
| ត. | អត្តនា, អត្តេន | អត្តនេហិ, អត្តនេភិ |
| ច. | អត្តនោ, អត្តស្ស | អត្តានំ |
| បញ្ច. | អត្តនា | អត្តនេហិ, អត្តនេភិ |
| ឆ. | អត្តនោ, អត្តស្ស | អត្តានំ |
| ស. | អត្តនិ | អត្តនេសុ, អត្តេសុ |
| អា. | អត្ត, អត្តា | អត្តានោ, អត្តា |

មានវិធីផ្សំដូច្នេះ (អត្ត + អា) > អត្តា., (អត្ត + អានោ) > អត្តានោ ។

## កំណត់សម្គាល់

*សូមសង្កេតមើលការបំបែកខាងលើនេះ ។*

*១. **អត្ត** នេះជាឯកវចនៈតែម្យ៉ាងប៉ុណ្ណោះ ពីព្រោះប្រើសំដៅយកតែ **អត្ត** =ខ្លួន តែមួយ ដូច្នេះមិនអាចជាពហុវចនៈបានឡើយ ។ ក្នុងច្បាប់សិក្សាខ្លះថាមិនមានប្រើជាពហុវចនៈទេ ខ្លះថាមានប្រើតិចតួចតែឃើញមានបំបែកឱ្យមើលដូចខាងលើ ។*

*២. បើចង់ឱ្យជាពហុវចនៈក៏បាន គឺត្រូវប្រើសព្ទផ្ទួនគ្នាដូចជា* **អត្តា អត្តា** *=ខ្លួន ៗ (ខ្លួនទាំងឡាយ),* **អត្តនោ អត្តនោ** *=របស់ខ្លួន ៗ (របស់ខ្លួនទាំងឡាយ) ។*

## ប្រយោគឧទាហរណ៍

**១. អត្តា ហិ អត្តនោ នាថោ ។** *ខ្លួន ពិត ជាទីពឹង របស់ខ្លួន ។*

**២. អត្តា អត្តនោ គតិ ។** *ខ្លួន ជាគតិ របស់ខ្លួន ។*

**៣. បុត្តា អត្តនិ ជាយន្តិ ។** *បុត្រ.ទ. តែងកើត ក្នុងខ្លួន ។*

**៤. ភិក្ខូ <u>អត្តនោ</u> <u>អត្តនោ</u> បត្តាសនេសុ និសីទឹសុ ។**

*ភិក្ខុ.ទ. អង្គុយហើយ លើ អាសនៈដែលចាត់ហើយ សម្រាប់ខ្លួន ៗ ។*

*(បើប្រែយកតែសេចក្ដីថា ភិក្ខុមួយអង្គ ៗ គង់លើអាសនៈដែលចាត់ហើយរៀង ៗ ព្រះអង្គ) ។*

**៥. ពហូ ភិក្ខូ អារាមំ គច្ឆន្តិ, អត្តនោ អត្តនោ បត្តេ ហរន្តិ ។**

*ភិក្ខុ.ទ. ច្រើន កំពុងទៅ កាន់វត្ត, (ភិក្ខុ.ទ.) កំពុងស្ពាយ នូវបាត្រ.ទ. របស់ខ្លួន ៗ ។*

*៣. អាចផ្លាស់* ត *ទីបំផុតជា* រ *(*អត្ត *>* អត្រ*) ដូចជា* អត្រជ *= ដែលកើតក្នុងខ្លួន ។*

**មាតាបិតា <u>ច</u> អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ ។** *<u>ក៏</u> ម្ដាយនិងឪពុក.ទ. តែងរក្សា នូវកូនតូច ដែលកើតក្នុងខ្លួន(ដែលខ្លួនមាន) ជានិច្ច ។*

**អត្តនា** <u>**ឋិ**</u> **កតំ ចាបំ អត្រជំ អត្តសម្ភវំ ។** <u>*ក៏*</u> *បាប ដែលកើតក្នុងខ្លួន មានខ្លួនជាដែនកើត គឺខ្លួន ធ្វើហើយ ។*

*៤. ពាក្យពីរម៉ាត់គឺ* **ស** *និង* **សក** *បើប្រើជាបទគុណអាចប្រែថា "របស់ខ្លួន, ជារបស់ខ្លួន" ដូច* **អត្ត** *ត្រង់ឆដ្ឋីវិភត្តិដែរ ។ ក្នុងសៀវភៅខ្លះថា ផ្ទាស់* **អត្ត** *ជា* **ស** *ឬ* **សក** *បើប្រើអធិប្បាយនាមបទណាត្រូវបំបែក ឱ្យស្មើគ្នា គឺមានវិភត្តិដូចនាមជាប្រធានជានិច្ច មិនថាប្រើជាបទវាយឬបទសមាសឡើយដូចជា* **សេហិ កម្មេហិ** *= ដោយកម្ម.ទ. របស់ខ្លួន,.* **សហត្ថ** (**សក** + **ហត្ថ**) *=ដៃរបស់ខ្លួន, ឬ* **កម្មស្សកោម្ហិ** (**កម្ម** + **សក** + **អម្ហិ**)*=យើងជាអ្នកមានកម្មជារបស់ខ្លួន ។ ពាក្យថា* **សេហិ** *ប្រែថា "ជារបស់ខ្លួន" នោះមិនមែនជាពាក្យប្រែរបស់***ឆដ្ឋីវិភត្តិ***ដូច* **អត្ត***នោះទេ គឺជាស័ព្ទវិសេសនៈឬបទគុណសម្រាប់អធិប្បាយបទ* **កម្មេហិ** *។ ប៉ុន្តែនិយមឱ្យប្រែថា "របស់ខ្លួន" ជានិច្ចមិនថាមានរូបជាវិភត្តិអ្វីទេ ។*

## ប្រយោគឧទាហរណ៍

**មាតា មិត្តំ** <u>**សកេ**</u> **ឃរេ ។** *មាតា ជាមិត្ត ក្នុងផ្ទះ* <u>*របស់ខ្លួន*</u> *។*

<u>**សកម្មុនា**</u> **ហញ្ញតិ ចាបធម្មោ ។** *បុគ្គលអ្នកមានសន្តានអាក្រក់តែងក្តៅក្រហាយ (លំបាក)* <u>*ព្រោះកម្មជារបស់ខ្លួន*</u> *។*

<u>សាធិ</u> **ធាធាធិ អត្តជា ជាយន្តិ ។** *ទ្រព្យ.ទ. របស់ខ្លួន តែងកើត អំពីខ្លួន ។*

**យេន <u>សកោ</u> អាកាមោ តេន ចាយាសិ ។** *ឧទ្យាន របស់ខ្លួន (នៅ) ឯណា គេ ដើរទៅហើយ កាន់ទីនោះ ។*

*៥. ស័ព្ទថា* **សយំ, សាមំ** *ក៏ប្រែថា "ខ្លួនឯង" ដែរដូចជា* **សយម្ភូ** (**សយំ** + **ភូ**) =*អ្នកត្រាស់ដឹងដោយខ្លួនឯង (ព្រះនាមព្រះពុទ្ធអង្គ) ។* **សយមត** (**សយំ** + **មត**) =*ដែលស្លាប់ហើយខ្លួនឯង ។* **សាមំ ធិដ្ឋំ** = *ឃើញហើយខ្លួនឯង ។*

## នាមស័ព្ទ (ត)

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| **សេតច្ឆត្ត** នបុំ. | *ឆត្រ័ពណ៌ស* | **អមច្ច** បុំ. | *អាមាត្យ* |
| **រដ្ឋ** នបុំ. | *រាជ្យ* | **ចាសាធ** បុំ. | *ប្រាសាទ* |
| **ធាធាសិប្ប** នបុំ. | *សិល្បៈនានា* | **ធុម្មេធ** គុ. | *ល្ងង់* |
| **អមិត្ត** បុំ. | *សត្រូវ* | **ធុព្វល** គុ. | *ខ្សោយ* |
| **ជេតុ** បុំ. | *អ្នកឈ្នះ* | **មហាតី** ឥ. | *ធំ* |
| **បវត្តិ** នបុំ. | *ដំណឹង* | **បុរត្ថិម** គុ. | *ខាងកើត* |
| **សង្គាម** បុំ. | *សង្គ្រាម* | **ចាបកា** គុ. | *ជាបាប, អាក្រក់* |

## ធាតុស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| ប + ហា | តាំងនៅចំពោះ | និ + លី | ពួន, សម្ងំ |
| អនុ + គម | ទៅតាម | ប + អា + រុប | ដណ្ដប់, ឃ្លុំ |
| បដិ + វិទ | ប្រាប់ឱ្យដឹង | ចុម្ព | ថើប |
| អា + ទា | យក | ហា > ឋបេតិ | ទុក, ដាក់ |
| ឱ + លោក | មើល | ថក | បិទ |
| ប + អជ | បរ, បើកបរ | នដ | រាំ |

## លំហាត់នៃមេរៀនទី ២៣

### ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើ **បកិណ្ណកៈ** ប្រែថាដូចម្ដេច ?

២. តើ **បកិណ្ណកស័ព្ទ** ជាស័ព្ទប្រភេទយ៉ាងណា ? មានប៉ុន្មានស័ព្ទ ?

៣. តើ បកិណ្ណកស័ព្ទ ចែកជាប៉ុន្មានពួក ?

៤. តើពួក **រាជាទិគណៈ** មានស័ព្ទអ្វីខ្លះ ?

៥. បើស័ព្ទសមាសដែលមាន **រាជ** ជាបទចុង តើមានវិធីបំបែកយ៉ាង ម៉េច ? សូមឱ្យឧទាហរណ៍ ។

ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. តុម្ហេ ព្រហ្មំ ធម្មំ សុណាថ, ធម្មំ ទេសិស្សាមិ ។

២. ភិក្ខូ អត្តនោ អត្តនោ អាសនេសុ និសីទឹសុ ។

៣. សខាយោ មហាតិយំ នទិយំ នហាយឹសុ ។

៤. រាជា អត្តនោ មហាជនំ ចាលេតិ ។

៥. អត្តា អត្តនោ នាថោ ហោតិ ។

៦. រញ្ញោ អស្សា អរញ្ញេ ធាវិស្សន្តិ ។

៧. ពហូ សាមណេរា អត្តនោ អត្តនោ ចីវរានិ ចារុបន្តិ ។

៨. ត្វំ សខិស្ស ភត្តំ សជ្ឈ័ស្ស អាហារ ។

៩. រាជា នគរេ ចរន្តោ ធម្មំ ទេសេន្តំ ឯកំ តាបសំ បស្សិ ។

១០. ធម្មំ សុណន្តា ពហូ មនុស្សា អាគច្ឆន្តេ រាជិនី ឱលោកេសុំ។

១១. រាជូសុ អត្តនោ អត្តនោ រជ្ជេសុ ចរន្តេសុ ពហូ សាវកា
សេតច្ឆត្តានិ គហេត្វា តេ អនុគច្ឆន្តិ ។

១២. រាជានោ អត្តានំ កុមារេ សកេ សកេ រជ្ជេ បតិដ្ឋាបេតុំ
ឥច្ឆន្តា នានាសិប្បានិ សិក្ខាបេន្តិ ។

១៣. ចោរេសុ ពលវន្តេសុ ជាតេសុ រាជានោ ទុព្វលា ហោន្តិ ។

១៤. ពាលា ទុម្មេធា ចាបកានិ កម្មានិ ករោន្តា អមិត្តេន អត្តនា
ឥវ ចរន្តិ ។

១៥. អត្តនោ សខារំ ជេតា មិត្តោ ន ហោតិ ។

១៦. ចូតោ អាគម្ម រញ្ញោ សង្គាមស្ស បវត្តឹ បដិវេទេសិ ។
១៧. កស្សកោ ខេត្តម្ហា អាគន្ត្វា កត្តំ កុញ្ចតិ ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី*

*១. រាជិនី កាលពន្យល់ នូវសំនួរ.ទ. ដែលសួរហើយ ដោយនារី.ទ. ប្រថាប់ហើយ ក្នុងទីប្រជុំ អញ្ជើញហើយ នូវបុរស ឱ្យពោលហើយ នូវសំដី ។*

*២. ធម៌ គឺព្រះពុទ្ធ សំដែងហើយ ដល់ព្រហ្ម.ទ. ។*

*៣. ព្រះរាជា ញុំាងអាមាត្យ ប្រាំរូប ឱ្យទៅ កាន់ផ្ទះ របស់មន្ត្រី ម្នាក់ ។*

*៤. មនុស្ស.ទ. ក្នុងលោក គប្បីធ្វើ នូវទីពឹង ដើម្បីខ្លួន ៗ ។*

*៥. ឥឡូវនេះ សូមអាមាត្យ មើល នូវលិខិត គឺព្រះរាជា សរសេរហើយ ។*

*៦. ព្រះរាជា ពីរព្រះអង្គ យាងមកហើយ ពីទិសខាងកើត ដើម្បីឃើញ ព្រះរាជា របស់ខ្ញុំ ។*

*៧. ព្រះរាជា មួយអន្លើ ដោយព្រះមហេសី យាងទៅហើយ កាន់ប្រាសាទ ។*

*៨. ព្រះរាជា.ទ. បួនព្រះអង្គ ពីទិស.ទ. បួន មកហើយ ថ្វាយបង្គំហើយ នូវព្រះពុទ្ធ សួរហើយ នូវប្រយោជន៍ នេះ ។*

*៩. ក្មេងស្រី នាំមកហើយ នូវភត្ត.ទ. របស់សំឡាញ់ ដើម្បីព្រះសង្ឃ.ទ.។*

*១០. តង្វាយ ទាំងនេះ គឺព្រះរាជា ទ្រង់ផ្ញើមក ដើម្បីប្រគេន ដល់ភិក្ខុ.ទ. ៥០អង្គ ។*

(ចប់មេរៀនទី ២៣)

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| ប្រយោជន៍ខ្លួន | ត្រូវតែគិត | គ្មានច្បាប់ឃាត់ |
| តែកុំក្បត់ | នូវសាធា- | រណប្រយោជន៍ |
| កុំបង្កន់ | ប្រយោជន៍រួម | ឱ្យតិចហោច |
| ហើយបេះបោច | មកធ្វើជា | ប្រយោជន៍ខ្លួន ។ |

*ដកស្រង់ពីសៀវភៅ "រៀនភាសាអង់គ្លេស ៦៣ ម៉ោងដោយខ្លួនឯង"*
*ទំព័រ៤៩៣ ដោយលោក* **ឱម ណារ៉ាត្រី**

# មេរៀនទី ២៨

## អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (ត) និង
## ប្រយោគជ្រែក (Absolute construction)

## វិធីបំបែកពួកទី ២ (ភគវន្តាទិគណៈ)

*ភគវន្តាទិគណៈមាន ៣ ស័ព្ទគឺ* **ភគវន្តុ**, **អរហន្ត**, **ភវន្ត** *ដែលមានវិធីបំបែកតាមបែប* **ភគវន្តុ** *ជាដើម ។* **ភគវន្តុ** *ស័ព្ទមានទីបំផុតជា* **-វន្តុ** *ដែលជាបច្ច័យមានក្នុងតទ្ធិត (មានពោលនៅខាងមុខ)គឺ* (**ភគ** + **វន្តុ**) > **ភគវន្តុ** *ជា* **ឧ** *ការន្តបុំលិង្គ ។ ប៉ុន្តែនឹងហៅថា* **ឧ** *ការន្តដូច* **គរុ** *ឬ* **ភិក្ខុ** *ពុំកើតឡើយ ពីព្រោះ* **ភគវន្តុ** *ប្រែថា “ព្រះមានព្រះភាគ” ។ ភាគច្រើន* **វន្តុ** *បច្ច័យរបស់តទ្ធិតនិយមចុះក្នុងនាមនាមដែលជា* **អ**, **អា** *ការន្តដូចជា* (**បុញ្ញ** + **វន្តុ**) > **បុញ្ញវន្តុ** *=អ្នកមានបុណ្យ*, (**គុណ** + **វន្តុ**) > **គុណវន្តុ** = *អ្នកមានគុណ*, (**បញ្ញា** + **វន្តុ**) > **បញ្ញវន្តុ** *=អ្នកមានបញ្ញា ។*

១.) **ភគវន្តុ** *=ព្រះមានព្រះភាគ មានវិធីបំបែកខុសពី* **ឧ** *ការន្តនៃសាមញ្ញស័ព្ទគឺត្រូវបំបែកដោយឡែកដូចមាននៅខាងក្រោមនេះ ។*

## វិភត្តិសម្រេរបស់ ភគវន្តុ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | អា, ឱ |
| ទុ. | អំ | ឯ, ឱ |
| ត. | អា | ឯហិ, ឯភិ |
| ច. | ឱ | អំ, អានំ |
| បញ្ច. | អា | ឯហិ, ឯភិ |
| ឆ. | ឱ | អំ, អានំ |
| ស. | ឥ, ឯ | ឯសុ |
| អា. | អ, អា | អា, ឱ |

## វិធីបំបែក ភគវន្តុ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ភគវា | ភគវន្តា, ភគវន្តោ |
| ទុ. | ភគវន្តំ | ភគវន្តេ, ភគវន្តោ |
| ត. | ភគវតា, ភគវន្តេន | ភគវន្តេហិ, ភគវន្តេភិ |
| ច. | ភគវតោ, ភគវន្តស្ស | ភគវតំ, ភគវន្តានំ |
| បញ្ច. | ភគវតា | ភគវន្តេហិ, ភគវន្តេភិ |

| | | |
|---|---|---|
| ឆ. | ភគវតោ, ភគវន្តស្ស | ភគវតំ, ភគវន្តានំ |
| ស. | ភគវតិ, ភគវន្តេ | ភគវន្តេសុ |
| អា. | ភគវ, ភគវា | ភគវន្តា, ភគវន្តោ |

## កំណត់សម្គាល់

១. វន្តុ កាលបើចុះខាងចុងនាមស័ព្ទណា នាមស័ព្ទនោះក្លាយទៅជាគុណស័ព្ទវិញ ប៉ុន្តែបើគ្មាននាមជាប្រធានសម្រាប់អធិប្បាយទេ ស័ព្ទនោះ ៗ នៅជានាមនាមដដែល ។ រីឯ **ភគវន្តុ** ជាអសាធារណនាមជាឈ្មោះឬព្រះនាមមួយរបស់ព្រះសម្មាសម្ពុទ្ធបន្ទាប់ពីព្រះនាមថា **ព្រះពុទ្ធ** អាស្រយ័ហេតុនេះបញ្ជាក់ឱ្យឃើញថា នឹងប្រើជាគុណនាមពុំបានទេ ហើយគឺជាបុំលិង្គតែម៉្យាង ។

២. នៅមានស័ព្ទជាច្រើនទៀតដែលមានទីបំផុតជា វន្តុ និង **មន្តុ** បច្ច័យនិងដែលមានវិធីបំបែកតាមបែប **ភគវន្តុ** ដូចមានខាងក្រោមនេះ

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| **គុណវន្តុ** | អ្នកមានគុណ | **ធនវន្តុ** | អ្នកមានទ្រព្យ |
| **បញ្ញវន្តុ** | អ្នកមានបញ្ញា | **បុញ្ញវន្តុ** | អ្នកមានបុណ្យ |
| **អាយស្មន្តុ** | អ្នកមានអាយុ | **ចក្ខុមន្តុ** | អ្នកមានចក្ខុ |
| **ពន្ធុមន្តុ** | អ្នកមានញាតិ | **ជុតិមន្តុ** | អ្នកមានពន្លឺ |
| **ធិតិមន្តុ** | អ្នកមានបញ្ញា | **សតិមន្តុ** | អ្នកមានសតិ |

៣. វន្តុ បច្ច័យសម្រាប់ចុះជាមួយស័ព្ទដែលជា អ, អា ការន្តដូចជា (គុណ + វន្តុ) > **គុណវន្តុ** ។ រីឯ **មន្តុ** បច្ច័យសម្រាប់ចុះក្នុងស័ព្ទដែលជា **ឥ** ឬ **ឧ** ការន្ត ដូចជា (**ពន្ធុ** + **មន្តុ**) > **ពន្ធុមន្តុ**, (**សតិ** + **មន្តុ**) > **សតិមន្តុ** ជាដើម ។

៤. ស័ព្ទទាំងឡាយនេះជាសព្ទ័សម្រេចមកពីបច្ច័យក្នុងតទ្ធិត (មានពោលនៅខាងមុខ) បើប្រើជាបទវិសេសនគឺជាគុណនាម (តែក៏អាចប្រើជានាមនាមបានដែរ)បំបែកបានទាំងបីលិង្គដូច្នេះ

៤.១ បើប្រើអធិប្បាយនាមដែលជាបុំលិង្គ ត្រូវបំបែកតាម **ភគវន្តុ** គ្រប់វិភត្តិ ។

៤.២ បើប្រើអធិប្បាយនាមដែលជាឥត្ថីលិង្គត្រូវផ្លាស់ **ន្តុ** > **ត** និងត្រូវចុះបច្ច័យ **ឦ** ទៅជា **គុណវតី** ហើយបំបែកតាមបែប **ឆារី** ។

៤.៣ បើប្រើអធិប្បាយនាមជានបុំសកលិង្គត្រូវបំបែកដូច **ភគវន្តុ** គ្រប់យ៉ាង វៀរតែបឋមាវិភត្តិឯកវចនៈជា **គុណវំ** ,**គុណវន្តំ** និងពហុវចនៈជា **គុណវន្តានិ** ទាំងបឋមានិងទុតិយាវិភត្តិ ។ រីឯអាលបនឯកវចនៈ **គុណវ** ។

២.) **អរហន្ត** =ព្រះអរហន្ត, ជានាមនាម **អ** ការន្តបុំលិង្គបំបែកដូច **ភគវន្តុ**, វៀរតែបឋមាវិភត្តិឯកវចនៈប៉ុណ្ណោះដែលមានរូបជា **អរហំ** ។ បើឥត្ថីលិង្គត្រូវចុះបច្ច័យ **ឦ** ទៅជា **អរហន្តី** មានវិធីបំបែកដូច **ឆារី** ។

# វិធីបំបែក អរហន្ត =ព្រះអរហន្ត

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អរហា, អរហំ | អរហន្តា, អរហន្តោ |
| ទុ. | អរហន្តំ | អរហន្តេ, អរហន្តោ |
| ត. | អរហតា | អរហន្តេហិ, អរហន្តេភិ |
| ច. | អរហតោ | អរហតំ, អរហន្តានំ |
| បញ្ច. | អរហតា | អរហន្តេហិ, អរហន្តេភិ |
| ឆ. | អរហតោ | អរហតំ, អរហន្តានំ |
| ស. | អរហតិ, អរហន្តេ | អរហន្តេសុ |
| អា. | អរហ , អរហា | អរហន្តា, អរហន្តោ |

## ប្រយោគឧទាហរណ៍

១. នមោ តស្ស ភគវតោ₁ អរហតោ₂ សម្មាសម្ពុទ្ធស្ស ។

*ប្រែថា កិរិយានមស្ការ ថ្វាយបង្គំ (សូមមាន) ដល់ព្រះមានព្រះភាគ₁ ព្រះអង្គនោះ ព្រះអង្គជាព្រះអរហន្ត₂ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។*

២. យោ សោ ភគវា₁ អរហំ₂ សម្មាសម្ពុទ្ធោ ។បេ។

*ប្រែថា ព្រះមានព្រះភាគ[១] អង្គឯណា ព្រះអង្គជាព្រះអរហន្ត[២] ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។ល។*

**៣. ស្វាក្ខាតោ យេន ភគវតា ធម្មោ ។បេ។**

*ព្រះសទ្ធម្ម ដែលព្រះមានព្រះភាគ អង្គឯណា ទ្រង់ត្រាស់ល្អហើយ ។ល។*

**៤. សុបដិបន្នោ យស្ស ភគវតោ សាវកសង្ឃោ ។បេ។**

*ពួកនៃសាវក របស់ព្រះមានព្រះភាគ អង្គឯណា បដិបត្តិល្អហើយ ។ល។*

**៥. ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។បេ។**

*ក៏ព្រោះហេតុនេះ ព្រះមានព្រះភាគ អង្គនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។ល។*

**៦. ភគវា[១] វិហារេ រាជូនំ ធម្មំ អទេសយិ, រាជានោ តស្ស ភគវតោ[២] ធម្មំ អស្សុណឹសុ ។** *ព្រះមានព្រះភាគ[១] ទ្រង់បានសំដែងរួចហើយ នូវធម៌ ដល់ព្រះរាជា.ទ. ក្នុងវិហារ, ព្រះរាជា.ទ. បានស្តាប់ហើយ នូវធម៌ របស់ព្រះមានព្រភាគ[២] អង្គនោះ ។*

**៧. បរិព្វាជកោ ភគវតា សទ្ធឹ សម្មោទិ ។**

*បរិព្វាជក មួយអន្លើដោយ ព្រះមានព្រះភាគ រីករាយហើយ ។*

៣.) **ភវន្ត** *បើតាមរូបសព្ទ័សម្រេចមកពី* **ភូ** *ធាតុប្រែថា* "មាន, *ជា, កើត*" និង **អន្ត** *បច្ច័យក្នុងកិតកិរិយា, វស្ស:* **ឩ** *នៃ* **ភូ** *ជា* **ឱ** *ហើយផ្លាស់*

**ឱ** > **ឱ** រូបផ្លាស់ **ឱ** > **អវ** គឺ (**ភូ** > **ភវ** + **អន្ត**) > **ភវន្ត** ប្រែថា “អ្នកដ៏ចំរើន” ឋិតក្នុងប្រភេទនាម ហើយបង្ហាញឱ្យឃើញថាជាស័ព្ទមានទីបំផុតជា **ន្ត** បច្ច័យ ។ **ភវន្ត** ជា **អ** ការន្តនិងជាទ្វិលិង្គ គឺអាចជាបុំលិង្គនិងឥត្ថីលិង្គ (បើប្រាថ្នាឱ្យទៅជាឥត្ថីលិង្គត្រូវបុះ **ឦ** បច្ច័យទៅជា **ភវន្តី** មានវិធីបំបែកដូច **ណារី**) ដូចមានការបំបែកខាងក្រោមនេះ ។

## វិធីបំបែក ភវន្ត =លោកដ៏ចំរើន

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ភវំ, ភោ | ភវន្តា, ភវន្តោ, ភោន្តោ |
| ទុ. | ភវន្តំ | ភវន្តេ, ភវន្តោ |
| ត. | ភវតា, ភោតា, ភវន្តេន | ភវន្តេហិ, ភវន្តេភិ |
| ច. | ភវតោ, ភោតោ, ភវន្តស្ស | ភវតំ, ភវន្តានំ |
| បញ្ច. | ភវតា,ភោតា,ភវន្តស្មា, -ម្ហា | ភវន្តេហិ, ភវន្តេភិ |
| ឆ. | ភវតោ, ភោតោ, ភវន្តស្ស | ភវតំ, ភវន្តានំ |
| ស. | ភវតិ, ភវន្តេ, ភវន្តស្មឹ | ភវន្តេសុ |
| អា. | ភោ, ភន្តេ | ភវន្តោ, ភោន្តោ ភវន្តោ |

## កំណត់សម្គាល់

១. **ភវន្ត** ក្នុងរូបបឋមាវិភត្តិឯកវចនៈ កាលបើលុប **ន្ត** ទៅជា **ភវ** បំបែកជា **អំ** ទៅជា **ភវំ** និងក៏អាចផ្លាស់ **ភវ** ជា **ភោ** ផងដែរ ។

២. អាលបនវិភត្តិឯកវចនៈអាចផ្លាស់ **ភវ** > **ភោ** បាន ។

៣. ក្នុងរូបជាតតិយា, ចតុត្ថី, បញ្ចមី និង ឆដ្ឋីវិភត្តិឯក. អាចផ្លាស់ **ន្ត** > **ត** បាន, ដោយផ្លាស់ **ភវ** > **ភោ** > **ភោត** ដែលបំបែកដូច **ភគវន្តុ** ។

៤. **ភវន្ត** បើប្រាថ្នាឱ្យទៅជាឥត្ថីលិង្គត្រូវចុះ ឦ បច្ច័យទៅជា **ភវន្តី** ឬ **ភោតី** មានវិធីបំបែកដូច **នារី** ។

៥. ពាក្យថា **ភោ**, **ភោន្តោ** ពុំសូវមានប្រើក្នុងប្រយោគប៉ុន្មានទេ ។

## ប្រយោគឧទាហរណ៍

**១. អថ ខោ ភគវា ឧទានំ ឧទានេសិ "អញ្ញាសិ វត <u>ភោ</u> កោណ្ឌញ្ញោ, អញ្ញាសិ វត <u>ភោ</u> កោណ្ឌញ្ញោតិ ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសីតិ" ។**

*ប្រែថា លំដាប់នោះឯង ព្រះមានព្រះភាគ បានទ្រង់បន្លឺឡើង នូវព្រះឧទានថា "<u>ម្នាលលោកដ៏ចម្រើន</u> កោណ្ឌញ្ញៈ បានដឹងហើយ ហ្ន៎, <u>ម្នាលលោកដ៏ចម្រើន</u> កោណ្ឌញ្ញៈ បានដឹងហើយ ហ្ន៎ , ព្រោះហេតុនោះ ឈ្មោះនេះថា "អញ្ញាកោណ្ឌញ្ញៈ" យ៉ាងនេះឯង បានមានហើយ ចំពោះលោកដ៏មានអាយុ កោណ្ឌញ្ញៈ ដោយប្រការដូច្នេះ" ។*

(នេះជាព្រះតម្រាស់របស់ព្រះមានព្រះភាគបានទ្រង់ឧទានឡើង នាកាលព្រះកោណ្ឌញ្ញៈបានចក្ខុ ឃើញធម៌គ្រាដំបូង ទើបបានថែមឈ្មោះខាងដើមថា **អញ្ញាកោណ្ឌញ្ញ** តាំងពីពេលនោះជាប់រហូតតមក ហើយលោកបានបួសជាព្រះសង្ឃទីមួយក្នុងព្រះពុទ្ធសាសនា ដែលមានតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ ។

**ឥតិហិជំ** < ( **ឥតិ** + **ឥជំ** ) ។

វិធីសរសេរនិងប្រើ **ឥតិ** ស័ព្ទមានអធិប្បាយនៅខាងមុខ ។

**២. អជ្ជ ភោន្តោ បក្ខស្ស បណ្ណរសីឧិវសោ ។បេ។**

នៃលោកដ៏ចំរើន.ទ. ថ្ងៃនេះ ជាថ្ងៃ បណ្ណរសី(ទី១៥) របស់បក្ស ។ល។

ជាពាក្យប្រកាសរបស់ឧបាសកឧបាសិកាក្នុងថ្ងៃសមាទានសីលថ្ងៃទី១៥កើតឬរនោច ចាត់ជាថ្ងៃឧបោសថ ។

ចូរចំណាំថា មានអាលបននិបាតពីរស័ព្ទគឺ **ភោ** ប្រែថា "នៃអ្នកដ៏ចម្រើន, ម្នាលគ្នាយើងដ៏ចម្រើន, វ៉ើយ" និង **ភន្តេ** ប្រែថា "បពិត្រព្រះអង្គដ៏ចម្រើន, បពិត្រលោកឬលោកម្ចាស់ដ៏ចម្រើន" ។ **ភន្តេ**, **ភទន្តេ** ពីរស័ព្ទនេះបគប្បីលើកយកប្រើឱ្យសមសួន ជាស័ព្ទសម្រាប់គ្រហស្ថប្រើនិយាយទៅកាន់បព្វជិតដោយសេចក្តីគោរព ឬ បព្វជិតអ្នកមានវស្សាតិពោលចំពោះបព្វជិតមានវស្សាចាស់ជាងដូចមានបទសន្ទនាខ្លីមួយខាងក្រោមនេះ

**កាតមំ បង ភន្តេ គន្ធធុរំ ?**

*ព្រះអង្គដ៏ចំរើន ក៏ គន្ធធុរៈ ណាមួយ?*

**ភទន្តេតិ តេ ភិក្ខូ ភគវតោ (វចនំ) បច្ចស្សោសុំ ។**

*ភិក្ខុ.ទ. នោះ បានស្តាប់ ចំពោះហើយ (នូវព្រះតម្រាស់) របស់ព្រះមានព្រះភាគ (ហើយទូលតប)ថា "ភទន្តេ=បពិត្រព្រះអង្គដ៏ចំរើន" ។*

*ពាក្យថា* **ភទន្តេ** *បើជាពហុវចនៈថា* **ភទន្តា** *ក៏បានខ្លះ គឺឃើញមានប្រើនៅក្នុងបទជំនុំទេវតា (បទសគ្គេ) ត្រង់ទីបញ្ចប់ថា* **......ធម្មស្សវនកាលោ អយម្ភទន្តា** (អយំ + ភទន្តា) ។

*ប្រែថា នៃអ្នកដ៏ចំរើន.ទ. វេលានេះ ជាវេលាស្តាប់ធម៌ (ថា ៣ ដង) ។ ឥឡូវនេះពុទ្ធសាសនិកប្រទេសខាងលិច និយមប្រើក្នុងការនិយាយជាមួយភិក្ខុថា* **ភន្តេ** *ច្រើនជាង* **ភទន្តេ** ។

*៤.)* **សន្ត** *ក៏ជាសព្ទមានទីបំផុតជា* **ន្ត** *ដែរប្រែថា "សប្បុរស" មានវិធីបំបែកដូចខាងក្រោមនេះ*

## វិធីបំបែក សន្ត =សប្បុរស

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | **សំ, សន្តោ** | **សន្តោ, សន្តា** |
| *ទុ.* | **សំ, សន្តំ** | **សន្តេ** |

| | | |
|---|---|---|
| គ. | សតា, សន្តេន | សន្តេហិ, សព្ភិ |
| ច. | សតោ, សន្តស្ស | សតំ, សតានំ, សន្តានំ |
| បញ្ច. | សតា, សន្តា, សន្តស្មា, សន្តម្ហា | សន្តេហិ, សព្ភិ |
| ឆ. | សតោ, សន្តស្ស | សតំ, សតានំ, សន្តានំ |
| ស. | សតិ, សន្តេ, សន្តស្មឹ, សន្តម្ហិ | សន្តេសុ |
| អា. | សន្ត | សន្តោ, សន្តា |

## កំណត់សម្គាល់

*មានស័ព្ទខ្លះមានរូបដូច* **សន្ត** *នេះដែរ ។ បើជាគុណនាមប្រែថា "មាន" ដែលអាចបំបែកតាមបែប* **គច្ឆន្ត** *ដែលមិនមានរូបជា* **សព្ភិ** *ទេតែមានរូបជា* **សតិ** *ក្នុងសត្តមីវិភត្តិ ។ បើជាកិតកិរិយាគឺមកពី* **អស** *ធាតុ ។ ប្រសិនបើមានរូបជា* **សានិ, សេន, សម្ហិ** *ជាដើមនោះគឺមកពី* **សក** *ប្រែថា "របស់ខ្លួន" ចូរមើលមេរៀនទី ២៣ ។*

# ប្រយោគជ្រែក

## (Absolute Construction)

ពាក្យថា ប្រយោគជ្រែក បានដល់ប្រយោគណាដែលមានសេចក្តីពុំទាន់ពេញលេញ ហើយជ្រែកចូលមកត្រង់កណ្តាលនៃប្រយោគមួយទៀតក៏មាន, ជ្រែកចូលត្រង់ខាងដើមក៏មានដែរ ។ ប្រយោគជ្រែកនេះមានច្រើនប្រភេទ ប៉ុន្តែសូមលើកយកតែ ២ ប្រភេទទេគឺ **ប្រយោគ-អនាទរ** និង **ប្រយោគលក្ខណា** ។

## ១. ប្រយោគអនាទរ:

ប្រយោគអនាទរ: បានដល់ឃ្លាឬសង្កាត់ដែលមានបទនាមនាមបំបែកជា **ឆដ្ឋីវិភត្តិ** ប្រើពាក្យ ប្រែថា "កាល, កាលបើ, កាលដែល" ជាបទប្រធាននៃប្រយោគ និងមានបទកិរិយាប្រកបជាមួយ **ត**, **អន្ត**, **មាន** បច្ច័យហើយដែលបំបែកជាឆដ្ឋីវិភត្តិដូចគ្នានឹងបទប្រធានដែរ ដែលមានឈ្មោះថា **អនាទរកិរិយា** ។ បើជា**បច្ចុប្បន្នកាល**ប្រើ **អន្ត**, **មាន** បច្ច័យប្រែថា "កាលឬកំពុង", បើជា**អតីតកាល**ប្រើ **ត** បច្ច័យ ។ ចំណែកឯវាចកអ្វីនោះស្រេចលើសេចក្តីក្នុងទីនោះ ៗ គឺត្រូវយកបច្ច័យជាការសំខាន់ ។ បើមានសេចក្តីត្រូវជ្រែកចូលត្រង់ណា ត្រូវរៀងដាក់ត្រង់នោះ ដូចមានឧទាហរណ៍ខ្លះខាងក្រោមនេះ

១. <u>ថេរស្ស</u>[១] និទ្ទំ <u>អនោក្កមន្តស្ស</u>[២] អក្ខិម្ហិ រោគោ ឧប្បជ្ជិ ។

រោគ ក្នុងភ្នែក <u>កាលព្រះថេរ</u>[១] <u>កាលមិនចុះស៊ុប</u>[២] ក្នុងដំណេក កើត

*ហើយ ។*

*ឬនឹងប្រែប្រយោគអនាទរមុនក៏បាន*

*កាលព្រះថេរ កាលមិនចុះស៊ុប ក្នុងដំណោក ពោគ កើតហើយក្នុងក្អែក ។*

(*ចាប់ពី* **ថេរស្ស ជិច្ឆំ អជោក្កាមន្តស្ស** *ជាប្រយោគអនាទរជ្រែកចូលមកខាងដើមនៃប្រយោគ ។*)

២. **<u>សាមណេរស្ស</u> ធម្មំ <u>កាថេន្តស្ស</u> អរុណោ ជាតោ ។**

*កាលសាមណេរ កំពុងសំដែង នូវធម៌, ភាពងងឹត កើតហើយ ។*

៣. **<u>បុត្តស្ស</u> <u>រុទមានស្ស</u> មាតា គេហម្ហា និក្ខមតិ ។**

*កាលកូន កំពុងយំ ម្តាយ ចាកចេញ ពីផ្ទះ ។*

៤. **<u>កស្សកស្ស</u> ខេត្តំ <u>កសន្តស្ស</u> ភរិយា អាហារំ អាហរិ ។**

*កាលកសិករ កំពុងភ្ជួរ នូវស្រែ ភរិយា នាំមកហើយ នូវអាហារ ។*

៥. **សេដ្ឋិនោ ភរិយា <u>តស្ស</u> វនំ <u>គតស្ស</u> គាមេ កម្មំ ករោតិ ។**

*ភរិយា របស់សេដ្ឋី, កាលបើសេដ្ឋីនោះ ទៅហើយ កាន់ព្រៃ, កំពុងធ្វើនូវ ការងារ ឯផ្ទះ ។*

*សូមសង្កេតមើលប្រយោគទី ៥ គឺចាប់ពី* **តស្ស វនំ គតស្ស** *ជាប្រយោគអនាទរជ្រែកចូលមកក្នុងកណ្តាលនៃប្រយោគ ។ កិតកិរិយាដែលប្រើដូច្នេះក៏អាចមានបទកម្មដែរដូចជា* **<u>ធម្មំ</u> កាថេន្តស្ស, <u>ខេត្តំ</u> កសន្តស្ស, <u>វនំ</u> គតស្ស** *ជាដើម ។*

## ២. ប្រយោគលក្ខណៈ

*ប្រយោគលក្ខណៈ បានដល់ឃ្លាឬសង្កាត់ដែលមាននាមនាមបំបែកជា**សត្តមីវិភត្តិ** ប្រើពាក្យប្រែថា "នាកាល" ជាបទប្រធាន, មានបទកិរិយាប្រកបដោយបច្ច័យ ៣ តួដូចប្រយោគអនាទរៈដែរ ។ ប៉ុន្តែត្រូវបំបែកជាសត្តមីវិភត្តិនិងត្រូវឱ្យមានការន្ត, លិង្គ, វចនៈស្មើនឹងបទប្រធានមានគតិដូចប្រយោគអនាទរគ្រប់ប្រការ ដែលមានឈ្មោះថា* **លក្ខណកិរិយា** *ដូចឧទាហរណ៍ខាងក្រោមនេះ*

១. បទុមានិ, <u>សុរិយេ</u> <u>ឧគ្គច្ឆន្តេ</u>, បុប្ផន្តិ ។

*ផ្កាឈូក.ទ., នាកាលព្រះអាទិត្យ កំពុងរះឡើង, រមែងរីក ។*

២. <u>សុរិយេ</u> <u>អត្ថង្គតេ</u>, ចន្ទោ ឧគ្គច្ឆតិ ។

*នាកាលព្រះអាទិត្យ លិចហើយ, ព្រះចន្ទ តែងរះឡើង ។*

៣. ពុទ្ធោ, <u>ឧបាសកេសុ</u> វិហារំ <u>អាគតេសុ</u>, ធម្មំ ទេសេតិ ។

*ព្រះពុទ្ធ, នាកាលឧបាសក.ទ. មកហើយ កាន់ព្រះវិហារ, កំពុងសំដែង នូវធម៌ ។*

*សូមអ្នកសិក្សាសង្កេតមើលភាពប្លែកគ្នារវាងប្រយោគទាំងពីរយ៉ាងខាងលើនេះ និងការប្រើសំខ្យាក្នុងរូបជាឆដ្ឋីនិងសត្តមីវិភត្តិក្នុងមេរៀនទី ១៧ ។*

## នាមស័ព្ទ (ត)

| ស័ព្ទបាលី | ពាក្យប្រែ | ស័ព្ទបាលី | ពាក្យប្រែ |
|---|---|---|---|
| សាវត្ថី ឥ. | ក្រុងសាវត្ថី | សេវកា បុំ. | អ្នកបំរើ |
| ភាតុ បុំ. | បងប្អូនប្រុស | ហិមវន្ត គុ. | មានទឹកសន្សើម |
| កិលញ្ជ បុំ. | កន្ទេល | យសវន្ត គុ. | មានយស, ល្បី |
| បសុ បុំ. | សត្វចិញ្ចឹម | ទក្ខិណា គុ. | ខាងស្ដាំ |
| ឧរគ បុំ. | ពស់ | បុរតោ អព្យ. | អំពីខាងមុខ |
| បភូ បុំ. | អ្នកគ្រប់គ្រង | បច្ឆតោ អព្យ. | អំពីខាងក្រោយ |
| បមាទ បុំ. | សេចក្ដីប្រមាទ | វាមតោ អព្យ. | អំពីខាងឆ្វេង |
| មច្ចុ បុំ. | សេចក្ដីស្លាប់ | តតោ អព្យ. | ពីទីនោះ |
| ពិល នបុំ. | រន្ធ, រូង | តត្រ អព្យ. | ក្នុងទីនោះ |
| ពន្ធុ, ពន្ធវ បុំ. | ញាតិ, បងប្អូន | អវស្សំ និ. | ដោយពិត, មែន |

## ធាតុស័ព្ទ (ត)

| ធាតុស័ព្ទ | ពាក្យប្រែ | ធាតុស័ព្ទ | ពាក្យប្រែ |
|---|---|---|---|
| សំ + ឥជ | សម្រេច | ប + មជ | ប្រមាទ, ប្រហែស |
| ប + កុស | ហៅ | ប + ថរ > បត្ថរ | ក្រាល, លាត |
| ឧ + គម | ឡើង | បល | បោល, ហើរ |

| | | | |
|---|---|---|---|
| **វិ + ហរ** | *នៅ, អាស្រ័យ* | **មា** | *សាង, សង់* |
| **មុច** | *រួច, របូត* | **វប** | *សាប, ព្រួស* |

## លំហាត់នៃមេរៀនទី ២៤

*ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ*

*១. តើ* **ភគវន្តាទិគណ** *មានស័ព្ទអ្វីខ្លះ ?*

*២. តើស័ព្ទដែលជា* **ឧ** *ការន្តដូចជា* **ភគវន្តុ** *មានការបំបែកខុសប្លែកពីពួក* **ឧ** *ការន្តសាមញ្ញស័ព្ទត្រង់កន្លែងណាខ្លះ ?*

*៣. តើបច្ច័យ* **វន្តុ, មន្តុ** *ពីតួនេះសម្រាប់ប្រើដូចម្ដេចខ្លះ ? សូមឱ្យឧទាហរណ៍ ។*

*៤. តើប្រយោគជ្រែកជាប្រយោគប្រភេទដូចម្ដេច ?*

*៥. តើប្រយោគអនាទរៈបានដល់ប្រយោគយ៉ាងមេច ? សូមឱ្យឧទាហរណ៍ ។*

*៦. តើប្រយោគលក្ខណៈបានដល់ប្រយោគយ៉ាងមេច ? សូមឱ្យឧទាហរណ៍ ។*

*ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ*

**១. ភគវា សាវត្ថិយំ វិហរន្តោ ទេវានំ មនុស្សានំ ច ធម្មំ ទេសេសិ។**

**២. ភិក្ខវោ ភគវន្តំ វន្ទឹសុ ។**

៣.ភិក្ខវោ ភគវតា ទេសិតំ ធម្មំ សុត្វា សតិមន្តា ភវិតុំ វាយមឹសុ។

៤. បញ្ញវន្តេហិ ឥច្ឆិតំ បត្ថិតំ សមិជ្ឈិស្សតិ ។

៥. កុលវតោ ភាតា ភគវតា សហ មន្តេតោ ភូមិយំ បត្ថរិតេ កិលញ្ជេ និសន្នោ អហោសិ ។

៦. ហិមវតិ ពហូ បសវោ ច បក្ខី ច ឧរគា ច វសន្តិ ។

៧. សីលវន្តា ធម្មំ សុត្វា ចក្ខុមន្តា ភវិតុំ ឧស្សហិស្សន្តិ ។

៨. ពុទ្ធិមា បុរិសោ ធាបំ ករោន្តេ បុត្តេ អនុសាសិតុំ បញ្ញវន្តំ ភិក្ខុំ បក្កោសិ ។

៩. យសវតិយា ពន្ធវោ ពលវន្តោ បភុនោ អភវិសុ ។

១០. អរហន្តោ ភគវតោ បុរតោ ច បច្ឆតោ ច ទក្ខិណតោ ច វាមតោ ច និសីទឹសុ, ភគវា តេសំ អរហន្តានំ មជ្ឈេ និសីទិ ។

១១. សព្វេ អរហន្តោ សតិមន្តោ ហោន្តិ, តេ បុញ្ញស្មា ចេវ ធាបា ច មុច្ចឹសុ ។

១២. យោ ភគវន្តំ វា អរហន្តេ វា បហរតិ, តស្សេវ ធាបំ ឧប្បជ្ជតិ, សោ អវស្សំ និរិយំ គច្ឆតិ ។

១៣. យោ ភគវតោ បច្ឆតោបិ អនុគច្ឆតិ, ធម្មំ បន ន ចរតិ, សោ ពុទ្ធំ ន បស្សតិ នាម ។

១៤. បមាទោ មច្ចុនោ បទំ, សតិមា ន បមជ្ជតិ ។

១៥. គហបតិស្ស បស្សន្តស្ស ចោរា ភណ្ឌានិ ហរឹសុ ។

១៦. រុក្ខស្ស សាខាសុ ភិជ្ជន្តីសុ បក្ខិនោ តតោ ឧឌ្ឌេន្តិ ។
១៧. គេហំ មាបេន្តេសុ ជនេសុ ភូមឹ ខនមានេសុ តត្រ ពិលម្ហា
អហិ ឧគ្គច្ឆហិ ។
១៨. ជាតិយា ជរា មរណំ ច (សម្ភវន្តិ) ។

*គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី ។*

*១. ជន.ទ. បូជាហើយ នូវបច្ច័យ.ទ. បួន ដល់ព្រះអរហន្ត.ទ. ច្រើនអង្គ។*
*២. ព្រះមានព្រះភាគ កំពុងសំដែង នូវធម៌ ដល់ព្រហ្ម.ទ. ។*
*៣. កាលក្មេងប្រុស.ទ. កំពុងច្រៀង នូវចម្រៀង ក្មេងស្រី.ទ. រាំហើយ ។*
*៤. កាលកសិករ កំពុងភ្ជួរ នូវស្រែ ប្រពន្ធ របស់គាត់ ចម្អិន នូវបាយ ឯផ្ទះ ។*
*៥. កាលលោកគ្រូ កំពុងបង្រៀន សិស្ស.ទ. អង្គុយហើយ កំពុងស្តាប់ លោកគ្រូ នោះ ។*
*៦. យើង កាលកំពុងទៅ តាមផ្លូវ ឮហើយ នូវសំឡេង របស់ស្រី.ទ. ដែលកំពុងច្រៀង ក្នុងព្រៃ ធំ ។*
*៧. ខ្ញុំ បានឃើញ ដើមឈើ.ទ. ដែលមានផ្លែ ក្នុងភ្នំហិមពាន្ត ។*
*៨. ភិក្ខុ.ទ. ចូលទៅហើយ កាន់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំ ព្រះមានព្រះភាគ ។*
*៩. បុណ្យ ផង បាប ផង តែង មិនមាន ដល់ព្រះអរហន្ត.ទ. ។*
*១០. ជនណា ទៅតាម ខាងក្រោយ របស់ព្រះមានព្រះភាគ មិនប្រព្រឹត្ត*

នូវធម៌ ជននោះ រមែងមិនឃើញ នូវព្រះពុទ្ធ ។

១១. ព្រះ អរហន្ត.ទ. ទាំងពួង ជាអ្នកមានសតិ, ព្រះអរហន្តទាំងនោះ រមែងរួចផុត ចាកបាប ព្រោះបញ្ញា ។

១២. ជនណា ប្រហារ ព្រះមានជោគ ក្ដី ព្រះអរហន្ត.ទ. ក្ដី បាប តែងកើត ដល់ជននោះ, ជននោះ នឹងទៅ កាន់នរក ដោយពិត ។

(ចប់មេរៀនទី ២៤)

## កំណាព្យដាស់តឿនស្មារតី

| | | |
|---|---|---|
| រីសៀវភៅ | គ្រាន់ជាផ្លូវ | ឬជាប្ញង៌ |
| ជាតម្រា | ប្រាប់ទម្រង់ | អង្គចំណេះ |
| អ្នកចំណូល | ចូលចិត្តរៀន | ទើបបានចេះ |
| បើមិនរៀន | សៀវភៅនេះ | បានការអ្វី ? |

ដកស្រង់ពីសៀវភៅ "រៀនភាសាអង់គ្លេស ៦៣ ម៉ោងដោយខ្លួនឯង" ទំព័រ៥២៨ ដោយលោក **ឱម ណារ៉ា**

# មេរៀនទី ២៨

## អធិប្បាយអំពីបកិណ្ណកនាមស័ព្ទ (ត) និង
## វិធីប្រើនិងប្រែអាលបនស័ព្ទ

### វិធីបំបែកពួកទី ៣ ( សត្ថាទិគណៈ )

*សត្ថាទិគណៈមានបីសព្ទ័គឺ* ***សត្ថុ, បិតុ, មាតុ*** *មានវិធីបំបែកតាមបែប* ***សត្ថុ*** *ជាដើម ។* ***សត្ថុ*** *តាមរូបស័ព្ទគឺសម្រេចមកពី* ***សាស*** *ធាតុប្រែថា "បង្រៀន" និង* ***វត្ថុ*** *បច្ច័យក្នុងកិតនាម ។ បច្ច័យណាដែលមានតួ* ***វ*** *អាចឱ្យលុបតួទីបំផុតធាតុចោលសល់តែ* ***សា*** *រួចត្រូវរស្សៈ* ***អា*** *>* ***អ*** *ទៅជា* ***ស*** *រួចលុប* ***វ*** *នៃ* ***វត្ថុ*** *ចេញសល់នៅតែ* ***ត្ថុ*** *សម្រេចបានជា* ***សត្ថុ*** < ( ***សាស*** + ***វត្ថុ*** > ***សត្ថុ*** ) *ប្រែថា "អ្នកបង្រៀន" ប៉ុន្តែនិយមប្រែថា "សាស្តា ឬ ព្រះសាស្តា" គ្រប់កន្លែងនិងប្រើជានាមនាមបុំលិង្គតែម៉្យាង ។*

*១.* ***សត្ថុ*** *ស័ព្ទទោះបីជាមានការន្តជា* ***ឧ*** *ក៏ដោយមិនបំបែកតាម* ***ឧ*** *ការន្តដូចបានអធិប្បាយរួចហើយទេ ពីព្រោះវេលាបំបែកត្រូវលុបស្រៈ* ***ឧ*** *ចេញនិងក្នុងរូបវិភត្តិខ្លះមានចុះ* ***វ*** *ផងដូចមានវិភត្តិសម្រេចខាងក្រោមនេះ*

### វិភត្តិសម្រេចរូបនៃ សត្ថុ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | ឱ |
| ទុ. | អំ | ឱ |
| ត. | អា | ឯហិ, ឯភិ |
| ច. | ឧ | អានំ |
| បញ្ច. | អា | ឯហិ, ឯភិ |
| ឆ. | ឧ | អានំ |
| ស. | ឥ | ឯសុ |
| អា. | អា | ឱ |

## វិធីបំបែក សត្ថុ = សាស្តា, គ្រូ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សត្ថា | សត្ថារោ |
| ទុ. | សត្ថារំ | សត្ថារោ |
| ត. | សត្ថារា | សត្ថារេហិ, សត្ថារេភិ |
| ច. | សត្ថុ | សត្ថារានំ |
| បញ្ច. | សត្ថារា | សត្ថារេហិ, សត្ថារេភិ |
| ឆ. | សត្ថុ | សត្ថារានំ |

| | | |
|---|---|---|
| *ស.* | *សត្ថរិ* | *សត្ថារេសុ* |
| *អា.* | *សត្ថា* | *សត្ថារោ* |

## កំណាត់សម្គាល់

*១. ក្នុងតតិយាវិភត្តិឯកវចនៈមានរូបជា* **សត្ថុនា**, *ក្នុងទុតិយាវិភត្តិពហុវចនៈមានរូបជា* **សត្ថារេ**, *ក្នុងចតុត្ថីនិងឆដ្ឋីវិភត្តិឯកវចនៈមានរូបជា* **សត្ថុនោ**, **សត្ថុស្ស** *និងពហុវចនៈមានរូបជា* **សត្ថានំ**, **សត្ថូនំ** *និងក្នុងអាលបនវិភត្តិឯកវចនៈមានរូបជា* **សត្ថ** *ផងដែរ ។ សូមសង្កេតមើលរូបស័ព្ទទាំងនេះជាការបំបែកតាមបែប* **គរុ**, **ឱ** *ការន្តបុំលិង្គ ។*

*២. មានស័ព្ទដទៃជាច្រើនទៀតមានទីបំផុតជា* **តុ** *(បច្ច័យក្នុងកិតនាមដែលកើតពី* **ធាតុ** + **តុ** *បច្ច័យ) ដែលបំបែកដូច* **សត្ថុ** *ដែរ ។*

| *ស័ព្ទបាលី* | *ពាក្យប្រែ* | *ស័ព្ទបាលី* | *ពាក្យប្រែ* |
|---|---|---|---|
| **កាត្តុ** | *អ្នកធ្វើ* | **ខត្តុ** | *អ្នកជីក* |
| **ញាតុ** | *អ្នកដឹង* | **ទាតុ** | *អ្នកឱ្យ* |
| **ជត្តុ** | *ចៅ* | **នេតុ** | *អ្នកនាំទៅ* |
| **ភត្តុ** | *អ្នកចិញ្ចឹម(ប្តី)* | **វត្តុ** | *អ្នកពោល* |
| **សោតុ** | *អ្នកស្តាប់* | **ហន្តុ** | *អ្នកសម្លាប់* |
| **គន្តុ** | *អ្នកទៅ* | **វត្តុ** | *អ្នកពោល* |
| **វិនេតុ** | *អ្នកឱ្យដំបូន្មាន* | **ជេតុ** | *អ្នកឈ្នះ* |

## វិធីបំបែក កត្តុ = អ្នកធ្វើ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កត្តា | កត្តារោ |
| ទុ. | កត្តារំ | កត្តារោ |
| ត. | កត្តារា | កត្តារេហិ, កត្តារេភិ |
| ច. | កត្តុ | កត្តារានំ |
| បញ្. | កត្តារា | កត្តារេហិ, កត្តារេភិ |
| ឆ. | កត្តុ | កត្តារានំ |
| ស. | កត្តរិ | កត្តារេសុ |
| អា. | កត្តា | កត្តារោ |

៣. **សត្ថុ** ស័ព្ទដែលបំបែកក្នុងរូបជាបឋមាវិភត្តិឯកវចនៈថា **សត្ថា** ឬក្នុងរូបដទៃទៀតជាឯកវចនៈត្រូវប្រើសម្រាប់តែព្រះនាមរបស់ព្រះមានព្រះភាគប៉ុណ្ណោះ និយមប្រែថា ព្រះសាស្តា ឧ. **ត្វំ ភោ សត្ថុនោ វចនំ សុណាហិ** ។ លោកម្ចាស់ដ៏ចម្រើន លោក សូមស្តាប់ នូវព្រះតម្រាស់ (=ពាក្យសំដី) របស់ព្រះសាស្តា ។ ប្រសិនបើជាពហុវចនៈនោះសំដៅដល់សាស្តាដទៃទៀតគឺគ្រូទាំងប្រាំមួយរូបមាន **បូរណកស្សបៈ** ជាដើម ។ និងសំដៅដល់ព្រះនាមរបស់ព្រះពុទ្ធអង្គក្នុងកាលកន្លងទៅប៉ុណ្ណោះ ពីព្រោះក្នុងអតីតកាលមានព្រះពុទ្ធច្រើនអង្គ ហើយភាគច្រើននោះ មាន

សព្ទថា **អតីតេ** =ក្នុងអតីតកាល ឬពាក្យថា **បុព្វេ** =ក្នុងកាលកន្លង ប្រាកដនៅក្នុងប្រយោគនោះ ៗ ចូរមើលឧទាហរណ៍នៅខាងមុខ ។

២. **បិតុ** =ឪពុក, តាមរូបស័ព្ទសម្រេចមកពី **បា** ធាតុក្នុងន័យថា ចិញ្ចឹម, រក្សា, គ្រប់គ្រង, ចុះ **តុ** បច្ច័យក្នុងកិតនាម ។ ធាតុដែលមាន **អា** ជាទីបំផុតអាចផ្លាស់ **អា** នៃ **បា** ជា **ឥ**, ដោយអំណាចនៃ **តុ** បច្ច័យចុះនៅខាងចុងបានរូបជា **បិតុ** (**បា** + **តុ** > **បិតុ**), ឬចុះ **រិតុ** បច្ច័យ ។ បច្ច័យដែលមានតួ **រ** អាចលុបទីបំផុតធាតុនិងលុបតួ **រ** ចោលសល់នៅតែ **ឥតុ** សម្រេចបានជា **បិតុ** (**បា** + **រិតុ** > **បិតុ**) ប្រែថា "បុរសអ្នករក្សានូវបុត្រ" ជាស័ព្ទសម្រេចមកពីសាធនរបស់កិតនាម (មានអធិប្បាយនៅខាងមុខ) និយមប្រើជានាមនាមប្រែថា "ឪពុក ឬ បិតា" ជា **ឧ** ការន្តបុំលិង្គតែត្រូវបំបែកតាមបែប **សត្ថុ** ។

## វិភត្តិសម្រេចរូបរបស់ បិតុ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | ឧ |
| ទុ. | អំ | ឧ |
| ត. | អា, ឧនា | ឯហិ, ឯភិ, ឩហិ, ឩភិ |
| ច. | ឧ, ឧនោ, ឧស្ស | អានំ, ឩនំ |

| | | |
|---|---|---|
| *បញ្ច.* | អា | ឯហិ, ឯភិ, ឱហិ, ឱភិ |
| *ឆ.* | ឧ, ឧណោ, ឧស្ស | អានំ, ឱនំ |
| *ស.* | ឥ | ឯសុ, ឱសុ |
| *អា.* | អា | ឱ |

## វិធីបំបែក បិតុ = ឪពុក, បិតា

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | បិតា | បិតរោ |
| *ទុ.* | បិតរំ | បិតរោ |
| *ត.* | បិតរា, បិតុណា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| *ច.* | បិតុ, បិតុណោ, បិតុស្ស | បិតរានំ, បិតូនំ |
| *បញ្ច.* | បិតរា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| *ឆ.* | បិតុ, បិតុណោ, បិតុស្ស | បិតរានំ, បិតូនំ |
| *ស.* | បិតរិ | បិតរេសុ, បិតូសុ |
| *អា.* | បិតា, បិត | បិតរោ |

## កំណត់សម្គាល់

*១. សូមសង្កេតមើលការបំបែក* បិតុ *មានប្លែកពី* សត្ថុ *ស័ព្ទបន្តិច*

គឺ **បិតុ** ស័ព្ទត្រូវផ្លាស់ជា **បិតរ** មិនមែនជា **អារ** ដូច **សត្ថុ** ទេ ។

២. មានស័ព្ទដែលមានទីបំផុតជា **តុ** បច្ច័យហើយដែលបំបែកដូច **បិតុ** ពីរស័ព្ទគឺ **ភាតុ, ជាមាតុ** ។ **ភាតុ** =បងប្រុសឬប្អូនប្រុស ដើម្បីឱ្យច្បាស់ថាជាបងឬប្អូននោះត្រូវចុះស័ព្ទដទៃពីខាងដើមជា **ជេដ្ឋាភាតុ** = បងប្រុស, **កនិដ្ឋភាតុ** =ប្អូនប្រុស **ជាមាតុ** =កូនប្រសារប្រុស ។

៣. មានករណីពិសេសមួយដែលគួរចងចាំគឺ **បិតុ** ស័ព្ទដែលបំ-បែកក្នុងរូបជាអាលបនទាំងឯកវចនៈនិងពហុវចននោះ គ្រាន់តែបំបែកឱ្យមានទេ ។ វេលាតែងប្រយោគក្នុងភាសាបាលីឬនិយាយមិននិយមប្រើជា **បិត, បិតា, បិតរោ** ទេ លោកឱ្យប្រើស័ព្ទថា **តាត** ជំនួសវិញ ។ ដូច្នេះបើជាឯកវចនៈ **បិត, បិតា** ត្រូវប្រើ **តាត** ជំនួសនិងបើជាពហុ-វចនៈ **បិតរោ** ប្រើ **តាតា** ជំនួសវិញ ។

ពាក្យថា **តាត** ឬ **តាតា** ប្រែថា "លោកឪពុក, បពិត្របិតា" ប្រើចំពោះតែអាលបនវិភត្តិប៉ុណ្ណោះ ជាពាក្យសម្រាប់កូនប្រុសស្រីប្រើហៅឪពុក(បិតា)ក៏បាន ឬក៏មាតាបិតាប្រើហៅកូនប្រុសវិញក៏បាន ។ ជនដទៃដែលជាមនុស្សចាស់នឹងប្រើហៅក្មេងប្រុស ដែលអាយុតិចជាងក៏បានដែរ ប៉ុន្តែត្រូវប្រែថា "នែកូន, នែបា, ហៃបា" ។ល។

**បិតា តេ តាត ឥមស្មឹ គេហេ វសតិ ។**

នែបា(កូនប្រុស), ឪពុក របស់អ្នក កំពុងនៅ ក្នុងផ្ទះ នេះ ។

(ជាសម្ដីរបស់ម្ដាយនិយាយជាមួយកូនប្រុសដោយផ្អែមល្ហែម ត្រូវនឹងពាក្យខ្មែរដែលមនុស្សចាស់និយាយទៅកាន់ក្មេងប្រុសថា "នែបា" នោះឯង) ។

៣. **មាតុ** សម្រេចមកពី **មាន** ធាតុក្នុងសេចក្ដីថា "ស្រឡាញ់, បូជា, សាកល្បង" ចុះ **រាតុ** បច្ច័យក្នុងកិតនាម ។ បច្ច័យណាដែលមានតួ រ ជាអនុព័ន្ធត្រូវលុបទីបំផុតធាតុសល់នៅត្រឹមតែ **មា** ហើយលុប រ ទៀត សល់នៅតែ **អាតុ** ទៅជា **មាតុ** (**មាន** + **រាតុ** > **មាតុ**) ប្រែថា "ស្រីអ្នករាប់អាននូវកូន" ប៉ុន្តែយកមកប្រើជានាមនាមប្រែថា "ម៉ែ, ម្ដាយ, មាតា" ជាស័ព្ទសម្រេចមកពីសាធនៈរបស់កិតនាមដូច **បិតុ** ដែរ ។ **មាតុ** ជា ឧការន្តឥត្ថីលិង្គ ដូច្នេះត្រូវមានវិធីបំបែកប្លែកពី **បិតុ** បន្តិចគឺព្រោះលិង្គខុសគ្នា ដូចមានវិភត្តិសម្រេចខាងក្រោមនេះ

## វិភត្តិសម្រេចរូបរបស់ មាតុ ស័ព្ទ

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អា | ឧ |
| ទុ. | អំ | ឧ |
| ត. | អា, ឧយា | អាហិ, អាភិ, ឩហិ, ឩភិ |
| ច. | ឧ, ឧយា | អានំ, ឩនំ |

| | | |
|---|---|---|
| *បញ្ច.* | អា | អាហិ, អាភិ, ឩហិ, ឩភិ |
| *ឆ.* | ឧ, ឧយា | អានំ, ឩនំ |
| *ស.* | ឥ | អាសុ, ឩសុ |
| *អា.* | អា | ឱ |

## វិធីបំបែក មាតុ = ម្ដាយ, មាតា

| *វិភត្តិ* | *ឯកវចនៈ* | *ពហុវចនៈ* |
|---|---|---|
| *ប.* | មាតា | មាតរោ |
| *ទុ.* | មាតរំ | មាតរោ |
| *ត.* | មាតរា, មាតុយា | មាតរាហិ, មាតរាភិ, មាតូហិ, មាតូភិ |
| *ច.* | មាតុ, មាតុយា | មាតរានំ, មាតូនំ |
| *បញ្ច.* | មាតា | មាតរាហិ, មាតរាភិ, មាតូហិ, មាតូភិ |
| *ឆ.* | មាតុ, មាតុយា | មាតរានំ, មាតូនំ |
| *ស.* | មាតរិ | មាតរេសុ, មាតូសុ |
| *អា.* | មាតា | មាតរោ |

## កំណត់សម្គាល់

*១. មានស័ព្ទដែលបំបែកដូច* មាតុ *ពីរស័ព្ទគឺ* ធីតុ, ទុហិតុ *ប្រែថា*

"កូនស្រី, ធីតា" ។

២. **មាតុ** មានវិធីបំបែកស្រដៀងនឹង **បិតុ** ដែរ ។

៣. **មាតុ** ក្នុងរូបជាអាលបនទាំងឯកវចនៈនិងពហុវចនៈ វេលាយកមករៀងក្នុងប្រយោគភាសាបាលីមិននិយមប្រើ **មាតា** ឬ **មាតរោ** ទេលោកឱ្យប្រើ **អម្ម** ជំនួស ។ ដូច្នេះបើជាឯកវចនៈ **មាតា** ប្រើ **អម្ម** ជំនួសនិងបើជាពហុវចនៈ **មាតរោ** ប្រើ **អម្មា** ជំនួសវិញ ។

ពាក្យថា **អម្ម** ឬ **អម្មា** ប្រើសម្រាប់អាលបនៈប៉ុណ្ណោះ ជាពាក្យសម្រាប់កូនប្រុសស្រីប្រើហៅម្ដាយ ប្រែថា "ម៉ែ, បពិត្រមាតា, អ្នកម្ដាយ" ឬមាតាបិតាប្រើហៅកូនស្រីវិញក៏បាន តែត្រូវប្រែថា "ម្នាលកូន, នែកូន, នែនាង, នែមេ" ។ សូម្បីតែមនុស្សចាស់ក៏ប្រើហៅក្មេងស្រីជាងក៏បានដែរ

**ឧ. ត្វំ <u>អម្ម</u> តវ មាតុយា ឥមំ វត្ថំ ទេហិ ។**

<u>នែមេ</u>(កូនស្រី) កូនឯង ចូរឱ្យ នូវសំពត់ ដុំនេះ ដល់ម៉ែ របស់អ្នក ។

ជាពាក្យសម្ដីរបស់ឪពុកនិយាយទៅកាន់កូនស្រី ដោយភាពផ្អែម-ល្ហែម ត្រូវគ្នានឹងពាក្យភាសាខ្មែរដែលមនុស្សចាស់ប្រើហៅក្មេងស្រីថា "មេនាង" នោះឯង ។

***សូមកត់សម្គាល់*** ស័ព្ទដែលមានទីបំផុតជា **តុ** និង **ត** ដែលជាបកិណ្ណកស័ព្ទមានវិធីបំបែកផ្សេងគ្នាដូច្នេះ គឺ

១. ស័ព្ទណាមានទីបំផុតជា **វន្តុ** បច្ច័យក្នុងតទ្ធិត, សព្ទ័នោះ ៗ

និយមប្រកបរូបមកពីនាមនាមដែលជា **អ**, **អា** ការន្តដូចជា **គុណវន្តុ**, **បញ្ញវន្តុ** ជាដើម, និងត្រូវបំបែកដូច **ភគវន្តុ** ។ បើមានទីបំផុតជា **មន្តុ** បច្ច័យស័ព្ទនោះច្រើនប្រកបរូបមកពីនាមនាមដែលជា **ឥ**, **ឧ** ការន្តដូចជា **ជិតិមន្តុ** =ជនមានបញ្ញា, **ចក្ខុមន្តុ** =ជនមានចក្ខុ ជាដើម និងត្រូវបំបែកដូច **ភគវន្តុ** ដែរ ។ ស័ព្ទទាំងនេះសម្រេចមកពីតទ្ធិតនាម ។

២. ស័ព្ទណាដែលមានទីបំផុតជា **អន្ត** បច្ច័យក្នុងកិតកិរិយា ស័ព្ទនោះ ៗ ត្រូវតែសម្រេចមកពីធាតុដូចជា **ភវន្ត**, **អរហន្ត** ប្រើជានាមនាមក៏បាននិងជាគុណនាមក៏បាន ត្រូវបំបែកដូច **ភគវន្តុ** ។

៣. ស័ព្ទណាដែលមានទីបំផុតជា **តុ** បច្ច័យក្នុងកិតនាម ស័ព្ទនោះ ៗ ត្រូវតែសម្រេចមកពីធាតុដូចជា **ញាតុ** =អ្នកដឹង, **ទាតុ** =អ្នកឱ្យ ។ ប្រើជានាមនាមត្រូវបំបែកដូច **សត្ថុ** ចូរមើលកិតនាមនៅខាងមុខ ។

៤. នាមស័ព្ទដែលមានទីបំផុតជា **តុ** និងដែលមិនមែនជាបកិណ្ណកស័ព្ទដូចជា **សត្តុ** =សត្រូវ, **សេតុ** =ស្ពាន, **កេតុ** =ទង់ ជាដើម ជានាម-នាមប្រភេទសាមញ្ញស័ព្ទ ត្រូវបំបែកតាម **ឧ** ការន្តនៃលិង្គនោះ ៗ ។

## វិធីប្រែភាសាបាលីពេញបរិបូណ៌

វិធីលើកស័ព្ទប្រែក្នុងកាលកន្លងមកមិនមានអាលបនស័ព្ទទេ ។ ប្រសិនបើមានអាលបនស័ព្ទនៅក្នុងប្រយោគផងដែរ នោះត្រូវថែមវិធី

ប្រែទៀតដូចខាងក្រោមនេះ

## វិធីប្រែប្រយោគកត្តុវាចក: (តចប់)

**បទអាលបន** (បើមាន)....................................................... ប្រែទី ១
បទវិសេសននៃបទអាលបន (បើមាន).................................. ប្រែទី ២
**បទនិបាត** (ពួកខ្លះបើមាន).................................................. ប្រែទី ៣
**បទកាលសត្តមី** (បើមាន).................................................. ប្រែទី ៤
បទប្រធាន (មានរូបបឋមាវិភត្តិ)............................................ ប្រែទី ៥
បទវិសេសននៃបទប្រធាន (បើមាន)...................................... ប្រែទី ៦
បទអនុកិរិយា (កិតកិរិយា បើមាន)....................................... ប្រែទី ៧
បទកម្មឬបទកិរិយាវិសេសន៍នៃអនុកិរិយា............................. ប្រែទី ៨
បទមហាកិរិយា (អាខ្យាតកិរិយាឬកិតកិរិយា)......................... ប្រែទី ៩
បទកម្មនៃមហាកិរិយា (មានរូបជាទុតិយាវិភត្តិ បើមាន).......... ប្រែទី ១០
បទវិសេសនៈនៃបទកម្មរបស់មហាកិរិយា (បើមាន)................ ប្រែទី ១១

ខាងលើនេះជាវិធីលើកស័ព្ទប្រែតាមលំដាប់លេខពី ១-២-៣-៤-៥ រហូតដល់អស់ប្រយោគរបស់ប្រយោគកត្តុវាចក: ។ ដើម្បីប្រែប្រយោគបាលីឱ្យបានល្អ យើងត្រូវសិក្សាឱ្យយល់ថាលេខ ១ បទអាលបនជាស័ព្ទ

ប្រភេទណា, លេខ ២ បទនិបាតជាស័ព្ទប្រភេទណា, និបាតនោះ ៗ ប្រាប់ន័យដូចម្ដេចខ្លះ, បទកាលសត្តមីជាស័ព្ទប្រភេទណា រហូតដល់អស់លេខថាជាស័ព្ទអ្វីខ្លះ ។ ចាប់ពីលេខ ៥-១០ បានពោលទុកក្នុងវិធីប្រែប្រយោគកត្តុវាចកៈខាងដើមរួចហើយ តទៅនឹងអធិប្បាយពីលេខ ១-៤ ប៉ុណ្ណោះ ។

## វិធីប្រើនិងប្រែស័ព្ទអាលបន

ស័ព្ទអាលបនក្នុងភាសាបាលីមាន ២ យ៉ាងគឺ អាលបននាម និង អាលបននិបាត ។

### ១. វិធីប្រើអាលបននាម

អាលបននាម បានដល់នាមនាមទាំងឡាយណាដែលបំបែកក្នុងរូបជាអាលបនវិភត្តិទាំងជាឯកវចនៈនិងពហុវចនៈ មានអាយតនិបាតប្រែថា "បពិត្រ, ម្នាល, នែ, ហែ" ដូចជាពាក្យថា **បុរិស**, **បុរិសា**, **ភិក្ខុ**, **ភិក្ខវេ** ជាដើម ។

រីឯអាលបននិបាតវិញជាពាក្យពុំចាំបាច់បំបែកទេ ជាពាក្យសម្រាប់និយាយចំពោះបុគ្គលមានឋានៈឬវណ្ណៈ ដូចជាពាក្យថា **យគ្ឃេ**, **ភន្តេ**, **ភទន្តេ** (**ភទ្ទន្តេ**) ជាដើម ។

*រឿងដែលគប្បីដឹងគឺថា កាលបើមានបទអាលបននិបាតនិងបទអាលបននាមនៅក្នុងប្រយោគតែមួយជាមួយគ្នា តើនឹងលើកប្រែដោយវិធីណា ? មានអធិប្បាយដូចតទៅនេះ*

*ប្រសិនបើមានបទអាលបនៈប្រភេទណាមួយក្នុងប្រយោគណាមួយ យើងគប្បីលើកបទអាលបននោះប្រែមុនគេបង្អស់ ដើម្បីឱ្យត្រូវតាមក្បួនប្រែភាសាបាលី ដូចឧទាហរណ៍ខាងក្រោមនេះ -*

## វិធីប្រើនិងប្រែបទអាលបននាម

**១. ធម្មំ$_{១០}$ វោ$_{១១}$ ភិក្ខវេ$_{១}$ ទេសិស្សាមិ$_{៩}$ ។**

*ម្នាលភិក្ខុ.ទ.$_{១}$ (តថាគត$_{៥}$) នឹងសំដែង$_{៩}$ នូវធម៌$_{១០}$ ដល់អ្នក.ទ.$_{១១}$ ។*

**២. មា គច្ឆ$_{៩}$ បុត្ត$_{១}$ តំ$_{១១}$ គាមំ$_{១០}$ ។**

*នែកូន$_{១}$ (ឯង$_{៥}$) ចូរកុំទៅ$_{៩}$ កាន់ស្រុក$_{១០}$ នោះឡើយ$_{១១}$ ។*

*ប្រសិនបើមានបទអាលបននាមច្រើនបទត្រូវប្រែបទមួយឱ្យជាបទវិសេសនៈរបស់បទមួយទៀត ឧ.*

**៣. ឥង្ឃ$_{៣}$ បស្ស$_{៩}$ នដបុត្ត$_{២}$ ឧគ្គសេន$_{១}$ មហាពល$_{២}$ ។**

*ម្នាលឧគ្គសេន$_{១}$ ជាកូនអ្នករបាំ$_{២}$ ដែលមានកម្លាំងច្រើន$_{២}$ សូមអញ្ជើញ$_{៣}$ មើលចុះ$_{៩}$ ។*

## ២. វិធីប្រើអាលបននិបាត

*អាលបននិបាតបានដល់អព្យយស័ព្ទមួយពួកប្រើជានិបាត និងជាស័ព្ទដែលពុំចាំបាច់បំបែកទេ មាន ១០ ស័ព្ទគឺ* **យគ្ឃេ, ភន្តេ, ភទន្តេ (ភទ្ទន្តេ), ភណេ, អម្ភោ, អាវុសោ, រេ, អរេ, ហេ, ជេ ។**

*ពាក្យថា "អាលបន" ប្រែថា "ហៅរក" ជាពាក្យសម្រាប់ប្រើហៅរកគ្នាឬពោលទៅមករកគ្នាដែលមានដប់ស័ព្ទខាងលើនេះ ត្រូវលើកស័ព្ទណាមួយមកប្រើឱ្យត្រូវតាមកាលៈទេសៈ និងវណ្ណៈរបស់ជននោះ ៗ ពីព្រោះជនទាំងឡាយមានឋានៈមិនដូចគ្នា ដូច្នេះស័ព្ទមួយ ៗ មានពាក្យប្រែនិងវិធីប្រើមិនដូចគ្នាទេ ។*

## វិធីប្រើនិងប្រែបទអាលបននិបាត

*១.* **យគ្ឃេ** *ប្រែថា "សូមព្រះតេជះ, សូមព្រះរាជតេជះតម្កល់លើត្បូង, សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះតេជះ, សូមទានមេត្តាប្រោស, ទានប្រោស" ។ ស័ព្ទនេះប្រើបានចំពោះតែក្រាបទូលព្រះមហាក្សត្រទ្រង់រាជ្យ ឬឥស្សរជនមានអនុភាពធំជាងខ្លួន ឬក៏គ្រហស្ថនិយាយក្នុងជំនុំសង្ឃដែលគ្រហស្ថនោះមានសេចក្ដីគោរពច្រើន ឱ.*

**យស្មា₁ នេ₂ ជានេយ្យាសិ₉ ។**

*សូមព្រះរាជតេជះតម្កល់លើត្បូង₁ បពិត្រព្រះសម្មតិទេព₂ សូមព្រះអង្គទ្រង់ជ្រាប₉ ។*

២. **ភន្តេ, ភទន្តេ** *ពីរស័ព្ទនេះប្រែថា "បពិត្រព្រះអង្គ, ព្រះករុណាដ៏ចម្រើន, បពិត្រព្រះអង្គដ៏ចម្រើន" ។ គប្បីលើកយកប្រើឱ្យសមសួន ជាស័ព្ទសម្រាប់គ្រហស្ថប្រើនិយាយទៅកាន់បព្វជិតដោយសេចក្តីគោរព ឬបព្វជិតមានវស្សាតិចនិយាយចំពោះបព្វជិតមានវស្សាចាស់ជាង ដូចមានបទសន្ទនាខ្លីមួយខាងក្រោមនេះ*

**១. កាតមំ₄ បន₂ ភន្តេ₁ គន្ធធុរំ₃ ?**

*បពិត្រព្រះអង្គដ៏ចម្រើន₁ ចំណែក₂ ជាគន្ថធុរៈ₃ តើដូចម្តេច₄ ?*

*ឧទាហរណ៍នេះជាប្រយោគសំនួរ ដូច្នេះវិធីលើកស័ព្ទប្រែមានលក្ខណៈខុសពីតារាងខាងលើ សូមរកមើលក្នុងមេរៀនទី ១១ បន្ថែមផង ។*

**២. ភទន្តេតិ តេ₆ ភិក្ខូ₄ ភគវតោ₁₁ (វចនំ)₁₀ បច្ចស្សោសុំ₉។**

*ភិក្ខុ.ទ. នោះ បានទទួលស្តាប់ហើយ (នូវព្រះតម្រាស់) របស់ព្រះមានព្រះភាគ (តប)ថា "***ភទន្តេ*** *=បពិត្រព្រះអង្គដ៏ចម្រើន" ។*

☸ *វិធីសរសេរនិងប្រើ* **ឥតិ** *ស័ព្ទមានអធិប្បាយនៅខាងមុខ ។*

*ពាក្យថា* **ភទន្តេ** *បើជាពហុវចនៈថា* **ភទន្តា** *ក៏បានខ្លះ គឺឃើញ*

មានប្រើនៅក្នុងបទជំនុំទេវតា(បទសគ្គេ)ត្រង់ទីបញ្ចប់ថា

**ជម្មស្សវនកាលោ អយម្ភទន្តា** (អយំ + ភទន្តា) ។

ប្រែថា នៃអ្នកដ៏ចម្រើន.ទ. វេលានេះ ជាវេលាស្តាប់ធម៌ (ថាបីដង) ។

៣. **ភណេ** ប្រែថា "នៃនាយ, ចៅ, ប្រស្តែង, វ៉ី, វ៉ើយ" ជាពាក្យសម្រាប់អ្នកមានយសស័ក្តិមានដំណែងខ្ពស់ ក្នុងសម័យពុទ្ធកាលពួកព្រាហ្មណ៍ត្រូវបានគេឱ្យកិត្តិយសថាជាជនមានវណ្ណៈខ្ពស់ ភាគច្រើនប្រើពាក្យថា **ភណេ** ឧ.

**ទុក្ករំ ភណេ ព្រាហ្មណេន កតំ ។**

នៃនាយ កម្មដែលបុគ្គលធ្វើដោយលំបាក គឺព្រាហ្មណ៍ ធ្វើហើយ ។

(នេះជាប្រយោគកម្ម សូមមើលតារាងប្រែនៅខាងមុខ) ។

ពាក្យថា **ភណេ** ក្នុងភាសាបាលីមានប្រើតិចតួចទេ ។

៤. **អម្ភោ** ប្រែថា "នៃអ្នកដ៏ចម្រើន, នៃលោក, នៃអ្នក, នាង, អានាង, វ៉ី, វ៉ើយ" មានពាក្យប្រែច្រើនស័ព្ទ សូមលើកយកណាមួយមកប្រើឱ្យសមសួន គឺជាពាក្យសម្រាប់និយាយទៅកាន់ក្មេងប្រុស ជាពាក្យផ្អែមល្ហែម ឧ.

**អម្ភោ₁ ឯសោ₄ សាលិកាចោតកោ₅, តំ₁₀ កណ្ហាថ₉។**

អ្នកដ៏ចម្រើន₁ នោះ₄ ជាកូនចាបសាលិកា₅, (ឯង.ទ.₈) ចូរចាប់₉ នូវវា₁₀ ។

(ចាប់ពី **អម្ភោ ឯសោ សាលិកាចោតកោ**, ជាប្រយោគបទវិកតិកត្តា សូមមើលវិធីប្រែប្រយោគវិកតិកត្តានៅខាងមុខនិងក្នុងមេរៀនទី ១០) ។

៥. **អាវុសោ** ប្រែថា "ម្នាលលោកដ៏មានអាយុ" ជាពាក្យសម្រាប់បព្វជិត(ភិក្ខុ)អ្នកមានវស្សាចាស់និយាយចំពោះបព្វជិតអ្នកមានវស្សាតិចជាង ឬបព្វជិតនិយាយទៅកាន់គ្រហស្ថក៏បាន ឧ.

**មា អាវុសោ₁ ឯវំ₁₀ អវច₉** ។ ម្នាលលោកដ៏មានអាយុ₁ លោក₈ កុំនិយាយឡើយ₉ យ៉ាងនេះ₁₀ ។

៦. **រេ**, **អរេ** ពាក្យពីរម៉ាត់នេះប្រែថា "រ៉ឺ, រ៉ឺយ, អាខ្វច, អាចង្រៃ, មេខ្វច, មេចង្រៃ, អានេះ, មេនេះ" ជាពាក្យទ្រគោះមាក់ងាយ ឧ.

**អរេ ខុជ្ជេ** ។ នែមេគមចង្រៃ ។

**តិដ្ឋ រេ** ។ ឯង ចូរឈរ (ឈប់) រ៉ឺ ។

៧. **ហេ** ប្រែថា "ហឺយ, រ៉ឺយ ឬ អ្នកទាំងឡាយ" ជាពាក្យសម្រាប់និយាយទៅកាន់មនុស្សមិនល្អ ជាពាក្យទ្រគោះ ឧ.

**ហេ₂ មល្លិកេ₁ កស្មា₂ ឯវរូបមកាសិ₉ (=ឯវរូបំ + អកាសិ)** ។

នែនាងមល្លិកា₁ ហឺយ₂ ហេតុណាមួយ₃ (នាង₄) បានធ្វើហើយនូវកម្មមានសភាពយ៉ាងនេះ₉ ?

(នេះជាប្រយោគបុច្ឆា សូមរកមើលក្នុងមេរៀនទី ១១) ។

ពាក្យថា រេ, អរេ, ហេ ទាំងបីម៉ាត់នេះមានប្រើតិចតួចទេ ។

ប៉ុន្តែក្នុងភាសាខ្មែរក៏មានប្រើពាក្យបែបនេះច្រើនណាស់ដែរ ជាពិសេសអ្នកដែលពុំសូវគិតគូពីរឿងសុភាពរាបសារ ដូចជាពាក្យថា "អានេះ, មេនេះ, មេនោះ, អាដែង, អ្អែង, ហង" ជាដើម ។

៨. ជេ ប្រែថា "នែហង, នែមេ" សម្រាប់ប្រើហៅស្រីឬស្រីបាវបម្រើ ឬស្រីបម្រើមានឋានៈតូចទាបជាងខ្លួនក្នុងភាពផ្អែមល្ហែម ឧ.

**ហន្ទ ជេ ឥមំ ភណ្ឌំ គណ្ហាហិ ។**

ហ៎ នែហង ចូរឯងយក នូវវត្ថុ នេះ ។

"**ហេ ជេ កាលិ** !" "ហឺយ នែមេកាលិ!"

"**កឹ អយ្យេ** ?" "ចាស អ្នកនាង"

"**កឹ ជេ ទិវា ឧដ្ឋាសីតិ** ?" "ម៉េចឯង ក្រោក ថ្ងៃម្ល៉េះ ?"

## កំណត់សម្គាល់

១. ប្រសិនបើមានបទអាលបននាមច្រើនបទនៅក្នុងប្រយោគតែ-មួយ គឺត្រូវប្រែបទមួយឱ្យជាបទវិសេសនៈរបស់បទមួយទៀត ។ បទមួយដែលមិនមែនជាវិសេសនៈត្រូវប្រែចេញពាក្យអាយតនិបាត ។ រីឯបទមួយដែលជាបទវិសេសនៈត្រូវប្រែទទេ ៗ ត្រឹមស័ព្ទប៉ុណ្ណោះ ឧ.

**ឥង្ឃ៍៣ បស្ស៤ ជាជបុត្ត២ ឧក្កសេន១ មហាព្វល២។**

ម្នាលឧគ្គសេន១ ជាកូនអ្នករបាំ១ ដែលមានកម្លាំងច្រើន២ សូមអញ្ជើញ៣ មើលចុះ៤ ។

ឧទាហរណ៍នេះបទថា **ជាជបុត្ត** និង **ឧក្កសេន** ពីរបទនេះជាបទអាលបននាមដូចគ្នា ពេលប្រែត្រូវប្រែឱ្យ **ជាជបុត្ត** ជាបទវិសេសនៈក្នុង **ឧក្កសេន** ។ សូមអ្នកសិក្សាជ្រាបតាមសេចក្ដីនេះផងចុះ ។

២. ប្រសិនបើមានបទអាលបននិបាតច្រើនបទនៅក្នុងប្រយោគតែមួយវិញ មិនត្រូវប្រែបទមួយឱ្យជាបទវិសេសនៈរបស់បទមួយទៀតទេ ត្រូវប្រែតាមស័ព្ទនោះ ៗ ពីព្រោះលោកមិនបានចាត់អាលបននិបាតជាគុណបទឡើយ ឧ.

**យគ្ឃេ១ ភន្តេ២ ភិក្ខុសង្ឃោ ឥធំ មេ បច្ឆិមទានំ បដិគណ្ហាតិ ។**

សូមទានមេត្តាប្រោស១ បពិត្រព្រះករុណាដ៏ចម្រើន២ សូមព្រះភិក្ខុសង្ឃ ទទួល នូវទាន នេះ ដែលជាទានចុងក្រោយបំផុត របស់ខ្ញុំព្រះករុណា ។

**យគ្ឃេ១ ភន្តេ២ សង្ឃោ ជានាតុ ។** សូមទានមេត្តាប្រោស១ បពិត្រព្រះករុណាដ៏ចម្រើន២ ព្រះសង្ឃ សូមជ្រាបចុះ ។

៣. តែបើមានអាលបនៈទាំងពីរប្រភេទនៅក្នុងប្រយោគតែមួយ គឺបទអាលបននាមនិងអាលបននិបាតផង ឃើញនិយមរៀងបទអាលបននិបាតដាក់ខាងដើមឬខាងមុខអាលបននាមជានិច្ច ក្នុងករណីបែបនេះ

វេលាប្រែត្រូវលើកយកអាលបននាមប្រែទី ១, បទអាលបននិបាតក្លាយជាបទគុណប្រែទី ២ ឱ.

**អម្ហោ**$_{២}$ **កុមារា**$_{១}$ =នៃកុមារទាំងឡាយ$_{១}$ ដ៏ចម្រើន$_{២}$ ។

**អាវុសោ**$_{២}$ **តិស្ស**$_{១}$ =ម្នាលតិស្សៈ$_{១}$ អ្នកមានអាយុ$_{២}$ ។

សូមមើលឧទាហរណ៍ខាងលើត្រង់ **អម្ហោ** ស័ព្ទថែមផង ។

ប្រសិនបើមានស័ព្ទអាលបនៈនៅក្នុងប្រយោគ យើងអាចសង្កេតឃើញយ៉ាងងាយ ពីព្រោះនិយមរៀងទី ២, ឬទី ៣, ឬក៏ទី ៤ នៅខាងដើមនៃប្រយោគនោះ ៗ ។

## វិធីប្រែប្រយោគបទវិកតិកត្តា

អាលបន (បើមាន).................................................................. ប្រែទី ១

បទវិសេសនៈនៃបទអាលបនៈ (បើមាន)............................... ប្រែទី ២

បទនិបាត (ពួកខ្លះបើមាន).................................................... ប្រែទី ៣

បទកាលសត្តមី (បើមាន)........................................................ ប្រែទី ៤

បទប្រធាន (មានរូបបឋមាវិភត្តិ)............................................ ប្រែទី ៥

បទវិសេសនៈនៃបទប្រធាន (បើមាន)..................................... ប្រែទី ៦

**បទវិកតិកត្តា** ............................................................... ប្រែទី ៧

បទកិរិយាគ្រប់គ្រង (ប្រើ **អស**, **ភូ**, **ហុ** ធាតុ)......................... ប្រែទី ៨

## ប្រយោគឧទាហរណ៍

**១. តាត$_{១}$ មហល្លកស្ស$_{៦}$ ហិ$_{២}$ អត្តនោ$_{៦}$ ហត្ថបាទាបិ$_{៧}$ អនស្សវា$_{៥}$ ហោន្តិ ។**

*នៃប្អូន$_{១}$ ព្រោះថា$_{២}$ សូម្បីរីដៃនិងជើង.ទ.$_{៥}$ នៃខ្លួន$_{៦}$ របស់បុគ្គលចាស់$_{៦}$ ជាអវយវៈមិនស្តាប់បង្គាប់$_{៧}$ ។*

**២. មហាសុវណ្ណោ$_{៦}$ នាម កុដុម្ពិកោ$_{៧}$ អហោសិ$_{៨}$ អឌ្ឍោ$_{៧}$ មហទ្ធនោ$_{៧}$ មហាភោគោ$_{៧}$ អបុត្តកោ$_{៧}$ ។**

(**សេដ្ឋី**$_{៥}$=*រីសេដ្ឋី*$_{៥}$) *ឈ្មោះ មហាសុវណ្ណ$_{៦}$ ជាកុដុម្ពីក៍$_{៧}$ ជាអ្នកមានសម្បត្តិ$_{៧}$ ជាអ្នកស្តុកស្តម្ភ$_{៧}$ ជាអ្នកមានទ្រព្យច្រើន$_{៧}$ ជាអ្នកមិនមានបុត្រ$_{៧}$ ។*

*សូមសម្គាល់ថា មហាកិរិយាស័ព្ទដូនណាមិនមានក្នុងប្រយោគទេ តែបើមានវិញ ចង់ប្រែក៏បានមិនបាច់ប្រែក៏បានដែរ ប៉ុន្តែមិនសូវនិយមប្រែទេ ។ សូមរកមើលរឿងរីកតិកត្តានេះក្នុងមេរៀនទី ១០ សាឡើងវិញផង ។*

## វិធីប្រែប្រយោគហេតុកត្តុវាចក: (តចប់)

*បទអាលបន (បើមាន)*........................................................ *ប្រែទី ១*

*បទវិសេសននៃបទអាលបន (បើមាន)*.................................. *ប្រែទី ២*

បទនិបាត (ពួកខ្លះបើមាន)................................................ ប្រែទី ៣
បទកាលសត្តមី (បើមាន)................................................... ប្រែទី ៤
បទប្រធាន (មានរូបជាបឋមាវិភត្តិ)...................................... ប្រែទី ៥
បទវិសេសនៈនៃបទប្រធាន (បើមាន)................................. ប្រែទី ៦
បទការីតកម្ម (មានរូបជាទុតិយាឬតតិយាវិភត្តិ)...................... ប្រែទី ៧
បទវិសេសនៈនៃបទការីតកម្ម (ជាឆដ្ឋីវិភត្តិ,គុ.,កិតកិរិយា)....... ប្រែទី ៨
បទអនុកិរិយា (មានរូបជាកិតកិរិយា បើមាន)........................ ប្រែទី ៩
បទកម្មឬបទកិរិយាវិសេសន៍នៃអនុកិរិយា (បើមាន)............... ប្រែទី ១០
បទមហាកិរិយាស័ព្ទ (ជាអាខ្យាតកិរិយាហេតុកត្តុវាចកៈ)........ ប្រែទី ១១
បទអវុត្តកម្ម(ជាទុ.វិភត្តិ ឬបទសម្បទាន ជាច.វិភត្តិ បើមាន).... ប្រែទី ១២
បទវិសេសននៃបទអវុត្តកម្ម (តតិ,ឆដ្ឋី,សត្តមីវិភត្តិ,គុ.បើមាន). ប្រែទី ១៣

## ប្រយោគឧទាហរណ៍

ព្រហ្មណោ៥ ឧណ្ហោទកកុំ១០ កាជំ១០ បុរិសេន៧ គាហាបេត្វា៩ ជាណិតស្ស១០ ច បុជំ១០ អាយស្នុន្តោ១២ ឧបាជស្ស១២ អជាសិ១១។

ព្រាហ្មណ៍៥ ញុំាងបុរស៧ ឱ្យនាំមក៩ នូវអម្រែក១០ នៃទឹកក្ដៅ១០(=ទឹកក្ដៅ ៗ មួយអម្រែក) និង នូវកញ្ជ្រោង១០ នៃស្កុរអំពៅ១០ (=ស្ករអំពៅ

មួយកញ្ជ្រោង) ឱ្យហើយ[១១] ដល់លោកដ៏មានអាយុ[១២] ឧបវាន:[១២] ។

រឿងហេតុកត្តុវាចក:នេះសូមរកមើលក្នុងមេរៀនទី ១៦ សាឡើងវិញផង ។

## វិធីប្រែប្រយោគកម្មវាចក: (តចប់)

អាលបន (បើមាន)............................................................ប្រែទី ១

បទវិសេសន:នៃបទអាលបន: (បើមាន)..............................ប្រែទី ២

បទនិបាត (ពួកខ្លះបើមាន)...................................................ប្រែទី ៣

បទកាលសត្តមី (បើមាន).....................................................ប្រែទី ៤

បទប្រធាន (មានរូបជាបឋមាវិភត្តិ).........................................ប្រែទី ៥

បទវិសេសន:នៃបទប្រធាន (បើមាន)....................................ប្រែទី ៦

បទអនភិហិតកត្តា (មានរូបជាតតិយាវិភត្តិជាតួកត្តា).............ប្រែទី ៧

បទវិសេសន:នៃបទអនភិហិតកត្តា (បើមាន).........................ប្រែទី ៨

បទអនុកិរិយាស័ព្ទ (មានរូបជាកិរិយាកិតក បើមាន)................ប្រែទី ៩

បទកម្មឬបទវិសេសន:នៃអនុកិរិយាស័ព្ទ (ជាទុតិយាវិភត្តិ)......ប្រែទី ១០

បទមហាកិរិយាស័ព្ទ (មានរូបជាកម្មវាចកកិរិយា)...................ប្រែទី ១១

បទវិសេសន:ឬកន្សោមពាក្យចូលនឹងមហាកិរិយា (បើមាន)....ប្រែទី ១២

## ប្រយោគឧទាហរណ៍

**ភាវេតព្វំ យំ ភិញ្ញំ បុគ្គលេន ភាវិយតេ ។**

*វត្ថុណាមួយ ដែលគួរចម្រើន គឺបុគ្គល រមែងឲ្យចម្រើន ។*

**យស្ស ចាបំ កាតំ កម្មំ កុសលេន បហីយតិ ។**

*កម្ម អាក្រក់ របស់បុគ្គលណា គឺគេធ្វើហើយ គេរមែងលះ ដោយកុសល ។*

*សូមរកមើលក្នុងមេរៀនទី ១៤ សាឡើងវិញផង ។*

## វិធីប្រែប្រយោគហេតុកម្មវាចកៈ (តចប់)

*អាលបន (បើមាន)............................................................ ប្រែទី ១*

*បទវិសេសនៈនៃបទអាលបន (បើមាន)............................. ប្រែទី ២*

*បទនិបាត (ពួកខ្លះបើមាន)................................................. ប្រែទី ៣*

*បទកាលសត្តមី (បើមាន)................................................... ប្រែទី ៤*

*បទប្រធាន (មានរូបជាបឋមាវិភត្តិ)........................................ ប្រែទី ៥*

*បទវិសេសនៈនៃបទប្រធាន (បើមាន).................................. ប្រែទី ៦*

*បទអនភិហិតកត្តា (មានរូបជាតតិយាវិភត្តិជាតួកត្តា)............ ប្រែទី ៧*

បទវិសេសនៈនៃបទអនភិហិតកត្តា (បើមាន)........................ ប្រែទី ៨
បទការីតកម្ម (មានរូបជាទុតិយា,តតិយាវិភត្តិ)...................... ប្រែទី ៩
បទវិសេសនៈនៃបទការីតកម្ម (ជាឆដ្ឋីវិភត្តិ,គុ.,កិតកិរិយា)..... ប្រែទី ១០
បទអនុកិរិយាស័ព្ទ (មានរូបជាកិតកិរិយា បើមាន)................. ប្រែទី ១១
បទកម្មឬបទវិសេសនៈនៃអនុកិរិយាស័ព្ទ (ជាទុ.វិភត្តិ)............ ប្រែទី ១២
បទមហាកិរិយាស័ព្ទ (មានរូបជាហេតុកម្មវាចកកិរិយា).......... ប្រែទី ១៣
បទអវុត្តកម្ម (មានរូបជាទុតិយាវិភត្តិ បើមាន)........................ ប្រែទី ១៤
បទវិសេសនៈនៃបទអវុត្តកម្ម (ជាតតិយា,ឆដ្ឋី,សត្តមី,គុ.)......... ប្រែទី ១៥

## ប្រយោគឧទាហរណ៍

**១. គុណវិសេសោ៥ អារទ្ធវីរិយេន៧ សិស្សេ៩ អជិកច្ឆាបិយតេ១៣។**

*គុណវិសេស៥ គឺលោកអ្នកមានព្យាយាមប្រារព្ធ៧ ញុំាំងសិស្ស.ទ.៩ ឱ្យសម្រេច១៣ ។ (នេះជាអាខ្យាតកិរិយា)*

**២. គុណវិសេសោ៥ អារទ្ធវីរិយេន៧ សិស្សេ៩ អជិតតោ១៣ ។**

*គុណវិសេស៥ គឺលោកអ្នកមានព្យាយាមប្រារព្ធ៧ ញុំាំងសិស្ស.ទ.៩ ឱ្យសម្រេចហើយ១៣ ។ (នេះជាកិតកិរិយា)*

*រឿងហេតុកម្មវាចកនេះសូមរកមើលក្នុងមេរៀនទី ១៦ សាឡើងវិញផង ។*

# លំហាត់នៃមេរៀនទី ២៩

## ក. ចូរឆ្លើយនឹងសំនួរទាំងឡាយខាងក្រោមនេះ

១. តើ **សត្ថុ** ស័ព្ទសម្រេចមកពីអ្វីខ្លះ ប្រែថាដូចម្ដេច ?

២. តើ **បិតុ** ស័ព្ទសម្រេចមកពីអ្វីខ្លះ ប្រែថាដូចម្ដេច ?

៣. តើ មាតុ ស័ព្ទសម្រេចមកពីអ្វីខ្លះ ប្រែថាដូចម្ដេច ?

៤. តើស័ព្ទអាលបនៈមានប៉ុន្មានយ៉ាង ?

៥. តើពាក្យដូចជា **បុរិស**, **កុមារ**, **ឆារិ**, វធុ ជាស័ព្ទអាលបនៈអ្វី ?

៦. តើស័ព្ទអាលបននិបាតមានប៉ុន្មានស័ព្ទ, គឺអ្វីខ្លះ ?

៧. ប្រសិនបើមានបទអាលបននាមច្រើនបទក្នុងប្រយោគតែមួយ តើត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

៨. ប្រសិនបើមានបទអាលបននិបាតច្រើនបទក្នុងប្រយោគតែមួយ តើត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

៩. ប្រសិនបើមានបទអាលបនទាំងពីរប្រភេទក្នុងប្រយោគតែមួយ តើត្រូវប្រែដូចម្ដេច ? សូមឱ្យឧទាហរណ៍ ។

## ខ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាខ្មែរ

១. សត្ថា សាវកេ សាវកានំ ធម្មំ ទេសាបេតិ ។

២. មាតា ជីតរំ ឧបាហេត្វា ចាបសាលំ បេសេសិ ។

៣. បិតា បុត្តំ គាមំ គមេតិ ។

៤. ភត្តា អត្តនោ ភរិយាយ អតិថយោ សង្គណ្ហាបេសិ ។

៥. ធីតរោ ទាសេហិ ទារូនិ អាហរាបេត្វា អគ្គឹ ទាបេថ ។

៦. ធីតូហិ មាតរោ ច បិតរោ ច រក្ខិតព្វា, មាតូហិ ច ធីតរោ រក្ខិតព្វា ។

៧. មាតុល, មយំ បន តវ នត្តរោ ហោម, តស្មា នោ សាធុកំ ឧគ្គណ្ហាបេតិ ។

៨. សត្ថា សោតារេ សច្ចានិ ពោធេន្តោ គាមា គាមំ នគរា នគរំ វិចរតិ ។

៩. តេសំ រដ្ឋេ ជិតិមន្តេ នេតារេ ន បស្សាម ។

១០. មាតរិ ច បិតរិ ច អានយេន មយ្ហំ ភត្តា អត្តនោ ធនេន មហន្តំ ឃរំ ការាបេត្វា តេ តត្ថ វសាបេសិ ។

១១. មយ្ហំ មាតា យាគុំ បចិត្វា ធីតរានំ ទទិស្សតិ ។

១២. កញ្ញានំ បិតរោ ធីតរានំ វុទ្ធឹ ឥច្ឆន្តិ ។

១៣. ទារិយា ទុហិតរោ មគ្គេសុ សយិស្សន្តិ ។

១៤. ធនវតិយា នត្តារោ មគ្គេ តិរិយំ ធាវិត្វា អជរឹ បរិសិត្វា និលីយឹសុ ។

១៥. ភគិនិយា ធីតរោ អារាមំ គន្ត្វា សត្ថារំ មាលាហិ បូជេសុំ ។

១៦. អហំ មាតុយា ច បិតរា ច សទ្ធឹ អារាមំ គន្ត្វា តេ ធម្មំ សាវេស្សាមិ ។

## គ. ចូរប្រែប្រយោគទាំងឡាយខាងក្រោមនេះជាភាសាបាលី

១. ម្ដាយ របស់ក្មេងស្រី នោះ ឱ្យហើយ នូវកម្រងផ្កា ដល់ឪពុក ។

២. នែនាង, តើប្អូនស្រី របស់ឪពុក របស់អ្នក រស់នៅ ឯណា ?

៣. កូនស្រី.ទ. របស់កសិករ អង្គុយហើយ លើគ្រែ បរិភោគហើយ នូវបាយ កំពុងបេះ ផ្កា.ទ. ក្នុងសួន ។

៤. ម្ដាយ និង ឪពុក ជាមួយនឹង កូនស្រី និង កូនប្រុស ទៅហើយ កាន់វត្ត ដើម្បីស្ដាប់ នូវធម៌ ។

៥. ម្ដាយ ញុំាងចៅ.ទ. ឱ្យប្រគេន នូវអាហារ.ទ. ដល់ សាវក.ទ. របស់ព្រះសាស្ដា ។

៦. កូនប្រុស ក្ដី កូនស្រី ក្ដី គប្បីស្ដាប់ ឱវាទ របស់មាតា និង បិតា ។

៧. អ្នកនិយាយ មិនមែនជា អ្នកធ្វើ ជានិច្ចទេ. ។

៨. កាល កូនស្រី កំពុងចម្អិន បាយ រីម្ដាយ និយាយ ជាមួយនឹង ឪពុក ។

៩. សូមឱ្យព្រះសាស្ដា ញុំាងភិក្ខុ រូបនោះ សំដែង ធម៌, អ្នកចេះ.ទ. នឹងមាន, គេ.ទ. នឹងយល់ នូវសច្ចៈ ។

១០. ឪពុក របស់យើង ញុំាងបងប្រុស.ទ. ឱ្យកាត់ ដើមឈើ.ទ. ខាងក្រោយ ផ្ទះ ។

១១. អ្នកឈ្នះ ញុំាងជន.ទ. ឱ្យសាងសង់ នូវសាលា ធំ មួយ ក្នុងក្រុង ។

១២. នែកូនស្រី អ្នក មិនគប្បីធ្វើ នូវអំពើបាបទេ, មិនគប្បីញុំាងអ្នកដទៃឱ្យធ្វើ នូវបាប ដែរ ។

១៣. អ្នកដឹកនាំ មិនមែនជា អ្នកឈ្នះ ជានិច្ចទេ ។

១៤. អ្នកសង់ នូវផ្ទះ ឱ្យហើយ នូវឫស្សី ដល់ចៅ របស់គាត់ ។

១៥. ម្ដាយ កាលឱ្យ នូវឱវាទ ដល់កូនស្រី ថើបហើយ នូវក្បាល អង្អែល ហើយ នូវដៃ លួងលោមហើយ ។

លួងលោម= **សមស្សាសេតិ** ( **សំ** + **អា** + **សស** ) ។

អង្អែល= **អាមសតិ** ( **អា** + **មស** ) ។

**(ចប់មេរៀនទី ២៥)**

# វាក្យានុក្រម

## អក្សរសង្ខេប

| | |
|---|---|
| ឥ. ឥត្ថីលិង្គ | បុំ. = បុំលិង្គ |
| កិ.វិ. = កិរិយាវិសេសន៍ | អតិ. គុ. =អតិវិសេសគុណនាម |
| គុ. = គុណនាមន | វិ. គុ. = វិសេសគុណនាម |
| នបុំ. = នបុំសកលិង្គ | សព្វ. = សព្វនាម |
| | សំ. = សំខ្យា |

អក្ខរ បុំ, នបុំ. អក្សរ, អក្ខរៈ

អគារ នបុំ. រោង, ផ្ទះ

អគ្គ ប្រសើរ

អគ្គិ បុំ. ភ្លើង, អគ្គី

អង្គ នបុំ. ខ្លួន, អង្គ

អង្គុលិ ឥ. ម្រាមដៃ

អច្ចិ ឥ. អណ្តាតភ្លើង

អច្ឆរា ឥ. ស្រីអប្សរ

អជ្ជ អព្យ. ថ្ងៃនេះ

អញ្ញ សព្វ. ដទៃ, ឯទៀត

អញ្ញតម សព្វ. ណាមួយ, ម្នាក់

អញ្ញតរ សព្វ. ណាមួយ, ម្នាក់

អដវិ ឥ. ព្រៃ

អដ្ឋង្គិកា គ. ប្រកបដោយអង្គ៨

អដ្ឋអសីតិ សំ. ៨៨

អដ្ឋចត្តាឡីស សំ. ៤៨

អដ្ឋត្តាឡីស សំ. ៤៨

អដ្ឋត្តឹស សំ. ៣៨

អដ្ឋត្តឹសតិ សំ. ៣៨

អដ្ឋបញ្ញាស សំ. ៥៨

អដ្ឋបណ្ណាស សំ. ៥៨

អដ្ឋវីស សំ. ២៨

អដ្ឋវីសតិ សំ. ២៨
អដ្ឋាទស សំ. ១៨
អដ្ឋារស សំ. ១៨
អដ្ឋាសីតិ សំ. ៨៨
អដ្ឋិ នបុំ. ឆ្អឹង, អដ្ឋិ
អឌ្ឍ បុំ. កន្ទះ
អណ្ឌ នបុំ. ពង,ស៊ុត
អតិថិ បុំ. ភ្ញៀវ
អត្ត បុំ. ខ្លួន, អាត្មា
អត្ថ បុំ. ប្រយោជន៍
អថ និ. បើ, បើជា
អទ្ធិកា គុ. ជិត
អទ្រិ បុំ. ភ្នំ
អទ្ធគូ បុំ. អ្នកដើរដំណើរ
អទ្ធាន នបុំ. ផ្លូវឆ្ងាយ
អនិច្ច គុ. មិនទៀង
អន្តិម គុ. ទីបំផុត, ចុង
អន្នទ បុំ. អ្នកឱ្យនូវអាហារ
អន្វេសនា ឥ. ការស្វែងរក

អបរ សព្វ. ដទៃទៀត, ផ្សេងទៀត
អបរណ្ហ អព្យ. ពេលរសៀល
អបរាធ បុំ. ពាក្យតិទៀន
អប្ប គុ. តិច
អប្បកា នបុំ. តិច
អប្បេវនាម អព្យ. ធ្វើម្ដេចហ្ន៎
អភិណ្ហ គុ. រឿយៗ, ញយៗ
អភិភូ បុំ. ព្រះអភិភូ
អភិរូប គុ. មានរូបស្អាត
អមច្ច បុំ. អាមាត្យ
អមិត្ត បុំ. សត្រូវ
អម្ព បុំ.,នបុំ. ដើមស្វាយ
អម្ពុ នបុំ. ទឹក
អយ្យិកា បុំ. ជីតា, តា
អយ្យិកា ឥ. ជីដូន,យាយ
អរញ្ញ នបុំ. ព្រៃ
អរហន្ត បុំ. ព្រះអរហន្ត
អរិ បុំ. សត្រូវ
អរិយ បុំ. ព្រះអរិយៈ

**អរិយសច្ច** នបុំ. សេចក្ដីពិត

**អរុ** នបុំ. ដំបៅ

**អរោគ** គុ. មិនមានរោគ

**អលាត** នបុំ. រងើកភ្លើង

**អលិកវាទី** បុំ. អ្នកពោលពាក្យ-មិនពិត

**អវស្សំ** និ. ដោយពិត, មែន

**អសនិ** ឥ. រន្ទះ

**អសិ** បុំ. ដាវ

**អសីតិ** សំ. ៨០

**អស្ស** បុំ. សេះ

**អស្សុ** នបុំ. ទឹកភ្នែក

**អហិ** បុំ. ពស់

**អាកាស** បុំ. អាកាស

**អាចរិយ** បុំ. គ្រូ, អាចារ្យ

**អាចរិយានី** ឥ. អ្នកគ្រូ

**អាណិ** ឥ. ស្នឹង

**អាទិច្ចវារ** បុំ. ថ្ងៃអាទិត្យ

**អាបណ** បុំ. ផ្សារ, ហាង

**អាពាធ** បុំ. ឈឺ, អាពាធ

**អាភា** ឥ. រស្មី

**អាម** និ. បាទ, ចាស

**អាម** គុ. ខ្ចី

**អាយស្មន្តុ** គុ. អ្នកមានអាយុ

**អាយុ** នបុំ. អាយុ

**អារម្មណ** នបុំ. អារម្មណ៍

**អារាម** បុំ. អារាម, សួន

**អាលិន្ទ** បុំ. របៀង

**អាលោក** បុំ.រស្មី, ពន្លឺ

**អាវាស** បុំ. វត្ត, អាវាស

**អាហារ** បុំ. អាហារ

**ឥណ** នបុំ. បំណុល

**ឥតោ** អព្យ. អំពី...នេះ

**ឥត្ថី** ឥ. ស្រី

**ឥទានិ** កិ.វិ. ឥឡូវនេះ

**ឥទ្ធិ** ឥ. ឫទ្ធ

**ឥធ** កិ.វិ. ទីនេះ

**ឥសិ** បុំ. ឫសី, ឥសី

ឡៀតិ ឥ. ចង្រៃ, អន្តរាយ
ឧក្កា ឥ. គុបភ្លើង
ឧក្ខលិ ឥ. ឆ្នាំងបាយ
ឧច្ច គុ. ខ្ពស់
ឧញ្ឆ បុំ. ស្បៀងត្រៀម
ឧណ្ហ គុ. ក្តៅ
ឧត្តាន គុ. រាក់
ឧទក នបុំ. ទឹក
ឧទធិ បុំ. សមុទ្រ
ឧបជ្ឈាយ បុំ. ឧបជ្ឈាយ៍
ឧបាធាននបុំ. សេចក្តីប្រកាន់
ឧបាសិកា ឥ. ឧបាសិកា
ឧភ, ឧភយ សព្វ. ពីរ, ទាំងពីរ
ឧរុ បុំ., នបុំ. ខ្សាច់
ឧយ្យាន នបុំ. សួន, ឧទ្យាន
ឧរគ បុំ. ពស់
ឩនអសីតិ សំ. ៧៩
ឩនចត្តាឡីស សំ. ៣៩
ឩនតាឡីស សំ. ៣៩
ឩនត្តឹស សំ. ២៩
ឩនត្តឹសតិ សំ. ២៩
ឩននវុតិ សំ. ៨៩
ឩនបញ្ញាស សំ. ៤៩
ឩនបណ្ណាស សំ. ៤៩
ឩនវីសតិ សំ. ១៩
ឩនវីស សំ. ១៩
ឩនសដ្ឋី សំ. ៥៩
ឩនសត សំ. ៩៩
ឩនសត្តតិ សំ. ៦៩
ឩនសត្តរិ សំ. ៦៩
ឩមិ ឥ. រលក
ឯក សំ. មួយ,
ឯក សព្វ. មួយ, ពួកមួយ
ឯកអសីតិ សំ. ៨១
ឯកចត្តាឡីស សំ. ៤១
ឯកច្ច សព្វ. អ្នកខ្លះ, ពួកខ្លះ
ឯកត្តាឡីស សំ. ៤១
ឯកត្តឹស សំ. ៣១

ឯកាត្តឹសតិ សំ. ៣១
ឯកាមដ្ឋំក្នុងកន្លែងមួយ
ឯការីស សំ. ២១
ឯការីសតិ សំ. ២១
ឯកាទស សំ. ១១,
ឯការស សំ. ១១
ឯកាសីតិ សំ. ៨១
ឯកូនអសីតិ សំ. ៧៩
ឯកូនចត្តាឡីស សំ. ៣៩
ឯកូនតាឡីស សំ. ៣៩
ឯកូនត្តឹស សំ. ២៩
ឯកូនត្តឹសតិ សំ. ២៩
ឯកូននវុតិ សំ. ៨៩
ឯកូនបញ្ញាស សំ. ៤៩
ឯកូនបណ្ណាស សំ. ៤៩
ឯកូនវីស សំ. ១៩
ឯកូនវីសតិ សំ. ១៩
ឯកូនសដ្ឋី សំ. ៥៩
ឯកូនសត សំ. ៩៩
ឯកូនសត្តតិ សំ. ៦៩
ឯកូនសត្តរិ សំ. ៦៩
ឯកូនាសីតិ សំ. ៧៩
ឯវ,ឯវំ អព្យ.ពិត, តែ-ប៉ុណ្ណោះ
ឱក នបុំ. ទឹក
ឱឃ បុំ. អន្លង់ទឹក
ឱជា ឥ. ឱជា, រស
ឱទន បុំ. បាយ
ឱវាទ បុំ. ឱវាទ
កច្ឆា ឥ. ក្លៀក
កជិ ឥ. ចង្កេះ
កណិដ្ឋ អតិ.គុ. តិចឬចាស់បំផុត
កណិយ វិ.គុ. តិចឬក្មេងជាង
កណ្ដក នបុំ. បន្លា
កណ្ឋ បុំ. ព្រួញ
កតញ្ញូ គុ. អ្នកដឹងនូវគុណ
កតម សព្វ. ណា, ណាមួយ, អ្វី
កតរ សព្វ. ណា, ណាមួយ, អ្វី
កត្តុ បុំ. អ្នកធ្វើ

កាចលី ឥ. ចេក
កាជា អព្យ. កាលណា
កាដិដ្ឋ បុំ. ប្អូនប្រុស
កាបិ បុំ. ស្វា
កាមល នបុំ. ផ្កាឈូក
កាម្បតិ កិ. កក្រើក, ញ័រ
កាម្ម នបុំ. កម្ម, ការងារ
កាល្យាណា គុ. ល្អ, ពិរោះ
កាយ បុំ. កាយ
ការី បុំ. ជាង
កាល បុំ. កាល, សម័យ
កាលញ្ញូ គុ. អ្នកដឹងនូវកាល
កាសុ ឥ. រណ្ដៅ
កាឡ្ឃ គុ. ខ្មៅ
កិត្តិ ឥ. ល្បីល្បាញ, កេរ្តិ៍
កិលញ្ជ បុំ. កន្ទេល
កិលេស នបុំ. កិលេស
កិស គុ. ស្គម
កុក្កុដ បុំ. មាន់ឈ្មោល
កុក្កុដី ឥ. មាន់ញី
កុច្ឆិ បុំ., ឥ. ក្បាលពោះ
កុញ្ជរ បុំ. ដំរី
កុជិ ឥ. ខ្ទម, កុដិ
កុជ្ជី បុំ. អ្នកកើតឃ្វង់
កុឌ្ឍ នបុំ. ជញ្ជាំង
កុតោ អព្យ. ពីទីណា
កុទ្ទាល បុំ. ចប, ប៉ែល
កុមារ បុំ. ក្មេងប្រុស
កុមារី ឥ. ក្មេងស្រី
កុសល បុំ. សេចក្តីល្អ
កុសីត គុ. ខ្ជិល,ច្រអូស
កុសុម នបុំ. ផ្កាឈើ
កុហឹ ឥ. ក្នុងទីណា
កូប បុំ. អណ្តូង
កូល នបុំ. ច្រាំង
កេតុ បុំ. ទង់
កេវដ្ដ បុំ. អ្នកនេសាទ
កោស បុំ. សក់

ក្វចិ អព្យ. ក្នុងទីខ្លះ

ខន្តិ ឥ. ការអត់ធ្មត់, ខន្តី

ខរ គុ. ខ្លាំង,រឹង,គ្រោត,គ្រើម

ខុទា ឥ. សេចក្តីឃ្លាន

ខុទ្ទក គុ. តូច

គង្គា ឥ. ទន្លេ

គណ បុំ. ក្រុម, ពួក

គណ្ឋី ឥ. រគាំង

គទា ឥ. ដំបង, ព្រនួង

គន្តុ បុំ. អ្នកទៅ

គន្ថ បុំ. គម្ពីរ

គន្ធ បុំ. ក្លិន

គព្ភ បុំ. ពោះ, ផ្ទៃ, បន្ទប់

គម្ភីរ គុ. ជ្រៅ

គរិដ្ឋ អតិ.គុ. ធ្ងន់បំផុត

គរិយ វិ.គុ. ធ្ងន់ជាង

គរុ បុំ. គ្រូ, អាចារ្យ

គរុ គុ. ធ្ងន់

គហបតិ បុំ. គហបតី

គាថា ឥ. គាថា

គាម បុំ. ស្រុក, ភូមិ

គាវី ឥ. គោញី

គារវ បុំ. សេចក្តីគោរព

គិរិ បុំ. ភ្នំ, គិរី

គីត នបុំ. ការច្រៀង

គុណ បុំ. គុណ

គុណវន្តុ គុ. អ្នកមានគុណ

គេហ នបុំ. ផ្ទះ

គោ បុំ. គោ

គោណ បុំ. គោឈ្មោល

គោតម បុំ. ព្រះគោតមៈ

គោប្ផក នបុំ. កជើង

ឃរ នបុំ. ផ្ទះ

ឃរណី ឥ. ស្រីមេផ្ទះ

ឃាន នបុំ. ច្រមុះ

ចក្ក នបុំ. កង់, ចក្រ

ចក្កវត្តិ បុំ. ស្តេចចក្រពត្តិ

ចក្ខុ នបុំ. ភ្នែក, ចក្ខុ

ចក្ខុមន្តុ គុ. អ្នកមានចក្ខុ
ចណ្ឌា គុ. កាច
ចតុអសីតិ សំ. ៨៤
ចតុចត្តាឡីស សំ. ៤៤
ចតុត្តាឡីស សំ. ៤៤
ចតុត្តឹស សំ. ៣៤
ចតុត្តឹសតិ សំ. ៣៤
ចតុរាសីតិ សំ. ៨៤
ចតុទ្ទស សំ. ១៤
ចតុស្សដ្ឋី សំ. ៦៤
ចត្តាឡីស សំ. ៤០
ចន្ទ បុំ. ព្រះចន្ទ
ចមូ ឥ. កងទ័ព, សេនា
ចាជិ ឥ. ក្អមទឹក, ឆ្នាំង
ចិរំ កិ.វិ. យូរ, អស់កាលយូរ
ចីវរ នបុំ. សំពត់ចីវរ
ចុទ្ទស សំ. ១៤
ចេ និ. បើ
ចេតនា ឥ. ចេតនា
ចេតិយ នបុំ. ចេតីយ៍
ចោរ បុំ. ចោរ
ឆអសីតិ សំ. ៨៦
ឆចត្តាឡីស សំ. ៤៦
ឆណា បុំ. មហោស្រព
ឆត្តាឡីស សំ. ៤៦
ឆត្តី គុ. អ្នកកាន់ឆ័ត្រ
ឆត្តឹស សំ. ៣៦,
ឆត្តឹសតិ សំ. ៣៦
ឆនវុតិ សំ. ៩៦,
ឆន្នវុតិ សំ. ៩៦
ឆព្វីស សំ. ២៦,
ឆព្វីសតិ សំ. ២៦
ឆវិ សម្បុរស្បែក
ឆរាសីតិ សំ. ៨៦,
ឆាសីតិ សំ. ៨៦,
ឆស្សដ្ឋី សំ. ៦៦
ឆឡាសីតិ សំ. ៨៦
ឆាយា ឥ. ម្លប់, ស្រមោល

ឆេកា គុ. ឈ្លាស

ជតុ ជ័រ, ល័ក្ខ

ជន បុំ. ជន

ជនកា បុំ. ឪពុក, បិតា

ជននី ឥ. ម្ដាយ

ជនបទ បុំ. ស្រុកស្រែ

ជនិកា ឥ. ម្ដាយ,ម៉ែ,មាតា

ជន្តុ បុំ. អ្នកកើត (គឺសត្វ)

ជបា ឥ. ផ្កាកុលាប

ជម្ពូ ឥ. ដើមព្រីង

ជល នបុំ. ទឹក

ជល្លិ ឥ. កំទេចឈើ

ជិណ្ណ គុ. ចាស់

ជីវ្ហា ឥ. អណ្ដាត

ជុតិមន្តុ គុ. អ្នកមានពន្លឺ

ជេដ្ឋ អតិ.គុ. ចាស់បំផុត

ជេតុ បុំ. អ្នកឈ្នះ

ជេយ្យ វិ.គុ. ចាស់ជាង

ញាណ នបុំ. សេចក្ដីដឹង

ញាតុ បុំ. អ្នកដឹង

តច បុំ. ស្បែក

តណ្ហា ឥ. ចំណង់

តតោ អព្យ. ពីទីនោះ

តត្រ អព្យ. ក្នុងទីនោះ

តថាគត បុំ. ព្រះតថាគត

តន្តិ ឥ. សណ្ឋាន, បែប

តបស្សី គុ. អ្នកមានតបៈ

តរុណី ឥ. ស្រីក្មេង

តស្មា អព្យ. ព្រោះនោះ

តឡាកា បុំ., នបុំ. ត្រពាំង, ស្រះ

តារា ឥ. ផ្កាយ, តារា

តាឡីស សំ. ៤០

តិណ នបុំ. ស្មៅ

តិបុ នបុំ. សំណ

តឹស សំ. ៣០

តឹសតិ សំ. ៣០

តុណ្ឌ នបុំ. ចំពុះ

តុម្ហេ សព្វ. អ្នកទាំងឡាយ

តុរគ បុំ. សេះ
តុលា ឥ. ជញ្ជីញ
តេអសីតិ សំ. ៨៣
តេចត្តាឡីស សំ. ៤៣
តេតាឡីស សំ. ៤៣
តេត្តឹស សំ. ៣៣
តេត្តឹសតិ សំ. ៣៣
តេរស សំ. ១៣
តេល នបុំ. ប្រេង
តេវីស សំ. ២៣
តេវីសតិ សំ. ២៣
តេឡស សំ. ១៣
ត្យាសីតិ សំ. ៨៣
ត្វំ សព្វ. អ្នក, ឯង, លោក
ថបតិ បុំ. ជាងឈើ
ថវិកា ឥ. ថង់
ថិរ គុ. មាំមួន
ថី ឥ. ស្រី
ថុល្ល គុ. ធាត់
ថេន បុំ. ចោរ
ទក្ខ គុ. ប្រសប់
ទក្ខិណា គុ. ខាងស្តាំ
ទណ្ឌី គុ. អ្នកកាន់ឈើច្រត់
ទធិ នបុំ. ទឹកដោះជូរ
ទន្ត បុំ. ធ្មេញ
ទន្ធ គុ. ខ្ជិល, ល្ងង់
ទលិទ្ទ បុំ. អ្នកក្រខ្សត់
ទស សំ. ១០
ទស្សនីយ គុ. គួរមិលមើល
ទហារ បុំ. ក្មេង
ទឡ្ហ គុ. មាំមួន, ខ្លាំង
ទាឋី គុ. សត្វមានចង្កូម
ទាតុ បុំ. អ្នកឱ្យ
ទាយកា បុំ. អ្នកឱ្យ,ទាយ
ទាយិកា ឥ. អ្នកឱ្យ, ទាយិកា
ទារកា បុំ. ក្មេងប្រុស, ទារក
ទារិកា ឥ. ក្មេងស្រី
ទារុ នបុំ. ឧស, ឈើ

ទិដ្ឋិ ឥ. ការឃើញ
ទិវស បុំ. ថ្ងៃ
ទីឃ គុ. វែង
ទីឃជីវី គុ. អ្នកមានអាយុវែង
ទុក្ខំ កិ.វិ. ដោយកម្រ
ទុក្ខនិរោធ បុំ. សេចក្ដីរំលត់ទុក្ខ
ទុក្ខសមុទយ បុំ. ហេតុនាំឱ្យ
កើតទុក្ខ
ទុព្វល គុ. ខ្សោយ
ទុម្មុខ គុ. ល្វីង
ទូត បុំ. ទូត
ទេវតា ឥ. ទេវតា
ទេវលោក បុំ. ឋានសួគ៌
ទោណិ ឥ. ទូក
ទោលា ឥ. ទោង
ទ្វត្តឹស សំ. ៣២
ទ្វត្តឹសតិ សំ. ៣២
ទ្វាទស សំ. ១២
ទ្វានវុតិ សំ. ៩២
ទ្វារកោដ្ឋក បុំ. ក្លោងទ្វារ
ទ្វាវីស សំ. ២២
ទ្វាវីសតិ សំ. ២២
ទ្វាសដ្ឋី សំ. ៦២
ទ្វាសត្តតិ សំ. ៧២
ទ្វាសត្តរិ សំ. ៧២
ទ្វាសីតិ សំ. ៨២
ទ្វិ សំ. ២
ទ្វិក្ខត្តុំ កិ.វិ. ពីរដង
ទ្វិយាសីតិ សំ. ៨២
ទ្វេអសីតិ សំ. ៨២
ទ្វេចត្តាឡីស សំ. ៤២
ទ្វេតាឡីស សំ. ៤២
ទ្វេនវុតិ សំ. ៩២
ទ្វេបញ្ញាស សំ. ៥២
ទ្វេបណ្ណាស សំ. ៥២
ទ្វេសដ្ឋី សំ. ៦២
ទ្វេសត្តតិ សំ. ៧២
ទ្វេសត្តរិ សំ. ៧២

**ធញ្ញ** បុំ. ស្រូវ, ធញ្ញជាតិ
**ធន** នបុំ. ទ្រព្យ, ធន
**ធនវន្តុ** គុ. អ្នកមានទ្រព្យ
**ធនិក** បុំ. កំណាប់ទ្រព្យ
**ធនុ** នបុំ. ធ្នូ
**ធម្ម** បុំ. ព្រះធម៌
**ធម្មកថិក** បុំ. អ្នកសំដែងធម៌
**ធាតុ** ឥ. ឆ្អឹង,ធាតុ
**ធានី** ឥ. ក្រុង
**ធារា** ឥ. ធារទឹក
**ធិតិមន្តុ** គុ. អ្នកមានបញ្ញា
**ធេនុ** ឥ. មេគោ
**នខ** បុំ. ក្រចក
**នត្តុ** បុំ. ចៅ
**នទី** ឥ. ស្ទឹង, ទន្លេ
**នន្ទិ** ឥ. ភាពភ្លើតភ្លើន
**នមោ** អព្យ.
**នរបតិ** បុំ. ស្តេច
**នវ** គុ. ថ្មី
**នវុតិ** ៩០
**នាថ** បុំ. ជាទីពឹង
**នានាសិប្ប** នបុំ. សិល្បៈនានា
**នាវា** ឥ. ទូក, នាវា
**នារី** ឥ. ស្រី
**នាឡិ** ឥ. នាឡិ (រង្វាស់)
**និទ្ទា** ឥ. ការដេក, និទ្រា
**និធិ** បុំ. កំណាប់ទ្រព្យ
**និរយ** នបុំ. នរក
**នីច** គុ. ទាប, ថោក
**នីល** គុ. ខៀវ
**នេតុ** បុំ. អ្នកនាំទៅ
**នេទិដ្ឋ** អតិ.គុ. ជិតបំផុត
**នេទិយ** វិ.គុ. ជិតជាង
**បក្ក** គុ. ទុំ
**បក្ខ** បុំ. ពួក, បក្ស
**បក្ខី** បុំ. សត្វស្លាប, បក្សី
**បច្ចយ** បុំ. បច្ច័យ
**បច្ឆតោ** អព្យ. អំពីខាងក្រោយ

បច្ឆា អព្យ. វេលាក្រោយ
បញ្ច សំ. ប្រាំ
បញ្ចអសីតិ សំ. ៨៥
បញ្ចចត្តាឡីស សំ. ៤៥
បញ្ចត្តាឡីស សំ. ៤៥
បញ្ចត្តឹស សំ. ៣៥
បញ្ចត្តឹសតិ សំ. ៣៥
បញ្ចទស សំ. ១៥
បញ្ចវីស សំ. ២៥
បញ្ចវីសតិ សំ. ២៥
បញ្ចាសីតិ សំ. ៨៥
បញ្ញវន្តុ គុ. អ្នកមានបញ្ញា
បញ្ញា ឥ. បញ្ញា
បញ្ញាស សំ. ៥០
បញ្ហា ឥ. សំនួរ,បញ្ហា
បណ្ហិ ឥ. កែងជើង
បឋមយាម នបុំ. យាមទី១, បឋមយាម
បឋវី ឥ. ដី
បណីត គុ. ប្រណិត
បណ្ឌិត គុ. ឆ្លាត
បណ្ណ នបុំ. សៀវភៅ, សន្លឹក
បណ្ណរស សំ. ១៥
បណ្ណាការ បុំ. អំណោយ
បណ្ណាស សំ. ៥០
បណ្ណាស សំ. ៥០
បត្ត បុំ. បាត្រ
បតិ បុំ. ម្ចាស់, ប្តី
បទុម នបុំ. ផ្កាឈូក
បទស បុំ. ខ្ទុរ
បព្វត បុំ. ភ្នំ, បុព្វតា
បភា ឥ. រស្មី
បភូ បុំ. អ្នកគ្រប់គ្រង
បមាទ បុំ. សេចក្តីប្រមាទ
បរ សព្វ. ដទៃ, ឯទៀត
បរិសា ឥ. បរិស័ទ
បវត្តិ នបុំ. ដំណឹង
បវរ គុ. ប្រសើរ, បវរ

បសដ្ឋ គុ. ប្រសើរ
បសាទ បុំ. សេចក្ដីជ្រះថ្លា
បសុ បុំ. សត្វចិញ្ចឹម
ចាឋសាលា ឥ. សាលារៀន
ចាណិ បុំ. បាតដៃ
ចាណី បុំ. សត្វលោក
ចាតោ អព្យ. ក្នុងពេលព្រឹក
ចាទ បុំ. ជើង, បាទ
ចាបក គុ. ជាបាប, អាក្រក់
ចាបការី បុំ. អ្នកធ្វើអំពើបាប
ចារ នបុំ. ច្រាំង
ចារគូ បុំ. អ្នកដល់នូវត្រើយ
ចាលិកាសា ឥ. ភាសាបាលី
ចាវក បុំ. ភ្លើង
ចាសាទ បុំ. ប្រាសាទ
បិតុ បុំ. ឪពុក, បិតា
បិចាសា ឥ. សេចក្ដីស្រេក
បិយ គុ. ជាទីស្រឡាញ់
បីឋ នបុំ. កៅអី
បីត គុ. លឿង
បុគ្គល បុំ. បុគ្គល
បុគ្គលញ្ញូ គុ. អ្នកដឹងនូវបុគ្គល
បុញ្ញ បុំ. បុណ្យ, សេចក្ដីល្អ
បុញ្ញវន្តុ គុ. អ្នកមានបុណ្យ
បុត្ត បុំ. កូនប្រុស
បុព្វ អព្យ. គ្រាមុន, កាលមុន
បុព្វណ្ហ បុំ. ពេលព្រឹក
បុប្ផ នបុំ. ផ្កា, បុប្ផា
បុរតោ អព្យ. អំពីខាងមុខ
បុរត្ថិម គុ. ខាងកើត
បុលិន នបុំ. ខ្សាច់
ចោក្ខរណី ឥ. ស្រះ, ត្រពាំង
ផរសុ បុំ. ពូថៅ, ដឹង
ផល នបុំ. ផ្លែ, ផល
ពក បុំ. កុក (សត្វ)
ពត្តឹស សំ. ៣២
ពត្តឹសតិ សំ. ៣២
ពន្ធវ បុំ. ញាតិ, បងប្អូន

ពន្ធុ បុំ. ញាតិ, បងប្អូន,

ពន្ធុមន្តុ គុ. អ្នកមានញាតិ

ពព្ពុ បុំ. ឆ្មា, ខ្លាត្រី

ពលវន្តុ គុ. ខ្លាំង

ពហុ, ពហុកា គុ. ច្រើន

ពល នបុំ. កម្លាំង, ពល

ពលី គុ. អ្នកមានកម្លាំង

ពារស សំ. ១២

ពាល គុ. ល្ងង់, ក្មេង

ពាវីស សំ. ២២

ពាវីសតិ សំ. ២២

ពាហា ឥ. ខែល

ពាឡ្ហ គុ. ខ្លាំង

ពិល នបុំ. រន្ធ, រូង

ពុទ្ធ បុំ. ព្រះពុទ្ធ

ពុទ្ធសាសន នបុំ. ពុទ្ធសាសនា

ពោធិរុក្ខ បុំ. ដើមពោធិ

ព្យគ្ឃ បុំ. ខ្លាធំ

ព្យាធិ បុំ. ជំងឺ

ព្រហ្ម បុំ. ព្រះព្រហ្ម

ព្រហ្មចរិយ នបុំ. ការប្រព្រឹត្តដ៏ប្រសើរ

ព្រាហ្មណី ឥ. ស្រីព្រាហ្មណ៍

ភគវន្តុ បុំ. ព្រះមានព្រះភាគ

ភត្ត នបុំ. បាយ, ភត្ត

ភត្តុ បុំ. អ្នកចិញ្ចឹម (ប្តី)

ភរិយា ឥ. ប្រពន្ធ, ភរិយា

ភវ បុំ. ភព

ភវន្ត បុំ. អ្នកដ៏ចំរើន

ភាជន នបុំ. ក្អម,ឆ្នាំង, ភាជន៍

ភាណី គុ. អ្នកពោល, អ្នកសូត្រ

ភាតុ បុំ. បងប្អូនប្រុស

ភាសា ឥ. ភាសា

ភិក្ខុ បុំ. ភិក្ខុ, អ្នកបួស

ភិក្ខុនី ឥ. ភិក្ខុនី

ភូ ឥ. ផែនដី, លោក

ភេសជ្ជ នបុំ. ថ្នាំ, ភេសជ្ជ

ភោគី បុំ. អ្នកមានទ្រព្យ

ភោគ បុំ. ទ្រព្យ
មក្កដ បុំ. ស្វា
មគធ បុំ. ដែនមគធ:
មគ្គិក គុ. អ្នកដំណើរ
មច្ចុ បុំ. សេចក្ដីស្លាប់
មច្ឆ បុំ. ត្រី
មជ្ជ នបុំ. ទឹកស្រវឹង
មជ្ឈ នបុំ. ទីកណ្ដាល
មជ្ឈិម គុ. កណ្ដាល
មញ្ច បុំ. គ្រែ
មណិ បុំ. ត្បូង, កែវមណី
មត្តញ្ញូ គុ. អ្នកដឹងនូវប្រមាណ
មតិ ឥ. ការដឹង, មតិ
មធុ នបុំ. ទឹកឃ្មុំ
មន បុំ. ចិត្ត
មនុស្ស បុំ. មនុស្ស
មនុស្សលោក បុំ. ឋានមនុស្ស
មន្តី បុំ. មន្ត្រី
មន្ទ គុ. តិច, ខ្សោយ
មយ្ហំ សព្វ. របស់យើង
មរណ នបុំ.សេចក្ដីស្លាប់
មស្សុ នបុំ. ពុកមាត់
មហទ្ធន គុ. មានទ្រព្យច្រើន
មហាតី គុ. ធំ
មហន្ត គុ. ធំ
មហល្លក គុ. ចាស់ (អាយុ)
មហី ឥ. ផែនដី, (ឈ្មោះ)
មំស នបុំ. សាច់
មាណវី ឥ. ស្រីក្រមុំ
មាតុ ឥ. ម្ដាយ, មាតា
មាតុល បុំ. មា (ខាងម្ដាយ)
មាលា ឥ. កម្រងផ្កា, របៀប
មាលី គុ. អ្នកមានកម្រងផ្កា
មាស បុំ. ខែ, សណ្ដែក
មាឃបុណ្ណមីទិវស បុំ, នបុំ. ថ្ងៃ
មាឃបូជា
មុត្តិ ឥ. ការរួចផុត
មុទុ គុ. ទន់

មុនិ បុំ. អ្នកបេះ, មុនី

មូល នបុំ. គល់ឈើ, ឫស

មេធាវី បុំ. អ្នកមានបញ្ញា

យ សព្វ. អ្នកណា ,អ្នកឯណា

យគ្ឃេ អា.និ. សូមតេជ:

យទិ និ. បើ, ប្រសិនបើ

យន្នូន និ. បើដូច្នោះ, បើដូច្នោះ

យាចក បុំ. អ្នកសុំ, យាចក

យាន នបុំ. គ្រឿងជិះ, យាន

យុវ បុំ. ប្រុសកម្លោះ

យុវ គុ. ក្មេង

យុវតិ ឥ. យុវតី

យសវន្តុ គុ. មានយស, ល្បី

រជ្ជ នបុំ. រាជ្យ

រជ្ជុ ឥ. ខ្សែ

រដ្ឋ បុំ. ដែន, រដ្ឋ

រតន នបុំ. កែវ, ត្បូង

រត្ត គុ. ក្រហម

រថ បុំ. រទេះ, រថ

រស្មិ ឥ. រស្មី

រស្ស គុ. ខ្លី

រាជ បុំ. ស្តេច, ព្រះរាជា

រាជភដ បុំ. ទាហាន

រាជិនី ឥ. ស្តេចស្រី

រាសិ បុំ. គំនរ, រាសី

រិបុ បុំ. សត្រូវ

រុក្ខ បុំ. ដើមឈើ, រុក្ខៈ

រុក្ខមូល នបុំ. គល់ឈើ

លទ្ធិ ឥ. ទំនៀម, លទ្ធិ

លាភី បុំ. អ្នកមានលាភ

លាពុ, លាវុ ឥ. ឃ្លោក

លុទ្ទក បុំ. ព្រានព្រៃ

លេខន នបុំ. សំបុត្រ

លេឌ្ឌុ បុំ. ដុំដី

លោម បុំ. រោម

លោចន នបុំ. ភ្នែក, ចក្ខុ

វ អព្យ. ប៉ុណ្ណោះ

វចន នបុំ. ពាក្យ, សំដី

**វណ្ណា** ឥ. ស្រីអារ
**វដ្ដ** នបុំ. ការវិល
**វឌ្ឍកី** បុំ. ជាងឈើ
**វណ្ណ** បុំ. ពណ៌
**វត្ត** បុំ. អ្នកពោល
**វត្ថ** នបុំ. សំពត់
**វេទញ្ញូ** គុ. អ្នកដឹងនូវពាក្យសំដី
**វន** នបុំ. ព្រៃ
**វបុ** នបុំ. អត្តភាព, រាងកាយ
**វស្ស** បុំ.,នបុំ. រដូវភ្លៀង, ឆ្នាំ
**វាណិជ** បុំ. ឈ្មួញ, ពាណិ
**វាត** បុំ. ខ្យល់, វាយោ
**វាបី** ឥ. ត្រពាំង, បឹង
**វាមតោ** អព្យ. អំពីខាងឆ្វេង
**វាលធិ** បុំ. កន្ទុយ
**វិជ្ជា** ឥ. ចំណេះ,វិជ្ជា
**វិជ្ជុ** ឥ. ផ្ទេកបន្ទោរ
**វិញ្ញូ** បុំ. អ្នកចេះ
**វិទេស** បុំ. ប្រទេសដ៏ទៃ
**វិធិ** បុំ. របៀប, វិធី
**វិនេតុ** បុំ. អ្នកឱ្យដំបូន្មាន
**វិបស្សនា** ឥ. ការឃើញច្បាស់
**វិរិយ** នបុំ. សេចក្ដីព្យាយាម
**វិរូ** ឥ. សណ្ដែក
**វិវិត្ត** គុ. ស្ងាត់
**វិសាខបុណ្ណមីទិវស** នបុំ. ថ្ងៃ
វិសាខបូជាអាម
**វិសិខា** ឥ. ផ្លូវ, ថ្នល់
**វីជនី** ឥ. ផ្លិត
**វីស** សំ. ២០
**វីសតិ** សំ. ២០
**វីហិ** បុំ. ស្រូវ
**វុឌ្ឍ** គុ. ចាស់
**វុឌ្ឍិ** ឥ. សេចក្ដីចំរើន
**វេជ្ជ** បុំ. គ្រូពេទ្យ
**វេឡុ** បុំ. ដើមឫស្សី
**ព្យាចាគ** បុំ. ព្យាបាទ
**សកឹ** កិ.វិ. មួយដង, ម្ដង

សកុណា បុ. បក្សី.
សក្ក បុំ. ដែនសក្យៈ
សក្ខរា ឥ. គ្រួស
សក្យ គុ. ផៅពង្សសក្យៈ
សខ បុំ. សំឡាញ់
សង្ការ បុ. សម្រាម
សង្ខារ បុំ. សង្ខារ
សង្គាម បុំ. សង្គ្រាម
សង្ឃ បុំ. ក្រុម, សង្ឃ
សចេ និ. បើ, ប្រសិនបើ
សច្ច នបុំ. សេចក្តីពិត
សជ្ឈុ នបុំ. ប្រាក់(លោហ)
សដ្ឋី សំ. ៦០
សណ្ឋាន នបុំ. ទ្រង់ទ្រាយ
សត សំ. ១០០
សតិមន្តុ គុ. អ្នកមានសតិ
សត្ត បុំ. សត្វ
សត្តអសីតិ សំ. ៨៧
សត្តចត្តាឡីស សំ. ៤៧
សត្តត្តាឡីស សំ. ៤៧
សត្តតិ សំ. ៧០
សត្តទស សំ. ១៧
សត្តរស សំ. ១៧
សត្តរិ សំ. ៧០
សត្តត្តឹស សំ. ៣៧
សត្តត្តឹសតិ សំ. ៣៧
សត្តវីស សំ. ២៧
សត្តវីសតិ សំ. ២៧
សត្តាសីតិ សំ. ៨៧
សត្ថុ បុំ. សត្រូវ
សត្ថុ បុំ. គ្រូ, សាស្តា
សទ្ទ បុំ. សំលេង, ស័ព្ទ
សនិកំ កិ.វិ. យឺត ៗ
សន្តិ ឥ. សេចក្តីស្ងប់
សន្តិក នបុំ. សំណាក់
សន្និបាត បុំ. ការប្រជុំ
សប្ប បុំ. ពស់
សប្បុរិស បុំ. បុរសល្អ, សប្បុរស

**សព្វ** សព្វ. ទាំងពួង, សព្វ
**សព្វញ្ញូ** បុំ. អ្នកដឹងសព្វ
**សព្វទា** កិ.វិ. រាល់ថ្ងៃ
**សមណា** បុំ. អ្នកបួស
**សមាធិ** បុំ. សមាធិ
**សមំ** កិ.វិ. ដោយស្មើ
**សម្បត្តិ** នបុំ. ទ្រព្យ, សម្បត្តិ
**សម្ផស្ស** បុំ. ការប៉ះពាល់
**សម្ភាវនា** ឥ. សេចក្ដីសរសើរ
**សម្មជ្ជនិ** ឥ. អំបោស
**សភា** ឥ. ទីប្រជុំ
**សយម្ភូ** បុំ. ព្រះសយម្ភូ
**សរណា** នបុំ. ទីពឹង, ទីរលឹក
**សរភូ** បុំ. សត្វតុកកែ
**សល្វ** បុំ. កូនសរ
**សសី** បុំ. ដួងចន្ទ
**សស្ស** នបុំ. សំណាប
**សស្សុ** ឥ. ម៉ែក្មេក
**សហសា** កិ.វិ. ដោយប្រញាប់
**សាជុកំ** កិ.វិ. ប្រពៃហើយ
**សាយំ** កិ.វិ. វេលាល្ងាច
**សារថី** បុំ. អ្នកបររទេះ
**សាលា** ឥ. សាលា
**សារកា** បុំ. សារិក
**សាវត្ថី** ឥ. ក្រុងសាវត្ថី
**សាសន** នបុំ. ពាក្យប្រៀនប្រដៅ
**សិក្ខា** ឥ. ការសិក្សា
**សិក្ខាកាម** គុ. អ្នកស្រឡាញ់ការសិក្សា
**សិខី** បុំ. ក្ងោក
**សិន្ធុ** បុំ. ទន្លេសិន្ធុ
**សិប្ប** នបុំ. សិល្បៈ
**សិម្ពលី** បុំ. ដើមរកា
**សិលា** ឥ. ថ្ម, សិលា
**សិស្ស** បុំ. សិស្ស
**សីឃំ** កិ.វិ. ដោយរួសរាន់
**សីត** គុ. ត្រជាក់
**សីល** នបុំ. សីល

សីហ បុំ. តោ, សិង្ហ
សុខ បុំ.,នបុំ. សេចក្តីសុខ
សុគតិ ឥ. ដំណើរល្អ, សុគតិ
សុចរិត នបុំ. ការប្រព្រឹត្តល្អ
សុនខ បុំ. ឆ្កែ
សុរា ឥ. ស្រា, សុរា
សុរិយ បុំ. ព្រះអាទិត្យ
សុរូប គុ. មានរូបស្អាត
សុវ បុំ. សេក
សុវច គុ. ដែលប្រដៅងាយ
សុវណ្ណ នបុំ. មាស
សូករ បុំ. ជ្រូក
សេត គុ. ពណ៌ស
សេតច្ឆត្ត នបុំ. ឆ័ត្រពណ៌ស
សេដ្ឋ អតិ.គុ. ប្រសើរបំផុត
សេតុ បុំ. ស្ពាន
សេយ្យ វិ.គុ. ប្រសើរជាង
សេយ្យា ឥ. ការដេក
សេវក បុំ. អ្នកបំរើ
សោតុ បុំ. អ្នកស្តាប់
សោចាណ បុំ. ជណ្តើរ
សោរវារ បុំ. ថ្ងៃសៅរ៍
សោឡស សំ. ១៦
សំវច្ឆរ នបុំ. ឆ្នាំ
ស្វេ កិ.វិ. ថ្ងៃស្អែក
ហត្ថ បុំ. ដៃ
ហត្ថកា ឥ. ចង្កា
ហន្តុ បុំ. អ្នកសម្លាប់
ហិត បុំ.,នបុំ. ប្រយោជន៍
ហិមវន្តុ គុ. មានទឹកសន្សើម
ហីយោ កិ.វិ. ម្សិលមិញ
ហេតុ បុំ. ហេតុ

# អាខ្យាតកិរិយានុក្រម

អង្គតិ (អគ, អគិ + ◌ំ + អ + តិ) *ទៅ, ដល់, ប្រព្រឹត្ត ។*

អជិគច្ឆតិ (អជិ + គម + អ + តិ) *អុជ, ដុត ។*

អនុគច្ឆតិ (អនុ + គម + អ + តិ) *ទៅតាម ។*

អនុគ្គណ្ហាតិ (អនុ + គហ + ណ្ហា + តិ) *អនុគ្រោះ, ជួយ ។*

អនុភោតិ (អនុ + ភូ + អ + តិ) *សោយ, ទទួល ។*

អនុសាសតិ (អនុ + សាស + អ + តិ) *បង្រៀន ។*

អត្ថិ (អស + អ + តិ) *មាន, ជា ។*

អសុណាតិ (អសុ + ណា + តិ) *ហូរទៅ ។*

អាកង្ខតិ (អា + កខ + ◌ំ + តិ) *ប្រាថ្នា, ប៉ុនប៉ង, ចង់បាន ។*

អាកង្ខតិ (អា + កង្ខ + តិ) *ប្រាថ្នា, ប៉ុនប៉ង, ចង់បាន ។*

អាគច្ឆតិ (អា + គម + អ + តិ) *មក ។*

អាទទាតិ, អាទេតិ (អា + ទា + អ + តិ) *យក ។*

អានេតិ ( អា + នី + អ + តិ) *នាំមក ។*

អាបយតិ (អាប + ណាយ + តិ) *ជ្រាបចូល ។*

អាបេតិ (អាប + ណេ + តិ) *ជ្រាបចូល ។*

អារព្ភតិ, អារភតិ (អា + រភ + អ + តិ) *ប្រារព្ធ ។*

អារុហតិ (អា + រុហ + អ + តិ) *ឡើង ។*

អាសឹសតិ (អា + សិស + អ + តិ) *ប៉ុនប៉ង, ប្រាថ្នា, សង្ឃឹម ។*

អាហរតិ (អា + ហរ + អ+ តិ) *នាំមក ។*

អាហិណ្ឌតិ (អា + ហិឌ + ំ + អ + តិ) *ដើរត្រាច់* ។

ឥក្ខតិ (ឥក្ខ + អ + តិ) *មើល, ឃើញ* ។

ឥច្ឆតិ (ឥស + អ + តិ) *ចង់, ប្រាថ្នា* ។

ឥស្សតិ (ឥស្ស + អ + តិ) *ប្រណែន* ។

ឰជិយតិ (ឰជិ + ណាយ + តិ) *ខ្លាច* ។

ឰជេតិ (ឰជិ + ណេ + តិ) *ខ្លាច* ។

ឧក្កច្ឆតិ (ឧ + គម + អ + តិ) *ឡើងទៅ* ។

ឧគ្គណ្ហាតិ (ឧ + គហ + ណ្ហា + តិ) *រៀន* ។

ឧដ្ឋាតិ (ឧ + ឋា + អ + តិ) *ក្រោក, រះឡើង* ។

ឧឌ្ឌេតិ (ឧ + ឌិ + អ + តិ) *ហើរ, ហោះឡើង* ។

ឧជាធេតិ (ឧ + ជ *អា.* + អា + ជី + អ + តិ) *ឧទានឡើង* ។

ឧជេតិ (ឧ + ជ *អា.* + ឥ + អ + តិ) *រះឡើង* ។

ឧបក្កមាលតិ (ឧប + កាម + អាល + តិ) *ឈានចូលទៅរក* ។

ឧប្បតតិ (ឧ + បត + អ + តិ) *ហើរ* ។

ឧប្បជ្ជតិ (ឧ + បជ + យ + តិ) *កើត* ។

ឧបសង្កមតិ (ឧប + សំ + កាម + អ + តិ) *ចូលទៅជិត* ។

ឧស្សហតិ (ឧ + សហ + អ + តិ) *ខិតខំ, ប្រឹងប្រែង* ។

ឯតិ (ឥ + អ + តិ) *ទៅ* ។

ឱចិជាតិ (ឱ + ចិ + ជា + តិ) *សន្សំ, បេះ* ។

ឱចិណាបេតិ ( ឱ + ចិ + ណា + ណាបេ + តិ ) *ឱ្យសន្សំ, ឱ្យបេះ ។*

ឱតរតិ ( ឱ + តរ + អ + តិ ) *ចុះ, ឆ្លងចុះ ។*

ឱរុហតិ ( ឱ + រុហ + អ + តិ ) *ចុះ ។*

ឱលោកេតិ ( ឱ + លោក + ឯ + តិ ) *មើល ។*

ឱវទតិ ( ឱ + វទ + អ + តិ ) *ទូន្មាន, ប្រដៅ ។*

កថយតិ ( កថ + ណយ + តិ ) *ពោល, និយាយ ។*

កថេតិ ( កថ + ណេ + តិ ) *ពោល, និយាយ ។*

កយិរតិ ( ករ + យិរ + តិ ) *ធ្វើ ។*

កយិរា ( ករ + យិរ + ឯយ្យ ) *គប្បីធ្វើ ។*

ករោតិ ( ករ + ឱ + តិ ) *ធ្វើ ។*

ការេតិ ( ករ + ណេ + តិ ) *ឱ្យធ្វើ ។*

កសតិ ( កស + អ + តិ ) *ភ្ជួរ, រាស់ ។*

ការាបេតិ ( ករ + ណាបេ + តិ ) *ឱ្យធ្វើ ។*

កីណាតិ ( កី + ណា + តិ ) *ទិញ ។*

កីឡតិ ( កីឡ + អ + តិ ) *លេង ។*

កុជ្ឈតិ ( កុធ + យ + តិ ) *ក្រោធ, ខឹង ។*

កោលតិ ( កោល + អ + តិ ) *ទៅ, ដល់ ។*

ខណតិ ( ខណ + អ + តិ ) *ជីក ។*

ខាទតិ ( ខាទ + អ + តិ ) *ទំពារស៊ី ។*

ខិបតិ ( ខិប + អ + តិ ) បោះចោល ។

ខីយតិ ( ខី + យ + តិ ) អស់ ,អស់ទៅ ។

គច្ឆតិ ( គម + អ + តិ ) ទៅ, ដល់ ។

គណ្ហាតិ ( គហ + ណ្ហា + តិ ) យក, កាន់យក ។

គណ្ហាបេតិ ( គហ + ណ្ហា + ណាបេ + តិ ) ឱ្យយក, ឱ្យកាន់យក ។

គមេតិ ( គម + ឯ + តិ ) ទៅ, ដល់ ។

គរហតិ ( គរហ + អ + តិ ) តិះដៀល ។

គាធតិ ( គាធ + អ + តិ ) តាំងនៅមាំ ។

គាយតិ ( គេ + អ + តិ ) ច្រៀង, បំពេរ ។

គាហេតិ ( គហ + ណេ + តិ ) ឱ្យកាន់យក ។

គូហតិ ( គូហ + អ + តិ ) លាក់, បិទបាំង ។

គូបយតិ ( គុប + ណយ + តិ ) ឱ្យគ្រប់គ្រង ។

គគ្គរាយតិ ( គគ្គរី + អាយ + តិ ) ប្រព្រឹត្តនូវសូរពោទ៍ ។

ឃាតេតិ ( ហន > ឃាត + ណេ + តិ ) ឱ្យកំចាត់ ។

ឃាយតិ ( ឃា + យ + តិ ) ហិត, ស្រូប ។

ឃុរុឃុរាយតិ ( ឃុរុឃុរុ + អាយ + តិ ) ប្រព្រឹត្តនូវសូរឃូរ ៗ ។

ឃេប្បតិ ( គហ > ឃេ + ប្ប + តិ ) ឱ្យចាប់ ។

ចង្កមតិ ( កាម + អ + តិ ) ដើរទៅដើរមក, ចង្រ្កម ។

ចញ្ចលតិ ( ចល + ំ + អ + តិ ) កំរើក, រំជួល, ញ័រ ។

ចរតិ (ចរ + អ + តិ) *ដើរ, ត្រាច់ ។*

ចវតិ (ចុ + អ + តិ) *ច្យុត, ឃ្លាត ។*

ចោរយតិ (ចុរ + ណ្យ + តិ) *លួច ។*

ចោរេតិ (ចុរ + ណេ + តិ) *លួច ។*

ចិកិច្ឆតិ (កិត + ឆ + តិ) *រក្សា, ព្យាបាល ។*

ចិច្ឆតិ (ឆិទ + ឆ + តិ) *កាត់ ។*

ចិឆេទតិ (ឆិទ + ឆ + តិ) *កាត់ ។*

ចិណាតិ (ចិ + ណា + តិ) *សន្សំ, បេះ ។*

ចិន្តយតិ (ចិន្ត + ណយ + តិ) *គិត ។*

ចិន្តេតិ (ចិន្ត + ណេ + តិ) *គិត ។*

ចិរាយតិ (ចិរំ + អាយ + តិ) *ប្រព្រឹត្តយូរ ។*

ចីវរីយតិ (ចីវរ + ឦយ + តិ) *ចង់បានទូវចីវរដើម្បីខ្លួន ។*

ចុម្ពតិ (ចុម្ព + អ + តិ) *ថើប ។*

ឆឌ្ឌេតិ (ឆឌ្ឌ + ណេ + តិ) *ចោល, បោះចោល ។*

ឆត្តីយតិ (ឆត្ត + ឦយ + តិ) *ប្រព្រឹត្តថាដូចជាឆ័ត្រ ។*

ឆាទយតិ (ឆទ + ណយ + តិ) *គ្រប, ប្រក ។*

ឆាទេតិ (ឆទ + ណេ + តិ) *គ្រប, ប្រក ។*

ឆិន្ទតិ (ឆិទ + ំ + អ + តិ) *កាត់, ផ្ដាច់ ។*

ឆិន្ទាបេតិ (ឆិទ + ំ + ណាបេ + តិ) *ឱ្យកាត់, ឱ្យផ្ដាច់ ។*

ឆេទេតិ (ឆិទ + ណេ + តិ) ឲ្យកាត់ ។

ជនេតិ (ជន + ណេ + តិ) ឲ្យកើត ។

ជង្គមតិ (គម + អ + តិ) ទៅ, ដើរទៅ ។

ជយតិ (ជិ + អ + តិ) ឈ្នះ ។

ជហតិ, ជហាតិ (ហា + អ + តិ) លះ, លះបង់។

ជហារតិ (ហារ + អ + តិ) នាំទៅ ។

ជហាសតិ (ហាស + អ + តិ) សើច ។

ជាគរតិ (ជាគរ + អ + តិ) ដាស់តឿន ។

ជានាតិ (ញា > ជា + អ + តិ) ដឹង, បេះ ។ ឲ្យ

ជានាបេតិ (ញា > ជា + ណាបេ + តិ) ឲ្យដឹង, ឲ្យបេះ ។

ជលតិ (ជល + អ + តិ) រុងរឿង ។

ជាលយតិ (ជល + ណាយ + តិ) កំចាត់, ដុត ។

ជាលេតិ (ជល + ណេ + តិ) កំចាត់, ដុត ។

ជិគុច្ឆតិ (គុប + ឆ + តិ) ខ្ពើម, ឆ្អើម ។

ជិឃច្ឆតិ (ឃស + ឆ + តិ) ប្រាថ្នាដើម្បីស៊ី, ចង់ស៊ី ។

ជិគឹសតិ, ជិគីសតិ (ហារ + ស + តិ) ប្រាថ្នាដើម្បីនាំទៅ, ចង់បាន ។

ជិនាតិ (ជិ + នា + តិ) ឈ្នះ ។

ជីវតិ (ជីវ + អ + តិ) រស់នៅ ។

ជុហតិ, ជុហោតិ, ជុហវតិ (ហុ, ហូ + អ + តិ) បូជា ។

ជេតិ (ជិ + អ + តិ) *ឈ្នះ ។*

ជោតតិ (ជុត + អ + តិ) *រុងរឿង ។*

ជោតលតិ (ជុត + អល + តិ) *រុងរឿង ។*

ឈាយតិ (ឈា + យ + តិ) *ដុត ។*

ឋបេតិ (ឋា + ណាបេ + តិ) *ទុក, ដាក់ ។*

ឌហតិ (ឌហ + អ + តិ) *ឆេះ, រលាក, ដុត ។*

តក្កេតិ (តក្ក + ណេ + តិ) *ត្រិះរិះ ។*

តដតដាយតិ (តដតដ + អាយ + តិ) *ប្រព្រឹត្តនូវសូរតដៈតដៈ ។*

តណោតិ (តណ + ឱ + តិ) *ផ្សាយ, ត្រដាង ។*

តិកិច្ឆតិ (កិត + ឆ + តិ) *រក្សា, ព្យាបាល ។*

តិដ្ឋតិ (ឋា + អ + តិ) *ឈរ, តាំងនៅ ។*

តិតិក្ខតិ (តិជ + ខ + តិ) *អត់ទ្រាំ ។*

តីរេតិ (តីរ + ណេ + តិ) *ដល់ត្រើយ ។*

តីរេតិ (តីរ + ណេ + តិ) *គិតសាឡើងវិញ ។*

តុលេតិ (តុល + ណេ + តិ) *ថ្លឹង ។*

ថកេតិ (ថក + ណេ + តិ) *បិទ ។*

ថុណាតិ (ថុ + ណា + តិ) *សរសើរ, ស្ញើច ។*

ទទាតិ (ទា + អ + តិ) *ឱ្យ ។*

ទទាតិ (ទា + អ + តិ) *ទ្រទ្រង់ ។*

ទមេតិ (ទម + ណេ + តិ) ទូន្មាន, ហ្វឹក ។

ទាបេតិ (ទា + ណាបេ + តិ) ឱ្យឱ្យ ។

ទិច្ឆតិ (ទា + ឆ + តិ) ប្រាថ្នាដើម្បីឱ្យ, ចង់ឱ្យ ។

ទិព្វតិ (ទិវ + យ + តិ) លេង ។

ទិប្បតិ (ទិប + យ + តិ) រះ ។

ទិសេតិ (ទិស + ណេ + តិ) សំដែង ។

ទុក្ខេតិ (ទុក្ខ + ណេ + តិ) ឱ្យសេចក្ដីទុក្ខ ។

ទេតិ (ទា > ទេ + អ + តិ) ឱ្យ ។

ទេសេតិ (ទិស + ណេ + តិ) សំដែង ។

ធនីយតិ (ធន + ឦយ + តិ) ប្រាថ្នានូវទ្រព្យដើម្បីខ្លួន ។

ធារេតិ (ធរ + ណេ + តិ) ទ្រទ្រង់ ។

ធាវតិ (ធាវ + អ + តិ) រត់ ។

ធាវេតិ (ធាវ + ណេ + តិ) រញ្ជួយ ។

ធោវតិ (ធោវ + អ + តិ) បោកគក់, លាង ។

នច្ចតិ (នដ + យ + តិ) រាំ ។

នមតិ (នម + អ + តិ) ឱនទៅ, បង្អោនទៅ ។

នមស្សតិ (នមស្ស + អ + តិ) ថ្វាយបង្គំ ។

នយតិ, នេតិ (នី + អ + តិ) នាំទៅ ។

នាមេតិ (នម + ណេ + តិ) ឱ្យឱនទៅ, ឱ្យបង្អោនទៅ ។

ណាយរេ (ញ្ញា > ណា + ណា + តិ > រេ) ដឹង, គប្បីដឹង ។

ណាយេតិ (ណី + ណោ + តិ) ឱ្យនាំទៅ ។

និក្ខមតិ (និ + កាម + អ + តិ) បេញទៅ ។

និបជ្ជតិ (និ + បទ + យ + តិ) ដេក ។

និមន្តេតិ (និ + មន្ត + ណោ + តិ) អញ្ជើញ ។

និលីយតិ (និ + លី + យ + តិ) ពួន, សម្ងំ ។

និសីទតិ (និ + សីទ + អ + តិ) អង្គុយចុះ ។

នេតិ (នី + អ + តិ) នាំទៅ ។

បក្កោសតិ (ប + កុស + អ + តិ) ហៅ ។

បចតិ (បច + អ + តិ) ចម្អិន ។

បជហាតិ (ប + ហា + អ + តិ) លះបង់ ។

បដិគ្គណ្ហាតិ (បដិ + គហ + ណ្ហា + តិ) ទទួល ។

បដិវេទេតិ (បដិ + វិទ + ណោ តិ) ប្រាប់ឱ្យដឹង ។

បតតិ (បត + អ + តិ) ធ្លាក់ ។

បតិដ្ឋាតិ (ប + ឋា + អ + តិ) តាំងនៅចំពោះ ។

បត្តីយតិ (បត្ត + ឦយ + តិ) ចង់បានទូវបាត្រដើម្បីខ្លួន ។

បត្ថរតិ (ប + ថរ + អ + តិ) ក្រាល, លាត ។

បព្វតាយតិ (បព្វត + អាយ + តិ) ប្រព្រឹត្តថាដូចជាភ្នំ ។

បមជ្ជតិ (ប + មទ + យ + តិ) ប្រមាទ, ប្រហែស, ស្រវឹង ។

បវត្តេតិ (ប + វត + ណេ + តិ) ប្រព្រឹត្តទៅ ។

បវិសតិ (ប + វិស + អ + តិ) ចូល ។

បវេសេតិ (ប + វិស + ណេ + តិ) ឱ្យចូល ។

បរិយេសតិ (បរិ + ឯស + អ + តិ) ស្វែងរក ។

បរិវារេតិ (បរិ + វរ + ណេ + តិ) ហែហម ។

បលាយតិ, បលេតិ (បល + ឯ + តិ) បោល, ហើរ, អណ្តែត ។

បសំសតិ (ប + សំស + អ + តិ) សរសើរ ។

បស្សតិ (ទិស > បស្ស + អ + តិ) ឃើញ ។

បហរតិ (ប + ហរ + អ + តិ) វាយ, ប្រហារ ។

បហិណាតិ (ប + ហិ + ណា + តិ) ផ្ញើ ។

បាចាបេតិ (បច + ណាបេ + តិ) ឱ្យចម្អិន ។

បាជេតិ (ប + អជ + ណេ + តិ) បរ, បើកបរ ។

បាតេតិ (បត + ណេ + តិ) ឱ្យធ្លាក់, ទម្លាក់ ។

បាបុណាតិ (ប + អប + ឧណា + តិ) ដល់, សម្រេច, លុះ ។

បាយេតិ (បា + ណេ + តិ) ឱ្យផឹក, បៅ ។

បារុបតិ (ប + អា + រុប + អ + តិ) ដណ្តប់, ឃ្លុំ ។

បាលេតិ (បាល + ណេ + តិ) រក្សា, ថែទាំ ។

បិធាបេតិ (អបិ, បិ + ធា + ណេ + តិ) ឱ្យបិទ ។

បិធហតិ (អបិ, បិ + ធា + អ + តិ) បិទ ។

បិជាបេតិ(អបិ បិ + ជា + ណេ + តិ) ឱ្យបិទ ។

បិយាយតិ (បិយ + អាយ + តិ) ប្រព្រឹត្តឱ្យជាទីស្រឡាញ់ ។

បិវតិ (ចា > បិវ + អ + តិ) ផឹក ។

បិវាសតិ (ចា + ស + តិ) ប្រាថ្នាដើម្បីផឹក, ចង់ផឹក ។

បីឡេតិ (បីឡ + ណេ + តិ) បៀតបៀន ។

បុច្ឆតិ (បុច្ឆ + អ តិ) សួរ ។

បុត្តីយតិ (បុត្ត + ឦយ + តិ) ប្រព្រឹត្តថាដូចជាកូន ។

បូជេតិ (បូជ + ណេ + តិ) ថ្វាយ, បូជា ។

បូរេតិ (បុរ + ណេ + តិ) បំពេញ, ពេញ ។

ចោសេតិ (បុស + ណេ + តិ) ចិញ្ចឹម, ថែទាំ ។

ផុជាតិ (ផុ + ជា + តិ) រោយ, ប្រោះ(ទឹក) ។

ផុសតិ (ផុស + អ + តិ) ប៉ះ, ស្ទាប ។

ពន្ធតិ (ពន្ធ + អ + តិ) ចង ។

ពុជ្ឈតិ (ពុធ + យ + តិ) ចេះ, ត្រាស់ដឹង ។

ពុទ្ធាយតិ (ពុទ្ធ + អាយ + តិ) ប្រព្រឹត្តឱ្យដូចជាព្រះពុទ្ធ ។

ពុពោធតិ (ពុធ + អ + តិ) ចេះ ។

ពុភុក្ខតិ (ភុជ + ខ + តិ) ប្រាថ្នាដើម្បីស៊ី, ចង់ស៊ី ។

ព្យាករោតិ (វិ + អា + ករ + ឱ + តិ) ទាយ ។

ភជតិ (ភជ + អ + តិ) សេពគប់ ។

ភណតិ (ភណ + អ + តិ) *និយាយ ។*

ភវតិ (ភូ + អ + តិ) *ជា, មាន, កើត ។*

ភាតិ (ភា + អ + តិ) *រះ ។*

ភាយតិ (ភិ + អ + តិ) *ខ្លាច, ភ័យ ។*

ភាវេតិ (ភូ + ណេ + តិ) *ដល់, លុះ ។*

ភាសតិ (ភាស + អ + តិ) *ពោល, និយាយ ។*

ភិជ្ជតិ (ភិទ + យ + តិ) *បែក ។*

ភិន្ទតិ (ភិទ + ំ + អ + តិ) *ទំលាយ ។*

ភុញ្ជតិ (ភុជ + ំ + អ + តិ) *ស៊ី, បរិភោគ ។*

ភោជេតិ (ភុជ + ណេ + តិ) *ចិញ្ចឹម, ថែទាំ ។*

មគ្គតិ (មគ្គ + អ + តិ) *ស្វែងរក ។*

មច្ឆរាយតិ (មច្ឆរ + អាយ + តិ) *ប្រព្រឹត្តនូវសេចក្តីកំណាញ់ ។*

មន្តេតិ (មន្ត + ណេ + តិ) *ជជែក, ពិភាក្សា ។*

មានេតិ (មាន + ណា + តិ) *រាប់អាន ។*

មាបេតិ (មាប + ណេ + តិ) *សាង, សង់ ។*

មារេតិ (មរ + ណេ + តិ) *សម្លាប់ ។*

មុច្ចតិ (មុច + យ + តិ) *រួច, ផុត, របូត ។*

មុញ្ចតិ (មុច + ំ + អ + តិ) *លែង, រួច ។*

មុយ្ហតិ (មុហ + យ + តិ) *វង្វេង ។*

មុស្សតិ (មុស + យ + តិ) *ភ្លេច ។*

យាចតិ (យាច + អ + តិ) *សុំ ។*

យាបេតិ (យា + ណាបេ + តិ) *ឱ្យទៅ ។*

យុញ្ជតិ (យុជ + ំ + អ + តិ) *ប្រកប ។*

យោជេតិ (យុជ + ណេ + តិ) *ទឹម, សង្រួម ។*

រក្ខតិ (រក្ខ + អ + តិ) *រក្សា ។*

រជ្ជតិ (រជ, រញ្ជ + យ + តិ) *ជ្រលក់, រីករាយ ។*

រជ្ឈតិ (រធ + យ + តិ) *បៀតបៀន ។*

រមតិ (រម + អ + តិ) *រីករាយ ។*

រវតិ (រុ + អ + តិ) *រង៉ាវ, ស្រែក ។*

រុន្ធតិ (រុធ + ំ + អ + តិ) *បិទ ។*

រុចេតិ (រុច + ណេ + តិ) *រុងរឿង, គាប់ចិត្ត ។*

រោទតិ (រុទ + អ + តិ) *យំ ។*

រោធេតិ (រុធ + ណេ + តិ) *ឱ្យបិទ ។*

រោបេតិ (រុប + ណេ + តិ) *ដាំ, បណ្ដុះ ។*

លក្ខេតិ (លក្ខ + ណេ + តិ) *កំណត់ ។*

លគ្គេតិ (លគ + ណេ + តិ) *ជាប់, ទើ ។*

លភតិ (លភ + អ + តិ) *ទទួល, បាន ។*

លាលបតិ, លាលប្បតិ (លប + អ + តិ) *និយាយរអ៊ូ*

លិខតិ (លិខ + អ + តិ) សរសេរ ។

លិម្បតិ (លិប + ំ + អ + តិ) លាប ។

លិប្បតិ (លិប + យ + តិ) ប្រឡាក់, ជ្រលក់ ។

លុម្បតិ (លុប + ំ + អ + តិ) ប្លន់ ។

វចតិ (វច + អ + តិ) ពោល ។

វញ្ចេតិ (វញ្ច + ណេ តិ) ប្រវញ្ចន៍, បោក ។

វញ្ឆតិ (វធិ + អ + តិ) ប្រាថ្នា ។

វឌ្ឍតិ (វឌ្ឍ + អ + តិ) ចម្រើន, រុងរឿង ។

វឌ្ឍេតិ (វឌ្ឍ + ណេ + តិ) ឱ្យចម្រើន, ឱ្យរុងរឿង ។

វន្ទតិ (វន្ទ + អ + តិ) សំពះ, ថ្វាយបង្គំ ។

វបតិ (វប + អ + តិ) សាប, ព្រោះ ។

វវក្ខតិ (វច + ខ + តិ) ប្រាថ្នាដើម្បីពោល, ចង់ពោល ។

វសតិ (វស + អ + តិ) នៅ, រស់នៅ ។

វហតិ (វហ + អ + តិ) ទាញទៅ, អូសទៅ ។

វាចេតិ (វច + ណេ + តិ) ឱ្យពោល, ឱ្យនិយាយ ។

វាតិ (វា + អ + តិ) បក់, ផាត់ ។

វាយមតិ (វាយម + អ + តិ) ព្យាយាម ។

វិក្កីណាតិ (វិ + កី + ណា + តិ) លក់ ។

វិចរតិ (វិ + ចរ + អ + តិ) ត្រាច់ចរ ។

វិចិកិច្ឆតិ (វិ + កិត + ឆ + តិ) សង្ស័យ ។

វិជិគឹសតិ ,វិជិគីសតិ (វិ + ជិ + ស + តិ) ប្រាថ្នាដើម្បីឈ្នះ, ចង់ឈ្នះ ។

វិជ្ឈតិ (វិជ + យ + តិ) បាញ់, ចាក់ ។

វិន្ទតិ (វិទ + ◌ំ + អ + តិ) ប្រទះ,ប្រសព្វ, បាន ។

វិមំសតិ (វិ + មាន + ស + តិ) ល្បង, ពិចារណា ។

វីវិច្ឆតិ ប្រាថ្នាចង់បាន, ចង់បាន

វិហរតិ (វិ + ហរ + អ + តិ) នៅ, អាស្រ័យ ។

វុច្ចរេ (វច + យ + តិ > រេ) ពោល, ហៅ ។

វុណាតិ (វុ + ណា + តិ) ក្រង ។

វ្យាករោតិ (វិ + អា + ករ + ឱ + តិ) ពន្យល់ ។

សក្កុណាតិ (សក + ឧណា + តិ) អាច, អង់អាច ។

សង្គណ្ហាតិ (សំ + គហ + ណ្ហា + តិ) សង្គ្រោះ ។

សជ្ឈាយតិ (សំ + ឈេ + អ + តិ) សូត្រ, ទន្ទេញ ។

សន្ថារតិ (សន្ថ + អារ + តិ) ធ្វង់ដោយប្រពៃ ។

សន្និបតតិ (សំ + និ + បត + អ + តិ) ប្រជុំ ។

សម្មិជ្ឈតិ (សំ + ឥជ + យ + តិ) សម្រេច ។

សយតិ (សី > សយ + អ + តិ) ដេក ។

សរតិ (សរ + អ + តិ) រលឹក, ចងចាំ ។

សល្លបតិ (សំ + លប + អ + តិ) សន្ទនា ។

សំហរតិ ( សំ + ហរ + អ + តិ ) បេះ(ផ្កា) ។

សិក្ខតិ ( សិក្ខ + អ + តិ ) សិក្សា ។

សិញ្ចតិ ( សិច + ំ + អ + តិ ) ស្រោច, ប្រោះ ។

សិណោតិ ( សិ + ណុ + តិ ) ចង ។

សិព្វតិ ( សិវ + យ + តិ ) លេង ។

សុខាយតិ ( សុខ + អាយ + តិ ) ប្រព្រឹត្តនូវសេចក្ដីសុខ ។

សុខេតិ ( សុខ + ណេ + តិ ) ឱ្យសេចក្ដីសុខ

សុណាតិ ( សុ + ណា + តិ ) ស្ដាប់ ។

សុណោតិ ( សុ + ណុ + តិ ) ស្ដាប់ ។

សុបតិ ( សុប + អ + តិ ) ដេក ។

សុម្ភតិ ( សុម្ភ + អ + តិ ) បៀតបៀន ។

សុស្សូសតិ ( សុ + ស + តិ ) ប្រាថ្នាដើម្បីស្ដាប់, ចង់ស្ដាប់ ។

សេតិ ( សី + អ + តិ ) ដេក ។

ហរតិ ( ហរ + អ + តិ ) នាំទៅ ។

ហសតិ ( ហស + អ + តិ ) សើច ។

ហាបេតិ ( ហា + ណាបេ + តិ ) ឱ្យលះ, ឱ្យសាបសូន្យ ។

ហឹសតិ ( ហឹស + អ + តិ ) បៀតបៀន ។

ហោតិ ( ហុ, ហូ + អ + តិ ) មាន ។

## ☜វេយ្យាករណានុក្រម☞


អក្ខរៈ ១

អក្សរ ១

អកម្មធាតុ ៣៩

អឃោសៈ ៣

អតិវិសេសគុណនាម ១៨៧

អតីតកាល ៤៤, ៤៥

អតីតកិតកិរិយា ៣៦០, ៣៨៨

អតីតបច្ចុប្បន្នកាល ៤៦

អតីតានាគតកាល ៤៧

អត្តនោបទ ៤៣

អនភិហិតកត្តា ១៦២

អនាគតកាល ៤៤, ៤៥

អនាគតបច្ចុប្បន្នកាល ៤៦

អនាគតរបស់បច្ចុប្បន្ន ៤៦

អនាគតរបស់អតីត ៤៧

អនាទរកិរិយា ៥០៧

អនិយម ២០០

អនិយមសព្វនាម ២០០

អនុករណត្ថកិរិយាស័ព្ទ ៣០៤

អនុកិរិយាស័ព្ទ ៣៧០

អនុត្តកាល ៤៥, ៤៧

អនុត្តកាលកិតកិរិយា ៤៣៣

អនុមត្តិ ៤៧, ៨៣

អនុមត្តិកិតកិរិយា ៣៦០

អបរកាលកិរិយា ៤២៦

អប្បច្ចក្ខាតីតកាល ៤៦

អព្ភន្តរកិរិយា ៣៧២

អព្ភាស ២៩១

អព្យយកិតកិរិយា ៣៥៦, ៣៦០, ៤១០

អសជាតុ ៥៣, ៧០, ៨៥, ១៤៤

អសាធារណនាម ១៦

អាខ្យាតកិរិយា ៣៧

អាគមរបស់អាខ្យាត ១៤៤

អាណត្តិ ៤៧, ៦៨
អាយតនិបាត ២២
អាលបននិបាត៥២៩
អាសិដ្ឋ ៤៧, ៦៨
ឥច្ឆិតុមត្ថកិរិយា ៣០០
ឥត្ថីលិង្គ ១៧
ឧត្តមបុរិសសព្វនាម ១០១
ឧត្តមបុរិសៈ ៤២
ឯកវចនៈ ១៩, ២៣
កត្តុវាចក ៤៨
កម្មបទ ៣២
កម្មវាចក ៤៨
កាល ៤៤
កាលាតិបត្តិវិភត្តិ ១៧៨
ការន្ត ១៦
ការក ២១
កិច្ចប្បច្ច័យ ៣៥៩, ៣៦១
កិតក ៣៥៦
កិតកិច្ចប្បច្ច័យ ៣៥៩, ៣៦១
កិតកិរិយា ៣៥៦
កិតនាម ៣៥៦
កិតប្បច្ច័យ ៣៥៩, ៣៦០
កិរិយាកិតក ៣៥៦
កិរិយានុគ្រោះ ៤៥
កិរិយាវិសេសន ៤២៨
កិរិយាស័ព្ទ ៣៧
គុណនាម ១៨២
ឃោសៈ ៣
ជាតិលិង្គ ១៨
ឈ្មោះការន្ត ១៧
ឈ្មោះវិភត្តិនាម ២០
តុមត្ថកត្តា ៤៦៧
តុមត្ថសម្បទាន ៤៦៥
ទ្វិកម្មធាតុ ៣៩
ធាតុ ៣៧, ៣៨
នបុំសកលិង្គ ១៧
នាមកិតក ៣៥៦
នាមនាម ១៥

នាមវិសេសន ២៤៧
នាមស័ព្ទ ១៥
និបាតស័ព្ទ ៧៦
និយម ១៦៥
និយមសព្វនាម ១៦៥, ១៧១
បកតិគុណនាម ១៨៦
បកតិសំខ្យា ២២០
បកិណ្ណកនាម៤៧៤
បច្ច័យ ៣៧
បច្ច័យរបស់អាខ្យាត ៣៩
បច្ចុប្បន្នកាល ៤៤, ៤៥
បច្ចុប្បន្នកិតកិរិយា ៣៦០, ៣៦១
បច្ចុប្បន្នជិតអតីត ៤៦
បច្ចុប្បន្នជិតអនាគត៤៦
បច្ចុប្បន្នសុទ្ធ ៤៦
បច្ចុប្បន្នាគតកាល ៤៦
បច្ចេកបច្ច័យ ៣០៦
បញ្ចមីវិភត្តិអាខ្យាត ៦៧
បដិសេធវិធី ៨៨
បឋមបុរិស ៤២
បឋមបុរិសសព្វនាម ១០១
បទ ៤៣
បទអនភិហិតកត្តា ៣២៦
បទអវុត្តកម្ម ៣២០
បទការីតកម្ម ៣២០
បទគុណ ១៩១
បទប្រធាន ៣២
បទសម្បាបុណីយកម្ម ៣២៣
បទវិកតិកត្តា ១៨៩
បទវិសេសនៈ ១៩១
បរស្សបទ ៤៣
បរិកប្ប ៤៧, ៨៣
បរិកប្បនិបាត ៨៦
បរិយោសានកាលកិរិយា ៤២៥
បរោក្ខាវិភត្តិ២៨៨
បុច្ឆនសព្វនាម ២០១
បុច្ឆាសព្វនាម ២០៩, ២១១
បុព្វកាលកិរិយា ៤២៥

បុរិស ៤២
បុរិសសព្វនាម ១០០
បុំលិង្គ ១៧
បូរណសំខ្យា ៣៣២
ប្រយោគអនាទរ ៥០៧
ប្រយោគកត្តុវាចក: ៥៤
ប្រយោគកម្មវាចក: ២៧៨
ប្រយោគជ្រែក ៥០៧
ប្រយោគភាវវាចក:១៦២
ប្រយោគលក្ខណ ៥០៩
ប្រយោគហេតុកត្តុវាចក: ៣១៩
ប្រយោគហេតុកម្មវាចក: ៣២៥
ពហុវចន ១៩, ២៣
ព្យញ្ជន: ២
ភវិស្សន្តិវិភត្តិ ១៥៧
ភាវវាចក ៤៨
មជ្ឈិមបុរិស ៤២
មជ្ឈិមបុរិសសព្វនាម ១០១
មហាកិរិយាស័ព្ទ ៣៧០
លក្ខណកិរិយា ៥០៩
លិង្គ ១៧
លិង្គដោយសន្មតិ ១៩
លិង្គពីកំណើត ១៨
វចន ១៩
វចន:របស់កិរិយាស័ព្ទ ៤២
វចីវិភាគ ១៥
វត្តមានាវិភត្តិ ៤១
វាក្យាង្គ ៣១
វាចក ៤៧
វិកតិកត្តា ៣២
វិភត្តិ ២០
វិភត្តិអាខ្យាត ៣៨, ៤០
វិភត្តិនាម ២០
វិលោមកម្ម ២១៥
វិសេសគុណនាម ១៨៦
វិសេសនសព្វនាម ១៦៣
សកម្មធាតុ ៣៨
សត្តមីវិភត្តិអាខ្យាត ៨៣

សព្វនាម ៩៩
សមានកាលកិរិយា៤២៥
សម្ពន្ធសព្វនាម ២០១
សម្មតិលិង្គ ១៨
សរៈ ១
សំខ្យា ២២០
សំខ្យាគុណនាម ២២៩
សំខ្យានាម ២២៩
សំខ្យាសព្វនាម ២២៩
សំយោគព្យញ្ជនៈ ៤
សាធារណនាម ១៦
សុទ្ធបច្ចុប្បន្នកាល ៤៦
ស្រៈ ១
ស្រៈទីឃៈ ២
ស្រៈនិស្ស័យ ១
ស្រៈពេញតួ ១
ស្រៈរស្សៈ ២
ស្រៈសំឡេងខ្ពី ២
ស្រៈសំឡេងផ្សំ ២
ស្រៈសំឡេងវែង ២
ស្រៈសំយុត្ត ២
ហើយត្តនីវិភត្តិ ១០៧
ហើយោបភូត្យាតីតកាល ៤៦
ហេតុកត្តា ៣២៥
ហេតុកត្តុវាចក ៤៨, ៣១២
ហេតុកម្មវាចក ៤៩
ហេតុកាលកិរិយា ៤២៧
ហេតុប្បច្ច័យ ៣១២

# ឈ្មោះសៀវភៅប្រើប្រាស់ក្នុងការរៀបរៀង

## សៀវភៅជាភាសាខ្មែរ

បាលីវេយ្យាករណ៍ *ព្រះពុទ្ធវង្ស សេក នាង ។*

កច្ចាយនរូបត្ថម្ភក *ភាគ ១, ២ ព្រះសាសនសោភ័ណ ជួន ណាត ។*

បទានុក្រមធម្មបទ *ភាគ ១, ២, ៣ ព្រះគ្រូសេរីសោភ័ណ កិម តូរ ។*

វិធីប្រែបាលី *ឃុន សុវត្ថិវេទី យូរ អ៊ុន ។*

សម្ពន្ធមាលា *លោកគ្រូ អ៊ុក ជា ។*

វចនានុក្រមខ្មែរ *ភាគ ១, ២, ពុទ្ធសាសនបណ្ឌិត្យ ។*

## សៀវភៅជាភាសាថៃ

សៀវភៅរៀនភាសាបាលីដោយខ្លួនឯង *ប្រះឱស្ថ បុញ្ញភក្តី ។*

វចនានុក្រម បាលី-ថៃ សម្រាប់អ្នកសិក្សា *ជវិន្ទ្រ ស:រ:ខាំ ។*

វចនានុក្រម កិរិយាអាខ្យាត *ផាន់ទ្រី ប៉. ហ៊ុងសមប៊ុន ។*

វចនានុក្រម កិរិយាកិតក *ផាន់ទ្រី ប៉. ហ៊ុងសមប៊ុន ។*

## សៀវភៅជាភាសាអង់គ្លេស

The New Pali course book 1&2 ,Prof. A. P. Buddhatatta Maha Nayaka Thera.

The Higher Pali course for Advance students, A. P. Buddhatatta
Maha Nayaka Thera.

An Elementary Pali course, Narada Thera.

Pali Primer, Lily de Silva.

Pali Made Easy, Balangoda Ananda Maitreya.

Practical Grammar of the Pali Language, Charles Duroiselle.

A Pali Grammar for Students, Steven Collins.

Pali Grammar, Vito Perniola.

Introduction to Pali, Antony Kennedy Warder.

Concise Pali-English Dictionary, Prof. A. P. Buddhatatta
Maha Nayaka Thera.

Pali-English Dictionary, Rhys Davids and William Sted

# បញ្ជីរាយនាមសប្បុរសជនចូលបច្ច័យចោះសៀវភៅ

## ប្រទេសញូហ្ស៊ីឡែន

| លរ | នាមសប្បុរសជន | ទីក្រុង/រដ្ឋ | ទឹកប្រាក់ |
|---|---|---|---|
| ១ | ភិក្ខុ ចន្ទបញ្ញោ ប៉ាង សារឿន | វែលិង្ដុន | ១៥០ NZ |
| ២ | ពុទ្ធបរិស័ទនៅទីក្រុងនែលសិន | នែលសិន | ៥៥០ NZ |
| ៣ | កុមារា ចិត្រា ព្រមទាំងគ្រួសា សុខ លី | វែលិង្ដុន | ២០០ NZ |
| ៤ | ឧបាសិកា អ៊ុច សាន់ | វែលិង្ដុន | ២៣០ US |
| ៥ | អ្នកស្រី ចន្ទីនិងស្វាមី វណ្ណ ព្រម ទាំងបុត្រី | វែលិង្ដុន | ២៣០ US |
| ៦ | ឧបាសិកា កុត សាខន ព្រមទាំង កូនចៅ | វែលិង្ដុន | ២៣០ US |
| ៧ | ឧបាសិកា សៀក ឆេង ឧបាសិកា សៀក អេង ព្រមទាំងកូនចៅ | វែលិង្ដុន | ២០០ NZ |
| ៨ | ឧបាសិកា កុត រឿន និងឧបាសិកា អ៊ុ ខេង | វែលិង្ដុន | ១៥០ NZ |
| ៩ | ឧបាសិកា ឆាយ គឹមលៀង ឧបាសិកា ផៃ សុខហេង | វែលិង្ដុន | ១៥០ NZ |
| ១០ | ឧបាសិកា កុត នៀវ ព្រមទាំងកូន ចៅ | វែលិង្ដុន | ១៤០ NZ |

| | | | |
|---|---|---|---|
| ១១ | ឧបាសិកា ជុក ផលា ឧបាសក ជុក ម៉ន ព្រមទាំងកូនចៅ | វែលិ្ងងតុន | ២០០ NZ |
| ១២ | ឧបាសិកា វ៉ូវ គឹម ហៀង ព្រមទាំងកូនចៅ | វែលិ្ងងតុន | ១២០ NZ |
| ១៣ | លោក តាំង ស៊ុយ ហៀង និង ភរិយា ព្រមទាំងបុត្រី | វែលិ្ងងតុន | ១០០ US |
| ១៤ | ឧបាសិកា សុខ ឡាច ស្រួន ព្រមទាំងកូន ចៅ | វែលិ្ងងតុន | ៨០ NZ |
| ១៥ | លោកយាយ អាចារ្យ សេង វួចគី | វែលិ្ងងតុន | ៥០ US |
| ១៦ | លោក កុត សុផល និង ភរិយា សុខា | វែលិ្ងងតុន | ៦០ NZ |
| ១៧ | ឧបាសិកា ប៉ាច សួន | វែលិ្ងងតុន | ៥០ NZ |
| ១៨ | ឧបាសក ជា វន | វែលិ្ងងតុន | ៥០ NZ |
| ១៩ | ឧបាសិកា ម៉ម ទូច | វែលិ្ងងតុន | ៤០ NZ |
| ២០ | អ្នកស្រី កុត វណ្ណា និង ស្វាមី សាក់ ព្រមទាំងកូនចៅ | វែលិ្ងងតុន | ៤០ NZ |
| ២១ | ឧបាសិកា យូ សុខុម | វែលិ្ងងតុន | ៣០ NZ |
| ២២ | ឧបាសិកា សុខ សៃវ៉ាន | វែលិ្ងងតុន | ៣០ NZ |
| ២៣ | ឧបាសិកា ជំ ប៉ាត់ | វែលិ្ងងតុន | ២០ NZ |
| | | | |

| | | | | |
|---|---|---|---|---|
| ២៤ | ស្រី ពេជ្រ និង ស្វាមីព្រមទាំងបុត្រាបុត្រី | វែលិង្ដុន | ២០ | NZ |
| ២៥ | ឧបាសិកា អុំ វន | វែលិង្ដុន | ២០ | NZ |
| ២៦ | លោក ម៉ម សុវណ្ណ និងភរិយាព្រមទាំងបុត្រា | វែលិង្ដុន | ២០ | NZ |
| ២៧ | ឧបាសិកា គឹម សាន | វែលិង្ដុន | ២០ | NZ |
| ២៨ | លោក ផាត់ ម៉ាប់ បុត្រី | ម៉ាណាវ៉ាធូ | ២០ | NZ |
| ២៩ | អ្នកស្រី កុត រំដួល និងស្វាមី ព្រមទាំងបុត្រាបុត្រី | វែលិង្ដុន | ១០ | US |
| ៣០ | ឧបាសិកា ម៉ារិន | វែលិង្ដុន | ១០ | NZ |
| ៣១ | ឧបាសិកា សួន ប៉ែត | វែលិង្ដុន | ១០ | NZ |
| ៣២ | ឧបាសក សេក អ៊ិម | វែលិង្ដុន | ១០ | NZ |
| ៣៣ | ឧបាសិកា អ៊ិម កែម | វែលិង្ដុន | ១០ | NZ |
| ៣៤ | កញ្ញា ស្រី ពៅ | វែលិង្ដុន | ១០ | NZ |
| ៣៥ | កុមារី សួង ស្រីដា និង កុមារ សួង អិតវដ | វែលិង្ដុន | ១០ | NZ |

# ប្រទេសអូស្ត្រាលី

| លរ | នាម | ក្រុង/រដ្ឋ | ប្រាក់ |
|---|---|---|---|
| ១ | ភិក្ខុ ពរ សារឿង | ស៊ីដនីយ៍ | ១០០ AUD |
| ២ | លោក ញឹម ថារី អ្នកស្រី ទុន សារិន | ស៊ីដនីយ៍ | ៥០០ AUD |
| ៣ | អ្នកស្រី ទុន យេន | ស៊ីដនីយ៍ | ១០០ AUD |
| ៤ | លោក សុខ អ្នកស្រី សាង | ស៊ីដនីយ៍ | ១០០ AUD |
| ៥ | លោកតា ម៉ុង ចាយ | ស៊ីដនីយ៍ | ៧០ AUD |
| ៦ | វេជ្ជបណ្ឌិត ទូ វ៉ារី | ស៊ីដនីយ៍ | ៥០ AUD |
| ៧ | លោក ប៉ែន វ៉េនឆេង សុវណ្ណ ឆាយ | ស៊ីដនីយ៍ | ៥០ AUD |
| ៨ | លោកយាយ ឡាង លោកតា ស្រេង | ស៊ីដនីយ៍ | ២៥ AUD |

## ប្រទេសកាណាដា

| លរ | នាម | ទីក្រុង/រដ្ឋ | ទឹកប្រាក់ |
|---|---|---|---|
| ១ | ភិក្ខុ ស្វាត សាលឿម | អូតាវ៉ា | ២០ USD |
| ២ | ភិក្ខុ ផន វីរៈ | តូរ៉ាន់តូ | ២០ USD |
| ៣ | ភិក្ខុ ជឿន និល | តូរ៉ាន់តូ | ២០ USD |
| ៤ | ឧបាសក កែវ គៀម ឧបាសិកា សូត្រ ម៉ើ ព្រមទាំងកូននិងចៅ | សាំងខាតថារិន | ៥០ USD |
| ៥ | លោក អាចារ្យ អ៊ីម រុន និង ភរិយា | សាំងខាតថារិន | ១០ USD |
| ៦ | លោក ប៊ុត យ៉ត និងគ្រួសារ | តូរ៉ាន់តូ | ១០ USD |
| ៧ | ភិក្ខុ កុំ គង់វណ្ណាវ័ត្ន | ក្រុងហាមិលតុន | ៥០ USD |

## សហរដ្ឋអាមេរិក

| លរ | នាម | ទីក្រុង/រដ្ឋ | ទឹកប្រាក់ |
|---|---|---|---|
| ១ | អ្នកស្រី ឡិប ពេញចិត្ត និងស្វាមី | ភិលឡា | ១៥០ US |
| ២ | លោក ស្រី ពេជ្រ សុភាពនិងស្វាមី | ភិលឡា | ៥០ US |

# ប្រទេសកម្ពុជា

| ល.រ | នាម | ទីក្រុង/រដ្ឋ | ទឹកប្រាក់ |
|---|---|---|---|
| ១ | ឧបាសិកា ឡឹង រ៉ុង ព្រមទាំងកូនចៅ | ស្រុកបវេល បាត់ដំបង | ៤០០០០ ៛ |
| ២ | អ្នកស្រីទិត្យ ច័ន្ទផល្លី ព្រមទាំងបុត្រ | ស្រុកបវេល បាត់ដំបង | ១០០០០០ ៛ |

# រៀនភាសាបាលី
# បែបទំនើប

## ភាគ ១

អ្នករៀបរៀង **ញ្ញឹម ថារី**
អ្នកផ្ទៀងផ្ទាត់ ទូច សុវណ្ណមុនី

ព.ស.២៥៥៧ ក.ស២០១៨